# សុត្តន្តបិដក





៤៩

# SUTTANTA PITAKA

# ព្រះ
# ត្រៃបិដកបាលី
# និង
# សេចក្តីប្រែជាភាសាខ្មែរ
# សុត្តន្តបិដក
# អង្គុត្តរនិកាយ នវកនិបាត
# ទសមភាគ
# ៤៩



ផ្សព្វផ្សាយដោយសម្ដេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី បួរ គ្រី
សម្ដេចព្រះមហាសង្ឃរាជនៃគណៈធម្មយុត្តិកនិកាយ
នៃព្រះរាជាណាចក្រកម្ពុជា
*ព. ស. ២៥៥៣*

# SUTTANTAPIṬAKA

## AṄGUTTARANIKĀYA

## NAVAKANIPĀTA

## DASAMABHĀGA

## 49

សម្តេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី បួរ គ្រី
សម្តេចព្រះមហាសង្ឃរាជ នៃគណៈធម្មយុត្តិកនិកាយ នៃព្រះរាជាណាចក្រកម្ពុជា

# និយមវចនៈ

ព្រះត្រៃបិដកត្រូវបានបង្កើតឡើង ប្រមាណ៥០០ឆ្នាំប្លាយ ក្រោយអំពីការរំលត់ព្រះខន្ធចូលកាន់ ព្រះបរមនិព្វានរបស់សម្តេចព្រះសម្មាសម្ពុទ្ធព្រះបរមគ្រូជាអម្ចាស់នៃយើងគ្រប់គ្នា ។ គ្រប់ប្រទេស អ្នកកាន់ព្រះពុទ្ធសាសនា និងប្រទេសខ្លះមួយចំនួនមិនមែនអ្នកកាន់ព្រះពុទ្ធសាសនា គ្រប់អង្គការ ពុទ្ធិកសមាគម និងតាមបណ្ណាល័យជាតិធំ ៗ តែងតែបានទទួលយកមកតម្កល់ទុកធ្វើជាគ្រឹះ ដើម្បីធ្វើការស្រាវជ្រាវសិក្សាស្វែងយល់ តាមអ្វីដែលហៅថាព្រះពុទ្ធវាចា (ពុទ្ធធម៌) ។ កាលដើមឡើយគេនាំគ្នា កត់ត្រាលើស្លឹករឹត ព្រមទាំងសរសេរចារឹកលើផែនថ្ម និងលើផែនលោហៈក៏មាន លុះចំណេរតមក ក៏បាននាំគ្នាបោះពុម្ពលើក្រដាសចងក្រងជាសៀវភៅ (គម្ពីរ) រហូតបច្ចុប្បន្ននេះ បច្ចេកវិជ្ជាកាន់តែ ចម្រើនឡើង គេបានវាយបញ្ចូលក្នុងកុំព្យូទ័រ តែទោះបីជាបច្ចេកទេសម៉ាស៊ីនចម្រើនឡើងយ៉ាងណា ក៏នៅមិនអាចបោះបង់សៀវភៅចោលបានឡើយ ដូច្នេះហើយទើបយើងខ្ញុំបានខិតខំធ្វើឲ្យកើតមាន ឡើងនូវក្រុមអក្សរព្រះត្រៃបិដក ដើម្បីជួយធ្វើឲ្យអក្ខរៈខ្លះដែលរលុបមិនអាចអានច្បាស់បាន ឲ្យមាន ការច្បាស់តាមតួអក្ខរៈឡើងវិញ ។

ដោយសទ្ធាជ្រះថ្លាដ៏មុតមាំដែលមានចំពោះព្រះពុទ្ធសាសនា ហើយក៏ជាកាតព្វកិច្ចមួយដ៏ធំក្នុងតួនាទីជាពុទ្ធបរិស័ទ ដែលបានប្រគល់កាយថ្វាយជីវិត អ្នកធ្វើដំណើរតាមស្នាមព្រះបាទសម្តេចព្រះពុទ្ធអង្គ រួមកម្លាំងទ្រទ្រង់ បានធ្វើការលះបង់កម្លាំងកាយ វាចា ចិត្ត ទ្រព្យធនផ្ទាល់ ព្រមទាំងបបួលពុទ្ធបរិស័ទ ញាតិមិត្តជិតឆ្ងាយ ក្នុងនិងក្រៅប្រទេសធ្វើឡើង ដើម្បីជាពុទ្ធបូជា ធម្មបូជា សង្ឃបូជា ។

សូមសេចក្តីឧស្សាហ៍ក្នុងការជាកុសលនេះ សម្រេចប្រយោជន៍ជូនដល់ព្រះពុទ្ធសាសនាជូនដល់ពុទ្ធបរិស័ទ សូមបានប្រកបតែនឹងសេចក្តីសុខចម្រើនរុងរឿង ក្នុងលោកនេះផង និងលោកដទៃខាងមុខទៀតផង ជាភិយ្យោភាពតរៀងទៅ ។

វត្តបទុមឌ. ថ្ងៃទី ០៨ ខែមិថុនា ឆ្នាំ ២០០៩

បួរ-គ្រី

VATT Botum Dhammavutt Sangkat Chatumuk Khan Daun Penh P.Penh

# ទំព័រទទេ

# សេចក្ដីណែនាំក្នុងការអាន

១) *ប្រសិនបើលោកអ្នកអាន បានឃើញពាក្យទាំងឡាយណា ដែលមានសញ្ញាលេខបូកនៅពីខាងក្រោម ហើយបន្ទាប់មកបានឃើញព្យញ្ជនៈមួយតួទៀតនៅខាងចុងពាក្យនោះ សូមមេត្តាកត់សម្គាល់ថា ព្យញ្ជនៈដែលនៅខាងចុងនោះគឺជាជើងរបស់ព្យញ្ជនៈដែលមានសញ្ញាលេខបូកនៅពីខាងក្រោម ដោយកំហុសបច្ចេកទេសកុំព្យូទ័រ ។*

*ឧទាហរណ៍*

*-ពាក្យខ្មែរ:* **សម្ល** *ក្នុងពាក្យនេះ ព្យញ្ជនៈ* **ល** *គឺជាជើងរបស់ព្យញ្ជនៈ* **ម** *ដូច្នេះពាក្យនេះគឺ* **សម្ល** *។*

*-ពាក្យបាលី:* **តស្ស** *គឺ* **តស្ស** *។*

២) *ចំពោះពាក្យខ្មែរ យើងសម្រេចយកតាមវចនានុក្រមខ្មែរ របស់សម្ដេចព្រះសង្ឃរាជជោតញ្ញាណោ* (**ជួន-ណាត**) *ជាគោល ។ ប៉ុន្តែបើពាក្យទាំងឡាយណា ដែលអាចសរសេរតាមបែបបុរាណក៏ត្រឹមត្រូវដែរនោះ យើងខ្ញុំសូមរក្សានូវពាក្យទាំងនោះទុកដដែល ។*

៣) *ចំពោះ* **សន្ធឹកច្រាប់ពាក្យខុស-ត្រូវ** *ដែលមាននៅផ្នែកខាងចុងនៃព្រះត្រៃបិដកច្បាប់ដើម ក្រុមយើងខ្ញុំសូមមិនដាក់ទៀតទេ ព្រោះក្រុមការងារយើងបានកែតម្រូវតាមនោះរួចរាល់ហើយ ។*

# សុត្តន្តបិដក

# អង្គុត្តរនិកាយ នវកនិបាត

## ទសមភាគ

## ៤៩

ព. ស. ២៤៩៨

# សុត្តន្តបិដកេ

# អង្គុត្តរនិកាយស្ស នវកនិបាតោ

# ទសមោ ភាគោ

---

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

## បណ្ណាសកេ

## បឋមោ សម្ពោធវគ្គោ

[១] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ភិក្ខវោតិ ។ ភទន្តេតិ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច សចេ ភិក្ខវេ អញ្ញតិត្ថិយា បរិព្វាជកា ឯវំ បុច្ឆេយ្យុំ សម្ពោធបក្ខិកានំ អាវុសោ ធម្មានំ កា ឧបនិសា ភាវនាយាតិ ឯវំ បុដ្ឋា តុម្ហេ ភិក្ខវេ តេសំ អញ្ញតិត្ថិយានំ បរិព្វាជកានំ កិន្តិ ព្យាករេយ្យាថាតិ ។

# សុត្តន្តបិដក

# អង្គុត្តរនិកាយ នវកនិបាត

# ទសមភាគ

---

*សូមនមស្ការព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ព្រះអង្គនោះ ។*

## បណ្ណាសក

## សម្ពោធវគ្គ ទី ១

[១] *ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅ ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយក្នុងទីនោះថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះ ទទួលស្តាប់ព្រះពុទ្ធដីកាព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ប្រសិនបើពួកបរិព្វាជក ជាអន្យតិរ្ថិយ គប្បីសួរយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ហេតុនៃសេចក្តីចម្រើន នូវពួកធម៌ជាចំណែកនៃការត្រាស់ដឹង តើដូចម្តេច ម្នាលភិក្ខុទាំងឡាយ បើពួកអន្យតិរ្ថិយសួរយ៉ាងនេះហើយ អ្នកទាំងឡាយគប្បីដោះស្រាយ ដល់ពួកបរិព្វាជកជាអន្យតិរ្ថិយទាំងនោះដូចម្តេច ។*

ភគវំមូលកា នោ ភន្តេ ធម្មា ។ បេ ។ ភគវតោ សុត្វា ភិក្ខូ ធារេស្សន្តីតិ ។ តេនហិ ភិក្ខវេ សុណាថ សាធុកំ មនសិ ករោថ ភាសិស្សាមីតិ ។ ឯវម្ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច សចេ ភិក្ខវេ អញ្ញតិត្ថិយា បរិព្វាជកា ឯវំ បុច្ឆេយ្យុំ សម្ពោធបក្ខិកានំ អាវុសោ ធម្មានំ កា ឧបនិសា ភាវនាយាតិ ឯវំ បុដ្ឋា តុម្ហេ ភិក្ខវេ តេសំ អញ្ញតិត្ថិយានំ បរិព្វាជកានំ ឯវំ ព្យាករេយ្យាថ ឥធាវុសោ ភិក្ខុ កល្យាណមិត្តោ ហោតិ កល្យាណសហាយោ កល្យាណសម្បវង្កោ ។ សម្ពោធបក្ខិកានំ អាវុសោ ធម្មានំ អយំ បឋមា ឧបនិសា ភាវនាយ ។ បុន ច បរំ អាវុសោ ភិក្ខុ សីលវា ហោតិ បាតិមោក្ខសំវរសំវុតោ វិហរតិ

បពិត្រព្រះអង្គដ៏ចម្រើន ធម៌ទាំងឡាយរបស់យើងខ្ញុំព្រះអង្គ មានព្រះដ៏មានព្រះភាគជាមូល ។ បេ ។ ពួកភិក្ខុបានស្តាប់ចំពោះព្រះដ៏មានព្រះភាគហើយ ក៏នឹងចាំទុក ។ ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ អ្នកទាំង-ឡាយចូរចាំស្តាប់ ចូរធ្វើទុកក្នុងចិត្តឲ្យប្រពៃចុះ តថាគតនឹងសម្តែងប្រាប់ ។ ភិក្ខុទាំងនោះ ទទួលស្តាប់ព្រះពុទ្ធដីកាព្រះដ៏មានព្រះភាគថាព្រះករុណាព្រះអង្គ ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ប្រសិនបើ ពួកបរិព្វាជក ជាអន្យតិរ្ថិយ គប្បីសួរយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ហេតុនៃសេចក្តីចម្រើន នូវពួកធម៌ជាចំណែកនៃការត្រាស់ដឹង តើដូចម្តេច ម្នាលភិក្ខុទាំងឡាយ កាលបើពួកអន្យតិរ្ថិយសួរយ៉ាងនេះ អ្នកទាំងឡាយ គប្បីដោះស្រាយដល់ពួកបរិព្វាជក ជាអន្យតិរ្ថិយទាំងនោះយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានមិត្រល្អ មានសំឡាញ់ល្អ សមគប់នឹងមិត្រល្អ ។ ម្នាលអាវុសោទាំងឡាយ នេះជាហេតុនៃសេចក្តីចម្រើននូវពួកធម៌ជាចំណែកនៃការត្រាស់ដឹង ទី ១ ។ ម្នាលអាវុសោទាំង-ឡាយ មួយទៀត ភិក្ខុជាអ្នកមានសីល សង្រួមក្នុងបាតិមោក្ខសំវរៈ

៣

បណ្ណាសកេ សម្ពោធវគ្គោ

អាចារគោចរសម្បន្នោ អណុមត្តេសុ វជ្ជេសុ ភយទស្សាវី សមាទាយ សិក្ខតិ សិក្ខាបទេសុ ។ សម្ពោធបក្ខិកានំ អាវុសោ ធម្មានំ អយំ ទុតិយា ឧបនិសា ភាវនាយ ។ បុន ច បរំ អាវុសោ ភិក្ខុ យាយំ កថា អភិសល្លេខិកា ចេតោវិវរណសប្បាយា សេយ្យថីទំ អប្បិច្ឆកថា សន្តុដ្ឋិ-កថា បវិវេកកថា អសំសគ្គកថា វីរិយារម្ភកថា សីលកថា សមាធិកថា បញ្ញាកថា វិមុត្តិកថា វិមុត្តិញាណទស្សនកថា ឯវរូបិយា កថាយ និកាម-លាភី ហោតិ អកិច្ឆលាភី អកសិរលាភី ។ សម្ពោធ-បក្ខិកានំ អាវុសោ ធម្មានំ អយំ តតិយា ឧបនិសា ភាវនាយ ។ បុន ច បរំ អាវុសោ ភិក្ខុ អារទ្ធវីរិយោ វិហរតិ អកុសលានំ ធម្មានំ បហានាយ កុសលានំ ធម្មានំ ឧបសម្បទាយ ថាមវា ទឡ្ហបរក្កមោ អនិក្ខិ-ត្តធុរោ កុសលេសុ ធម្មេសុ ។ សម្ពោធបក្ខិកានំ អាវុសោ ធម្មានំ អយំ ចតុត្ថា ឧបនិសា ភាវនាយ ។

បរិបូណ៌ដោយអាចារៈនិងគោចរៈ ឃើញនូវភ័យក្នុងទោសទាំងឡាយ សូម្បីបន្តិចបន្តួច សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ ។ ម្នាលអាវុសោទាំងឡាយ នេះជាហេតុនៃសេចក្តីចម្រើន នូវពួកធម៌ជាចំណែកនៃការត្រាស់ដឹងទី ២ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុជាអ្នកបានតាមប្រាថ្នា បានដោយមិនលំបាក បានដោយងាយ នូវកថាមានសភាពយ៉ាងនេះ ដែលជាកថាផូរផង់ ជាទីសប្បាយទូលាយចិត្ត គឺអប្បិច្ឆកថា សន្តុដ្ឋិកថា បវិវេកកថា អសំសគ្គកថា វីរិយារម្ភកថា សីលកថា សមាធិកថា បញ្ញាកថា វិមុត្តិកថា វិមុត្តិញ្ញាណទស្សនកថា ។ ម្នាលអាវុសោទាំងឡាយ នេះជាហេតុនៃសេចក្តីចម្រើន នូវពួកធម៌ជាចំណែកនៃការត្រាស់ដឹង ទី ៣ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុប្រារព្ធនូវសេចក្តីព្យាយាម ដើម្បីលះបង់នូវពួកអកុសលធម៌ចេញ ដើម្បីញុំាងពួកកុសលធម៌ឲ្យកើតឡើង ជាអ្នកមានកម្លាំង មានសេចក្តីប្រឹងប្រែងខ្ជាប់ខ្ជួន មិនដាក់ធុរៈចោល ក្នុងធម៌ទាំងឡាយ ជាកុសល ។ ម្នាលអាវុសោទាំងឡាយ នេះជាហេតុនៃសេចក្តីចម្រើន នូវពួកធម៌ជាចំណែកនៃការត្រាស់ដឹង ទី ៤ ។

បុន ច បរំ អាវុសោ ភិក្ខុ បញ្ញវា ហោតិ ឧទយត្ថគាមិនិយា បញ្ញាយ សមន្នាគតោ អរិយាយ និព្វេធិកាយ សម្មាទុក្ខក្ខយគាមិនិយា ។ សម្ពោធបក្ខិកានំ អាវុសោ ធម្មានំ អយំ បញ្ចមី ឧបនិសា ភាវនាយ ។ កល្យាណមិត្តស្សេតំ ភិក្ខវេ ភិក្ខុនោ ចាដិកង្ខំ កល្យាណសហាយស្ស កល្យាណសម្បវង្កស្ស សីលវា ភវិស្សតិ ចាតិមោក្ខសំវរសំវុតោ វិហរិស្សតិ អាចារគោចរសម្បន្នោ អណុមត្តេសុ វជ្ជេសុ ភយទស្សាវី សមាទាយ សិក្ខិស្សតិ សិក្ខាបទេសុ ។ កល្យាណមិត្តស្សេតំ ភិក្ខវេ ភិក្ខុនោ ចាដិកង្ខំ កល្យាណសហាយស្ស កល្យាណសម្បវង្កស្ស យាយំ កថា អភិសល្លេខិកា ចេតោវិវរណសប្បាយា សេយ្យថីទំ អប្បិច្ឆកថា សន្តុដ្ឋិកថា បវិវេកកថា អសំសគ្គកថា វីរិយារម្ភកថា សីលកថា សមាធិកថា បញ្ញាកថា វិមុត្តិកថា វិមុត្តិញ្ញាណទស្សនកថា ឯវរូបិយា កថាយ និកាមលាភី ភវិស្សតិ អកិច្ឆលាភី អកសិរលាភី ។

ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុជាអ្នកមានបញ្ញា ប្រកប ដោយបញ្ញាដែលអាចកំណត់ នូវការកើតឡើងនិងការវិនាសទៅ (នៃខន្ធបញ្ចកៈ) ជាគ្រឿងទម្លាយនូវកិលេសដ៏ប្រសើរ ជាធម្មជាតិ ដល់នូវកិរិយាអស់ទៅនៃទុក្ខដោយប្រពៃ ។ ម្នាលអាវុសោទាំងឡាយ នេះជាហេតុនៃសេចក្តីចម្រើន នូវពួកធម៌ ជាចំណែកនៃការត្រាស់ដឹង ទី ៥ ។ ម្នាលភិក្ខុទាំងឡាយ ហេតុនេះរមែងកើតប្រាកដដល់ភិក្ខុអ្នក មានមិត្រល្អ មានសំឡាញ់ល្អ សមគប់នឹងមិត្រល្អ គឺភិក្ខុនោះ នឹងបានជាអ្នកមានសីល សង្រួមក្នុងបាតិមោក្ខសំវរៈ បរិបូណ៌ដោយ អាចារៈនិងគោចរៈ ជាអ្នកឃើញភ័យក្នុងទោសទាំងឡាយ សូម្បី បន្តិចបន្តួច សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ ។ ម្នាលភិក្ខុ ទាំងឡាយ ហេតុនេះរមែងកើតប្រាកដដល់ភិក្ខុអ្នកមានមិត្រល្អ មាន សំឡាញ់ល្អ សមគប់នឹងមិត្រល្អ គឺភិក្ខុនោះនឹងបានជាអ្នកបានតាម ប្រាថ្នា បានដោយមិនលំបាក បានដោយងាយនូវកថាមានសភាពយ៉ាង នេះ ដែលជាកថាផូរផង់ ជាទីសប្បាយទូលាយចិត្ត គឺអប្បិច្ឆកថា សន្តុដ្ឋិកថា បវិវេកកថា អសំសគ្គកថា វីរិយារម្ភកថា សីលកថា សមាធិកថា បញ្ញាកថា វិមុត្តិកថា វិមុត្តិញ្ញាណទស្សនកថា ។

## ៤



កល្យាណមិត្តស្សេតំ ភិក្ខវេ ភិក្ខុនោ បាដិកង្ខំ កល្យាណសហាយស្ស កល្យាណសម្បវង្កស្ស អារទ្ធវីរិយោ វិហរិស្សតិ អកុសលានំ ធម្មានំ បហានាយ កុសលានំ ធម្មានំ ឧបសម្បទាយ ថាមវា ទឡ្ហបរក្កមោ អនិក្ខិត្តធុរោ កុសលេសុ ធម្មេសុ ។ កល្យាណមិត្តស្សេតំ ភិក្ខវេ ភិក្ខុនោ បាដិកង្ខំ កល្យាណសហាយស្ស កល្យាណសម្បវង្កស្ស បញ្ញវា ភវិស្សតិ ឧទយត្ថគាមិនិយា បញ្ញាយ សមន្នាគតោ អរិយាយ និព្វេធិកាយ សម្មាទុក្ខក្ខយគាមិនិយា ។ តេន ច បន ភិក្ខវេ ភិក្ខុនា ឥមេសុ បញ្ចសុ ធម្មេសុ បតិដ្ឋាយ ចត្តារោ ធម្មា ឧត្តរី ភាវេតព្វា អសុភា ភាវេតព្វា រាគស្ស បហានាយ មេត្តា ភាវេតព្វា ព្យាបាទស្ស បហានាយ អានាបានស្សតិ ភាវេតព្វា វិតក្កុបច្ឆេទាយ អនិច្ចសញ្ញា ភាវេតព្វា អស្មិមានសមុគ្ឃាតាយ ។ អនិច្ចសញ្ញិនោ ភិក្ខវេ ភិក្ខុនោ អនត្តសញ្ញា សណ្ឋាតិ អនត្តសញ្ញី អស្មិមានសមុគ្ឃាតំ បាបុណាតិ ទិដ្ឋេវ ធម្មេ និព្វានន្តិ ។

បណ្ណាសក សម្ពោធវគ្គ

ម្នាលភិក្ខុទាំងឡាយ ហេតុនេះរមែងកើតប្រាកដដល់ភិក្ខុអ្នកមានមិត្រល្អ មានសំឡាញ់ល្អ សមគប់នឹងមិត្រល្អ គឺភិក្ខុនោះនឹងបានជាអ្នកប្រារព្ធនូវសេចក្ដីព្យាយាម ដើម្បីលះបង់នូវពួកអកុសលធម៌ចេញ ដើម្បីញុំាងពួកកុសលធម៌ឲ្យកើតឡើង ជាអ្នកមានកម្លាំង មានសេចក្ដីប្រឹងប្រែងខ្ជាប់ខ្ជួន មិនដាក់ធុរៈចោល ក្នុងកុសលធម៌ទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ហេតុនេះ រមែងកើតប្រាកដដល់ភិក្ខុអ្នកមានមិត្រល្អ មានសំឡាញ់ល្អ សមគប់នឹងមិត្រល្អ គឺភិក្ខុនោះនឹងបានជាអ្នកមានបញ្ញា ប្រកបដោយបញ្ញា ដែលអាចកំណត់នូវការកើតឡើងនិងការវិនាសទៅ (នៃខន្ធបញ្ចកៈ) ជាគ្រឿងទម្លាយនូវកិលេសដ៏ប្រសើរ ជាធម្មជាតិដល់នូវកិរិយាអស់ទៅនៃទុក្ខដោយប្រពៃ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុនោះតាំងនៅក្នុងធម៌ទាំង ៥ នេះហើយ គប្បីចម្រើន នូវធម៌ ៤ យ៉ាងតទៅទៀត គឺចម្រើនអសុភ ដើម្បីលះរាគៈ ចម្រើនមេត្តា ដើម្បីលះព្យាបាទ ចម្រើនអានាបានស្សតិ ដើម្បីផ្ដាច់ផ្ដិលនូវវិតក្កៈ ចម្រើនអនិច្ច-សញ្ញា ដើម្បីដកចោលនូវអស្មិមានះ ។ ម្នាលភិក្ខុទាំងឡាយ សេចក្ដីសម្គាល់ថា មិនមែនខ្លួន រមែងប្រាកដដល់ភិក្ខុអ្នកមានសេចក្ដីសម្គាល់ថា មិនទៀង ភិក្ខុអ្នកមានសេចក្ដីសម្គាល់ថា មិនមែនខ្លួន រមែងដល់នូវព្រះនិព្វានជាគ្រឿងដកចោលនូវអស្មិមានះ ក្នុងបច្ចុប្បន្ន ។

៦

## សុត្តន្តបិដកេ អង្គុត្តរនិកាយស្ស នវកនិបាតោ

[២] អថខោ អញ្ញតរោ ភិក្ខុ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ ។ បេ ។ ឯកមន្តំ និសិន្នោ ខោ សោ ភិក្ខុ ភគវន្តំ ឯតទវោច និស្សយសម្បន្នោ និស្សយសម្បន្នោតិ ភន្តេ វុច្ចតិ កិត្តាវតា នុ ខោ ភន្តេ ភិក្ខុ និស្សយសម្បន្នោ ហោតីតិ ។ សទ្ធញ្ចេ ភិក្ខុ និស្សាយ អកុសលំ បជហាតិ កុសលំ ភាវេតិ បហីនមេវស្ស តំ អកុសលំ ហោតិ ។ ហិរិញ្ចេ ភិក្ខុ និស្សាយ ឱត្តប្បញ្ចេ ភិក្ខុ និស្សាយ វីរិយញ្ចេ ភិក្ខុ និស្សាយ បញ្ញញ្ចេ ភិក្ខុ និស្សាយ អកុសលំ បជហាតិ កុសលំ ភាវេតិ បហីនមេវស្ស តំ អកុសលំ ហោតិ តញ្ហិស្ស ភិក្ខុនោ អកុសលំ បហីនំ ហោតិ សុប្បហីនំ យស្ស អរិយាយ បញ្ញាយ ទិស្វា បហីនំ ។ តេន ច បន ភិក្ខវេ ភិក្ខុនា ឥមេសុ បញ្ចសុ ធម្មេសុ បតិដ្ឋាយ ចត្តារោ ឧបនិស្សយា វិហរិតព្វា[១] ។

---

១ ឱ. ចត្តារោ ធម្មា ឧបនិស្សាយ វិហាតព្វា ។

[២] គ្រានោះ ភិក្ខុ ១ រូប ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ។ បេ ។ លុះភិក្ខុនោះអង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលសួរព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន គេតែងនិយាយថា ភិក្ខុអ្នកបរិបូណ៌ដោយនិស្ស័យ (ទីពឹង) អ្នកបរិបូណ៌ដោយនិស្ស័យដូច្នេះ បពិត្រព្រះអង្គដ៏ចម្រើន ចុះភិក្ខុអ្នកបរិបូណ៌ដោយនិស្ស័យ តើដោយហេតុដូចម្តេច ។ ម្នាលភិក្ខុ បើភិក្ខុអាស្រ័យដោយសទ្ធាហើយលះបង់នូវអកុសល ចម្រើននូវកុសលបាន អកុសលនោះ ឈ្មោះថាភិក្ខុនោះបានលះបង់ហើយ ។ បើភិក្ខុអាស្រ័យហិរិ បើភិក្ខុអាស្រ័យឱត្តប្បៈ បើភិក្ខុអាស្រ័យវិរិយៈ បើភិក្ខុអាស្រ័យបញ្ញា ហើយលះបង់នូវអកុសល ចម្រើននូវកុសលបាន អកុសលនោះឈ្មោះថាភិក្ខុនោះបានលះបង់ហើយ ព្រោះថា អកុសលដែលភិក្ខុណាឃើញដោយបញ្ញាដ៏ប្រសើរហើយលះ អកុសលនោះឈ្មោះថាភិក្ខុនោះលះហើយ លះស្រឡះហើយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះតាំងនៅក្នុងធម៌ទាំង ៥ នេះហើយ ត្រូវប្រកបដោយឧបនិស្ស័យ ៤ យ៉ាង ។

កតមេ ចត្តារោ ។ ឥធ ភិក្ខវេ ភិក្ខុ[១] សង្ខាយេកំ បដិសេវតិ សង្ខាយេកំ អធិវាសេតិ សង្ខាយេកំ បរិវជ្ជេតិ សង្ខាយេកំ វិនោទេតិ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ និស្សយសម្បន្នោ ហោតីតិ ។

[៣] ឯកំ សមយំ ភគវា ចាលិកាយំ វិហរតិ ចាលិកាបព្វតេ ។ តេន ខោ បន សមយេន អាយស្មា មេឃិយោ ភគវតោ ឧបដ្ឋាកោ ហោតិ ។ អថខោ អាយស្មា មេឃិយោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ ។ ឯកមន្តំ ឋិតោ ខោ អាយស្មា មេឃិយោ ភគវន្តំ ឯត-ទវោច ឥច្ឆាមហំ ភន្តេ ជន្តុគ្គាមំ បិណ្ឌាយ បវិសិតុន្តិ ។ យស្សទានិ ត្វំ មេឃិយ កាលំ មញ្ញសីតិ ។ អថខោ អាយស្មា មេឃិយោ បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ ជន្តុគ្គាមំ បិណ្ឌាយ ចាវិសិ

១ ឱ. ម. ឥធ ភិក្ខុ ភិក្ខុ ។

ឧបនិស្ស័យ ៤ យ៉ាង តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណាហើយ ទើបសេពនូវវត្ថុដែលគួរសេព ១ ពិចារណាហើយ ទើបអត់សង្កត់នូវវត្ថុដែលគួរអត់សង្កត់ ១ ពិចារណាហើយ ទើបវៀរនូវវត្ថុដែលគួរវៀរ ១ ពិចារណាហើយ ទើបបន្ទោបង់ចោលនូវវត្ថុដែលគួរបន្ទោបង់ចោល ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកបរិបូណ៌ ដោយនិស្ស័យយ៉ាងនេះឯង ។

[៣] សម័យមួយ ព្រះដ៏មានព្រះភាគ គង់លើភ្នំចាលិកា ទៀបក្រុងចាលិកា ។ សម័យនោះឯង ព្រះមេឃិយៈដ៏មានអាយុ ជាឧបដ្ឋាកព្រះដ៏មានព្រះភាគ ។ គ្រានោះ ព្រះមេឃិយៈដ៏មានអាយុ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយ ឋិតនៅក្នុងទីដ៏សមគួរ ។ លុះព្រះមេឃិយៈដ៏មានអាយុ ឋិតនៅក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គប្រាថ្នានឹងចូលទៅកាន់ជន្តុគ្រាមដើម្បីបិណ្ឌបាត ។ ម្នាលមេឃិយៈ អ្នកចូរសម្គាល់នូវកាលដែលគួរនឹងទៅ ក្នុងកាលឥឡូវនេះចុះ ។ គ្រានោះ មេឃិយៈដ៏មានអាយុ ស្លៀកស្បង់ប្រដាប់បាត្រនិងចីវរ ក្នុងបុព្វណ្ហសម័យ ហើយចូលទៅកាន់ជន្តុគ្រាម ដើម្បីបិណ្ឌបាត

ជន្តុគ្គាមេ បិណ្ឌាយ ចរិត្វា បច្ឆាភត្តំ បិណ្ឌបា-
តប្បដិក្កន្តោ យេន កិមិកាឡាយ នទិយា
តីរំ តេនុបសង្កមិ ។ អទ្ទសា ខោ អាយស្មា
មេឃិយោ កិមិកាឡាយ នទិយា តីរេ ជង្ឃាវិហារំ
អនុចង្កមមានោ អនុវិចរមានោ អម្ពវនំ បាសាទិកំ
រមណីយំ ទិស្វានស្ស ឯតទហោសិ បាសាទិកំ
វតិទំ អម្ពវនំ រមណីយំ អលំ វតិទំ កុលបុត្តស្ស
បធានត្ថិកស្ស បធានាយ សចេ មំ ភគវា អនុ-
ជានេយ្យ អាគច្ឆេយ្យាហំ ឥមំ អម្ពវនំ បធានាយាតិ ។
អថខោ អាយស្មា មេឃិយោ យេន ភគវា តេនុប-
សង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ
និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា មេឃិយោ
ភគវន្តំ ឯតទវោច ឥធាហំ ភន្តេ បុព្វណ្ហសមយំ
និវាសេត្វា បត្តចីវរមាទាយ ជន្តុគ្គាមំ បិណ្ឌាយ បាវិសឹ

លុះត្រាច់ទៅបិណ្ឌបាតក្នុងជន្តុគ្រាមហើយ ក៏ត្រឡប់អំពីបិណ្ឌបាតក្នុងកាលជាខាងក្រោយនៃភត្ត ក៏ចូលទៅរកឆ្នេរស្ទឹងកិមិកាឡា ។ ព្រះមេឃិយៈដ៏មានអាយុ កំពុងចង្ក្រមតាមលំដាប់ ត្រាច់ទៅតាមលំដាប់ ដើម្បីសម្រាកស្មង ទៀបឆ្នេរស្ទឹងកិមិកាឡា បានឃើញព្រៃស្វាយជាទីជ្រះថ្លា ជាទីត្រេកអរ លុះឃើញហើយលោកក៏មានសេចក្តីត្រិះរិះដូច្នេះថា ឱហ្ន៎ ព្រៃស្វាយនេះ ជាទីជ្រះថ្លា ជាទីត្រេកអរ ឱហ្ន៎ ព្រៃស្វាយនេះ គួរដល់ការតាំងព្យាយាមរបស់កុលបុត្ត អ្នកត្រូវការដោយការតាំងព្យាយាម ប្រសិនបើព្រះដ៏មានព្រះភាគ ទ្រង់អនុញ្ញាតឲ្យអាត្មាអញ អាត្មាអញនឹងមកកាន់ព្រៃស្វាយនេះ ដើម្បីតាំងសេចក្តីព្យាយាម ។ លំដាប់នោះ ព្រះមេឃិយៈដ៏មានអាយុ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះព្រះមេឃិយៈដ៏មានអាយុ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ក្នុងទីឯណោះ ខ្ញុំព្រះអង្គស្លៀកស្បង់ប្រដាប់បាត្រនិងចីវរក្នុងបុព្វណ្ហសម័យ ហើយចូលទៅកាន់ជន្តុគ្រាម ដើម្បីបិណ្ឌបាត

៩

បណ្ណាសកេ សម្ពោធវគ្គោ

ជន្តុគ្គាមេ បិណ្ឌាយ ចរិត្វា បច្ឆាភត្តំ បិណ្ឌបា-តប្បដិក្កន្តោ យេន កិមិកាឡាយ នទិយា តីរំ តេនុបសង្កមិំ អទ្ទសំ ខោ អហំ ភន្តេ កិមិកាឡាយ នទិយា តីរេ ជង្ឃវិហារំ អនុចង្កមមានោ អនុវិចរមានោ អម្ពវនំ បាសាទិកំ រមណីយំ ទិស្វាន មេ ឯតទហោសិ បាសាទិកំ វតិទំ អម្ពវនំ រមណីយំ អលំ វតិទំ កុលបុត្តស្ស បធានត្ថិកស្ស បធានាយ សចេ មំ ភគវា អនុជានេយ្យ អាគច្ឆេយ្យាហំ ឥមំ អម្ពវនំ បធានាយាតិ ។ សចេ មំ ភគវា អនុជានេយ្យ គច្ឆេយ្យាហំ តំ អម្ពវនំ បធានាយាតិ ។ ឯវំ វុត្តេ ភគវា អាយស្មន្តំ មេឃិយំ ឯតទវោច អាគមេហិ តាវ មេឃិយ ឯកកម្ហិ តាវ យាវ អញ្ញោបិ កោចិ ភិក្ខុ ទិស្សត្វតិ ។ ទុតិយម្បិ ខោ អាយស្មា មេឃិយោ ភគវន្តំ ឯតទវោច

លុះត្រាច់ទៅបិណ្ឌបាត ក្នុងជន្តុគ្រាមហើយ ត្រឡប់មកអំពីបិណ្ឌបាត ក្នុងកាលជាខាងក្រោយនៃភត្ត រួចក៏ចូលទៅរកឆ្នេរស្ទឹងកិមិកាឡា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គកំពុងដើរចង្រ្កមតាមលំដាប់ ត្រាច់ទៅតាមលំដាប់ ដើម្បីសម្រាកស្មងទៀបឆ្នេរស្ទឹងកិមិកាឡា បានឃើញព្រៃស្វាយជាទីជ្រះថ្លា ជាទីត្រេកអរ លុះឃើញហើយ ខ្ញុំព្រះអង្គក៏មានសេចក្តីត្រិះរិះដូច្នេះថា ឱហ្ន៎ ព្រៃស្វាយនេះ ជាទីជ្រះថ្លា ជាទីត្រេកអរ ឱហ្ន៎ ព្រៃស្វាយនេះ គួរដល់ការតាំងព្យាយាមរបស់កុលបុត្រ អ្នកត្រូវការដោយការតាំងព្យាយាម ប្រសិនបើព្រះដ៏មានព្រះភាគ ទ្រង់អនុញ្ញាតឲ្យអាត្មាអញ អាត្មាអញនឹងមកកាន់ព្រៃស្វាយនេះ ដើម្បីតាំងសេចក្តីព្យាយាម ។ ប្រសិនបើព្រះដ៏មានព្រះភាគ ទ្រង់អនុញ្ញាតឲ្យខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គនឹងទៅកាន់ព្រៃស្វាយនោះ ដើម្បីតាំងសេចក្តីព្យាយាម ។ កាលបើព្រះមេឃិយៈដ៏មានអាយុ ពោលយ៉ាងនេះហើយ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់នឹងព្រះមេឃិយៈដ៏មានអាយុដូច្នេះថា ម្នាលមេឃិយៈ អ្នកចូរបង្អង់សិនចុះ កុំអាល ដ្បិតតថាគតតែម្នាក់ឯង ទម្រាំមានភិក្ខុណាមួយឯទៀត មកប្រាកដសិន (សឹមអ្នកទៅចុះ) ។ ព្រះមេឃិយៈដ៏មានអាយុ ក្រាបបង្គំទូលព្រះដ៏មានព្រះភាគជាគម្រប់ ២ ដងដូច្នេះថា

ភគវតោ ភន្តេ នត្ថិ កិញ្ចិ ឧត្តរឹ ករណីយំ នត្ថិ កតស្ស បដិចយោ មយ្ហំ ខោ បន ភន្តេ អត្ថិ ឧត្តរឹ ករណីយំ អត្ថិ កតស្ស បដិចយោ សចេ មំ ភគវា អនុជានេយ្យ គច្ឆេយ្យាហំ តំ អម្ពវនំ បធានាយាតិ ។ អាគមេហិ តាវ មេឃិយ ឯកកម្ហិ តាវ យាវ អញ្ញោបិ កោចិ ភិក្ខុ ទិស្សតូតិ ។ តតិយម្បិ ខោ អាយស្មា មេឃិយោ ភគវន្តំ ឯត-ទវោច ភគវតោ ភន្តេ នត្ថិ កិញ្ចិ ឧត្តរឹ ករណីយំ នត្ថិ កតស្ស បដិចយោ មយ្ហំ ខោ បន ភន្តេ អត្ថិ ឧត្តរឹ ករណីយំ អត្ថិ កតស្ស បដិចយោ សចេ មំ ភគវា អនុជានេយ្យ គច្ឆេយ្យាហំ តំ អម្ពវនំ បធានា-យាតិ ។ បធានន្តិ ខោ មេឃិយ វទមានំ កិន្តិ វទេ-យ្យាម យស្សទានិ ត្វំ មេឃិយ កាលំ មញ្ញសីតិ ។

បពិត្រព្រះអង្គដ៏ចម្រើន កិច្ចដែលត្រូវធ្វើតទៅទៀតបន្តិចបន្តួច របស់ព្រះដ៏មានព្រះភាគ មិនមាន ការសន្សំនូវកិច្ចដែលធ្វើហើយមិនមានទេ បពិត្រព្រះអង្គដ៏ចម្រើន ចំណែកខ្ញុំព្រះអង្គ នៅមានករណីយកិច្ចតទៅទៀត នៅមានការសន្សំនូវកិច្ច ដែលធ្វើហើយ ប្រសិនបើ ព្រះដ៏មានព្រះភាគ ទ្រង់អនុញ្ញាតឲ្យខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គនឹងទៅកាន់ព្រៃស្វាយនោះ ដើម្បីតាំងព្យាយាម ។ ម្នាលមេឃិយៈ អ្នកចូរបង្អង់សិនចុះ កុំអាល ដ្បិតតថាគតតែម្នាក់ឯង ទម្រាំមានភិក្ខុណាមួយឯទៀត មកប្រាកដសិន (សឹមអ្នកទៅចុះ) ។ ព្រះមេឃិយៈដ៏មានអាយុបានក្រាបបង្គំទូលព្រះដ៏មានព្រះភាគជាគម្រប់ ៣ ដងដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ករណីយកិច្ចតទៅទៀតបន្តិចបន្តួចរបស់ព្រះដ៏មានព្រះភាគ មិនមាន ការសន្សំនូវកិច្ចដែលធ្វើហើយមិនមាន បពិត្រព្រះអង្គដ៏ចម្រើន ចំណែកខ្ញុំព្រះអង្គ នៅមានករណីយកិច្ចតទៅទៀត នៅមានការសន្សំនូវកិច្ចដែលធ្វើហើយ ប្រសិនបើព្រះដ៏មានព្រះភាគ ទ្រង់អនុញ្ញាតឲ្យខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គគប្បីទៅកាន់ព្រៃស្វាយនោះ ដើម្បីតាំងព្យាយាម ។ ម្នាលមេឃិយៈ តថាគតគប្បីនិយាយដូចម្ដេចនឹងអ្នក ដែលចេះតែនិយាយថា ការតាំងព្យាយាមដូច្នេះ ម្នាលមេ-ឃិយៈ អ្នកចូរសម្គាល់នូវកាល ដែលគួរនឹងទៅក្នុងកាលឥឡូវនេះចុះ ។

## បណ្ណាសកេ សម្ពោធវគ្គោ

អថខោ អាយស្មា មេឃិយោ ឧដ្ឋាយាសនា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា យេន តំ អម្ពវនំ តេនុបសង្កមិ ឧបសង្កមិត្វា តំ អម្ពវនំ អជ្ឈោ-គាហេត្វា អញ្ញតរស្មឹ រុក្ខមូលេ ទិវាវិហារំ និសីទិ ។ អថខោ អាយស្មតោ មេឃិយស្ស តស្មឹ អម្ពវនេ វិហរន្តស្ស យេភុយ្យេន តយោ បាបកា អកុសលា វិតក្កា សមុទាចរន្តិ សេយ្យថីទំ កាមវិតក្កោ ព្យាបាទវិតក្កោ វិហឹសាវិតក្កោ ។ អថខោ អាយស្មតោ មេឃិយស្ស ឯតទហោសិ អច្ឆរិយំ វត ភោ អព្ភុតំ វត ភោ សទ្ធាយ តម្ហា អគារស្មា អនគារិយំ បព្វជិតា អថ ច បនិមេហិ តីហិ បាបកេហិ អកុសលេហិ វិតក្កេហិ អន្វាសត្តា កាមវិតក្កេន ព្យាបាទវិតក្កេន វិហឹសាវិតក្កេនាតិ ។ អថខោ អាយស្មា មេឃិយោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា មេឃិយោ

គ្រានោះឯង ព្រះមេឃិយៈ ដ៏មានអាយុ ក្រោកចាកអាសនៈ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ធ្វើប្រទក្សិណហើយចូលទៅរកព្រៃស្វាយនោះ លុះទៅដល់ហើយ ក៏ចូលទៅកាន់ព្រៃស្វាយនោះ អង្គុយសម្រាកក្នុងវេលាថ្ងៃ ទៀបគល់ឈើ ១ ដើម ។ លំដាប់នោះ កាលព្រះមេឃិយៈដ៏មានអាយុ នៅក្នុងព្រៃស្វាយនោះ អកុសលវិតក្កៈដ៏លាមក ៣ យ៉ាង គឺ កាមវិតក្កៈ ១ ព្យាបាទវិតក្កៈ ១ វិហឹសាវិតក្កៈ ១ ក៏ពុះពោរឡើងរឿយៗ ។ លំដាប់នោះ ព្រះមេឃិយៈដ៏មានអាយុ ក៏មានសេចក្តីត្រិះរិះថា យីអើ អស្ចារ្យណាស់ យីអើ ចំឡែកណាស់ហ្ន៎ បុគ្គលទាំងឡាយចេញចាកផ្ទះនោះ ចូលកាន់ផ្នួសដោយសទ្ធា ក៏នៅតែមានអកុសលវិតក្កៈដ៏លាមក ៣ ប្រការនេះ គឺកាម-វិតក្កៈ ១ ព្យាបាទវិតក្កៈ ១ វិហឹសាវិតក្កៈ ១ តាមរួបរឹតទៀត ។ លំដាប់នោះ ព្រះមេឃិយៈដ៏មានអាយុ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះព្រះមេឃិយៈដ៏មានអាយុអង្គុយ ក្នុងទីសមគួរហើយ

ភគវន្តំ ឯតទវោច ឥធ មយ្ហំ ភន្តេ តស្មឹ អម្ពវនេ វិហរន្តស្ស យេភុយ្យេន តយោ បាបកា អកុសលា វិតក្កា សមុទាចរន្តិ សេយ្យថីទំ កាមវិតក្កោ ព្យាបាទវិតក្កោ វិហឹសាវិតក្កោ តស្ស មយ្ហំ ភន្តេ ឯតទហោសិ អច្ឆរិយំ វត ភោ អព្ភុតំ វត ភោ សទ្ធាយ តម្ហា អគារស្មា អនគារិយំ បព្វជិតា អថ ច បនិមេហិ តីហិ បាបកេហិ អកុសលេហិ វិតក្កេហិ អន្វាសត្តា កាមវិតក្កេន ព្យាបាទវិតក្កេន វិហឹសាវិតក្កេនាតិ ។ អបរិបក្កាយ មេឃិយ ចេតោវិមុត្តិយា បញ្ច ធម្មា បរិបក្កាយ សំវត្តន្តិ ។ កតមេ បញ្ច ។ ឥធ មេឃិយ ភិក្ខុ កល្យាណមិត្តោ ហោតិ កល្យាណសហាយោ កល្យាណសម្បវង្កោ ។ អបរិបក្កាយ មេឃិយ ចេតោវិមុត្តិយា អយំ បឋមោ ធម្មោ បរិបក្កាយ សំវត្តតិ ។ បុន ច បរំ មេឃិយ ភិក្ខុ សីលវា ហោតិ បាតិមោក្ខសំវរសំវុតោ វិហរតិ អាចារគោចរសម្បន្នោ

ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ក្នុងទីឯណោះ កាលខ្ញុំព្រះអង្គនៅក្នុងព្រៃស្វាយនោះ អកុសលវិតក្កៈដ៏លាមក ៣ ប្រការ គឺកាមវិតក្កៈ ១ ព្យាបាទវិតក្កៈ ១ វិហឹសាវិតក្កៈ ១ តែងពុះពោរឡើងរឿយៗ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនោះ មានសេចក្តីត្រិះរិះដូច្នេះថា យីអើ អស្ចារ្យណាស់ យីអើ ចំឡែកណាស់ កុលបុត្តទាំងឡាយ ចេញចាកផ្ទះនោះ ចូលកាន់ផ្នួសដោយសទ្ធាហើយ ក៏នៅតែមានអកុសលវិតក្កៈដ៏លាមក ៣ ប្រការនេះ គឺ កាមវិតក្កៈ ១ ព្យាបាទវិតក្កៈ ១ វិហឹសាវិតក្កៈ ១ តាមរួបរឹតទៀត ។ ម្នាលមេឃិយៈ ធម៌ទាំងឡាយ ៥ យ៉ាង តែងប្រព្រឹត្តទៅ ដើម្បីចេតោវិមុត្តិ ដែលពុំទាន់ចាស់ក្លា ឲ្យចាស់ក្លាឡើងបាន ។ ធម៌ ៥ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលមេឃិយៈ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានមិត្រល្អ មានសំឡាញ់ល្អ សមគប់នឹងមិត្រល្អ ។ ម្នាលមេឃិយៈ នេះជាធម៌ទី ១ តែងប្រព្រឹត្តទៅ ដើម្បីចេតោវិមុត្តិ ដែលពុំទាន់ចាស់ក្លា ឲ្យចាស់ក្លាឡើងបាន ។ ម្នាលមេឃិយៈ មួយទៀត ភិក្ខុជាអ្នកមានសីល សង្រួមហើយដោយការសង្រួមក្នុងបាតិមោក្ខ បរិបូណ៌ដោយអាចារៈនិងគោចរៈ

បណ្ណាសកេ សម្ពោធវគ្គោ

អណុមត្តេសុ វជ្ជេសុ ភយទស្សាវី សមាទាយ សិក្ខតិ សិក្ខាបទេសុ ។ អបរិបក្កាយ មេឃិយ ចេតោវិមុត្តិយា អយំ ទុតិយោ ធម្មោ បរិបក្កាយ សំវត្តតិ ។ បុន ច បរំ មេឃិយ ភិក្ខុ យាយំ កថា អភិសល្លេខិកា ចេតោវិវរណសប្បាយា សេយ្យថីទំ អប្បិច្ឆកថា សន្តុដ្ឋិកថា បវិវេកកថា អសំសគ្គកថា វីរិយារម្ភកថា សីលកថា សមាធិកថា បញ្ញាកថា វិមុត្តិកថា វិមុត្តិញ្ញាណទស្សនកថា ឯវរូបិយា កថាយ និកាមលាភី ហោតិ អកិច្ឆលាភី អកសិរលាភី ។ អបរិបក្កាយ មេឃិយ ចេតោវិមុត្តិយា អយំ តតិយោ ធម្មោ បរិបក្កាយ សំវត្តតិ ។ បុន ច បរំ មេឃិយ ភិក្ខុ អារទ្ធវីរិយោ វិហរតិ អកុសលានំ ធម្មានំ បហានាយ កុសលានំ ធម្មានំ ឧបសម្បទាយ ថាមវា ទឡ្ហបរក្កមោ អនិក្ខិត្តធុរោ កុសលេសុ ធម្មេសុ ។ អបរិបក្កាយ មេឃិយ ចេតោវិមុត្តិយា អយំ ចតុត្ថោ ធម្មោ បរិបក្កាយ សំវត្តតិ ។

ឃើញភ័យ ក្នុងទោសទាំងឡាយសូម្បីបន្តិចបន្តួច សមាទានសិក្សា ក្នុងសិក្ខាបទទាំងឡាយ ។ ម្នាលមេឃិយៈ នេះជាធម៌ ទី ២ តែងប្រព្រឹត្តទៅ ដើម្បីចេតោវិមុត្តិ ដែលពុំទាន់ចាស់ក្លា ឲ្យចាស់ក្លាឡើងបាន ។ ម្នាលមេឃិយៈ មួយទៀត ភិក្ខុជាអ្នកបានតាមប្រាថ្នា បានមិនលំបាក បានដោយងាយនូវកថាមានសភាពយ៉ាងនេះ ដែលជាកថាដ៏ផូរផង់ ជាទីសប្បាយទូលាយចិត្ត គឺអប្បិច្ឆកថា សន្តុដ្ឋិកថា បវិវេកកថា អសំសគ្គកថា វីរិយារម្ភកថា សីលកថា សមាធិកថា បញ្ញាកថា វិមុត្តិកថា វិមុត្តិញ្ញាណទស្សនកថា ។ ម្នាលមេឃិយៈ នេះជាធម៌ទី ៣ ប្រព្រឹត្តទៅ ដើម្បីចេតោវិមុត្តិ ដែលពុំទាន់ចាស់ក្លា ឲ្យចាស់ក្លាឡើងបាន ។ ម្នាលមេឃិយៈ មួយទៀត ភិក្ខុជាអ្នកប្រារព្ធនូវសេចក្តីព្យាយាម ដើម្បីលះបង់នូវពួកអកុសលធម៌ចេញ ដើម្បីញ៉ាំងពួកកុសលធម៌ឲ្យកើតឡើង ជាអ្នកមានកម្លាំង មានសេចក្តីប្រឹងប្រែងដ៏មាំមួន មិនដាក់ធុរៈចោលក្នុងកុសលធម៌ទាំង-ឡាយ ។ ម្នាលមេឃិយៈ នេះជាធម៌ ទី ៤ តែងប្រព្រឹត្តទៅ ដើម្បីចេតោវិមុត្តិ ដែលពុំទាន់ចាស់ក្លា ឲ្យចាស់ក្លាឡើងបាន ។

បុន ច បរំ មេឃិយ ភិក្ខុ បញ្ញវា ហោតិ ឧទយត្ថគា-មិនិយា បញ្ញាយ សមន្នាគតោ អរិយាយ និព្វេធិកាយ សម្មាទុក្ខក្ខយគាមិនិយា ។ អបរិបក្កាយ មេឃិយ ចេតោវិមុត្តិយា អយំ បញ្ចមោ ធម្មោ បរិបក្កាយ សំវត្តតិ ។ កល្យាណមិត្តស្សេតំ មេឃិយ ភិក្ខុនោ បាដិកង្ខំ កល្យាណសហាយស្ស កល្យាណសម្ប-វង្កស្ស សីលវា ភវិស្សតិ ។ បេ ។ សមាទាយ សិក្ខិស្សតិ សិក្ខាបទេសុ ។ កល្យាណមិត្តស្សេតំ មេឃិយ ភិក្ខុនោ បាដិកង្ខំ កល្យាណសហាយស្ស កល្យាណសម្បវង្កស្ស យាយំ កថា អភិសល្លេខិកា ចេតោវិវរណសប្បាយា សេយ្យថីទំ អប្បិច្ឆកថា ។ បេ ។ វិមុត្តិញ្ញាណទស្សនកថា ឯវរូបិយា កថាយ និកាម-លាភី ភវិស្សតិ អកិច្ឆលាភី អកសិរលាភី ។ កល្យា-ណមិត្តស្សេតំ មេឃិយ ភិក្ខុនោ បាដិកង្ខំ កល្យា-ណសហាយស្ស កល្យាណសម្បវង្កស្ស អារទ្ធវីរិយោ វិហរិស្សតិ ។ បេ ។ អនិក្ខិត្តធុរោ កុសលេសុ ធម្មេសុ ។

ម្នាលមេឃិយៈ មួយទៀត ភិក្ខុជាអ្នកមានប្រាជ្ញា ប្រកបដោយប្រាជ្ញា ដែលកំណត់នូវការកើតឡើង និងវិនាសទៅ ជាគ្រឿងទម្លាយនូវកិលេសដ៏ប្រសើរ ជាធម្មជាតិដល់នូវកិរិយាអស់ទៅនៃទុក្ខដោយប្រពៃ ។ ម្នាលមេឃិយៈ នេះជាធម៌ទី ៥ តែងប្រព្រឹត្តទៅ ដើម្បីចេតោវិមុត្តិ ដែលពុំទាន់ចាស់ក្លា ឲ្យចាស់ក្លាឡើងបាន ។ ម្នាលមេឃិយៈ ហេតុនេះរមែងកើតប្រាកដដល់ភិក្ខុអ្នកមានមិត្រល្អ មានសំឡាញ់ល្អ សមគប់នឹងមិត្រល្អ គឺភិក្ខុនោះនឹងបានជាអ្នកមានសីល ។ បេ ។ សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ ។ ម្នាលមេឃិយៈ ហេតុនេះ រមែងកើតប្រាកដដល់ភិក្ខុអ្នកមានមិត្រល្អ មានសំឡាញ់ល្អ សមគប់នឹងមិត្រល្អ គឺភិក្ខុនោះនឹងបានជាអ្នកបានតាមប្រាថ្នា បានដោយមិនលំបាក បានដោយងាយ នូវកថាមានសភាពយ៉ាងនេះ ដែលជាកថាដ៏ផូរផង់ ជាទីសប្បាយទូលាយចិត្ត គឺអប្បិច្ឆកថា ។ បេ ។ វិមុត្តិញ្ញាណទស្សនកថា ។ ម្នាលមេឃិយៈ ហេតុនេះ រមែងកើតប្រាកដដល់ភិក្ខុអ្នកមានមិត្រល្អ មានសំឡាញ់ល្អ សមគប់នឹងមិត្រល្អ គឺភិក្ខុនោះនឹងបានជាអ្នកប្រារព្ធនូវសេចក្តីព្យាយាម ។ បេ ។ ជាអ្នកមិនដាក់ធុរៈចោល ក្នុងកុសលធម៌ទាំងឡាយ ។

១៨



កល្យាណមិត្តស្សេតំ មេឃិយ ភិក្ខុនោ បាដិកង្ខំ កល្យាណសហាយស្ស កល្យាណសម្បវង្កស្ស បញ្ញវា ភវិស្សតិ ។ បេ ។ សម្មាទុក្ខក្ខយគាមិនិយា ។ តេន ច បន មេឃិយ ភិក្ខុនា ឥមេសុ បញ្ចសុ ធម្មេសុ បតិដ្ឋាយ ចត្តារោ ធម្មា ឧត្តរឹ ភាវេតព្វា អសុភា ភាវេតព្វា រាគស្ស បហានាយ មេត្តា ភាវេតព្វា ព្យាបាទស្ស បហានាយ អានាបានស្សតិ ភាវេតព្វា វិតក្កុបច្ឆេទាយ អនិច្ចសញ្ញា ភាវេតព្វា អស្មិមានសមុគ្ឃាតាយ ។ អនិច្ចសញ្ញិនោ មេឃិយ អនត្តសញ្ញា សណ្ឋាតិ អនត្តសញ្ញី អស្មិមាន-សមុគ្ឃាតំ បាបុណាតិ ទិដ្ឋេវ ធម្មេ និព្វានន្តិ ។

[៤] ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន អាយស្មា នន្ទកោ ឧបដ្ឋានសាលាយំ ភិក្ខូ ធម្មិយា កថាយ សន្ទ-ស្សេតិ សមាទបេតិ សមុត្តេជេតិ សម្បហំសេតិ ។

ម្នាលមេឃិយៈ ហេតុនេះ រមែងកើតប្រាកដដល់ភិក្ខុ អ្នកមានមិត្រល្អ មានសំឡាញ់ល្អ សមគប់នឹងមិត្រល្អ គឺភិក្ខុនោះ នឹងបានជាអ្នកមានបញ្ញា ។ បេ ។ ជាធម្មជាតិដល់នូវកិរិយាអស់ទៅ នៃទុក្ខដោយប្រពៃ ។ ម្នាលមេឃិយៈ មួយទៀត ភិក្ខុនោះតាំងនៅក្នុងធម៌ទាំង ៥ នេះហើយ គប្បីចម្រើននូវធម៌ ៤ យ៉ាងតទៅគឺចម្រើនអសុភ ដើម្បីលះរាគៈ ចម្រើនមេត្តា ដើម្បីលះព្យាបាទ ចម្រើនអានាបានស្សតិ ដើម្បីផ្ដាច់បង់នូវវិតក្កៈ ចម្រើនអនិច្ចសញ្ញា ដើម្បីដកចោលនូវអស្មិមានះ ។ ម្នាលមេឃិយៈ សេចក្ដីសម្គាល់ថា មិនមែនខ្លួន រមែងប្រាកដដល់ភិក្ខុអ្នកមានសេចក្ដីសម្គាល់ថា មិនទៀង ភិក្ខុអ្នកមានសេចក្ដីសម្គាល់ថា មិនមែនខ្លួន រមែងដល់ព្រះនិព្វានជាគ្រឿងដកចោលនូវអស្មិមានះ ក្នុងបច្ចុប្បន្ន ។

[៤] សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅ ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ព្រះនន្ទកៈដ៏មានអាយុ បានញុំាងភិក្ខុទាំងឡាយឲ្យឃើញច្បាស់ ឲ្យកាន់យក ឲ្យអាចហាន ឲ្យរីករាយ ដោយធម្មីកថា ក្នុងឧបដ្ឋានសាលា ។

អថខោ ភគវា សាយណ្ហសមយំ បដិសល្លានា វុដ្ឋិតោ យេនុបដ្ឋានសាលា តេនុបសង្កមិ ឧបសង្កមិត្វា ពហិទ្វារកោដ្ឋកេ អដ្ឋាសិ កថាបរិយោសានំ អាគមយមានោ ។ អថខោ ភគវា កថាបរិយោសានំ វិទិត្វា ឧក្កាសេត្វា អគ្គឡំ អាកោដេសិ ។ វិវរឹសុ ខោ តេ ភិក្ខូ ភគវតោ ទ្វារំ ។ អថខោ ភគវា ឧបដ្ឋានសាលំ បវិសិត្វា បញ្ញត្តេ អាសនេ និសីទិ ។ និសជ្ជ ខោ ភគវា អាយស្មន្តំ នន្ទកំ ឯតទវោច ទីឃោ ខោ ត្យាយំ នន្ទក ធម្មបរិយាយោ ភិក្ខូនំ បដិភាសិ អបិ មេ បិដ្ឋិ អាគិលាយតិ ពហិទ្វារកោដ្ឋកេ ឋិតស្ស កថាបរិយោសានំ អាគមយមានស្សាតិ ។ ឯវំ វុត្តេ អាយស្មា នន្ទកោ សារជ្ជមានរូបោ ឱត្តប្បមានោ[១] ភគវន្តំ ឯតទវោច ន ខោ បន មយំ ភន្តេ ជានាម ភគវា ពហិទ្វារកោដ្ឋកេ ឋិតោតិ សចេ ហិ មយំ ភន្តេ ជានេយ្យាម ភគវា ពហិទ្វារកោដ្ឋកេ ឋិតោតិ ឯត្តកំបិ នោ នប្បដិភាសេយ្យាតិ ។

---

១ ឱ. ឱត្តប្បមានោតិ អយំ បាឋោ ន ទិស្សតិ ។

គ្រានោះ ព្រះដ៏មានព្រះភាគ ចេញអំពីទីពួនសម្ងំ ក្នុងសាយណ្ហសម័យ ចូលទៅឧបដ្ឋានសាលា លុះស្តេចចូលទៅដល់ហើយ ក៏ប្រថាប់នៅទៀបក្លោងទ្វារខាងក្រៅ រង់ចាំចប់កថា ។ លំដាប់នោះ ព្រះដ៏មានព្រះភាគ ទ្រង់ជ្រាបច្បាស់ថាចប់កថាហើយ ក៏គ្រហែមហើយគោះសន្ទះទ្វារ ។ ពួកភិក្ខុទាំងនោះ ក៏បើកទ្វារថ្វាយព្រះដ៏មានព្រះភាគ ។ លំដាប់នោះ ព្រះដ៏មានព្រះភាគ ស្តេចចូលទៅក្នុងឧបដ្ឋានសាលាហើយ ទ្រង់គង់លើអាសនៈដែលគេក្រាលថ្វាយ ។ លុះព្រះដ៏មានព្រះភាគ គង់ហើយ ទ្រង់ត្រាស់នឹងព្រះនន្ទកៈដ៏មានអាយុថា នៃនន្ទកៈ ធម្មបរិយាយរបស់អ្នកនេះ វែងពេកណាស់ប្រាកដដល់ភិក្ខុទាំងឡាយហើយ ប៉ុនអម្បាល តថាគតឈរទៀបក្លោងទ្វារខាងក្រៅ រង់ចាំទម្រាំតែចប់កថាទាល់តែរួយខ្នង ។ កាលបើព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ ព្រះនន្ទកៈដ៏មានអាយុ ក៏អៀនអន់ខ្មាច បានក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន យើងខ្ញុំមិនដឹងជាព្រះដ៏មានព្រះភាគ ទ្រង់ប្រថាប់នៅទៀបក្លោងទ្វារខាងក្រៅទេ បពិត្រព្រះអង្គដ៏ចម្រើន បើប្រសិនជា ខ្ញុំព្រះអង្គដឹងថា ព្រះដ៏មានព្រះភាគ ទ្រង់សណ្ឋិតនៅទៀបក្លោងទ្វារខាងក្រៅ ដូច្នេះ ខ្ញុំព្រះអង្គក៏មិនគប្បីសម្តែងនូវពាក្យមានប្រមាណប៉ុណ្ណោះទេ ។

១៧

បណ្ណាសកេ សម្ពោធវគ្គោ

អថខោ ភគវា អាយស្មន្តំ នន្ទកំ សារជ្ជមានរូបំ វិទិត្វា អាយស្មន្តំ នន្ទកំ ឯតទវោច សាធុ សាធុ នន្ទក ឯតំ ខោ នន្ទក តុម្ហាកំ បដិរូបំ កុលបុត្តានំ សទ្ធាយ អគារស្មា អនគារិយំ បព្វជិតានំ យំ តុម្ហេ ធម្មិយា កថាយ សន្និសីទេយ្យាថ សន្និបតិតានំ វោ នន្ទក ទ្វយំ ករណីយំ ធម្មី វា កថា អរិយោ វា តុណ្ហីភាវោ ។ សទ្ធោ នន្ទក ភិក្ខុ ហោតិ នោ សីលវា ឯវំ សោ តេនង្គេន អបរិបូរោ ហោតិ តេន តំ អង្គំ បរិបូរេតព្វំ កិន្នាហំ[1] សទ្ធោ ច អស្សំ សីលវា ចាតិ ។ យតោ ច ខោ នន្ទក ភិក្ខុ សទ្ធោ ច ហោតិ សីលវា ច ឯវំ សោ តេនង្គេន បរិបូរោ ហោតិ សទ្ធោ ច នន្ទក ភិក្ខុ ហោតិ សីលវា ច នោ ច លាភី អជ្ឈត្តំ ចេតោស-មាធិស្ស[2] ឯវំ សោ តេនង្គេន អបរិបូរោ ហោតិ តេន តំ អង្គំ បរិបូរេតព្វំ កិន្នាហំ សទ្ធោ ច អស្សំ សីលវា ច លាភី ច អជ្ឈត្តំ ចេតោសមាធិស្សាតិ ។

១ ឱ. កិន្តាហំ ។ ២ ឱ. ចេតោសមថស្ស ។

លំដាប់នោះ ព្រះដ៏មានព្រះភាគ ទ្រង់ជ្រាបច្បាស់នូវព្រះនន្ទកៈ ដ៏មានអាយុ ជាអ្នកមានសភាពអៀនអន់ ហើយទ្រង់ត្រាស់នឹងព្រះនន្ទកៈ ដ៏មានអាយុថា ម្នាលនន្ទកៈ ប្រពៃហើយៗ ម្នាលនន្ទកៈ អ្នកទាំងឡាយ គប្បីអង្គុយប្រជុំគ្នា ដោយធម្មីកថាណា ការអង្គុយប្រជុំគ្នាដោយធម្មីកថានុ៎ះ សមគួរដល់អ្នកទាំងឡាយ ដែលជាកុលបុត្តចេញចាកផ្ទះ ចូលកាន់ផ្នួស ដោយសទ្ធាហើយ ម្នាលនន្ទកៈ អ្នកទាំងឡាយដែលប្រជុំគ្នាហើយ គប្បីធ្វើកិច្ច ២ យ៉ាងគឺ ធម្មីកថា ១ អរិយតុណ្ហីភាព ១ ។ ម្នាលនន្ទកៈ ភិក្ខុជាអ្នកមានសទ្ធាតែគ្មានសីល កាលបើយ៉ាងនេះ ភិក្ខុនោះឈ្មោះថា មិនពេញដោយអង្គនោះទេ ភិក្ខុនោះ ត្រូវបំពេញអង្គនោះដោយគិតថា អាត្មាអញគប្បីជាអ្នកមានសទ្ធាផង មានសីលផង មិនដូច្នោះឬ ។ ម្នាលនន្ទកៈ កាលណាភិក្ខុជាអ្នកមានសទ្ធាផង មានសីលផង កាលបើយ៉ាងនេះ ភិក្ខុនោះឈ្មោះថាជាអ្នកពេញដោយអង្គនោះ ម្នាលនន្ទកៈ ភិក្ខុមានសទ្ធាផង មានសីលផង តែមិនបាននូវចេតោសមាធិខាងក្នុងសន្តាន កាលបើយ៉ាងនេះ ភិក្ខុនោះឈ្មោះថា មិនពេញដោយអង្គនោះទេ ភិក្ខុនោះ ត្រូវបំពេញអង្គនោះដោយគិតថា អាត្មាអញគប្បីជាអ្នកមានសទ្ធាផង មានសីលផង បាននូវចេតោសមាធិខាងក្នុងសន្តានផង មិនដូច្នោះឬ ។

យតោ ច ខោ ជន្ទក ភិក្ខុ សទ្ធោ ច ហោតិ សីលវា ច លាភី ច អជ្ឈត្តំ ចេតោសមាធិស្ស ឯវំ សោ តេនង្គេន បរិបូរោ ហោតិ សទ្ធោ ច ជន្ទក ភិក្ខុ ហោតិ សីលវា ច លាភី ច អជ្ឈត្តំ ចេតោសមា-ធិស្ស ន លាភី អធិប្បញ្ញាធម្មវិបស្សនាយ ឯវំ សោ តេនង្គេន អបរិបូរោ ហោតិ ។ សេយ្យថាបិ ជន្ទក ទ្វិបាទកោ ចតុប្បាទកោ តស្ស តស្ស ឯកោ បាទោ ឱមកោ លាមកោ ឯវំ សោ តេនង្គេន អបរិបូរោ អស្ស ឯវមេវ ខោ ជន្ទក ភិក្ខុ សទ្ធោ ច ហោតិ សីលវា ច លាភី ច អជ្ឈត្តំ ចេតោស-មាធិស្ស ន លាភី អធិប្បញ្ញាធម្មវិបស្សនាយ ឯវំ សោ តេនង្គេន អបរិបូរោ ហោតិ តេន តំ អង្គំ បរិបូរេតព្វំ កិន្តាហំ សទ្ធោ ច អស្សំ សីលវា ច លាភី ច អជ្ឈត្តំ ចេតោសមាធិស្ស លាភី ច អធិប្បញ្ញាធម្មវិបស្ស-នាយាតិ ។ យតោ ច ខោ ជន្ទក ភិក្ខុ សទ្ធោ ច ហោតិ សីលវា ច លាភី ច អជ្ឈត្តំ ចេតោ-សមាធិស្ស លាភី ច អធិប្បញ្ញាធម្មវិបស្សនាយ ឯវំ

ម្នាលនន្ទក: កាលណាភិក្ខុជាអ្នកមានសទ្ធាផង មានសីលផង បាននូវចេតោសមាធិខាងក្នុងសន្តានផង កាលបើយ៉ាងនេះ ភិក្ខុនោះ ឈ្មោះថាជាអ្នកពេញដោយអង្គនោះ ម្នាលនន្ទក: ភិក្ខុជាអ្នកមានសទ្ធាផង មានសីលផង បាននូវចេតោសមាធិ ខាងក្នុងសន្តានផង តែមិនបាននូវអធិប្បញ្ញាធម្មវិបស្សនា កាលបើយ៉ាងនេះ ភិក្ខុនោះ ឈ្មោះថាមិនពេញដោយអង្គនោះ ។ ម្នាលនន្ទក: ដូចសត្វជើង ២ សត្វជើង ៤ តែជើង ១ របស់សត្វនោះៗ ថោកថយ អន់ កាលបើយ៉ាងនេះ សត្វនោះឈ្មោះថា មិនពេញដោយអង្គនោះ យ៉ាងណាមិញ ម្នាលនន្ទក: ភិក្ខុជាអ្នកមានសទ្ធាផង មានសីលផង បាននូវចេតោសមាធិខាងក្នុងសន្តានផង តែមិនបាននូវអធិប្បញ្ញាធម្មវិបស្សនា កាលបើយ៉ាងនេះ ភិក្ខុនោះឈ្មោះថាមិនពេញដោយអង្គនោះ ភិក្ខុនោះត្រូវបំពេញអង្គនោះ ដោយគិតថា អាត្មាអញ គប្បីជាអ្នកមានសទ្ធាផង មានសីលផង បាននូវចេតោសមាធិ ខាងក្នុងសន្តានផង បាននូវអធិ-ប្បញ្ញាធម្មវិបស្សនាផង មិនដូច្នោះឬ ក៏យ៉ាងនោះដែរ ។ ម្នាលនន្ទក: កាលណា ភិក្ខុជាអ្នកមានសទ្ធាផង មានសីលផង បាននូវចេតោសមាធិខាងក្នុងសន្តានផង បាននូវអធិប្បញ្ញាធម្មវិបស្សនាផង កាលបើយ៉ាងនេះ

សោ តេនង្គេន បរិបូរោ ហោតីតិ ។ ឥទមវោច ភគវា ឥទំ វត្វាន សុគតោ ឧដ្ឋាយាសនា វិហារំ បាវិសិ ។ អថខោ អាយស្មា នន្ទកោ អចិរប្បក្កន្តស្ស ភគវតោ ភិក្ខូ អាមន្តេសិ ឥទានាវុសោ ភគវា ចតូហិ បទេហិ កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ បកាសេត្វា ឧដ្ឋាយាសនា វិហារំ បវិដ្ឋោ សទ្ធោ នន្ទក ភិក្ខុ ហោតិ នោ សីលវា ឯវំ សោ តេនង្គេន អបរិបូរោ ហោតិ តេន តំ អង្គំ បរិបូរេតព្វំ កិន្តាហំ សទ្ធោ ច អស្សំ សីលវា ចាតិ ។ យតោ ច ខោ នន្ទក ភិក្ខុ សទ្ធោ ច ហោតិ សីលវា ច ឯវំ សោ តេនង្គេន បរិបូរោ ហោតិ សទ្ធោ ច នន្ទក ភិក្ខុ ហោតិ សីលវា ច នោ ច លាភី អជ្ឈត្តំ ចេតោសមាធិស្ស ។ បេ ។ លាភី ច អជ្ឈត្តំ ចេតោសមាធិស្ស ន លាភី អធិប្បញ្ញាធម្មវិបស្សនាយ ឯវំ សោ តេនង្គេន អបរិបូរោ ហោតិ

ភិក្ខុនោះឈ្មោះថា ជាអ្នកពេញដោយអង្គនោះ ។ ព្រះដ៏មានព្រះភាគ ត្រាស់ពាក្យនោះចប់ហើយ លុះព្រះសុគតទ្រង់ពោលពាក្យនេះហើយ ក៏ក្រោកចាកអាសនៈ ចូលទៅកាន់វិហារ ។ គ្រានោះ ព្រះនន្ទកៈដ៏មានអាយុ កាលព្រះដ៏មានព្រះភាគចៀសចេញទៅ មិនយូរប៉ុន្មាន ក៏ហៅភិក្ខុទាំងឡាយមកថា ម្នាលអាវុសោទាំងឡាយ ឥឡូវនេះ ព្រះដ៏មានព្រះភាគ ទ្រង់ប្រកាសព្រហ្មចរិយធម៌ដ៏បរិសុទ្ធ គ្រប់ទាំងអស់ដោយបទទាំងឡាយ ៤ ហើយទ្រង់ស្តេចក្រោកចាកអាសនៈ ចូលទៅកាន់វិហារ ត្រាស់ថា ម្នាលនន្ទកៈ ភិក្ខុជាអ្នកមានសទ្ធាតែគ្មានសីល កាលបើយ៉ាងនេះ ភិក្ខុនោះឈ្មោះថា មិនពេញដោយអង្គនោះ ភិក្ខុនោះត្រូវតែបំពេញអង្គនោះដោយគិតថា អាត្មាអញ គប្បីជាអ្នកមានសទ្ធាផង មានសីលផង មិនដូច្នោះឬ ។ ម្នាលនន្ទកៈ កាលណា ភិក្ខុជាអ្នកមានសទ្ធាផង មានសីលផង កាលបើយ៉ាងនេះ ភិក្ខុនោះឈ្មោះថា ពេញដោយអង្គនោះ ម្នាលនន្ទកៈ ភិក្ខុជាអ្នកមានសទ្ធាផង មានសីលផង តែមិនបាននូវចេតោសមាធិ ខាងក្នុងសន្តាន ។ បេ ។ បាននូវចេតោសមាធិ ខាងក្នុងសន្តានផង តែមិនបាននូវអធិប្បញ្ញាធម្មវិបស្សនា កាលបើយ៉ាងនេះ ភិក្ខុនោះឈ្មោះថាមិនពេញដោយអង្គនោះ

សេយ្យថាបិ ជន្នក ទ្វិចាងកោ ចតុប្បាទកោ តស្ស តស្ស ឯកោ បាទោ ឱមកោ លាមកោ ឯវំ សោ តេនង្គេន អបរិបូរោ អស្ស ឯវមេវ ខោ ជន្នក ភិក្ខុ សទ្ធោ ច ហោតិ សីលវា ច លាភី ច អជ្ឈត្តំ ចេតោ-សមាធិស្ស ន លាភី អធិប្បញ្ញាធម្មវិបស្សនាយ ឯវំ សោ តេនង្គេន អបរិបូរោ ហោតិ តេន តំ អង្គំ បរិបូរេតព្វំ កិន្តាហំ សទ្ធោ ច អស្សំ សីលវា ច លាភី ច អជ្ឈត្តំ ចេតោសមាធិស្ស លាភី ច អធិប្បញ្ញាធម្ម-វិបស្សនាយាតិ ។ យតោ ច ខោ ជន្នក ភិក្ខុ សទ្ធោ ច ហោតិ សីលវា ច លាភី ច អជ្ឈត្តំ ចេតោសមា-ធិស្ស លាភី ច អធិប្បញ្ញាធម្មវិបស្សនាយ ឯវំ សោ តេនង្គេន បរិបូរោ ហោតីតិ ។ បញ្ចមេ អាវុសោ អាទិសំសា កាលេន ធម្មស្សវនេ កាលេន ធម្មសា-កច្ឆាយ ។ កតមេ បញ្ច ។ ឥធាវុសោ ភិក្ខុ ភិក្ខូនំ ធម្មំ ទេសេតិ អាទិកល្យាណំ មជ្ឈេ-កល្យាណំ បរិយោសានកល្យាណំ សាត្ថំ សព្យញ្ជនំ កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ បកាសេតិ

ម្នាលនន្ទក: ដូចសត្វជើង ២ សត្វជើង ៤ តែជើងមួយរបស់សត្វនោះៗ ថោកថយ អន់ កាលបើយ៉ាងនេះ សត្វនោះឈ្មោះថាមិនពេញដោយអង្គនោះ យ៉ាងណាមិញ ម្នាលនន្ទក: ភិក្ខុជាអ្នកមានសទ្ធាផង មានសីលផង បាននូវចេតោសមាធិខាងក្នុងសន្តានផង តែមិនបាននូវអធិប្បញ្ញាធម្មវិបស្សនា កាលបើយ៉ាងនេះ ភិក្ខុនោះឈ្មោះថាមិនពេញដោយអង្គនោះ ភិក្ខុនោះ ត្រូវបំពេញអង្គនោះ ដោយគិតថា អាត្មាអញគប្បីជាអ្នកមានសទ្ធាផង មានសីលផង បាននូវចេតោសមាធិខាងក្នុងសន្តានផង បាននូវអធិប្បញ្ញាធម្មវិបស្សនាផង មិនដូច្នោះឬ ក៏យ៉ាងនោះដែរ ។ ម្នាលនន្ទក: កាលណា ភិក្ខុជាអ្នកមានសទ្ធាផង មានសីលផង បាននូវចេតោសមាធិខាងក្នុងសន្តានផង បាននូវអធិប្បញ្ញាធម្មវិបស្សនាផង កាលបើយ៉ាងនេះ ភិក្ខុនោះ ឈ្មោះថាពេញដោយអង្គនោះ ។ ម្នាលអាវុសោទាំងឡាយ អានិសង្សក្នុងការស្តាប់ធម៌តាមកាលគួរ ក្នុងការសាកច្ឆាធម៌តាមកាលគួរនេះ មាន ៥ យ៉ាង ។ អានិសង្ស ៥ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ សម្តែងធម៌ដល់ភិក្ខុទាំងឡាយ ជាធម៌ពីរោះបទដើម ពីរោះបទកណ្តាល ពីរោះបទចុង ប្រកបដោយអត្ថ ប្រកបដោយព្យញ្ជនៈ ប្រកាស នូវព្រហ្មចរិយធម៌ដ៏បរិសុទ្ធ បរិបូណ៌ទាំងអស់

២១

បណ្ណាសកេ សម្មោធវគ្គោ

យថា យថាវុសោ ភិក្ខុ ភិក្ខូនំ ធម្មំ ទេសេតិ អាទិកល្យាណំ មជ្ឈេកល្យាណំ បរិយោសានកល្យាណំ សាត្ថំ សព្យញ្ជនំ កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ បកាសេតិ តថា តថា តស្ស តស្ស សត្ថុ បិយោ ហោតិ មនាបោ ច គរុ ច ភាវនីយោ ។ អយំ អាវុសោ បឋមោ អានិសំសោ កាលេន ធម្មស្សវនេ កាលេន ធម្មសាកច្ឆាយ ។ បុន ច បរំ អាវុសោ ភិក្ខុ ភិក្ខូនំ ធម្មំ ទេសេតិ អាទិកល្យាណំ មជ្ឈេកល្យាណំ បរិយោសានកល្យាណំ សាត្ថំ សព្យញ្ជនំ កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ បកាសេតិ យថា យថាវុសោ ភិក្ខុ ភិក្ខូនំ ធម្មំ ទេសេតិ អាទិកល្យាណំ ។ បេ ។ ព្រហ្មចរិយំ បកាសេតិ តថា តថា សោ តស្មឹ ធម្មេ អត្ថប្បដិសំវេទី ច ហោតិ ធម្មប្បដិសំវេទី ច ។ អយំ អាវុសោ ទុតិយោ អានិសំសោ កាលេន ធម្មស្សវនេ កាលេន ធម្មសាកច្ឆាយ ។

ម្នាលអាវុសោទាំងឡាយ ភិក្ខុសម្ដែងធម៌ដល់ភិក្ខុទាំងឡាយ ជាធម៌ពីពោះបទដើម ពីពោះបទកណ្ដាល ពីពោះបទចុង ប្រកបដោយអត្ថ ប្រកបដោយព្យញ្ជនៈ ប្រកាសនូវព្រហ្មចរិយធម៌ដ៏បរិសុទ្ធ បរិបូណ៌ទាំងអស់ ដោយប្រការណាៗ ភិក្ខុនោះ ជាទីស្រឡាញ់ផង ជាទីគាប់ចិត្តផង ជាទីគោរពផង ជាទីសរសើរផង របស់គ្រូនោះៗដោយប្រការដូច្នោះៗ ។ ម្នាលអាវុសោទាំងឡាយ នេះជាអានិសង្សទី ១ ក្នុងការស្ដាប់ធម៌តាមកាលគួរ ក្នុងការសាកច្ឆាធម៌តាមកាលគួរ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុសម្ដែងធម៌ដល់ភិក្ខុទាំងឡាយ ជាធម៌ពីពោះបទដើម ពីពោះបទកណ្ដាល ពីពោះបទចុង ប្រកបដោយអត្ថ ប្រកបដោយព្យញ្ជនៈ ប្រកាសនូវព្រហ្មចរិយធម៌ ដ៏បរិសុទ្ធ បរិបូណ៌ទាំងអស់ ម្នាលអាវុសោទាំងឡាយ ភិក្ខុសម្ដែងធម៌ដល់ភិក្ខុទាំងឡាយ ជាធម៌ពីពោះបទដើម ។ បេ ។ ប្រកាសនូវព្រហ្មចរិយធម៌ដោយប្រការណាៗ ភិក្ខុនោះ ជាអ្នកដឹងច្បាស់នូវអត្ថផង ដឹងច្បាស់នូវធម៌ផង ក្នុងធម៌នោះដោយប្រការដូច្នោះៗ ។ ម្នាលអាវុសោទាំងឡាយ នេះជាអានិសង្សទី ២ ក្នុងការស្ដាប់ធម៌តាមកាលគួរ ក្នុងការសាកច្ឆាធម៌តាមកាលគួរ ។

បុន ច បរំ អាវុសោ ភិក្ខុ ភិក្ខូនំ ធម្មំ ទេសេតិ អាទិកល្យាណំ មជ្ឈេកល្យាណំ បរិយោសានកល្យាណំ សាត្ថំ សព្យញ្ជនំ កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ បកាសេតិ យថា យថាវុសោ ភិក្ខុ ភិក្ខូនំ ធម្មំ ទេសេតិ អាទិកល្យាណំ ។ បេ ។ ព្រហ្មចរិយំ បកាសេតិ តថា តថា សោ តស្មឹ ធម្មេ គម្ភីរំ អត្ថបទំ បញ្ញាយ បដិវិជ្ឈំ បស្សតិ ។ អយំ អាវុសោ តតិយោ អានិសំសោ កាលេន ធម្មស្សវនេ កាលេន ធម្មសាកច្ឆាយ ។ បុន ច បរំ អាវុសោ ភិក្ខុ ភិក្ខូនំ ធម្មំ ទេសេតិ អាទិកល្យាណំ ។ បេ ។ ព្រហ្មចរិយំ បកាសេតិ តថា តថា នំ សព្រហ្មចារី ឧត្តរឹ សម្ភាវេន្តិ អទ្ធា អយមាយស្មា បត្តោ វា គច្ឆតិ វាតិ ។ អយំ អាវុសោ ចតុត្ថោ អានិសំសោ កាលេន ធម្មស្សវនេ កាលេន ធម្មសាកច្ឆាយ ។ បុន ច បរំ អាវុសោ ភិក្ខុ ភិក្ខូនំ ធម្មំ ទេសេតិ

ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុសម្តែងធម៌ដល់ភិក្ខុទាំងឡាយ ជាធម៌ពីរោះបទដើម ពីរោះបទកណ្តាល ពីរោះបទចុង ប្រកបដោយអត្ថ ប្រកបដោយព្យញ្ជនៈ ប្រកាសនូវព្រហ្មចរិយធម៌ដ៏បរិសុទ្ធ បរិបូណ៌ទាំងអស់ ម្នាលអាវុសោទាំងឡាយ ភិក្ខុសម្តែងធម៌ដល់ភិក្ខុទាំងឡាយ ជាធម៌ពីរោះបទដើម ។ បេ ។ ប្រកាសនូវព្រហ្មចរិយធម៌ ដោយប្រការណាៗ ភិក្ខុនោះ រមែងឃើញច្បាស់នូវអត្ថនិងបទដ៏ជ្រាលជ្រៅក្នុងធម៌នោះ ដែលខ្លួនចាក់ធ្លុះ ដោយបញ្ញាដោយប្រការដូច្នោះៗ ។ ម្នាលអាវុសោទាំងឡាយ នេះជាអានិសង្សទី ៣ ក្នុងការស្តាប់ធម៌តាមកាលគួរ ក្នុងការសាកច្ឆាធម៌តាមកាលគួរ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុសម្តែងធម៌ដល់ភិក្ខុទាំងឡាយ ជាធម៌ពីរោះបទដើម ។ បេ ។ ប្រកាសនូវព្រហ្មចរិយធម៌ សព្រហ្មចារីបុគ្គលទាំងឡាយ តែងសរសើរនូវភិក្ខុនោះតទៅ ដោយប្រការដូច្នោះៗថា ភិក្ខុដ៏មានអាយុនេះ ដល់ហើយ ឬនឹងដល់ (នូវព្រះអរហត្តមិនខាន) ។ ម្នាលអាវុសោទាំងឡាយ នេះជាអានិសង្សទី ៤ ក្នុងការស្តាប់ធម៌តាមកាលគួរ ក្នុងការសាកច្ឆាធម៌តាមកាលគួរ ។ ម្នាលអាវុសោទាំងឡាយ មួយវិញទៀត ភិក្ខុសម្តែងធម៌ដល់ភិក្ខុទាំងឡាយ

បណ្ណាសកេ សម្មោធវគ្គោ

អាទិកល្យាណំ មជ្ឈេកល្យាណំ បរិយោសានកល្យាណំ សាត្ថំ សព្យញ្ជនំ កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ បកាសេតិ យថា យថាវុសោ ភិក្ខុ ភិក្ខូនំ ធម្មំ ទេសេតិ អាទិកល្យាណំ មជ្ឈេកល្យាណំ បរិយោសានកល្យាណំ សាត្ថំ សព្យញ្ជនំ កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ បកាសេតិ តត្ថ យេ តេ ភិក្ខូ សេក្ខា អប្បត្តមានសា អនុត្តរំ យោគក្ខេមំ បត្ថយមានា វិហរន្តិ តេ តំ ធម្មំ សុត្វា វីរិយំ អារភន្តំ អប្បត្តស្ស បត្តិយា អនធិគតស្ស អធិគមាយ អសច្ឆិកតស្ស សច្ឆិកិរិយាយ យេ បន តត្ថ ភិក្ខូ អរហន្តោ ខីណាសវា វុសិតវន្តោ កតករណីយា ឱហិតភារា អនុប្បត្តសទត្ថា បរិក្ខីណភវសញ្ញោជនា សម្មទញ្ញា វិមុត្តា តេ តំ ធម្មំ សុត្វា ទិដ្ឋធម្មសុខវិហារំ យេវ អនុយុត្តា វិហរន្តិ ។

ជាធម៌ពីរោះបទដើម ពីរោះបទកណ្ដាល ពីរោះបទចុង ប្រកបដោយអត្ថ ប្រកបដោយព្យញ្ជនៈ ប្រកាសនូវព្រហ្មចរិយធម៌ ដ៏បរិសុទ្ធបរិបូណ៌ទាំងអស់ ម្នាលអាវុសោទាំងឡាយ ភិក្ខុសម្ដែងធម៌ដល់ភិក្ខុទាំងឡាយ ជាធម៌ពីរោះបទដើម ពីរោះបទកណ្ដាល ពីរោះបទចុង ប្រកបដោយអត្ថ ប្រកបដោយព្យញ្ជនៈ ប្រកាសនូវព្រហ្មចរិយធម៌ ដ៏បរិសុទ្ធ បរិបូណ៌ទាំងអស់ ដោយប្រការណាៗ បណ្ដាភិក្ខុទាំងនោះ ពួកភិក្ខុណាជាសេក្ខៈ មានសេចក្ដីប្រាថ្នាក្នុងចិត្តគឺអរហត្តមិនទាន់សម្រេច ប្រាថ្នានូវធម៌ក្សេមចាកយោគៈដ៏ប្រសើរ ពួកភិក្ខុទាំងនោះ បានស្ដាប់ធម៌នោះហើយ ក៏រមែងប្រារព្ធសេចក្ដីព្យាយាម ដើម្បីដល់នូវធម៌ដែលខ្លួនមិនទាន់ដល់ ដើម្បីត្រាស់ដឹងនូវធម៌ ដែលខ្លួនមិនទាន់ត្រាស់ដឹង ដើម្បីធ្វើឲ្យជាក់ច្បាស់នូវធម៌ដែលខ្លួនមិនទាន់ធ្វើឲ្យជាក់ច្បាស់ មួយទៀត បណ្ដាភិក្ខុទាំងនោះ ពួកភិក្ខុណា ជាអរហន្តខីណាស្រព ប្រព្រឹត្តព្រហ្មចរិយធម៌ចប់ហើយ មានសោឡសកិច្ចធ្វើស្រេចហើយ មានភារៈដាក់ចុះហើយ បានសម្រេចប្រយោជន៍របស់ខ្លួន ដោយលំដាប់ហើយ មានធម៌ជាគ្រឿងប្រកបសត្វក្នុងភពអស់ហើយ មានចិត្តផុតស្រឡះហើយ ព្រោះដឹងដោយប្រពៃ ភិក្ខុទាំងនោះ បានស្ដាប់ធម៌នោះហើយ រមែងប្រកបរឿយៗ នូវធម៌ជាគ្រឿងនៅជាសុខក្នុងបច្ចុប្បន្ន ។

អយំ អាវុសោ បញ្ចមោ អានិសំសោ កាលេន ធម្មស្សវនេ កាលេន ធម្មសាកច្ឆាយ ។ ឥមេ ខោ អាវុសោ បញ្ច អានិសំសា កាលេន ធម្មស្សវនេ កាលេន ធម្មសាកច្ឆាយាតិ ។

[៥] ចត្តារិមានិ ភិក្ខវេ ពលានិ ។ កតមានិ ចត្តារិ ។ បញ្ញាពលំ វិរិយពលំ អនវជ្ជពលំ សង្គហ-ពលំ ។ កតមញ្ច ភិក្ខវេ បញ្ញាពលំ ។ យេ ធម្មា កុសលា កុសលសង្ខាតា យេ ធម្មា អកុសលា អកុសលសង្ខាតា យេ ធម្មា សាវជ្ជា សាវជ្ជសង្ខាតា យេ ធម្មា អនវជ្ជា អនវជ្ជសង្ខាតា យេ ធម្មា កណ្ហា កណ្ហសង្ខាតា យេ ធម្មា សុក្កា សុក្កសង្ខាតា យេ ធម្មា អសេវិតព្វា អសេវិតព្វសង្ខាតា យេ ធម្មា សេវិតព្វា សេវិតព្វសង្ខាតា យេ ធម្មា នាល-មរិយា នាលមរិយសង្ខាតា យេ ធម្មា អលមរិយា អលមរិយសង្ខាតា ត្យស្សុ ធម្មា បញ្ញាយ វោទិដ្ឋា ហោន្តិ វោចរិតា ឥទំ វុច្ចតិ ភិក្ខវេ បញ្ញាពលំ ។

ម្នាលអាវុសោទាំងឡាយ នេះជាអានិសង្សទី ៤ ក្នុងការស្តាប់ធម៌តាមកាលគួរ ក្នុងការសាកច្ឆាធម៌តាមកាលគួរ ។ ម្នាលអាវុសោទាំងឡាយ នេះជាអានិសង្ស ៤ ប្រការ ក្នុងការស្តាប់ធម៌តាមកាលគួរ ក្នុងការសាកច្ឆាធម៌តាមកាលគួរ ។

[៥] ម្នាលភិក្ខុទាំងឡាយ ពលៈនេះមាន ៤ យ៉ាង ។ ពលៈ ៤ យ៉ាង តើដូចម្តេច ។ គឺ បញ្ញាពលៈ ១ វិរិយពលៈ ១ អនវជ្ជពលៈ ១ សង្គហពលៈ ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះបញ្ញាពលៈ តើដូចម្តេច ។ ធម៌ទាំងឡាយណា ជាកុសល រាប់ថាជាកុសល ធម៌ទាំងឡាយណា ជាអកុសល រាប់ថាអកុសល ធម៌ទាំងឡាយណា មានទោស រាប់ថាមានទោស ធម៌ទាំងឡាយណា មិនមានទោស រាប់ថាមិនមានទោស ធម៌ទាំងឡាយណា ជាធម៌ខ្មៅ រាប់ថាជាធម៌ខ្មៅ ធម៌ទាំងឡាយណា ជាធម៌ស រាប់ថាជាធម៌ស ធម៌ទាំងឡាយណាមិនគួរសេព រាប់ថាជាធម៌មិនគួរសេព ធម៌ទាំងឡាយណាគួរសេព រាប់ថាជាធម៌គួរសេព ធម៌ទាំងឡាយណា មិនគួរដល់ព្រះអរិយៈ រាប់ថាជាធម៌មិនគួរដល់ព្រះអរិយៈ ធម៌ទាំងឡាយណាគួរដល់ព្រះអរិយៈ រាប់ថាជាធម៌គួរដល់ព្រះអរិយៈ ធម៌ទាំងនោះ បុគ្គលឃើញច្បាស់ ស្ទង់ចុះដោយបញ្ញាតាមពិត ម្នាលភិក្ខុទាំងឡាយ នេះហៅថា បញ្ញាពលៈ ។

កតមញ្ច ភិក្ខវេ វីរិយពលំ ។ យេ ធម្មា អកុសលា អកុសលសង្ខាតា យេ ធម្មា សាវជ្ជា សាវជ្ជសង្ខាតា យេ ធម្មា កណ្ហា កណ្ហសង្ខាតា យេ ធម្មា អសេវិតព្វា អសេវិតព្វសង្ខាតា យេ ធម្មា នាលមរិយា នាលមរិយសង្ខាតា តេសំ ធម្មានំ បហានាយ ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ។ យេ ធម្មា កុសលា កុសលសង្ខាតា យេ ធម្មា អនវជ្ជា អនវជ្ជសង្ខាតា យេ ធម្មា សុក្កា សុក្កសង្ខាតា យេ ធម្មា សេវិតព្វា សេវិតព្វសង្ខាតា យេ ធម្មា អលមរិយា អលមរិយសង្ខាតា តេសំ ធម្មានំ បដិលាភាយ ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ឥទំ វុច្ចតិ ភិក្ខវេ វីរិយពលំ ។ កតមញ្ច ភិក្ខវេ អនវជ្ជពលំ ។ ឥធ ភិក្ខវេ អរិយស្សាវកោ អនវជ្ជេន កាយកម្មេន សមន្នាគតោ ហោតិ អនវជ្ជេន វចីកម្មេន សមន្នាគតោ ហោតិ

បណ្ណាសក សម្ពោធវគ្គ

ម្នាលភិក្ខុទាំងឡាយ ចុះវីរិយពលៈ តើដូចម្តេច ។ ធម៌ទាំងឡាយណា ជាអកុសល រាប់ថាជាអកុសល ធម៌ទាំងឡាយណា មានទោស រាប់ថាជាធម៌ មានទោស ធម៌ទាំងឡាយណា ជាធម៌ខ្មៅ រាប់ថាជាធម៌ខ្មៅ ធម៌ទាំងឡាយណា មិនគួរសេព រាប់ថាជាធម៌ មិនគួរសេព ធម៌ទាំងឡាយណា មិនគួរដល់ព្រះអរិយៈ រាប់ថាជាធម៌ មិនគួរដល់ព្រះអរិយៈ បុគ្គលក៏បានញុំាំងឆន្ទៈឲ្យកើត ប្រឹងប្រែងប្រារព្ធព្យាយាម ផ្គងចិត្ត តម្កល់ចិត្ត ដើម្បីលះបង់នូវធម៌ទាំងនោះ ។ ធម៌ទាំងឡាយណា ជាកុសល រាប់ថាជាកុសល ធម៌ទាំងឡាយណា មិនមានទោស រាប់ថាជាធម៌ មិនមានទោស ធម៌ទាំងឡាយណា ជាធម៌ស រាប់ថា ជាធម៌ស ធម៌ទាំងឡាយណា គួរសេព រាប់ថាជាធម៌ គួរសេព ធម៌ទាំងឡាយណា គួរដល់ព្រះអរិយៈ រាប់ថាជាធម៌គួរដល់ព្រះអរិយៈ បុគ្គលក៏បានញុំាំងឆន្ទៈឲ្យកើត ប្រឹងប្រែងប្រារព្ធព្យាយាម ផ្គងចិត្ត តម្កល់ចិត្ត ដើម្បីឲ្យបាននូវធម៌ទាំងនោះ ម្នាលភិក្ខុទាំងឡាយ នេះហៅថា វីរិយពលៈ ។ ម្នាលភិក្ខុទាំងឡាយ ចុះអនវជ្ជពលៈ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវ័កក្នុងសាសនានេះ ជាអ្នកប្រកបដោយកាយកម្មមិនមានទោស ប្រកបដោយវចីកម្មមិនមានទោស

អនវជ្ជេន មនោកម្មេន សមន្នាគតោ ហោតិ ឥទំ វុច្ចតិ ភិក្ខវេ អនវជ្ជពលំ ។ កតមញ្ច ភិក្ខវេ សង្គហពលំ ។ ចត្តារិមានិ ភិក្ខវេ សង្គហវត្ថូនិ ទានំ បេយ្យវជ្ជំ អត្ថចរិយា សមានត្តតា ឯតទគ្គំ ភិក្ខវេ ទានានំ យទិទំ ធម្មទានំ ឯតទគ្គំ ភិក្ខវេ បេយ្យវជ្ជានំ យទិទំ អត្ថិកស្ស ឱហិតសោតស្ស បុនប្បុនំ ធម្មំ ទេសេតិ ឯតទគ្គំ ភិក្ខវេ អត្ថចរិយានំ យទិទំ អស្សទ្ធំ សទ្ធាសម្បទាយ សមាទបេតិ និវេសេតិ បតិដ្ឋាបេតិ ទុស្សីលំ សីលសម្បទាយ មច្ឆរឹ ចាគសម្បទាយ ទុប្បញ្ញំ បញ្ញាសម្បទាយ សមាទបេតិ និវេសេតិ បតិដ្ឋាបេតិ ឯតទគ្គំ ភិក្ខវេ សមានត្តតានំ យទិទំ សោតាបន្នេន[១] សោតាបន្នស្ស សមានត្តោ

១ ឱ. ម. សោតាបន្នោ ។

ប្រកបដោយមនោកម្មមិនមានទោស ម្នាលភិក្ខុទាំងឡាយ នេះហៅថា អនវជ្ជពលៈ ។ ម្នាលភិក្ខុទាំងឡាយ ចុះសង្គហពលៈ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ សង្គហវត្ថុនេះមាន ៤ យ៉ាង គឺការឲ្យទាន ១ ការពោលពាក្យជាទីស្រឡាញ់ ១ ការប្រព្រឹត្តអំពើឲ្យជាប្រយោជន៍ ១ ភាពជាអ្នកតាំងខ្លួនស្មើ ១ ម្នាលភិក្ខុទាំងឡាយ បណ្តាទានទាំងឡាយ ទានដែលប្រសើរបំផុតនុ៎ះ គឺធម្មទាន ម្នាលភិក្ខុទាំងឡាយ បណ្តាការពោលពាក្យជាទីស្រឡាញ់ទាំងឡាយ ការពោលពាក្យជាទីស្រឡាញ់ដ៏ប្រសើរបំផុតនុ៎ះ គឺធម្មកថិក សម្តែងធម៌រឿយៗ ដល់អ្នកត្រូវការស្តាប់ អ្នកផ្ទៀងត្រចៀកស្តាប់ ម្នាលភិក្ខុទាំងឡាយ បណ្តាការប្រព្រឹត្តអំពើឲ្យជាប្រយោជន៍ទាំងឡាយ ការប្រព្រឹត្តអំពើឲ្យជាប្រយោជន៍ដ៏ប្រសើរនុ៎ះ គឺបុគ្គលអ្នកញុំាងជនមិនមានសទ្ធា ឲ្យកាន់យក ឲ្យតាំងនៅ ឲ្យតម្កល់ស៊ប់ក្នុងសទ្ធាសម្បទា ញុំាងជនទ្រុស្តសីល ឲ្យកាន់យក ឲ្យតាំងនៅ ឲ្យតម្កល់ស៊ប់ក្នុងសីលសម្បទា ញុំាងជនអ្នកមានសេចក្តីកំណាញ់ឲ្យកាន់យក ឲ្យតាំងនៅ ឲ្យតម្កល់ស៊ប់ក្នុងចាគសម្បទា ញុំាងជនអ្នកមិនមានបញ្ញាឲ្យកាន់យក ឲ្យតាំងនៅ ឲ្យតម្កល់ស៊ប់ ក្នុងបញ្ញាសម្បទា ម្នាលភិក្ខុទាំងឡាយ បណ្តាភាពជាអ្នកតាំងខ្លួនស្មើទាំងឡាយ ភាពជាអ្នកតាំងខ្លួនស្មើដ៏ប្រសើរនុ៎ះ គឺសោតាបន្នបុគ្គល មានខ្លួនស្មើនឹងសោតាបន្នបុគ្គល

## ២៧



សកាមាមិជា[១] សកាមាមិស្ស សមានត្តោ អជាមាមិជា[២] អជាមាមិស្ស សមានត្តោ អរហតា អរហតោ សមានត្តោ ឥទំ វុច្ចតិ ភិក្ខវេ សង្គហពលំ ។ ឥមានិ ខោ ភិក្ខវេ ចត្តារិ ពលានិ ។ ឥមេហិ ខោ ភិក្ខវេ ចតូហិ ពលេហិ សមន្នាគតោ អរិយសាវកោ បញ្ច ភយានិ សមតិក្កន្តោ ហោតិ ។ កតមានិ បញ្ច ។ អាជីវិតភយំ អសិលោកភយំ បរិសំ សារជ្ជភយំ មរណភយំ ទុគ្គតិភយំ ។ សោ ខោ ភិក្ខវេ អរិយសាវកោ ឥតិ បដិសញ្ចិក្ខតិ ជាហំ អាជីវិតភយស្ស ភាយាមិ កិស្សាហំ អាជីវិតភយស្ស ភាយិស្សាមិ អត្ថិ មេ ចត្តារិ ពលានិ បញ្ញាពលំ វីរិយពលំ អនវជ្ជពលំ សង្គហពលំ ។ ទុប្បញ្ញោ ខោ អាជីវិតភយស្ស ភាយេយ្យ កុសីតោ អាជីវិតភយស្ស ភាយេយ្យ សាវជ្ជកាយកម្មន្តវចីកម្មន្តមនោកម្មន្តជីវិតភយស្ស ភាយេយ្យ អសង្គហកោ អាជីវិតភយស្ស ភាយេយ្យ

---

១ ឱ. ម. សកទាគាមី ។ ២ ឱ. ម. អនាគាមី ។

សកទាគាមិបុគ្គល មានខ្លួនស្មើនឹងសកទាគាមិបុគ្គល អនាគាមិបុគ្គល មានខ្លួនស្មើនឹងអនាគាមិបុគ្គល អរហន្ត មានខ្លួនស្មើនឹងអរហន្ត ម្នាលភិក្ខុទាំងឡាយ នេះហៅថា សង្គហពលៈ ។ ម្នាលភិក្ខុទាំងឡាយ ពលៈមាន ៤ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវ័ក ប្រកប ដោយពលៈ ៤ យ៉ាងនេះហើយ រមែងជាអ្នកឆ្លងផុតភ័យ ៥ យ៉ាង ។ ភ័យ ៥ យ៉ាង តើដូចម្ដេច ។ គឺអាជីវិតភយៈ (ភ័យអំពីការចិញ្ចឹមជីវិត) ១ អសិលោកភយៈ (ភ័យអំពីការមិនសរសើរ) ១ បរិសំសារជ្ជភយៈ (ភ័យអំពីការកោតញញើតក្នុងបរិសទ្យ) ១ មរណភយៈ (ភ័យអំពីសេចក្ដីស្លាប់) ១ ទុគ្គតិភយៈ (ភ័យអំពីទុគ្គតិ) ១ ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវ័កនោះ ពិចារណាដូច្នេះថា អាត្មាអញមិនខ្លាច ចំពោះអាជីវិត-ភ័យ អាត្មាអញនឹងខ្លាចអាជីវិតភ័យដូចម្ដេច បើពលៈទាំង ៤ គឺបញ្ញាពលៈ វិរិយពលៈ អនវជ្ជពលៈ សង្គហពលៈ របស់អាត្មាអញ មានស្រេចហើយ ។ ឯបុគ្គលគ្មានប្រាជ្ញា គប្បីខ្លាចអាជីវិតភ័យ បុគ្គលខ្ជិល គប្បីខ្លាចអាជីវិតភ័យ គប្បីខ្លាចអាជីវិតភ័យដោយកាយកម្ម វចីកម្ម មនោកម្ម ដែលមានទោស បុគ្គលជាអ្នកមិនសង្គ្រោះ គប្បីខ្លាច អាជីវិតភ័យ

ជាហំ អសិលោកភយស្ស ភាយាមិ ។ បេ ។ ជាហំ បរិសំ សារជ្ជភយស្ស ភាយាមិ ជាហំ មរណភយស្ស ភាយាមិ ជាហំ ទុគ្គតិភយស្ស ភាយាមិ កិស្សាហំ ទុគ្គតិភយស្ស ភាយិស្សាមិ អត្ថិ មេ ចត្តារិ ពលានិ បញ្ញាពលំ វីរិយពលំ អនវជ្ជពលំ សង្គហពលំ ។ ទុប្បញ្ញោ ខោ ទុគ្គតិភយស្ស ភាយេយ្យ កុសីតោ ទុគ្គតិភយស្ស ភាយេយ្យ សាវជ្ជកាយកម្មន្តវចីកម្មន្តមនោកម្មន្តទុគ្គតិភយស្ស ភាយេយ្យ អសង្គាហកោ ទុគ្គតិភយស្ស ភាយេយ្យ ។ ឥមេហិ ខោ ភិក្ខវេ ចតូហិ ពលេហិ សមន្នាគតោ អរិយសាវកោ ឥមានិ បញ្ច ភយានិ សមតិក្កន្តោ ហោតីតិ ។

[៦] តត្រ ខោ អាយស្មា សារីបុត្តោ ភិក្ខូ អាមន្តេសិ ។ បេ ។ អាយស្មា សារីបុត្តោ ឯតទវោច បុគ្គលោបិ អាវុសោ ទុវិធេន វេទិតព្វោ សេវិតព្វោបិ អសេវិតព្វោបិ ចីវរម្បិ អាវុសោ ទុវិធេន វេទិតព្វំ សេវិតព្វម្បិ អសេវិតព្វម្បិ បិណ្ឌបាតោបិ អាវុសោ ទុវិធេន វេទិតព្វោ សេវិតព្វោបិ អសេវិតព្វោបិ

អាត្មាអញ មិនខ្លាចអសិលោកភ័យទេ ។ បេ ។ អាត្មាអញមិនខ្លាចបរិសំសារជ្ជភ័យទេ អាត្មាអញ មិនខ្លាចមរណភ័យទេ អាត្មាអញមិនខ្លាចទុគ្គតិភ័យទេ អាត្មាអញនឹងខ្លាចទុគ្គតិភ័យដូចម្តេច បើ ពលៈទាំង ៤ គឺ បញ្ញាពលៈ វិរិយពលៈ អនវជ្ជពលៈ សង្គហពលៈរបស់អាត្មាអញ មានស្រេចហើយ ។ ឯបុគ្គលគ្មានប្រាជ្ញា គប្បីខ្លាចទុគ្គតិភ័យ បុគ្គលខ្ជិល គប្បីខ្លាចទុគ្គតិភ័យ គប្បីខ្លាចទុគ្គតិភ័យដោយកាយកម្ម វចីកម្ម មនោកម្ម ដែលមានទោស បុគ្គលមិនមានសេចក្តីសង្គ្រោះ គប្បីខ្លាចទុគ្គតិភ័យ ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវក ប្រកបដោយពលៈ ៤ យ៉ាងនេះឯង ជាអ្នកកន្លងផុតនូវភ័យទាំង ៥ នេះបាន ។

[៦] ក្នុងទីនោះឯង ព្រះសារីបុត្តដ៏មានអាយុ ហៅភិក្ខុទាំងឡាយថា ។ បេ ។ ព្រះសារីបុត្តដ៏មានអាយុ បានពោលដូច្នេះថា ម្នាលអាវុសោទាំងឡាយ អ្នកទាំងឡាយ គប្បីស្គាល់បុគ្គលពីរពួក គឺបុគ្គលគួរសេពគប់ ១ បុគ្គលមិនគួរសេពគប់ ១ ម្នាលអាវុសោទាំង-ឡាយ អ្នកទាំងឡាយ គប្បីស្គាល់ចីវរពីរយ៉ាង គឺចីវរគួរប្រើប្រាស់ ១ មិនគួរប្រើប្រាស់ ១ ម្នាលអាវុសោទាំងឡាយ អ្នកទាំងឡាយ គប្បីស្គាល់ បិណ្ឌបាត ២ យ៉ាង គឺបិណ្ឌបាតគួរសេព ១ មិនគួរសេព ១

២៩



សេនាសនម្បិ អាវុសោ ទុវិធេន វេទិតព្វំ សេវិតព្វម្បិ អសេវិតព្វម្បិ គាមនិគមោបិ អាវុសោ ទុវិធេន វេទិតព្វោ សេវិតព្វោបិ អសេវិតព្វោបិ ជនបទប្បទេសោបិ អាវុសោ ទុវិធេន វេទិតព្វោ សេវិតព្វោបិ អសេវិតព្វោបិ ។ បុគ្គលោបិ អាវុសោ ទុវិធេន វេទិតព្វោ សេវិតព្វោបិ អសេវិតព្វោបីតិ ឥតិ ខោ បនេតំ វុត្តំ កិញ្ចេតំ បដិច្ច វុត្តំ ។ តត្ថ យំ ជញ្ញា បុគ្គលំ ឥមំ ខោ មេ បុគ្គលំ សេវតោ អកុសលា ធម្មា អភិវឌ្ឍន្តិ កុសលា ធម្មា បរិហាយន្តិ យេ ច ខោ មេ បព្វជិតេន ជីវិតបរិក្ខារា សមុទានេតព្វា ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារា តេ ច កសិរេន សមុទាហរន្តិ[១] យស្ស ចម្ហិ អត្ថាយ អគារស្មា អនគារិយំ បព្វជិតោ

១ ឱ. ម. សមុទាគច្ឆន្តិ ។

បណ្ណាសក សម្ពោធវគ្គ

ម្នាលអាវុសោទាំងឡាយ អ្នកទាំងឡាយ គប្បីស្គាល់សេនាសនៈពីរយ៉ាង គឺសេនាសនៈគួរសេព ១ មិនគួរសេព ១ ម្នាលអាវុសោទាំងឡាយ អ្នកទាំងឡាយ គប្បីស្គាល់ស្រុកនិងនិគមពីរយ៉ាង គឺស្រុកនិងនិគម គួរសេព ១ មិនគួរសេព ១ ម្នាលអាវុសោទាំងឡាយ អ្នកទាំងឡាយ គប្បីស្គាល់ជនបទនិងប្រទេសពីរយ៉ាងគឺជនបទនិងប្រទេសដែលគួរសេព ១ មិនគួរសេព ១ ។ ក៏ពាក្យថា ម្នាលអាវុសោទាំងឡាយ អ្នកទាំងឡាយ គប្បីស្គាល់បុគ្គលពីរពួក គឺបុគ្គលគួរសេព ១ មិនគួរសេព ១ ដូច្នេះនេះ ដែលខ្ញុំពោលហើយ ពាក្យដែលខ្ញុំពោលហើយនុ៎ះ តើព្រោះអាស្រ័យហេតុដូចម្តេច ។ បណ្តាបុគ្គលទាំងពីរពួកនោះ បើបុគ្គលស្គាល់បុគ្គលណាថា កាលបើអាត្មាអញសេពគប់បុគ្គលនេះ អកុសលធម៌ទាំងឡាយ តែងចម្រើនឡើង កុសលធម៌ទាំងឡាយ តែងវិនាសទៅ មួយទៀត គ្រឿងបម្រុងជីវិតទាំងឡាយណា គឺចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជ-បរិក្ខារ ដែលអាត្មាអញ ជាបព្វជិតត្រូវប្រមូលមក ក៏គ្រឿងបម្រុងជីវិតទាំងនោះ តែងមូលមកបានដោយក្រ មួយទៀត អាត្មាអញចេញចាកផ្ទះចូលទៅកាន់ផ្នួស ដើម្បីប្រយោជន៍ដល់ប្រយោជន៍នៃសមណៈណា

សោ ច មេ សាមញ្ញត្ថោ ន ភាវនាបារិបូរឹ គច្ឆតីតិ តេនាវុសោ បុគ្គលេន សោ បុគ្គលោ សង្ខាបិ(១) រត្តិភាគំ វា ទិវសភាគំ វា អនាបុច្ឆា វា បក្កមិតព្វោ នានុពន្ធិតព្វោ ។ តត្ថ យំ ជញ្ញា បុគ្គលំ ឥមំ ខោ មេ បុគ្គលំ សេវតោ អកុសលា ធម្មា បរិហាយន្តិ កុសលា ធម្មា អភិវឌ្ឍន្តិ យេ ច ខោ មេ បព្វជិតេន ជីវិតបរិក្ខារា សមុទានេតព្វា ចីវរបិណ្ឌបាតសេនា-សនគិលានប្បច្ចយភេសជ្ជបរិក្ខារា តេ ច អប្បក-សិរេន សមុទាហរន្តិ យស្ស ចម្ហិ អត្ថាយ អគារស្មា អនគារិយំ បព្វជិតោ សោ ច មេ សាមញ្ញត្ថោ ភាវនា-បារិបូរឹ គច្ឆតីតិ តេនាវុសោ បុគ្គលេន សោ បុគ្គលោ សង្ខាបិ យាវជីវំ(២) អនុពន្ធិតព្វោ ន បក្កមិតព្វោ ។

---

១ ឱ. សង្ខាបីតិ អយំ បាឋោ នត្ថិ ។ ២ ឱ. ម. យាវជីវន្តិ បាឋោ នត្ថិ ។

ប្រយោជន៍នៃសមណៈនោះ មិនដល់នូវការបរិបូណ៌ដោយភាវនា ដល់អាត្មាអញដូច្នេះ ម្នាលអាវុសោទាំងឡាយ បុគ្គលអ្នកសេពគប់នោះ លុះដឹងក្នុងចំណែកពាត្រីក្តី ក្នុងចំណែកថ្ងៃក្តី មិនគប្បីលាហើយចៀសចេញទៅ ឬក៏មិនគប្បីជាប់តាមបុគ្គលមិនគួរសេពគប់នោះឡើយ ។ បណ្តាបុគ្គលទាំងពីរពួកនោះ បុគ្គលស្គាល់បុគ្គលណាថា កាលបើអាត្មាអញសេពគប់បុគ្គលនោះ អកុសលធម៌ទាំងឡាយ តែងវិនាសទៅ កុសលធម៌ទាំងឡាយ តែងចម្រើនឡើង មួយទៀត គ្រឿងបម្រុងជីវិតទាំងឡាយណា គឺចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជ-បរិក្ខារ ដែលអាត្មាអញ ជាបព្វជិតត្រូវប្រមូលមក ក៏គ្រឿងបម្រុងជីវិតទាំងនោះតែងមូលមកបានដោយងាយ មួយទៀត អាត្មាអញចេញចាកផ្ទះចូលទៅកាន់ផ្នួស ដើម្បីប្រយោជន៍ដល់ប្រយោជន៍នៃសមណៈណា ប្រយោជន៍នៃសមណៈនោះ ដល់នូវការបរិបូណ៌ដោយភាវនា ដល់អាត្មាអញ ដូច្នេះ ម្នាលអាវុសោទាំងឡាយ បុគ្គលនោះ បើស្គាល់ហើយ គប្បីជាប់តាមបុគ្គលនោះ មិនគប្បីចៀសចេញទៅដរាបដល់អស់ជីវិតឡើយ ។

តត្ថ យំ ជញ្ញា បុគ្គលំ ឥមំ ខោ មេ បុគ្គលំ សេវតោ អកុសលា ធម្មា បរិហាយន្តិ កុសលា ធម្មា អភិវឌ្ឍន្តិ យេ ច ខោ មេ បព្វជិតេន ជីវិត-បរិក្ខារា សមុទានេតព្វា ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារា តេ ច អប្បកសិរេន សមុទាហរន្តិ យស្ស ចម្ហិ អត្ថាយ អគារស្មា អនគារិយំ បព្វជិតោ សោ ច មេ សាមញ្ញត្ថោ ភាវនាបារិបូរឹ គច្ឆតីតិ តេនាវុសោ បុគ្គលេន សោ បុគ្គលោ យាវជីវំ[១] អនុពន្ធិតព្វោ ន បក្កមិ-តព្វោ ។ តត្ថ យំ ជញ្ញា បុគ្គលំ ឥមំ ខោ មេ បុគ្គលំ សេវតោ អកុសលា ធម្មា បរិហាយន្តិ កុសលា ធម្មា អភិវឌ្ឍន្តិ យេ ច មេ បព្វជិតេន ជីវិតបរិក្ខារា សមុទានេតព្វា ចីវរបិណ្ឌ-បាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារា តេ ច អប្បកសិរេន សមុទាហរន្តិ យស្ស ចម្ហិ អត្ថាយ អគារស្មា អនគារិយំ បព្វជិតោ

១ ឱ. ម. យាវជីវន្តិ បាឋោ នត្ថិ ។

បណ្ដាបុគ្គលទាំងពីរពួកនោះ បុគ្គលស្គាល់បុគ្គលណាថា កាលអាត្មាអញសេពគប់បុគ្គលនេះ អកុសលធម៌ទាំងឡាយ តែងវិនាសទៅ កុសល-ធម៌ទាំងឡាយ តែងចម្រើនឡើង មួយទៀត គ្រឿងបម្រុងជីវិតទាំងឡាយណា គឺចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារ ដែលអាត្មាអញ ជាបព្វជិតត្រូវប្រមូលមក ក៏គ្រឿងបម្រុងជីវិតទាំងនោះ មូលមកបានដោយងាយ មួយទៀត អាត្មាអញចេញចាកផ្ទះចូលទៅកាន់ផ្នួស ដើម្បីប្រយោជន៍ដល់ប្រយោជន៍នៃសមណៈណា ប្រយោជន៍នៃសមណៈនោះ តែងដល់នូវការបរិបូណ៌ ដោយភាវនាដល់អាត្មាអញ ដូច្នេះ ម្នាលអាវុសោទាំងឡាយ បុគ្គលនោះគប្បីជាប់តាមបុគ្គលនោះ មិនគប្បីចៀសចេញទៅដរាបដល់អស់ជីវិតឡើយ ។ បណ្ដាបុគ្គលទាំងពីរពួកនោះ បុគ្គលស្គាល់បុគ្គលណាថា កាលបើអាត្មាអញសេពគប់បុគ្គលនេះ អកុសលធម៌ទាំងឡាយ តែងសាបសូន្យទៅ កុសលធម៌ទាំងឡាយ តែងចម្រើនឡើង មួយទៀត គ្រឿងបម្រុងជីវិតទាំង-ឡាយណា គឺចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារ ដែលអាត្មាអញ ជាបព្វជិតត្រូវប្រមូលមក ក៏គ្រឿងបម្រុងជីវិតទាំងនោះ មូលមកបានដោយងាយ មួយទៀត អាត្មាអញចេញចាកផ្ទះចូលទៅកាន់ផ្នួស ដើម្បីប្រយោជន៍ដល់ប្រយោជន៍នៃសមណៈណា

សោ ច មេ សាមញ្ញត្ថោ ភាវនាបារិបូរឹ គច្ឆតីតិ តេនាវុសោ បុគ្គលេន សោ បុគ្គលោ យាវជីវំ អនុពន្ធិតព្វោ ន បក្កមិតព្វោ អបិ បនុជ្ជមានេន ។ បុគ្គលោបិ អាវុសោ ទុវិធេន វេទិតព្វោ សេវិតព្វោបិ អសេវិតព្វោបីតិ ឥតិ យន្តំ វុត្តំ ឥទមេតំ បដិច្ច វុត្តំ ។ ចីវរម្បិ អាវុសោ ទុវិធេន វេទិតព្វំ សេវិ-តព្វម្បិ អសេវិតព្វម្បីតិ ឥតិ ខោ បនេតំ វុត្តំ កិញ្ចេតំ បដិច្ច វុត្តំ ។ តត្ថ យំ ជញ្ញា ចីវរំ ឥទំ ខោ មេ ចីវរំ សេវតោ អកុសលា ធម្មា អភិវឌ្ឍន្តិ កុសលា ធម្មា បរិហាយន្តីតិ ឯវរូបំ ចីវរំ ន សេវិ-តព្វំ ។ តត្ថ យំ ជញ្ញា ចីវរំ ឥទំ ខោ មេ ចីវរំ សេវតោ អកុសលា ធម្មា បរិហាយន្តិ កុសលា ធម្មា អភិវឌ្ឍន្តីតិ ឯវរូបំ ចីវរំ សេវិតព្វំ ។

ប្រយោជន៍នៃសមណៈនោះ តែងដល់នូវការបរិបូណ៌ ដោយភាវនាដល់អាត្មាអញ ដូច្នេះ ម្នាលអាវុសោទាំងឡាយ បុគ្គលនោះ ទោះបីត្រូវគេបណ្តេញចេញ គប្បីជាប់តាមបុគ្គលនោះ មិនគប្បីចៀសចេញទៅដរាបដល់អស់ជីវិតឡើយ ។ ពាក្យណាថា ម្នាលអាវុសោទាំង-ឡាយ អ្នកទាំងឡាយ គប្បីស្គាល់បុគ្គលពីរពួក គឺបុគ្គលគួរសេព ១ មិនគួរសេព ១ ដូច្នេះ ដែលខ្ញុំពោលហើយ ពាក្យដែលខ្ញុំពោលហើយនុ៎ះ ព្រោះអាស្រ័យហេតុនេះ ។ ក៏ពាក្យថា ម្នាលអាវុសោទាំងឡាយ អ្នកទាំងឡាយគប្បីស្គាល់ចីវរពីរយ៉ាង គឺចីវរគួរប្រើប្រាស់ ១ មិនគួរប្រើប្រាស់ ១ ដូច្នេះនេះ ដែលខ្ញុំពោលហើយ ពាក្យដែលខ្ញុំពោលហើយនុ៎ះ តើព្រោះអាស្រ័យ ហេតុដូចម្តេច ។ បណ្តាចីវរទាំងពីរយ៉ាងនោះ ភិក្ខុស្គាល់ចីវរណាថា កាលអាត្មាអញប្រើប្រាស់ចីវរនេះហើយ អកុសលធម៌ទាំងឡាយ តែងចម្រើនឡើង កុសលធម៌ទាំងឡាយ តែងសាបសូន្យទៅដូច្នេះ ចីវរបែបនេះ ភិក្ខុមិនគួរប្រើប្រាស់ឡើយ ។ បណ្តាចីវរទាំង ២ យ៉ាងនោះ ភិក្ខុស្គាល់ចីវរបែបណាថា កាលបើអាត្មាអញប្រើប្រាស់ចីវរនេះ អកុសលធម៌ទាំងឡាយ តែងសាបសូន្យទៅ កុសលធម៌ទាំងឡាយ តែងចម្រើនឡើង ដូច្នេះ ចីវរបែបនេះ ភិក្ខុគួរប្រើប្រាស់បាន ។

៣៣

បណ្ណាសកេ សម្ពោធវគ្គោ

ចីវរម្បិ អាវុសោ ទុវិធេន វេទិតព្វំ សេវិតព្វម្បិ អសេវិតព្វម្បីតិ ឥតិ យន្តំ វុត្តំ ឥទមេតំ បដិច្ច វុត្តំ ។ បិណ្ឌបាតោបិ អាវុសោ ទុវិធេន វេទិតព្វោ សេវិតព្វោបិ អសេវិតព្វោបីតិ ឥតិ ខោ បនេតំ វុត្តំ កិញ្ចេតំ បដិច្ច វុត្តំ ។ តត្ថ យំ ជញ្ញា បិណ្ឌបាតំ ឥមំ ខោ មេ បិណ្ឌបាតំ សេវតោ អកុសលា ធម្មា អភិវឌ្ឍន្តិ កុសលា ធម្មា បរិហាយន្តីតិ ឯវរូបោ បិណ្ឌបាតោ ន សេវិតព្វោ ។ តត្ថ យំ ជញ្ញា បិណ្ឌបាតំ ឥមំ ខោ មេ បិណ្ឌបាតំ សេវតោ អកុ-សលា ធម្មា បរិហាយន្តិ កុសលា ធម្មា អភិវឌ្ឍន្តីតិ ឯវរូបោ បិណ្ឌបាតោ សេវិតព្វោ ។ បិណ្ឌបាតោបិ អាវុសោ ទុវិធេន វេទិតព្វោ សេវិតព្វោបិ អសេវិ-តព្វោបីតិ ឥតិ យន្តំ វុត្តំ ឥទមេតំ បដិច្ច វុត្តំ ។

ពាក្យណាថា ម្នាលអាវុសោទាំងឡាយ ភិក្ខុត្រូវស្គាល់ចីវរមាន ២ យ៉ាង គឺចីវរគួរប្រើប្រាស់ ១ មិនគួរប្រើប្រាស់ ១ ដូច្នេះ ដែលខ្ញុំពោលហើយ ពាក្យដែលខ្ញុំពោលហើយនុ៎ះ ព្រោះអាស្រ័យហេតុនេះ ។ ក៏ពាក្យថា ម្នាលអាវុសោទាំងឡាយ អ្នកទាំងឡាយ គប្បីស្គាល់បិណ្ឌបាត ២ យ៉ាង គឺបិណ្ឌបាតគួរសេព ១ មិនគួរសេព ១ ដូច្នេះនេះ ដែលខ្ញុំពោលហើយ ពាក្យដែលខ្ញុំពោលហើយនុ៎ះ តើព្រោះអាស្រ័យហេតុដូចម្តេច ។ បណ្តាបិណ្ឌបាតទាំង ២ យ៉ាងនោះ ភិក្ខុស្គាល់បិណ្ឌបាតណាថា កាលបើអាត្មាអញសេពនូវបិណ្ឌបាតនេះ អកុសលធម៌ទាំងឡាយ តែងចម្រើនឡើង កុសលធម៌ទាំងឡាយ តែងសាបសូន្យទៅដូច្នេះ បិណ្ឌបាតបែបនេះ ភិក្ខុមិនគួរសេពឡើយ ។ បណ្តាបិណ្ឌបាតទាំង ២ យ៉ាងនោះ ភិក្ខុស្គាល់បិណ្ឌបាតណាថា កាលបើអាត្មាអញ សេពនូវបិណ្ឌបាតនេះ អកុសលធម៌ទាំងឡាយ តែងសាបសូន្យទៅ កុសលធម៌ទាំងឡាយ តែងចម្រើនឡើងដូច្នេះ បិណ្ឌបាតបែបនេះ ភិក្ខុគួរសេពបាន ។ ពាក្យណាថា ម្នាលអាវុសោទាំងឡាយ អ្នកទាំងឡាយ គប្បីស្គាល់បិណ្ឌ-បាត ២ យ៉ាង គឺបិណ្ឌបាតគួរសេព ១ មិនគួរសេព ១ ដូច្នេះ ដែលខ្ញុំពោលហើយ ពាក្យដែលខ្ញុំពោលហើយនុ៎ះ ព្រោះអាស្រ័យហេតុនោះ ។

សេនាសនម្បិ អាវុសោ ទុវិធេន វេទិតព្វំ សេវិតព្វម្បិ អសេវិតព្វម្បីតិ ឥតិ ខោ បនេតំ វុត្តំ កិញ្ចេតំ បដិច្ច វុត្តំ ។ តត្ថ យំ ជញ្ញា សេនាសនំ ឥមំ ខោ មេ សេនាសនំ សេវតោ អកុសលា ធម្មា អភិវឌ្ឍន្តិ កុសលា ធម្មា បរិហាយន្តីតិ ឯវរូបំ សេនាសនំ ន សេវិតព្វំ ។ តត្ថ យំ ជញ្ញា សេនាសនំ ឥមំ ខោ មេ សេនាសនំ សេវតោ អកុសលា ធម្មា បរិហាយន្តិ កុសលា ធម្មា អភិវឌ្ឍន្តីតិ ឯវរូបំ សេនាសនំ សេវិតព្វំ ។ សេនាសនម្បិ អាវុសោ ទុវិធេន វេទិតព្វំ សេវិតព្វម្បិ អសេវិតព្វម្បីតិ ឥតិ យន្តំ វុត្តំ ឥទមេតំ បដិច្ច វុត្តំ ។ គាមនិគមោបិ អាវុសោ ទុវិធេន វេទិតព្វោ សេវិតព្វោបិ អសេវិតព្វោបីតិ ឥតិ ខោ បនេតំ វុត្តំ កិញ្ចេតំ បដិច្ច វុត្តំ ។

ក៏ពាក្យថា ម្នាលអាវុសោទាំងឡាយ អ្នកទាំងឡាយ គប្បីស្គាល់សេនាសនៈ ២ យ៉ាង គឺសេនាសនៈគួរសេព ១ មិនគួរសេព ១ ដូច្នេះ នេះដែលខ្ញុំពោលហើយ ពាក្យដែលខ្ញុំពោលហើយនុ៎ះ ព្រោះអាស្រ័យហេតុដូចម្តេច ។ បណ្តាសេនាសនៈទាំង ២ យ៉ាងនោះ ភិក្ខុស្គាល់សេនាសនៈណាថា កាលបើអាត្មាអញសេពនូវសេនាសនៈនេះ អកុសលធម៌ទាំងឡាយ តែងចម្រើនឡើង កុសលធម៌ទាំងឡាយ តែងសាបសូន្យទៅដូច្នេះ សេនាសនៈបែបនេះ ភិក្ខុមិនគួរសេពឡើយ ។ បណ្តាសេនាសនៈទាំង ២ យ៉ាងនោះ ភិក្ខុស្គាល់សេនាសនៈណាថា កាលបើអាត្មាអញ សេពនូវសេនាសនៈនេះហើយ អកុសលធម៌ទាំងឡាយ តែងសាបសូន្យទៅ កុសលធម៌ទាំងឡាយ តែងចម្រើនឡើងដូច្នេះ សេនាសនៈបែបនេះ ភិក្ខុគួរសេពបាន ។ ក៏ពាក្យណាថា ម្នាលអាវុសោទាំងឡាយ អ្នកទាំងឡាយ គប្បីស្គាល់សេនាសនៈ ២ យ៉ាង គឺសេនាសនៈគួរសេព ១ មិនគួរសេព ១ ដូច្នេះ ដែលខ្ញុំពោលហើយ ពាក្យដែលខ្ញុំពោលហើយនុ៎ះ ព្រោះអាស្រ័យហេតុនេះ ។ ក៏ពាក្យថា ម្នាលអាវុសោទាំងឡាយ អ្នកទាំងឡាយ គប្បីស្គាល់ស្រុកនិងនិគម ២ យ៉ាង គឺ ស្រុកនិងនិគមគួរសេព ១ មិនគួរសេព ១ ដូច្នេះនេះ ដែលខ្ញុំពោលហើយ ពាក្យដែលខ្ញុំពោលហើយនុ៎ះ តើព្រោះអាស្រ័យហេតុដូចម្តេច ។

តត្ថ យំ ជញ្ញា គាមនិគមំ ឥមំ ខោ មេ គាមនិគមំ សេវតោ អកុសលា ធម្មា អភិវឌ្ឍន្តិ កុសលា ធម្មា បរិហាយន្តីតិ ឯវរូបោ គាមនិគមោ ន សេវិតព្វោ ។ តត្ថ យំ ជញ្ញា គាមនិគមំ ឥមំ ខោ មេ គាមនិគមំ សេវតោ អកុសលា ធម្មា បរិហាយន្តិ កុសលា ធម្មា អភិវឌ្ឍន្តីតិ ឯវរូបោ គាមនិគមោ សេវិតព្វោ ។ គាមនិគមោបិ អាវុសោ ទុវិធេន វេទិតព្វោ សេវិតព្វោបិ អសេវិតព្វោបីតិ ឥតិ យន្តំ វុត្តំ ឥទមេតំ បដិច្ច វុត្តំ ។ ជនបទប្បទេ-សោបិ អាវុសោ ទុវិធេន វេទិតព្វោ សេវិតព្វោបិ អសេវិតព្វោបីតិ ឥតិ ខោ បនេតំ វុត្តំ កិញ្ចេតំ បដិច្ច វុត្តំ ។ តត្ថ យំ ជញ្ញា ជនបទប្បទេសំ ឥមំ ខោ មេ ជនបទប្បទេសំ សេវតោ អកុសលា ធម្មា អភិវឌ្ឍន្តិ កុសលា ធម្មា បរិហាយន្តីតិ

បណ្ដាស្រុកនិងនិគមទាំង ២ យ៉ាងនោះ ភិក្ខុស្គាល់នូវស្រុកនិងនិគមណាថា កាលបើអាត្មាអញសេពស្រុកនិងនិគមនេះ អកុសលធម៌ទាំងឡាយតែងចម្រើនឡើង កុសលធម៌ទាំងឡាយ តែងសាបសូន្យទៅដូច្នេះ ស្រុកនិងនិគមបែបនេះ ភិក្ខុមិនគួរសេពឡើយ ។ បណ្ដាស្រុកនិងនិគម ២ យ៉ាងនោះ ភិក្ខុស្គាល់ស្រុកនិងនិគមណាថា កាលបើអាត្មាអញ សេពស្រុកនិងនិគមនេះ អកុសលធម៌ទាំងឡាយ តែងសាបសូន្យទៅ កុសលធម៌ទាំងឡាយ តែងចម្រើនឡើងដូច្នេះ ស្រុកនិងនិគមបែបនេះ ភិក្ខុគួរសេពបាន ។ ក៏ពាក្យណាថា ម្នាលអាវុសោទាំងឡាយ អ្នកទាំងឡាយគប្បីស្គាល់ស្រុកនិងនិគម ២ យ៉ាង គឺស្រុកនិងនិគមគួរសេព ១ មិនគួរសេព ១ ដូច្នេះ ដែលខ្ញុំពោលហើយ ពាក្យនុ៎ះ ដែលខ្ញុំពោលហើយព្រោះអាស្រ័យហេតុនេះ ។ ក៏ពាក្យថា ម្នាលអាវុសោទាំងឡាយ អ្នកទាំងឡាយ គប្បីស្គាល់ជនបទនិងប្រទេស ២ យ៉ាង គឺ ជនបទនិងប្រទេសដែលគួរសេព ១ មិនគួរសេព ១ ដូច្នេះនេះ ដែលខ្ញុំពោលហើយ ពាក្យដែលខ្ញុំពោលហើយនុ៎ះ តើព្រោះអាស្រ័យហេតុដូចម្ដេច ។ បណ្ដាជនបទនិងប្រទេសទាំង ២ យ៉ាងនោះ ភិក្ខុស្គាល់ជនបទនិងប្រទេសណាថា កាលបើអាត្មាអញសេពជនបទនិងប្រទេសនេះ អកុសលធម៌ទាំង-ឡាយ តែងចម្រើនឡើង កុសលធម៌ទាំងឡាយ តែងសាបសូន្យទៅដូច្នេះ

ឯវរូបោ ជនបទប្បទេសោ ន សេវិតព្វោ ។ តត្ថ យំ ជញ្ញា ជនបទប្បទេសំ ឥទំ ខោ មេ ជនបទប្បទេសំ សេវតោ អកុសលា ធម្មា បរិហាយន្តិ កុសលា ធម្មា អភិវឌ្ឍន្តីតិ ឯវរូបោ ជនបទប្បទេសោ សេវិតព្វោ ។ ជនបទប្បទេសោបិ អាវុសោ ទុវិធេន វទាមិ សេវិតព្វោបិ អសេវិតព្វោបីតិ ឥតិ យន្តំ វុត្តំ ឥទមេតំ បដិច្ច វុត្តន្តិ ។

[៧] ឯកំ សមយំ ភគវា រាជគហេ វិហរតិ គិជ្ឈកូដេ បព្វតេ ។ អថខោ សុតវា បរិព្វាជកោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតា សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ សុតវា បរិព្វាជកោ ភគវន្តំ ឯតទវោច

ជនបទនិងប្រទេសបែបនេះ ភិក្ខុមិនគួរសេពឡើយ ។ បណ្ដាជនបទនិងប្រទេសទាំង ២ យ៉ាងនោះ ភិក្ខុស្គាល់ជនបទនិងប្រទេសណាថា កាលបើអាត្មាអញ សេពនូវជនបទនិងប្រទេសនេះ អកុសលធម៌ទាំងឡាយតែងសាបសូន្យទៅ កុសលធម៌ទាំងឡាយ តែងចម្រើនឡើងដូច្នេះ ជនបទនិងប្រទេសបែបនេះ ភិក្ខុគួរសេពបាន ។ ក៏ពាក្យណាថា ម្នាលអាវុសោទាំងឡាយ អ្នកទាំងឡាយ គប្បីស្គាល់ជនបទនិងប្រទេស ២ យ៉ាង គឺជនបទនិងប្រទេសដែលគួរសេព ១ មិនគួរសេព ១ ដូច្នេះ ដែលខ្ញុំពោលហើយ ពាក្យដែលខ្ញុំពោលហើយនុ៎ះ ព្រោះអាស្រ័យហេតុនេះ ។

[៧] សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់លើភ្នំគិជ្ឈកូដ ទៀបក្រុងរាជគ្រឹះ ។ គ្រានោះឯង បរិព្វាជក ឈ្មោះសុតវន្តុ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្ដីរីករាយជាមួយនឹងព្រះដ៏មានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយនិងពាក្យដែលគួររលឹកហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះសុតវន្តុបរិព្វាជក អង្គុយក្នុងទីសមគួរហើយ ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា

៣៧



ឯកមិទាហំ ភន្តេ សមយំ ភគវា ឥធេវ រាជគហេ វិហរាមិ គិរិព្វជេ[១] ។ តត្រ ខោ[២] មេ ភន្តេ ភគវតោ សម្មុខា សុតំ សម្មុខា បដិគ្គហិតំ យោ សោ សុតវា ភិក្ខុ អរហំ ខីណាសវោ វុសិតវា កតករណីយោ ឱហិតភារោ អនុប្បត្តសទត្ថោ បរិក្ខីណភវសញ្ញោជនោ សម្មទញ្ញាវិមុត្តោ អភព្វោ សោ បញ្ចដ្ឋានានិ អជ្ឈាចរិតុំ អភព្វោ ខីណាសវោ ភិក្ខុ សញ្ចិច្ច បាណំ ជីវិតា វោរោបេតុំ អភព្វោ ខីណាសវោ ភិក្ខុ អទិន្នំ ថេយ្យសង្ខាតំ អាទាតុំ អភព្វោ ខីណាសវោ ភិក្ខុ មេថុនំ ធម្មំ បដិសេវិតុំ អភព្វោ ខីណាសវោ ភិក្ខុ សម្បជានមុសា ភាសិតុំ អភព្វោ ខីណាសវោ ភិក្ខុ សន្និធិការកំ[៣] កាមេ បរិភុញ្ជិតុំ សេយ្យថាបិ បុព្វេ អគារិយភូតោ[៤] កច្ចិ មេតំ ភន្តេ ភគវតោ សុស្សុតំ សុគ្គហិតំ សុមនសិកតំ សូបធារិតន្តិ ។

១ ឱ. ឯកមិទំ ភន្តេ សមយំ ភគវា ឥធេវ រាជគហេ វិហរតិ គិរិព្វជេ ។ ២ ឱ.ម. ខោសទ្ទោ នត្ថិ ។ ៣ ឱ. ម. សន្និធិការកេ ។ ៤ ឱ. ម. អគារិយភូតោតិ ។

បណ្ណាសក សម្ពោធវគ្គ

បពិត្រព្រះដ៏មានព្រះភាគដ៏ចម្រើន សម័យមួយ ខ្ញុំព្រះអង្គនៅក្នុងក្រុងរាជគ្រឹះ ដែលមានភ្នំ (ព័ទ្ធជុំវិញ) ដូចជាក្រោលនេះឯង ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គ បានស្តាប់ចំពោះព្រះភក្ត្រ បានទទួលយកចំពោះព្រះភក្ត្រនៃព្រះដ៏មានព្រះភាគ ក្នុងទីនោះថា ម្នាលសុតវន្តុ ភិក្ខុណា ជាអរហន្តខីណាស្រព មានព្រហ្មចរិយធម៌ បានប្រព្រឹត្តរួចហើយ មានសោឡសកិច្ច បានធ្វើស្រេចហើយ មានភារៈដាក់ចុះហើយ មានប្រយោជន៍ របស់ខ្លួនសម្រេចហើយ មានធម៌ជាគ្រឿងប្រកបសត្វក្នុងភពអស់ហើយ ជាអ្នករួចស្រឡះ ព្រោះដឹងដោយប្រពៃ ភិក្ខុនោះ មិនគួរប្រព្រឹត្តកន្លងនូវហេតុ ៥ យ៉ាង គឺ ភិក្ខុជាខីណាស្រព មិនគួរក្លែងផ្តាច់បង់ជីវិតសត្វ ១ ភិក្ខុជាខីណាស្រព មិនគួរកាន់យកនូវវត្ថុ ដែលគេមិនបានឲ្យ ដែលហៅថាលួច ១ ភិក្ខុជាខីណាស្រព មិនគួរសេពមេថុនធម្ម ១ ភិក្ខុជាខីណាស្រព មិនគួរពោលពាក្យកុហកទាំងដឹងខ្លួន ១ ភិក្ខុជាខីណាស្រព មិនគួរធ្វើនូវការសន្សំទុក ហើយបរិភោគនូវកាមទាំងឡាយ ដូចជានៅជាគ្រហស្ថក្នុងកាលមុន ១ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានស្តាប់ល្អហើយ បានទទួលល្អហើយ បានធ្វើទុកក្នុងចិត្តល្អហើយ ចាំបានល្អហើយនូវព្រះពុទ្ធដីកា របស់ព្រះដ៏មានព្រះភាគនុ៎ះមែនឬ ។

៣៨



តស្ស តេ ឯតំ សុប្បត្តំ សុគ្គហិតំ សុមនសិកតំ សូបធារិតំ បុព្វេ ចាហំ សុតវា ឯតរហិ ច ឯវំ វទាមិ យោ សោ ភិក្ខុ អរហំ ខីណាសវោ វុសិតវា កតករណីយោ ឱហិតភារោ អនុប្បត្តសទត្ថោ បរិក្ខីណភវសញ្ញោជនោ សម្មទញ្ញាវិមុត្តោ អភព្វោ សោ នវដ្ឋានានិ អជ្ឈាចរិតុំ អភព្វោ ខីណាសវោ ភិក្ខុ សញ្ចិច្ច ចាណំ ជីវិតា វោរោបេតុំ អភព្វោ ខីណាសវោ ភិក្ខុ អទិន្នំ ថេយ្យសង្ខាតំ អាទាតុំ អភព្វោ ខីណាសវោ ភិក្ខុ មេថុនំ ធម្មំ បដិសេវិតុំ អភព្វោ ខីណាសវោ ភិក្ខុ សម្បជានមុសា ភាសិតុំ អភព្វោ ខីណាសវោ ភិក្ខុ សន្និធិការកំ កាមេ បរិភុញ្ជិតុំ សេយ្យថាបិ បុព្វេ អគារិយភូតោ អភព្វោ ខីណាសវោ ភិក្ខុ ឆន្ទាគតឹ គន្តុំ អភព្វោ ខីណាសវោ ភិក្ខុ ទោសាគតឹ គន្តុំ អភព្វោ ខីណាសវោ ភិក្ខុ មោហាគតឹ គន្តុំ អភព្វោ ខីណាសវោ ភិក្ខុ ភយាគតឹ គន្តុំ បុព្វេ ចាហំ សុតវា ឯតរហិ ច ឯវំ វទាមិ

អើពាក្យនុ៎ះ អ្នកស្តាប់ល្អហើយ រៀនល្អហើយ ធ្វើទុកក្នុងចិត្តល្អហើយ ចាំល្អហើយ ម្នាលសុតវន្តុ ក្នុងកាលពីដើមក្តី ក្នុងកាលឥឡូវនេះក្តី តថាគត តែងពោលយ៉ាងនេះថា ភិក្ខុណា ជាអរហន្តខីណាស្រព មានព្រហ្មចរិយធម៌បានប្រព្រឹត្តរួចហើយ មានសោឡសកិច្ច បានធ្វើស្រេចហើយ មានភារៈដាក់ចុះហើយ មានប្រយោជន៍របស់ខ្លួនសម្រេចហើយ មានធម៌ជាគ្រឿងប្រកបសត្វ ក្នុងភពអស់ហើយ ជាអ្នករួចស្រឡះព្រោះដឹងដោយប្រពៃ ភិក្ខុនោះ មិនគួរប្រព្រឹត្តកន្លងនូវហេតុ ៩ យ៉ាង គឺភិក្ខុជាខីណាស្រព មិនគួរក្លែងផ្តាច់បង់ជីវិតសត្វ ១ ភិក្ខុជាខីណាស្រព មិនគួរកាន់យកនូវវត្ថុដែលគេមិនបានឲ្យ ដែលហៅថាលួច ១ ភិក្ខុជាខីណាស្រព មិនគួរសេពមេថុនធម្ម ១ ភិក្ខុជាខីណាស្រព មិនគួរពោលពាក្យកុហកទាំងដឹងខ្លួន ១ ភិក្ខុជាខីណាស្រព មិនគួរធ្វើនូវការសន្សំទុកហើយបរិភោគនូវកាមទាំងឡាយ ដូចជានៅជាគ្រហស្ថក្នុងកាលមុន ១ ភិក្ខុជាខីណាស្រពមិនគួរលុះក្នុងឆន្ទាគតិ ១ ភិក្ខុជាខីណាស្រព មិនគួរលុះក្នុងទោសាគតិ ១ ភិក្ខុជាខីណាស្រព មិនគួរលុះក្នុងមោហាគតិ ១ ភិក្ខុជាខីណាស្រព មិនគួរលុះក្នុងភយាគតិ ១ ម្នាលសុតវន្តុ ក្នុងកាលពីដើមក្តី ក្នុងកាលឥឡូវនេះក្តី តថាគតតែងពោលយ៉ាងនេះថា

យោ សោ ភិក្ខុ អរហំ ខីណាសវោ វុសិតវា កតករណីយោ ឱហិតភារោ អនុប្បត្តសទត្ថោ បរិក្ខីណភវសញ្ញោជនោ សម្មទញ្ញាវិមុត្តោ អភព្វោ សោ ឥមានិ នវដ្ឋានានិ អជ្ឈាចរិតុន្តិ ។

[៨] ឯកំ សមយំ ភគវា រាជគហេ វិហរតិ គិជ្ឈកូដេ បព្វតេ ។ អថខោ សជ្ឈោ បរិព្វាជកោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតា សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ សជ្ឈោ បរិព្វាជកោ ភគវន្តំ ឯតទវោច ឯកមិទាហំ ភន្តេ សមយំ ភគវា ឥធេវ រាជគហេ វិហរាមិ គិរិព្វជេ[១] ។ តត្រ មេ ភន្តេ ភគវតោ សម្មុខា សុតំ សម្មុខា បដិគ្គហិតំ យោ សោ សជ្ឈ ភិក្ខុ អរហំ ខីណាសវោ វុសិតវា កតករណីយោ

១ ឱ. ឯកមិទំ ភន្តេ សមយំ ភគវា ឥធេវ រាជគហេ វិហរតិ គិរិព្វជេ ។

ភិក្ខុណាជាអរហន្តខីណាស្រព ដែលមានព្រហ្មចរិយធម៌ បានប្រព្រឹត្ត រួចហើយ មានសោឡសកិច្ច បានធ្វើស្រេចហើយ មានភារៈដាក់ចុះ ហើយ មានប្រយោជន៍របស់ខ្លួនសម្រេចហើយ មានធម៌ជាគ្រឿងប្រកប សត្វក្នុងភពអស់ហើយ ជាអ្នករួចស្រឡះ ព្រោះដឹងដោយប្រពៃ ភិក្ខុ នោះ មិនគួរប្រព្រឹត្តកន្លងនូវហេតុទាំង ៩ យ៉ាងនេះ ។

[៨] សម័យមួយ ព្រះដ៏មានព្រះភាគ កាលគង់លើភ្នំគិជ្ឈកូដ ទៀប ក្រុងរាជគ្រឹះ ។ គ្រានោះឯង បរិព្វាជកឈ្មោះសជ្ឈៈ ចូលទៅគាល់ព្រះ ដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្ដីរីករាយជាមួយនឹងព្រះ ដ៏មានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររលឹក ហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះសជ្ឈបរិព្វាជក អង្គុយក្នុងទីសមគួរ ហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះដ៏មាន ព្រះភាគដ៏ចម្រើន សម័យមួយ ខ្ញុំព្រះអង្គនៅក្នុងក្រុងរាជគ្រឹះ ដែលមានភ្នំ (ព័ទ្ធជុំវិញ) ដូចជាក្រោលនេះឯង ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបាន ស្ដាប់ចំពោះព្រះភក្ត្រ បានទទួលយកចំពោះព្រះភក្ត្រព្រះដ៏មានព្រះភាគ ក្នុងទីនោះថា ម្នាលសជ្ឈៈ ភិក្ខុណាជាអរហន្តខីណាស្រព មានព្រហ្ម- ចរិយធម៌បានប្រព្រឹត្តរួចហើយ មានសោឡសកិច្ចបានធ្វើស្រេចហើយ

៤០



ឱហិតភារោ អនុប្បត្តសទត្ថោ បរិក្ខីណភវសញ្ញោជនោ សម្មទញ្ញាវិមុត្តោ អភព្វោ សោ បញ្ចដ្ឋានានិ អជ្ឈាចរិតុំ អភព្វោ ខីណាសវោ ភិក្ខុ សញ្ចិច្ច ចាណំ ជីវិតា វោរោបេតុំ អភព្វោ ខីណាសវោ ភិក្ខុ អទិន្នំ ថេយ្យសង្ខាតំ អាទាតុំ អភព្វោ ខីណាសវោ ភិក្ខុ មេថុនំ ធម្មំ បដិសេវិតុំ អភព្វោ ខីណាសវោ ភិក្ខុ សម្បជានមុសា ភាសិតុំ អភព្វោ ខីណាសវោ ភិក្ខុ សន្និធិការកំ កាមេ បរិភុញ្ជិតុំ សេយ្យថាបិ បុព្វេ អគារិយភូតោ កច្ចិ មេតំ ភន្តេ ភគវតោ សុស្សុតំ សុគ្គហិតំ សុមនសិកតំ សូបធារិតន្តិ ។ តគ្ឃ តេ ឯតំ សច្ច សុស្សុតំ សុគ្គហិតំ សុមនសិកតំ សូបធារិតំ ។ បុព្វេ ចាហំ សច្ច ឯតរហិ ច ឯវំ វទាមិ យោ សោ ភិក្ខុ អរហំ ខីណាសវោ វុសិតវា កតករណីយោ ឱហិតភារោ អនុប្បត្តសទត្ថោ

មានភារៈដាក់ចុះហើយ មានប្រយោជន៍របស់ខ្លួនសម្រេចហើយ មានធម៌ជាគ្រឿងប្រកបសត្វក្នុងភពអស់ហើយ ជាអ្នករួចស្រឡះ ព្រោះដឹងដោយប្រពៃ ភិក្ខុនោះមិនគួរប្រព្រឹត្តកន្លងនូវហេតុ ៥ យ៉ាង គឺភិក្ខុជាខីណាស្រព មិនគួរក្លែងផ្តាច់បង់ជីវិតសត្វ ១ ភិក្ខុជាខីណាស្រពមិនគួរកាន់យកនូវវត្ថុដែលគេមិនបានឲ្យដែលហៅថាលួច ១ ភិក្ខុជាខីណាស្រព មិនគួរសេពនូវមេថុនធម្ម ១ ភិក្ខុជាខីណាស្រព មិនគួរពោលនូវពាក្យកុហកទាំងដឹងខ្លួន ១ ភិក្ខុជាខីណាស្រព មិនគួរធ្វើនូវការសន្សំទុកហើយបរិភោគនូវកាមទាំងឡាយ ដូចជានៅជាគ្រហស្ថក្នុងកាលមុន ១ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានស្តាប់ល្អហើយ បានទទួលល្អហើយ បានធ្វើទុកក្នុងចិត្តល្អហើយ ចាំបានល្អហើយនូវព្រះពុទ្ធដីកានុ៎ះ របស់ព្រះដ៏មានព្រះភាគមែនឬ ។ ម្នាលសដ្ឋៈ អើពាក្យនុ៎ះ អ្នកបានស្តាប់ល្អហើយ បានទទួលល្អហើយ បានធ្វើទុកក្នុងចិត្តល្អហើយ បានចាំទុកល្អហើយ ។ ម្នាលសដ្ឋៈ ក្នុងកាលពីដើមក្តី ឥឡូវនេះក្តី តថាគតក៏ពោលយ៉ាងនេះថា ភិក្ខុណា ជាអរហន្តខីណាស្រព ជាអ្នកមានព្រហ្មចរិយធម៌ បានប្រព្រឹត្តរួចហើយ មានសោឡសកិច្ចបានធ្វើស្រេចហើយ មានភារៈដាក់ចុះហើយ មានប្រយោជន៍របស់ខ្លួនសម្រេចហើយ

បរិក្ខីណភវសញ្ញោជនោ សម្មទញ្ញាវិមុត្តោ អភព្វោ សោ នវដ្ឋានានិ អជ្ឈាចរិតុំ អភព្វោ ខីណាសវោ ភិក្ខុ សញ្ចិច្ច បាណំ ជីវិតា វោរោបេតុំ ។ បេ ។ អភព្វោ ខីណាសវោ ភិក្ខុ សន្និធិការកំ កាមេ បរិភុញ្ជិតុំ សេយ្យថាបិ បុព្វេ អគារិយភូតោ អភព្វោ ខីណាសវោ ភិក្ខុ ពុទ្ធំ បច្ចក្ខាតុំ អភព្វោ ខីណាសវោ ភិក្ខុ ធម្មំ បច្ចក្ខាតុំ អភព្វោ ខីណាសវោ ភិក្ខុ សង្ឃំ បច្ចក្ខាតុំ អភព្វោ ខីណាសវោ ភិក្ខុ សិក្ខំ បច្ចក្ខាតុំ បុព្វេ ចាហំ សជ្ឈ ឯតរហិ ច ឯវំ វទាមិ យោ សោ ភិក្ខុ អរហំ ខីណាសវោ វុសិតវា កតករណីយោ ឱហិតភារោ អនុប្បត្តសទត្ថោ បរិក្ខីណភវសញ្ញោជនោ សម្មទញ្ញាវិមុត្តោ អភព្វោ សោ ឥមានិ នវដ្ឋានានិ អជ្ឈាចរិតុន្តិ ។

[៩] នវយិមេ ភិក្ខវេ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មឹ ។ កតមេ នវ ។ អរហា

មានធម៌ជាគ្រឿងប្រកបសត្វ ក្នុងភពអស់ហើយ ជាអ្នករួចស្រឡះ ព្រោះដឹងដោយប្រពៃ ភិក្ខុនោះមិនគួរប្រព្រឹត្តកន្លងនូវហេតុ ៩ យ៉ាង គឺភិក្ខុជាខីណាស្រព មិនគួរក្លែងផ្តាច់បង់ជីវិតសត្វ ១ ។ បេ ។ ភិក្ខុជាខីណាស្រព មិនគួរធ្វើនូវការសន្សំទុក ហើយបរិភោគនូវកាមទាំងឡាយ ដូចជានៅជាគ្រហស្ថក្នុងកាលមុន ១ ភិក្ខុជាខីណាស្រព មិនគួរលះបង់ព្រះពុទ្ធ ១ ភិក្ខុជាខីណាស្រព មិនគួរលះបង់ព្រះធម៌ ១ ភិក្ខុជាខីណាស្រព មិនគួរលះបង់ព្រះសង្ឃ ១ ភិក្ខុជាខីណាស្រព មិនគួរលះបង់សិក្ខា ១ ម្នាលសជ្ឈៈ ក្នុងកាលពីដើមក្តី ឥឡូវនេះក្តី តថាគតក៏ពោលយ៉ាងនេះថា ភិក្ខុណា ជាអរហន្តខីណាស្រព មានព្រហ្មចរិយធម៌ បានប្រព្រឹត្តរួចហើយ មានសោឡសកិច្ចបានធ្វើស្រេចហើយ មានភារៈដាក់ចុះហើយ មានប្រយោជន៍របស់ខ្លួនសម្រេចហើយ មានធម៌ជាគ្រឿងប្រកបសត្វក្នុងភពអស់ហើយ ជាអ្នករួចស្រឡះ ព្រោះដឹងដោយប្រពៃ ភិក្ខុនោះ មិនគួរប្រព្រឹត្តកន្លង នូវហេតុ ៩ យ៉ាងនេះ ។

[៩] ម្នាលភិក្ខុទាំងឡាយ បុគ្គល ៩ ពួកនេះ តែងមានប្រាកដ ក្នុងលោក ។ បុគ្គល ៩ ពួក តើដូចម្តេច ។ គឺអរហន្ត ១

អរហត្តាយ បដិបន្នោ អនាគាមី អនាគាមិផល-សច្ឆិកិរិយាយ បដិបន្នោ សកទាគាមី សកទា-គាមិផលសច្ឆិកិរិយាយ បដិបន្នោ សោតាបន្នោ សោតាបត្តិផលសច្ឆិកិរិយាយ បដិបន្នោ បុថុជ្ជនោ ។ ឥមេ ខោ ភិក្ខវេ នវ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មិន្តិ ។

[១០] នវយិមេ ភិក្ខវេ បុគ្គលា អាហុនេយ្យា បាហុនេយ្យា ទក្ខិណេយ្យា អញ្ជលិករណីយា អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស ។ កតមេ នវ ។ អរហា អរហត្តាយ បដិបន្នោ អនាគាមី អនាគាមិផលសច្ឆិកិរិ-យាយ បដិបន្នោ សកទាគាមី សកទាគាមិផល-សច្ឆិកិរិយាយ បដិបន្នោ សោតាបន្នោ សោតាបត្តិផល-សច្ឆិកិរិយាយ បដិបន្នោ គោត្រភូ ។ ឥមេ ខោ ភិក្ខវេ នវ បុគ្គលា អាហុនេយ្យា ។ បេ ។ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ ។

សម្ពោធវគ្គោ បឋមោ ។

បុគ្គលប្រតិបត្តិដើម្បីអរហត្ត ១ អនាគាមិបុគ្គល ១ បុគ្គលប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល ១ សកទាគាមិបុគ្គល ១ បុគ្គលប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិផល ១ សោតាបន្នបុគ្គល ១ បុគ្គលប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល ១ បុថុជ្ជន ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល ៩ ពួកនេះឯង តែងមានប្រាកដក្នុងលោក ។

[១០] ម្នាលភិក្ខុទាំងឡាយ បុគ្គល ៩ ពួកនេះ ជាអ្នកគួរទទួលនូវចតុប្បច្ច័យ ដែលគេនាំមកបូជា គួរទទួលនូវអាគន្តុកទាន ដែលគេនាំមកដើម្បីភ្ញៀវ គួរទទួលនូវទក្ខិណាទាន គួរដល់អញ្ជលិកម្ម ជាបុញ្ញក្ខេត្តដ៏ប្រសើររបស់សត្វលោក ។ បុគ្គល ៩ ពួក តើដូចម្ដេច ។ គឺអរហន្ត ១ បុគ្គលប្រតិបត្តិដើម្បីអរហត្ត ១ អនាគាមិបុគ្គល ១ បុគ្គលប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល ១ សកទាគាមិបុគ្គល ១ បុគ្គលប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិផល ១ សោតាបន្នបុគ្គល ១ បុគ្គលអ្នកប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល ១ គោត្រភូ-បុគ្គល ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលទាំង ៩ ពួកនេះឯង ជាអ្នកគួរទទួលនូវចតុប្បច្ច័យ ដែលគេនាំមកបូជា ។ បេ ។ ជាបុញ្ញក្ខេត្តដ៏ប្រសើរ របស់សត្វលោក ។

ចប់ សម្ពោធវគ្គទី ១ ។

៤៣

បណ្ណាសកេ សម្ភោធវគ្គោ

# តត្រុទ្ធានំ ភវតិ

សម្ភោជិ និស្សយោ ចេវ មេឃិយំ ឆន្ទកំ ពលំ
សេវនា សុតវា សង្ខ្យា ឫក្កលោ អាហុនេយ្យា ចាតិ ។

---

# ឧទ្ទានក្នុងសម្មោធវគ្គនោះគឺ

*និយាយអំពីការត្រាស់ដឹង ១ អំពីនិស្ស័យ ១ អំពីមេឃិ-យត្ថេរ ១ អំពីនន្ទកត្ថេរ ១ អំពីពលៈ ១ អំពីការសេព ១ អំពីសុតវន្តុបរិញ្ញាជក ១ អំពីសង្ឃបរិញ្ញាជក ១ អំពីបុគ្គល ១ អំពីអាហុនេយ្យបុគ្គល ១ ។*

# បណ្ណាសកេ សីហនាទវគ្គោ

[១១] ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ អថខោ អាយស្មា សារីបុត្តោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា សារីបុត្តោ ភគវន្តំ ឯតទវោច វុដ្ឋោ មេ ភន្តេ សាវត្ថិយំ វស្សាវាសោ ឥច្ឆាមហំ ភន្តេ ជនបទចារិកំ បក្កមិតុន្តិ ។ យស្សទានិ ត្វំ សារីបុត្ត កាលំ មញ្ញសីតិ ។ អថខោ សោ អាយស្មា សារីបុត្តោ ឧដ្ឋាយាសនា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា បក្កាមិ ។ អថខោ អញ្ញតរោ ភិក្ខុ អចិរប្បក្កន្តេ អាយស្មន្តេ សារីបុត្តេ ភគវន្តំ ឯតទវោច

# បណ្ណាសក សីហនាទវគ្គ

[១១] សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅ ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះ ព្រះសារីបុត្ត ដ៏មានអាយុ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះ ព្រះសារីបុត្តដ៏មានអាយុ អង្គុយក្នុងទីសមគួរហើយ បានក្រាបបង្គំទូល ព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ការនៅចាំវស្សា ក្នុងក្រុងសាវត្ថី ខ្ញុំព្រះអង្គនៅរួចហើយ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ខ្ញុំព្រះអង្គប្រាថ្នា ដើម្បីទៅកាន់ចារិកក្នុងជនបទ ។ ព្រះអង្គត្រាស់ថា ម្នាលសារីបុត្ត ចូរអ្នកសម្គាល់នូវកាលគួរ ក្នុងកាលឥឡូវនេះចុះ ។ លំដាប់នោះ ព្រះសារីបុត្តដ៏មានអាយុនោះ ក្រោកចាកអាសនៈ ថ្វាយបង្គំលាព្រះដ៏មានព្រះភាគ ធ្វើប្រទក្សិណហើយចៀសចេញទៅ ។ លំដាប់នោះ កាលព្រះសារីបុត្តដ៏មានអាយុ ចៀសចេញទៅមិន យូរប៉ុន្មាន ភិក្ខុ ១ រូប បានក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា

បណ្ណាសកេ សីហនាទវគ្គោ

អាយស្មា មំ ភន្តេ សារីបុត្តោ អាសជ្ជ[១] អប្ប-ដិនិស្សជ្ជ ចារិកំ បក្កន្តោតិ ។ អថខោ ភគវា អញ្ញតរំ ភិក្ខុំ អាមន្តេសិ ឯហិ ត្វំ ភិក្ខុ មម វចនេន សារីបុត្តំ អាមន្តេសិ សត្ថា តំ អាវុសោ សារីបុត្ត អាមន្តេតីតិ ។ ឯវំ ភន្តេតិ ខោ សោ ភិក្ខុ ភគវតោ បដិស្សុត្វា យេនាយស្មា សារីបុត្តោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ សារីបុត្តំ ឯតទវោច សត្ថា តំ អាវុសោ សារីបុត្ត អាម-ន្តេតីតិ ។ ឯវមាវុសោតិ ខោ អាយស្មា សារីបុត្តោ តស្ស ភិក្ខុនោ បច្ចស្សោសិ ។ តេន ខោ បន សមយេន អាយស្មា ច មហាមោគ្គល្លានោ អាយស្មា ច អានន្ទោ អបាបុរណំ អាទាយ វិហារំ អាហិណ្ឌន្តិ អភិក្កមថាយស្មន្តោ អភិក្កមថាយស្មន្តោ

១ អាបជ្ជាតីបិ បាឋោ ទិស្សតិ ។

បពិត្រព្រះអង្គដ៏ចម្រើន ព្រះសារីបុត្តដ៏មានអាយុ បានប៉ះ[១] ខ្ញុំព្រះអង្គ មិនបានខមាទោស ហើយចៀសចេញទៅកាន់ចារិក ។ លំដាប់នោះ ព្រះដ៏មានព្រះភាគ ត្រាស់ហៅភិក្ខុ ១ រូប មកថា ម្នាលភិក្ខុ អ្នកចូរមកអាយ ចូរទៅហៅសារីបុត្តតាមពាក្យតថាគតថា ម្នាលអាវុសោសារីបុត្ត ព្រះសាស្តាទ្រង់ត្រាស់ហៅលោក ។ ភិក្ខុនោះទទួលព្រះពុទ្ធដីកា នៃព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ហើយក៏ចូលទៅរកព្រះសារីបុត្តដ៏មានអាយុ លុះចូលទៅដល់ហើយ បាននិយាយនឹងព្រះសារីបុត្តដ៏មានអាយុ ដូច្នេះថា ម្នាលអាវុសោសារីបុត្ត ព្រះសាស្តាទ្រង់ត្រាស់ហៅលោក ។ ព្រះសារីបុត្តដ៏មានអាយុ ទទួលពាក្យភិក្ខុនោះថា ករុណាអាវុសោ ។ សម័យនោះឯង ព្រះមហាមោគ្គល្លានដ៏មានអាយុ និងព្រះអានន្ទ ដ៏មានអាយុ កាន់យកនូវកូនសោ ដើរចូលទៅកាន់វិហារហើយនិយាយថា លោកដ៏មានអាយុទាំងឡាយ ចូរទៅឆាប់ លោកដ៏មានអាយុទាំងឡាយ ចូរទៅឆាប់

---

១ មានតំណាលថា កាលព្រះសារីបុត្តថ្វាយបង្គំលា ព្រះទសពលញ្ញាណ ហើយថយចេញពីទីនោះទៅ ជាយចីវរលោកក៏បក់ទៅប៉ះសរីរៈភិក្ខុនោះបន្តិច ព្រោះហេតុនោះបានជាភិក្ខុនោះចងគំនុំ លុះឃើញព្រះសារីបុត្តមានភិក្ខុបរិវារចោមរោមច្រើន ក៏យកសេចក្តីនោះក្រាបបង្គំទូលព្រះ ដើម្បីធ្វើឲ្យអាក់ខានដំណើរនោះ ដោយសេចក្តីក្រោធ ។ អដ្ឋកថា ។

ឥទានាយស្មា សារីបុត្តោ ភគវតោ សម្មុខា សីហ-
នាទំ នទិស្សតីតិ ។ អថខោ អាយស្មា សារីបុត្តោ
យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ
អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ
ខោ អាយស្មន្តំ សារីបុត្តំ ភគវា ឯតទវោច ឥធ តេ
សារីបុត្ត អញ្ញតរោ សព្រហ្មចារី ខីយធម្មំ អាបន្នោ
អាយស្មា មំ ភន្តេ សារីបុត្តោ អាសជ្ជ អប្បដិ-
និស្សជ្ជ ចារិកំ បក្កន្តោតិ ។ យស្ស នូន ភន្តេ
កាយេ កាយគតា សតិ អនុបដ្ឋិតា អស្ស សោ
ឥធ អញ្ញតរំ សព្រហ្មចារឹ អាសជ្ជ អប្បដិនិស្សជ្ជ
ចារិកំ បក្កមេយ្យ សេយ្យថាបិ ភន្តេ បឋវិយំ សុចិម្បិ
និក្ខិបន្តិ អសុចិម្បិ និក្ខិបន្តិ គូថគតម្បិ និក្ខិបន្តិ
មុត្តគតម្បិ និក្ខិបន្តិ ខេឡគតម្បិ និក្ខិបន្តិ បុព្វគតម្បិ
និក្ខិបន្តិ លោហិតគតម្បិ និក្ខិបន្តិ ន ច តេន បឋវី
អដ្ដីយតិ វា ហរាយតិ វា ជិគុច្ឆតិ វា ឯវមេវ ខោ
អហំ ភន្តេ បឋវីសមេន ចេតសា វិហរាមិ វិបុលេន
មហគ្គតេន អប្បមាណេន អវេរេន អព្យាបជ្ជេន

ដ្បិតព្រះសារីបុត្តដ៏មានអាយុ នឹងបន្លឺនូវសីហនាទ ចំពោះព្រះភក្ត្រ នៃព្រះដ៏មានព្រះភាគក្នុងកាលឥឡូវនេះ ។ គ្រានោះ ព្រះសារីបុត្ត ដ៏មានអាយុ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ក្រាប ថ្វាយបង្គំ ព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះ ព្រះសារីបុត្តដ៏មានអាយុ អង្គុយក្នុងទីដ៏សមគួរហើយ ព្រះដ៏មានព្រះភាគ បានត្រាស់ដូច្នេះថា ម្នាលសារីបុត្ត ក្នុងទីនេះ មានសព្រហ្មចារី ១ រូប អាក់អន់ចិត្តនឹងអ្នកថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះសារីបុត្តដ៏មានអាយុ បានប៉ះខ្ញុំព្រះអង្គ មិនបានខមាទោស ហើយចៀសចេញទៅកាន់ ចារិក ។ ព្រះសារីបុត្តក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន កាយ-គតាសតិ ដែលបុគ្គលណាមិនបានតាំងទុកក្នុងកាយហើយ បុគ្គលនោះ ប៉ះ សព្រហ្មចារីណាមួយក្នុងលោកនេះ មិនបានខមាទោស ហើយ ចៀសចេញទៅកាន់ចារិក បពិត្រព្រះអង្គដ៏ចម្រើន ពួកអ្នកផងដាក់វត្ថុ ស្អាតក្តី ដាក់វត្ថុមិនស្អាតក្តី ដាក់លាមកក្តី ដាក់មូត្រក្តី ដាក់ទឹកមាត់ក្តី ដាក់ខ្ទុះក្តី ដាក់ឈាមក្តី លើផែនដី ផែនដីមិនធុញទ្រាន់ មិននឿយ ណាយ មិនខ្ពើមរអើម ដោយវត្ថុនោះទេ យ៉ាងណាមិញ បពិត្រ ព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមានចិត្តស្មើដោយផែនដី ជាចិត្តទូលាយ ប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ យ៉ាងនោះឯង ។

៤៧



យស្ស នូន ភន្តេ កាយេ កាយគតា សតិ អនុបដ្ឋិតា អស្ស សោ ឥធ អញ្ញតរំ សព្រហ្មចារឹ អាសជ្ជ អប្បដិនិស្សជ្ជ ចារិកំ បក្កមេយ្យ ។ សេយ្យថាបិ ភន្តេ អាបស្មឹ សុចិម្បិ ធោវន្តិ អសុចិម្បិ ធោវន្តិ គូថគតម្បិ មុត្តគតម្បិ ខេឡគតម្បិ បុព្វគតម្បិ លោហិតគតម្បិ ធោវន្តិ ន ច តេន អាបោ អដ្ដីយតិ វា ហរាយតិ វា ជិគុច្ឆតិ វា ឯវមេវ ខោ អហំ ភន្តេ អាបោសមេន ចេតសា វិហរាមិ វិបុលេន មហគ្គតេន អប្បមាណេន អវេរេន អព្យាបជ្ជេន ។ យស្ស នូន ភន្តេ កាយេ កាយគតា សតិ អនុបដ្ឋិតា អស្ស សោ ឥធ អញ្ញតរំ សព្រហ្មចារឹ អាសជ្ជ អប្បដិនិស្សជ្ជ ចារិកំ បក្កមេយ្យ ។ សេយ្យថាបិ ភន្តេ តេជោ សុចិម្បិ ឌហតិ អសុចិម្បិ ឌហតិ គូថគតម្បិ មុត្តគតម្បិ ខេឡគតម្បិ បុព្វគតម្បិ លោហិតគតម្បិ ឌហតិ ន ច តេន តេជោ អដ្ដីយតិ វា ហរាយតិ វា ជិគុច្ឆតិ វា

បពិត្រព្រះអង្គដ៏ចម្រើន កាយគតាសតិ ដែលបុគ្គលណាមិនបានតាំងទុកហើយ ក្នុងកាយដោយពិត បុគ្គលនោះ ប៉ះ សព្រហ្មចារីណាមួយក្នុងលោកនេះ មិនបានខមាទោស គប្បីចៀសចេញទៅកាន់ចារិក ។ បពិត្រព្រះអង្គដ៏ចម្រើន ពួកអ្នកផង លាងវត្ថុស្អាតក្តី លាងវត្ថុមិនស្អាតក្តី លាងលាមកក្តី មូត្រក្តី ទឹកមាត់ក្តី ខ្ទុះក្តី ឈាមក្តី ក្នុងទឹក ទឹករមែងមិនធុញទ្រាន់ ឬនឿយណាយ ឬក៏ខ្ពើមរអើមដោយវត្ថុនោះទេ យ៉ាងណាមិញ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមានចិត្តស្មើដោយទឹក ជាចិត្តធំទូលាយ ប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ក៏យ៉ាងនោះឯង ។ បពិត្រព្រះអង្គដ៏ចម្រើន កាយគតាសតិ ដែលបុគ្គលណាមិនបានតាំងទុកហើយ ក្នុងកាយដោយពិត បុគ្គលនោះ ប៉ះ សព្រហ្មចារីណាមួយក្នុងលោកនេះ មិនបានខមាទោស គប្បីចៀសចេញទៅកាន់ចារិក ។ បពិត្រព្រះអង្គដ៏ចម្រើន ភ្លើងតែងឆេះវត្ថុស្អាតក្តី ឆេះវត្ថុមិនស្អាតក្តី ឆេះលាមកក្តី មូត្រក្តី ទឹកមាត់ក្តី ខ្ទុះក្តី ឈាមក្តី ភ្លើងរមែងមិនធុញទ្រាន់ឬនឿយណាយ ឬក៏ខ្ពើមរអើមដោយវត្ថុនោះ យ៉ាងណា

ឯវមេវ ខោ អហំ ភន្តេ តេជោសមេន ចេតសា វិហរាមិ វិបុលេន មហគ្គតេន អប្បមាណេន អវេរេន អព្យាបជ្ជេន ។ យស្ស នូន ភន្តេ កាយេ កាយ-គតា សតិ អនុបដ្ឋិតា អស្ស សោ ឥធ អញ្ញតរំ សព្រហ្មចារឹ អាសជ្ជ អប្បដិនិស្សជ្ជ ចារិកំ បក្កា-មេយ្យ ។ សេយ្យថាបិ ភន្តេ វាយោ សុចិម្បិ ឧបវាយតិ អសុចិម្បិ ឧបវាយតិ គូថគតម្បិ មុត្តគតម្បិ ខេឡគតម្បិ បុព្វគតម្បិ លោហិតគតម្បិ ឧបវាយតិ ន ច តេន វាយោ អដ្ដីយតិ វា ហរាយតិ វា ជិគុច្ឆតិ វា ឯវមេវ ខោ អហំ ភន្តេ វាយោសមេន ចេតសា វិហរាមិ វិបុលេន មហគ្គតេន អប្បមាណេន អវេរេន អព្យា-បជ្ជេន ។ យស្ស នូន ភន្តេ កាយេ កាយគតា សតិ អនុបដ្ឋិតា អស្ស សោ ឥធ អញ្ញតរំ សព្រហ្ម-ចារឹ អាសជ្ជ អប្បដិនិស្សជ្ជ ចារិកំ បក្កមេយ្យ ។

បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមានចិត្តស្មើដោយភ្លើង ជាចិត្តធំទូលាយ ប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ក៏យ៉ាងនោះឯង ។ បពិត្រព្រះអង្គដ៏ចម្រើន កាយគតាសតិ ដែលបុគ្គលណា មិនបានតាំងទុកហើយ ក្នុងកាយដោយពិត បុគ្គលនោះ ប៉ះ សព្រហ្មចារីណាមួយ ក្នុងលោកនេះ ហើយមិនបានខមាទោស គប្បីចៀសចេញទៅកាន់ចារិក ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្យល់បក់វត្ថុស្អាតក្តី បក់វត្ថុមិនស្អាតក្តី បក់លាមកក្តី មូត្រក្តី ទឹកមាត់ក្តី ខ្ទុះក្តី ឈាមក្តី ខ្យល់រមែងមិនធុញទ្រាន់ ឬនឿយណាយ ឬក៏ខ្ពើមរអើមដោយវត្ថុនោះ យ៉ាងណាមិញ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមានចិត្ត ស្មើដោយខ្យល់ ជាចិត្តធំទូលាយ ប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ក៏យ៉ាងនោះឯង ។ បពិត្រព្រះអង្គដ៏ចម្រើន កាយគតាសតិ ដែលបុគ្គលណា មិនបានតាំងទុកក្នុងកាយដោយពិត បុគ្គលនោះ ប៉ះ សព្រហ្មចារីណាមួយក្នុងលោកនេះ មិនបានខមាទោស គប្បីចៀសចេញទៅកាន់ចារិក ។

៤៩



សេយ្យថាបិ ភន្តេ រជោហរណំ សុចិម្បិ មុញ្ចតិ អសុចិម្បិ មុញ្ចតិ គូថគតម្បិ មុត្តគតម្បិ ខេឡគតម្បិ បុព្វគតម្បិ លោហិតគតម្បិ មុញ្ចតិ ន ច តេន រជោហរណំ អដ្ដីយតិ វា ហរាយតិ វា ជិគុច្ឆតិ វា ឯវមេវ ខោ អហំ ភន្តេ រជោហរណសមេន ចេតសា វិហរាមិ វិបុលេន មហគ្គតេន អប្បមា-ណេន អវេរេន អព្យាបជ្ឈេន ។ យស្ស នូន ភន្តេ កាយេ កាយគតា សតិ អនុបដ្ឋិតា អស្ស សោ ឥធ អញ្ញតរំ សព្រហ្មចារឹ អាសជ្ជ អប្បដិនិស្សជ្ជ ចារិកំ បក្កមេយ្យ ។ សេយ្យថាបិ ភន្តេ ចណ្ឌាល-កុមារកោ វា ចណ្ឌាលកុមារិកា វា កឡោបិ-ហត្ថោ នន្តកវាសី គាមំ វា និគមំ វា បវិសន្តោ នីចចិត្តំយេវ ឧបដ្ឋបេត្វា បវិសតិ ឯវមេវ ខោ អហំ ភន្តេ ចណ្ឌាលកុមារកសមេន ចេតសា វិហរាមិ វិបុលេន មហគ្គតេន អប្បមាណេន អវេរេន អព្យាបជ្ឈេន ។

បណ្ណាសក សីហនាទវគ្គ

បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលជូតវត្ថុ ស្អាតក្តី ជូតវត្ថុមិនស្អាតក្តី ជូតលាមកក្តី មូត្រក្តី ទឹកមាត់ក្តី ខ្ទុះក្តី ឈាមក្តី ដោយសំពត់សម្រាប់ជូតធូលីៗ រមែងមិនធុញទ្រាន់ ឬនឿយណាយ ឬក៏ខ្ពើមរអើមនឹងវត្ថុនោះទេ យ៉ាងណាមិញ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមានចិត្តស្មើដោយសំពត់សម្រាប់ជូតធូលី ជាចិត្តធំទូលាយ ប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ក៏យ៉ាងនោះឯង ។ បពិត្រព្រះអង្គដ៏ចម្រើន កាយគតាសតិ ដែលបុគ្គលណា មិនបានតាំងទុកក្នុងកាយដោយពិត បុគ្គលនោះ ប៉ះសព្រហ្មចារីណាមួយ ក្នុងលោកនេះ មិនបានខមាទោស គប្បីចៀសចេញទៅកាន់ចារិក ។ បពិត្រព្រះអង្គដ៏ចម្រើន ចណ្ឌាលកុមារក្តី ចណ្ឌាលកុមារីក្តី មានដៃកាន់កញ្ជើ ស្លៀកពាក់សំពត់រេចរោយ ចូលទៅកាន់ស្រុកក្តី និគមក្តី រមែងដាក់ចិត្តឲ្យទាប ហើយចូលទៅ យ៉ាងណាមិញ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមានចិត្តស្មើដោយចណ្ឌាលកុមារ ជាចិត្តធំទូលាយ ប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ក៏យ៉ាងនោះដែរ ។

យស្ស នូន ភន្តេ កាយេ កាយគតា សតិ អនុបដ្ឋិតា អស្ស សោ ឥធ អញ្ញតរំ សព្រហ្មចារឹ អាសជ្ជ អប្បដិនិស្សជ្ជ ចារិកំ បក្កមេយ្យ ។ សេយ្យថាបិ ភន្តេ ឧសភោ ឆិន្នវិសាណោ សុរតោ សុទន្តោ សុសិក្ខិតោ(១) រថិយាយ រថិយំ សិង្ឃាដកេន សិង្ឃាដកំ អន្វាហិណ្ឌន្តោ ន កិញ្ចិ ហឹសតិ បាទេន វា វិសាណេន វា ឯវមេវ ខោ អហំ ភន្តេ ឧសភឆិន្ន-វិសាណសមេន ចេតសា វិហរាមិ វិបុលេន មហគ្គតេន អប្បមាណេន អវេរេន អព្យាបជ្ជេន ។ យស្ស នូន ភន្តេ កាយេ កាយគតា សតិ អនុបដ្ឋិតា អស្ស សោ ឥធ អញ្ញតរំ សព្រហ្មចារឹ អាសជ្ជ អប្បដិនិស្សជ្ជ ចារិកំ បក្កមេយ្យ ។ សេយ្យថាបិ ភន្តេ ឥត្ថី វា បុរិសោ វា ទហរោ វា យុវា វា មណ្ឌនកជាតិកោ(២) អហិកុណបេន វា កុក្កុរកុណបេន វា(៣) កណ្ឋេ អាលគ្គេន(៤) អដ្ដិយេយ្យ ហរាយេយ្យ ជិគុច្ឆេយ្យ

១ ឱ. ម សុវិនីតោ ។ ២ ឱ. ឯត្ថន្តរេ សីសំ នហាតោតិ បាឋោ អត្ថិ ។ ៣ ឱ. ម. ឯត្ថន្តរេ មនុស្សកុណបេន វាតិ បាឋោ អត្ថិ ។ ៤ ឱ. ម. អ

បពិត្រព្រះអង្គដ៏ចម្រើន កាយគតាសតិ ដែលបុគ្គលណា មិនបាន តាំងទុក ក្នុងកាយដោយពិត បុគ្គលនោះ ប៉ះសព្រហ្មចារីណាមួយ ក្នុងលោកនេះ មិនបានខមាទោស គប្បីចៀសចេញទៅកាន់ចារិក ។ បពិត្រព្រះអង្គដ៏ចម្រើន គោឧសភ បាក់ស្នែងជាសត្វស្លូត ដែលគេទូន្មានហើយ បង្ហាត់ល្អហើយ ដើរទៅកាន់ច្រកតាមច្រក ដើរទៅកាន់ផ្លូវបែក តាមផ្លូវបែក មិនដែលបៀតបៀនអ្វីៗ ដោយជើងក្តី ដោយស្នែងក្តី យ៉ាងណាមិញ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមានចិត្តស្មើដោយគោឧសភបាក់ស្នែង ជាចិត្តធំ ទូលាយ ប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ក៏យ៉ាងនោះឯង ។ បពិត្រព្រះអង្គដ៏ចម្រើន កាយគតាសតិ ដែលបុគ្គលណា មិនបានតាំងទុកហើយ ក្នុងកាយដោយពិត បុគ្គលនោះ ប៉ះសព្រហ្មចារីណាមួយ ក្នុងលោកនេះ មិនបានខមាទោស គប្បីចៀសចេញទៅកាន់ចារិក ។ បពិត្រព្រះ ព្រះអង្គដ៏ចម្រើន ស្ត្រី ឬបុរសកំលោះ ឬជំទង់ ប្រកបដោយជាតិជាអ្នកស្អិតស្អាង គប្បីធុញទ្រាន់ នឿយណាយ ខ្ពើមរអើម នឹងសាក-សពពស់ ឬសាកសពកូនសុនខ ដែលជាប់ត្រង់ក យ៉ាងណាមិញ

៤១

បណ្ណាសកេ សីហនាទវគ្គោ

ឯវមេវ ខោ អហំ ភន្តេ ឥមិនា បូតិកាយេន អដ្ដិយាមិ ហរាយាមិ ជិគុច្ឆាមិ ។ យស្ស នូន ភន្តេ កាយេ កាយគតា សតិ អនុបដ្ឋិតា អស្ស សោ ឥធ អញ្ញតរំ សព្រហ្មចារឹ អាសជ្ជ អប្បដិនិស្សជ្ជ ចារិកំ បក្ក-មេយ្យ ។ សេយ្យថាបិ ភន្តេ បុរិសោ មេទកថាលិកំ បរិហរេយ្យ ឆិទ្ទាវឆិទ្ទំ ឧគ្ឃរន្តំ បគ្ឃរន្តំ ឯវមេវ ខោ អហំ ភន្តេ ឥមំ កាយំ បរិហរាមិ ឆិទ្ទាវឆិទ្ទំ ឧគ្ឃរន្តំ បគ្ឃរន្តំ ។ យស្ស នូន ភន្តេ កាយេ កាយគតា សតិ អនុបដ្ឋិតា អស្ស សោ ឥធ អញ្ញតរំ សព្រហ្មចារឹ អាសជ្ជ អប្បដិនិស្សជ្ជ ចារិកំ បក្កមេយ្យាតិ ។ អថខោ សោ ភិក្ខុ ឧដ្ឋាយាសនា ឯកំសំ ឧត្តរាសង្គំ ករិត្វា ភគវតោ បាទេសុ សិរសា និបតិត្វា ភគវន្តំ ឯតទវោច អច្ចយោ មំ ភន្តេ អច្ចគមា យថាពាលំ យថាមូឡ្ហំ យថាអកុសលំ

បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គ រមែងធុញទ្រាន់ នឿយណាយ ខ្ពើមរអើម នឹងកាយស្អុយនេះ ក៏យ៉ាងនោះឯង ។ បពិត្រព្រះអង្គដ៏ចម្រើន កាយគតាសតិ ដែលបុគ្គលណា បានតាំងទុកក្នុងកាយដោយពិត បុគ្គលនោះ ប៉ះសព្រហ្មចារីណាមួយ ក្នុងលោកនេះ មិនបានខមាទោស គប្បីចៀសចេញទៅកាន់ចារិក ។ បពិត្រព្រះអង្គដ៏ចម្រើន បុរសរក្សាភាជន៍សម្រាប់ដាក់ខ្លាញ់ ដែលមានរន្ធតូច-ធំ ហូរចេញចូល យ៉ាងណាមិញ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គរក្សានូវកាយនេះ ដែលមានរន្ធតូច-ធំ ហូរចេញចូល ក៏យ៉ាងនោះឯង ។ បពិត្រព្រះអង្គដ៏ចម្រើន កាយគតាសតិ ដែលបុគ្គលណាបានតាំងទុកក្នុងកាយដោយពិត បុគ្គលនោះ ប៉ះសព្រហ្មចារីណាមួយក្នុងលោកនេះ មិនបានខមាទោស គប្បីចៀសចេញទៅកាន់ចារិក ។ លំដាប់នោះ ភិក្ខុនោះ ក្រោកចាកអាសនៈ ធ្វើសំពត់ឧត្តរាសង្គៈឆៀងស្មាម្ខាង ក្រាបចុះទៀបព្រះបាទទាំងគូ របស់ព្រះដ៏មានព្រះភាគ ដោយក្បាល ហើយក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ទោសដែលប្រព្រឹត្តកន្លងហើយ នូវខ្ញុំព្រះអង្គ ព្រោះជាមនុស្សពាល ជាមនុស្សវង្វេង ជាមនុស្សមិនឈ្លាស យ៉ាងណា

យោ អហំ អាយស្មន្តំ សារីបុត្តំ អសតា តុច្ឆា មុសា អភូតេន អព្ភាចិក្ខឹ តស្ស មេ ភន្តេ ភគវា អច្ចយំ អច្ចយតោ បដិគ្គណ្ហាតុ អាយតឹ សំវរាយាតិ ។ តគ្ឃតំ ភិក្ខុ អច្ចយោ អច្ចគមា យថា-ពាលំ យថាមូឡ្ហំ យថាអកុសលំ យោ តំ សារីបុត្តំ អសតា តុច្ឆា មុសា អភូតេន អព្ភាចិក្ខិ យតោ ច ខោ តំ ភិក្ខុ អច្ចយំ អច្ចយតោ ទិស្វា យថាធម្មំ បដិករោសិ តន្តេ មយំ បដិគ្គណ្ហាម វុឌ្ឍិ ហេសា ភិក្ខុ អរិយស្ស វិនយេ យោ អច្ចយំ អច្ចយតោ ទិស្វា យថាធម្មំ បដិករោតិ អាយតឹ សំវរំ អាបជ្ជតីតិ ។ អថខោ ភគវា អាយស្មន្តំ សារីបុត្តំ អាមន្តេសិ ខម សារីបុត្ត ឥមស្ស មោឃបុរិសស្ស បុរាយំ តត្ថេវ សត្តធា មុទ្ធា ផលិស្សតីតិ ។ ខមាមហំ ភន្តេ តស្ស អាយស្មតោ សចេ មមំ សោ អាយស្មា ឯវមាហ ខមតុ ច មេ សោ អាយស្មាតិ ។

ខ្ញុំព្រះអង្គណា និយាយបង្កាច់ព្រះសារីបុត្តដ៏មានអាយុ ដោយពាក្យមិនមែន ជាពាក្យទទេ ជាពាក្យកុហក មិនពិត បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះដ៏មានព្រះភាគ អត់ទោសតាមទោស ដល់ខ្ញុំព្រះអង្គនោះដើម្បីសង្រួមតទៅ ។ ម្នាលភិក្ខុ អើទោសកំហុស ដែលប្រព្រឹត្តកន្លងនូវអ្នក ព្រោះជាមនុស្សពាល ជាមនុស្សល្ងង់ ជាមនុស្សមិនឈ្លាសយ៉ាងណា អ្នកពោលបង្កាច់សារីបុត្ត ដោយពាក្យមិនមែន ជាពាក្យទទេ កុហកមិនពិត ម្នាលភិក្ខុ កាលណាបើអ្នក ឃើញទោសតាមទោស ដែលប្រព្រឹត្តកន្លងហើយ ត្រឡប់ធ្វើឲ្យត្រូវតាមធម៌វិញ តថាគតក៏អត់ទោសអ្នក បើបុគ្គលណាឃើញទោសតាមទោស ដែលប្រព្រឹត្តកន្លងហើយ ត្រឡប់ធ្វើឲ្យត្រូវតាមធម៌វិញ ដល់នូវការសង្រួមតទៅ ម្នាលភិក្ខុ នេះជាសេចក្តីចម្រើន ក្នុងវិន័យរបស់ព្រះអរិយៈ ។ លំដាប់នោះព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហៅព្រះសារីបុត្តដ៏មានអាយុថា ម្នាលសារីបុត្ត លោកចូរអត់ទោសដល់មោឃបុរសនេះចុះ ដ្បិតមោឃបុរសនេះ នឹងបែកក្បាលជា ៧ ភាគ ក្នុងទីនោះឯង ។ ព្រះសារីបុត្តក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គអត់ទោសដល់លោកដ៏មានអាយុនោះ បើលោកដ៏មានអាយុនោះ និយាយនឹងខ្ញុំព្រះអង្គយ៉ាងនេះ សូមលោកដ៏មានអាយុនោះ អត់ទោសខ្ញុំព្រះអង្គវិញ ។

[១២] ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ អថខោ អាយស្មា សារីបុត្តោ បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ សាវត្ថឹ បិណ្ឌាយ បាវិសិ ។ អថខោ អាយស្មតោ សារីបុត្តស្ស ឯត-ទហោសិ អតិប្បគោ ខោ តាវ សាវត្ថិយំ បិណ្ឌាយ ចរិតុំ យន្នូនាហំ យេន អញ្ញតិត្ថិយានំ បរិព្វាជកានំ អារាមោ តេនុបសង្កមេយ្យន្តិ ។ អថខោ អាយស្មា សារីបុត្តោ យេន អញ្ញតិត្ថិយានំ បរិព្វាជកានំ អារាមោ តេនុបសង្កមិ ឧបសង្កមិត្វា តេហិ អញ្ញតិត្ថិយេហិ បរិព្វាជកេហិ សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ តេន ខោ បន សមយេន តេសំ អញ្ញតិត្ថិយានំ បរិព្វាជកានំ សន្និសិន្នានំ សន្និបតិ-តានំ អយមន្តរាកថា ឧទបាទិ យោ ហិ កោចិ អាវុសោ សឧបាទិសេសោ កាលំ ករោតិ សព្វោ សោ អបរិមុត្តោ និរយា អបរិមុត្តោ តិរច្ឆានយោនិយា

បណ្ណាសក សីហនាទវគ្គ

[១២] សម័យមួយ ព្រះដ៏មានព្រះភាគ កាលគង់នៅ ក្នុងវត្ត ជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះ ព្រះសារីបុត្តដ៏មានអាយុ ស្លៀកស្បង់ប្រដាប់បាត្រនិងចីវរក្នុងបុព្វណ្ហសម័យ ចូលទៅបិណ្ឌបាតក្នុងក្រុងសាវត្ថី ។ លំដាប់នោះ ព្រះសារីបុត្តដ៏មានអាយុ មានសេចក្តីត្រិះរិះដូច្នេះថា ការត្រាច់ទៅបិណ្ឌបាតក្នុងក្រុងសាវត្ថី នៅព្រឹកនៅឡើយ បើដូច្នោះគួរអាត្មាអញ ចៀងចូលទៅឯអារាមពួកអន្យតិរ្ថិយបរិព្វាជកសិន ។ ទើបព្រះសារីបុត្តដ៏មានអាយុ ចៀងចូលទៅឯអារាម របស់ពួកអន្យតិត្ថិយបរិព្វាជក លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយទៅរកពួកអន្យតិត្ថិយបរិព្វាជក លុះបញ្ចប់ពាក្យ ដែលគួររីករាយនិងពាក្យដែលគួររលឹកហើយ ក៏អង្គុយក្នុងទីសមគួរ ។ សម័យនោះឯង អន្តរាកថានេះ កើតដល់ពួកអន្យតិរ្ថិយបរិព្វាជក ដែលកំពុងអង្គុយប្រជុំគ្នាទាំងនោះថា ម្នាលអាវុសោទាំងឡាយ បុគ្គលណានីមួយ ជាសឧបាទិសេស ធ្វើមរណកាលទៅ បុគ្គលទាំងអស់នោះ មិនដែលផុតអំពីនរក មិនផុតអំពីកំណើតតិរច្ឆាន

អបរិមុត្តោ បិត្តិវិសយា អបរិមុត្តោ អចាយទុគ្គតិវិនិចា-
តាតិ ។ អថខោ អាយស្មា សារីបុត្តោ តេសំ អញ្ញតិត្ថិ-
យានំ បរិព្វាជកានំ ភាសិតំ នេវ អភិនន្ទិ នប្បដិ-
ក្កោសិ អនភិនន្ទិត្វា អប្បដិក្កោសិត្វា ឧដ្ឋាយាសនា
បក្កាមិ ភគវតោ សន្តិកេ ឯតស្ស ភាសិតស្ស អត្ថំ
អាជានិស្សាមីតិ ។ អថខោ អាយស្មា សារីបុត្តោ
សាវត្ថិយំ បិណ្ឌាយ ចរិត្វា បច្ឆាភត្តំ បិណ្ឌាចាតប្ប-
ដិក្កន្តោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា
ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ
និសិន្នោ ខោ អាយស្មា សារីបុត្តោ ភគវន្តំ ឯត-
ទវោច ឥធាហំ ភន្តេ បុព្វណ្ហសមយំ និវាសេត្វា
បត្តចីវរមាទាយ សាវត្ថឹ បិណ្ឌាយ ចាវិសឹ ។ តស្ស
មយ្ហំ ភន្តេ ឯតទហោសិ អតិប្បគោ ខោ តាវ
សាវត្ថិយំ បិណ្ឌាយ ចរិតុំ យន្នូនាហំ យេន អញ្ញតិត្ថិ-
យានំ បរិព្វាជកានំ អារាមោ តេនុបសង្កមេយ្យន្តិ ។

មិនផុតអំពីបិត្តិវិស័យ មិនផុតអំពីអបាយ ទុគ្គតិ និងវិនិបាតទេ ។ គ្រានោះ ព្រះសារីបុត្តដ៏មានអាយុ មិនត្រេកអរ មិនជំទាស់នឹងភាសិត របស់អន្យតិរ្ថិយបរិព្វាជកទាំងនោះ លុះមិនត្រេកអរ មិនជំទាស់ហើយ ទើបក្រោកចាកអាសនៈ ចៀសចេញទៅ ដោយគិតថា អាត្មាអញនឹងដឹងនូវសេចក្តីនៃភាសិតនេះ ក្នុងសំណាក់នៃព្រះដ៏មានព្រះភាគ ។ លំដាប់នោះ ព្រះសារីបុត្តដ៏មានអាយុ ចូលទៅបិណ្ឌបាតក្នុងក្រុងសាវត្ថី លុះត្រឡប់អំពីបិណ្ឌបាត ក្នុងវេលាខាងក្រោយភត្តហើយ ក៏ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគហើយអង្គុយក្នុងទីសមគួរ ។ លុះព្រះសារីបុត្តដ៏មានអាយុ អង្គុយក្នុងទីសមគួរហើយ បានក្រាបបង្គំទូលព្រះដ៏មានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ក្នុងទីឯណោះ ខ្ញុំព្រះអង្គស្លៀកស្បង់ប្រដាប់បាត្រនិងចីវរ ក្នុងបុព្វណ្ហសម័យ ដើម្បីចូលទៅបិណ្ឌបាតក្នុងក្រុងសាវត្ថី ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមានសេចក្តីត្រិះរិះ ដូច្នេះថា ការចូលទៅបិណ្ឌបាតក្នុងក្រុងសាវត្ថី នៅព្រឹកនៅឡើយ បើដូច្នោះគួរតែអាត្មាអញឈៀងចូលទៅឯអារាម របស់ពួកអន្យតិរ្ថិយបរិព្វាជកសិន ។

៥៥



អថខោហំ ភន្តេ យេន អញ្ញតិត្ថិយានំ បរិព្វាជកានំ អារាមោ តេនុបសង្កមឹ ឧបសង្កមិត្វា តេហិ អញ្ញតិត្ថិ-
យេហិ បរិព្វាជកេហិ សទ្ធឹ សម្មោទឹ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទឹ ។ តេន ខោ បន សមយេន តេសំ អញ្ញតិត្ថិយានំ បរិព្វា-
ជកានំ សន្និសិន្នានំ សន្និបតិតានំ អយមន្តរាកថា ឧទបាទិ យោ ហិ កោចិ អាវុសោ សឧបាទិសេសោ កាលំ ករោតិ សព្វោ សោ អបរិមុត្តោ និរយា អបរិមុត្តោ តិរច្ឆានយោនិយា អបរិមុត្តោ បិត្តិវិសយា អបរិមុត្តោ អបាយទុគ្គតិវិនិបាតាតិ ។ អថខោហំ ភន្តេ តេសំ អញ្ញតិត្ថិយានំ បរិព្វាជកានំ ភាសិតំ នេវ អភិនន្ទឹ នប្បដិក្កោសឹ អនភិនន្ទិត្វា អប្បដិក្កោសិត្វា ឧដ្ឋាយាសនា បក្កាមឹ ភគវតោ សន្តិកេ ឯតស្ស ភាសិតស្ស អត្ថំ អាជានិស្សាមីតិ ។ កេចិ សារីបុត្ត អញ្ញតិត្ថិយា បរិព្វាជកា ពាលា អព្យត្តា កេចិ សឧបាទិសេសំ វា សឧបាទិសេសោតិ ជានិស្សន្តិ

បពិត្រព្រះអង្គដ៏ចម្រើន ទើបខ្ញុំព្រះអង្គចៀងចូលទៅឯអារាម របស់ពួកអន្យតិរ្ថិយបរិព្វាជក លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយទៅរកអន្យតិរ្ថិយបរិព្វាជកទាំងនោះ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររលឹកហើយ ក៏អង្គុយក្នុងទីសមគួរ ។ សម័យនោះឯង អន្តរាកថានេះ កើតឡើងដល់ពួកអន្យតិរ្ថិយបរិព្វាជក ដែលកំពុងអង្គុយប្រជុំគ្នាថា ម្នាលអាវុសោទាំងឡាយ បុគ្គលណានីមួយ ជាសឧបាទិ-សេស ធ្វើមរណកាលទៅ បុគ្គលទាំងអស់នោះ មិនដែលផុតអំពីនរក មិនផុតអំពីកំណើតតិរច្ឆាន មិនផុតអំពីបិត្តិវិស័យ មិនផុតអំពីអបាយ ទុគ្គតិ និងវិនិបាតទេ ។ បពិត្រព្រះអង្គដ៏ចម្រើន លំដាប់នោះ ខ្ញុំព្រះអង្គមិនត្រេកអរ មិនជំទាស់នឹងភាសិត របស់ពួកអន្យតិរ្ថិយបរិព្វាជកទាំងនោះ លុះខ្ញុំព្រះអង្គមិនត្រេកអរ មិនជំទាស់ហើយ ទើបក្រោកចាកអាសនៈចៀសចេញទៅ ដោយគិតថា អាត្មាអញនឹងដឹងនូវសេចក្តីនៃភាសិតនេះ ក្នុងសំណាក់នៃព្រះដ៏មានព្រះភាគ ។ ព្រះអង្គត្រាស់ថា ម្នាលសារីបុត្ត ពួកអន្យតិរ្ថិយបរិព្វាជកនីមួយ ជាមនុស្សល្ងង់ ជាមនុស្សមិនឈ្លាស ពួកណាខ្លះនឹងដឹងនូវសឧបាទិសេសបុគ្គល ថាជាសឧបាទិសេសបុគ្គលក្តី

អនុបាទិសេសំ វា អនុបាទិសេសោតិ ជានិស្សន្តិ ។ នវយិមេ សារីបុត្ត បុគ្គលា សឧបាទិសេសា កាលំ កុរុមានា បរិមុត្តា និរយា បរិមុត្តា តិរច្ឆានយោនិយា បរិមុត្តា បិត្តិវិសយា បរិមុត្តា អបាយទុគ្គតិវិនិបាតា ។ កតមេ នវ ។ ឥធ សារីបុត្ត ឯកច្ចោ បុគ្គលោ សីលេសុ បរិបូរីការី ហោតិ សមាធិស្មឹ បរិបូរីការី បញ្ញាយ[1] មត្តសោការី[2] សោ បញ្ចន្នំ ឱរម្ភាគិយានំ សំយោជនានំ បរិក្ខយា អន្តរាបរិនិព្វាយី ហោតិ ។ អយំ សារីបុត្ត បឋមោ បុគ្គលោ សឧបាទិសេសោ កាលំ កុរុមានោ បរិមុត្តោ និរយា បរិមុត្តោ តិរច្ឆានយោនិយា បរិមុត្តោ បិត្តិវិសយា បរិមុត្តោ អបាយទុគ្គតិវិនិបាតា ។ បុន ចបរំ សារីបុត្ត ឥធេកច្ចោ បុគ្គលោ សីលេសុ បរិបូរីការី ហោតិ សមាធិស្មឹ បរិបូរីការី បញ្ញាយ មត្តសោការី

១ ឱ. ឯត្ថន្តរេ ន បរិបូរការីតិ បាឋោ អត្ថិ ។ ២ ឱ. មត្តសោការីតិ អយំ បាឋោ នត្ថិ ។

នឹងដឹងនូវអនុបាទិសេសបុគ្គល ថាជាអនុបាទិសេសបុគ្គលក្តី ។ ម្នាលសារីបុត្ត បុគ្គលជាសឧបាទិសេសនេះ មាន ៩ ពួក កាលធ្វើមរណៈកាលទៅ តែងផុតចាកនរក ផុតចាកកំណើតតិរច្ឆាន ផុតចាកបិត្តិវិស័យ ផុតចាកអបាយ ទុគ្គតិនិងវិនិបាត ។ បុគ្គល ៩ ពួកដូចម្តេចខ្លះ ។ ម្នាលសារីបុត្ត បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកធ្វើឲ្យបរិបូណ៌ក្នុងសីល ធ្វើឲ្យបរិបូណ៌ក្នុងសមាធិ តែធ្វើឲ្យល្មមប្រមាណក្នុងបញ្ញា បុគ្គលនោះ ជាអន្តរាបរិនិព្វាយី ព្រោះអស់សំយោជនៈជាចំណែកខាងក្រោម ៥ ។ ម្នាលសារីបុត្ត នេះជាសឧបាទិសេសបុគ្គលទី ១ កាលធ្វើមរណកាលទៅ ផុតចាកនរក ផុតចាកកំណើតតិរច្ឆាន ផុតចាកបិត្តិវិស័យ ផុតចាកអបាយ ទុគ្គតិនិងវិនិបាតហើយ ។ ម្នាលសារីបុត្ត មួយទៀត បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកធ្វើឲ្យបរិបូណ៌ក្នុងសីល ធ្វើឲ្យបរិបូណ៌ក្នុងសមាធិ តែធ្វើឲ្យល្មមប្រមាណក្នុងបញ្ញា

៤៧

បណ្ណាសកេ សីហនាទវគ្គោ

សោ បញ្ចន្នំ ឱរម្ភាគិយានំ សំយោជនានំ បរិក្ខយា ឱបបាតិកោ ហោតិ តត្ថ បរិនិព្វាយី អនាវត្តិធម្មោ តស្មា លោកា ។

សោ បញ្ចន្នំ ឱរម្ភាគិយានំ សំយោជនានំ បរិក្ខយា ឧបហច្ចបរិនិព្វាយី ហោតិ អសង្ខារបរិនិព្វាយី ហោតិ សសង្ខារបរិនិព្វាយី ហោតិ ឧទ្ធំសោតោ ហោតិ អកនិដ្ឋគាមី ។ អយំ សារីបុត្ត បញ្ចមោ បុគ្គលោ សឧបាទិសេសោ កាលំ កុរុមានោ បរិមុត្តោ និរយា បរិមុត្តោ តិរច្ឆានយោនិយា បរិមុត្តោ បិត្តិវិសយា បរិមុត្តោ អបាយទុគ្គតិវិនិបាតា ។ បុន ចបរំ សារីបុត្ត ឥធេកច្ចោ បុគ្គលោ សីលេសុ បរិបូរីការី ហោតិ សមាធិស្មឹ មត្តសោការី បញ្ញាយ មត្តសោការី សោ តិណ្ណំ សំយោជនានំ បរិក្ខយា រាគទោសមោហានំ តនុត្តា សកទាគាមី ហោតិ សកិទេវ ឥមំ លោកំ អាគន្ត្វា ទុក្ខស្សន្តំ ករោតិ ។ អយំ សារីបុត្ត ឆដ្ឋោ បុគ្គលោ សឧបាទិសេសោ កាលំ កុរុមានោ បរិមុត្តោ និរយា ។ បេ ។ បរិមុត្តោ អបាយទុគ្គតិវិនិបាតា ។ បុន ចបរំ សារីបុត្ត ឥធេកច្ចោ បុគ្គលោ សីលេសុ បរិបូរីការី ហោតិ សមាធិស្មឹ មត្តសោការី បញ្ញាយ មត្តសោការី

បុគ្គលនោះ ជាឧបហច្ចបរិនិព្វាយី ជាអសង្ខារបរិនិព្វាយី ជាសសង្ខារ-បរិនិព្វាយី ជាឧទ្ធំសោតអកនិដ្ឋគាមី ព្រោះអស់ទៅ នៃសំយោជនៈជាចំណែកខាងក្រោម ៥ ។ ម្នាលសារីបុត្ត នេះជាសឧបាទិសេសបុគ្គលទី ៥ កាលធ្វើមរណកាលទៅ ផុតចាកនរក ផុតចាកកំណើតតិរច្ឆាន ផុតចាកបិត្តិវិស័យ ផុតចាកអបាយ ទុគ្គតិនិងវិនិបាតហើយ ។ ម្នាលសារីបុត្ត មួយទៀត បុគ្គលខ្លះ ក្នុងលោកនេះ ធ្វើឲ្យបរិបូណ៌ក្នុងសីល តែធ្វើឲ្យល្មមប្រមាណក្នុងសមាធិ ធ្វើឲ្យល្មមប្រមាណក្នុងបញ្ញា បុគ្គលនោះ ជាសកទាគាមី ព្រោះអស់សំយោជនៈ ៣ ព្រោះមានរាគៈ ទោសៈ មោហៈស្រាលស្តើង មកកាន់មនុស្សលោកនេះម្តងទៀត ទើបធ្វើទីបំផុតទុក្ខបាន ។ ម្នាលសារីបុត្ត នេះជាសឧបាទិសេសបុគ្គលទី ៦ កាលធ្វើមរណកាលទៅ ផុតចាកនរក ។ បេ ។ ផុតចាកអបាយ ទុគ្គតិនិងវិនិបាតហើយ ។ ម្នាលសារីបុត្ត មួយទៀត បុគ្គលខ្លះ ក្នុងលោកនេះ ធ្វើឲ្យបរិបូណ៌ក្នុងសីល តែធ្វើឲ្យល្មមប្រមាណក្នុងសមាធិ ធ្វើឲ្យល្មមប្រមាណក្នុងបញ្ញា

សោ តិណ្ណំ សំយោជនានំ បរិក្ខយា ឯកពីជី ហោតិ ឯកំយេវ មានុសកំ ភវំ និព្វត្តេត្វា ទុក្ខស្សន្តំ ករោតិ ។ អយំ សារីបុត្ត សត្តមោ បុគ្គលោ សឧបាទិសេសោ កាលំ កុរុមានោ បរិមុត្តោ និរយា ។ បេ ។ បរិមុត្តោ អបាយទុគ្គតិវិនិបាតា ។ បុន ចបរំ សារីបុត្ត ឥធេកច្ចោ បុគ្គលោ សីលេសុ បរិបូរីការី ហោតិ សមាធិស្មឹ មត្តសោការី បញ្ញាយ មត្តសោការី សោ តិណ្ណំ សំយោជនានំ បរិក្ខយា កោលំកោលោ ហោតិ ទ្វេ វា តីណិ វា កុលានិ សន្ធាវិត្វា សំសរិត្វា ទុក្ខស្សន្តំ ករោតិ ។ អយំ សារីបុត្ត អដ្ឋមោ បុគ្គលោ សឧបាទិសេសោ កាលំ កុរុមានោ បរិមុត្តោ និរយា ។ បេ ។ បរិមុត្តោ អបាយទុគ្គ-តិវិនិបាតា ។ បុន ចបរំ សារីបុត្ត ឥធេកច្ចោ បុគ្គលោ សីលេសុ បរិបូរីការី ហោតិ សមាធិស្មឹ មត្តសោការី បញ្ញាយ មត្តសោការី សោ តិណ្ណំ សំយោជនានំ បរិក្ខយា សត្តក្ខត្តុំបរមោ[១] ហោតិ

១ ឱ. ម. សត្តក្ខត្តុបរមោ ។

បុគ្គលនោះ ជាឯកពីជី ព្រោះអស់សំយោជនៈ ៣ ត្រូវកើតក្នុងមនុស្សភព ម្តងទៀត ទើបធ្វើទីបំផុតទុក្ខបាន ។ ម្នាលសារីបុត្ត នេះជាសឧបាទិសេសបុគ្គលទី ៧ កាលធ្វើមរណកាលទៅ ផុតចាកនរក ។ បេ ។ ផុតចាកអបាយ ទុគ្គតិនិងវិនិបាតហើយ ។ ម្នាលសារីបុត្ត មួយទៀត បុគ្គលខ្លះ ក្នុងលោកនេះ ធ្វើឲ្យបរិបូណ៌ក្នុងសីល តែធ្វើឲ្យល្មមប្រមាណក្នុងសមាធិ ធ្វើឲ្យល្មមប្រមាណក្នុងបញ្ញា បុគ្គលនោះ ជាកោលំកោលៈ ព្រោះអស់សំយោជនៈ ៣ ត្រាច់រង្គាត់ អន្ទោលទៅកាន់ត្រកូលពីរ ឬបីទៀត ទើបធ្វើទីបំផុតទុក្ខបាន ។ ម្នាលសារីបុត្ត នេះជាសឧបាទិសេសបុគ្គលទី ៨ កាលធ្វើមរណកាលទៅ ផុតចាកនរក ។ បេ ។ ផុតចាកអបាយ ទុគ្គតិនិងវិនិបាតហើយ ។ ម្នាលសារីបុត្ត មួយវិញទៀត បុគ្គលខ្លះ ក្នុងលោកនេះ ធ្វើឲ្យបរិបូណ៌ក្នុងសីល តែធ្វើឲ្យល្មមប្រមាណក្នុងសមាធិ ធ្វើឲ្យល្មមប្រមាណក្នុងបញ្ញា បុគ្គលនោះ ជាសត្តក្ខត្តុំបរមៈ ព្រោះអស់សំយោជនៈ ៣

សត្តក្ខត្តុំបរមំ ទេវេ ច មនុស្សេ ច សន្ធាវិត្វា សំសរិត្វា ទុក្ខស្សន្តំ ករោតិ ។ អយំ សារីបុត្ត នវមោ បុគ្គលោ សឧបាទិសេសោ កាលំ កុរុមានោ បរិមុត្តោ និរយា បរិមុត្តោ តិរច្ឆានយោនិយា បរិមុត្តោ បិត្តិវិសយា បរិមុត្តោ អបាយទុគ្គតិវិនិបាតា ។ កេចិ សារីបុត្ត អញ្ញតិត្ថិយា បរិព្វាជកា ពាលា អព្យត្តា កេចិ សឧបាទិសេសំ វា សឧបាទិសេសោតិ ជានិស្សន្តិ អនុបាទិសេសំ វា អនុបាទិសេសោតិ ជានិស្សន្តិ ។ ឥមេ ខោ សារីបុត្ត នវ បុគ្គលា សឧបាទិសេសា កាលំ កុរុមានា បរិមុត្តា និរយា បរិមុត្តា តិរច្ឆានយោនិយា បរិមុត្តា បិត្តិវិសយា បរិមុត្តា អបាយទុគ្គតិវិនិបាតា ។ ន តាវាយំ សារីបុត្ត ធម្មបរិយាយោ បតិភាសិ ភិក្ខូនំ ភិក្ខុនីនំ ឧបាសកានំ ឧបាសិកានំ ។ តំ កិស្ស ហេតុ ។ មា ឥមំ ធម្មបរិយាយំ សុត្វា បមាទំ អាហរីសូតិ អបិ ច មយា យោ បញ្ហាធិប្បាយេន ភាសិតោតិ ។

ត្រាច់រង្គាត់ អន្ទោលទៅ កាន់ទេវលោកនិងមនុស្សលោក ៧ ដងទៀត ដោយច្រើន ទើបធ្វើទីបំផុតទុក្ខបាន ។ ម្នាលសារីបុត្ត នេះជាសឧបាទិសេសបុគ្គលទី ៩ កាលធ្វើមរណកាលទៅ ផុតចាកនរក ផុតចាកកំណើតតិរច្ឆាន ផុតចាកបិត្តិវិស័យ ផុតចាកអបាយ ទុគ្គតិនិងវិនិបាតហើយ ។ ម្នាលសារីបុត្ត ពួកអន្យតិរ្ថិយបរិព្វាជកនីមួយ ជាមនុស្សល្ងង់ មិនឈ្លាស ពួកណាខ្លះនឹងដឹងនូវសឧបាទិសេសបុគ្គលថាជាសឧបាទិសេសបុគ្គលក្តី នឹងដឹងនូវអនុបាទិសេសបុគ្គល ថាជាអនុបាទិសេសបុគ្គលក្តី ។ ម្នាលសារីបុត្ត សឧបាទិសេសបុគ្គលទាំង ៩ ពួកនេះឯង កាលធ្វើមរណកាលទៅ ផុតចាកនរក ផុតចាកកំណើតតិរច្ឆាន ផុតចាកបិត្តិវិស័យ ផុតចាកអបាយ ទុគ្គតិនិងវិនិបាតហើយ ។ ម្នាលសារីបុត្ត ធម្មបរិយាយនេះ មិនទាន់ភ្លឺច្បាស់ដល់ពួកភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា នៅឡើយទេ ។ ដំណើរនេះ ព្រោះហេតុអ្វី ។ ព្រោះថា ធម្មបរិយាយណា ដែលតថាគតសម្តែងហើយ ដោយបញ្ហាធិប្បាយ ពួកជនបានស្តាប់ធម្មបរិយាយនោះហើយ ចូរកុំដល់នូវសេចក្តីប្រមាទឡើយ ។

[១៣] អថខោ អាយស្មា មហាកោដ្ឋិតោ យេនាយស្មា សារីបុត្តោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មតា សារីបុត្តេន សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា មហាកោដ្ឋិតោ អាយស្មន្តំ សារីបុត្តំ ឯតទវោច កិន្នុខោ អាវុសោ សារីបុត្ត យំ កម្មំ ទិដ្ឋធម្មវេទនីយំ តំ មេ កម្មំ សម្បរាយវេទនីយំ ហោតូតិ ឯតស្ស អត្ថាយ ភគវតិ ព្រហ្មចរិយំ វុស្សតីតិ ។ នោ ហិទំ អាវុសោ ។ កឹ បនាវុសោ សារីបុត្ត យំ កម្មំ សម្បរាយវេទនីយំ តំ មេ កម្មំ ទិដ្ឋធម្មវេទនីយំ ហោតូតិ ឯតស្ស អត្ថាយ ភគវតិ ព្រហ្មចរិយំ វុស្សតីតិ ។ នោ ហិទំ អាវុសោ ។ កិន្នុ ខោ អាវុសោ សារីបុត្ត យំ កម្មំ សុខវេទនីយំ តំ មេ កម្មំ ទុក្ខវេទនីយំ ហោតូតិ ឯតស្ស អត្ថាយ ភគវតិ ព្រហ្មចរិយំ វុស្សតីតិ ។ នោ ហិទំ អាវុសោ ។ កឹ

[១៣] គ្រានោះ ព្រះមហាកោដ្ឋិតៈដ៏មានអាយុ ចូលទៅរកព្រះសារីបុត្តដ៏មានអាយុ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយជាមួយនឹងព្រះសារីបុត្តដ៏មានអាយុ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររលឹកហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះព្រះមហាកោដ្ឋិតៈដ៏មានអាយុ អង្គុយក្នុងទីសមគួរហើយ បានសួរព្រះសារីបុត្តដ៏មានអាយុដូច្នេះថា ម្នាលអាវុសោសារីបុត្ត ចុះបុគ្គលប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសំណាក់ព្រះដ៏មានព្រះភាគ ដើម្បីប្រយោជន៍ដល់ហេតុនេះថា កម្មណាដែលឲ្យផល ក្នុងបច្ចុប្បន្ន សូមឲ្យកម្មនោះឲ្យផល ក្នុងបរលោកដល់អាត្មាអញវិញ បានឬ ។ ម្នាលអាវុសោ មិនបានទេ ។ ម្នាលអាវុសោសារីបុត្ត ចុះបុគ្គលប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសំណាក់ព្រះដ៏មានព្រះភាគ ដើម្បីប្រយោជន៍ដល់ហេតុនេះថា កម្មណាឲ្យផល ក្នុងបរលោក សូមឲ្យកម្មនោះឲ្យផល ក្នុងបច្ចុប្បន្នដល់អាត្មាអញវិញ បានដែរឬ ។ ម្នាលអាវុសោ មិនបានទេ ។ ម្នាលអាវុសោសារីបុត្ត ចុះបុគ្គលប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសំណាក់ព្រះដ៏មានព្រះភាគ ដើម្បីប្រយោជន៍ដល់ហេតុនេះថា កម្មណាដែលឲ្យផលជាសុខ សូមឲ្យកម្មនោះឲ្យផលជាទុក្ខដល់អាត្មាអញវិញ បានដែរឬ ។ ម្នាលអាវុសោ មិនបានទេ ។

បជាវុសោ សារីបុត្ត យំ កម្មំ ទុក្ខវេទនីយំ តំ មេ កម្មំ សុខវេទនីយំ ហោតូតិ ឯតស្ស អត្ថាយ ភគវតិ ព្រហ្មចរិយំ វុស្សតីតិ ។ នោ ហិទំ អាវុសោ ។ កិន្នុ ខោ អាវុសោ សារីបុត្ត យំ កម្មំ បរិបក្កវេទនីយំ តំ មេ កម្មំ អបរិបក្កវេទនីយំ ហោតូតិ ឯតស្ស អត្ថាយ ភគវតិ ព្រហ្មចរិយំ វុស្សតីតិ ។ នោ ហិទំ អាវុសោ ។ កឹ បជាវុសោ សារីបុត្ត យំ កម្មំ អបរិ-បក្កវេទនីយំ តំ មេ កម្មំ បរិបក្កវេទនីយំ ហោតូតិ ឯតស្ស អត្ថាយ ភគវតិ ព្រហ្មចរិយំ វុស្សតីតិ ។ នោ ហិទំ អាវុសោ ។ កិន្នុ ខោ អាវុសោ សារីបុត្ត យំ កម្មំ ពហុវេទនីយំ តំ មេ កម្មំ អប្បវេទនីយំ ហោតូតិ ឯតស្ស អត្ថាយ ភគវតិ ព្រហ្មចរិយំ វុស្សតីតិ ។ នោ ហិទំ អាវុសោ ។

ម្នាលអាវុសោសារីបុត្ត ចុះបុគ្គលប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសំណាក់ព្រះដ៏មានព្រះភាគ ដើម្បីប្រយោជន៍ដល់ហេតុនេះថា កម្មណាឲ្យផលជាទុក្ខ សូមឲ្យកម្មនោះឲ្យផល ជាសុខដល់អាត្មាអញវិញ បានដែរឬ ។ ម្នាលអាវុសោ មិនបានទេ ។ ម្នាលអាវុសោសារីបុត្ត ចុះបុគ្គលប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសំណាក់ព្រះដ៏មានព្រះភាគ ដើម្បីប្រយោជន៍ដល់ហេតុនេះថា កម្មណាដែលមានវារៈឲ្យផល សូមឲ្យកម្មនោះទៅជាមានវារៈ មិនឲ្យផលដល់អាត្មាអញវិញ បានដែរឬ ។ ម្នាលអាវុសោ មិនបានទេ ។ ម្នាលអាវុសោសារីបុត្ត ចុះបុគ្គលប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសំណាក់ព្រះដ៏មានព្រះភាគ ដើម្បីប្រយោជន៍ដល់ហេតុនេះថា កម្មណាដែលមានវារៈមិនឲ្យផល សូមឲ្យកម្មនោះ ទៅជាមានវារៈ ឲ្យផលដល់អាត្មាអញវិញ បានដែរឬ ។ ម្នាលអាវុសោ មិនបានទេ ។ ម្នាលអាវុសោសារីបុត្ត ចុះបុគ្គលប្រព្រឹត្តព្រហ្មចរិយ-ធម៌ ក្នុងសំណាក់ព្រះដ៏មានព្រះភាគ ដើម្បីប្រយោជន៍ដល់ហេតុនេះថា កម្មណាឲ្យផលច្រើន សូមឲ្យកម្មនោះ ត្រឡប់ទៅជាឲ្យផលតិចដល់អាត្មាអញវិញ បានដែរឬ ។ ម្នាលអាវុសោ មិនបានទេ ។

កឹ បនាវុសោ សារីបុត្ត យំ កម្មំ អប្បវេទនីយំ តំ មេ កម្មំ ពហុវេទនីយំ ហោតូតិ ឯតស្ស អត្ថាយ ភគវតិ ព្រហ្មចរិយំ វុស្សតីតិ ។ នោ ហិទំ អាវុសោ ។ កិន្នុ ខោ អាវុសោ សារីបុត្ត យំ កម្មំ វេទនីយំ តំ មេ កម្មំ អវេទនីយំ ហោតូតិ ឯតស្ស អត្ថាយ ភគវតិ ព្រហ្មចរិយំ វុស្សតីតិ ។ នោ ហិទំ អាវុសោ ។ កឹ បនាវុសោ សារីបុត្ត យំ កម្មំ អវេទនីយំ តំ មេ កម្មំ វេទនីយំ ហោតូតិ ឯតស្ស អត្ថាយ ភគវតិ ព្រហ្មចរិយំ វុស្សតីតិ ។ នោ ហិទំ អាវុសោ ។

កិន្នុ ខោ អាវុសោ សារីបុត្ត យំ កម្មំ ទិដ្ឋធម្ម-វេទនីយំ តំ មេ កម្មំ សម្បរាយវេទនីយំ ហោតូតិ ឯតស្ស អត្ថាយ ភគវតិ ព្រហ្មចរិយំ វុស្សតីតិ ឥតិ បុដ្ឋោ សមានោ នោ ហិទំ អាវុសោតិ វទេសិ ។

ម្នាលអាវុសោសារីបុត្ត ចុះបុគ្គលប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសំណាក់ព្រះដ៏មានព្រះភាគ ដើម្បីប្រយោជន៍ដល់ហេតុនេះថា កម្មណាឲ្យផលតិច សូមឲ្យកម្មនោះ ត្រឡប់ទៅជាឲ្យផលច្រើនដល់អាត្មាអញវិញ បានដែរឬ ។ ម្នាលអាវុសោ មិនបានទេ ។ ម្នាលអាវុសោសារីបុត្ត ចុះបុគ្គលប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសំណាក់ព្រះដ៏មានព្រះភាគ ដើម្បីប្រយោជន៍ដល់ហេតុនេះថា កម្មណា ដែលឲ្យផល សូមឲ្យកម្មនោះ ត្រឡប់ជាមិនឲ្យផលដល់អាត្មាអញវិញ បានដែរឬ ។ ម្នាលអាវុសោ មិនបានទេ ។ ម្នាលអាវុសោសារីបុត្ត ចុះបុគ្គលប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសំណាក់ព្រះដ៏មានព្រះភាគ ដើម្បីប្រយោជន៍ដល់ហេតុនេះថា កម្មណាដែលមិនឲ្យផល សូមឲ្យកម្មនោះ ត្រឡប់ជាឲ្យផលដល់អាត្មាអញវិញ បានដែរឬ ។ ម្នាលអាវុសោ មិនបានទេ ។

ព្រះមហាកោដ្ឋិតៈដ៏មានអាយុពោលថា កាលដែលខ្ញុំសួរដូច្នេះថា ម្នាលអាវុសោសារីបុត្ត ចុះបុគ្គលប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសំណាក់ព្រះដ៏មានព្រះភាគ ដើម្បីប្រយោជន៍ដល់ហេតុនេះថា កម្មណាដែលឲ្យផល ក្នុងបច្ចុប្បន្ន សូមឲ្យកម្មនោះឲ្យផល ក្នុងបរលោកដល់អាត្មាអញវិញ បានដែរឬ លោកឆ្លើយថា ម្នាលអាវុសោ មិនបានទេ ។

៦៣

បណ្ណាសកេ សីហនាទវគ្គោ

កឹ បនាវុសោ សារីបុត្ត យំ កម្មំ សម្បរាយវេទនីយំ តំ មេ កម្មំ ទិដ្ឋធម្មវេទនីយំ ហោតូតិ ឯតស្ស អត្ថាយ ភគវតិ ព្រហ្មចរិយំ វុស្សតីតិ ឥតិ បុដ្ឋោ សមានោ នោ ហិទំ អាវុសោតិ វទេសិ ។ កិន្នុ ខោ អាវុសោ សារីបុត្ត យំ កម្មំ សុខវេទនីយំ តំ មេ កម្មំ ទុក្ខវេទនីយំ ហោតូតិ ឯតស្ស អត្ថាយ ភគវតិ ព្រហ្មចរិយំ វុស្សតីតិ ឥតិ បុដ្ឋោ សមានោ នោ ហិទំ អាវុសោតិ វទេសិ ។ កឹ បនាវុសោ សារីបុត្ត យំ កម្មំ ទុក្ខវេទនីយំ តំ មេ កម្មំ សុខវេទនីយំ ហោតូតិ ឯតស្ស អត្ថាយ ភគវតិ ព្រហ្មចរិយំ វុស្សតីតិ ឥតិ បុដ្ឋោ សមានោ នោ ហិទំ អាវុសោតិ វទេសិ ។

កាលដែលខ្ញុំសួរដូច្នេះថា ម្នាលអាវុសោសារីបុត្ត ចុះបុគ្គលប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសំណាក់ព្រះដ៏មានព្រះភាគ ដើម្បីប្រយោជន៍ដល់ហេតុនេះថា កម្មណាដែលឲ្យផល ក្នុងបរលោក សូមឲ្យកម្មនោះឲ្យផល ក្នុងបច្ចុប្បន្ននេះដល់អាត្មាអញវិញ បានដែរឬ លោកឆ្លើយថា ម្នាលអាវុសោ មិនបានទេ ។ កាលដែលខ្ញុំសួរដូច្នេះថា ម្នាលអាវុសោសារីបុត្ត ចុះបុគ្គលប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសំណាក់ព្រះដ៏មានព្រះភាគ ដើម្បីប្រយោជន៍ដល់ហេតុនេះថា កម្មណាឲ្យផលជាសុខ សូមឲ្យកម្មនោះ ឲ្យផលជាទុក្ខដល់អាត្មាអញវិញ បានដែរឬ លោកឆ្លើយថា ម្នាលអាវុសោ មិនបានទេ ។ កាលដែលខ្ញុំសួរដូច្នេះថា ម្នាលអាវុសោសារីបុត្ត ចុះបុគ្គលប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសំណាក់ព្រះដ៏មានព្រះភាគ ដើម្បីប្រយោជន៍ដល់ហេតុនេះថា កម្មណាដែលឲ្យផលជាទុក្ខ សូមឲ្យកម្មនោះ ត្រឡប់ឲ្យផលជាសុខដល់អាត្មាអញវិញ បានដែរឬ លោកឆ្លើយថា ម្នាលអាវុសោ មិនបានទេ ។

៦៤



កិន្នុ ខោ អាវុសោ សារីបុត្ត យំ កម្មំ បរិបក្កវេ-
ទនីយំ តំ មេ កម្មំ អបរិបក្កវេទនីយំ ហោតូតិ
ឯតស្ស អត្ថាយ ភគវតិ ព្រហ្មចរិយំ វុស្សតីតិ ឥតិ
បុដ្ឋោ សមានោ នោ ហិទំ អាវុសោតិ វទេសិ ។
កឹ បនាវុសោ សារីបុត្ត យំ កម្មំ អបរិបក្កវេទនីយំ
តំ មេ កម្មំ បរិបក្កវេទនីយំ ហោតូតិ ឯតស្ស អត្ថាយ
ភគវតិ ព្រហ្មចរិយំ វុស្សតីតិ ឥតិ បុដ្ឋោ សមានោ
នោ ហិទំ អាវុសោតិ វទេសិ ។ កិន្នុ ខោ អាវុសោ
សារីបុត្ត យំ កម្មំ ពហុវេទនីយំ តំ មេ កម្មំ អប្ប-
វេទនីយំ ហោតូតិ ឯតស្ស អត្ថាយ ភគវតិ ព្រហ្មចរិយំ
វុស្សតីតិ ឥតិ បុដ្ឋោ សមានោ នោ ហិទំ អាវុសោតិ
វទេសិ ។ កឹ បនាវុសោ សារីបុត្ត យំ កម្មំ
អប្បវេទនីយំ តំ មេ កម្មំ ពហុវេទនីយំ ហោតូតិ
ឯតស្ស អត្ថាយ ភគវតិ ព្រហ្មចរិយំ វុស្សតីតិ ឥតិ
បុដ្ឋោ សមានោ នោ ហិទំ អាវុសោតិ វទេសិ ។

កាលដែលខ្ញុំសួរដូច្នេះថា ម្នាលអាវុសោសារីបុត្ត ចុះបុគ្គលប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសំណាក់ព្រះដ៏មានព្រះភាគ ដើម្បីប្រយោជន៍ដល់ហេតុនេះថា កម្មណាដែលមានវារៈឲ្យផល សូមឲ្យកម្មនោះ មានវារៈមិនឲ្យផលដល់អាត្មាអញវិញ បានដែរឬ លោកឆ្លើយថា ម្នាលអាវុសោមិនបានទេ ។ កាលដែលខ្ញុំសួរដូច្នេះថា ម្នាលអាវុសោសារីបុត្ត ចុះបុគ្គលប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសំណាក់ព្រះដ៏មានព្រះភាគ ដើម្បីប្រយោជន៍ដល់ហេតុនេះថា កម្មណាដែលមានវារៈមិនឲ្យផល សូមឲ្យកម្មនោះ មានវារៈឲ្យផលដល់អាត្មាអញវិញ បានដែរឬ លោកឆ្លើយថា ម្នាលអាវុសោ មិនបានទេ ។ កាលដែលខ្ញុំសួរដូច្នេះថា ម្នាលអាវុសោសារីបុត្ត ចុះបុគ្គលប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសំណាក់ព្រះដ៏មានព្រះភាគ ដើម្បីប្រយោជន៍ដល់ហេតុនេះថា កម្មណាដែលឲ្យផលច្រើន សូមឲ្យកម្មនោះ ត្រឡប់ឲ្យផលតិចដល់អាត្មាអញវិញ បានដែរឬ លោកឆ្លើយថា ម្នាលអាវុសោ មិនបានទេ ។ កាលដែលខ្ញុំសួរដូច្នេះថា ម្នាលអាវុសោសារីបុត្ត ចុះបុគ្គលប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសំណាក់ព្រះដ៏មានព្រះភាគ ដើម្បីប្រយោជន៍ដល់ហេតុនេះថា កម្មណាដែលឲ្យផលតិច សូមឲ្យកម្មនោះ ត្រឡប់ជាឲ្យផលច្រើនដល់អាត្មាអញវិញ បានដែរឬ លោកឆ្លើយថា ម្នាលអាវុសោ មិនបានទេ ។

កិន្នុ ខោ អាវុសោ សារីបុត្ត យំ កម្មំ វេទនីយំ តំ មេ កម្មំ អវេទនីយំ ហោតូតិ ឯតស្ស អត្ថាយ ភគវតិ ព្រហ្មចរិយំ វុស្សតីតិ ឥតិ បុដ្ឋោ សមានោ នោ ហិទំ អាវុសោតិ វទេសិ ។ កឹ បនាវុសោ សារីបុត្ត យំ កម្មំ អវេទនីយំ តំ មេ កម្មំ វេទនីយំ ហោតូតិ ឯតស្ស អត្ថាយ ភគវតិ ព្រហ្មចរិយំ វុស្សតីតិ ឥតិ បុដ្ឋោ សមានោ នោ ហិទំ អាវុសោតិ វទេសិ អថ កិមត្ថំ ចរតាវុសោ[១] ភគវតិ ព្រហ្មចរិយំ វុស្សតីតិ ។ យំ ខោស្ស អាវុសោ អត្ថាយ អញ្ញាតំ អទិដ្ឋំ អប្បត្តំ អសច្ឆិកតំ អនភិសមេតំ តស្ស ញាណាយ ទស្សនាយ បត្តិយា សច្ឆិកិរិយាយ អភិសមយាយ ភគវតិ ព្រហ្មចរិយំ វុស្សតិ ឥទំ ទុក្ខន្តិ ខោស្ស អាវុសោ អយំ ទុក្ខសមុទយោតិ ខោស្ស អាវុសោ អយំ ទុក្ខនិរោធោតិ

---

១ ឱ. បរហាវុសោ ។

កាលដែលខ្ញុំសួរដូច្នេះថា ម្នាលអាវុសោសារីបុត្ត ចុះបុគ្គល ប្រព្រឹត្ត ព្រហ្មចរិយធម៌ ក្នុងសំណាក់ព្រះដ៏មានព្រះភាគ ដើម្បីប្រយោជន៍ដល់ហេតុនេះថា កម្មណា ដែលឲ្យផល សូមឲ្យកម្មនោះ ត្រឡប់ជាមិនឲ្យផល ដល់អាត្មាអញវិញ បានដែរឬ លោកឆ្លើយថា ម្នាលអាវុសោ មិនបានទេ ។ កាលដែលខ្ញុំសួរដូច្នេះថា ម្នាលអាវុសោសារីបុត្ត ចុះបុគ្គល ប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសំណាក់ព្រះដ៏មានព្រះភាគ ដើម្បីប្រយោជន៍ដល់ហេតុនេះថា កម្មណា ដែលមិនឲ្យផល សូមឲ្យកម្មនោះ ត្រឡប់ជាឲ្យផល ដល់អាត្មាអញវិញ បានដែរឬ លោកឆ្លើយថា ម្នាលអាវុសោ មិនបានទេ ម្នាលអាវុសោ កាលបើដូច្នេះ ចុះបុគ្គល ប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសំណាក់ព្រះដ៏មានព្រះភាគ តើប្រព្រឹត្តដើម្បីអ្វី ។ ម្នាលអាវុសោ គុណជាតណា ដែលបុគ្គលមិនបានដឹង មិនបានឃើញ មិនបានដល់ មិនបានធ្វើឲ្យជាក់ច្បាស់ មិនបានត្រាស់ដឹងនៅឡើយ បុគ្គលប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសំណាក់ព្រះដ៏មានព្រះភាគ ដើម្បីដឹង ដើម្បីឃើញ ដើម្បីដល់ ដើម្បីធ្វើឲ្យជាក់ច្បាស់ ដើម្បីត្រាស់ដឹង នូវគុណជាតនោះ ម្នាលអាវុសោ នេះជាទុក្ខ ម្នាលអាវុសោ នេះជាទុក្ខសមុទ័យ ម្នាលអាវុសោ នេះជាទុក្ខនិរោធ

ខោស្ស អាវុសោ អយំ ទុក្ខនិរោធគាមិនី បដិបទាតិ ខោស្ស អាវុសោ អញ្ញាតំ អទិដ្ឋំ អប្បត្តំ អសច្ឆិកតំ អនភិសមេតំ តស្ស ញាណាយ ទស្សនាយ បត្តិយា សច្ឆិកិរិយាយ អភិសមយាយ ភគវតិ ព្រហ្មចរិយំ វុស្សតិ ឥទំ ខោស្ស អាវុសោ អញ្ញាតំ អទិដ្ឋំ អប្បត្តំ អសច្ឆិកតំ អនភិសមេតំ តស្ស ញាណាយ ទស្សនាយ បត្តិយា សច្ឆិកិរិយាយ អភិសមយាយ ភគវតិ ព្រហ្មចរិយំ វុស្សតីតិ ។

[១៤] អថខោ អាយស្មា សមិទ្ធិ យេនាយស្មា សារីបុត្តោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ សារីបុត្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ អាយស្មន្តំ សមិទ្ធឹ អាយស្មា សារីបុត្តោ ឯតទវោច កិមារម្មណា សមិទ្ធិ បុរិសស្ស សង្កប្បវិតក្កា ឧប្បជ្ជន្តីតិ ។ នាមរូបារម្មណា ភន្តេតិ ។ តេ បន សមិទ្ធិ ក្វ នានត្តំ គច្ឆន្តីតិ ។

ម្នាលអាវុសោ នេះជាទុក្ខនិរោធគាមិនី បដិបទា ដែលបុគ្គល មិនបានដឹង មិនបានឃើញ មិនបានដល់ មិនបានធ្វើឲ្យជាក់ច្បាស់ មិនបានត្រាស់ដឹង បុគ្គលប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងសំណាក់ព្រះដ៏មានព្រះភាគ ដើម្បីដឹង ដើម្បីឃើញ ដើម្បីដល់ ដើម្បីធ្វើឲ្យជាក់ច្បាស់ ដើម្បីត្រាស់ដឹងនូវគុណជាតនោះ ម្នាលអាវុសោ នេះឯង ជាគុណជាត ដែលបុគ្គល មិនបានដឹង មិនបានឃើញ មិនបានដល់ មិនបានធ្វើឲ្យជាក់ច្បាស់ មិនបានត្រាស់ដឹង បុគ្គលប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសំណាក់ព្រះដ៏មានព្រះភាគ ដើម្បីដឹង ដើម្បីឃើញ ដើម្បីដល់ ដើម្បីធ្វើឲ្យជាក់ច្បាស់ ដើម្បីត្រាស់ដឹងនូវគុណជាតនោះ ។

[១៤] គ្រានោះ ព្រះសមិទ្ធិដ៏មានអាយុ ចូលទៅរកព្រះសារីបុត្តដ៏មានអាយុ លុះចូលទៅដល់ ថ្វាយបង្គំព្រះសារីបុត្តដ៏មានអាយុ ហើយអង្គុយក្នុងទីសមគួរ ។ លុះព្រះសិមិទ្ធិដ៏មានអាយុ អង្គុយក្នុងទីសមគួរហើយ ព្រះសារីបុត្តដ៏មានអាយុ សួរដូច្នេះថា ម្នាលសមិទ្ធិ វិតក្កៈជាសង្កប្បៈ របស់បុរស មានអ្វី ជាអារម្មណ៍ ទើបកើតឡើង ។ ព្រះសមិទ្ធិឆ្លើយតបថា បពិត្រលោកម្ចាស់ដ៏ចម្រើន មាននាមនិងរូប ជាអារម្មណ៍ ។ ម្នាលសមិទ្ធិ ធម៌ទាំងនោះ ដល់នូវភាពផ្សេងគ្នា ក្នុងទីដូចម្តេច ។

៦៧



ធាតូសុ ភន្តេតិ ។ តេ បន សមិទ្ធិ កឹសមុទយាតិ ។ ផស្សសមុទយា ភន្តេតិ ។ តេ បន សមិទ្ធិ កឹសមោសរណាតិ ។ វេទនាសមោសរណា ភន្តេតិ ។ តេ បន សមិទ្ធិ កឹបមុខាតិ ។ សមាធិប្បមុខា ភន្តេតិ ។ តេ បន សមិទ្ធិ កឹអាធិបតេយ្យាតិ ។ សតាធិបតេយ្យា ភន្តេតិ ។ តេ បន សមិទ្ធិ កឹឧត្តរាតិ ។ បញ្ញុត្តរា ភន្តេតិ ។ តេ បន សមិទ្ធិ កឹសារាតិ ។ វិមុត្តិសារា ភន្តេតិ ។ តេ បន សមិទ្ធិ កឹឱគធាតិ ។ អមតោគធា ភន្តេតិ ។ កិមារម្មណា សមិទ្ធិ បុរិសស្ស សង្កប្បវិតក្កា ឧប្បជ្ជន្តីតិ ឥតិ បុដ្ឋោ សមានោ នាមរូបារម្មណា ភន្តេតិ វទេសិ ។ តេ បន សមិទ្ធិ ក្វ នានត្តំ គច្ឆន្តីតិ ឥតិ បុដ្ឋោ សមានោ ធាតូសុ ភន្តេតិ វទេសិ ។

បពិត្រលោកម្ចាស់ដ៏ចម្រើន ក្នុងពួកជាតុ ។ ម្នាលសមិទ្ធិ ធម៌ទាំងនោះ មានអ្វី ជាដែនកើត ។ បពិត្រលោកម្ចាស់ដ៏ចម្រើន មានផស្សៈ ជាដែនកើត ។ ម្នាលសមិទ្ធិ ធម៌ទាំងនោះ មានអ្វីជាទីប្រជុំចុះ ។ បពិត្រលោកម្ចាស់ដ៏ចម្រើន មានវេទនា ជាទីប្រជុំចុះ ។ ម្នាលសមិទ្ធិ ធម៌ទាំងនោះមានអ្វី ជាប្រធាន ។ បពិត្រលោកម្ចាស់ដ៏ចម្រើន មានសមាធិ ជាប្រធាន ។ ម្នាលសមិទ្ធិ ធម៌ទាំងនោះ មានអ្វី ជាអធិបតី ។ បពិត្រលោកម្ចាស់ដ៏ចម្រើន មានសតិ ជាអធិបតី ។ ម្នាលសមិទ្ធិ ធម៌ទាំងនោះ មានអ្វី ជារបស់ខ្ពង់ខ្ពស់ ។ បពិត្រលោកម្ចាស់ដ៏ចម្រើន មានបញ្ញា ជារបស់ខ្ពង់ខ្ពស់ ។ ម្នាលសមិទ្ធិ ធម៌ទាំងនោះ មានអ្វី ជាខ្លឹម ។ បពិត្រលោកម្ចាស់ដ៏ចម្រើន មានវិមុត្តិ ជាខ្លឹម ។ ម្នាលសមិទ្ធិ ធម៌ទាំងនោះ មានអ្វី ជាទីតាំងនៅស៊ប់ ។ បពិត្រលោកម្ចាស់ដ៏ចម្រើន មានអមតៈ ជាទីតាំងនៅស៊ប់ ។ កាលដែលខ្ញុំសួរថា ម្នាលសមិទ្ធិ វិតក្កៈ ជាសង្កប្បៈ របស់បុរស មានអ្វី ជាអារម្មណ៍ ទើបកើតឡើង លោកឆ្លើយថា បពិត្រលោកម្ចាស់ដ៏ចម្រើន មាននាមនិងរូប ជាអារម្មណ៍ ។ កាលដែលខ្ញុំសួរថា ម្នាលសមិទ្ធិ ធម៌ទាំងនោះដល់នូវភាពផ្សេងគ្នា ក្នុងទីដូចម្តេច លោកឆ្លើយថា បពិត្រលោកម្ចាស់ដ៏ចម្រើន ក្នុងពួកជាតុ ។

៦៨



តេ បន សមិទ្ធិ កឹសមុទយាតិ ឥតិ បុដ្ឋោ សមានោ ផស្សសមុទយា ភន្តេតិ វទេសិ ។ តេ បន សមិទ្ធិ កឹសមោសរណាតិ ឥតិ បុដ្ឋោ សមានោ វេទនាសមោសរណា ភន្តេតិ វទេសិ ។ តេ បន សមិទ្ធិ កឹបមុខាតិ ឥតិ បុដ្ឋោ សមានោ សមាធិប្បមុខា ភន្តេតិ វទេសិ ។ តេ បន សមិទ្ធិ កឹអាធិបតេយ្យាតិ ឥតិ បុដ្ឋោ សមានោ សតាធិបតេយ្យា ភន្តេតិ វទេសិ ។ តេ បន សមិទ្ធិ កឹឧត្តរាតិ ឥតិ បុដ្ឋោ សមានោ បញ្ញុត្តរា ភន្តេតិ វទេសិ ។ តេ បន សមិទ្ធិ កឹសារាតិ ឥតិ បុដ្ឋោ សមានោ វិមុត្តិសារា ភន្តេតិ វទេសិ ។ តេ បន សមិទ្ធិ កឹឱគធាតិ ឥតិ បុដ្ឋោ សមានោ អមតោគធា ភន្តេតិ វទេសិ ។ សាធុ សាធុ សមិទ្ធិ សាធុ ខោ ត្វំ សមិទ្ធិ បញ្ហំ បុដ្ឋោ វិស្សជ្ជេសិ តេន ច មា មញ្ញីតិ ។

កាលដែលខ្ញុំសួរថា ម្នាលសមិទ្ធិ ធម៌ទាំងឡាយនោះ មានអ្វី ជាដែនកើត លោកឆ្លើយថា បពិត្រលោកម្ចាស់ដ៏ចម្រើន មានផស្សៈ ជាដែនកើត ។ កាលដែលខ្ញុំសួរថា ម្នាលសមិទ្ធិ ធម៌ទាំងនោះ មានអ្វី ជាទីប្រជុំចុះ លោកឆ្លើយថា បពិត្រលោកម្ចាស់ដ៏ចម្រើន មានវេទនា ជាទីប្រជុំចុះ ។ កាលដែលខ្ញុំសួរថា ម្នាលសមិទ្ធិ ធម៌ទាំងនោះ មានអ្វី ជាប្រធាន លោកឆ្លើយថា បពិត្រលោកម្ចាស់ដ៏ចម្រើន មានសមាធិ ជាប្រធាន ។ កាលដែលខ្ញុំសួរថា ម្នាលសមិទ្ធិ ធម៌ទាំងនោះ មានអ្វី ជាអធិបតី លោកឆ្លើយថា បពិត្រលោកម្ចាស់ដ៏ចម្រើន មានសតិ ជាអធិបតី ។ កាលដែលខ្ញុំសួរថា ម្នាលសមិទ្ធិ ធម៌ទាំងនោះ មានអ្វី ជារបស់ខ្ពង់ខ្ពស់ លោកឆ្លើយថា បពិត្រលោកម្ចាស់ដ៏ចម្រើន មានបញ្ញា ជារបស់ខ្ពង់ខ្ពស់ ។ កាលដែលខ្ញុំសួរថា ម្នាលសមិទ្ធិ ធម៌ទាំងនោះ មានអ្វី ជាខ្លឹម លោកឆ្លើយថា បពិត្រលោកម្ចាស់ដ៏ចម្រើន មានវិមុត្តិ ជាខ្លឹម ។ កាលដែលខ្ញុំសួរថា ម្នាលសមិទ្ធិ ធម៌ទាំងនោះ មានអ្វី ជាទីតាំងនៅស៊ប់ លោកឆ្លើយថា បពិត្រលោកម្ចាស់ដ៏ចម្រើន មានអមតៈ ជាទីតាំងនៅស៊ប់ ។ ម្នាលសមិទ្ធិ ប្រពៃណាស់ ម្នាលសមិទ្ធិ អ្នកវិសជ្ជនាប្រស្នាដែលខ្ញុំសួរហើយត្រូវណាស់ មួយទៀត អ្នកកុំបានចិត្តព្រោះការវិសជ្ជនាប្រស្នានោះឡើយ ។

បណ្ណាសកេ សីហនាទវគ្គោ

[១៨] សេយ្យថាបិ ភិក្ខវេ គណ្ឌោ អនេកវស្សគណិកោ តស្សស្សុ នវ វណមុខានិ នវ អភេទនមុខានិ តតោ យំ កិញ្ចិ បគ្ឃរេយ្យ អសុចិយេវ បគ្ឃរេយ្យ ទុគ្គន្ធំយេវ បគ្ឃរេយ្យ ជេគុច្ឆិយំយេវ បគ្ឃរេយ្យ យំ កិញ្ចិ បសវេយ្យ អសុចិយេវ បសវេយ្យ ទុគ្គន្ធំយេវ បសវេយ្យ ជេគុច្ឆិយំយេវ បសវេយ្យ ។ គណ្ឌោតិ ខោ ភិក្ខវេ ឥមស្សេតំ ចាតុម្មហាភូតិកស្ស កាយស្ស អធិវចនំ មាតាបេត្តិកសម្ភវស្ស ឱទនកុម្មាសុបចយស្ស អនិច្ចុច្ឆាទនបរិមទ្ទនភេទនវិទ្ធំសនធម្មស្ស តស្ស នវ វណមុខានិ នវ អភេទនមុខានិ តតោ យំ កិញ្ចិ បគ្ឃរតិ អសុចិយេវ បគ្ឃរតិ ទុគ្គន្ធំយេវ បគ្ឃរតិ ជេគុច្ឆិយំយេវ បគ្ឃរតិ យំ កិញ្ចិ បសវតិ អសុចិយេវ បសវតិ ទុគ្គន្ធំយេវ បសវតិ ជេគុច្ឆិយំយេវ បសវតិ តស្មាតិហ ភិក្ខវេ ឥមស្មឹ កាយេ និព្វិន្ទថាតិ ។

[១៥] ម្នាលភិក្ខុទាំងឡាយ ដូចបូសរាប់ដោយឆ្នាំមិនតែមួយ មុខដំបៅមាន ៩ គឺមុខដំបៅដែលមិនមានអ្នកណាទម្លាយទាំង ៩ របស់បូសនោះទេ វត្ថុទីមួយគប្បីហូរចេញ របស់មិនស្អាតក៏គប្បីហូរចេញ ក្លិនអាក្រក់ ក៏គប្បីផ្សាយចេញ របស់គួរខ្ពើមក៏គប្បីហូរចេញ វត្ថុទីមួយក៏គប្បីជ្រាបចេញ របស់មិនស្អាតក៏គប្បីជ្រាបចេញ ក្លិនអាក្រក់ក៏គប្បីផ្សាយចេញ របស់ដែលគួរខ្ពើមក៏គប្បីផ្សាយចេញអំពីមុខដំបៅនោះ ។ ម្នាលភិក្ខុទាំងឡាយ ពាក្យថា បូសនេះ ជាឈ្មោះរបស់កាយ ដែលប្រកបដោយមហាភូតរូប ៤ នេះ មានមាតាបិតា ជាដែនកើត ចម្រើនដោយបាយនិងនំកុម្មាស មានសេចក្តីមិនទៀង មានកិរិយាប្រោះព្រំ គក់ច្របាច់បែកធ្លាយ វិនាសខ្ចាត់ខ្ចាយជាធម្មតា មុខដំបៅមាន ៩ គឺមុខដំបៅដែលមិនមានអ្នកណាទម្លាយទាំង ៩ របស់កាយនោះទេ វត្ថុមួយតែងហូរចេញ របស់មិនស្អាតក៏ហូរចេញ ក្លិនអាក្រក់ក៏ហូរចេញ របស់គួរខ្ពើមក៏ហូរចេញ វត្ថុទីមួយក៏ជ្រាបចេញ របស់មិនស្អាតក៏ជ្រាបចេញ ក្លិនអាក្រក់ក៏ជ្រាបចេញ របស់គួរខ្ពើមក៏ជ្រាបចេញ អំពីមុខដំបៅនោះ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកទាំងឡាយ ចូរនឿយណាយក្នុងកាយនេះ ។

[១៦] នវយិមា ភិក្ខវេ សញ្ញា ភាវិតា ពហុលីកតា មហប្ផលា ហោន្តិ មហានិសំសា អមតោគធា អមតបរិយោសានា ។ កតមា នវ ។ អសុភសញ្ញា មរណសញ្ញា អាហារេ បដិកូលសញ្ញា សព្វលោកេ អនភិរតសញ្ញា អនិច្ចសញ្ញា អនិច្ចេ ទុក្ខសញ្ញា ទុក្ខេ អនត្តសញ្ញា បហានសញ្ញា វិរាគសញ្ញា ។ ឥមា ខោ ភិក្ខវេ នវ សញ្ញា ភាវិតា ពហុលីកតា មហប្ផលា ហោន្តិ មហានិសំសា អមតោគធា អមតបរិយោសានាតិ ។

[១៧] នវហិ ភិក្ខវេ អង្គេហិ សមន្នាគតំ កុលំ អនុបគន្ត្វា វា នាលំ ឧបគន្តុំ ឧបគន្ត្វា វា នាលំ និសីទិតុំ ។ កតមេហិ នវហិ ។ ន មនាបេន បច្ចុដ្ឋេន្តិ ន មនាបេន អភិវាទេន្តិ ន មនាបេន អាសនំ ទេន្តិ សន្តមស្ស បរិគុយ្ហន្តិ ពហុកម្បិ ថោកំ ទេន្តិ បណីតម្បិ លូខំ ទេន្តិ អសក្កច្ចំ ទេន្តិ នោ សក្កច្ចំ

[១៦] ម្នាលភិក្ខុទាំងឡាយ សញ្ញា ៩ យ៉ាងនេះ ដែលបុគ្គលចម្រើន ធ្វើឲ្យច្រើនហើយ រមែងមានផលច្រើន មានអានិសង្សច្រើន មានអមតៈ ជាទីតាំងនៅស៊ប់ មានអមតៈ ជាបរិយោសាន ។ សញ្ញា ៩ យ៉ាង តើដូចម្តេចខ្លះ ។ គឺ អសុភសញ្ញា ១ មរណសញ្ញា ១ អាហារេ បដិកូលសញ្ញា ១ សព្វលោកេអនភិរតសញ្ញា ១ អនិច្ចសញ្ញា ១ អនិច្ចេទុក្ខសញ្ញា ១ ទុក្ខេអនត្តសញ្ញា ១ បហានសញ្ញា ១ វិរាគសញ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ សញ្ញាមាន ៩ យ៉ាងនេះឯង ដែលបុគ្គលចម្រើន ធ្វើឲ្យច្រើនហើយ រមែងមានផលច្រើន មានអានិសង្សច្រើន មានអមតៈ ជាទីតាំងនៅស៊ប់ មានអមតៈជាបរិយោសាន ។

[១៧] ម្នាលភិក្ខុទាំងឡាយ ត្រកូលប្រកបដោយអង្គ ៩ ដែលភិក្ខុមិនទាន់ចូលទៅ ក៏មិនគួរចូលទៅ បើភិក្ខុចូលជ្រុលទៅហើយ ក៏មិនគួរអង្គុយ ។ ត្រកូលប្រកបដោយអង្គ ៩ តើដូចម្តេចខ្លះ ។ គឺគេមិនក្រោកទទួល ដោយសេចក្តីពេញចិត្ត ១ មិនថ្វាយបង្គំ ដោយសេចក្តីពេញចិត្ត ១ មិនឲ្យអាសនៈ ដោយសេចក្តីពេញចិត្ត ១ លាក់របស់ដែលមាន ១ របស់មានច្រើនឲ្យតិច ១ មានរបស់ដែលថ្លៃថ្លា ឲ្យរបស់សៅហ្មង ១ ឲ្យដោយមិនគោរព មិនឲ្យ ដោយគោរព ១

៧១

## បណ្ណាសកេ សីហនាទវគ្គោ

ន ឧបនិសីទន្តិ ធម្មស្សវនាយ ភាសិតមស្ស ន រមិស្សន្តិ ។ ឥមេហិ ខោ ភិក្ខវេ នវហង្គេហិ សមន្នាគតំ កុលំ អនុបគន្ត្វា វា នាលំ ឧបគន្តុំ ឧបគន្ត្វា វា នាលំ និសីទិតុំ ។ នវហិ ភិក្ខវេ អង្គេហិ សមន្នាគតំ កុលំ អនុបគន្ត្វា វា អលំ ឧបគន្តុំ ឧបគន្ត្វា វា អលំ និសីទិតុំ ។ កតមេហិ នវហិ ។ មនាបេន បច្ចុដ្ឋេន្តិ មនាបេន អភិវាទេន្តិ មនាបេន អាសនំ ទេន្តិ សន្តមស្ស ន បរិគុយ្ហន្តិ ពហុកម្បិ ពហុកំ ទេន្តិ បណីតម្បិ បណីតំ ទេន្តិ សក្កច្ចំ ទេន្តិ នោ អសក្កច្ចំ ឧបនិសីទន្តិ ធម្មស្សវនាយ ភាសិតមស្ស រមិស្សន្តិ ។ ឥមេហិ ខោ ភិក្ខវេ នវហង្គេហិ សមន្នាគតំ កុលំ អនុបគន្ត្វា វា អលំ ឧបគន្តុំ ឧបគន្ត្វា វា អលំ និសីទិតុន្តិ ។

មិនចូលទៅអង្គុយជិត ដើម្បីស្តាប់ធម៌ដោយគោរព ១ មិនត្រេកអរនឹងភាសិតរបស់ភិក្ខុនោះ ១ ។ ម្នាលភិក្ខុទាំងឡាយ ត្រកូលប្រកបដោយអង្គ ៩ នេះឯង ដែលភិក្ខុមិនធ្លាប់ចូលទៅ ក៏មិនគួរចូលទៅ ឬ ចូលជ្រុលទៅហើយ ក៏មិនគួរអង្គុយ ។ ម្នាលភិក្ខុទាំងឡាយ ត្រកូលប្រកបដោយអង្គ ៩ ដែលភិក្ខុមិនទាន់ចូលទៅ ក៏ចូលទៅបាន ឬ ចូលទៅហើយ ក៏គួរអង្គុយបាន ។ ត្រកូលប្រកបដោយអង្គ ៩ តើដូចម្តេចខ្លះ ។ គឺគេក្រោកទទួល ដោយសេចក្តីពេញចិត្ត ១ ថ្វាយបង្គំដោយសេចក្តីពេញចិត្ត ១ ឲ្យអាសនៈ ដោយសេចក្តីពេញចិត្ត ១ មិនលាក់របស់ដែលមាន ១ របស់ដែលមានច្រើនឲ្យច្រើន ១ របស់ថ្លៃថ្លាឲ្យរបស់ថ្លៃថ្លា ១ ឲ្យដោយគោរព មិនឲ្យដោយមិនគោរព ១ ចូលទៅអង្គុយជិត ដើម្បីស្តាប់ធម៌ ១ ត្រេកអរនឹងភាសិតរបស់ភិក្ខុនោះ ១ ។ ម្នាលភិក្ខុទាំងឡាយ ត្រកូលប្រកបដោយអង្គ ៩ នេះឯង ដែលភិក្ខុមិនទាន់ចូលទៅ ក៏គួរចូលទៅបាន ឬចូលទៅហើយ ក៏គួរអង្គុយបាន ។

[១៨] នវហង្គេហិ សមន្នាគតោ ភិក្ខវេ ឧបោសថោ ឧបវុត្ថោ មហប្ផលោ ហោតិ មហានិសំសោ មហាជុតិកោ មហាវិប្ផារោ ។ កថំ ឧបវុត្ថោ ច ភិក្ខវេ នវហង្គេហិ សមន្នាគតោ ឧបោសថោ មហប្ផលោ ហោតិ មហានិសំសោ មហាជុតិកោ មហាវិប្ផារោ ។ ឥធ ភិក្ខវេ អរិយសាវកោ ឥតិ បដិសញ្ចិក្ខតិ យាវជីវំ អរហន្តោ បាណាតិបាតំ បហាយ បាណាតិបាតា បដិវិរតា និហិតទណ្ឌា និហិតសត្ថា លជ្ជី ទយាបន្នា សព្វបាណភូតហិតានុកម្បិនោ វិហរន្តិ អហម្បជ្ជ ឥមញ្ច រត្តឹ ឥមញ្ច ទិវសំ បាណាតិបាតំ បហាយ បាណាតិបាតា បដិវិរតោ និហិតទណ្ឌោ និហិតសត្ថោ លជ្ជី ទយាបន្នោ សព្វបាណភូតហិតានុកម្បី វិហរាមិ ឥមិនាបង្គេន អរហតំ អនុករោមិ ឧបោសថោ ច មេ ឧបវុត្ថោ ភវិស្សតីតិ ឥមិនា បឋមេន ចង្គេន សមន្នាគតោ ហោតិ ។ បេ ។

[១៨] ម្នាលភិក្ខុទាំងឡាយ ឧបោសថប្រកបដោយអង្គ ៩ ប្រការ ដែលបុគ្គលចាំរក្សាហើយ រមែងមានផលច្រើន មានអានិសង្សច្រើន មានសេចក្តីរុងរឿងច្រើន មានការផ្សាយទៅច្រើន ។ ម្នាលភិក្ខុទាំងឡាយ ឧបោសថប្រកបដោយអង្គ ៩ ប្រការ ដែលបុគ្គលចាំរក្សាហើយ រមែងមានផលច្រើន មានអានិសង្សច្រើន មានសេចក្តីរុងរឿងច្រើន មានការផ្សាយទៅច្រើន តើដោយប្រការដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវ័ក ក្នុងសាសនានេះ ពិចារណាដូច្នេះថា ព្រះអរហន្តទាំងឡាយ លះបង់បាណាតិបាត វៀរចាកបាណាតិបាត មានអាជ្ញាដាក់ចុះហើយ មានគ្រឿងសស្ត្រាដាក់ចុះហើយ មានសេចក្តីខ្មាស ដល់នូវសេចក្តីអាណិតអាសូរ អនុគ្រោះដោយប្រយោជន៍ដល់សត្វទាំងអស់ដរាបអស់ជីវិត ក្នុងថ្ងៃនេះ ចំណែកអាត្មាអញក៏លះបង់នូវបាណាតិបាត វៀរចាកបាណាតិបាត មានអាជ្ញាដាក់ចុះហើយ មានគ្រឿងសស្ត្រាដាក់ចុះហើយ មានសេចក្តីខ្មាស ដល់នូវសេចក្តីអាណិតអាសូរ អនុគ្រោះដោយប្រយោជន៍ដល់សត្វទាំងពួង អស់យប់នេះ និងថ្ងៃនេះដែរ អាត្មាអញយកតម្រាប់ព្រះអរហន្តផង អាត្មាអញនឹងចាំរក្សាឧបោសថដោយអង្គនេះផង ឧបោសថប្រកបដោយអង្គទី ១ នេះ ដូច្នេះ ។ បេ ។

## ៧៣



យាវជីវំ អរហន្តោ ឧច្ចាសយនមហាសយនំ បហាយ ឧច្ចាសយនមហាសយនា បដិវិរតា នីចសេយ្យំ កប្បេន្តិ មញ្ចកេ វា តិណសន្ថរកេ វា អហម្បជ្ជ ឥមញ្ច រត្តឹ ឥមញ្ច ទិវសំ ឧច្ចាសយនមហាសយនំ បហាយ ឧច្ចាសយនមហាសយនា បដិវិរតោ នីចសេយ្យំ កប្បេមិ មញ្ចកេ វា តិណសន្ថរកេ វា ឥមិនាបង្គេន អរហតំ អនុករោមិ ឧបោសថោ ច មេ ឧបវុត្ថោ ភវិស្សតីតិ ឥមិនា អដ្ឋមេន ចង្គេន សមន្នាគតោ ហោតិ មេត្តាសហគតេន ចេតសា ឯកំ ទិសំ ផរិត្វា វិហរតិ តថា ទុតិយំ តថា តតិយំ តថា ចតុត្ថំ ឥតិ ឧទ្ធមធោ តិរិយំ សព្វធិ សព្វត្តតាយ សព្វាវន្តំ លោកំ មេត្តាសហគតេន ចេតសា វិបុលេន មហគ្គតេន អប្បមាណេន អវេរេន អព្យាបជ្ឈេន ផរិត្វា វិហរតិ ឥតិ ឥមិនា នវមេន ចង្គេន សមន្នាគតោ ហោតិ ។ ឯវញ្ច ឧបវុត្ថោ ខោ ភិក្ខវេ នវង្គសមន្នាគតោ ឧបោសថោ មហប្ផលោ ហោតិ មហានិសំសោ មហាជុតិកោ មហាវិប្ផារោតិ ។

ព្រះអរហន្ត លះបង់ទីដេកដ៏ខ្ពស់ និងទីដេកដ៏ប្រសើរ វៀរចាកទីដេកដ៏ខ្ពស់ និងទីដេកដ៏ប្រសើរ សម្រេចនូវទីដេកដ៏ទាប គឺលើគ្រែតូចក្តី លើកម្រាលស្មៅក្តី ដរាបអស់ជីវិត ក្នុងថ្ងៃនេះ ចំណែកអាត្មាអញ ក៏លះបង់ទីដេកដ៏ខ្ពស់ និងទីដេកដ៏ប្រសើរ វៀរចាកទីដេកដ៏ខ្ពស់ និងទីដេកដ៏ប្រសើរ សម្រេចទីដេកដ៏ទាប គឺលើគ្រែតូចក្តី លើកម្រាលស្មៅក្តី អស់យប់នេះនិងថ្ងៃនេះដែរ អាត្មាអញយកតម្រាប់ព្រះអរហន្តផង អាត្មាអញនឹងរក្សាឧបោសថដោយអង្គនេះឯង ឧបោសថប្រកបដោយអង្គទី ៨ នេះដូច្នេះ បុគ្គលមានចិត្តប្រកបដោយមេត្តា ផ្សាយទៅកាន់ទិសទី ១ ទី ២ ទី ៣ ទី ៤ ក៏ដូចៗ គ្នា ផ្សាយទៅកាន់ទិសខាងលើ ខាងក្រោម និងទិសទទឹង មានចិត្តប្រកបដោយមេត្តាដ៏ទូលាយ ប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់សត្វលោកទាំងពួង ដោយយកខ្លួនប្រៀបផ្ទឹមនឹងសត្វទាំងពួង ក្នុងទីទាំងពួង ឧបោសថប្រកបដោយអង្គ ៩ នេះដូច្នេះ ។ ម្នាលភិក្ខុទាំង-ឡាយ ឧបោសថប្រកបដោយអង្គ ៩ ប្រការ ដែលបុគ្គលចាំរក្សាហើយរមែងមានផលច្រើន មានអានិសង្សច្រើន មានតេជះច្រើន មានការផ្សាយទៅច្រើន យ៉ាងនេះឯង ។

[១៩] ឥមញ្ច ភិក្ខវេ រត្តឹ សម្ពហុលា ទេវតា អភិក្កន្តាយ រត្តិយា អភិក្កន្តវណ្ណា កេវលកប្បំ ជេតវនំ ឱភាសេត្វា យេនាហំ តេនុបសង្កមឹសុ ឧបសង្កមិត្វា មំ អភិវាទេត្វា ឯកមន្តំ អដ្ឋំសុ ។ ឯកមន្តំ ឋិតា ខោ ភិក្ខវេ តា មំ ឯតទវោចុំ ឧបសង្កមឹសុ ទោ ភន្តេ បុព្វេ មនុស្សភូតានំ បព្វជិតា អគារានិ តេ មយំ ភន្តេ បច្ចុដ្ឋិម្ហ នោ ច ខោ អភិវាទិម្ហ តេ មយំ ភន្តេ អបរិបុណ្ណកម្មន្តា វិប្បដិសារិនិយោ បច្ឆានុតាបិនិយោ ហីនំ កាយំ ឧបបន្នាតិ ។ អបរាបិ មំ ភិក្ខវេ សម្ពហុលា ទេវតា ឧបសង្កមិត្វា ឯតទវោចុំ ឧបសង្កមឹសុ នោ ភន្តេ បុព្វេ មនុស្សភូតានំ បព្វជិតា អគារានិ តេ មយំ ភន្តេ បច្ចុដ្ឋិម្ហ ច អភិវាទិម្ហ ច នោ ច ខោ អាសនំ អទិម្ហ តេ មយំ ភន្តេ អបរិបុណ្ណកម្មន្តា វិប្បដិសារិនិយោ បច្ឆានុតាបិនិយោ

[១៩] ម្នាលភិក្ខុទាំងឡាយ ក្នុងវេលាយប់នេះ ពួកទេវតាជាច្រើន កាលដែលរាត្រីបឋមយាម កន្លងទៅហើយ មានរស្មីដ៏រុងរឿង ញុំាងវត្តជេតពនទាំងអស់ឲ្យភ្លឺច្បាស់ ចូលមករកតថាគត លុះចូលមកដល់ហើយ ក៏ថ្វាយបង្គំតថាគត ហើយឋិតនៅក្នុងទីសមគួរ ។ ម្នាលភិក្ខុទាំងឡាយ លុះពួកទេវតាទាំងនោះ ឋិតនៅក្នុងទីសមគួរហើយ បានពោលនឹងតថាគតដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ពួកបព្វជិតបានមកកាន់ផ្ទះយើងខ្ញុំព្រះអង្គ កាលដែលកើតជាមនុស្ស ក្នុងកាលមុន បពិត្រព្រះអង្គដ៏ចម្រើន យើងខ្ញុំព្រះអង្គទាំងនោះ បានក្រោកទទួលហើយ តែមិនបានថ្វាយបង្គំ បពិត្រព្រះអង្គដ៏ចម្រើន យើងខ្ញុំព្រះអង្គទាំងនោះ ជាអ្នកមានបុញ្ញកម្ម មិនបរិបូណ៌ គួរឲ្យមានសេចក្តីស្តាយក្តៅក្រហាយជាខាងក្រោយ ទើបបានទៅកើត ក្នុងពួកថោកទាប ។ ម្នាលភិក្ខុទាំងឡាយ ពួកទេវតាជាច្រើនពួកទៀត ចូលមករកតថាគតហើយពោលដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ពួកបព្វជិតចូលមកកាន់ផ្ទះរបស់យើងខ្ញុំព្រះអង្គ កាលដែលកើតជាមនុស្ស ក្នុងកាលមុន យើងខ្ញុំព្រះអង្គទាំងនោះបានក្រោកទទួលផង បានថ្វាយបង្គំផង ហើយតែមិនបានប្រគេនអាសនៈ បពិត្រព្រះអង្គដ៏ចម្រើន យើងខ្ញុំព្រះអង្គទាំងនោះ ជាអ្នកមានបុញ្ញកម្ម មិនបរិបូណ៌ មានសេចក្តីស្តាយ ក្តៅក្រហាយជាខាងក្រោយ

## ៧៤



ហីនំ កាយំ ឧបបន្នាតិ ។ អបរាបិ មំ ភិក្ខវេ សម្ពហុលា ទេវតា ឧបសង្កមិត្វា ឯតទវោចុំ ឧបសង្កមឹសុ នោ ភន្តេ បុព្វេ មនុស្សភូតានំ បព្វជិតា អគារានិ តេ មយំ ភន្តេ បច្ចុដ្ឋិម្ហ ច អភិវាទិម្ហ ច អាសនញ្ច អទម្ហ នោ ច ខោ យថាសត្តិ យថាពលំ សំវិភជិម្ហ ។ បេ ។ យថាសត្តិ យថាពលំ សំវិភជិម្ហ នោ ច ខោ ឧបនិសីទិម្ហ ធម្មស្សវនាយ ឧបនិសីទិម្ហ ធម្មស្សវនាយ នោ ច ខោ ឱហិតសោតា ធម្មំ សុណិម្ហ ឱហិតសោតា ធម្មំ សុណិម្ហ នោ ច ខោ សុត្វា ធម្មំ ធារយិម្ហ សុត្វា ច ធម្មំ ធារយិម្ហ នោ ច ខោ ធាតានំ ធម្មានំ អត្ថំ ឧបបរិក្ខិម្ហ ធាតានញ្ច ធម្មានំ អត្ថំ ឧបបរិក្ខិម្ហ នោ ច ខោ អត្ថមញ្ញាយ ធម្មមញ្ញាយ ធម្មានុធម្មប្បដិបជ្ជិម្ហ តេ មយំ ភន្តេ អបរិបុណ្ណកម្មន្តា វិប្បដិសារិនិយោ បច្ឆានុតាបិនិយោ ហីនំ កាយំ ឧបបន្នាតិ ។

ទើបបានទៅកើត ក្នុងពួកបោកទាប ។ ម្នាលភិក្ខុទាំងឡាយ ពួកទេវតាជាច្រើនផ្សេងៗ ទៀត ចូលមករកតថាគត បានពោលដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ពួកបព្វជិតបានចូលមកកាន់ផ្ទះរបស់យើងខ្ញុំព្រះអង្គ កាលដែលកើតជាមនុស្ស ក្នុងកាលមុន បពិត្រព្រះអង្គដ៏ចម្រើន យើងខ្ញុំទាំងនោះបានក្រោកទទួលផង ថ្វាយបង្គំផង បានប្រគេនអាសនៈផង តែមិនបានចាត់ចែង តាមសមគួរដល់យសស័ក្តិ តាមសមគួរដល់កម្លាំង ។ បេ ។ ចាត់ចែងតាមសមគួរដល់យសស័ក្តិ តាមសមគួរដល់កម្លាំងហើយ តែមិនបានចូលទៅអង្គុយជិត ដើម្បីស្តាប់ធម៌ បានចូលទៅអង្គុយជិត ដើម្បីស្តាប់ធម៌ហើយ តែមិនបានផ្ទង់ត្រចៀកស្តាប់ធម៌ បានផ្ទង់ត្រចៀកស្តាប់ធម៌ហើយ តែជាស្តាប់ធម៌ហើយមិនបានចាំទុក បានស្តាប់ធម៌ចាំទុកហើយ តែជាមិនបានពិចារណាសេចក្តីនៃធម៌ដែលចាំទុក ពិចារណាសេចក្តីនៃធម៌ដែលចាំទុកបានហើយ តែជាយល់អត្ថ យល់ធម៌ហើយ មិនបានប្រតិបត្តិធម៌ តាមសមគួរដល់ធម៌ បពិត្រព្រះអង្គដ៏ចម្រើន យើងខ្ញុំព្រះអង្គទាំងនោះ ជាអ្នកមានបុញ្ញកម្ម មិនបរិបូណ៌ គួរឲ្យមានសេចក្តីស្តាយ ក្តៅក្រហាយខាងក្រោយ ទើបទៅកើត ក្នុងពួកបោកទាប ។

អបរាបិ មំ ភិក្ខវេ សម្ពហុលា ទេវតា ឧបសង្កមិត្វា ឯតទវោចុំ ឧបសង្កមឹសុ នោ ភន្តេ បុព្វេ មនុស្ស-ភូតានំ បព្វជិតា អគារានិ តេ មយំ ភន្តេ បច្ចុដ្ឋិម្ហ ច អភិវាទិម្ហ ច អាសនញ្ច អទិម្ហ យថាសត្តិ យថាពលំ សំវិភជិម្ហ ឧបនិសីទិម្ហ ច ធម្មស្សវនាយ ឱហិតស្សោតា ច ធម្មំ សុណិម្ហ សុត្វា ធម្មំ ធារយិម្ហ ធាតានញ្ច ធម្មានំ អត្ថំ ឧបបរិក្ខិម្ហ អត្ថមញ្ញាយ ធម្មមញ្ញាយ ធម្មានុធម្មប្បដិបជ្ជិម្ហ តេ មយំ ភន្តេ បរិបុណ្ណកម្មន្តា អវិប្បដិសារិនិយោ អបច្ឆានុតាបិនិយោ បណីតំ កាយំ ឧបបន្នាតិ ។ ឯតានិ ភិក្ខវេ រុក្ខមូ-លានិ ឯតានិ សុញ្ញាគារានិ ឈាយថ ភិក្ខវេ មា បមាទថ មា បច្ឆាវិប្បដិសារិនោ អហុវត្ថ សេយ្យថាបិ តា បុរិមិកា ទេវតាតិ ។

ម្នាលភិក្ខុទាំងឡាយ ពួកទេវតាជាច្រើនផ្សេងទៀត ចូលមករកតថាគត ហើយពោលដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ពួកបព្វជិតចូលមកកាន់ផ្ទះរបស់យើងខ្ញុំព្រះអង្គ កាលដែលកើតជាមនុស្ស ក្នុងកាលមុន យើងខ្ញុំព្រះអង្គទាំងនោះ បានក្រោកទទួលផង បានថ្វាយបង្គំផង បានប្រគេនអាសនៈផង បានចាត់ចែង តាមសមគួរដល់យសស័ក្តិ តាមសមគួរដល់កម្លាំងផង ចូលទៅអង្គុយជិតស្តាប់ធម៌ផង ផ្ទង់ត្រចៀកស្តាប់ធម៌ផង ស្តាប់ធម៌ហើយ បានចាំទុកផង បានពិចារណាសេចក្តីនៃធម៌ដែលចាំទុកផង យល់អត្ថ យល់ធម៌ ហើយប្រតិបត្តិធម៌តាមសមគួរដល់ធម៌ផង បពិត្រព្រះអង្គដ៏ចម្រើន យើងខ្ញុំព្រះអង្គទាំងនោះ ជាអ្នកមានបុញ្ញកម្មបរិបូណ៌ មិនមានសេចក្តីស្តាយ ក្តៅក្រហាយខាងក្រោយ ទើបបានទៅកើត ក្នុងពួកខ្ពង់ខ្ពស់ ។ ម្នាលភិក្ខុទាំងឡាយ នុ៎ះជារុក្ខមូល នុ៎ះជាសុញ្ញាគារដ្ឋាន ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរចម្រើនឈាន ចូរកុំប្រមាទ ចូរកុំមានសេចក្តីស្តាយ ក្នុងកាលខាងក្រោយ ដូចជាពួកទេវតាមុននោះឡើយ ។

បណ្ណាសកេ សីហនាទវគ្គោ

[២០] ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ អថខោ អនាថបិណ្ឌិកោ គហបតិ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ អនាថបិណ្ឌិកំ គហបតឹ ភគវា ឯតទវោច អបិ នុ តេ គហបតិ កុលេ ទានំ ទិយ្យតីតិ ។ ទិយ្យតិ មេ ភន្តេ កុលេ ទានំ តញ្ច ខោ លូខំ កាណាជកំ ពិលង្គទុតិយន្តិ ។ លូខំ វាបិ គហបតិ ទានំ ទេតិ បណីតំ វា តញ្ច អសក្កច្ចំ ទេតិ អបចិត្តឹ កត្វា ទេតិ អសហត្ថា ទេតិ អបវិទ្ធំ ទេតិ អនាគមនទិដ្ឋិកោ ទេតិ យត្ថ យត្ថ តស្ស តស្ស ទានស្ស វិបាកោ និព្វត្តតិ ន ឧឡារាយ ភត្តភោគាយ ចិត្តំ នមតិ ន ឧឡារាយ វត្ថភោគាយ ចិត្តំ នមតិ ន ឧឡារាយ យានភោគាយ ចិត្តំ នមតិ ន ឧឡារេសុ បញ្ចសុ កាមគុណេសុ ភោគាយ ចិត្តំ នមតិ យេបិស្ស តេ ហោន្តិ បុត្តាតិ វា ទារាតិ វា ទាសាតិ វា

បណ្ណាសក សីហនាទវគ្គ

[២០] *សម័យមួយ ព្រះដ៏មានព្រះភាគ កាលគង់ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះ អនាថបិណ្ឌិក-គហបតី ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះអនាថបិណ្ឌិក-គហបតី អង្គុយក្នុងទីសមគួរហើយ ទើបព្រះដ៏មានព្រះភាគទ្រង់ត្រាស់សួរដូច្នេះថា ម្នាលគហបតី ទានក្នុងត្រកូលអ្នកនៅតែឲ្យដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ទានក្នុងត្រកូលខ្ញុំព្រះអង្គនៅតែឲ្យដែរ តែទាននោះឯងសៅហ្មង គឺបាយចុងអង្ករនិងទឹកជ្រក់ជាគម្រប់ពីរ ។ ម្នាលគហបតី បុគ្គលឲ្យទានសៅហ្មងក្តី ឲ្យទានថ្លៃថ្លាក្តី តែឲ្យទាននោះមិនគោរព ធ្វើសេចក្តីមិនកោតក្រែងហើយឲ្យ មិនឲ្យដោយដៃខ្លួនឯង បោះឲ្យ យល់ថាមិនមានផលហើយឲ្យ វិបាករបស់ទាននោះៗកើតក្នុងត្រកូលណាៗ ចិត្តក៏មិនឱនទៅ ដើម្បីប្រើប្រាស់នូវភត្តដ៏ថ្លៃថ្លា ចិត្តមិនឱនទៅ ដើម្បីប្រើប្រាស់នូវសំពត់ដ៏ថ្លៃថ្លា ចិត្តមិនឱនទៅ ដើម្បីប្រើប្រាស់យានដ៏ថ្លៃថ្លា ចិត្តមិនឱនទៅ ដើម្បីប្រើប្រាស់ក្នុងកាមគុណ ៥ ដ៏ថ្លៃថ្លា មួយទៀត ពួកជនណា ដែលជាកូនក្តី ប្រពន្ធក្តី ទាសៈក្តី*

បេស្សាតិ វា កម្មករាតិ វា តេបិ ន សុស្សុសន្តិ ន សោតំ ឱទហន្តិ អញ្ញាចិត្តំ ឧបដ្ឋបេន្តិ ។ តំ កិស្ស ហេតុ ។ ឯវញ្ហេតំ គហបតិ ហោតិ អសក្កច្ចកតានំ កម្មានំ វិបាកោ លូខំ វាបិ គហបតិ ទានំ ទេតិ បណីតំ វា តញ្ច សក្កច្ចំ ទេតិ បចិត្តីកត្វា ទេតិ សហត្ថា ទេតិ អនបវិទ្ធំ ទេតិ អាគមនទិដ្ឋិកោ ទេតិ យត្ថ យត្ថ តស្ស តស្ស ទានស្ស វិបាកោ និព្វត្តតិ ឧឡារាយ ភត្តភោគាយ ចិត្តំ នមតិ ឧឡារាយ វត្ថភោគាយ ចិត្តំ នមតិ ឧឡារាយ យានភោគាយ ចិត្តំ នមតិ ឧឡារេសុ បញ្ចសុ កាមគុណេសុ ភោគាយ ចិត្តំ នមតិ យេបិស្ស តេ ហោន្តិ បុត្តាតិ វា ទារាតិ វា ទាសាតិ វា បេស្សាតិ វា កម្មករាតិ វា តេបិ សុស្សុសន្តិ សោតំ ឱទហន្តិ ន អញ្ញាចិត្តំ ឧបដ្ឋហន្តិ ។ តំ កិស្ស ហេតុ ។ ឯវញ្ហេតំ គហបតិ ហោតិ សក្កច្ចកតានំ កម្មានំ វិបាកោ ។ ភូតបុព្វំ គហបតិ វេលាមោ នាម ព្រាហ្មណោ អហោសិ សោ ឯវរូបំ ទានំ អទាសិ មហាទានំ

អ្នកបម្រើក្តី កម្មករក្តី របស់បុគ្គលនោះ ជនទាំងនោះមិនស្តាប់ មិនផ្ទង់ត្រចៀកស្តាប់ រមែងបញ្ជូនចិត្តទៅក្នុងអារម្មណ៍ដទៃ ។ ដំណើរនោះព្រោះហេតុអ្វី ។ ម្នាលគហបតី ព្រោះថា វិបាកនៃកម្មទាំងឡាយដែលបុគ្គលធ្វើដោយមិនគោរព រមែងមានយ៉ាងនេះឯង ម្នាលគហបតី បុគ្គលឲ្យទានសៅហ្មងក្តី ថ្លៃថ្លាក្តី តែឲ្យទាននោះដោយគោរព ធ្វើសេចក្តីកោតក្រែងហើយឲ្យ ឲ្យដោយដៃខ្លួនឯង មិនបោះទុយ យល់ថាមានផលហើយឲ្យ វិបាករបស់ទាននោះៗ កើតក្នុងត្រកូលណាៗ ចិត្តក៏រមែងឱនទៅ ដើម្បីប្រើប្រាស់ភត្តដ៏ថ្លៃថ្លា ចិត្តរមែងឱនទៅ ដើម្បីប្រើប្រាស់សំពត់ដ៏ថ្លៃថ្លា ចិត្តរមែងឱនទៅ ដើម្បីប្រើប្រាស់យានដ៏ថ្លៃថ្លា ចិត្តរមែងឱនទៅ ដើម្បីប្រើប្រាស់ក្នុងកាមគុណ ៥ ដ៏ថ្លៃថ្លា មួយទៀត ពួកជនណាដែលជាកូនក្តី ប្រពន្ធក្តី ទាសៈក្តី អ្នកបម្រើក្តី កម្មករក្តី របស់បុគ្គលនោះ ជនទាំងនោះ រមែងស្តាប់ ផ្ទង់ត្រចៀកស្តាប់ មិនបញ្ជូនចិត្ត ទៅក្នុងអារម្មណ៍ដទៃឡើយ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលគហបតី ព្រោះថាវិបាករបស់កម្មទាំងឡាយ ដែលបុគ្គលធ្វើដោយគោរព រមែងមានយ៉ាងនេះឯង ។ ម្នាលគហបតី កាលពីព្រេងនាយ មានព្រាហ្មណ៍ឈ្មោះវេលាម លោកបានឲ្យទាន ជាមហាទាន មានសភាពយ៉ាងនេះ

៧៩

បណ្ណាសកេ  សីហនាទវគ្គោ

ចតុរាសីតិ សុវណ្ណចាតិសហស្សានិ អទាសិ រូបិយ-
បូរានិ ចតុរាសីតិ រូបិយចាតិសហស្សានិ អទាសិ
សុវណ្ណបូរានិ ចតុរាសីតិ កំសចាតិសហស្សនិ អទាសិ
ហិរញ្ញបូរានិ ចតុរាសីតិ ហត្ថិសហស្សានិ អទាសិ
សោវណ្ណាលង្ការានិ សោវណ្ណទ្ធជានិ ហេមជាលប្ប-
ដិច្ឆន្នានិ ចតុរាសីតិ រថសហស្សានិ អទាសិ សីហ-
ចម្មបរិវារានិ ព្យគ្ឃចម្មបរិវារានិ ទីបិចម្មបរិវារានិ បណ្ឌុ-
កម្ពលបរិវារានិ សោវណ្ណាលង្ការានិ សោវណ្ណទ្ធជានិ
ហេមជាលប្បដិច្ឆន្នានិ ចតុរាសីតិ ធេនុសហស្សានិ
អទាសិ ទុកុលសន្ទនានិ កំសូបធារណានិ ចតុរាសីតិ
កញ្ញាសហស្សានិ អទាសិ អាមុត្តមណិកុណ្ឌលាយោ
ចតុរាសីតិ បល្លង្កសហស្សានិ អទាសិ គោនកត្ថតានិ
បដិកត្ថតានិ បដលិកត្ថតានិ កទលិមិគប្បវរប្បច្ចត្ថ-
រណានិ សឧត្តរច្ឆទានិ ឧភតោលោហិតកូបធានានិ
ចតុរាសីតិ វត្ថកោដិសហស្សានិ អទាសិ ខោមសុ-
ខុមានំ កោសេយ្យសុខុមានំ កប្បាសិកសុខុមានំ

គឺបានឲ្យភាជន៍មាស ៨៤.០០០ ដែលពេញដោយប្រាក់ បានឲ្យភាជន៍ប្រាក់ ៨៤.០០០ ដែលពេញដោយមាស បានឲ្យភាជន៍សំរិទ្ធិ ៨៤.០០០ ដែលពេញដោយប្រាក់ បានឲ្យដំរី ៨៤.០០០ ដែលមានគ្រឿងអលង្ការមាស មានទង់ជ័យមាស ព្រមទាំងដោយបណ្ដាញមាស បានឲ្យរថ ៨៤.០០០ ដែលពាសដោយស្បែកសីហៈ ដែលពាសដោយស្បែកខ្លាធំ ពាសដោយស្បែកខ្លាដំបង ពាសដោយសំពត់កម្ពល មានពណ៌លឿង មានគ្រឿងអលង្ការមាស មានទង់ជ័យមាស បិទបាំងដោយបណ្ដាញមាស បានឲ្យមេគោ ៨៤.០០០ សម្រាប់រឹតបង្ហូរ (ទឹកដោះ) មានភាជន៍សំរិទ្ធិសម្រាប់ត្រង បានឲ្យនាងកញ្ញា ៨៤.០០០ ដែលពាក់កែវមណីនិងកណ្ឌល បានឲ្យបល្ល័ង្ក ៨៤.០០០ ដែលក្រាលដោយព្រំ ក្រាលដោយកម្រាលរោម មានពណ៌ស ក្រាលដោយកម្រាលរោមមានផ្កាជាចង្កោម ក្រាលដោយកម្រាល ដ៏ប្រសើរធ្វើពីរោមម្រឹគឈ្មុស មានខ្នើយមានពណ៌ក្រហម ទាំងពីរខាង ព្រមទាំងពិតានមានពណ៌ក្រហម បានឲ្យកោដិ[១] នៃសំពត់ ៨៤.០០០ គឺ សំពត់ធ្មៃមានសាច់ល្អិត សំពត់សូត្រមានសាច់ល្អិត សំពត់អំបោះមានសាច់ល្អិត

១ កោដិក្នុងទីនេះសំដៅយក សំពត់សាដក ១០ ហៅថាមួយកោដិ ។ អដ្ឋកថា ។

កោ បន វាទោ អន្នស្ស ចានស្ស ខជ្ជស្ស ភោជនស្ស លេបនស្ស សេយ្យស្ស នជ្ជោ មញ្ញេ វិសន្ទន្តិ សិយា ខោ បន តេ គហបតិ ឯវមស្ស អញ្ញោ នូន តេន សមយេន វេលាមោ ព្រាហ្មណោ អហោសិ សោ តំ ទានំ អទាសិ មហាទានន្តិ ។ ន ខោ បនេតំ គហបតិ ឯវំ ទដ្ឋព្វំ អហំ តេន សមយេន វេលាមោ ព្រាហ្មណោ អហោសឹ អហំ តំ ទានំ អទាសឹ មហាទានំ ។ តស្មឹ ខោ បន គហបតិ ទានេ ន កោចិ ទក្ខិណេយ្យោ អហោសិ ន តំ កោចិ ទក្ខិណំ វិសោធេតិ ។ យំ គហបតិ វេលាមោ ព្រាហ្មណោ ទានំ អទាសិ មហាទានំ យោ ចេកំ ទិដ្ឋិសម្បន្នំ ភោជេយ្យ ឥទំ តតោ មហប្ផលតរំ យោ ច សតំ ទិដ្ឋិសម្បន្នានំ ភោជេយ្យ យោ ចេកំ សកទាគាមឹ ភោជេយ្យ ។ បេ ។ យោ ច សតំ សកទាគាមីនំ ភោជេយ្យ យោ ចេកំ អនាគាមឹ ភោជេយ្យ យោ ច សតំ អនាគាមីនំ ភោជេយ្យ

បាច់និយាយថ្វី ដល់បាយ ទឹក បង្អែម ភោជន គ្រឿងលាប ទីដេក ដូចជាស្ទឹងតែងហូរទៅ ម្នាលគហបតី អ្នកប្រហែលជាមាន សេចក្តីសម្គាល់នូវវេលាមព្រាហ្មណ៍នុ៎ះ យ៉ាងនេះថា ក្នុងសម័យនោះ វេលាមព្រាហ្មណ៍ជាបុគ្គលដទៃដោយពិត (ក្រៅពីតថាគត) លោក បានឲ្យទាននោះជាមហាទាន ។ ម្នាលគហបតី ហេតុនុ៎ះ អ្នកមិនត្រូវ យល់យ៉ាងនេះឡើយ ក្នុងសម័យនោះ វេលាមព្រាហ្មណ៍ ក៏គឺតថាគត ទានដែលតថាគតបានឲ្យនោះ ជាមហាទាន ។ ម្នាលគហបតី មិនមាន ទក្ខិណេយ្យបុគ្គលណាមួយ ក្នុងទាននោះទេ មិនមានបុគ្គលណាមួយ សម្អាតទក្ខិណាទាននោះទេ ។ ម្នាលគហបតី វេលាមព្រាហ្មណ៍បាន ឲ្យទានណា ដែលឈ្មោះថាមហាទាន និងបុគ្គលណាញ៉ាំងបុគ្គលដែល មានទិដ្ឋិល្អ ១ រូប (សោតាបន្នបុគ្គល) ឲ្យបរិភោគ ទាននេះ ជាទាន មានផលច្រើនជាងមហាទាន បុគ្គលណា ញ៉ាំងបុគ្គល ដែលមានទិដ្ឋិ ល្អ ១០០ រូបឲ្យបរិភោគ និងបុគ្គលណា ញ៉ាំងបុគ្គល ជាសកទាគាមី ១ រូបឲ្យបរិភោគ ។ បេ ។ បុគ្គលណា ញ៉ាំងបុគ្គល ជាសកទាគាមី ១០០ រូបឲ្យបរិភោគ និងបុគ្គលណា ញ៉ាំងបុគ្គល ជាអនាគាមី ១ រូបឲ្យ បរិភោគ បើបុគ្គលណា ញ៉ាំងបុគ្គល ជាអនាគាមី ១០០ រូបឲ្យបរិភោគ

យោ ចេតំ អរហន្តំ ភោជេយ្យ យោ ច សតំ អរហន្តានំ ភោជេយ្យ យោ ចេតំ បច្ចេកពុទ្ធំ ភោជេយ្យ យោ ច សតំ បច្ចេកពុទ្ធានំ ភោជេយ្យ យោ ច តថាគតំ អរហន្តំ សម្មាសម្ពុទ្ធំ ភោជេយ្យ យោ ច ពុទ្ធប្បមុខំ ភិក្ខុសង្ឃំ ភោជេយ្យ យោ ច ចាតុទ្ទិសំ សង្ឃំ ឧទ្ទិស្ស វិហារំ ការាបេយ្យ យោ ច បសន្នចិត្តោ ពុទ្ធញ្ច ធម្មញ្ច សង្ឃញ្ច សរណំ គច្ឆេយ្យ យោ ច បសន្នចិត្តោ សិក្ខាបទានិ សមាទិយេយ្យ បាណាតិបាតា វេរមណី អទិន្នាទានា វេរមណី កាមេសុ មិច្ឆាចារា វេរមណី មុសាវាទា វេរមណី សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី យោ ច បសន្នចិត្តោ សិក្ខាបទានិ សមាទិយេយ្យ បាណាតិបាតា វេរមណី ។ បេ ។ សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី យោ ច អន្តមសោ គទ្ទូហនមត្តម្បិ[១] មេត្តចិត្តំ ភាវេយ្យ ឥទំ តតោ មហប្ផលតរំ ។

១ ម. គន្ធោហនមត្តម្បិ ។ អដ្ឋកថាយំ បន គទ្ទូហនមត្តំ គោទោហនមត្តំ វាតិ ទិស្សតិ ។

និងបុគ្គលណា ញ៉ាំងបុគ្គលជាព្រះអរហន្ត ១ រូបឲ្យបរិភោគ បុគ្គលណា ញ៉ាំងបុគ្គលជាព្រះអរហន្ត ១០០ រូបឲ្យបរិភោគ និងបុគ្គលណា ញ៉ាំងព្រះបច្ចេកពុទ្ធ ១ អង្គឲ្យបរិភោគ បុគ្គលណា ញ៉ាំងព្រះបច្ចេកពុទ្ធ ១០០ អង្គឲ្យបរិភោគ និងបុគ្គលណា ញ៉ាំងព្រះតថាគត អរហន្តសម្មាសម្ពុទ្ធឲ្យបរិភោគ បុគ្គលណា ញ៉ាំងសង្ឃ មានព្រះពុទ្ធជាប្រធានឲ្យបរិភោគ និងបុគ្គលណា ឲ្យគេធ្វើវិហារ ឧទ្ទិសចំពោះសង្ឃមកពីទិសទាំង ៤ បុគ្គលណា មានចិត្តជ្រះថ្លាដល់នូវព្រះពុទ្ធផង ព្រះធម៌ផង ព្រះសង្ឃផង ជាទីពឹង និងបុគ្គលណា មានចិត្តជ្រះថ្លា សមាទាន នូវសិក្ខាបទទាំងឡាយ គឺចេតនាវៀរចាកបាណាតិបាត វៀរចាកអទិន្នាទាន វៀរចាកកាមេសុមិច្ឆាចារ វៀរចាកមុសាវាទ វៀរចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ ដោយការផឹក នូវទឹកស្រវឹងគឺសុរានិងមេរ័យ បុគ្គលណា មានចិត្តជ្រះថ្លា សមាទាន នូវសិក្ខាបទទាំងឡាយ គឺចេតនាវៀរចាកបាណាតិបាត ។ បេ ។ វៀរចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ ដោយការផឹក នូវទឹកស្រវឹងគឺសុរានិងមេរ័យ ដោចហោចទៅ បុគ្គលណា ចម្រើននូវមេត្តាចិត្ត សូម្បីអស់កាលត្រឹមតែមួយរឹតទឹកដោះគោប៉ុណ្ណោះ ការចម្រើនមេត្តាចិត្តនេះ របស់បុគ្គលទាំងនោះ មានផលច្រើន ជាងទាននោះទៅទៀត ។

យញ្ច គហបតិ វេលាមោ ព្រាហ្មណោ ទានំ អទាសិ មហាទានំ យោ ចេកំ ទិដ្ឋិសម្បន្នំ ភោជេយ្យ យោ ច សតំ ទិដ្ឋិសម្បន្នានំ ភោជេយ្យ យោ ចេកំ សកទា-គាមឹ ភោជេយ្យ យោ ច សតំ សកទាគាមីនំ ភោជេយ្យ យោ ចេកំ អនាគាមឹ ភោជេយ្យ យោ ច សតំ អនាគាមីនំ ភោជេយ្យ យោ ចេកំ អរហន្តំ ភោជេយ្យ យោ ច សតំ អរហន្តានំ ភោជេយ្យ យោ ចេកំ បច្ចេកពុទ្ធំ ភោជេយ្យ យោ ច សតំ បច្ចេកពុទ្ធានំ ភោជេយ្យ យោ ច តថាគតំ អរហន្តំ សម្មាសម្ពុទ្ធំ ភោជេយ្យ យោ ច ពុទ្ធប្បមុខំ ភិក្ខុសង្ឃំ ភោជេយ្យ យោ ច ចាតុទ្ទិសំ សង្ឃំ ឧទ្ទិស្ស វិហារំ ការាបេយ្យ យោ ច បសន្នចិត្តោ ពុទ្ធញ្ច ធម្មញ្ច សង្ឃញ្ច សរណំ គច្ឆេយ្យ យោ ច បសន្នចិត្តោ សិក្ខាបទានិ សមាទិយេយ្យ បាណាតិបាតា វេរមណី ។ បេ ។ សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី

ម្នាលគហបតី វេលាមព្រាហ្មណ៍ បានឲ្យទាន ជាមហាទានណា និងបុគ្គលណា ញុំាងបុគ្គលមានទិដ្ឋិល្អ ១ រូបឲ្យបរិភោគ បុគ្គលណា ញុំាងបុគ្គលមានទិដ្ឋិល្អ ១០០ រូបឲ្យបរិភោគ និងបុគ្គលណា ញុំាងបុគ្គល ជាសកទាគាមី ១ រូបឲ្យបរិភោគ បុគ្គលណា ញុំាងបុគ្គល ជាសកទាគាមី ១០០ រូបឲ្យបរិភោគ និងបុគ្គលណា ញុំាងបុគ្គល ជាអនាគាមី ១ រូបឲ្យបរិភោគ បុគ្គលណា ញុំាងបុគ្គល ជាអនាគាមី ១០០ រូបឲ្យបរិភោគ និងបុគ្គលណា ញុំាងព្រះអរហន្ត ១ អង្គឲ្យបរិភោគ បុគ្គលណា ញុំាងព្រះអរហន្ត ១០០ អង្គឲ្យបរិភោគ និងបុគ្គលណា ញុំាងព្រះបច្ចេកពុទ្ធ ១ អង្គឲ្យបរិភោគ បុគ្គលណា ញុំាងពួកព្រះបច្ចេកពុទ្ធ ១០០ អង្គឲ្យបរិភោគ និងបុគ្គលណា ញុំាងព្រះតថាគត អរហន្តសម្មាសម្ពុទ្ធឲ្យបរិភោគ បុគ្គលណា ញុំាងភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានឲ្យបរិភោគ និងបុគ្គលណា ឲ្យគេធ្វើវិហារ ឧទ្ទិសចំពោះសង្ឃមកអំពីទិសទាំង ៤ បុគ្គលណា មានចិត្តជ្រះថ្លាដល់នូវព្រះពុទ្ធផង ព្រះធម៌ផង ព្រះសង្ឃផង ជាទីពឹង និងបុគ្គលណា មានចិត្តជ្រះថ្លា សមាទាននូវសិក្ខាបទទាំងឡាយ គឺចេតនាវៀរចាកបាណាតិបាត ។ បេ ។ វៀរចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ ដោយការផឹក នូវទឹកស្រវឹងគឺសុរានិងមេរ័យ

៨៣



យោ ច អន្តមសោ គន្ធូហនមត្តម្បិ មេត្តចិត្តំ ភាវេយ្យ យោ ច អច្ឆរាសង្ឃាតមត្តម្បិ អនិច្ចសញ្ញំ ភាវេយ្យ ឥទំ តតោ មហប្ផលតរន្តិ ។

សីហនាទវគ្គោ ទុតិយោ ។

តត្រុទ្ទានំ

វុត្ថោ សឧចាជិសោសោ ច កោដ្ឋិតេន សមិទ្ធិនា គណ្ឌសញ្ញា កុលេ សត្តា[១] ទេវតា វេលាមេន ចាតិ ។

១ ឱ. ម. មេត្តា ។

ដោយហោចទៅ និងបុគ្គលណា ចម្រើនូវមេត្តាចិត្ត សូម្បីអស់កាលត្រឹមតែមួយរីតទឹកដោះគោប៉ុណ្ណោះ និងបុគ្គលណា ចម្រើននូវអនិច្ចសញ្ញា សូម្បីអស់កាលគ្រាន់តែផ្ទាត់ម្រាមដៃប៉ុណ្ណោះ ការចម្រើននេះមានផលច្រើនជាងទាននោះទៅទៀត ។

ចប់ សីហនាទវគ្គទី ២ ។

ឧទ្ទានក្នុងសីហនាទវគ្គនោះគឺ

និយាយអំពីការចាំរក្សាឧបោសថ ១ សឧបាទិសេស និងអនុបាទិសេស ១ ព្រះកោដ្ឋិតភិក្ខុ ១ ព្រះសមិទ្ធិភិក្ខុ ១ កាយដូចជាបូស ១ សញ្ញា ១ ត្រកូល ១ មេត្តា ១ ទេវតា ១ វេលាមព្រាហ្មណ៍ ១ ។

# តតិយោ សត្តាវាសវគ្គោ

[២១] តីហិ ភិក្ខវេ ឋានេហិ ឧត្តរកុរុកា មនុស្សា ទេវេ ច តាវត្តឹសេ អធិគ្គណ្ហន្តិ ជម្ពុទីបកេ ច មនុស្សេ ។ កតមេហិ តីហិ ។ អមមា អបរិគ្គហា និយតាយុកា វិសេសគុណា ។ ឥមេហិ ខោ ភិក្ខវេ តីហិ ឋានេហិ ឧត្តរកុរុកា មនុស្សា ទេវេ ច តាវត្តឹសេ អធិគ្គណ្ហន្តិ ជម្ពុទីបកេ ច មនុស្សេ ។ តីហិ ភិក្ខវេ ឋានេហិ ទេវា តាវត្តឹសា ឧត្តរកុរុកេ ច មនុស្សេ អធិគ្គណ្ហន្តិ ជម្ពុទីបកេ ច មនុស្សេ ។ កតមេហិ តីហិ ។ ទិព្វេន អាយុនា ទិព្វេន វណ្ណេន ទិព្វេន សុខេន ។ ឥមេហិ ខោ ភិក្ខវេ តីហិ ឋានេហិ ទេវា តាវត្តឹសា ឧត្តរកុរុកេ ច មនុស្សេ អធិគ្គណ្ហន្តិ ជម្ពុទីបកេ ច មនុស្សេ ។ តីហិ ភិក្ខវេ ឋានេហិ ជម្ពុទីបកា មនុស្សា ឧត្តរកុរុកេ ច មនុស្សេ អធិគ្គណ្ហន្តិ ទេវេ ច តាវត្តឹសេ ។ កតមេហិ តីហិ ។

# សត្តាវាសវគ្គ ទី ៣

[២១] ម្នាលភិក្ខុទាំងឡាយ ពួកមនុស្សអ្នកនៅក្នុងឧត្តរកុរុទ្វីប ខ្ពង់ខ្ពស់ ហួសពួកទេវតាជាន់តាវត្តិង្សផង និងពួកមនុស្សអ្នកនៅក្នុងជម្ពូទ្វីបផង ដោយស្ថាន ៣ យ៉ាង ។ ស្ថាន ៣ យ៉ាង តើដូចម្តេចខ្លះ ។ គឺមិនមានសេចក្តីអន្ទះសា ១ មិនមានសេចក្តីហួងហែង ១ មានអាយុទៀង មានកំណើតដ៏វិសេស ១ ។ ម្នាលភិក្ខុទាំងឡាយ ពួកមនុស្សនៅក្នុងឧត្តរកុរុទ្វីប តែងខ្ពង់ខ្ពស់ ហួសពួកទេវតាជាន់តាវត្តិង្សផង និងពួកមនុស្សអ្នកនៅក្នុងជម្ពូទ្វីបផង ដោយស្ថាន ៣ យ៉ាង នេះឯង ។ ម្នាលភិក្ខុទាំងឡាយ ពួកទេវតាជាន់តាវត្តិង្ស ខ្ពង់ខ្ពស់ហួសពួកមនុស្សអ្នកនៅក្នុងឧត្តរកុរុទ្វីបផង និងពួកមនុស្សអ្នកនៅក្នុងជម្ពូទ្វីបផង ដោយស្ថាន ៣ យ៉ាង ។ ស្ថាន ៣ យ៉ាង តើដូចម្តេចខ្លះ ។ គឺអាយុជាទិព្វ ១ សម្បុរជាទិព្វ ១ សេចក្តីសុខជាទិព្វ ១ ។ ម្នាលភិក្ខុទាំងឡាយ ពួកទេវតាជាន់តាវត្តិង្ស តែងខ្ពង់ខ្ពស់ហួសពួកមនុស្សអ្នកនៅ ក្នុងឧត្តរ-កុរុទ្វីបផង និងពួកមនុស្សអ្នកនៅ ក្នុងជម្ពូទ្វីបផង ដោយស្ថាន ៣ យ៉ាង នេះឯង ។ ម្នាលភិក្ខុទាំងឡាយ ពួកមនុស្សអ្នកនៅក្នុងជម្ពូទ្វីប ខ្ពង់ខ្ពស់ហួសពួកមនុស្សអ្នកនៅក្នុងឧត្តរកុរុទ្វីបផង និងពួកទេវតាជាន់តាវត្តិង្សផង ដោយស្ថាន ៣ យ៉ាង ។ ស្ថាន ៣ យ៉ាង តើដូចម្តេចខ្លះ ។

សុរា សតិមន្តោ អធិព្រហ្មចរិយវាសា[១] ។ ឥមេហិ ខោ ភិក្ខវេ តីហិ ឋានេហិ ជម្ពុទីបកា មនុស្សា ឧត្តរកុរុកេ ច មនុស្សេ អធិគ្គណ្ហន្តិ ទេវេ ច តាវត្តឹសេតិ ។

[២២] តយោ ច ភិក្ខវេ អស្សខឡុង្គេ[២] ទេសេស្សាមិ តយោ ច បុរិសខឡុង្គេ តយោ ច អស្សសទស្សេ តយោ ច បុរិសសទស្សេ តយោ ច ភទ្រេ អស្សាជានិយេ តយោ ច ភទ្រេ បុរិសាជា-និយេ តំ សុណាថ ។ កតមេ ច ភិក្ខវេ តយោ អស្សខឡុង្គា ។ ឥធ ភិក្ខវេ ឯកច្ចោ អស្សខឡុង្គោ ជវសម្បន្នោ ហោតិ ន វណ្ណសម្បន្នោ ន អារោ-ហបរិណាហសម្បន្នោ ។ ឥធ បន ភិក្ខវេ ឯកច្ចោ អស្សខឡុង្គោ ជវសម្បន្នោ ហោតិ វណ្ណសម្បន្នោ ន អារោហបរិណាហសម្បន្នោ ។ ឥធ បន ភិក្ខវេ ឯកច្ចោ អស្សខឡុង្គោ ជវសម្បន្នោ ច ហោតិ

១ ឱ. ម. ឥធព្រហ្មចរិយវាសោ ។ ២ ឱ. ម. អស្សខឡុង្គេ ៗ អដ្ឋកថាយម្បិ ឦទិសោ ហោតិ ។

គឺមានសេចក្តីក្លៀវក្លា ១ មានស្មារតី (ខ្ជាប់ខ្ជួន) ១ មានការបំពេញព្រហ្មចរិយធម៌ដ៏វិសេស ១ ។ ម្នាលភិក្ខុទាំងឡាយ ពួកមនុស្សនៅក្នុងជម្ពូទ្វីប តែងខ្ពង់ខ្ពស់ ហួសពួកមនុស្សអ្នកនៅក្នុងឧត្តរកុរុទ្វីបផង និងពួកទេវតាជាន់តាវត្តិង្សផង ដោយស្ថាន ៣ យ៉ាងនេះឯង ។

[៤២] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងនូវសេះខឡុង្គៈ[១] ៣ ពួកផង នូវបុរសខឡុង្គៈ ៣ ពួកផង នូវសេះ[២]សទស្សៈ ៣ ពួកផង នូវបុរសសទស្សៈ ៣ ពួកផង នូវសេះអាជានេយ្យ[៣] ដ៏ប្រសើរ ៣ ពួកផង នូវបុរសអាជានេយ្យដ៏ប្រសើរ ៣ ពួកផង ចូរអ្នកទាំងឡាយ ស្តាប់នូវធម៌នោះ ។ ម្នាលភិក្ខុទាំងឡាយ ចុះសេះខឡុង្គៈ ៣ ពួក តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ សេះខឡុង្គៈខ្លះ ក្នុងលោកនេះ ជាសត្វបរិបូណ៌ដោយសន្ទុះ តែមិនបរិបូណ៌ដោយសម្បុរ មិនបរិបូណ៌ដោយកម្ពស់និងទំហំ ១ ។ ម្នាលភិក្ខុទាំងឡាយ សេះខឡុង្គៈខ្លះ ក្នុងលោកនេះ ជាសត្វបរិបូណ៌ដោយសន្ទុះ បរិបូណ៌ដោយពណ៌សម្បុរ តែមិនបរិបូណ៌ដោយកម្ពស់និងទំហំ ១ ។ ម្នាលភិក្ខុទាំងឡាយ សេះខឡុង្គៈខ្លះ ក្នុងលោកនេះ បរិបូណ៌ដោយសន្ទុះផង

១ ពាក្យថាខឡុង្គៈនេះគឺ ជាគោត្ររបស់សេះមួយពួក ។ សំដៅយកពួកសេះធុនអន់ជាងគេបំផុត ។ ២ សំដៅយកសេះធុនកណ្តាល (ល្អជាងពួកសេះខឡុង្គៈ) ។ ៣ ពួកសេះដែលស្គាល់ហេតុខុស-ត្រូវ (សេះធុនល្អបំផុត) ។

វណ្ណសម្បន្នោ ច អារោហបរិណាហសម្បន្នោ ច ។ ឥមេ ខោ ភិក្ខវេ តយោ អស្សខលុង្កា ។ កតមេ ច ភិក្ខវេ តយោ បុរិសខលុង្កា ។ ឥធ ភិក្ខវេ ឯកច្ចោ បុរិសខលុង្កោ ជវសម្បន្នោ ហោតិ ន វណ្ណសម្បន្នោ ន អារោហបរិណាហសម្បន្នោ ។ ឥធ បន ភិក្ខវេ ឯកច្ចោ បុរិសខលុង្កោ ជវសម្បន្នោ ហោតិ វណ្ណសម្បន្នោ ន អារោហបរិណាហសម្បន្នោ ។ ឥធ បន ភិក្ខវេ ឯកច្ចោ បុរិសខលុង្កោ ជវសម្បន្នោ ច ហោតិ វណ្ណសម្បន្នោ ច អារោហបរិណាហសម្បន្នោ ច ។ ឥមេ ខោ ភិក្ខវេ តយោ បុរិសខលុង្កា ។ កថញ្ច ភិក្ខវេ បុរិសខលុង្កោ ជវសម្បន្នោ ហោតិ ន វណ្ណសម្បន្នោ ន អារោហបរិណាហសម្បន្នោ ។ ឥធ បន ភិក្ខវេ ភិក្ខុ ឥទំ ទុក្ខន្តិ យថាភូតំ បជានាតិ អយំ ទុក្ខសមុទយោតិ យថាភូតំ បជានាតិ អយំ ទុក្ខនិរោធោតិ យថាភូតំ បជានាតិ អយំ ទុក្ខនិរោធគាមិនី បដិបទាតិ យថាភូតំ បជានាតិ ឥទមស្ស ជវស្មឹ វទាមិ

បរិបូណ៌ដោយពណ៌សម្បុរផង បរិបូណ៌ដោយកម្ពស់និងទំហំផង ១ ។ ម្នាលភិក្ខុទាំងឡាយ សេះខឡុង្គៈមាន ៣ ពួកនេះឯង ។ ម្នាលភិក្ខុទាំង-ឡាយ ចុះបុរសខឡុង្គៈ ៣ ពួក តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បុរសខឡុង្គៈខ្លះក្នុងលោកនេះ ជាអ្នកបរិបូណ៌ដោយសន្ទុះ តែមិនបរិបូណ៌ ដោយគុណ មិនបរិបូណ៌ដោយកម្ពស់និងទំហំ ១ ។ ម្នាលភិក្ខុទាំង-ឡាយ បុរសខឡុង្គៈខ្លះក្នុងលោកនេះ ជាអ្នកបរិបូណ៌ដោយសន្ទុះ បរិបូណ៌ ដោយគុណ តែមិនបរិបូណ៌ដោយកម្ពស់និងទំហំ ១ ។ ម្នាលភិក្ខុទាំង-ឡាយ បុរសខឡុង្គៈខ្លះ ក្នុងលោកនេះ ជាអ្នកបរិបូណ៌ដោយសន្ទុះផង បរិបូណ៌ដោយគុណផង បរិបូណ៌ដោយកម្ពស់និងទំហំផង ១ ។ ម្នាល ភិក្ខុទាំងឡាយ បុរសខឡុង្គៈមាន ៣ ពួកនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះបុរសខឡុង្គៈ ជាអ្នកបរិបូណ៌ដោយសន្ទុះ តែមិនបរិបូណ៌ដោយគុណ មិនបរិបូណ៌ដោយកម្ពស់និងទំហំ តើដោយប្រការដូចម្តេច ។ ម្នាល ភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ដឹងច្បាស់តាមពិតថា នេះជាទុក្ខ ដឹងច្បាស់តាមពិតថា នេះជាហេតុនាំឲ្យកើតទុក្ខ ដឹងច្បាស់តាមពិត ថា នេះជាធម៌រំលត់ទុក្ខ ដឹងច្បាស់តាមពិតថា នេះជាបដិបទាជា ដំណើរទៅកាន់ធម៌រំលត់ទុក្ខ តថាគតពោលថា នេះជាសន្ទុះរបស់ភិក្ខុនោះ

៨៧

បណ្ណាសកេ សត្តាវាសវគ្គោ

អភិធម្មេ ខោ បន អភិវិនយេ បញ្ហំ បុដ្ឋោ វិស្សជ្ជេតិ នោ សម្បាទេតិ[១] ឥទមស្ស ន វណ្ណស្មឹ វទាមិ ន ខោ បន លាភី ហោតិ ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារានំ ឥទមស្ស ន អារោហបរិណាហស្មឹ វទាមិ ។ ឯវំ ខោ ភិក្ខវេ បុរិសខឡុង្គោ ជវសម្បន្នោ ហោតិ ន វណ្ណសម្បន្នោ ន អារោហបរិណាហសម្បន្នោ ។ កថញ្ច ភិក្ខវេ បុរិសខឡុង្គោ ជវសម្បន្នោ ហោតិ វណ្ណសម្បន្នោ ច ន អារោហបរិណាហសម្បន្នោ ។ ឥធ ភិក្ខវេ ភិក្ខុ ឥទំ ទុក្ខន្តិ យថាភូតំ បជានាតិ ។ បេ ។ អយំ ទុក្ខនិរោធគាមិនី បដិបទាតិ យថាភូតំ បជានាតិ ឥទមស្ស ជវស្មឹ វទាមិ អភិធម្មេ ខោ បន អភិវិនយេ បញ្ហំ បុដ្ឋោ វិស្សជ្ជេតិ នោ សម្បាទេតិ ឥទមស្ស វណ្ណស្មឹ វទាមិ ន ខោ បន លាភី ហោតិ ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារានំ ឥទមស្ស ន អារោហបរិណាហស្មឹ វទាមិ ។

១ ឱ. សំសាទេតិ នោ វិសជ្ជេតិ ។

បណ្ណាសក សត្ថាវាសវគ្គ

កាលបើគេសួរប្រស្នា ក្នុងអភិធម្ម ឬក្នុងអភិវិន័យ ដោះស្រាយមិនបរិបូណ៌ តថាគតពោលថា នេះមិនមែនជាគុណរបស់ភិក្ខុនោះទេ ទាំងជាអ្នកឆ្អែងលាភចំពោះ ចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារ តថាគតពោលថា នេះមិនមែនជាកម្ពស់និងទំហំរបស់ភិក្ខុនោះទេ ។ ម្នាលភិក្ខុទាំងឡាយ បុរសខឡុង្គៈ អ្នកបរិបូណ៌ដោយសន្ទុះ តែមិនបរិបូណ៌ដោយគុណ មិនបរិបូណ៌ដោយកម្ពស់និងទំហំយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះបុរស អ្នកបរិបូណ៌ដោយសន្ទុះផង បរិបូណ៌ដោយគុណផង តែមិនបរិបូណ៌ដោយកម្ពស់និងទំហំ តើដោយប្រការដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ដឹងច្បាស់តាមពិតថា នេះជាទុក្ខ ។ បេ ។ ដឹងច្បាស់តាមពិតថា នេះជាបដិបទា ជាដំណើរទៅកាន់ធម៌រំលត់ទុក្ខ តថាគតពោលថា នេះជាសន្ទុះរបស់ភិក្ខុនោះ កាលបើគេសួរប្រស្នាក្នុងអភិធម្ម ឬក្នុងអភិវិន័យ ដោះស្រាយរួច មិនទើសទាល់ឡើយ តថាគតពោលថា នេះជាគុណរបស់ភិក្ខុនោះ ប៉ុន្តែជាអ្នកឆ្អែងលាភចំពោះ ចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារ តថាគតពោលថា នេះមិនមែនជាកម្ពស់និងទំហំរបស់ភិក្ខុនោះទេ ។

ឯវំ ខោ ភិក្ខវេ បុរិសខឡុង្កោ ជវសម្បន្នោ ហោតិ វណ្ណសម្បន្នោ ច ន អារោហបរិណាហសម្បន្នោ ។ កថញ្ច ភិក្ខវេ បុរិសខឡុង្កោ ជវសម្បន្នោ ច ហោតិ វណ្ណសម្បន្នោ ច អារោហបរិណាហសម្បន្នោ ច ។ ឥធ ភិក្ខវេ ភិក្ខុ ឥទំ ទុក្ខន្តិ យថាភូតំ បជានាតិ ។ បេ ។ អយំ ទុក្ខនិរោធគាមិនី បដិបទាតិ យថាភូតំ បជានាតិ ឥទមស្ស ជវស្មឹ វទាមិ អភិធម្មេ ខោ បន អភិវិនយេ បញ្ហំ បុដ្ឋោ វិស្សជ្ជេតិ នោ សម្បាទេតិ ឥទមស្ស វណ្ណស្មឹ វទាមិ លាភី ខោ បន ហោតិ ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារានំ ឥទមស្ស អារោហបរិណាហស្មឹ វទាមិ ។ ឯវំ ខោ ភិក្ខវេ បុរិសខឡុង្កោ ជវសម្បន្នោ ច ហោតិ វណ្ណសម្បន្នោ ច អារោហបរិណាហសម្បន្នោ ច ។ ឥមេ ខោ ភិក្ខវេ តយោ បុរិសខឡុង្កា ។ កតមេ ច ភិក្ខវេ តយោ អស្សសទស្សា[១] ។ ឥធ ភិក្ខវេ ឯកច្ចោ អស្សសទស្សោ ។ បេ ។ ជវសម្បន្នោ ច ហោតិ

១ ម. អស្សបរស្សា ។

ម្នាលភិក្ខុទាំងឡាយ បុរសខឡុង្គៈ អ្នកបរិបូណ៌ដោយសន្ទុះផង បរិបូណ៌ដោយគុណផង តែមិនបរិបូណ៌ដោយកម្ពស់និងទំហំយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះបុរសខឡុង្គៈ អ្នកបរិបូណ៌ដោយសន្ទុះផង បរិបូណ៌ដោយគុណផង បរិបូណ៌ដោយកម្ពស់និងទំហំផង តើដោយប្រការដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ដឹងច្បាស់តាមពិតថា នេះជាទុក្ខ ។ បេ ។ ដឹងច្បាស់តាមពិតថា នេះជាបដិបទាជាដំណើរទៅកាន់ធម៌រំលត់ទុក្ខ តថាគតពោលថា នេះជាសន្ទុះរបស់ភិក្ខុនោះ កាលបើគេសួរប្រស្នាក្នុងអភិធម្ម ឬក្នុងអភិវិន័យ ដោះស្រាយរួចមិនទើសទាល់ឡើយ តថាគតពោលថា នេះជាគុណរបស់ភិក្ខុនោះ ទាំងជាអ្នកស្វាក់លាភចំពោះ ចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារ តថាគតពោលថា នេះជាកម្ពស់និងទំហំរបស់ភិក្ខុនោះ ។ ម្នាលភិក្ខុទាំងឡាយ បុរសខឡុង្គៈ អ្នកបរិបូណ៌ដោយសន្ទុះផង បរិបូណ៌ដោយគុណផង បរិបូណ៌ដោយកម្ពស់និងទំហំផង យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បុរសខឡុង្គៈមាន ៣ ពួកនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះសេះសទស្សៈ ៣ ពួក តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ សេះសទស្សៈខ្លះក្នុងលោកនេះ ។ បេ ។ ជាសត្វបរិបូណ៌ដោយសន្ទុះផង

វណ្ណសម្បន្នោ ច អារោហបរិណាហសម្បន្នោ ច ។ ឥមេ ខោ ភិក្ខវេ តយោ អស្សសទស្សា ។ កតមេ ច ភិក្ខវេ តយោ បុរិសសទស្សា ។ ឥធ ភិក្ខវេ ឯកច្ចោ បុរិសសទស្សោ ។ បេ ។ ជវសម្បន្នោ ច ហោតិ វណ្ណសម្បន្នោ ច អារោហបរិណាហសម្បន្នោ ច ។ កថញ្ច ភិក្ខវេ បុរិសសទស្សោ ជវសម្បន្នោ ច ហោតិ វណ្ណសម្បន្នោ ច អារោហបរិណាហសម្បន្នោ ច ។ ឥធ ភិក្ខវេ ភិក្ខុ បញ្ចន្នំ ឱរម្ភាគិយានំ សំយោជនានំ បរិក្ខយា ឱបបាតិកោ ហោតិ តត្ថ បរិនិព្វាយី អនាវត្តិធម្មោ តស្មា លោកា ឥទមស្ស ជវស្មឹ វទាមិ អភិធម្មេ ខោ បន អភិវិនយេ បញ្ហំ បុដ្ឋោ វិស្សជ្ជេតិ នោ សម្បាទេតិ ឥទមស្ស វណ្ណស្មឹ វទាមិ លាភី ខោ បន ហោតិ ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារានំ ឥទមស្ស អារោហបរិណាហស្មឹ វទាមិ ។ ឯវំ ខោ ភិក្ខវេ បុរិសសទស្សោ ជវសម្បន្នោ ច ហោតិ វណ្ណសម្បន្នោ ច អារោហបរិណាហសម្បន្នោ ច ។

បរិបូណ៌ដោយពណ៌សម្បុរផង បរិបូណ៌ដោយកម្ពស់និងទំហំផង ។ ម្នាលភិក្ខុទាំងឡាយ សេះសទស្សៈមាន ៣ ពួកនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះបុរសសទស្សៈ ៣ ពួក តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បុរសសទស្សៈខ្លះ ក្នុងលោកនេះ ។ បេ ។ អ្នកបរិបូណ៌ដោយសន្ទុះផង បរិបូណ៌ដោយគុណផង បរិបូណ៌ដោយកម្ពស់និងទំហំផង ។ ម្នាលភិក្ខុទាំងឡាយ ចុះបុរសសទស្សៈ អ្នកបរិបូណ៌ដោយសន្ទុះផង បរិបូណ៌ដោយគុណផង បរិបូណ៌ដោយកម្ពស់និងទំហំផង តើដោយប្រការដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ព្រោះអស់ទៅនៃសំយោជនៈ ជាចំណែកខាងក្រោម ៥ ជាឱបបាតិកសត្វ បរិនិព្វានក្នុងទីនោះ មានសភាពមិនបានត្រឡប់ចាកលោកនោះ តថាគតពោលថា នេះជាសន្ទុះរបស់ភិក្ខុនោះ កាលបើគេសួរប្រស្នាក្នុងអភិធម្ម ឬក្នុងអភិវិន័យ ដោះស្រាយរួច មិនទើសទាល់ តថាគតពោលថា នេះជាគុណរបស់ភិក្ខុនោះ ទាំងជាអ្នកស្វាក់លាភចំពោះ ចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារ តថាគតពោលថា នេះជាកម្ពស់និងទំហំរបស់ភិក្ខុនោះ ។ ម្នាលភិក្ខុទាំងឡាយ បុរសសទស្សៈ អ្នកបរិបូណ៌ដោយសន្ទុះផង បរិបូណ៌ដោយគុណផង បរិបូណ៌ដោយកម្ពស់និងទំហំផង យ៉ាងនេះឯង ។

ឥមេ ខោ ភិក្ខវេ តយោ បុរិសសទស្សា ។ កតមេ ច ភិក្ខវេ តយោ ភទ្ទា អស្សាជានិយា ។ ឥធ ភិក្ខវេ ឯកច្ចោ ភទ្ទោ អស្សាជានិយោ ។ បេ ។ ជវសម្បន្នោ ច ហោតិ វណ្ណសម្បន្នោ ច អារោហ-បរិណាហសម្បន្នោ ច ។ ឥមេ ខោ ភិក្ខវេ តយោ ភទ្ទា អស្សាជានិយា ។ កតមេ ច ភិក្ខវេ តយោ ភទ្ទា បុរិសាជានិយា ។ ឥធ ភិក្ខវេ ឯកច្ចោ ភទ្ទោ បុរិសាជានិយោ ។ បេ ។ ជវសម្បន្នោ ច ហោតិ វណ្ណសម្បន្នោ ច អារោហបរិណាហសម្បន្នោ ច ។ កថញ្ច ភិក្ខវេ ភទ្ទោ បុរិសាជានិយោ ។ បេ ។ ជវសម្បន្នោ ច ហោតិ វណ្ណសម្បន្នោ ច អារោហ-បរិណាហសម្បន្នោ ច ។ ឥធ ភិក្ខវេ ភទ្ទោ បុរិសាជានិយោ អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ ឥទមស្ស ជវស្មឹ វទាមិ

ម្នាលភិក្ខុទាំងឡាយ បុរសសទស្សៈមាន ៣ ពួកនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះសេះអាជានេយ្យដ៏ប្រសើរ ៣ ពួក តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ សេះអាជានេយ្យដ៏ប្រសើរខ្លះ ក្នុងលោកនេះ ។ បេ ។ ជាសត្វបរិបូណ៌ដោយសន្ទុះផង បរិបូណ៌ដោយពណ៌សម្បុរផង បរិបូណ៌ដោយកម្ពស់និងទំហំផង ។ ម្នាលភិក្ខុទាំងឡាយ សេះអាជានេយ្យដ៏ប្រសើរមាន ៣ ពួកនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះបុរសអាជានេយ្យដ៏ប្រសើរ ៣ ពួក តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បុរសអាជានេយ្យដ៏ប្រសើរខ្លះ ក្នុងលោកនេះ ។ បេ ។ ជាអ្នកបរិបូណ៌ដោយសន្ទុះផង បរិបូណ៌ដោយគុណផង បរិបូណ៌ដោយកម្ពស់និងទំហំផង ។ ម្នាលភិក្ខុទាំងឡាយ ចុះបុរសអាជានេយ្យដ៏ប្រសើរ តើដោយប្រការដូចម្តេច ។ បេ ។ ជាអ្នកបរិបូណ៌ដោយសន្ទុះផង បរិបូណ៌ដោយគុណផង បរិបូណ៌ដោយកម្ពស់និងទំហំផង ។ ម្នាលភិក្ខុទាំងឡាយ បុរសអាជានេយ្យដ៏ប្រសើរ ក្នុងលោកនេះ ធ្វើឲ្យជាក់ច្បាស់សម្រេចនូវចេតោវិមុត្តិ បញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯងក្នុងបច្ចុប្បន្ន តថាគតពោលថា នេះជាសន្ទុះរបស់ភិក្ខុនោះ

អភិធម្មេ ខោ បន អភិវិនយេ បញ្ហំ បុដ្ឋោ វិស្សជ្ជេតិ នោ សម្បាទេតិ អយមស្ស វណ្ណស្មឹ វទាមិ លាភី ខោ បន ហោតិ ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារានំ អយមស្ស អារោហបរិណាហស្មឹ វទាមិ ។ ឯវំ ខោ ភិក្ខវេ ភទ្ទោ បុរិសាជានិយោ ជវសម្បន្នោ ច ហោតិ វណ្ណសម្បន្នោ ច អារោហបរិណាហសម្បន្នោ ច ។ ឥមេ ខោ ភិក្ខវេ តយោ ភទ្ទា បុរិសាជានិយាតិ ។

[២៣] នវ ភិក្ខវេ តណ្ហាមូលកេ ធម្មេ ទេសេស្សាមិ តំ សុណាថ ។ បេ ។ កតមេ ច ភិក្ខវេ នវ តណ្ហាមូលកា ធម្មា ។ តណ្ហំ បដិច្ច បរិយេសនា បរិយេសនំ បដិច្ច លាភោ លាភំ បដិច្ច វិនិច្ឆយោ វិនិច្ឆយំ បដិច្ច ឆន្ទរាគោ ឆន្ទរាគំ បដិច្ច អជ្ឈោសានំ អជ្ឈោសានំ បដិច្ច បរិគ្គហោ បរិគ្គហំ បដិច្ច មច្ឆរិយំ

កាលបើគេសួរប្រស្នាក្នុងអភិធម្ម ឬក្នុងអភិវិន័យ អាចដោះស្រាយរួច មិនទើសទាល់ឡើយ តថាគតពោលថា នេះជាគុណរបស់ភិក្ខុនោះ ទាំងជាអ្នកស្ទាក់លាភចំពោះ ចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយ-ភេសជ្ជបរិក្ខារ តថាគតពោលថា នេះជាកម្ពស់និងទំហំរបស់ភិក្ខុនោះ ។ ម្នាលភិក្ខុទាំងឡាយ បុរសអាជានេយ្យដ៏ប្រសើរ ជាអ្នកបរិបូណ៌ដោយសន្ទុះផង បរិបូណ៌ដោយគុណផង បរិបូណ៌ដោយកម្ពស់និងទំហំផង យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បុរសអាជានេយ្យដ៏ប្រសើរ មាន ៣ ពួកនេះឯង ។

[២៣] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងនូវពួកធម៌ដែលមានតណ្ហាជាឫសគល់ ៩ យ៉ាង អ្នកទាំងឡាយ ចូរស្តាប់នូវធម៌នោះចុះ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ចុះពួកធម៌ដែលមានតណ្ហាជាឫសគល់ ៩ យ៉ាង តើដូចម្តេចខ្លះ ។ គឺការអាស្រ័យតណ្ហា ទើបមានការស្វែងរក ១ អាស្រ័យការស្វែងរក ទើបកើតលាភ ១ អាស្រ័យលាភទើបកើតសេចក្តីត្រិះរិះ ១ អាស្រ័យសេចក្តីត្រិះរិះ ទើបកើតសេចក្តីប្រាថ្នា សេចក្តីត្រេកអរ ១ អាស្រ័យសេចក្តីប្រាថ្នា សេចក្តីត្រេកអរ ទើបកើតសេចក្តីជឿស៊ប់ ១ អាស្រ័យសេចក្តីជឿស៊ប់ ទើបកើតការហួងហែងទុក ១ អាស្រ័យការហួងហែងទុក ទើបកើតសេចក្តីកំណាញ់ ១

មច្ឆរិយំ បដិច្ច អារក្ខោ អារក្ខាធិករណំ ទណ្ឌាទា-
នសត្ថាទានកលហវិគ្គហវិវាទា តុវំតុវំ បេសុញ្ញមុសា-
វាទា អនេកេ បាបកា អកុសលា ធម្មា សម្ភវន្តិ ។
ឥមេ ខោ ភិក្ខវេ នវ តណ្ហាមូលកា ធម្មាតិ ។

[២៤] នវយិមេ ភិក្ខវេ សត្តាវាសា ។ កតមេ
នវ ។ សន្តិ ភិក្ខវេ សត្តា នានត្តកាយា នានត្តសញ្ញិនោ
សេយ្យថាបិ មនុស្សា ឯកច្ចេ ទេវា ឯកច្ចេ ច
វិនិបាតិកា អយំ បឋមោ សត្តាវាសោ ។ សន្តិ ភិក្ខវេ
សត្តា នានត្តកាយា ឯកត្តសញ្ញិនោ សេយ្យថាបិ
ទេវា ព្រហ្មកាយិកា បឋមាភិនិព្វត្តា អយំ ទុតិយោ
សត្តាវាសោ ។ សន្តិ ភិក្ខវេ សត្តា ឯកត្តកាយា
នានត្តសញ្ញិនោ សេយ្យថាបិ ទេវា អាភស្សរា
អយំ តតិយោ សត្តាវាសោ ។ សន្តិ ភិក្ខវេ
សត្តា ឯកត្តកាយា ឯកត្តសញ្ញិនោ សេយ្យថាបិ
ទេវា សុភកិណ្ហា អយំ ចតុត្ថោ សត្តាវាសោ ។

អាស្រ័យសេចក្តីកំណាញ់ ទើបកើតការរក្សាទុក ១ អាស្រ័យការរក្សាជាហេតុហើយ ទើបអកុសលធម៌ទាំងឡាយ ដ៏លាមកជាច្រើន គឺការកាន់ដំបង កាន់គ្រឿងសស្ត្រាវុធ ឈ្លោះទាស់ទែង ជជែកគ្នាថាឯងៗ ទាំងនិយាយញុះញង់ និយាយកុហកក៏កើតឡើង ១ ។ ម្នាលភិក្ខុទាំង-ឡាយ ពួកធម៌មានតណ្ហាជាឫសគល់ មាន ៩ យ៉ាងនេះឯង ។

[២៤] ម្នាលភិក្ខុទាំងឡាយ សត្តាវាស (ប្រទេសជាទីនៅរបស់សត្វ) នេះមាន ៩ យ៉ាង ។ សត្តាវាស ៩ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វមានកាយផ្សេងគ្នា មានសញ្ញាផ្សេងគ្នា ក៏មាន ដូចពួកមនុស្សនិងទេវតាពួកខ្លះ និងអសុរកាយពួកខ្លះ នេះជាសត្តាវាសទី ១ ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វមានកាយផ្សេងគ្នា មានសញ្ញាដូចគ្នា ក៏មាន ដូចពួកព្រហ្មកា-យិកទេវតា ដែលកើតក្នុងជាន់បឋមជ្ឈានភូមិ នេះជាសត្តាវាសទី ២ ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វមានកាយដូចគ្នា មានសញ្ញាផ្សេងគ្នា ក៏មាន ដូចពួកទេវតា ជាន់អាភស្សរៈ នេះជាសត្តាវាសទី ៣ ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វមានកាយដូចគ្នា មានសញ្ញាដូចគ្នា ក៏មាន ដូចពួកទេវតាជាន់សុភកិណ្ហៈ នេះជាសត្តាវាសទី ៤ ។

៩៣

### បណ្ណាសកេ សត្តាវាសវគ្គោ

សន្តិ ភិក្ខវេ សត្តា អសញ្ញិនោ អប្បដិសំវេទិនោ សេយ្យថាបិ ទេវា អសញ្ញិសត្តា អយំ បញ្ចមោ សត្តាវាសោ ។ សន្តិ ភិក្ខវេ សត្តា សព្វសោ រូបសញ្ញានំ សមតិក្កមា បដិឃសញ្ញានំ អត្ថង្គមា នានត្តសញ្ញានំ អមនសិការា អនន្តោ អាកាសោតិ អាកាសានញ្ចាយតនូបគា អយំ ឆដ្ឋោ សត្តាវាសោ ។ សន្តិ ភិក្ខវេ សត្តា សព្វសោ អាកាសានញ្ចាយតនំ សមតិក្កម្ម អនន្តំ វិញ្ញាណន្តិ វិញ្ញាណញ្ចាយតនូបគា អយំ សត្តមោ សត្តាវាសោ ។ សន្តិ ភិក្ខវេ សត្តា សព្វសោ វិញ្ញាណញ្ចាយតនំ សមតិក្កម្ម នត្ថិ កិញ្ចីតិ អាកិញ្ចញ្ញាយតនូបគា អយំ អដ្ឋមោ សត្តាវាសោ ។ សន្តិ ភិក្ខវេ សត្តា សព្វសោ អាកិញ្ចញ្ញាយតនំ សមតិក្កម្ម នេវសញ្ញានាសញ្ញាយតនូបគា អយំ នវមោ សត្តាវាសោ ។ ឥមេ ខោ ភិក្ខវេ នវ សត្តាវាសាតិ ។

ម្នាលភិក្ខុទាំងឡាយ ពួកសត្វឥតសញ្ញា ឥតមានទទួលការដឹង ក៏មាន ដូចពួកទេវតាជាន់អសញ្ញីសត្វ នេះជាសត្តាវាសទី ៥ ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វលុះបានកន្លងរូបសញ្ញា បានរម្ងាប់បដិឃសញ្ញា មិនបានធ្វើទុកក្នុងចិត្ត ចំពោះនានត្តសញ្ញា ដោយប្រការទាំងពួង ហើយបានដល់អាកាសានញ្ចាយតនជ្ឈាន ដោយបរិកម្មថា អាកាស មិនមានទីបំផុតដូច្នេះ ក៏មាន នេះជាសត្តាវាសទី ៦ ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វកន្លងអាកាសានញ្ចាយនជ្ឈាន ដោយប្រការទាំងពួង ហើយបានដល់វិញ្ញាណញ្ចាយតនជ្ឈាន ដោយបរិកម្មថា វិញ្ញាណ មិនមានទីបំផុតដូច្នេះ ក៏មាន នេះជាសត្តាវាសទី ៧ ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វកន្លងវិញ្ញាណញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ហើយបានដល់អាកិញ្ចញ្ញាយតនជ្ឈាន ដោយបរិកម្មថា វត្ថុតិចតួចមិនមានដូច្នេះ នេះជាសត្តាវាសទី ៨ ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វកន្លងអាកិញ្ចញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង ហើយបានដល់នេវសញ្ញានាសញ្ញាយតនជ្ឈាន នេះជាសត្តាវាសទី ៩ ។ ម្នាលភិក្ខុទាំងឡាយ សត្តាវាសមាន ៩ យ៉ាងនេះឯង ។

[២៨] យតោ ខោ ភិក្ខវេ ភិក្ខុនោ បញ្ញាយ ចិត្តំ សុបរិចិតំ ហោតិ តស្សេតំ ភិក្ខវេ ភិក្ខុនោ កល្លំ វចនាយ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ ។ កថញ្ច ភិក្ខវេ ភិក្ខុនោ បញ្ញាយ ចិត្តំ សុបរិចិតំ ហោតិ ។ វីតរាគំ មេ ចិត្តន្តិ បញ្ញាយ ចិត្តំ សុបរិចិតំ ហោតិ វីតទោសំ មេ ចិត្តន្តិ បញ្ញាយ ចិត្តំ សុបរិចិតំ ហោតិ វីតមោហំ មេ ចិត្តន្តិ បញ្ញាយ ចិត្តំ សុបរិចិតំ ហោតិ អសរាគធម្មំ មេ ចិត្តន្តិ បញ្ញាយ ចិត្តំ សុបរិចិតំ ហោតិ អសទោសធម្មំ មេ ចិត្តន្តិ បញ្ញាយ ចិត្តំ សុបរិចិតំ ហោតិ អសមោ-ហធម្មំ មេ ចិត្តន្តិ បញ្ញាយ ចិត្តំ សុបរិចិតំ ហោតិ

[២៥] ម្នាលភិក្ខុទាំងឡាយ កាលណាបើចិត្តដែលភិក្ខុបាន សន្សំល្អហើយដោយប្រាជ្ញា ម្នាលភិក្ខុទាំងឡាយ ការសន្សំរបស់ភិក្ខុនោះគួរពោលថា ភិក្ខុនោះ រមែងដឹងច្បាស់ថា ជាតិអស់ហើយ មគ្គ-ព្រហ្មចរិយៈអាត្មាអញបានប្រព្រឹត្តរួចហើយ សោឡសកិច្ចអាត្មាអញបានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅ ដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ ម្នាលភិក្ខុទាំងឡាយ ចិត្តដែលភិក្ខុបានសន្សំល្អហើយ ដោយប្រាជ្ញា តើដោយប្រការដូចម្តេច ។ ចិត្តដែលភិក្ខុបានសន្សំល្អហើយ ដោយប្រាជ្ញាថា ចិត្តរបស់អាត្មាអញ ប្រាសចាករាគៈហើយ ចិត្តដែលភិក្ខុបានសន្សំល្អហើយ ដោយប្រាជ្ញាថា ចិត្តរបស់អាត្មាអញ ប្រាសចាកទោសៈហើយ ចិត្តដែលភិក្ខុបានសន្សំល្អហើយ ដោយប្រាជ្ញាថា ចិត្តរបស់អាត្មាអញ ប្រាសចាកមោហៈហើយ ចិត្តដែលភិក្ខុសន្សំល្អហើយ ដោយប្រាជ្ញាថា ចិត្តរបស់អាត្មាអញ មានសភាពមិនប្រកបដោយរាគៈ ចិត្តដែលភិក្ខុបានសន្សំល្អហើយ ដោយប្រាជ្ញាថា ចិត្តរបស់អាត្មាអញ មានសភាពមិនប្រកបដោយទោសៈ ចិត្តដែលភិក្ខុបានសន្សំល្អហើយ ដោយប្រាជ្ញាថា ចិត្តរបស់អាត្មាអញ មានសភាពមិនមិនប្រកបដោយមោហៈ ចិត្តដែលភិក្ខុបានសន្សំល្អហើយ ដោយប្រាជ្ញាថា

អនាវត្តិធម្មំ មេ ចិត្តំ កាមភវាយាតិ បញ្ញាយ ចិត្តំ សុបរិចិតំ ហោតិ អនាវត្តិធម្មំ មេ ចិត្តំ រូបភវាយាតិ បញ្ញាយ ចិត្តំ សុបរិចិតំ ហោតិ អនាវត្តិធម្មំ មេ ចិត្តំ អរូបភវាយាតិ បញ្ញាយ ចិត្តំ សុបរិចិតំ ហោតិ ។ យតោ ខោ ភិក្ខវេ ភិក្ខុនោ បញ្ញាយ ចិត្តំ សុបរិចិតំ ហោតិ តស្សេតំ ភិក្ខវេ ភិក្ខុនោ កល្លំ វចនាយ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ[១] ។

[២៦] ឯកំ សមយំ អាយស្មា ច សារីបុត្តោ អាយស្មា ច ចន្ទិកាបុត្តោ រាជគហេ វិហរន្តិ វេឡុវនេ កលន្ទកនិវាបេ ។ តត្រ ខោ អាយស្មា ចន្ទិកាបុត្តោ ភិក្ខូ អាមន្តេសិ ទេវទត្តោ អាវុសោ ភិក្ខូនំ ឯវំ ធម្មំ ទេសេតិ

១ ឱ. ម. បជានាមីតិ ។

ចិត្តរបស់អាត្មាអញ មានសភាពមិនត្រឡប់ទៅដើម្បីកាមរាគៈ ចិត្តដែលភិក្ខុបានសន្សំល្អហើយ ដោយប្រាជ្ញាថា ចិត្តរបស់អាត្មាអញ មានសភាពមិនត្រឡប់ទៅដើម្បីរូបរាគៈ ចិត្តដែលភិក្ខុបានសន្សំល្អហើយ ដោយប្រាជ្ញាថា ចិត្តរបស់អាត្មាអញ មានសភាពមិនត្រឡប់ទៅដើម្បីអរូបរាគៈ ។ ម្នាលភិក្ខុទាំងឡាយ កាលណាបើ ចិត្តដែលភិក្ខុបានសន្សំល្អហើយ ដោយប្រាជ្ញា ម្នាលភិក្ខុទាំងឡាយ ការសន្សំរបស់ភិក្ខុនោះ គួរពោលថា ភិក្ខុនោះដឹងច្បាស់ថា ជាតិអស់ហើយ មគ្គព្រហ្មចរិយៈអាត្មាអញបានប្រព្រឹត្តរួចហើយ សោឡសកិច្ចក៏អាត្មាអញបានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅ ដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។

[២៦] សម័យមួយ ព្រះសារីបុត្តដ៏មានអាយុ និងព្រះចន្ទិកាបុត្តដ៏មានអាយុ គង់ក្នុងវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថានជិតក្រុងរាជគ្រឹះ ។ ក្នុងទីនោះឯង ព្រះចន្ទិកាបុត្តដ៏មានអាយុហៅភិក្ខុទាំងឡាយមកថា ម្នាលអាវុសោទាំងឡាយ ទេវទត្តសម្តែងធម៌ដល់ភិក្ខុទាំងឡាយ យ៉ាងនេះថា

យតោ ខោ អាវុសោ ភិក្ខុនោ ចេតសា ចិត្តំ សុបរិចិតំ ហោតិ[១] តស្សេតំ ភិក្ខុនោ កល្លំ វេយ្យាករណាយ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ[២] ។ ឯវំ វុត្តេ អាយស្មា សារីបុត្តោ អាយស្មន្តំ ចន្ទិកាបុត្តំ ឯតទវោច ន ខោ អាវុសោ ចន្ទិកាបុត្ត ទេវទត្តោ ភិក្ខូនំ ឯវំ ធម្មំ ទេសេតិ យតោ ខោ អាវុសោ ភិក្ខុនោ ចេតសា ចិត្តំ សុបរិចិតំ ហោតិ[៣] តស្សេតំ ភិក្ខុនោ កល្លំ វេយ្យាករណាយ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ ។ ឯវញ្ច ខោ អាវុសោ ចន្ទិកាបុត្ត ទេវទត្តោ ភិក្ខូនំ ធម្មំ ទេសេតិ

១ ម. ចេតសា ចិតំ ហោតិ ។ ២ ឱ. ម. បជានាមីតិ ។ ៣ ម. ចេតសា ចិតំ ហោតិ។

ម្នាលអាវុសោទាំងឡាយ វេលាណាចិត្តដែលភិក្ខុចម្រើនល្អហើយ ដោយចិត្ត ចិត្តនុ៎ះ របស់ភិក្ខុនោះគួរដើម្បីព្យាករថា ភិក្ខុនោះរមែងដឹងច្បាស់ថា ជាតិរបស់អាត្មាអញអស់ហើយ មគ្គព្រហ្មចរិយៈ អាត្មាអញបានប្រព្រឹត្តរួចហើយ សោឡសកិច្ច អាត្មាអញបានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅ ដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ កាលបើព្រះចន្ទិកាបុត្តដ៏មានអាយុ ពោលយ៉ាងនេះហើយ ព្រះសារីបុត្តដ៏មានអាយុ ក៏ពោលទៅនឹងព្រះចន្ទិកាបុត្តដ៏មានអាយុ ដូច្នេះថា ម្នាលអាវុសោចន្ទិកាបុត្ត ទេវទត្តមិនសម្តែងធម៌ដល់ភិក្ខុទាំងឡាយ យ៉ាងនេះទេថា ម្នាលអាវុសោទាំងឡាយ វេលាណាចិត្តដែលភិក្ខុចម្រើនហើយដោយចិត្ត ចិត្តនុ៎ះរបស់ភិក្ខុនោះ គួរដើម្បីព្យាករថា ភិក្ខុនោះរមែងដឹងច្បាស់ថា ជាតិរបស់អាត្មាអញ អស់ហើយ មគ្គព្រហ្មចរិយៈ អាត្មាអញបានប្រព្រឹត្តរួចហើយ សោឡសកិច្ច អាត្មាអញ បានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅ ដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ ម្នាលអាវុសោចន្ទិកាបុត្ត ទេវទត្តបានតែសម្តែងធម៌ដល់ភិក្ខុទាំងឡាយ យ៉ាងនេះទេ

យតោ ខោ អាវុសោ ភិក្ខុនោ ចេតសា ចិត្តំ សុបរិចិតំ ហោតិ តស្សេតំ ភិក្ខុនោ កល្លំ វេយ្យាករណាយ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ ។ ទុតិយម្បិ ខោ អាយស្មា ចន្ទិកាបុត្តោ ភិក្ខូ អាមន្តេសិ ទេវទត្តោ អាវុសោ ភិក្ខូនំ ឯវំ ធម្មំ ទេសេតិ យតោ ខោ អាវុសោ ភិក្ខុនោ ចេតសា ចិត្តំ សុបរិចិតំ ហោតិ[១] តស្សេតំ ភិក្ខុនោ កល្លំ វេយ្យាករណាយ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ ។ ទុតិយម្បិ ខោ អាយស្មា សារីបុត្តោ អាយស្មន្តំ ចន្ទិកាបុត្តំ ឯតទវោច ន ខោ អាវុសោ ចន្ទិកាបុត្ត ទេវទត្តោ ភិក្ខូនំ ឯវំ ធម្មំ ទេសេតិ យតោ ខោ អាវុសោ ភិក្ខុនោ ចេតសា ចិត្តំ សុបរិចិតំ ហោតិ[២] តស្សេតំ ភិក្ខុនោ

១-២ ម. ចេតសា ចិតំ ហោតិ ។

ម្នាលអាវុសោទាំងឡាយ វេលាណាចិត្តដែលភិក្ខុចម្រើនល្អហើយ ដោយចិត្ត ចិត្តនុ៎ះរបស់ភិក្ខុនោះ គួរដើម្បីព្យាករថា ភិក្ខុនោះរមែងដឹងច្បាស់ថា ជាតិរបស់អាត្មាអញអស់ហើយ មគ្គព្រហ្មចរិយៈអាត្មាអញបានប្រព្រឹត្តរួចហើយ សោឡសកិច្ច អាត្មាអញបានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅ ដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ ព្រះចន្ទិកាបុត្តដ៏មានអាយុ ហៅភិក្ខុទាំងឡាយមក ជាគម្រប់ពីរដងទៀតថា ម្នាលអាវុសោទាំងឡាយ ទេវទត្តសម្តែងធម៌ ដល់ភិក្ខុទាំងឡាយយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ វេលាណាចិត្តដែលភិក្ខុចម្រើនល្អហើយ ដោយចិត្ត ចិត្តនុ៎ះរបស់ភិក្ខុនោះ គួរដើម្បីព្យាករថា ភិក្ខុនោះរមែងដឹងច្បាស់ថា ជាតិរបស់អាត្មាអញអស់ហើយ មគ្គព្រហ្មចរិយៈអាត្មាអញបានប្រព្រឹត្តរួចហើយ សោឡសកិច្ច អាត្មាអញបានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅ ដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ ព្រះសារីបុត្តដ៏មានអាយុ ពោលទៅនឹងព្រះចន្ទិកាបុត្តដ៏មានអាយុ ជាគម្រប់ពីរដងទៀតដូច្នេះថា ម្នាលអាវុសោចន្ទិកាបុត្ត ទេវទត្តមិនសម្តែងធម៌ ដល់ភិក្ខុទាំងឡាយយ៉ាងនេះទេថា ម្នាលអាវុសោទាំងឡាយ វេលាណាចិត្តដែលភិក្ខុចម្រើនល្អហើយ ដោយចិត្ត ចិត្តនុ៎ះរបស់ភិក្ខុនោះ

កល្លំ វេយ្យាករណាយ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ ។ ឯវញ្ច ខោ អាវុសោ ចន្ទិកាបុត្ត ទេវទត្តោ ភិក្ខូនំ ធម្មំ ទេសេតិ យតោ ខោ អាវុសោ ភិក្ខុនោ ចេតសា ចិត្តំ សុបរិចិតំ ហោតិ តស្សេតំ ភិក្ខុនោ កល្លំ វេយ្យាករណាយ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ ។ តតិយម្បិ ខោ អាយស្មា ចន្ទិកាបុត្តោ ភិក្ខូ អាមន្តេសិ ទេវទត្តោ អាវុសោ ភិក្ខូនំ ឯវំ ធម្មំ ទេសេតិ យតោ ខោ អាវុសោ ភិក្ខុនោ ចេតសា ចិត្តំ សុបរិចិតំ ហោតិ[១] តស្សេតំ ភិក្ខុនោ កល្លំ វេយ្យាករណាយ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ ។

---

១ ម. ចេតសា ចិតំ ហោតិ ។

គួរដើម្បីព្យាករថា ភិក្ខុនោះរមែងដឹងច្បាស់ថា ជាតិរបស់អាត្មាអញអស់ហើយ មគ្គព្រហ្មចរិយៈ អាត្មាអញបានប្រព្រឹត្តរួចហើយ សោឡសកិច្ច អាត្មាអញបានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅ ដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ ម្នាលអាវុសោចន្ទិកាបុត្តទេវទត្តបានតែសម្តែងធម៌ដល់ភិក្ខុទាំងឡាយយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ វេលាណា ចិត្តដែលភិក្ខុចម្រើនល្អហើយ ដោយចិត្ត ចិត្តនុ៎ះរបស់ភិក្ខុនោះ គួរដើម្បីព្យាករថា ភិក្ខុនោះរមែងដឹងច្បាស់ថា ជាតិរបស់អាត្មាអញអស់ហើយ មគ្គព្រហ្មចរិយៈ អាត្មាអញបានប្រព្រឹត្តរួចហើយ សោឡសកិច្ច អាត្មាអញបានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅ ដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ ព្រះចន្ទិកាបុត្តដ៏មានអាយុ ហៅភិក្ខុទាំងឡាយមក ជាគម្រប់បីដងទៀតថា ម្នាលអាវុសោទាំងឡាយ ទេវទត្តសម្តែងធម៌ ដល់ភិក្ខុទាំងឡាយយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ វេលាណាចិត្តដែលភិក្ខុចម្រើនល្អហើយ ដោយចិត្ត ចិត្តនុ៎ះរបស់ភិក្ខុនោះ គួរដើម្បីព្យាករថា ភិក្ខុនោះរមែងដឹងច្បាស់ថា ជាតិរបស់អាត្មាអញអស់ហើយ មគ្គព្រហ្មចរិយៈ អាត្មាអញបានប្រព្រឹត្តរួចហើយ សោឡសកិច្ច អាត្មាអញបានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅ ដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។

តតិយម្បិ ខោ អាយស្មា សារីបុត្តោ អាយស្មន្តំ ចន្ទិកាបុត្តំ ឯតទវោច ន ខោ អាវុសោ ចន្ទិ-កាបុត្ត ទេវទត្តោ ភិក្ខូនំ ឯវំ ធម្មំ ទេសេតិ យតោ ខោ អាវុសោ ភិក្ខុនោ ចេតសា ចិត្តំ សុបរិចិតំ ហោតិ[១] តស្សេតំ ភិក្ខុនោ កល្លំ វេយ្យាករណាយ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ ។ ឯវញ្ច ខោ អាវុសោ ចន្ទិកាបុត្ត ទេវទត្តោ ភិក្ខូនំ ធម្មំ ទេសេតិ យតោ ខោ អាវុសោ ភិក្ខុនោ ចេតសា ចិត្តំ សុបរិចិតំ ហោតិ តស្សេតំ ភិក្ខុនោ កល្លំ វេយ្យាករណាយ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ ។ កថញ្ច អាវុសោ ភិក្ខុនោ ចេតសា ចិត្តំ សុបរិចិតំ ហោតិ ។ វីតរាគំ មេ ចិត្តន្តិ ចេតសា ចិត្តំ សុបរិចិតំ ហោតិ វីតទោសំ មេ ចិត្តន្តិ ចេតសា ចិត្តំ សុបរិចិតំ ហោតិ

១ ម. ចេតសា ចិតំ ហោតិ ។

ព្រះសារីបុត្តដ៏មានអាយុ ពោលទៅនឹងព្រះចន្និកាបុត្តដ៏មានអាយុ ជាគម្រប់ ៣ ដងដូច្នេះថា ម្នាលអាវុសោចន្និកាបុត្ត ទេវទត្តមិនសម្ដែងធម៌ដល់ភិក្ខុទាំងឡាយយ៉ាងនេះទេថា ម្នាលអាវុសោទាំងឡាយ វេលាណាចិត្តដែលភិក្ខុចម្រើនល្អហើយដោយចិត្ត ចិត្តនុ៎ះរបស់ភិក្ខុនោះ គួរដើម្បីព្យាករថា ភិក្ខុនោះរមែងដឹងច្បាស់ថា ជាតិរបស់អាត្មាអញអស់ហើយ មគ្គព្រហ្មចរិយៈ អាត្មាអញបានប្រព្រឹត្តរួចហើយ សោឡសកិច្ច អាត្មាអញបានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅ ដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ ម្នាលអាវុសោចន្និកាបុត្ត ទេវទត្តបានតែសម្ដែងធម៌ ដល់ភិក្ខុទាំងឡាយយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ វេលាណាចិត្តដែលភិក្ខុចម្រើនល្អហើយ ដោយចិត្ត ចិត្តនុ៎ះរបស់ភិក្ខុនោះ គួរដើម្បីព្យាករថា ភិក្ខុនោះរមែងដឹងច្បាស់ថា ជាតិរបស់អាត្មាអញអស់ហើយ មគ្គព្រហ្មចរិយៈ អាត្មាអញបានប្រព្រឹត្តរួចហើយ សោឡសកិច្ច អាត្មាអញបានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅ ដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ ម្នាលអាវុសោ ចិត្តដែលភិក្ខុចម្រើនល្អហើយដោយចិត្ត តើដូចម្ដេច ។ ចិត្តដែលភិក្ខុចម្រើនល្អហើយដោយចិត្តថា ចិត្តរបស់អាត្មាអញប្រាសចាករាគៈហើយ ចិត្តដែលភិក្ខុចម្រើនល្អហើយ ដោយចិត្តថា ចិត្តរបស់អាត្មាអញ ប្រាសចាកទោសៈហើយ

វីតមោហំ មេ ចិត្តន្តិ ចេតសា ចិត្តំ សុបរិចិតំ ហោតិ អសារាគធម្មំ មេ ចិត្តន្តិ ចេតសា ចិត្តំ សុបរិចិតំ ហោតិ អសារោសធម្មំ មេ ចិត្តន្តិ ចេតសា ចិត្តំ សុបរិចិតំ ហោតិ អសមោហធម្មំ មេ ចិត្តន្តិ ចេតសា ចិត្តំ សុបរិចិតំ ហោតិ អនាវត្តិធម្មំ មេ ចិត្តំ កាម-ភវាយាតិ ចេតសា ចិត្តំ សុបរិចិតំ ហោតិ អនាវត្តិ-ធម្មំ មេ ចិត្តំ រូបភវាយាតិ ចេតសា ចិត្តំ សុបរិ-ចិតំ ហោតិ អនាវត្តិធម្មំ មេ ចិត្តំ អរូបភវាយាតិ ចេតសា ចិត្តំ សុបរិចិតំ ហោតិ ។ ឯវំ សម្មាវិមុត្តិ-ចិត្តស្ស[១] ខោ អាវុសោ ភិក្ខុនោ ភុសា ចេបិ ចក្ខុវិញ្ញេយ្យា រូបា ចក្ខុស្ស អាបាថំ អាគច្ឆន្តិ នេវស្ស ចិត្តំ បរិយាទិយន្តិ អមិស្សីកតមេវស្ស ចិត្តំ ហោតិ ឋិតំ អានេញ្ជប្បត្តំ វយញ្ចស្សានុបស្សតិ ភុសា ចេបិ សោតវិញ្ញេយ្យា សទ្ទា ។ បេ ។ ឃានវិញ្ញេយ្យា គន្ធា

១ ឱ. ម. សម្មាវិមុត្តចិត្តស្ស ។

ចិត្តដែលភិក្ខុចម្រើនល្អហើយ ដោយចិត្តថា ចិត្តរបស់អាត្មាអញ ប្រាសចាកមោហៈហើយ ចិត្តដែលភិក្ខុចម្រើនល្អហើយដោយចិត្តថា ចិត្តរបស់អាត្មាអញ មានសភាពមិនប្រកបដោយរាគៈ ចិត្តដែលភិក្ខុចម្រើនល្អហើយដោយចិត្តថា ចិត្តរបស់អាត្មាអញ មានសភាពមិនប្រកបដោយទោសៈ ចិត្តដែលភិក្ខុចម្រើនល្អហើយ ដោយចិត្តថា ចិត្តរបស់អាត្មាអញ មានសភាពមិនប្រកបដោយមោហៈ ចិត្តដែលភិក្ខុចម្រើនល្អហើយដោយចិត្តថា ចិត្តរបស់អាត្មាអញ មានសភាពមិនបានត្រឡប់មក ដើម្បីកាមភព ចិត្តដែលភិក្ខុចម្រើនល្អហើយ ដោយចិត្តថា ចិត្តរបស់អាត្មាអញ មានសភាពមិនបានត្រឡប់មក ដើម្បីរូបភព ចិត្តដែលភិក្ខុចម្រើនល្អហើយ ដោយចិត្តថា ចិត្តរបស់អាត្មាអញ មានសភាពមិនបានត្រឡប់មក ដើម្បីអរូបភព ។ ម្នាលអាវុសោ ភិក្ខុដែលមានចិត្តរួចស្រឡះដោយប្រពៃយ៉ាងនេះហើយ ទោះរូបដ៏ក្រៃលែងដែលគប្បីដឹងដោយចក្ខុ មកកាន់គន្លងនៃចក្ខុ ក៏គ្របសង្កត់ចិត្តរបស់ភិក្ខុនោះមិនបានឡើយ ចិត្តភិក្ខុនោះមិនជាប់ស្អិត ជាចិត្តតាំងនៅ ដល់នូវការមិនញាប់ញ័រ ភិក្ខុនោះរមែងពិចារណា ឃើញច្បាស់នូវសេចក្ដីវិនាសទៅនៃចិត្តនោះ ទោះបីសំឡេងដ៏ក្រៃលែង គប្បីដឹងដោយត្រចៀក ។ បេ ។ ក្លិនគប្បីដឹងដោយច្រមុះ

ជិវ្ហាវិញ្ញេយ្យា រសា កាយវិញ្ញេយ្យា ផោដ្ឋព្វា មនោវិញ្ញេយ្យា ធម្មា មនស្ស អាបាថំ អាគច្ឆន្តិ នេវស្ស ចិត្តំ បរិយាទិយន្តិ អមិស្សីកតមេវស្ស ចិត្តំ ហោតិ ឋិតំ អនេញ្ជប្បត្តំ វយញ្ចស្សានុបស្សតិ សេយ្យថាបិ អាវុសោ សិលាយូបោ សោឡសកុក្កុ[១] តស្ស[២] អដ្ឋ កុក្កូ ហេដ្ឋានេមង្គមា[៣] អដ្ឋ កុក្កូ ឧបរិ នេមស្ស អថ បុរត្ថិមាយ ចេបិ ទិសាយ អាគច្ឆេយ្យ ភុសា វាតវុដ្ឋិ នេវ សំកម្បេយ្យ ន សម្បកម្បេយ្យ ន សម្បវេធេយ្យ អថ បច្ឆិមាយ អថ ឧត្តរាយ អថ ទក្ខិណាយ ចេបិ ទិសាយ អាគច្ឆេយ្យ ភុសា វាតវុដ្ឋិ នេវ សំកម្បេយ្យ ន សម្បកម្បេយ្យ ន សម្បវេធេយ្យ ។ តំ កិស្ស ហេតុ ។ គម្ភីរត្តា អាវុសោ នេមស្ស សុនិខាតត្តា សិលាយូបស្ស ឯវមេវ ខោ អាវុសោ ឯវំ សម្មាវិមុត្តចិត្តស្ស ភិក្ខុនោ ភុសា ចេបិ ចក្ខុវិញ្ញេយ្យា រូបា ចក្ខុស្ស អាបាថំ អាគច្ឆន្តិ នេវស្ស ចិត្តំ បរិយាទិយន្តិ អមិស្សីកតមេវស្ស ចិត្តំ ហោតិ ឋិតំ អានេញ្ជប្បត្តំ

១ ឱ. ម. សោឡសកុក្កុកោ ។ អដ្ឋកថាយំ សោឡសកុក្កុកោតិបិ ទិស្សតិ ។ ២ ឱ. តស្ស អស្ស ។ ម. តស្សស្សុ ។ ៣ ឱ. ហេដ្ឋា នេមស្ស ។

រសគប្បីដឹងដោយអណ្តាត ផោដ្ឋព្វៈគប្បីដឹងដោយកាយ ធម្មារម្មណ៍ គប្បីដឹងដោយចិត្ត មកកាន់គន្លងនៃចិត្ត ក៏គ្របសង្កត់ចិត្តរបស់ភិក្ខុនោះ មិនបានឡើយ ចិត្តភិក្ខុនោះមិនជាប់ស្អិត ជាចិត្តតាំងនៅ ដល់នូវការ មិនញាប់ញ័រ ភិក្ខុនោះ រមែងពិចារណាឃើញច្បាស់នូវសេចក្តីវិនាស ទៅនៃចិត្តនោះ ម្នាលអាវុសោ ដូចសសរថ្ម មានប្រវែង ១៦ ហត្ថ សសរថ្មនោះដាំចុះទៅ ខាងក្រោមរណ្តៅ ៨ ហត្ថ សល់នៅខាងលើ រណ្តៅ ៨ ហត្ថ ខាងក្រោយមក ទោះបីភ្លៀងប្រកបដោយខ្យល់យ៉ាងខ្លាំង មកពីទិសខាងកើត ក៏មិនកម្រើក មិនញាប់ញ័រ មិនរំភើប ទោះបីភ្លៀង ប្រកបដោយខ្យល់យ៉ាងខ្លាំង មកពីទិសខាងលិច មកពីទិសខាងជើង ឬមកពីទិសខាងត្បូង ក៏មិនកម្រើក មិនញាប់ញ័រ មិនរំភើបដែរ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលអាវុសោ ព្រោះថា សសរថ្មដែលគេ ជីកដាំជ្រៅល្អយ៉ាងណាមិញ ម្នាលអាវុសោ ភិក្ខុដែលមានចិត្តរួចស្រឡះ ដោយប្រពៃយ៉ាងនេះហើយ ទោះបីរូបដ៏ក្រៃលែង ដែលគប្បីដឹងដោយ ចក្ខុ មកកាន់គន្លងនៃចក្ខុ ក៏គ្របសង្កត់ចិត្តរបស់ភិក្ខុនោះ មិនបានឡើយ ចិត្តភិក្ខុនោះ មិនជាប់ស្អិត ជាចិត្តតាំងនៅ ដល់នូវការមិនញាប់ញ័រ

វយញ្ចស្សានុបស្សតិ ភុសា ចេបិ សោតវិញ្ញេយ្យា សទ្ទា ។ បេ ។ ឃានវិញ្ញេយ្យា គន្ធា ជិវ្ហាវិញ្ញេយ្យា រសា កាយវិញ្ញេយ្យា ផោដ្ឋព្វា មនោវិញ្ញេយ្យា ធម្មា មនស្ស អាបាថំ អាគច្ឆន្តិ នេវស្ស ចិត្តំ បរិយាទិយន្តិ អមិស្សីកតមេវស្ស ចិត្តំ ហោតិ ឋិតំ អានេញ្ជប្បត្តំ វយញ្ចស្សានុបស្សតីតិ ។

[២៧] អថខោ អនាថបិណ្ឌិកោ គហបតិ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ អនាថបិណ្ឌិកំ គហបតឹ ភគវា ឯតទវោច យតោ ខោ គហបតិ អរិយសាវកស្ស បញ្ច ភយានិ វេរានិ វូបសន្តានិ ហោន្តិ ចតូហិ ច សោតាបត្តិយង្គេហិ សមន្នាគតោ ហោតិ សោ អាកង្ខមានោ អត្តនាវ អត្តានំ ព្យាករេយ្យ ខីណនិរយោម្ហិ ខីណតិរច្ឆានយោនិយោ ខីណបិត្តិវិស-យោ ខីណាបាយទុគ្គតិវិនិបាតោ សោតាបន្នោហមស្មិ

ភិក្ខុនោះ រមែងពិចារណាឃើញច្បាស់ នូវសេចក្តីវិនាសទៅនៃចិត្តនោះ ទោះបីសំឡេងដ៏ក្រៃលែង គប្បីដឹងដោយត្រចៀក ។ បេ ។ ក្លិនគប្បីដឹងដោយច្រមុះ រសគប្បីដឹងដោយអណ្តាត ផោដ្ឋព្វៈគប្បីដឹងដោយកាយ ធម្មារម្មណ៍ គប្បីដឹងដោយចិត្ត មកកាន់គន្លងនៃចិត្ត ក៏គ្របសង្កត់ចិត្តរបស់ភិក្ខុនោះ មិនបានឡើយ ចិត្តរបស់ភិក្ខុនោះ មិនជាប់ស្អិតជាចិត្តតាំងនៅ ដល់នូវការមិនញាប់ញ័រ ភិក្ខុនោះ រមែងពិចារណាឃើញច្បាស់នូវសេចក្តីវិនាសទៅនៃចិត្តនោះ ក៏យ៉ាងនោះដែរ ។

[២៧] គ្រានោះ អនាថបិណ្ឌិកគហបតី ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះអនាថបិណ្ឌិកគហបតី អង្គុយក្នុងទីសមគួរហើយ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលគហបតី វេលាណាអរិយសាវ័ក បានរម្ងាប់នូវភ័យនិងពៀរទាំង ៥ និងប្រកបដោយអង្គនៃសោតាបត្តិ ៤ យ៉ាងហើយ អរិយសាវ័កនោះ កាលប្រាថ្នា គប្បីព្យាករនូវខ្លួនដោយខ្លួនឯងបានថា អាត្មាអញ មាននរកអស់ហើយ មានតិរច្ឆានកំណើតអស់ហើយ មានបិត្តិវិស័យអស់ហើយ មានអបាយទុគ្គតិវិបាតអស់ហើយ អាត្មាអញ ជាអ្នកដល់នូវសោតៈ

អវិនិបាតធម្មោ និយតោ សម្ពោធិបរាយណោ ។ កតមានិ បញ្ច ភយានិ វេរានិ វូបសន្តានិ ហោន្តិ ។ យំ គហបតិ បាណាតិបាតី បាណាតិបាតប្បច្ចយា ទិដ្ឋធម្មិកម្បិ ភយំ វេរំ បសវតិ សម្បរាយិកម្បិ ភយំ វេរំ បសវតិ ចេតសិកម្បិ ទុក្ខំ ទោមនស្សំ បដិសំវេទេតិ បាណាតិបាតា បដិវិរតោ នេវ ទិដ្ឋធម្មិ-កម្បិ ភយំ វេរំ បសវតិ ន សម្បរាយិកម្បិ ភយំ វេរំ បសវតិ ន ចេតសិកម្បិ ទុក្ខំ ទោមនស្សំ បដិសំវេទេតិ បាណាតិបាតា បដិវិរតស្ស ឯវំ តំ ភយំ វេរំ វូបសន្តំ ហោតិ ។ យំ គហបតិ អទិន្នាទាយី ។ បេ ។ កាមេសុ មិច្ឆាចារី មុសាវាទី សុរាមេរយមជ្ជប្បមា-ទដ្ឋាយី សុរាមេរយមជ្ជប្បមាទដ្ឋានប្បច្ចយា ទិដ្ឋធម្មិ-កម្បិ ភយំ វេរំ បសវតិ សម្បរាយិកម្បិ ភយំ វេរំ បសវតិ ចេតសិកម្បិ ទុក្ខំ ទោមនស្សំ បដិសំវេទេតិ

មានសភាពមិនបានធ្លាក់ចុះ ជាបុគ្គលទៀង មានការត្រាស់ដឹងប្រព្រឹត្តទៅខាងមុខ ។ ភ័យនិងពៀរ ៥ ដែលអរិយសាវ័ក បានរម្ងាប់ហើយ តើដូចម្តេច ។ ម្នាលគហបតី បុគ្គលជាអ្នកសម្លាប់សត្វ រមែងបាននូវភ័យនិងពៀរ ដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្នផង បាននូវភ័យនិងពៀរ ដែលប្រព្រឹត្តទៅក្នុងលោកខាងមុខផង ទទួលនូវទុក្ខនិងទោមនស្ស ដែលប្រព្រឹត្តទៅក្នុងចិត្តផង ព្រោះការសម្លាប់សត្វជាបច្ច័យ បុគ្គលជាអ្នកវៀរចាកបាណាតិបាត រមែងមិនបាននូវភ័យនិងពៀរដែលប្រព្រឹត្តទៅ ក្នុងបច្ចុប្បន្នផង មិនបាននូវភ័យនិងពៀរដែលប្រព្រឹត្តទៅ ក្នុងលោកខាងមុខផង មិនបានទទួលនូវទុក្ខនិងទោមនស្សដែលប្រព្រឹត្តទៅក្នុងចិត្តផង កាលបើបុគ្គលវៀរចាកបាណាតិបាតហើយ ទើបភ័យនិងពៀរនោះ ស្ងប់រម្ងាប់ទៅបានយ៉ាងនេះ ។ ម្នាលគហបតី បុគ្គលជាអ្នកកាន់យកនូវរបស់ដែលគេមិនបានឲ្យ ។ បេ ។ ជាអ្នកប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ជាអ្នកពោលពាក្យកុហក ជាអ្នកផឹកនូវទឹកស្រវឹងគឺសុរានិងមេរ័យ ដែលជាទីតាំងនៃសេចក្តីប្រមាទ តែងបាននូវភ័យនិងពៀរដែលប្រព្រឹត្តទៅ ក្នុងបច្ចុប្បន្នផង បាននូវភ័យនិងពៀរដែលប្រព្រឹត្តទៅ ក្នុងលោកខាងមុខផង ទទួលនូវទុក្ខនិងទោមនស្ស ដែលប្រព្រឹត្តទៅក្នុងចិត្តផង ព្រោះការផឹកនូវទឹកស្រវឹងគឺសុរានិងមេរ័យ ដែលជាទីតាំងនៃសេចក្តីប្រមាទជាបច្ច័យ

សុរាមេរយមជ្ជប្បមាទដ្ឋានា បដិវិរតោ នេវ ទិដ្ឋធម្មិ-
កម្បិ ភយំ វេរំ បសវតិ ន សម្បរាយិកម្បិ
ភយំ វេរំ បសវតិ ន ចេតសិកម្បិ ទុក្ខំ
ទោមនស្សំ បដិសំវេទេតិ សុរាមេរយមជ្ជប្បមាទដ្ឋានា
បដិវិរតស្ស ឯវំ តំ ភយំ វេរំ វូបសន្តំ ហោតិ ។
ឥមានិ បញ្ច ភយានិ វេរានិ វូបសន្តានិ ហោន្តិ ។
កតមេហិ ចតូហិ សោតាបត្តិយង្គេហិ សមន្នា-
គតោ ហោតិ ។ ឥធ គហបតិ អរិយសាវកោ
ពុទ្ធេ អវេច្ចប្បសាទេន សមន្នាគតោ ហោតិ ឥតិបិ
សោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណ-
សម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិស-
ទម្មសារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ

បុគ្គលជាអ្នកវៀរចាកការផឹកនូវទឹកស្រវឹង គឺសុរានិងមេរ័យ ដែលជាទីតាំងនៃសេចក្ដីប្រមាទហើយ រមែងមិនបាននូវភ័យនិងពៀរ ដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្នផង មិនបាននូវភ័យនិងពៀរ ដែលប្រព្រឹត្តទៅ ក្នុងលោកខាងមុខផង មិនទទួលនូវទុក្ខនិងទោមនស្ស ដែលប្រព្រឹត្តទៅក្នុងចិត្តផង កាលបើបុគ្គលវៀរចាកការផឹកនូវទឹកស្រវឹង គឺសុរានិងមេរ័យ ដែលជាទីតាំងនៃសេចក្ដីប្រមាទហើយ ទើបភ័យនិងពៀរនោះស្ងប់រម្ងាប់ទៅបានយ៉ាងនេះឯង ។ ភ័យនិងពៀរ ដែលអរិយសាវ័ក បានរម្ងាប់ហើយមាន ៥ យ៉ាងនេះឯង ។ អរិយសាវ័ក ប្រកបដោយអង្គនៃសោតាបត្តិ ៤ យ៉ាង តើដូចម្ដេច ។ ម្នាលគហបតី អរិយសាវ័កក្នុងសាសនានេះ ជាអ្នកប្រកបដោយសេចក្ដីជ្រះថ្លា មិនកម្រើកក្នុងព្រះពុទ្ធថា ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់ឆ្ងាយចាកសេចក្ដីសៅហ្មងគ្រប់យ៉ាង ព្រះអង្គត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ដោយប្រពៃចំពោះព្រះអង្គ ព្រះអង្គបរិបូណ៌ដោយវិជ្ជានិងចរណៈ ព្រះអង្គមានដំណើរទៅកាន់ព្រះនិព្វាន ព្រះអង្គជ្រាបច្បាស់នូវត្រៃលោក ព្រះអង្គប្រសើរដោយសីលាទិគុណរកបុគ្គលណាមួយស្មើគ្មាន ព្រះអង្គជាអ្នកទូន្មាននូវបុរស ដែលគួរទូន្មានបាន ព្រះអង្គជាគ្រូនៃទេវតានិងមនុស្សទាំងឡាយ ព្រះអង្គត្រាស់ដឹងនូវចតុរារិយសច្ច ព្រះអង្គលែងវិលត្រឡប់មកកាន់ភពថ្មីទៀត ។

១០៨

បណ្ណាសកេ សត្តាវាសវគ្គោ

ធម្មេ អវេច្ចប្បសាទេន សមន្នាគតោ ហោតិ ស្វាក្ខា-
តោ ភគវតា ធម្មោ សន្ទិដ្ឋិកោ អកាលិកោ
ឯហិបស្សិកោ ឱបនយិកោ បច្ចត្តំ វេទិតព្វោ
វិញ្ញូហីតិ ។ សង្ឃេ អវេច្ចប្បសាទេន សមន្នាគតោ
ហោតិ សុប្បដិបន្នោ ភគវតោ សាវកសង្ឃោ ឧជុ-
ប្បដិបន្នោ ភគវតោ សាវកសង្ឃោ ញាយប្បដិបន្នោ
ភគវតោ សាវកសង្ឃោ សាមីចិប្បដិបន្នោ ភគវតោ
សាវកសង្ឃោ យទិទំ ចត្តារិ បុរិសយុគានិ
អដ្ឋ បុរិសបុគ្គលា ឯស ភគវតោ សាវកសង្ឃោ
អាហុនេយ្យោ បាហុនេយ្យោ ទក្ខិណេយ្យោ អញ្ជលិ-
ករណីយោ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ ។
អរិយកន្តេហិ សីលេហិ សមន្នាគតោ ហោតិ
អក្ខណ្ឌេហិ អច្ឆិទ្ទេហិ អសពលេហិ អកម្មាសេហិ

អរិយសាវ័ក ជាអ្នកប្រកបដោយសេចក្តីជ្រះថ្លា មិនកម្រើកក្នុងព្រះធម៌ថា ព្រះបរិយត្តិធម៌ ដែលព្រះដ៏មានព្រះភាគ ទ្រង់សម្តែងហើយដោយល្អ ជាធម៌ដែលបុគ្គល គប្បីឃើញច្បាស់ដោយខ្លួនឯង ជាធម៌ឲ្យនូវផល មិនរង់ចាំកាល ជាធម៌គួរដល់ឯហិបស្សវិធី ជាធម៌ដែលបុគ្គលគប្បី បង្អោនចូលមកទុកក្នុងខ្លួន ជាធម៌ដែលអ្នកប្រាជ្ញទាំងឡាយ គប្បីឃើញ ច្បាស់ក្នុងចិត្តនៃខ្លួន ។ អរិយសាវ័ក ជាអ្នកប្រកបដោយសេចក្តី ជ្រះថ្លាមិនកម្រើកក្នុងព្រះសង្ឃថា ព្រះសង្ឃសាវ័កនៃព្រះដ៏មានព្រះភាគ ប្រតិបត្តិដោយប្រពៃ ព្រះសង្ឃសាវ័កនៃព្រះដ៏មានព្រះភាគ ប្រតិបត្តិ ត្រង់ ព្រះសង្ឃសាវ័កនៃព្រះដ៏មានព្រះភាគ ប្រតិបត្តិដើម្បីត្រាស់ ដឹងនូវព្រះនិព្វាន ព្រះសង្ឃសាវ័កនៃព្រះដ៏មានព្រះភាគ ប្រតិបត្តិ សមគួរ គឺប្រតិបត្តិគួរដល់សីល សមាធិ បញ្ញា បុរសបុគ្គលណា បើរាប់ជាគូបាន ៤ គូ បើរាប់រៀងជាបុរសបុគ្គលមាន ៨ ព្រះសង្ឃសាវ័ក របស់ព្រះដ៏មានព្រះភាគនុ៎ះ លោកគួរទទួលនូវចតុប្បច្ច័យ ដែល បុគ្គលនាំមកបូជា គួរទទួលអាគន្តុកទាន គួរទទួលទក្ខិណាទាន គួរដល់អញ្ជលិកម្ម ជាបុញ្ញក្ខេត្តនៃសត្វលោក រកខេត្តដទៃក្រៃ លែងជាងគ្មាន ។ អរិយសាវ័កនោះ ប្រកបដោយសីល ជាទីត្រេកអរ របស់ព្រះអរិយៈ ជាសីលមិនដាច់ មិនធ្លុះ មិនពព្រុស មិនពពាល

កុជិស្សេហិ វិញ្ញុប្បសត្ថេហិ អបរាមដ្ឋេហិ សមាធិ-សំវត្តនិកេហិ ។ ឥមេហិ ចតូហិ សោតាបត្តិយង្គេហិ សមន្នាគតោ ហោតិ ។ យតោ ខោ គហបតិ អរិយស្សាវកស្ស ឥមានិ បញ្ច ភយានិ វេរានិ វូបសន្តានិ ហោន្តិ ឥមេហិ ច ចតូហិ សោតាបត្តិ-យង្គេហិ សមន្នាគតោ ហោតិ សោ អាកង្ខមានោ អត្តនា វ អត្តានំ ព្យាករេយ្យ ខីណនិរយោម្ហិ ខីណតិរច្ឆានយោនិយោ ខីណបិត្តិវិសយោ ខីណា-បាយទុគ្គតិវិនិបាតោ សោតាបន្នោហមស្មិ អវិនិបាត-ធម្មោ និយតោ សម្ពោធិបរាយនោតិ ។

[២៨] យតោ ខោ ភិក្ខវេ អរិយស្សាវកស្ស បញ្ច ភយានិ វេរានិ វូបសន្តានិ ហោន្តិ ចតូហិ ច សោតាបត្តិយង្គេហិ សមន្នាគតោ ហោតិ សោ អាកង្ខមានោ អត្តនា វ អត្តានំ ព្យាករេយ្យ ខីណនិរយោម្ហិ ខីណតិរច្ឆានយោនិយោ ខីណបិត្តិវិស-យោ ខីណាបាយទុគ្គតិវិនិបាតោ សោតាបន្នោហមស្មិ

ជាសីលជានា ដែលពួកអ្នកប្រាជ្ញសរសើរហើយ ជាសីលមិនបពោស អង្អែលដោយតណ្ហា ជាសីលប្រព្រឹត្តទៅដើម្បីសមាធិ ។ អរិយសាវ័ក ជាអ្នកប្រកបដោយអង្គនៃសោតាបត្តិ ៤ យ៉ាងនេះឯង ។ ម្នាលគហបតី វេលាណា អរិយសាវ័ក បានរម្ងាប់នូវភ័យនិងពៀរទាំង ៥ នេះ ទាំងប្រកបដោយអង្គនៃសោតាបត្តិទាំង ៤ យ៉ាងនេះហើយ អរិយសាវ័កនោះ កាលបើប្រាថ្នា គប្បីព្យាករខ្លួនដោយខ្លួនឯងបានថា អាត្មាអញ មាននរក អស់ហើយ មានតិរច្ឆានកំណើតអស់ហើយ មានបិត្តិវិស័យអស់ហើយ មានអបាយទុគ្គតិនិងវិនិបាតអស់ហើយ អាត្មាអញជាអ្នកដល់នូវសោតៈ ហើយ ជាអ្នកមានសភាព មិនបានធ្លាក់ចុះ ជាអ្នកទៀង មានសេចក្តីត្រាស់ដឹងប្រព្រឹត្តទៅខាងមុខ ។

[២៨] ម្នាលភិក្ខុទាំងឡាយ វេលាណា អរិយសាវ័ក បានរម្ងាប់ នូវភ័យនិងពៀរទាំង ៥ ទាំងប្រកបដោយអង្គនៃសោតាបត្តិទាំង ៤ យ៉ាងហើយ អរិយសាវ័កនោះ កាលបើប្រាថ្នា គប្បីព្យាករនូវខ្លួនដោយខ្លួនឯងបានថា អាត្មាអញ មាននរកអស់ហើយ មានតិរច្ឆានកំណើតអស់ហើយ មានបិត្តិវិស័យអស់ហើយ មានអបាយ ទុគ្គតិនិងវិនិបាតអស់ហើយ អាត្មាអញជាអ្នកដល់នូវសោតៈ

១០៧

បណ្ណាសកេ សត្តាវាសវគ្គោ

អវិនិបាតធម្មោ និយតោ សម្ពោធិបរាយណោ ។ កតមានិ បញ្ច ភយានិ វេរានិ វូបសន្តានិ ហោន្តិ ។ យំ ភិក្ខវេ បាណាតិបាតី បាណាតិបាតប្បច្ចយា ទិដ្ឋធម្មិកម្បិ ភយំ វេរំ បសវតិ សម្បរាយិកម្បិ ភយំ វេរំ បសវតិ ចេតសិកម្បិ ទុក្ខំ ទោមនស្សំ បដិសំវេទេតិ បាណាតិបាតា បដិវិរតោ ។ បេ ។ ឯវំ តំ ភយំ វេរំ វូបសន្តំ ហោតិ ។ យំ ភិក្ខវេ អទិន្នាទាយី ។ បេ ។ កាមេសុ មិច្ឆាចារី មុសាវាទី សុរាមេរយមជ្ជប្បមាទដ្ឋាយី សុរាមេរយមជ្ជប្បមាទដ្ឋានប្បច្ចយា ទិដ្ឋធម្មិកម្បិ ភយំ វេរំ បសវតិ សម្បរាយិកម្បិ ភយំ វេរំ បសវតិ ចេតសិកម្បិ ទុក្ខំ ទោមនស្សំ បដិសំវេទេតិ សុរាមេរយមជ្ជប្បមាទដ្ឋានា បដិវិរតោ

ជាអ្នកមានសភាពមិនបានធ្លាក់ចុះ ជាអ្នកទៀង មានសេចក្តីត្រាស់ដឹង ប្រព្រឹត្តទៅខាងមុខ ។ ភ័យនិងពៀរទាំង ៥ ដែលអរិយសាវ័ក បានរម្ងាប់ហើយ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលដែល ជាអ្នកសម្លាប់សត្វ តែងបាននូវភ័យនិងពៀរ ដែលប្រព្រឹត្តទៅ ក្នុងបច្ចុប្បន្នផង បាននូវភ័យនិងពៀរ ដែលប្រព្រឹត្តទៅ ក្នុងលោក ខាងមុខផង ទទួលនូវទុក្ខនិងទោមនស្ស ដែលប្រព្រឹត្តទៅក្នុង ចិត្តផង ព្រោះការសម្លាប់សត្វ ជាបច្ច័យ បុគ្គលជាអ្នកវៀរចាកការ សម្លាប់សត្វ ។ បេ ។ ទើបភ័យនិងពៀរនោះ រម្ងាប់ទៅបានយ៉ាង នេះឯង ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាន់យកទ្រព្យដែលគេមិន បានឲ្យ ។ បេ ។ បុគ្គលជាអ្នកប្រព្រឹត្តខុស ក្នុងកាមទាំងឡាយ ជាអ្នក ពោលពាក្យកុហក ជាអ្នកផឹកនូវទឹកស្រវឹង គឺសុរានិងមេរ័យ ដែល ជាទីតាំងនៃសេចក្តីប្រមាទ តែងបាននូវភ័យនិងពៀរ ដែលប្រព្រឹត្តទៅ ក្នុងបច្ចុប្បន្នផង បាននូវភ័យនិងពៀរ ដែលប្រព្រឹត្តទៅ ក្នុងលោក ខាងមុខផង ទទួលនូវទុក្ខនិងទោមនស្ស ដែលប្រព្រឹត្តទៅក្នុង ចិត្តផង ព្រោះការផឹកនូវទឹកស្រវឹង គឺសុរានិងមេរ័យ ដែល ជាទីតាំងនៃសេចក្តីប្រមាទ ជាបច្ច័យ បុគ្គលអ្នកវៀរចាកការផឹកនូវទឹក ស្រវឹង គឺសុរានិងមេរ័យ ដែលជាទីតាំងនៃសេចក្តីប្រមាទហើយ

នេវ ទិដ្ឋធម្មិកម្បិ ភយំ វេរំ បសវតិ ន សម្បរាយិកម្បិ ភយំ វេរំ បសវតិ ន ចេតសិកម្បិ ទុក្ខំ ទោមនស្សំ បដិសំវេទេតិ សុរាមេរយមជ្ជប្បមាទដ្ឋានា បដិវិរតស្ស ឯវំ តំ ភយំ វេរំ វូបសន្តំ ហោតិ ។ ឥមានិ បញ្ច ភយានិ វេរានិ វូបសន្តានិ ហោន្តិ ។ កតមេហិ ចតូហិ សោតាបត្តិយង្គេហិ សមន្នាគតោ ហោតិ ។ ឥធ ភិក្ខវេ អរិយសាវកោ ពុទ្ធេ អវេច្ចប្បសាទេន សមន្នាគតោ ហោតិ ឥតិបិ សោ ភគវា ។ បេ ។ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ ។ ធម្មេ ។ បេ ។ សង្ឃេ ។ អរិយកន្តេហិ សីលេហិ សមន្នាគតោ ហោតិ អខណ្ឌេហិ អច្ឆិទ្ទេហិ អសពលេហិ អកម្មាសេហិ ភុជិស្សេហិ វិញ្ញុប្បសត្ថេហិ អបរាមដ្ឋេហិ សមាធិសំវត្តនិកេហិ ។ ឥមេហិ ចតូហិ សោតាបត្តិយង្គេហិ សមន្នាគតោ ហោតិ ។

តែងមិនបាននូវភ័យនិងពៀរ ដែលប្រព្រឹត្តទៅ ក្នុងបច្ចុប្បន្នផង មិន បាននូវភ័យនិងពៀរ ដែលប្រព្រឹត្តទៅ ក្នុងលោកខាងមុខផង មិន ទទួលនូវទុក្ខនិងទោមនស្ស ដែលប្រព្រឹត្តទៅក្នុងចិត្តផង កាលបើ បុគ្គលវៀរចាកការផឹកនូវទឹកស្រវឹង គឺសុរានិងមេរ័យ ដែលជាទី តាំងនៃសេចក្តីប្រមាទហើយ ទើបភ័យនិងពៀរនោះ រម្ងាប់ទៅ បានយ៉ាងនេះ ។ ភ័យនិងពៀរដែលអរិយសាវ័ក បានរម្ងាប់ហើយ មាន ៥ យ៉ាងនេះឯង ។ ចុះអរិយសាវ័ក ដែលប្រកបដោយអង្គនៃ សោតាបត្តិ ៤ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវ័ក ក្នុងសាសនានេះ ជាអ្នកប្រកបដោយសេចក្តីជ្រះថ្លា មិនកម្រើក ក្នុង ព្រះពុទ្ធថា ព្រះដ៏មានព្រះភាគអង្គនោះ ។ បេ ។ ព្រះអង្គជាគ្រូនៃ ទេវតានិងមនុស្សទាំងឡាយ ព្រះអង្គទ្រង់ត្រាស់ដឹងនូវចតុរារិយសច្ច ព្រះអង្គលែងវិលមកកាន់ភពថ្មីទៀត ។ ក្នុងព្រះធម៌ ។ បេ ។ ក្នុង ព្រះសង្ឃ ។ អរិយសាវ័ក ប្រកបដោយសីលទាំងឡាយ ដែលជាទី ត្រេកអររបស់ព្រះអរិយៈ ជាសីលមិនដាច់ មិនធ្លុះ មិនពព្រុស មិនពពាល ជាសីលជានា ដែលពួកអ្នកប្រាជ្ញសរសើរហើយ ជាសីល មិនបបោសអង្អែលដោយតណ្ហា ជាសីលប្រព្រឹត្តទៅដើម្បីសមាធិ ។ អរិយសាវ័ក ប្រកបដោយអង្គនៃសោតាបត្តិ ៤ យ៉ាងនេះឯង ។

យតោ ខោ ភិក្ខវេ អរិយសាវកស្ស ឥមានិ បញ្ច ភយានិ វេរានិ វូបសន្តានិ ហោន្តិ ឥមេហិ ច ចតូហិ សោតាបត្តិយង្គេហិ សមន្នាគតោ ហោតិ សោ អាកង្ខមានោ អត្តនា វ អត្តានំ ព្យាករេយ្យ ខីណនិរយោម្ហិ ខីណតិរច្ឆានយោនិយោ ខីណបិត្តិវិស-យោ ខីណាបាយទុគ្គតិវិនិបាតោ សោតាបន្នោហមស្មិ អវិនិបាតធម្មោ និយតោ សម្ពោធិបរាយនោតិ ។

[២៩] នវយិមានិ ភិក្ខវេ អាឃាតវត្ថូនិ ។ កតមានិ នវ ។ អនត្ថំ មេ អចរីតិ អាឃាតំ ពន្ធតិ អនត្ថំ មេ ចរតីតិ អាឃាតំ ពន្ធតិ

ម្នាលភិក្ខុទាំងឡាយ វេលាណា អរិយសាវ័ក បានរម្ងាប់នូវភ័យនិងពៀរ ៥ យ៉ាងនេះ ទាំងប្រកបហើយដោយអង្គនៃសោតាបត្តិទាំង ៤ យ៉ាងនេះហើយ អរិយសាវ័កនោះ កាលបើប្រាថ្នាគប្បីព្យាករនូវខ្លួនដោយខ្លួនឯងបានថា អាត្មាអញ មាននរកអស់ហើយ មានតិរច្ឆានកំណើតអស់ហើយ មានបិត្តិវិស័យអស់ហើយ មានអបាយ ទុគ្គតិនិងវិនិបាតអស់ហើយ អាត្មាអញ ជាអ្នកដល់នូវសោតៈ ជាអ្នកមានសភាព មិនបានធ្លាក់ចុះ ជាអ្នកទៀង មានការត្រាស់ដឹងប្រព្រឹត្តទៅខាងមុខ ។

[២៩] ម្នាលភិក្ខុទាំងឡាយ អាឃាតវត្ថុ (ហេតុជាទីតាំងនៃសេចក្តីគុំកួន) នេះមាន ៩ យ៉ាង ។ អាឃាតវត្ថុទាំង ៩ យ៉ាងតើដូចម្តេចខ្លះ ។ គឺបុគ្គលចងគំនុំ ដោយគិតថា ជនឯណោះបានប្រព្រឹត្តនូវអំពើមិនជាប្រយោជន៍ ដល់អាត្មាអញ ១ ចងគំនុំ ដោយគិតថា ជនឯណោះ កំពុងប្រព្រឹត្តនូវអំពើមិនជាប្រយោជន៍ដល់អាត្មាអញ ១

១១០



អនត្ថំ មេ ចរិស្សតីតិ អាឃាតំ ពន្ធតិ បិយស្ស មេ មនាបស្ស អនត្ថំ អចរីតិ អាឃាតំ ពន្ធតិ បិយស្ស មេ មនាបស្ស អនត្ថំ ចរតីតិ អាឃាតំ ពន្ធតិ បិយស្ស មេ មនាបស្ស អនត្ថំ ចរិស្សតីតិ អាឃាតំ ពន្ធតិ អប្បិយស្ស មេ អមនាបស្ស អត្ថំ អចរីតិ អាឃាតំ ពន្ធតិ អប្បិយស្ស មេ អមនាបស្ស អត្ថំ ចរតីតិ អាឃាតំ ពន្ធតិ អប្បិយស្ស មេ អមនាបស្ស អត្ថំ ចរិស្សតីតិ អាឃាតំ ពន្ធតិ ។

ឥមានិ ខោ ភិក្ខវេ នវ អាឃាតវត្ថូនីតិ ។

ចងគំនុំ ដោយគិតថា ជនឯណោះនឹងប្រព្រឹត្តនូវអំពើ មិនជាប្រយោជន៍ដល់អាត្មាអញ ១ ចងគំនុំ ដោយគិតថា ជនឯណោះ បានប្រព្រឹត្តហើយនូវអំពើ មិនជាប្រយោជន៍ ដល់សត្វនិងសង្ខារជាទីស្រឡាញ់ ជាទីគាប់ចិត្តរបស់អាត្មាអញ ១ ចងគំនុំ ដោយគិតថា ជនឯណោះ កំពុងប្រព្រឹត្តនូវអំពើ មិនជាប្រយោជន៍ដល់សត្វនិងសង្ខារ ជាទីស្រឡាញ់ជាទីពេញចិត្តរបស់អាត្មាអញ ១ ចងគំនុំ ដោយគិតថា ជនឯណោះនឹងប្រព្រឹត្តនូវអំពើ មិនជាប្រយោជន៍ ដល់សត្វនិងសង្ខារជាទីស្រឡាញ់ជាទីគាប់ចិត្តរបស់អាត្មាអញ ១ ចងគំនុំ ដោយគិតថា ជនឯណោះបានប្រព្រឹត្តនូវអំពើជាប្រយោជន៍ដល់សត្វនិងសង្ខារ មិនជាទីស្រឡាញ់មិនជាទីគាប់ចិត្តរបស់អាត្មាអញ ១ ចងគំនុំ ដោយគិតថា ជនឯណោះកំពុងប្រព្រឹត្តនូវអំពើ ជាប្រយោជន៍ដល់សត្វនិងសង្ខារ មិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់អាត្មាអញ ១ ចងគំនុំ ដោយគិតថាជនឯណោះនឹងប្រព្រឹត្តនូវអំពើ ជាប្រយោជន៍ដល់សត្វនិងសង្ខារ មិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់អាត្មាអញ ១ ។ ម្នាលភិក្ខុទាំង-ឡាយ អាឃាតវត្ថុមាន ៩ យ៉ាងនេះឯង ។

បណ្ណាសកេ សត្ថាវាសវគ្គោ

[៣០] នវយិមេ ភិក្ខវេ អាឃាតប្បដិវិ-
នយា ។ កតមេ នវ ។ អនត្ថំ មេ អចរីតិ តំ
កុតេត្ថ លព្ភាតិ អាឃាតំ បដិវិនេតិ អនត្ថំ មេ
ចរតីតិ តំ កុតេត្ថ លព្ភាតិ អាឃាតំ បដិវិនេតិ
អនត្ថំ មេ ចរិស្សតីតិ តំ កុតេត្ថ លព្ភាតិ
អាឃាតំ បដិវិនេតិ បិយស្ស មេ មនាបស្ស អនត្ថំ
អចរីតិ តំ កុតេត្ថ លព្ភាតិ អាឃាតំ បដិវិនេតិ

[៣០] ម្នាលភិក្ខុទាំងឡាយ អាឃាតប្បដិវិន័យ (ការកម្ចាត់បង់នូវសេចក្ដីគុំកួន) នេះមាន ៩ យ៉ាង ។ អាឃាតប្បដិវិន័យទាំង ៩ យ៉ាង តើដូចម្ដេច ។ គឺបុគ្គលកម្ចាត់បង់នូវគំនុំ ដោយគិតថា ជនឯណោះ បានប្រព្រឹត្តនូវអំពើ មិនជាប្រយោជន៍ដល់អាត្មាអញ ព្រោះហេតុនោះ អាត្មាអញ គប្បីបាននូវអំពើមិនជាប្រយោជន៍នោះ ក្នុងបុគ្គលនុ៎ះ អំពីណា ១ កម្ចាត់បង់នូវគំនុំ ដោយគិតថា ជនឯណោះ កំពុងប្រព្រឹត្តនូវអំពើ មិនជាប្រយោជន៍ដល់អាត្មាអញ ព្រោះហេតុនោះ អាត្មាអញ គប្បីបាននូវអំពើ មិនជាប្រយោជន៍នោះ ក្នុងបុគ្គលនុ៎ះ អំពីណា ១ កម្ចាត់បង់នូវគំនុំ ដោយគិតថា ជនឯណោះ នឹងប្រព្រឹត្តនូវអំពើ មិនជាប្រយោជន៍ដល់អាត្មាអញ ព្រោះហេតុនោះ អាត្មាអញគប្បីបាននូវអំពើ មិនជាប្រយោជន៍នោះ ក្នុងបុគ្គលនុ៎ះ អំពីណា ១ កម្ចាត់បង់នូវគំនុំ ដោយគិតថា ជនឯណោះបានប្រព្រឹត្តនូវអំពើ មិនជាប្រយោជន៍ដល់សត្វនិងសង្ខារជាទីស្រឡាញ់ ជាទីគាប់ចិត្តរបស់អាត្មាអញ ព្រោះហេតុនោះ អាត្មាអញគប្បីបាននូវអំពើមិនជាប្រយោជន៍នោះ ក្នុងបុគ្គលនុ៎ះ អំពីណា ១

បិយស្ស មេ មនាបស្ស អនត្ថំ ចរតីតិ តំ កុតេត្ថ លព្ភាតិ អាឃាតំ បដិវិនេតិ បិយស្ស មេ មនាបស្ស អនត្ថំ ចរិស្សតីតិ តំ កុតេត្ថ លព្ភាតិ អាឃាតំ បដិវិនេតិ អប្បិយស្ស មេ អមនាបស្ស អត្ថំ អចរីតិ តំ កុតេត្ថ លព្ភាតិ អាឃាតំ បដិវិនេតិ អប្បិយស្ស មេ អមនាបស្ស អត្ថំ ចរតីតិ តំ កុតេត្ថ លព្ភាតិ អាឃាតំ បដិវិនេតិ

កម្ចាត់បង់នូវគំនុំ ដោយគិតថា ជនឯណោះ កំពុងប្រព្រឹត្តនូវអំពើមិនជាប្រយោជន៍ដល់សត្វនិងសង្ខារ ជាទីស្រឡាញ់ ជាទីគាប់ចិត្តរបស់អាត្មាអញ ព្រោះហេតុនោះអាត្មាអញ គប្បីបាននូវអំពើមិនជាប្រយោជន៍នោះ ក្នុងបុគ្គលនុ៎ះ អំពីណា ១ កម្ចាត់បង់នូវគំនុំ ដោយគិតថា ជនឯណោះ នឹងប្រព្រឹត្តនូវអំពើមិនជាប្រយោជន៍ដល់សត្វនិងសង្ខារ ជាទីស្រឡាញ់ ជាទីគាប់ចិត្តរបស់អាត្មាអញ ព្រោះហេតុនោះ អាត្មាអញគប្បីបាននូវអំពើមិនជាប្រយោជន៍នោះ ក្នុងបុគ្គលនុ៎ះអំពីណា ១ កម្ចាត់បង់នូវគំនុំ ដោយគិតថា ជនឯណោះ បានប្រព្រឹត្តនូវអំពើជាប្រយោជន៍ដល់សត្វនិងសង្ខារ មិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់អាត្មាអញ ព្រោះហេតុនោះ អាត្មាអញ គប្បីបាននូវអំពើជាប្រយោជន៍នោះ ក្នុងបុគ្គលនុ៎ះអំពីណា ១ កម្ចាត់បង់នូវគំនុំ ដោយគិតថា ជនឯណោះកំពុងប្រព្រឹត្តនូវអំពើជាប្រយោជន៍ដល់សត្វនិងសង្ខារ មិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់អាត្មាអញ ព្រោះហេតុនោះ អាត្មាអញគប្បីបាននូវអំពើជាប្រយោជន៍នោះ ក្នុងបុគ្គលនុ៎ះ អំពីណា ១

អប្បិយស្ស មេ អមនាបស្ស អត្ថំ ចរិស្សតីតិ តំ កុតេត្ថ លព្ភាតិ អាឃាតំ បដិវិនេតិ ។ ឥមេ ខោ ភិក្ខវេ នវ អាឃាតប្បដិវិនយាតិ ។

[៣១] នវយិមេ ភិក្ខវេ អនុបុព្វនិរោធា ។ កាតមេ នវ ។ បឋមជ្ឈានំ សមាបន្នស្ស អាមិសសញ្ញា(១) និរុទ្ធា ហោតិ ទុតិយជ្ឈានំ សមាបន្នស្ស វិតក្កវិចារា និរុទ្ធា ហោន្តិ តតិយជ្ឈានំ សមាបន្នស្ស បីតិ និរុទ្ធា ហោតិ ចតុត្ថជ្ឈានំ សមាបន្នស្ស អស្សាសបស្សាសា និរុទ្ធា ហោន្តិ អាកាសានញ្ចាយតនំ សមាបន្នស្ស រូបសញ្ញា និរុទ្ធា ហោតិ វិញ្ញាណញ្ចាយតនំ សមាបន្នស្ស អាកាសានញ្ចាយតនសញ្ញា និរុទ្ធា ហោតិ អា-កិញ្ចញ្ញាយតនំ សមាបន្នស្ស វិញ្ញាណញ្ចាយតន-សញ្ញា និរុទ្ធា ហោតិ នេវសញ្ញានាសញ្ញាយតនំ សមាបន្នស្ស អាកិញ្ចញ្ញាយតនសញ្ញា និរុទ្ធា ហោតិ

---

១ ឱ. ម. កាមសញ្ញា ។

កម្ចាត់បង់នូវគំនុំ ដោយគិតថា ជនឯណោះ នឹងប្រព្រឹត្តនូវអំពើជាប្រយោជន៍ដល់សត្វនិងសង្ខារ មិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់អាត្មាអញ ព្រោះហេតុនោះ អាត្មាអញ គប្បីបាននូវអំពើជាប្រយោជន៍នោះ ក្នុងបុគ្គលនុ៎ះ អំពីណា ១ ។ ម្នាលភិក្ខុទាំងឡាយ អាឃាតប្បដិវិន័យ មាន ៩ យ៉ាងនេះឯង ។

[៣១] ម្នាលភិក្ខុទាំងឡាយ អនុបុព្វនិរោធ (ធម៌ជាគ្រឿងរលត់ដោយលំដាប់ឈាន) នេះ មាន ៩ យ៉ាង ។ អនុបុព្វនិរោធទាំង ៩ យ៉ាង តើដូចម្តេច ។ គឺកាលបុគ្គលចូលបឋមជ្ឈានហើយ អាមិសសញ្ញា រលត់ទៅ ១ កាលចូលទុតិយជ្ឈាន វិតក្កវិចារៈរលត់ទៅ ១ កាលចូលតតិយជ្ឈាន បីតិរលត់ទៅ ១ កាលចូលចតុត្ថជ្ឈាន អស្សាសៈនិងបស្សាសៈ រលត់ទៅ ១ កាលចូលអាកាសានញ្ចាយតនជ្ឈាន រូបសញ្ញារលត់ទៅ ១ កាលចូលវិញ្ញាណញ្ចាយតនជ្ឈាន អាកាសានញ្ចាយតនសញ្ញារលត់ទៅ ១ កាលចូលអាកិញ្ចញ្ញាយតនជ្ឈាន វិញ្ញាណញ្ចាយតនសញ្ញារលត់ទៅ ១ កាលចូលនេវសញ្ញានាសញ្ញាយតនជ្ឈាន អាកិញ្ចញ្ញាយតនសញ្ញា រលត់ទៅ ១

សញ្ញាវេទយិតនិរោធំ សមាបន្នស្ស សញ្ញា ច វេទនា ច និរុទ្ធា ហោន្តិ ។ ឥមេ ខោ ភិក្ខវេ នវ អនុបុព្វនិរោធាតិ ។

សត្តាវាសវគ្គោ តតិយោ ។

## តត្រុទ្ទានំ ភវតិ

ឋានខឡុង្កោ តណ្ហា សត្តសញ្ញា សិលាយូបោ
ទ្វេ វេរា ទ្វេ អាឃាតានិ អនុបុព្វនិរោធេន ចាតិ ។

*កាលចូលសញ្ញាវេទយិតនិរោធ សញ្ញានិងវេទនារលត់ទៅ ១ ។ ម្នាលភិក្ខុទាំងឡាយ អនុបុព្វនិរោធ មាន ៩ យ៉ាងនេះឯង ។*

ចប់ សត្តាវាសវគ្គទី ៣ ។

## ឧទ្ទានក្នុងសត្តាវាសវគ្គនោះគឺ

*និយាយអំពីហេតុដ៏ប្រសើរ ១ អំពីគោត្រ ១ អំពីតណ្ហាមូលកធម៌ ១ អំពីវត្ថុសញ្ញា ១ អំពីការប្រៀបដោយសសរថ្ម ១ អំពីពៀរមានពីរលើក អំពីអាឃាតវត្ថុមានពីរលើក អំពីអនុបុព្វនិរោធ ១ ។*

---

# ចតុត្ថោ មហាវគ្គោ

[៣២] នវយិមេ ភិក្ខវេ អនុបុព្វវិហារា ។ កតមេ នវ ។ បឋមជ្ឈានំ ទុតិយជ្ឈានំ តតិយជ្ឈានំ ចតុត្ថជ្ឈានំ អាកាសានញ្ចាយតនំ វិញ្ញាណញ្ចាយតនំ អាកិញ្ចញ្ញាយតនំ នេវសញ្ញានាសញ្ញាយតនំ សញ្ញាវេទយិតនិរោធោ ។ ឥមេ ខោ ភិក្ខវេ នវ អនុបុព្វវិហារាតិ ។

[៣៣] នវយិមា ភិក្ខវេ អនុបុព្វវិហារសមាបត្តិយោ ទេសេស្សាមិ តំ សុណាថ ។ បេ ។ កតមា ច ភិក្ខវេ នវ អនុបុព្វវិហារសមាបត្តិយោ ។ យត្ថ កាមា និរុជ្ឈន្តិ យេ ច កាមេ និរោធេត្វា និរោធេត្វា វិហរន្តិ អទ្ធា តេ អាយស្មន្តោ និច្ឆាតា និព្ពុតា តិណ្ណា បារគតា តទង្គេនាតិ វទាមិ ។

# មហាវគ្គទី ៤

[៣២] ម្នាលភិក្ខុទាំងឡាយ អនុបុព្វវិហារ (ធម៌ជាគ្រឿងនៅតាមលំដាប់) នេះ មាន ៩ យ៉ាង ។ អនុបុព្វវិហារ ៩ យ៉ាង តើដូចម្តេច ។ គឺបឋមជ្ឈាន ១ ទុតិយជ្ឈាន ១ តតិយជ្ឈាន ១ ចតុត្ថជ្ឈាន ១ អាកាសានញ្ចាយតនជ្ឈាន ១ វិញ្ញាណញ្ចាយតនជ្ឈាន ១ អាកិញ្ចញ្ញាយតនជ្ឈាន ១ នេវសញ្ញានាសញ្ញាយតនជ្ឈាន ១ សញ្ញាវេទយិតនិរោធ ១ ។ ម្នាលភិក្ខុទាំងឡាយ អនុបុព្វវិហារមាន ៩ យ៉ាងនេះឯង ។

[៣៣] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងនូវអនុបុព្វវិហារសមាបត្តិ ៩ យ៉ាងនេះ អ្នកទាំងឡាយ ចូរប្រុងស្តាប់នូវអនុបុព្វវិហារសមាបត្តិនោះ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អនុបុព្វវិហារសមាបត្តិ ៩ យ៉ាង តើដូចម្តេចខ្លះ ។ តថាគតពោលថា កាមទាំងឡាយរលត់ទៅ ក្នុងទីណា មួយទៀត ជនទាំងឡាយណា បានរំលត់អស់ហើយ នូវកាមទាំងឡាយ អ្នកដ៏មានអាយុទាំងនោះ ឈ្មោះថា អ្នកមិនមានសេចក្តីស្រេកឃ្លាន អ្នករំលត់ទុក្ខ បានឆ្លងនូវកាមទាំងឡាយ បានដល់នូវត្រើយ ដោយអង្គនៃឈាននោះដោយពិត ។

កត្ថ កាមា និរុជ្ឈន្តិ កេ ច កាមេ និរោធេត្វា និរោធេត្វា វិហរន្តិ អហមេតំ ន ជានាមិ អហមេតំ ន បស្សាមីតិ ឥតិ យោ ឯវំ វទេយ្យ សោ ឯវមស្ស វចនីយោ ឥធាវុសោ ភិក្ខុ វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ សវិតក្កំ សវិចារំ វិវេកជំ បីតិសុខំ បឋមជ្ឈានំ ឧបសម្បជ្ជ វិហរតិ ឯត្ថ កាមា និរុជ្ឈន្តិ តេ ច កាមេ និរោធេត្វា និរោធេត្វា វិហរន្តីតិ ។ អទ្ធា ភិក្ខវេ អសឋោ អមាយាវី សាធូតិ ភាសិតំ អភិនន្ទេយ្យ អនុមោទេយ្យ សាធូតិ ភាសិតំ អភិនន្ទិត្វា អនុមោទិត្វា នមស្សមានោ បញ្ជលិកោ បយិរុបាសេយ្យ ។ យត្ថ វិតក្កវិចារា និរុជ្ឈន្តិ យេ ច វិតក្កវិចារេ និរោធេត្វា និរោធេត្វា វិហរន្តិ អទ្ធា តេ អាយស្មន្តោ និច្ឆាតា និព្វុតា តិណ្ណា បារគតា តទង្គេនាតិ វទាមិ ។

(បើ) បុគ្គលណាមួយ គប្បីពោលយ៉ាងនេះដូច្នេះថា កាមទាំងឡាយរលត់ទៅ ក្នុងទីដូចម្តេច មួយទៀត ពួកជនដូចម្តេចដែលរំលត់អស់ហើយនូវកាមទាំងឡាយ ខ្ញុំមិនស្គាល់នូវហេតុនុ៎ះ ខ្ញុំមិនឃើញនូវហេតុនុ៎ះទេ បុគ្គលនោះ អ្នកទាំងឡាយ គួរប្រាប់យ៉ាងនេះទៅវិញថា ម្នាលអាវុសោ ភិក្ខុក្នុងសាសនានេះ បានស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ បានដល់បឋមជ្ឈាន ដែលប្រកបដោយវិតក្កៈនិងវិចារៈ មានបីតិនិងសុខៈ ដែលកើតអំពីសេចក្តីស្ងប់ស្ងាត់កាមទាំងឡាយ តែងរលត់ទៅក្នុងបឋមជ្ឈាននុ៎ះ បុគ្គលទាំងនោះឈ្មោះថា បានរំលត់អស់ហើយនូវកាមទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាអ្នកមិនអួតអាង មិនមានមាយា គប្បីត្រេកអរ គប្បីអនុមោទនានូវភាសិតថា សាធុដូច្នេះ ដោយពិត លុះត្រេកអរនិងអនុមោទនានូវភាសិតថា សាធុដូច្នេះហើយ គប្បីនមស្ការប្រណម្យអញ្ជលីហើយចូលទៅអង្គុយជិត ។ តថាគតពោលថា វិតក្កៈនិងវិចារៈទាំងឡាយរលត់ទៅ ក្នុងទីណា មួយទៀត ពួកជនណា បានរំលត់អស់ហើយនូវវិតក្កៈនិងវិចារៈទាំងឡាយ អ្នកដ៏មានអាយុទាំងនោះ ឈ្មោះថាអ្នកមិនមានសេចក្តីស្រេកឃ្លាន អ្នករំលត់ទុក្ខ បានឆ្លងនូវកាមទាំងឡាយ បានដល់នូវត្រើយ ដោយអង្គនៃឈាននោះដោយពិត ។

១១៧



កត្ថ វិតក្កវិចារា និរុជ្ឈន្តិ កោ ច វិតក្កវិចារេ និរោធេត្វា និរោធេត្វា វិហរន្តិ អហមេតំ ន ជានាមិ អហមេតំ ន បស្សាមីតិ ឥតិ យោ ឯវំ វទេយ្យ សោ ឯវមស្ស វចនីយោ ឥធាវុសោ ភិក្ខុ វិតក្កវិចារានំ វូបសមា ។ បេ ។ ទុតិយជ្ឈានំ ឧបសម្បជ្ជ វិហរតិ ឯត្ថ វិតក្កវិចារា និរុជ្ឈន្តិ តេ ច វិតក្កវិចារេ និរោធេត្វា និរោធេត្វា វិហរន្តីតិ ។ អទ្ធា ភិក្ខវេ អសឋោ អមាយាវី សាធូតិ ភាសិតំ អភិនន្ទេយ្យ អនុមោទេយ្យ សាធូតិ ភាសិតំ អភិនន្ទិត្វា អនុមោ-ទិត្វា នមស្សមានោ បញ្ជលិកោ បយិរុបាសេយ្យ ។ យត្ថ បីតិ និរុជ្ឈតិ យេ ច បីតឹ និរោធេត្វា និរោធេត្វា វិហរន្តិ អទ្ធា តេ អាយស្មន្តោ និច្ឆាតា និព្វុតា តិណ្ណា បារគតា តទង្គេនាតិ វទាមិ ។

(បើ) បុគ្គលណា ពោលយ៉ាងនេះថា វិតក្កៈនិងវិចារៈ រលត់ទៅក្នុងទីដូចម្ដេច មួយទៀត ពួកជនដូចម្ដេច ដែលរំលត់នូវវិតក្កៈនិងវិចារៈ ខ្ញុំមិនស្គាល់នូវហេតុនុ៎ះ ខ្ញុំមិនឃើញនូវហេតុនុ៎ះទេ បុគ្គលនោះ អ្នកទាំង-ឡាយ គួរប្រាប់យ៉ាងនេះទៅវិញថា ម្នាលអាវុសោ ភិក្ខុក្នុងសាសនានេះ ព្រោះរម្ងាប់នូវវិតក្កៈនិងវិចារៈ ។ បេ ។ បានដល់នូវទុតិយជ្ឈានវិតក្កៈនិងវិចារៈ តែងរលត់ទៅ ក្នុងទុតិយជ្ឈាននុ៎ះ បុគ្គលទាំងនោះឈ្មោះថា រំលត់អស់ហើយនូវវិតក្កៈនិងវិចារៈ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាអ្នកមិនអួតអាង មិនមានមាយា គប្បីត្រេកអរ គប្បីអនុមោទនានូវភាសិតថា សាធុដូច្នេះ ដោយពិត លុះត្រេកអរអនុមោទនានូវភាសិតថា សាធុដូច្នេះហើយ គប្បីនមស្ការប្រណម្យអញ្ជលីហើយចូលទៅអង្គុយជិត ។ តថាគតពោលថា បីតិរលត់ទៅក្នុងទីណា មួយទៀត ពួកជនណា បានរំលត់អស់ហើយ នូវបីតិ អ្នកដ៏មានអាយុទាំងនោះឈ្មោះថា អ្នកមិនមានសេចក្ដីស្រេកឃ្លាន អ្នករំលត់ទុក្ខ បានឆ្លងនូវកាមទាំងឡាយ បានដល់នូវត្រើយដោយអង្គនៃឈាននោះដោយពិត ។

កត្ថ បីតិ និរុជ្ឈតិ កេ ច បីតឹ និរោធេត្វា និរោធេត្វា វិហរន្តិ អហមេតំ ន ជានាមិ អហមេតំ ន បស្សាមីតិ ឥតិ យោ ឯវំ វទេយ្យ សោ ឯវមស្ស វចនីយោ ឥធាវុសោ ភិក្ខុ បីតិយា ច វិរាគា ។ បេ ។ តតិយជ្ឈានំ ឧបសម្បជ្ជ វិហរតិ ឯត្ថ បីតិ និរុជ្ឈតិ តេ ច បីតឹ និរោធេត្វា និរោធេត្វា វិហរន្តីតិ ។ អទ្ធា ភិក្ខវេ អសឋោ អមាយាវី សាធូតិ ភាសិតំ អភិនន្ទេយ្យ អនុមោទេយ្យ សាធូតិ ភាសិតំ អភិនន្ទិត្វា អនុមោទិត្វា នមស្សមានោ បញ្ជលិកោ បយិរុបាសេយ្យ ។ យត្ថ ឧបេក្ខាសុខំ និរុជ្ឈតិ យេ ច ឧបេក្ខាសុខំ និរោធេត្វា និរោធេត្វា វិហរន្តិ អទ្ធា តេ អាយស្មន្តោ និច្ឆាតា និព្វុតា តិណ្ណា បារគតា តទង្គេនាតិ វទាមិ ។ កត្ថ ឧបេក្ខា-សុខំ និរុជ្ឈតិ កេ ច ឧបេក្ខាសុខំ និរោធេត្វា និរោធេត្វា វិហរន្តិ អហមេតំ ន ជានាមិ អហមេតំ ន បស្សាមីតិ ឥតិ យោ ឯវំ វទេយ្យ

(បើ) បុគ្គលណា ពោលយ៉ាងនេះថា បីតិរលត់ទៅ ក្នុងទីដូចម្ដេច មួយវិញទៀត ពួកជនដូចម្ដេច ដែលរំលត់អស់ហើយនូវបីតិ ខ្ញុំមិនស្គាល់នូវហេតុនុ៎ះ ខ្ញុំមិនឃើញនូវហេតុនុ៎ះទេ បុគ្គលនោះ អ្នកទាំង-ឡាយ គួរប្រាប់យ៉ាងនេះទៅវិញថា ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ព្រោះប្រាសចាកបីតិផង ។ បេ ។ បានដល់តតិយជ្ឈាន បីតិតែងរលត់ទៅក្នុងតតិយជ្ឈាននុ៎ះ បុគ្គលទាំងនោះឈ្មោះថារំលត់អស់ហើយនូវបីតិ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាអ្នកមិនអួតអាង មិនមានមាយា គប្បីត្រេកអរ គប្បីអនុមោទនា នូវភាសិតថា សាធុដូច្នេះ ដោយពិត លុះត្រេកអរអនុមោទនានូវភាសិតថា សាធុដូច្នេះហើយ គប្បីនមស្ការប្រណម្យអញ្ជលី ហើយចូលទៅអង្គុយជិត ។ តថាគតពោលថា សេចក្ដីសុខក្នុងឧបេក្ខារលត់ទៅក្នុងទីណា មួយទៀត ពួកជនណាបានរំលត់អស់ហើយនូវសេចក្ដីសុខ ក្នុងឧបេក្ខា អ្នកដ៏មានអាយុទាំងនោះឈ្មោះថា អ្នកមិនមានសេចក្ដីស្រេកឃ្លាន អ្នករំលត់ទុក្ខ បានឆ្លងនូវកាមទាំងឡាយ បានដល់នូវត្រើយ ដោយអង្គនៃឈាននោះដោយពិត ។ (បើ) បុគ្គលណាពោលយ៉ាងនេះថា សេចក្ដីសុខក្នុងឧបេក្ខារលត់ទៅក្នុងទីដូចម្ដេច មួយទៀត ពួកជនដូចម្ដេចដែលរលត់អស់ហើយនូវសេចក្ដីសុខក្នុងឧបេក្ខា ខ្ញុំមិនស្គាល់នូវហេតុនុ៎ះ ខ្ញុំមិនឃើញនូវហេតុនុ៎ះទេ

សោ ឯវមស្ស វចនីយោ ឥធាវុសោ ភិក្ខុ សុខស្ស ច បហានា ។ បេ ។ ចតុត្ថជ្ឈានំ ឧបសម្បជ្ជ វិហរតិ ឯត្ថ ឧបេក្ខាសុខំ និរុជ្ឈតិ តេ ច ឧបេក្ខាសុខំ និរោធេត្វា និរោធេត្វា វិហរន្តីតិ ។ អទ្ធា ភិក្ខវេ អសឋោ អមាយាវី សាធូតិ ភាសិតំ អភិនន្ទេយ្យ អនុមោទេយ្យ សាធូតិ ភាសិតំ អភិនន្ទិត្វា អនុមោទិត្វា នមស្សមានោ បញ្ជលិកោ បយិរុបាសេយ្យ ។ យត្ថ រូបសញ្ញា និរុជ្ឈន្តិ យេ ច រូបសញ្ញា និរោធេត្វា និរោធេត្វា វិហរន្តិ អទ្ធា តេ អាយស្មន្តោ និច្ឆាតា និព្ពុតា តិណ្ណា បារគតា តទង្គេនាតិ វទាមិ ។ កត្ថ រូបសញ្ញា និរុជ្ឈន្តិ កេ ច រូបសញ្ញា និរោធេត្វា និរោធេត្វា វិហរន្តិ អហមេតំ ន ជានាមិ អហមេតំ ន បស្សាមីតិ ឥតិ យោ ឯវំ វទេយ្យ

បុគ្គលនោះ អ្នកទាំងឡាយគួរប្រាប់យ៉ាងនេះទៅវិញថា ម្នាលអាវុសោ ភិក្ខុក្នុងសាសនានេះ ព្រោះលះបង់នូវសុខផង ។ បេ ។ បានដល់ចតុត្ថជ្ឈាន សេចក្តីសុខក្នុងឧបេក្ខា តែងរលត់ទៅក្នុងចតុត្ថជ្ឈានទុំះ ជនទាំងនោះឈ្មោះថា បានរំលត់អស់ហើយនូវសេចក្តីសុខក្នុងឧបេក្ខា ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាអ្នកមិនអួតអាង មិនមានមាយា គប្បីត្រេកអរ គប្បីអនុមោទនានូវភាសិតថា សាធុដូច្នេះ ដោយពិតលុះត្រេកអរអនុមោទនានូវភាសិតថា សាធុដូច្នេះហើយ គប្បីនមស្ការប្រណម្យអញ្ជលី ហើយចូលទៅអង្គុយជិត ។ តថាគតពោលថា រូបសញ្ញា រលត់ទៅក្នុងទីណា មួយទៀត ពួកជនណា បានរំលត់អស់ហើយ នូវរូបសញ្ញា អ្នកដ៏មានអាយុទាំងនោះ ឈ្មោះថា អ្នកមិនមានសេចក្តីស្រេកឃ្លាន អ្នករំលត់ទុក្ខ បានឆ្លងនូវកាមទាំងឡាយ បានដល់នូវត្រើយ ដោយអង្គនៃឈាននោះដោយពិត ។ (បើ) បុគ្គលណា ពោលយ៉ាងនេះថា រូបសញ្ញារលត់ទៅ ក្នុងទីដូចម្តេច មួយទៀត ពួកជនដូចម្តេច ដែលរំលត់អស់ហើយ នូវរូបសញ្ញា ខ្ញុំមិនស្គាល់នូវហេតុនុ៎ះ ខ្ញុំមិនឃើញនូវហេតុនុ៎ះទេ

សោ ឯវមស្ស វចនីយោ ឥធាវុសោ ភិក្ខុ សព្វសោ រូបសញ្ញានំ សមតិក្កមា បដិឃសញ្ញានំ អត្ថង្គមា នានត្តសញ្ញានំ អមនសិការា អនន្តោ អាកាសោតិ អាកាសានញ្ចាយតនំ ឧបសម្បជ្ជ វិហរតិ ឯត្ថ រូបសញ្ញា និរុជ្ឈន្តិ តេ ច រូបសញ្ញា និរោធេត្វា និរោធេត្វា វិហរន្តីតិ ។ អទ្ធា ភិក្ខវេ អសឋោ អមាយាវី សាធូតិ ភាសិតំ អភិនន្ទេយ្យ អនុមោទេយ្យ សាធូតិ ភាសិតំ អភិនន្ទិត្វា អនុមោទិត្វា នមស្សមានោ បញ្ជលិកោ បយិរុបាសេយ្យ ។ យត្ថ អាកាសា-នញ្ចាយតនសញ្ញា និរុជ្ឈតិ យេ ច អាកាសានញ្ចា-យតនសញ្ញំ និរោធេត្វា និរោធេត្វា វិហរន្តិ អទ្ធា តេ អាយស្មន្តោ និច្ឆាតា និព្វុតា តិណ្ណា បារគតា តទង្គេនាតិ វទាមិ ។ កត្ថ អាកាសានញ្ចាយតន-សញ្ញា និរុជ្ឈន្តិ កេ ច អាកាសានញ្ចាយតន-សញ្ញំ និរោធេត្វា និរោធេត្វា វិហរន្តិ អហមេតំ ន ជានាមិ អហមេតំ ន បស្សាមីតិ ឥតិ យោ ឯវំ វទេយ្យ

បុគ្គលនោះ អ្នកទាំងឡាយគួរប្រាប់យ៉ាងនេះទៅវិញថា ម្នាលអាវុសោ ភិក្ខុក្នុងសាសនានេះ ព្រោះកន្លងនូវរូបសញ្ញាដោយប្រការទាំងពួង ព្រោះអស់ទៅនៃបដិឃសញ្ញាហើយលែងធ្វើទុកក្នុងចិត្តនូវនានត្តសញ្ញា ហើយបានដល់នូវអាកាសានញ្ចាយតនជ្ឈាន ដោយធ្វើទុកក្នុងចិត្តថា អាកាសមិនមានទីបំផុតដូច្នេះ រូបសញ្ញាតែងរលត់ទៅក្នុងអាកាសានញ្ចាយតនជ្ឈាននុ៎ះ ជនទាំងនោះ ឈ្មោះថា បានរំលត់អស់ហើយនូវរូបសញ្ញា ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាអ្នកមិនអួតអាង មិនមានមាយា គប្បីត្រេកអរ គប្បីអនុមោទនានូវភាសិតថា សាធុដូច្នេះដោយពិត លុះត្រេកអរអនុមោទនានូវភាសិតថា សាធុដូច្នេះហើយ គប្បីនមស្ការប្រណម្យអញ្ជលីហើយចូលទៅអង្គុយជិត ។ តថាគតពោលថា អាកាសានញ្ចាយតនសញ្ញា រលត់ទៅក្នុងទីណា មួយទៀត ពួកជនណាបានរំលត់អស់ហើយនូវអាកាសានញ្ចាយតនសញ្ញា អ្នកដ៏មានអាយុទាំងនោះ ឈ្មោះថា អ្នកមិនមានសេចក្ដីស្រេកឃ្លាន អ្នករំលត់ទុក្ខ បានឆ្លងនូវកាមទាំងឡាយ ហើយបានដល់នូវត្រើយ ដោយអង្គនៃឈាននោះ ដោយពិត ។ (បើ) បុគ្គលណា ពោលយ៉ាងនេះថា អាកាសានញ្ចាយតនសញ្ញារលត់ទៅ ក្នុងទីដូចម្ដេច មួយទៀត ពួកជនដូចម្ដេច ដែលរំលត់អស់ហើយនូវ អាកាសានញ្ចាយតនសញ្ញា ខ្ញុំមិនស្គាល់នូវហេតុនុ៎ះ ខ្ញុំមិនឃើញនូវហេតុនុ៎ះទេ

១២១



សោ ឯវមស្ស វចនីយោ ឥធាវុសោ ភិក្ខុ សព្វសោ អាកាសានញ្ចាយតនំ សមតិក្កម្ម អនន្តំ វិញ្ញាណន្តិ វិញ្ញាណញ្ចាយតនំ ឧបសម្បជ្ជ វិហរតិ ឯត្ថ អាកាសានញ្ចាយតនសញ្ញា និរុជ្ឈតិ តេ ច អាកា-សានញ្ចាយតនសញ្ញំ និរោធេត្វា និរោធេត្វា វិហរន្តីតិ ។ អទ្ធា ភិក្ខវេ អសឋោ អមាយាវី សាធូតិ ភាសិតំ អភិនន្ទេយ្យ អនុមោទេយ្យ សាធូតិ ភាសិតំ អភិនន្ទិត្វា អនុមោទិត្វា នមស្សមានោ បញ្ជលិកោ បយិរុបាសេយ្យ ។ យត្ថ វិញ្ញាណញ្ចាយតនសញ្ញា និរុជ្ឈតិ យេ ច វិញ្ញាណញ្ចាយតនសញ្ញំ និរោធេត្វា និរោធេត្វា វិហរន្តិ អទ្ធា តេ អាយស្មន្តោ និច្ឆាតា និព្វុតា តិណ្ណា បារគតា តទង្គេ-នាតិ វទាមិ ។ កត្ថ វិញ្ញាណញ្ចាយតនសញ្ញា និរុជ្ឈតិ កេ ច វិញ្ញាណញ្ចាយតនសញ្ញំ និរោធេត្វា និរោធេត្វា វិហរន្តិ អហមេតំ ន ជានាមិ អហមេតំ ន បស្សាមិ ឥតិ យោ ឯវំ វទេយ្យ

បុគ្គលនោះ អ្នកទាំងឡាយ គួរប្រាប់យ៉ាងនេះទៅវិញថា ម្នាលអាវុសោ ភិក្ខុក្នុងសាសនានេះ ព្រោះកន្លងនូវអាកាសានញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ហើយបានដល់នូវវិញ្ញាណញ្ចាយតនជ្ឈាន ដោយធ្វើទុកក្នុងចិត្តថា វិញ្ញាណមិនមានទីបំផុតដូច្នេះ អាកាសានញ្ចាយតនសញ្ញា តែងរលត់ទៅក្នុងវិញ្ញាណញ្ចាយតនៈនុ៎ះ ជនទាំងនោះ ឈ្មោះថា បានរំលត់អស់ហើយនូវអាកាសានញ្ចាយតនសញ្ញា ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាអ្នកមិនអួតអាង មិនមានមាយា គប្បីត្រេកអរ គប្បីអនុមោទនានូវភាសិតថា សាធុដូច្នេះដោយពិត លុះត្រេកអរអនុមោទនានូវភាសិតថា សាធុដូច្នេះហើយ គប្បីនមស្ការប្រណម្យអញ្ជលី ហើយចូលទៅអង្គុយជិត ។ តថាគតពោលថា វិញ្ញាណញ្ចាយតនសញ្ញា រលត់ទៅក្នុងទីណា មួយទៀត ពួកជនណា បានរំលត់អស់ហើយនូវវិញ្ញាណញ្ចាយតនសញ្ញា អ្នកដ៏មានអាយុទាំងនោះ ឈ្មោះថា អ្នកមិនមានសេចក្តីស្រេកឃ្លាន អ្នករំលត់ទុក្ខ បានឆ្លងនូវកាមទាំងឡាយ ហើយបានដល់នូវត្រើយ ដោយអង្គនៃឈាននោះដោយពិត ។ (បើ) បុគ្គលណា ពោលយ៉ាងនេះថា វិញ្ញាណញ្ចាយតនសញ្ញាតែងរលត់ទៅក្នុងទីដូចម្តេច មួយទៀត ពួកជនដូចម្តេចដែលរំលត់អស់ហើយនូវវិញ្ញាណញ្ចាយតនសញ្ញា ខ្ញុំមិនស្គាល់នូវហេតុនុ៎ះ ខ្ញុំមិនឃើញនូវហេតុនុ៎ះទេ

សោ ឯវមស្ស វចនីយោ ឥធាវុសោ ភិក្ខុ សព្វសោ វិញ្ញាណញ្ចាយតនំ សមតិក្កម្ម នត្ថិ កិញ្ចីតិ អាកិញ្ច-ញ្ញាយតនំ ឧបសម្បជ្ជ វិហរតិ ឯត្ថ វិញ្ញាណញ្ចាយ-តនសញ្ញា និរុជ្ឈតិ តេ ច វិញ្ញាណញ្ចាយតនសញ្ញំ និរោធេត្វា និរោធេត្វា វិហរន្តីតិ ។ អទ្ធា ភិក្ខវេ អសឋោ អមាយាវី សាធូតិ ភាសិតំ អភិនន្ទេយ្យ អនុមោទេយ្យ សាធូតិ ភាសិតំ អភិនន្ទិត្វា អនុមោទិត្វា នមស្សមានោ បញ្ជលិកោ បយិរុបាសេយ្យ ។ យត្ថ អាកិញ្ចញ្ញាយតនសញ្ញា និរុជ្ឈតិ យេ ច អាកិ-ញ្ចញ្ញាយតនសញ្ញំ និរោធេត្វា និរោធេត្វា វិហរន្តិ អទ្ធា តេ អាយស្មន្តោ និច្ឆាតា និព្វុតា តិណ្ណា បារគតា តទង្គេនាតិ វទាមិ ។ កត្ថ អាកិញ្ចញ្ញាយតនសញ្ញា និរុជ្ឈតិ កេ ច អាកិញ្ចញ្ញាយតនសញ្ញំ និរោធេត្វា និរោធេត្វា វិហរន្តិ អហាមេតំ ន ជានាមិ អហាមេតំ ន បស្សាមីតិ ឥតិ យោ ឯវំ វទេយ្យ សោ

បុគ្គលនោះ អ្នកទាំងឡាយ គួរប្រាប់យ៉ាងនេះទៅវិញថា ម្នាលអាវុសោ ភិក្ខុក្នុងសាសនានេះ ព្រោះកន្លងនូវវិញ្ញាណញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ហើយបានដល់នូវអាកិញ្ចញ្ញាយតនជ្ឈាន ដោយធ្វើទុកក្នុងចិត្តថា របស់អ្វីបន្តិចបន្តួចមិនមានដូច្នេះ វិញ្ញាណញ្ចាយតនសញ្ញា តែងរលត់ទៅក្នុងអាកិញ្ចញ្ញាយតនៈនុ៎ះ ជនទាំងនោះ ឈ្មោះថា បានរំលត់អស់ហើយនូវវិញ្ញាណញ្ចាយតនសញ្ញា ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាអ្នកមិនអួតអាង មិនមានមាយា គប្បីត្រេកអរ គប្បីអនុមោទនានូវភាសិតថា សាធុដូច្នេះ លុះត្រេកអរអនុមោទនានូវភាសិតថា សាធុដូច្នេះហើយ គប្បីនមស្ការប្រណម្យអញ្ជលីហើយ ចូលទៅអង្គុយជិត ។ តថាគតពោលថា អាកិញ្ចញ្ញាយតនសញ្ញា តែងរលត់ទៅក្នុងទីណា មួយទៀត ពួកជនណា បានរំលត់អស់ហើយ នូវអាកិញ្ចញ្ញាយតនសញ្ញា អ្នកដ៏មានអាយុទាំងនោះឈ្មោះថា អ្នកមិនមានសេចក្តីស្រេកឃ្លាន អ្នករំលត់ទុក្ខ បានឆ្លងនូវកាមទាំងឡាយ បានដល់នូវត្រើយ ដោយអង្គនៃឈាននោះ ។ (បើ) បុគ្គលណាពោល យ៉ាងនេះថា អាកិញ្ចញ្ញាយតនសញ្ញា តែងរលត់ទៅក្នុងទីដូចម្តេច មួយទៀត ពួកជនដូចម្តេច ដែលរំលត់អស់ហើយនូវអាកិញ្ចញ្ញាយតនសញ្ញា ខ្ញុំមិនស្គាល់នូវហេតុនុ៎ះ ខ្ញុំមិនឃើញនូវហេតុនោះទេ

១២៣

បណ្ណាសកេ មហាវគ្គោ

ឯវមស្ស វចនីយោ ឥធាវុសោ ភិក្ខុ សព្វសោ អាកិញ្ចញ្ញាយតនំ សមតិក្កម្ម នេវសញ្ញានាសញ្ញាយតនំ ឧបសម្បជ្ជ វិហរតិ ឯត្ថ អាកិញ្ចញ្ញាយតនសញ្ញា និរុជ្ឈតិ តេ ច អាកិញ្ចញ្ញាយតនសញ្ញំ និរោធេត្វា និរោធេត្វា វិហរន្តីតិ ។ អទ្ធា ភិក្ខវេ អសឋោ អមាយាវី សាធូតិ ភាសិតំ អភិនន្ទេយ្យ អនុមោទេយ្យ សាធូតិ ភាសិតំ អភិនន្ទិត្វា អនុមោទិត្វា នមស្សមានោ បញ្ជលិកោ បយិរុបាសេយ្យ ។ យត្ថ នេវសញ្ញានាសញ្ញាយតនសញ្ញា និរុជ្ឈតិ យេ ច នេវសញ្ញានាសញ្ញាយតនសញ្ញំ និរោធេត្វា និរោធេត្វា វិហរន្តិ អទ្ធា តេ អាយស្មន្តោ និច្ឆាតា និព្វុតា តិណ្ណា បារគតា តទង្គេនាតិ វទាមិ ។ កត្ថ នេវសញ្ញានាសញ្ញាយតនសញ្ញា និរុជ្ឈតិ កេ ច នេវសញ្ញានាសញ្ញាយតនសញ្ញំ និរោធេត្វា និរោធេត្វា វិហរន្តិ អហមេតំ ន ជានាមិ អហមេតំ ន បស្សាមីតិ ឥតិ យោ ឯវំ វទេយ្យ

បុគ្គលនោះ អ្នកទាំងឡាយ គួរប្រាប់យ៉ាងនេះទៅវិញថា ម្នាលអាវុសោ ភិក្ខុក្នុងសាសនានេះ ព្រោះកន្លងនូវអាកិញ្ចញ្ញាយតនៈ ដោយប្រការទាំងពួង ហើយបានដល់នូវនេវសញ្ញានាសញ្ញាយតនជ្ឈាន អាកិញ្ចញ្ញា-យតនសញ្ញា តែងរលត់ទៅ ក្នុងនេវសញ្ញានាសញ្ញាយតនៈនុ៎ះ ជនទាំងនោះ ឈ្មោះថា បានរំលត់អស់ហើយនូវអាកិញ្ចញ្ញាយតនសញ្ញា ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាអ្នកមិនអួតអាង មិនមានមាយា គប្បីត្រេកអរ គប្បីអនុមោទនានូវភាសិតថា សាធុដូច្នេះដោយពិត លុះត្រេកអរអនុមោទនានូវភាសិតថា សាធុដូច្នេះហើយ គប្បីនមស្ការប្រណម្យអញ្ជលី ហើយចូលទៅអង្គុយជិត ។ តថាគតពោលថា នេវសញ្ញានាសញ្ញាយតនសញ្ញា តែងរលត់ទៅក្នុងទីណា មួយទៀត ពួកជនណា បានរំលត់អស់ហើយនូវនេវសញ្ញានាសញ្ញាយតនសញ្ញា អ្នកដ៏មានអាយុទាំងនោះ ឈ្មោះថា អ្នកមិនមានសេចក្តីស្រេកឃ្លាន អ្នករំលត់ទុក្ខ បានឆ្លងនូវកាមទាំងឡាយហើយ បានដល់នូវត្រើយដោយអង្គនៃឈាននោះដោយពិត ។ (បើ) បុគ្គលណា ពោលយ៉ាងនេះថា នេវសញ្ញានាសញ្ញាយតនសញ្ញា តែងរលត់ទៅក្នុងទីដូចម្តេចមួយទៀត ពួកជនដូចម្តេច ដែលរំលត់អស់ហើយនូវនេវសញ្ញានាសញ្ញា-យតនសញ្ញា ខ្ញុំមិនស្គាល់នូវហេតុនុ៎ះ ខ្ញុំមិនឃើញនូវហេតុនុ៎ះទេ

សោ ឯវមស្ស វចនីយោ ឥធាវុសោ ភិក្ខុ សព្វសោ នេវសញ្ញានាសញ្ញាយតនំ សមតិក្កម្ម សញ្ញាវេទយិតនិរោធំ ឧបសម្បជ្ជ វិហរតិ ឯត្ថ នេវសញ្ញានាសញ្ញាយតនសញ្ញា និរុជ្ឈតិ តេ ច នេវសញ្ញានាសញ្ញាយតនសញ្ញំ និរោធេត្វា និរោធេត្វា វិហរន្តីតិ ។ អទ្ធា ភិក្ខវេ អសឋោ អមាយាវី សាធូតិ ភាសិតំ អភិនន្ទេយ្យ អនុមោទេយ្យ សាធូតិ ភាសិតំ អភិនន្ទិត្វា អនុមោទិត្វា នមស្សមានោ បញ្ជលិកោ បយិរុបាសេយ្យ ។ ឥមា ខោ ភិក្ខវេ នវ អនុបុព្វវិហារសមាបត្តិយោតិ ។

[៣៤] ឯកំ សមយំ អាយស្មា សារីបុត្តោ រាជគហេ វិហរតិ វេឡុវនេ កលន្ទកនិវាបេ ។ តត្រ ខោ អាយស្មា សារីបុត្តោ ភិក្ខូ អាមន្តេសិ សុខមិទំ អាវុសោ និព្វានំ សុខមិទំ អាវុសោ និព្វានន្តិ ។ ឯវំ វុត្តេ អាយស្មា ឧទាយិ អាយស្មន្តំ សារីបុត្តំ ឯតទវោច

បុគ្គលនោះ អ្នកទាំងឡាយ គួរប្រាប់យ៉ាងនេះទៅវិញថា ម្នាលអាវុសោ ភិក្ខុក្នុងសាសនានេះ ព្រោះកន្លងនូវនេវសញ្ញានាសញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង បានដល់នូវសញ្ញាវេទយិតនិរោធ នេវសញ្ញា-នាសញ្ញាយតនសញ្ញា តែងរលត់ទៅក្នុងសញ្ញាវេទយិតនិរោធនុ៎ះ ជនទាំងនោះ ឈ្មោះថា បានរំលត់អស់ហើយនូវនេវសញ្ញានាសញ្ញាយតន-សញ្ញា ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាអ្នកមិនអួតអាង មិនមានមាយា គប្បីត្រេកអរ គប្បីអនុមោទនានូវភាសិតថា សាធុដូច្នេះដោយពិត លុះត្រេកអរ អនុមោទនានូវភាសិតថា សាធុដូច្នេះហើយ គប្បីនមស្ការប្រណាម្យអញ្ជលី ហើយចូលទៅអង្គុយជិត ។ ម្នាលភិក្ខុទាំងឡាយ អនុបុព្វវិហារសមាបត្តិ មាន ៩ យ៉ាងនេះឯង ។

[៣៤] សម័យមួយ ព្រះសារីបុត្តដ៏មានអាយុ គង់ក្នុងវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ក្បែរក្រុងរាជគ្រឹះ ។ ក្នុងទីនោះឯង ព្រះសារីបុត្តដ៏មានអាយុ ហៅភិក្ខុទាំងឡាយមកថា ម្នាលអាវុសោទាំងឡាយ និព្វាននេះជាសុខ ម្នាលអាវុសោទាំងឡាយ និព្វាននេះជាសុខ ។ កាលបើព្រះសារីបុត្តពោលយ៉ាងនេះហើយ ព្រះឧទាយិដ៏មានអាយុក៏បានពោលទៅនឹងព្រះសារីបុត្តដ៏មានអាយុដូច្នេះថា

កឹ បនេត្ថ អាវុសោ សារីបុត្ត សុខំ យទេត្ថ នត្ថិ វេទយិតន្តិ ។ ឯតទេវ ខ្វេត្ថ អាវុសោ សុខំ យទេត្ថ នត្ថិ វេទយិតំ ។ បញ្ចិមេ អាវុសោ កាមគុណា ។ កតមេ បញ្ច ។ ចក្ខុវិញ្ញេយ្យា រូបា ឥដ្ឋា កន្តា មនាបា បិយរូបា កាមូបសញ្ហិតា រជនីយា សោតវិញ្ញេយ្យា សទ្ទា ។ បេ ។ ឃានវិញ្ញេយ្យា គន្ធា ជិវ្ហាវិញ្ញេយ្យា រសា កាយវិញ្ញេយ្យា ផោដ្ឋព្វា ឥដ្ឋា កន្តា មនាបា បិយរូបា កាមូបសញ្ហិតា រជនីយា ។ ឥមេ ខោ អាវុសោ បញ្ច កាមគុណា ។ យំ ខោ អាវុសោ ឥមេ បញ្ច កាមគុណេ បដិច្ច ឧប្បជ្ជតិ សុខំ សោមនស្សំ ឥទំ វុច្ចតាវុសោ កាមសុខំ ។ ឥធាវុសោ ភិក្ខុ វិវិច្ចេវ កាមេហិ ។ បេ ។ បឋមជ្ឈានំ ឧបសម្បជ្ជ វិហរតិ តស្ស ចេ អាវុសោ ភិក្ខុនោ ឥមិនា វិហារេន វិហរតោ កាមសហគតា សញ្ញាម-នសិការា សមុទាចរន្តិ ស្វាស្ស ហោតិ អាពាធោ ។

ម្នាលអាវុសោសារីបុត្ត ការដឹងណា ក្នុងព្រះនិព្វានទុំះ មិនមានទេ ចុះសុខ ក្នុងព្រះនិព្វានទុំះតើដូចម្តេច ។ ម្នាលអាវុសោ ការដឹងណា ក្នុងព្រះនិព្វានទុំះ មិនមានទេ ហ្នឹងហើយជាសុខ ក្នុងព្រះនិព្វានទុំះ ឯង ។ ម្នាលអាវុសោ កាមគុណទាំងឡាយនេះ មាន ៥ យ៉ាង ។ កាមគុណ ៥ យ៉ាង តើដូចម្តេចខ្វះ ។ គឺរូបដែលគប្បីដឹងដោយភ្នែក ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត មានសភាពជាទីស្រឡាញ់ ប្រកបដោយកាម ជាទីរីករាយ សំឡេងដែលគប្បីដឹងដោយត្រចៀក ។ បេ ។ ក្លិនដែលគប្បីដឹងដោយច្រមុះ រសដែលគប្បីដឹងដោយ អណ្តាត ផោដ្ឋព្វៈដែលគប្បីដឹងដោយកាយ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត មានសភាព ជាទីស្រឡាញ់ ប្រកបដោយកាម ជាទី រីករាយ ។ ម្នាលអាវុសោ កាមគុណមាន ៥ យ៉ាងនេះឯង ។ ម្នាល អាវុសោ សុខនិងសោមនស្សណា កើតឡើង ព្រោះអាស្រ័យនូវ កាមគុណ ៥ យ៉ាងនេះ ម្នាលអាវុសោ នេះហៅថា កាមសុខ ។ ម្នាល អាវុសោ ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ បាន ដល់បឋមជ្ឈាន ម្នាលអាវុសោ កាលបើភិក្ខុនោះ កំពុងនៅដោយ វិហារធម៌នេះហើយ សញ្ញាមនសិការៈ (ការធ្វើទុកក្នុងចិត្តនូវសញ្ញា) ប្រកបដោយកាម ក៏ជ្រួលច្រាល់ឡើង នោះជាអាពាធរបស់ភិក្ខុនោះ ។

សេយ្យថាបិ អាវុសោ សុខិនោ ទុក្ខំ ឧប្បជ្ជេយ្យ យាវទេវ អាពាធាយ ឯវមេវស្ស តេ កាមសហគតា សញ្ញាមនសិការា សមុទាចរន្តិ ស្វាស្ស ហោតិ អាពាធោ ។ យោ ខោ បនាវុសោ អាពាធោ ទុក្ខមេតំ វុត្តំ ភគវតា ។ ឥមិនាបិ ខោ ឯតំ អាវុសោ បរិយាយេន វេទិតព្វំ យថាសុខំ និព្វានំ ។ បុន ចបរំ អាវុសោ ភិក្ខុ វិតក្កវិចារានំ វូបសមា ។ បេ ។ ទុតិយជ្ឈានំ ឧបសម្បជ្ជ វិហរតិ តស្ស ចេ អាវុសោ ភិក្ខុនោ ឥមិនា វិហារេន វិហរតោ វិតក្កសហគតា សញ្ញាមនសិការា សមុទាចរន្តិ ស្វាស្ស ហោតិ អាពាធោ ។ សេយ្យថាបិ អាវុសោ សុខិនោ ទុក្ខំ ឧប្បជ្ជេយ្យ យាវទេវ អាពាធាយ ឯវមេវស្ស តេ វិតក្កសហគតា សញ្ញាមនសិការា សមុទាចរន្តិ ស្វាស្ស ហោតិ អាពាធោ ។ យោ ខោ បនាវុសោ អាពាធោ ទុក្ខមេតំ វុត្តំ ភគវតា ។ ឥមិនាបិ ខោ ឯតំ អាវុសោ បរិយាយេន វេទិតព្វំ យថាសុខំ និព្វានំ ។

ម្នាលអាវុសោ ដូចសេចក្តីទុក្ខគប្បីកើតឡើង ដល់បុគ្គលដែលមានសេចក្តីសុខជាហេតុឲ្យកើតអាពាធ ជាកំណត់យ៉ាងណាមិញ សញ្ញាមនសិការៈប្រកបដោយកាមទាំងនោះ របស់ភិក្ខុនោះ ជ្រួលច្រាល់ឡើង នោះជាអាពាធរបស់ភិក្ខុនោះ ក៏យ៉ាងនោះដែរ ។ ម្នាលអាវុសោ អាពាធណាដែលកើតឡើងហើយ អាពាធនុ៎ះព្រះដ៏មានព្រះភាគទ្រង់ពោលថាជាទុក្ខ ។ ម្នាលអាវុសោ ព្រះនិព្វានដែលមានសេចក្តីសុខយ៉ាងណានុ៎ះ គប្បីដឹងដោយបរិយាយនេះចុះ ។ ម្នាលអាវុសោ មួយទៀត ភិក្ខុព្រោះរម្ងាប់នូវវិតក្កៈនិងវិចារៈទាំងឡាយ ។ បេ ។ បានដល់ទុតិយជ្ឈាន ម្នាលអាវុសោ កាលបើភិក្ខុនោះ កំពុងនៅដោយវិហារធម៌នេះហើយ សញ្ញាមនសិការៈដែលប្រកបដោយវិតក្កៈ ក៏ជ្រួលច្រាល់ឡើង នោះជាអាពាធរបស់ភិក្ខុនោះ ។ ម្នាលអាវុសោ ដូចសេចក្តីទុក្ខ គប្បីកើតឡើងដល់បុគ្គលដែលមានសេចក្តីសុខជាហេតុឲ្យកើតអាពាធ ជាកំណត់យ៉ាងណាមិញ សញ្ញាមនសិការៈដែលប្រកបដោយវិតក្កៈទាំងនោះ របស់ភិក្ខុនោះជ្រួលច្រាល់ឡើង នោះជាអាពាធរបស់ភិក្ខុនោះ ក៏យ៉ាងនោះដែរ ។ ម្នាលអាវុសោ អាពាធណាដែលកើតឡើងហើយ អាពាធនុ៎ះព្រះដ៏មានព្រះភាគទ្រង់ពោលថា ជាទុក្ខ ។ ម្នាលអាវុសោ ព្រះនិព្វានដែលមានសេចក្តីសុខយ៉ាងណានុ៎ះ គប្បីដឹងដោយបរិយាយនេះចុះ ។

១២៧



បុន ចបរំ អាវុសោ ភិក្ខុ បីតិយា ច វិរាគា ។ បេ ។ តតិយជ្ឈានំ ឧបសម្បជ្ជ វិហរតិ តស្ស ចេ អាវុសោ ភិក្ខុនោ ឥមិនា វិហារេន វិហរតោ បីតិសហគតា សញ្ញាមនសិការា សមុទាចរន្តិ ស្វាស្ស ហោតិ អាពាធោ ។ សេយ្យថាបិ អាវុសោ សុខិនោ ទុក្ខំ ឧប្បជ្ជេយ្យ យាវទេវ អាពាធាយ ឯវមេវស្ស តេ បីតិសហគតា សញ្ញាមនសិការា សមុទាចរន្តិ ស្វាស្ស ហោតិ អាពាធោ ។ យោ ខោ បនាវុសោ អាពាធោ ទុក្ខមេតំ វុត្តំ ភគវតា ។ ឥមិនាបិ ខោ ឯតំ អាវុសោ បរិយាយេន វេទិតព្វំ យថាសុខំ និព្វានំ ។ បុន ចបរំ អាវុសោ ភិក្ខុ សុខស្ស ច បហានា ។ បេ ។ ចតុត្ថជ្ឈានំ ឧបសម្បជ្ជ វិហរតិ តស្ស ចេ អាវុសោ ភិក្ខុនោ ឥមិនា វិហារេន វិហរតោ ឧបេក្ខាសហគតា សញ្ញាមនសិការា សមុទាចរន្តិ ស្វាស្ស ហោតិ អាពាធោ ។ សេយ្យថាបិ អាវុសោ សុខិនោ ទុក្ខំ ឧប្បជ្ជេយ្យ យាវទេវ អាពាធាយ

ម្នាលអាវុសោ មួយទៀត ភិក្ខុព្រោះនឿយណាយចាកបីតិផង ។ បេ ។ បានដល់តតិយជ្ឈាន ម្នាលអាវុសោ កាលបើភិក្ខុនោះ កំពុងនៅដោយវិហារធម៌នេះហើយ សញ្ញាមនសិការៈ ដែលប្រកបដោយបីតិក៏ជ្រួលច្រាល់ឡើង នោះជាអាពាធរបស់ភិក្ខុនោះ ។ ម្នាលអាវុសោ ដូចសេចក្តីទុក្ខ គប្បីកើតឡើងដល់បុគ្គលដែលមានសេចក្តីសុខជាហេតុឲ្យកើតអាពាធជាកំណត់ យ៉ាងណាមិញ សញ្ញាមនសិការៈ ដែលប្រកបដោយបីតិទាំងនោះ របស់ភិក្ខុនោះ ជ្រួលច្រាល់ឡើង នោះជាអាពាធ របស់ភិក្ខុនោះ ក៏យ៉ាងនោះដែរ ។ ម្នាលអាវុសោ អាពាធណាដែលកើតឡើងហើយ អាពាធនុ៎ះព្រះដ៏មានព្រះភាគ ទ្រង់ពោលថាជាទុក្ខ ។ ម្នាលអាវុសោ ព្រះនិព្វានដែលមានសេចក្តីសុខយ៉ាងណានុ៎ះ គប្បីដឹងដោយបរិយាយនេះចុះ ។ ម្នាលអាវុសោ មួយទៀត ភិក្ខុព្រោះលះបង់នូវសុខផង ។ បេ ។ បានដល់ចតុត្ថជ្ឈាន ម្នាលអាវុសោ កាលបើភិក្ខុនោះ កំពុងនៅដោយវិហារធម៌នេះហើយ សញ្ញាមនសិការៈ ដែលប្រកបដោយឧបេក្ខា ក៏ជ្រួលច្រាល់ឡើង នោះជាអាពាធរបស់ភិក្ខុនោះ ។ ម្នាលអាវុសោ ដូចសេចក្តីទុក្ខ គប្បីកើតឡើងដល់បុគ្គលដែលមានសេចក្តីសុខ ជាហេតុឲ្យកើតអាពាធជាកំណត់ យ៉ាងណាមិញ

ឯវមេវស្ស តេ ឧបេក្ខាសហគតា សញ្ញាមនសិការា សមុទាចរន្តិ ស្វាស្ស ហោតិ អាពាធោ ។ យោ ខោ បនាវុសោ អាពាធោ ទុក្ខមេតំ វុត្តំ ភគវតា ។ ឥមិនាបិ ខោ ឯតំ អាវុសោ បរិយាយេន វេទិតព្វំ យថាសុខំ និព្វានំ ។ បុន ចបរំ អាវុសោ ភិក្ខុ សព្វសោ រូបសញ្ញានំ សមតិក្កមា បដិឃសញ្ញានំ អត្ថង្គមា នានត្តសញ្ញានំ អមនសិការា អនន្តោ អាកាសោតិ អាកាសានញ្ចាយតនំ ឧបសម្បជ្ជ វិហរតិ តស្ស ចេ អាវុសោ ភិក្ខុនោ ឥមិនា វិហារេន វិហរតោ រូបសហគតា សញ្ញាមនសិការា សមុទាចរន្តិ ស្វាស្ស ហោតិ អាពាធោ ។ សេយ្យថាបិ អាវុសោ សុខិនោ ទុក្ខំ ឧប្បជ្ជេយ្យ យាវទេវ អាពាធាយ ឯវមេវស្ស តេ រូបសហគតា សញ្ញាមន-សិការា សមុទាចរន្តិ ស្វាស្ស ហោតិ អាពាធោ ។ យោ ខោ បនាវុសោ អាពាធោ ទុក្ខមេតំ វុត្តំ ភគវតា ។

សញ្ញាមនសិការៈ ដែលប្រកបដោយឧបេក្ខាទាំងនោះ របស់ភិក្ខុនោះ ជ្រួលច្រាល់ឡើង នោះជាអាពាធរបស់ភិក្ខុនោះ ក៏យ៉ាងនោះដែរ ។ ម្នាលអាវុសោ អាពាធណាដែលកើតឡើងហើយ អាពាធនុ៎ះព្រះដ៏មានព្រះភាគទ្រង់ពោលថាជាទុក្ខ ។ ម្នាលអាវុសោ ព្រះនិព្វាន ដែលមានសេចក្តីសុខយ៉ាងណានុ៎ះ គប្បីដឹងដោយបរិយាយនេះចុះ ។ ម្នាលអាវុសោ មួយទៀត ភិក្ខុព្រោះកន្លងបង់នូវរូបសញ្ញា ដោយប្រការទាំងពួង ព្រោះវិនាសទៅនៃបដិឃសញ្ញា ព្រោះមិនបានធ្វើទុកក្នុងចិត្តនូវនានត្តសញ្ញា ហើយបានដល់នូវអាកាសានញ្ចាយតនជ្ឈាន ដោយធ្វើទុកក្នុងចិត្តថា អាកាសមិនមានទីបំផុតដូច្នេះ ម្នាលអាវុសោ កាលបើភិក្ខុនោះកំពុងនៅដោយវិហារធម៌នេះហើយ សញ្ញាមនសិការៈ ដែលប្រកបដោយរូប ក៏ជ្រួលច្រាល់ឡើង នោះជាអាពាធរបស់ភិក្ខុនោះ ។ ម្នាលអាវុសោ ដូចសេចក្តីទុក្ខ គប្បីកើតឡើង ដល់បុគ្គលដែលមានសេចក្តីសុខជាហេតុឲ្យកើតអាពាធ យ៉ាងណាមិញ សញ្ញាមនសិការៈ ដែលប្រកបដោយរូបទាំងនោះ របស់ភិក្ខុនោះ ជ្រួលច្រាល់ឡើង នោះជាអាពាធរបស់ភិក្ខុនោះ ក៏យ៉ាងនោះដែរ ។ ម្នាលអាវុសោ អាពាធណាដែលកើតឡើងហើយ អាពាធនុ៎ះ ព្រះដ៏មានព្រះភាគទ្រង់ពោលថាជាទុក្ខ ។

ឥមិនាបិ ខោ តេ ឯតំ អាវុសោ បរិយាយេន វេទិតព្វំ យថាសុខំ និព្វានំ ។ បុន ចបរំ អាវុសោ ភិក្ខុ សព្វសោ អាកាសានញ្ចាយតនំ សមតិក្កម្ម អនន្តំ វិញ្ញាណន្តិ វិញ្ញាណញ្ចាយតនំ ឧបសម្បជ្ជ វិហរតិ តស្ស ចេ អាវុសោ ភិក្ខុនោ ឥមិនា វិហារេន វិហរតោ អាកាសានញ្ចាយតនសហគតា សញ្ញាមនសិការា សុមទាចរន្តិ ស្វាស្ស ហោតិ អាពាធោ ។ សេយ្យថាបិ អាវុសោ សុខិនោ ទុក្ខំ ឧប្បជ្ជេយ្យ យាវទេវ អាពាធាយ ឯវមេវស្ស តេ អាកាសានញ្ចាយតនសហគតា សញ្ញាមនសិការា សមុទាចរន្តិ ស្វាស្ស ហោតិ អាពាធោ ។ យោ ខោ បនាវុសោ អាពាធោ ទុក្ខមេតំ វុត្តំ ភគវតា ។ ឥមិនាបិ ខោ ឯតំ អាវុសោ បរិយាយេន វេទិតព្វំ យថាសុខំ និព្វានំ ។ បុន ចបរំ អាវុសោ ភិក្ខុ សព្វសោ វិញ្ញាណញ្ចាយតនំ សមតិក្កម្ម នត្ថិ កិញ្ចីតិ អាកិញ្ចញ្ញាយតនំ ឧបសម្បជ្ជ វិហរតិ

ម្នាលអាវុសោ ព្រះនិព្វានដែលមានសេចក្តីសុខយ៉ាងណានុ៎ះ គប្បីដឹងដោយបរិយាយនេះចុះ ។ ម្នាលអាវុសោ មួយទៀត ភិក្ខុ ព្រោះកន្លងបង់នូវអាកាសានញ្ចាយតនជ្ឈាន ដោយប្រការទាំងពួងហើយ បានដល់នូវវិញ្ញាណញ្ចាយតនជ្ឈាន ដោយធ្វើទុកក្នុងចិត្តថា វិញ្ញាណមិនមានទីបំផុតដូច្នេះ ម្នាលអាវុសោ កាលបើភិក្ខុនោះ កំពុងនៅដោយវិហារធម៌នេះហើយ សញ្ញាមនសិការៈ ដែលប្រកបដោយអាកាសានញ្ចាយតនជ្ឈាន ក៏ជ្រួលច្រាល់ឡើង នោះជាអាពាធរបស់ភិក្ខុនោះ ។ ម្នាលអាវុសោ ដូចសេចក្តីទុក្ខ គប្បីកើតឡើងដល់បុគ្គលដែលមានសេចក្តីសុខជាហេតុឲ្យកើតអាពាធជាកំណត់ យ៉ាងណាមិញ សញ្ញាមនសិការៈ ដែលប្រកបដោយអាកាសានញ្ចាយតនជ្ឈានទាំងនោះរបស់ភិក្ខុនោះ ជ្រួលច្រាល់ឡើង នោះជាអាពាធរបស់ភិក្ខុនោះ ក៏យ៉ាងនោះដែរ ។ ម្នាលអាវុសោ អាពាធណា ដែលកើតឡើងហើយ អាពាធនុ៎ះ ព្រះដ៏មានព្រះភាគ ទ្រង់ពោលថាជាទុក្ខ ។ ម្នាលអាវុសោ ព្រះនិព្វានដែលមានសេចក្តីសុខយ៉ាងណានុ៎ះ គប្បីដឹងដោយបរិយាយនេះចុះ ។ ម្នាលអាវុសោ មួយទៀត ភិក្ខុ ព្រោះកន្លងបង់នូវវិញ្ញាណញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ហើយបានដល់នូវអាកិញ្ចញ្ញាយតនជ្ឈាន ដោយធ្វើទុកក្នុងចិត្តថា របស់បន្តិចបន្តួចមិនមានដូច្នេះ

តស្ស ចេ អាវុសោ ភិក្ខុនោ ឥមិនា វិហារេន វិហរតោ វិញ្ញាណញ្ចាយតនសហគតា សញ្ញាមនសិការា សមុទាចរន្តិ ស្វាស្ស ហោតិ អាពាធោ ។ សេយ្យថាបិ អាវុសោ សុខិនោ ទុក្ខំ ឧប្បជ្ជេយ្យ យាវទេវ អាពា-ធាយ ឯវមេវស្ស តេ វិញ្ញាណញ្ចាយតនសហគតា សញ្ញាមនសិការា សមុទាចរន្តិ ស្វាស្ស ហោតិ អាពាធោ ។ យោ ខោ បនាវុសោ អាពាធោ ទុក្ខមេតំ វុត្តំ ភគវតា ។ ឥមិនាបិ ខោ ឯតំ អាវុសោ បរិយាយេន វេទិតព្វំ យថាសុខំ និព្វានំ ។ បុន ចបរំ អាវុសោ ភិក្ខុ សព្វសោ អាកិញ្ចញ្ញាយតនំ សមតិក្កម្ម នេវសញ្ញានាសញ្ញាយតនំ ឧបសម្បជ្ជ វិហរតិ តស្ស ចេ អាវុសោ ភិក្ខុនោ ឥមិនា វិហារេន វិហរតោ អាកិញ្ចញ្ញាយតនសហគតា សញ្ញាម-នសិការា សមុទាចរន្តិ ស្វាស្ស ហោតិ អាពាធោ ។ សេយ្យថាបិ អាវុសោ សុខិនោ ទុក្ខំ ឧប្បជ្ជេយ្យ

ម្នាលអាវុសោ កាលបើភិក្ខុនោះ កំពុងនៅដោយវិហារធម៌នេះហើយ សញ្ញាមនសិការៈ ដែលប្រកបដោយវិញ្ញាណញ្ចាយតនជ្ឈាន ក៏ផ្ទួលច្រាល់ឡើង នោះជាអាពាធរបស់ភិក្ខុនោះ ។ ម្នាលអាវុសោ ដូចសេចក្តីទុក្ខ គប្បីកើតឡើង ដល់បុគ្គលដែលមានសេចក្តីសុខជាហេតុឲ្យកើតអាពាធជាកំណត់យ៉ាងណាមិញ សញ្ញាមនសិការៈដែលប្រកបដោយវិញ្ញាណញ្ចាយតនជ្ឈានទាំងនោះ របស់ភិក្ខុនោះ ផ្ទួលច្រាល់ឡើងនោះជាអាពាធរបស់ភិក្ខុនោះ យ៉ាងនោះដែរ ។ ម្នាលអាវុសោ អាពាធណាដែលកើតឡើងហើយ អាពាធនុ៎ះ ព្រះដ៏មានព្រះភាគទ្រង់ពោលថាជាទុក្ខ ។ ម្នាលអាវុសោ ព្រះនិព្វានដែលមានសេចក្តីសុខយ៉ាងណានុ៎ះ គប្បីដឹងដោយបរិយាយនេះចុះ ។ ម្នាលអាវុសោ មួយទៀត ភិក្ខុព្រោះកន្លងបង់នូវអាកិញ្ចញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង ហើយបានដល់នេវសញ្ញានាសញ្ញាយតនជ្ឈាន ម្នាលអាវុសោ កាលបើភិក្ខុនោះ កំពុងនៅដោយវិហារធម៌នេះហើយ សញ្ញាមនសិការៈដែលប្រកបដោយអាកិញ្ចញ្ញាយតនជ្ឈានផ្ទួលច្រាល់ឡើង នោះជាអាពាធរបស់ភិក្ខុនោះ ។ ម្នាលអាវុសោ ដូចសេចក្តីទុក្ខ គប្បីកើតឡើងដល់បុគ្គលដែលមានសេចក្តីសុខជាហេតុឲ្យកើតអាពាធជាកំណត់ យ៉ាងណាមិញ

យាវទេវ អាពាធាយ ឯវមេវស្ស តេ អាកិញ្ចញ្ញា-យតនសហគតា សញ្ញាមនសិការា សមុទាចរន្តិ ស្វាស្ស ហោតិ អាពាធោ ។ យោ ខោ បនាវុសោ អាពាធោ ទុក្ខមេតំ វុត្តំ ភគវតា ។ ឥមិនាបិ ខោ ឯតំ អាវុសោ បរិយាយេន វេទិតព្វំ យថាសុខំ និព្វានំ ។ បុន ចបរំ អាវុសោ ភិក្ខុ សព្វសោ នេវសញ្ញានាសញ្ញាយតនំ សមតិក្កម្ម សញ្ញាវេទយិ-តនិរោធំ ឧបសម្បជ្ជ វិហរតិ បញ្ញាយបស្ស ទិស្វា អាសវា បរិក្ខីណា ហោន្តិ ។ ឥមិនាបិ ខោ ឯតំ អាវុសោ បរិយាយេន វេទិតព្វំ យថាសុខំ និព្វានន្តិ ។

[៣៨] សេយ្យថាបិ ភិក្ខវេ គាវី បព្វតេយ្យា ពាលា អព្យត្តា អក្ខេត្តញ្ញូ អកុសលា វិសមេ បព្វតេ ចរិតុំ តស្សា ឯវមស្ស យន្នូនាហំ អគត-បុព្វញ្ចេវ ទិសំ គច្ឆេយ្យំ អខាទិតបុព្វានិ ច តិណានិ ខាទេយ្យំ អបីតបុព្វានិ ច បានីយានិ បិវេយ្យន្តិ ។

សញ្ញាមនសិការៈ ដែលប្រកបដោយអាកិញ្ចញ្ញាយតនជ្ឈានទាំងនោះ របស់ភិក្ខុនោះ ជ្រួលច្រាល់ឡើង នោះជាអាពាធរបស់ភិក្ខុនោះ ក៏យ៉ាងនោះដែរ ។ ម្នាលអាវុសោ អាពាធណា ដែលកើតឡើងហើយ អាពាធនុ៎ះ ព្រះដ៏មានព្រះភាគទ្រង់ពោលថាជាទុក្ខ ។ ម្នាលអាវុសោ ព្រះនិព្វានដែលមានសេចក្តីសុខយ៉ាងណានុ៎ះ គប្បីដឹងដោយបរិយាយនេះចុះ ។ ម្នាលអាវុសោ មួយទៀត ភិក្ខុ ព្រោះកន្លងបង់នូវនេវសញ្ញា-នាសញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង ហើយបានដល់សញ្ញាវេទ-យិតនិរោធ អាសវៈទាំងឡាយរបស់ភិក្ខុនោះ ក៏អស់រលីងទៅ ព្រោះបានឃើញដោយបញ្ញា ។ ម្នាលអាវុសោ ព្រះនិព្វានដែលមានសេចក្តីសុខយ៉ាងណានុ៎ះ គប្បីដឹងដោយបរិយាយនេះចុះ ។

[៣៥] ម្នាលភិក្ខុទាំងឡាយ ដូចមេគោ ដើរទៅកាន់ភ្នំ ជាសត្វល្ងង់ មិនឈ្លាសវៃ មិនស្គាល់ខេត្ត មិនប្រសប់ ត្រាច់ទៅលើភ្នំដែលមិនស្មើ មេគោនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា បើដូច្នេះ គួរតែអាត្មាអញ ទៅកាន់ទិសដែលអញមិនធ្លាប់ទៅផង ទំពាស៊ីនូវស្មៅដែលអញមិនធ្លាប់ទំពាស៊ីផង ផឹកទឹកដែលអាត្មាអញមិនធ្លាប់ផឹកផង ។

សា បុរិមំ បាទំ ន សុប្បតិដ្ឋិតំ បតិដ្ឋាបេត្វា បច្ឆិមំ បាទំ ឧទ្ធរេយ្យ សា ន ចេវ អគតបុព្វំ ទិសំ គច្ឆេយ្យ ន ច អខាទិតបុព្វានិ ច តិណានិ ខាទេយ្យ ន ច អបីតបុព្វានិ ច បានីយានិ បិវេយ្យ យស្មឹបស្សា[1] ទេសេ[2] ឋិតាយ ឯវមេវស្ស យន្នូនាហំ អគតបុព្វញ្ចេវ ទិសំ គច្ឆេយ្យំ អខាទិតបុព្វានិ ច តិណានិ ខាទេយ្យំ អបីតបុព្វានិ ច បានីយានិ បិវេយ្យន្តិ ។ តញ្ច បទេសំ ន សោត្ថិនា បច្ចាគច្ឆេយ្យ ។ តំ កិស្ស ហេតុ ។ តថា ហិ សា ភិក្ខវេ គាវី បព្វតេយ្យា ពាលា អព្យត្តា អក្ខេត្តញ្ញូ អកុសលា វិសមេ បព្វតេ ចរិតុំ ។ ឯវមេវ ខោ ភិក្ខវេ ឥធេកច្ចោ ភិក្ខុ ពាលោ អព្យត្តោ អក្ខេត្តញ្ញូ អកុសលោ វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ សវិតក្កំ សវិចារំ វិវេកជំ បីតិសុខំ បឋមជ្ឈានំ ឧបសម្បជ្ជ វិហរិតុំ ។

---

១. ឱ. ម. យស្មឹ ចស្សា ។ ២. ឱ. បាទេ ។ ម. បទេសេ ។

មេគោនោះ មិនទាន់ឈរជើងមុខឲ្យស៊ប់ស្រួល ហើយលើកនូវជើងខាងក្រោយឡើង មេគោនោះ មិនគប្បីទៅកាន់ទិសដែលខ្លួនមិនធ្លាប់ទៅបានផង មិនគប្បីទំពាស៊ីនូវស្មៅដែលខ្លួនមិនធ្លាប់ទំពាស៊ីបានផង មិនគប្បីផឹកទឹកដែលខ្លួនមិនធ្លាប់ផឹកបានផង មេគោនោះឈរក្នុងប្រទេសណា តែងមានសេចក្តីត្រិះរិះយ៉ាងនេះថា បើដូច្នោះ គួរតែអាត្មាអញទៅកាន់ទិសដែលអញមិនធ្លាប់ទៅផង ទំពាស៊ីនូវស្មៅដែលអញមិនធ្លាប់ទំពាស៊ីផង ផឹកទឹកដែលអញមិនធ្លាប់ផឹកផង ។ មេគោនោះ មិនគប្បីត្រឡប់មកកាន់ប្រទេសនោះ ដោយសួស្តីបានវិញទេ ។ រឿងនោះព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះតែមេគោនោះ ត្រាច់ទៅកាន់ភ្នំ ជាសត្វល្ងង់ មិនឈ្លាសវៃ មិនស្គាល់ខេត្ត មិនប្រសប់ត្រាច់ទៅលើភ្នំ ដែលមិនស្មើ យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុខ្លះ ក្នុងសាសនានេះ ជាអ្នកល្ងង់ មិនឈ្លាសវៃ មិនស្គាល់ខេត្ត មិនប្រសប់ ក្នុងការស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយហើយ ដល់នូវបឋមជ្ឈាន ប្រកបដោយវិតក្កៈ និងវិចារៈ មានបីតិនិងសុខៈ ដែលកើតអំពីសេចក្តីស្ងាត់ ក៏យ៉ាងនោះដែរ ។

សោ តំ និមិត្តំ ន អាសេវតិ ន ភាវេតិ ន ពហុលីករោតិ ន ស្វាធិដ្ឋិតំ អធិដ្ឋាតិ តស្ស ឯវំ ហោតិ យន្នូនាហំ វិតក្កវិចារានំ វូបសមា អជ្ឈត្តំ សម្បសាទនំ ចេតសោ ឯកោទិភាវំ អវិតក្កំ អវិចារំ សមាធិជំ បីតិសុខំ ទុតិយជ្ឈានំ ឧបសម្បជ្ជ វិហរេយ្យន្តិ ។ សោ ន សក្កោតិ វិតក្កវិចារានំ វូបសមា ។ បេ ។ ទុតិយជ្ឈានំ ឧបសម្បជ្ជ វិហរិតុំ ។ តស្ស ឯវំ ហោតិ យន្នូនាហំ វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ សវិតក្កំ សវិចារំ វិវេកជំ បីតិសុខំ បឋមជ្ឈានំ ឧបសម្បជ្ជ វិហរេយ្យន្តិ ។ សោ ន សក្កោតិ វិវិច្ចេវ កាមេហិ ។ បេ ។ បឋមជ្ឈានំ ឧបសម្បជ្ជ វិហរិតុំ ។ អយំ វុច្ចតិ ភិក្ខវេ ភិក្ខុ ញាតោ[១] ភដ្ឋោ ឧភតោ បរិហីនោ សេយ្យថាបិ សា គាវី បព្វតេយ្យា ពាលា អព្យត្តា អក្ខេត្តញ្ញូ អកុសលា វិសមេ បព្វតេ ចរិតុំ ។

១. ឱ. ម. ឧភតោ ។

ភិក្ខុនោះ មិនសេព មិនចម្រើន មិនធ្វើឲ្យរឿយៗ នូវនិមិត្តនោះ មិនតាំងទុកនូវនិមិត្តដែលខ្លួនតាំងទុកល្អហើយ ភិក្ខុនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា បើដូច្នោះ គួរតែអាត្មាអញ រម្ងាប់វិតក្កៈនិងវិចារៈរួចហើយ ចូលកាន់ទុតិយជ្ឈាន ជាធម្មជាតកើតមាន ក្នុងសន្តាននៃខ្លួន ប្រកបដោយសេចក្តីជ្រះថ្លា គឺ សទ្ធា មានសភាពជាចិត្តខ្ពស់ឯក មិនមានវិតក្កៈមិនមានវិចារៈឡើយ មានតែបីតិនិងសុខៈ ដែលកើតអំពីសមាធិ គឺ បឋមជ្ឈាន ។ ភិក្ខុនោះមិនអាចដើម្បីរម្ងាប់វិតក្កៈវិចារៈ ។ បេ ។ បានដល់ទុតិយជ្ឈាន ។ ភិក្ខុនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា បើដូច្នោះ គួរតែអាត្មាអញ ស្ងាត់ចាកកាម ស្ងាត់ចាកអកុសលធម៌ហើយ ដល់នូវបឋមជ្ឈាន ប្រកបដោយវិតក្កៈនិងវិចារៈ មានតែបីតិនិងសុខៈ ដែលកើតអំពីសេចក្តីស្ងាត់ ។ ភិក្ខុនោះ មិនអាចស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ បានដល់បឋមជ្ឈានហើយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះហៅថាជាអ្នកដឹងផង ជាអ្នកអង់អាចផង ជាអ្នកសាបសូន្យចាកកាមនិងអកុសល-ធម៌ទាំងពីរផង ដូចជាមេគោនោះ ត្រាច់ទៅកាន់ភ្នំ ជាសត្វល្ងង់ មិនឈ្លាសវៃ មិនស្គាល់ខេត្ត មិនប្រសប់ ត្រាច់ទៅលើភ្នំ ដែលមិនស្មើ ។

សេយ្យថាបិ ភិក្ខវេ គាវី បព្វតេយ្យា បណ្ឌិតា ព្យត្តា ខេត្តញ្ញូ កុសលា វិសមេ បព្វតេ ចរិតុំ តស្សា ឯវមស្ស យន្នូនាហំ អគតបុព្វញ្ចេវ ទិសំ គច្ឆេយ្យំ អខាទិតបុព្វានិ ច តិណានិ ខាទេយ្យំ អបីតបុព្វានិ ច បានីយានិ បិវេយ្យន្តិ ។ សា បុរិមំ បាទំ សុប្បតិដ្ឋិតំ បតិដ្ឋាបេត្វា បច្ឆិមំ បាទំ ឧទ្ធរេយ្យ សា អគតបុព្វញ្ចេវ ទិសំ គច្ឆេយ្យ អខាទិតបុព្វានិ ច តិណានិ ខាទេយ្យ អបីតបុព្វានិ ច បានីយានិ បិវេយ្យ យស្មឹបស្សា ទេសេ ឋិតាយ ឯវមស្ស យន្នូនាហំ អគតបុព្វញ្ចេវ ទិសំ គច្ឆេយ្យំ អខាទិតបុព្វានិ ច តិណានិ ខាទេយ្យំ អបីតបុព្វានិ ច បានីយានិ បិវេយ្យន្តិ ។ តញ្ច បទេសំ សោត្ថិនា បច្ចាគច្ឆេយ្យ ។ តំ កិស្ស ហេតុ ។ តថា ហិ សា ភិក្ខវេ គាវី បព្វតេយ្យា បណ្ឌិតា ព្យត្តា ខេត្តញ្ញូ កុសលា វិសមេ បព្វតេ ចរិតុំ ។

ម្នាលភិក្ខុទាំងឡាយ ដូចមេគោ ត្រាច់ទៅលើភ្នំ ជាសត្វមានបញ្ញា ឈ្លាសវៃ ស្គាល់នូវខេត្ត ប្រសប់ ត្រាច់ទៅលើភ្នំ ដែលមិនស្មើ មេគោនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា បើដូច្នោះ គួរតែអាត្មាអញទៅកាន់ទិសដែលអញមិនធ្លាប់ទៅផង ទំពាស៊ីនូវស្មៅដែលអញមិនធ្លាប់ទំពាស៊ីផង ផឹកទឹកដែលអញមិនធ្លាប់ផឹកផង ។ មេគោនោះ ឈរជើងមុខឲ្យស៊ប់ល្អហើយ លើកជើងខាងក្រោយឡើង មេគោនោះ ទើបគប្បីទៅកាន់ទិសដែលខ្លួនមិនធ្លាប់ទៅបានផង ទំពាស៊ីនូវស្មៅដែលខ្លួនមិនធ្លាប់ទំពាស៊ីបានផង ផឹកទឹកដែលខ្លួនមិនធ្លាប់ផឹកបានផង កាលបើមេគោនោះ ឈរក្នុងប្រទេសណា មេគោនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា បើដូច្នោះ គួរតែអាត្មាអញ ទៅកាន់ទិសដែលអញមិនធ្លាប់ទៅផង ទំពាស៊ីស្មៅដែលអញមិនធ្លាប់ទំពាស៊ីផង ផឹកទឹកដែលអញមិនធ្លាប់ផឹកផង ។ មេគោនោះ គប្បីត្រឡប់មកកាន់ប្រទេសនោះវិញដោយសួស្តី ។ រឿងនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថា មេគោនោះ ត្រាច់ទៅកាន់ភ្នំ ជាសត្វមានបញ្ញាឈ្លាសវៃ ស្គាល់នូវខេត្ត ប្រសប់ត្រាច់ទៅលើភ្នំដែលមិនស្មើ យ៉ាងណាមិញ ។

ឯវមេវ ខោ ភិក្ខវេ ឥធេកច្ចោ ភិក្ខុ បណ្ឌិតោ ព្យត្តោ ខេត្តញ្ញូ កុសលោ វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ សវិតក្កំ សវិចារំ វិវេកជំ បីតិសុខំ បឋមជ្ឈានំ ឧបសម្បជ្ជ វិហរិតុំ ។ សោ តំ និមិត្តំ អាសេវតិ ភាវេតិ ពហុលីករោតិ ស្វាធិដ្ឋិតំ អធិដ្ឋាតិ តស្ស ឯវំ ហោតិ យន្នូនាហំ វិតក្កវិចារានំ វូបសមា អជ្ឈត្តំ សម្បសាទនំ ចេតសោ ឯកោទិភាវំ អវិតក្កំ អវិចារំ សមាធិជំ បីតិសុខំ ទុតិយជ្ឈានំ ឧបសម្បជ្ជ វិហរេយ្យន្តិ ។ សោ ទុតិយជ្ឈានំ អនភិហិសមានោ[១] វិតក្កវិចារានំ វូបសមា ។ បេ ។ ទុតិយជ្ឈានំ ឧបសម្បជ្ជ វិហរតិ ។ សោ តំ និមិត្តំ អាសេវតិ ភាវេតិ ពហុលីករោតិ ស្វាធិដ្ឋិតំ អធិដ្ឋាតិ តស្ស ឯវំ ហោតិ យន្នូនាហំ បីតិយា ច វិរាគា ឧបេក្ខកោ ច វិហរេយ្យំ សតោ ច សម្បជានោ សុខញ្ច កាយេន បដិសំវេទេយ្យំ យន្តំ អរិយា អាចិក្ខន្តិ

---

១. ឱ. ម. អនភិហិង្យមានោ ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុខ្លះ ក្នុងសាសនានេះ ជាអ្នកមានបញ្ញាឈ្លាសវៃ ស្គាល់នូវខេត្ត ជាអ្នកប្រសប់ ក្នុងការស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ហើយបានដល់បឋមជ្ឈាន ប្រកបដោយវិតក្កៈនិងវិចារៈ មានតែបីតិនិងសុខៈ ដែលកើតអំពីសេចក្តីស្ងាត់ ក៏យ៉ាង នោះដែរ ។ ភិក្ខុនោះខំសេព ខំចម្រើន ខំធ្វើឲ្យរឿយៗ នូវនិមិត្ត នោះ បានតាំងទុកនូវនិមិត្តដែលខ្លួនតាំងទុកល្អហើយ ភិក្ខុនោះ មាន សេចក្តីត្រិះរិះយ៉ាងនេះថា បើដូច្នោះ គួរតែអាត្មាអញ រម្ងាប់វិតក្កៈនិង វិចារៈហើយដល់នូវទុតិយជ្ឈាន ជាធម្មជាតកើតមាន ក្នុងសន្តាននៃខ្លួន ប្រកបដោយសេចក្តីជ្រះថ្លាគឺសទ្ធា មានសភាពជាចិត្តខ្ពស់ឯក មិនមាន វិតក្កៈ មិនមានវិចារៈ មានតែបីតិនិងសុខៈ ដែលកើតអំពីសមាធិ គឺបឋមជ្ឈាន ។ ភិក្ខុនោះ មិនបានសម្រេចទុតិយជ្ឈាន ក៏រម្ងាប់នូវ វិតក្កៈនិងវិចារៈ ។ បេ ។ បានដល់ទុតិយជ្ឈាន ។ ភិក្ខុនោះ ខំសេព ខំចម្រើន ខំធ្វើឲ្យរឿយៗ នូវនិមិត្តនោះ បានតាំងទុកនូវនិមិត្តដែលខ្លួន តាំងទុកល្អហើយ ភិក្ខុនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា បើដូច្នោះ គួរតែអាត្មាអញនឿយណាយចាកបីតិ ជាអ្នកប្រកបដោយឧបេក្ខាផង មានសតិនិងសម្បជញ្ញៈផង សោយនូវសុខ ដោយនាមកាយផង ព្រះ អរិយៈទាំងឡាយ តែងសរសើរបុគ្គលដែលបាននូវតតិយជ្ឈាន នោះថា

ឧបេក្ខកោ សតិមា សុខវិហារីតិ តតិយជ្ឈានំ ឧប-
សម្បជ្ជ វិហរេយ្យន្តិ ។ សោ តតិយជ្ឈានំ អនភិហិ-
សមានោ បីតិយា ច វិរាគា ។ បេ ។ តតិយជ្ឈានំ
ឧសម្បជ្ជ វិហរតិ ។ សោ តំ និមិត្តំ អាសេវតិ
ភាវេតិ ពហុលីករោតិ ស្វាធិដ្ឋិតំ អធិដ្ឋាតិ តស្ស ឯវំ
ហោតិ យន្នូនាហំ សុខស្ស ច បហានា ទុក្ខស្ស ច
បហានា បុព្វេវ សោមនស្សទោមនស្សានំ អត្ថង្គមា
អទុក្ខមសុខំ ឧបេក្ខាសតិបារិសុទ្ធឹ ចតុត្ថជ្ឈានំ
ឧបសម្បជ្ជ វិហរេយ្យន្តិ ។ សោ ចតុត្ថជ្ឈានំ
អនភិហិសមានោ សុខស្ស ច បហានា ។ បេ ។
ចតុត្ថជ្ឈានំ ឧបសម្បជ្ជ វិហរតិ ។ សោ តំ និមិត្តំ
អាសេវតិ ភាវេតិ ពហុលីករោតិ ស្វាធិដ្ឋិតំ
អធិដ្ឋាតិ តស្ស ឯវំ ហោតិ យន្នូនាហំ សព្វសោ
រូបសញ្ញានំ សមតិក្កមា បដិឃសញ្ញានំ អត្ថង្គមា
នានត្តសញ្ញានំ អមនសិការា អនន្តោ អាកាសោតិ
អាកាសានញ្ចាយតនំ ឧបសម្បជ្ជ វិហរេយ្យន្តិ ។

បុគ្គលប្រកបដោយឧបេក្ខា មានស្មារតី មានធម៌ជាគ្រឿងនៅជាសុខដូច្នេះ ព្រោះតតិយជ្ឈានណា ក៏គួរដល់នូវតតិយជ្ឈាននោះ ។ ភិក្ខុនោះ មិនបានសម្រេចនូវតតិយជ្ឈាន ព្រោះនឿយណាយចាកបីតិ ។ បេ ។ បានដល់នូវតតិយជ្ឈាន ។ ភិក្ខុនោះ ខំសេព ខំចម្រើន ខំធ្វើឲ្យរឿយៗ នូវនិមិត្តនោះ បានតាំងទុកនូវនិមិត្តដែលខ្លួនតាំងទុកល្អហើយ ភិក្ខុនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា បើដូច្នោះ គួរតែអាត្មាអញ លះបង់នូវសុខផង លះបង់នូវទុក្ខផង មានសោមនស្ស និងទោមនស្ស អស់ហើយក្នុងកាលមុនផង ហើយគួរដល់នូវចតុត្ថជ្ឈាន ជាធម្មជាតមានអារម្មណ៍ មិនជាទុក្ខមិនជាសុខ មានតែសតិដ៏បរិសុទ្ធកើតអំពីឧបេក្ខា ។ ភិក្ខុនោះ មិនបានសម្រេចចតុត្ថជ្ឈាន ព្រោះលះបង់នូវសុខផង ។ បេ ។ បានដល់នូវចតុត្ថជ្ឈាន ។ ភិក្ខុនោះ ខំសេព ខំចម្រើន ខំធ្វើឲ្យរឿយៗ នូវនិមិត្តនោះ បានតាំងទុកនូវនិមិត្តដែលខ្លួនតាំងទុកល្អហើយ ភិក្ខុនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា បើដូច្នោះ គួរតែអាត្មាអញកន្លងនូវរូបសញ្ញា ដោយប្រការទាំងពួង អស់ទៅនៃបដិឃសញ្ញាលែងធ្វើទុកក្នុងចិត្ត នូវនានត្តសញ្ញា ហើយគួរដល់អាកាសានញ្ចាយតនជ្ឈាន ដោយធ្វើទុកក្នុងចិត្តថា អាកាសមិនមានទីបំផុតដូច្នេះ ។

សោ អាកាសានញ្ចាយតនំ អនភិហិសមានោ សព្វសោ រូបសញ្ញានំ សមតិក្កមា ។ បេ ។ អាកាសានញ្ចាយតនំ ឧបសម្បជ្ជ វិហរតិ ។ សោ តំ និមិត្តំ អាសេវតិ ភាវេតិ ពហុលីករោតិ ស្វាធិដ្ឋិតំ អធិដ្ឋាតិ តស្ស ឯវំ ហោតិ យន្នូនាហំ សព្វសោ អាកាសានញ្ចាយតនំ សមតិក្កម្ម អនន្តំ វិញ្ញាណន្តិ វិញ្ញាណញ្ចាយតនំ ឧបសម្បជ្ជ វិហរេយ្យន្តិ ។ សោ វិញ្ញាណញ្ចាយតនំ អនភិហិសមានោ សព្វសោ អាកាសានញ្ចាយតនំ សមតិក្កម្ម អនន្តំ វិញ្ញាណន្តិ វិញ្ញាណញ្ចាយតនំ ឧបសម្បជ្ជ វិហរតិ ។ សោ តំ និមិត្តំ អាសេវតិ ភាវេតិ ពហុលីករោតិ ស្វាធិដ្ឋិតំ អធិដ្ឋាតិ តស្ស ឯវំ ហោតិ យន្នូនាហំ សព្វសោ វិញ្ញាណញ្ចាយតនំ សមតិក្កម្ម នត្ថិ កិញ្ចីតិ អាកិញ្ចញ្ញាយតនំ ឧបសម្បជ្ជ វិហរេយ្យន្តិ ។ សោ អាកិញ្ចញ្ញាយតនំ អនភិហិសមានោ សព្វសោ វិញ្ញាណញ្ចាយតនំ សមតិក្កម្ម

ភិក្ខុនោះ មិនបានសម្រេចអាកាសានញ្ចាយនជ្ឈាន ព្រោះកន្លង នូវរូបសញ្ញា ដោយប្រការទាំងពួង ។ បេ ។ បានដល់អាកាសា-នញ្ចាយតនជ្ឈាន ។ ភិក្ខុនោះ ខំសេព ខំចម្រើន ខំធ្វើឲ្យរឿយៗ នូវនិមិត្តនោះ បានតាំងទុកនូវនិមិត្តដែលខ្លួនតាំងទុកល្អហើយ ភិក្ខុនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា បើដូច្នោះ គួរតែអាត្មាអញ កន្លង នូវអាកាសានញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ហើយដល់ នូវវិញ្ញាណញ្ចាយតនជ្ឈាន ដោយការធ្វើទុកក្នុងចិត្តថា វិញ្ញាណមិនមាន ទីបំផុតដូច្នេះ ។ ភិក្ខុនោះ មិនបានសម្រេចវិញ្ញាណញ្ចាយតនជ្ឈាន ព្រោះកន្លងនូវអាកាសានញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ហើយ បានដល់នូវវិញ្ញាណញ្ចាយតនជ្ឈាន ដោយការធ្វើទុកក្នុងចិត្តថា វិញ្ញាណ មិនមានទីបំផុតដូច្នេះ ។ ភិក្ខុនោះ ខំសេព ខំចម្រើន ខំធ្វើឲ្យ រឿយៗ នូវនិមិត្តនោះ បានតាំងទុកនូវនិមិត្តដែលខ្លួនតាំងទុកល្អហើយ ភិក្ខុនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា បើដូច្នោះ គួរតែអាត្មាអញ កន្លងនូវវិញ្ញាណញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ហើយ ដល់នូវអាកិញ្ចញ្ញាយតនជ្ឈាន ដោយការធ្វើទុកក្នុងចិត្តថា វត្ថុតិចតួច មិនមានដូច្នេះ ។ ភិក្ខុនោះ មិនបានសម្រេចអាកិញ្ចញ្ញាយតន-ជ្ឈាន ហើយកន្លងនូវវិញ្ញាណញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង

នត្ថិ កិញ្ចីតិ អាកិញ្ចញ្ញាយតនំ ឧបសម្បជ្ជ វិហរតិ ។ សោ តំ និមិត្តំ អាសេវតិ ភាវេតិ ពហុលីករោតិ ស្វាធិដ្ឋិតំ អធិដ្ឋាតិ តស្ស ឯវំ ហោតិ យន្នូនាហំ សព្វសោ អាកិញ្ចញ្ញាយតនំ សមតិក្កម្ម នេវសញ្ញានាសញ្ញាយតនំ ឧបសម្បជ្ជ វិហរេយ្យន្តិ ។ សោ នេវសញ្ញានាសញ្ញាយតនំ អនភិហិសមានោ សព្វសោ អាកិញ្ចញ្ញាយតនំ សមតិក្កម្ម នេវសញ្ញានាសញ្ញាយតនំ ឧបសម្បជ្ជ វិហរតិ ។ សោ តំ និមិត្តំ អាសេវតិ ភាវេតិ ពហុលីករោតិ ស្វាធិដ្ឋិតំ អធិដ្ឋាតិ តស្ស ឯវំ ហោតិ យន្នូនាហំ សព្វសោ នេវសញ្ញានាសញ្ញាយតនំ សមតិក្កម្ម សញ្ញាវេទយិតនិរោធំ ឧបសម្បជ្ជ វិហរេយ្យន្តិ ។ សោ សញ្ញាវេទយិតនិរោធំ អនភិហិសមានោ សព្វសោ នេវសញ្ញានាសញ្ញាយតនំ សមតិក្កម្ម សញ្ញាវេទយិតនិរោធំ ឧបសម្បជ្ជ វិហរតិ ។ យតោ ខោ ភិក្ខវេ ភិក្ខុ តំ តទេវ សមាបត្តឹ សមាបជ្ជតិបិ វុដ្ឋាតិបិ តស្ស មុទុ ចិត្តំ ហោតិ

ហើយបានដល់នូវអាកិញ្ចញ្ញាយតនជ្ឈាន ដោយការធ្វើទុកក្នុងចិត្តថា វត្ថុតិចតួចមិនមានដូច្នេះ ។ ភិក្ខុនោះ ខំសេព ខំចម្រើន ខំធ្វើឲ្យរឿយៗ នូវនិមិត្តនោះ បានតាំងទុកនូវនិមិត្ត ដែលខ្លួនតាំងទុកល្អហើយ ភិក្ខុនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា បើដូច្នេះ គួរតែអាត្មាអញកន្លងនូវអាកិញ្ចញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង ហើយដល់នូវនេវសញ្ញានាសញ្ញាយតនជ្ឈាន ។ ភិក្ខុនោះ មិនបានសម្រេចនូវនេវសញ្ញានាសញ្ញាយតនជ្ឈាន ហើយកន្លងនូវអាកិញ្ចញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង ហើយដល់នូវនេវសញ្ញានាសញ្ញាយតនជ្ឈាន ។ ភិក្ខុនោះ ខំសេព ខំចម្រើន ខំធ្វើឲ្យរឿយៗ នូវនិមិត្តនោះ បានតាំងទុកនូវនិមិត្តដែលខ្លួនតាំងទុកល្អហើយ ភិក្ខុនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា បើដូច្នោះ គួរតែអាត្មាអញ កន្លងនូវនេវសញ្ញានាសញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង ហើយដល់នូវសញ្ញាវេទយិតនិរោធ ។ ភិក្ខុនោះ មិនបានសម្រេចសញ្ញាវេទយិតនិរោធ ក៏កន្លងនូវនេវសញ្ញានាសញ្ញា-យតនជ្ឈាន ដោយប្រការទាំងពួង ហើយដល់នូវសញ្ញាវេទយិត-និរោធ ។ ម្នាលភិក្ខុទាំងឡាយ កាលណាបើភិក្ខុ ចូលកាន់សមាបត្តិនោះៗ ក្តី ចេញចាកសមាបត្តិនោះ ៗ ក្តី ចិត្តរបស់ភិក្ខុនោះ ក៏ទន់

១៣៩



កម្មញ្ញំ មុទុនា ចិត្តេន កម្មញ្ញេន អប្បមាណោ សមាធិ ហោតិ សុភាវិតោ សោ អប្បមាណេន សមាធិនា សុភាវិតេន យំយស្សេវ[1] អភិញ្ញា សច្ឆិករណីយស្ស ធម្មស្ស ចិត្តំ អភិនិន្នាមេតិ អភិញ្ញា សច្ឆិកិរិយាយ តត្រ តត្រេវ សក្ខិភព្វតំ បាបុណាតិ សតិ សតិអាយតនេ ។ សោ សចេ អាកង្ខតិ អនេកវិហិតំ ឥទ្ធិវិធំ បច្ចនុភវេយ្យំ ឯកោបិ ហុត្វា ពហុធា អស្សំ ពហុធាបិ ហុត្វា ឯកោ អស្សំ ។ បេ ។ យាវ ព្រហ្មលោកាបិ កាយេន វសំ វត្តេយ្យន្តិ តត្រ តត្រេវ សក្ខិភព្វតំ បាបុណាតិ សតិ សតិអាយតនេ ។ សោ សចេ អាកង្ខតិ ទិព្វាយ សោតធាតុយា ។ បេ ។ សតិ សតិអាយតនេ ។ សោ សចេ អាកង្ខតិ បរសត្តានំ បរបុគ្គលានំ ចេតសា ចេតោ បរិច្ច បជានេយ្យំ សរាគំ វា ចិត្តំ សរាគំ ចិត្តន្តិ បជានេយ្យំ វីតរាគំ វា ចិត្តំ វីតរាគំ ចិត្តន្តិ បជានេយ្យំ សទោសំ វា ចិត្តំ

១. ឱ. ម. យស្ស យស្ស ។

គួរដល់ការនោកម្ម សមាធិដែលមានប្រមាណមិនបាន ដោយចិត្ត ក៏ទន់គួរដល់ការនោកម្ម ឈ្មោះថា ភិក្ខុនោះ បានចម្រើនហើយ ដោយប្រពៃ ភិក្ខុនោះ ក៏បង្អោនចិត្តទៅចំពោះធម៌ណា ដែលគប្បីធ្វើឲ្យជាក់ច្បាស់ ដោយបញ្ញាដ៏ឧត្តម ដោយសមាធិដែលមានប្រមាណមិនបាន ដែលខ្លួនបានចម្រើន ដោយប្រពៃ ដើម្បីធ្វើឲ្យជាក់ច្បាស់ ដោយបញ្ញាដ៏ឧត្តម កាលបើហេតុមានហើយ ភិក្ខុនោះ ក៏ដល់នូវភាវៈដែលគួរជាក់ច្បាស់ក្នុងធម៌នោះៗ បាន ។ បើភិក្ខុនោះ ប្រាថ្នាថា អាត្មាអញគប្បីសម្តែងនូវការតាក់តែងឫទ្ធិបានច្រើនប្រការគឺ អាត្មាអញតែម្នាក់ ធ្វើឲ្យទៅជាច្រើននាក់ក៏បាន ឬអាត្មាអញច្រើននាក់ ធ្វើឲ្យទៅជាម្នាក់វិញក៏បាន ។ បេ ។ អាត្មាអញធ្វើអំណាចឲ្យប្រព្រឹត្តទៅ ដោយកាយដរាបដល់ព្រហ្មលោកក៏បាន កាលបើហេតុមានហើយ ភិក្ខុនោះ ក៏ដល់នូវភាវៈដែលគួរជាក់ច្បាស់ក្នុងធម៌នោះៗ ។ បើភិក្ខុនោះ ប្រាថ្នា ដោយសោតធាតុជាទិព្វ ។ បេ ។ កាលបើហេតុមានហើយ ។ បើភិក្ខុនោះ ប្រាថ្នាថា អាត្មាអញគប្បីកំណត់ដឹងចិត្ត របស់សត្វដទៃ របស់បុគ្គលដទៃ ដោយចិត្តរបស់ខ្លួន គឺចិត្តដែលប្រកបដោយរាគៈក្តី អាត្មាអញ ក៏ស្គាល់ថា ចិត្តប្រកបដោយរាគៈ ចិត្តដែលប្រាសចាករាគៈក្តី ក៏ស្គាល់ថា ចិត្តប្រាសចាករាគៈ ចិត្តដែលប្រកបដោយទោសៈក្តី

សទោសំ ចិត្តន្តិ បជានេយ្យំ វីតទោសំ វា ចិត្តំ វីតទោសំ ចិត្តន្តិ បជានេយ្យំ សមោហំ វា ចិត្តំ សមោហំ ចិត្តន្តិ បជានេយ្យំ វីតមោហំ វា ចិត្តំ វីតមោហំ ចិត្តន្តិ បជានេយ្យំ សំខិត្តំ វា ចិត្តំ វិក្ខិត្តំ វា ចិត្តំ មហគ្គតំ វា ចិត្តំ អមហគ្គតំ វា ចិត្តំ សឧត្តរំ វា ចិត្តំ អនុត្តរំ វា ចិត្តំ អស-មាហិតំ វា ចិត្តំ សមាហិតំ វា ចិត្តំ វិមុត្តំ វា ចិត្តំ អវិមុត្តំ វា ចិត្តំ អវិមុត្តំ ចិត្តន្តិ បជានេយ្យន្តិ តត្រ តត្រេវ សក្ខិភព្វតំ បាបុណាតិ សតិ សតិអា-យតនេ ។ សោ សចេ អាកង្ខតិ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរេយ្យំ សេយ្យថីទំ ឯកម្បិ ជាតឹ ទ្វេបិ ជាតិយោ ។ បេ ។ ឥតិ សាការំ សឧទ្ទេសំ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរេយ្យន្តិ តត្រ តត្រេវ សក្ខិភព្វតំ បាបុណាតិ សតិ សតិអា-យតនេ ។ សោ សចេ អាកង្ខតិ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន ។ បេ ។

ក៏ស្គាល់ថា ចិត្តប្រកបដោយទោសៈ ចិត្តដែលប្រាសចាកទោសៈក្តី ក៏ស្គាល់ថា ចិត្តប្រាសចាកទោសៈ ចិត្តដែលប្រកបដោយមោហៈក្តី ក៏ស្គាល់ថា ចិត្តប្រកបដោយមោហៈ ចិត្តដែលប្រាសចាកមោហៈក្តី ក៏ស្គាល់ថា ចិត្តប្រាសចាកមោហៈ ចិត្តដែលរួញរាក្តី ចិត្តដែលរាយមាយក្តី ចិត្តដែលជាមហគ្គតៈ គឺរូបាវចរនិងអរូបាវចរក្តី ចិត្តដែលមិនមែនជាមហគ្គតៈ ចិត្តដែលជាឧត្តរៈ គឺចិត្តដែលមានចិត្តដទៃក្រៃលែងជាងក្តី ចិត្តដែលជាអនុត្តរៈ គឺចិត្តដែលមិនមានចិត្តដទៃក្រៃលែងជាងក្តី ចិត្តដែលមិនតាំងមាំក្តី ចិត្តដែលតាំងមាំក្តី ចិត្តដែលផុតស្រឡះក្តី ចិត្តដែលមិនផុតស្រឡះក្តី ក៏ស្គាល់ថា ចិត្តមិនទាន់ផុតស្រឡះ កាលបើហេតុមានហើយ ភិក្ខុនោះ ក៏ដល់នូវភាវៈដែលគួរជាក់ច្បាស់ក្នុងធម៌នោះៗ ។ បើភិក្ខុនោះ ប្រាថ្នាថា អាត្មាអញគប្បីរលឹកឃើញនូវបុព្វេនិវាស មានប្រការដ៏ច្រើន គឺរលឹកឃើញ ១ ជាតិខ្លះ ២ ជាតិខ្លះ ។ បេ ។ អាត្មាអញគប្បីរលឹកឃើញនូវបុព្វេនិវាស មានប្រការដ៏ច្រើន ព្រមទាំងអាការ ព្រមទាំងឧទ្ទេសដោយប្រការដូច្នេះ កាលបើហេតុមានហើយ ភិក្ខុនោះ ក៏ដល់នូវភាវៈដែលគួរជាក់ច្បាស់ក្នុងធម៌នោះៗ ។ បើភិក្ខុនោះ ប្រាថ្នាថា អាត្មាអញមានចក្ខុជាទិព្យដ៏បរិសុទ្ធ កន្លងបង់នូវចក្ខុរបស់មនុស្សធម្មតា ។ បេ ។

យថាកម្មុបគេ សត្តេ បជានេយ្យន្តិ តត្រ តត្រេវ សក្ខិភព្វតំ បាបុណាតិ សតិ សតិអាយតនេ ។ សោ សចេ អាកង្ខតិ អាសវានំ ខយា ។ បេ ។ សច្ឆិកត្វា ឧបសម្បជ្ជ វិហរេយ្យន្តិ តត្រ តត្រេវ សក្ខិភព្វតំ បាបុណាតិ សតិ សតិអាយតនេតិ ។

[៣៦] បឋមម្បាហំ[១] ភិក្ខវេ ឈានំ និស្សាយ អាសវានំ ខយំ វទាមិ ទុតិយម្បាហំ[១] ភិក្ខវេ ឈានំ និស្សាយ អាសវានំ ខយំ វទាមិ តតិយម្បាហំ ភិក្ខវេ ឈានំ និស្សាយ អាសវានំ ខយំ វទាមិ ចតុត្ថម្បាហំ ភិក្ខវេ ឈានំ និស្សាយ អាសវានំ ខយំ វទាមិ អាកាសានញ្ចាយតនម្បាហំ ភិក្ខវេ និស្សាយ អាសវានំ ខយំ វទាមិ ។ បេ ។ នេវសញ្ញានា-សញ្ញាយតនម្បាហំ ភិក្ខវេ និស្សាយ អាសវានំ ខយំ វទាមិ ។

បឋមម្បាហំ ភិក្ខវេ ឈានំ និស្សាយ អាសវានំ ខយំ វទាមីតិ ឥតិ ខោ បនេតំ វុត្តំ កិញ្ចេតំ បដិច្ច វុត្តំ ។

១. ឱ. បឋមម្បហំ ទុតិយម្បហំ ។ បេ ។

អាត្មាអញក៏ដឹងច្បាស់នូវពួកសត្វ ដែលអន្ទោលទៅតាមកម្ម (របស់ខ្លួន) កាលបើហេតុមានហើយ ភិក្ខុនោះ ក៏ដល់នូវភាវៈដែលគួរជាក់ច្បាស់ក្នុងធម៌នោះៗ ។ បើភិក្ខុនោះ ប្រាថ្នាថា អាត្មាអញគប្បីធ្វើឲ្យជាក់ច្បាស់បានដល់ ។ បេ ។ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ កាលបើហេតុមានហើយ ភិក្ខុនោះ ក៏ដល់នូវភាវៈដែលគួរជាក់ច្បាស់ក្នុងធម៌នោះៗ ។

[៣៦] ម្នាលភិក្ខុទាំងឡាយ តថាគត ពោលនូវការអស់ទៅនៃអាសវៈ ព្រោះអាស្រ័យបឋមជ្ឈានខ្លះ ម្នាលភិក្ខុទាំងឡាយ តថាគត ពោលនូវការអស់ទៅនៃអាសវៈ ព្រោះអាស្រ័យទុតិយជ្ឈានខ្លះ ម្នាលភិក្ខុទាំងឡាយ តថាគត ពោលនូវការអស់ទៅនៃអាសវៈ ព្រោះអាស្រ័យតតិយជ្ឈានខ្លះ ម្នាលភិក្ខុទាំងឡាយ តថាគត ពោលនូវការអស់ទៅនៃអាសវៈ ព្រោះអាស្រ័យចតុត្ថជ្ឈានខ្លះ ម្នាលភិក្ខុទាំងឡាយ តថាគត ពោលនូវការអស់ទៅនៃអាសវៈ ព្រោះអាស្រ័យអាកាសានញ្ចាយតនជ្ឈានខ្លះ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ តថាគត ពោលនូវការអស់ទៅនៃអាសវៈ ព្រោះអាស្រ័យនេវសញ្ញានាសញ្ញាយតនជ្ឈានខ្លះ ។

ម្នាលភិក្ខុទាំងឡាយ តថាគត ពោលនូវការអស់ទៅនៃអាសវៈ ព្រោះអាស្រ័យបឋមជ្ឈាន ព្រោះហេតុនោះ ពាក្យដែលតថាគតពោលហើយនុ៎ះ ពាក្យនុ៎ះតថាគត ពោលព្រោះអាស្រ័យសេចក្ដីដូចម្ដេច ។

៩៨ ភិក្ខវេ ភិក្ខុ វិវិច្ចេវ កាមេហិ ។ បេ ។ បឋមជ្ឈានំ ឧបសម្បជ្ជ វិហរតិ ។ សោ យទេវ តត្ថ ហោតិ រូបគតំ វេទនាគតំ សញ្ញាគតំ សង្ខារគតំ វិញ្ញាណគតំ តេ ធម្មេ អនិច្ចតោ ទុក្ខតោ រោគតោ គណ្ឌតោ សល្លតោ អឃតោ អាពាធតោ បរតោ បលោកតោ សុញ្ញតោ អនត្តតោ សមនុបស្សតិ ។ សោ តេហិ ធម្មេហិ ចិត្តំ បតិដ្ឋាបេតិ[១] សោ តេហិ ធម្មេហិ ចិត្តំ បតិដ្ឋាបេត្វា[២] អមតាយ ធាតុយា ចិត្តំ ឧបសំហរតិ ឯតំ សន្តំ ឯតំ បណីតំ យទិទំ សព្វសង្ខារសមថោ សព្វូបធិប្បដិនិស្សគ្គោ តណ្ហាក្ខយោ វិរាគោ និរោធោ និព្វានន្តិ ។ សោ តត្ថ ឋិតោ អាសវានំ ខយំ បាបុណាតិ នោ ចេ អាសវានំ ខយំ បាបុណាតិ តេនេវ ធម្មរាគេន តាយ ធម្មនន្ទិយា បញ្ចន្នំ ឱរម្ភាគិយានំ សំយោជនានំ បរិក្ខយា ឱបបាតិកោ ហោតិ តត្ថ បរិនិព្វាយី

---

១ ឱ. បដិវាបេតិ ។ ម. បដិបាទេតិ ។ ២. ឱ. បដិវាបេត្វា ។ ម. បដិបាទេត្វា ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ បានដល់បឋមជ្ឈាន ។ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណណាដែលប្រព្រឹត្តទៅ ក្នុងបឋមជ្ឈាននោះ ភិក្ខុនោះ ក៏រមែងពិចារណាឃើញច្បាស់នូវធម៌គឺបញ្ចក្ខន្ធទាំងនោះថាជារបស់មិនទៀង ជាទុក្ខ ជារោគ ជាពក ជាសរ ជាគ្រឿងបៀតបៀន ជាអាពាធ ជារបស់ដទៃ ជារបស់ទ្រុឌទ្រោម ជារបស់សូន្យ ជារបស់អនត្តា ។ ភិក្ខុនោះ ញុំាងចិត្តឲ្យតម្កល់នៅស៊ប់ដោយធម៌ទាំងនោះ លុះភិក្ខុនោះ ញុំាងចិត្តឲ្យតម្កល់នៅស៊ប់ដោយធម៌ទាំងនោះហើយ ក៏ប្រមូលមកនូវចិត្តទុកក្នុងអមតធាតុថា ការរម្ងាប់នូវសង្ខារទាំងពួង ការលះបង់នូវកិលេសទាំងពួង ការអស់ទៅនៃតណ្ហា សេចក្ដីនឿយណាយ សេចក្ដីរលត់តណ្ហា គឺព្រះនិព្វានណា ព្រះនិព្វាននុ៎ះជាទីស្ងប់ ព្រះនិព្វាននុ៎ះជារបស់ប្រសើរ ។ ភិក្ខុនោះ បានឋិតនៅក្នុងវិបស្សនា ដែលមានត្រៃលក្ខណ៍ជាអារម្មណ៍នោះ ហើយរមែងដល់នូវការអស់ទៅនៃអាសវៈទាំងឡាយ បើមិនបានដល់នូវការអស់ទៅនៃអាសវៈទេ ក៏គង់បានទៅកើតជាឱបបាតិកៈកំណើត ព្រោះសេចក្ដីត្រេកអរចំពោះសមថធម៌និងវិបស្សនាធម៌នោះ ព្រោះសេចក្ដីរីករាយ ចំពោះធម៌នោះ ព្រោះអស់ទៅនៃឱរម្ភាគិយសំយោជនៈ ៥ ហើយនឹងបរិនិព្វានក្នុងទីនោះ

អនាវត្តិធម្មោ តស្មា លោកា សេយ្យថាបិ ភិក្ខវេ ឥស្សាសោ វា ឥស្សាសន្តេវាសី វា តិណបុរិសរូបកេ[១] វា មត្តិកាបុញ្ជេ វា យោគំ ករិត្វា សោ អបរេន សមយេន ទូរេបាតី ច ហោតិ អក្ខណវេធី ច មហតោ ច កាយស្ស បទាលិតា ឯវមេវ ខោ ភិក្ខវេ ភិក្ខុ វិវិច្ចេវ កាមេហិ ។ បេ ។ បឋមជ្ឈានំ ឧបសម្បជ្ជ វិហរតិ ។ សោ យទេវ តត្ថ ហោតិ រូបគតំ វេទនាគតំ សញ្ញាគតំ សង្ខារគតំ វិញ្ញាណគតំ តេ ធម្មេ អនិច្ចតោ ទុក្ខតោ រោគតោ គណ្ឌតោ សល្លតោ អឃតោ អាពាធតោ បរតោ បលោកតោ សុញ្ញតោ អនត្តតោ សមនុបស្សតិ ។ សោ តេហិ ធម្មេហិ ចិត្តំ បតិដ្ឋាបេតិ សោ តេហិ ធម្មេហិ ចិត្តំ បតិដ្ឋាបេត្វា អមតាយ ធាតុយា ចិត្តំ ឧបសំហរតិ ឯតំ សន្តំ ឯតំ បណីតំ យទិទំ សព្វសង្ខារសមថោ សព្វូបធិប្បដិនិស្សគ្គោ តណ្ហាក្ខយោ វិរាគោ និរោធោ និព្វានន្តិ ។ សោ តត្ថ ឋិតោ

---
១. ឱ តិណបុរិសកេ វា ។

មិនត្រឡប់អំពីលោកនោះមកវិញឡើយ ម្នាលភិក្ខុទាំងឡាយ ដូចខ្មាន់ធ្នូក្តី កូនសិស្សរបស់ខ្មាន់ធ្នូក្តី ធ្វើនូវការប្រកបក្នុងរូបភាព បុរសជាវិការនៃស្មៅក្តី ក្នុងដុំដីស្អិតក្តី សម័យខាងក្រោយមក ខ្មាន់ធ្នូនោះ បាញ់បានឆ្ងាយផង បាញ់ត្រង់ផង អាចទម្លាយនូវកាយដ៏ធំផង យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ បានដល់បឋមជ្ឈាន ក៏យ៉ាងនោះដែរ ។ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណណា ដែលប្រព្រឹត្តទៅ ក្នុងបឋមជ្ឈាននោះ ភិក្ខុនោះ រមែងពិចារណាឃើញច្បាស់នូវធម៌ គឺបញ្ចក្ខន្ធទាំងនោះថា ជារបស់មិនទៀង ជាទុក្ខជារោគ ជាពក ជាសរ ជាគ្រឿងបៀតបៀន ជាអាពាធ ជារបស់ដទៃជារបស់ទ្រុឌទ្រោម ជារបស់សូន្យ ជារបស់អនត្តា ។ ភិក្ខុនោះ ញុំាងចិត្តឲ្យតម្កល់នៅស៊ប់ដោយធម៌ទាំងឡាយនោះ លុះភិក្ខុនោះ ញុំាងចិត្តឲ្យតម្កល់នៅស៊ប់ដោយធម៌ទាំងនោះហើយ ក៏ប្រមូលមកនូវចិត្ត ទុកក្នុងអមតធាតុថា ការរម្ងាប់បង់នូវសង្ខារទាំងពួង លះបង់នូវកិលេសទាំងពួង ការអស់ទៅនៃតណ្ហា សេចក្តីនឿយណាយ សេចក្តីរលត់តណ្ហា គឺព្រះនិព្វានណា ព្រះនិព្វាននុ៎ះជាទីស្ងប់ ព្រះនិព្វាននុ៎ះជារបស់ប្រសើរ ។ ភិក្ខុនោះ បានឋិតនៅក្នុងវិបស្សនា ដែលមានត្រៃលក្ខណ៍ជាអារម្មណ៍នោះ ហើយ

អាសវានំ ខយំ បាបុណាតិ នោ ច អាសវានំ ខយំ បាបុណាតិ តេនេវ ធម្មរាគេន តាយ ធម្មនន្ទិយា បញ្ចន្នំ ឱរម្ភាគិយានំ សំយោជនានំ បរិក្ខយា ឱបបាតិកោ ហោតិ តត្ថ បរិនិព្វាយី អនាវត្តិធម្មោ តស្មា លោកា ។ បឋមម្បាហំ ភិក្ខវេ ឈានំ និស្សាយ អាសវានំ ខយំ វទាមីតិ ឥតិ យន្តំ វុត្តំ ឥទមេតំ បដិច្ច វុត្តំ ។

ទុតិយម្បាហំ ភិក្ខវេ ឈានំ និស្សាយ ។ បេ ។ តតិយម្បាហំ ភិក្ខវេ ឈានំ និស្សាយ ។ បេ ។ ចតុត្ថម្បាហំ ភិក្ខវេ ឈានំ និស្សាយ អាសវានំ ខយំ វទាមីតិ ឥតិ ខោ បនេតំ វុត្តំ កិញ្ចេតំ បដិច្ច វុត្តំ ។ ឥធ ភិក្ខវេ ភិក្ខុ សុខស្ស ច បហានា ទុក្ខស្ស ច បហានា បុព្វេវ សោមនស្សទោមនស្សានំ អត្ថង្គមា អទុក្ខមសុខំ ឧបេក្ខាសតិបារិសុទ្ធឹ ចតុត្ថជ្ឈានំ ឧបសម្បជ្ជ វិហរតិ ។

រមែងដល់នូវការអស់ទៅនៃអាសវៈទាំងឡាយ បើមិនបានដល់នូវការអស់ទៅនៃអាសវៈទេ ក៏គង់បានទៅកើតជាឱបបាតិកៈកំណើត ព្រោះសេចក្តីត្រេកអរ ចំពោះធម៌នោះ ព្រោះសេចក្តីរីករាយ ចំពោះធម៌នោះ ព្រោះអស់ទៅនៃឱរម្ភាគិយសំយោជនៈ ៥ ហើយនឹងបរិនិព្វានក្នុងទីនោះ មិនត្រឡប់អំពីលោកនោះមកវិញឡើយ ។ ម្នាលភិក្ខុទាំងឡាយ ពាក្យណាដែលតថាគតពោលថា តថាគត ពោលនូវការអស់ទៅនៃអាសវៈ ព្រោះអាស្រ័យបឋមជ្ឈាន ពាក្យនុ៎ះតថាគត ពោលហើយ ព្រោះអាស្រ័យនូវហេតុនេះ ។ ម្នាលភិក្ខុទាំងឡាយ តថាគត ព្រោះអាស្រ័យនូវទុតិយជ្ឈាន ។ បេ ។ ម្នាលភិក្ខុទាំងឡាយ តថាគត ព្រោះអាស្រ័យនូវតតិយជ្ឈាន ។ បេ ។ ម្នាលភិក្ខុទាំងឡាយ តថាគត ពោលនូវការអស់ទៅនៃអាសវៈ ព្រោះអាស្រ័យនូវចតុត្ថជ្ឈាន ព្រោះហេតុនោះ ពាក្យដែលតថាគត ពោលហើយនុ៎ះ ពាក្យនុ៎ះ តថាគតពោល ព្រោះអាស្រ័យនូវហេតុដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ព្រោះលះបង់នូវសុខផង លះបង់នូវទុក្ខផង មានសោមនស្សនិងទោមនស្សអស់ទៅ ក្នុងកាលមុន ហើយដល់នូវចតុត្ថជ្ឈាន ដែលជាធម្មជាត មានអារម្មណ៍ មិនមែនជាទុក្ខ មិនមែនជាសុខគឺជាឧបេក្ខា មានសតិដ៏បរិសុទ្ធ ដោយឧបេក្ខា ។

សោ យទេវ តត្ថ ហោតិ រូបគតំ វេទនាគតំ សញ្ញា-
គតំ សង្ខារគតំ វិញ្ញាណគតំ តេ ធម្មេ អនិច្ចតោ
ទុក្ខតោ រោគតោ គណ្ឌតោ សល្លតោ អឃតោ
អាពាធតោ បរតោ បលោកតោ សុញ្ញតោ អនត្តតោ
សមនុបស្សតិ ។ សោ តេហិ ធម្មេហិ ចិត្តំ បតិដ្ឋា-
បេតិ សោ តេហិ ធម្មេហិ ចិត្តំ បតិដ្ឋាបេត្វា
អមតាយ ធាតុយា ចិត្តំ ឧបសំហរតិ ឯតំ សន្តំ
ឯតំ បណីតំ យទិទំ សព្វសង្ខារសមថោ សព្វូប-
ធិប្បដិនិស្សគ្គោ តណ្ហាក្ខយោ វិរាគោ និរោធោ
និព្វានន្តិ ។ សោ តត្ថ ឋិតោ អាសវានំ ខយំ
បាបុណាតិ នោ ចេ អាសវានំ ខយំ បាបុណាតិ
តេនេវ ធម្មរាគេន តាយ ធម្មនន្ទិយា បញ្ចន្នំ
ឱរម្ភាគិយានំ សំយោជនានំ បរិក្ខយា ឱបបាតិកោ
ហោតិ តត្ថ បរិនិព្វាយី អនាវត្តិធម្មោ តស្មា
លោកា ។ សេយ្យថាបិ ភិក្ខវេ ឥស្សាសោ វា

រូប វេទនា សញ្ញា សង្ខារ វិញ្ញាណណា ដែលប្រព្រឹត្តទៅក្នុងចតុត្ថជ្ឈាននោះ ភិក្ខុនោះ រមែងពិចារណាឃើញច្បាស់នូវធម៌ គឺបញ្ចក្ខន្ធទាំងនោះថា ជារបស់មិនទៀង ជាទុក្ខ ជារោគ ជាពក ជាសរ ជាគ្រឿងបៀតបៀន ជាអាពាធ ជារបស់ដទៃ ជារបស់ទ្រុឌទ្រោម ជារបស់សូន្យ ជារបស់អនត្តា ។ ភិក្ខុនោះ ញុំាងចិត្តឲ្យតម្កល់នៅស៊ប់ដោយធម៌ទាំងនោះ លុះភិក្ខុនោះ ញុំាងចិត្តឲ្យតម្កល់នៅស៊ប់ ដោយធម៌ទាំងនោះហើយ ក៏ប្រមូលមកនូវចិត្តទុកក្នុងអមតធាតុថា ការរម្ងាប់បង់នូវសង្ខារទាំងពួង ការលះបង់នូវកិលេសទាំងពួង ការអស់ទៅនៃតណ្ហា សេចក្តីនឿយណាយ សេចក្តីរលត់តណ្ហាគឺព្រះនិព្វានណា ព្រះនិព្វាននុ៎ះជាទីស្ងប់ ព្រះនិព្វាននុ៎ះ ជារបស់ប្រសើរ ។ ភិក្ខុនោះ បានឋិតនៅក្នុងវិបស្សនា ដែលមានត្រៃលក្ខណ៍ ជាអារម្មណ៍នោះហើយ រមែងដល់នូវការអស់ទៅនៃអាសវៈទាំងឡាយ បើមិនបានដល់នូវការអស់ទៅនៃអាសវៈទេ ក៏គង់បានទៅកើតជាឱបបាតិកៈកំណើត ព្រោះសេចក្តីត្រេកអរចំពោះធម៌នោះ ព្រោះសេចក្តីរីករាយចំពោះធម៌នោះ ព្រោះអស់ទៅនៃឱរម្ភាគិយសំយោជនៈ ៥ ហើយនឹងបរិនិព្វានក្នុងទីនោះ មិនត្រឡប់អំពីលោកនោះមកវិញឡើយ ។ ម្នាលភិក្ខុទាំងឡាយ ដូចនាយខ្មាន់ធ្នូក្តី

ឥស្សាសន្តេវាសី វា តិណបុរិសរូបកេ វា មត្តិកាបុញ្ជេ វា យោគំ ករិត្វា សោ អបរេន សមយេន ទូរេបាតី ច ហោតិ អក្ខណវេធី ច មហតោ ច កាយស្ស បទាលិតា ឯវមេវ ខោ ភិក្ខវេ ភិក្ខុ សុខស្ស ច បហានា ។ បេ ។ ចតុត្ថជ្ឈានំ ឧបសម្បជ្ជ វិហរតិ ។ សោ យទេវ តត្ថ ហោតិ រូបគតំ វេទនាគតំ ។ បេ ។ អនាវត្តិធម្មោ តស្មា លោកា ។ ចតុត្ថម្បាហំ ភិក្ខវេ ឈានំ និស្សាយ អាសវានំ ខយំ វទាមីតិ ឥតិ យន្តំ វុត្តំ ឥទមេតំ បដិច្ច វុត្តំ ។ អាកាសានញ្ចាយតនម្បាហំ ភិក្ខវេ ឈានំ និស្សាយ អាសវានំ ខយំ វទាមីតិ ឥតិ ខោ បនេតំ វុត្តំ កិញ្ចេតំ បដិច្ច វុត្តំ ។ ឥធ ភិក្ខវេ ភិក្ខុ សព្វសោ រូបសញ្ញានំ សមតិក្កមា បដិឃសញ្ញានំ អត្ថង្គមា នានត្តសញ្ញានំ អមនសិការា អនន្តោ អាកា-សោតិ អាកាសានញ្ចាយតនំ ឧបសម្បជ្ជ វិហរតិ ។

កូនសិស្សរបស់ខ្មាន់ធ្នូក្តី ធ្វើនូវគ្រឿងប្រកបក្នុងរូបភាពបុរស ជាវិការនៃស្មៅក្តី ក្នុងដុំដីស្អិតក្តី លុះសម័យខាងក្រោយមក ខ្មាន់ធ្នូនោះ បាញ់បានឆ្ងាយផង បាញ់ត្រង់ផង អាចទម្លាយនូវកាយដ៏ធំបានផង យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុ ព្រោះលះបង់នូវសុខផង ។ បេ ។ បានដល់ចតុត្ថជ្ឈាន ក៏យ៉ាងនោះដែរ ។ រូប វេទនាណា ដែលប្រព្រឹត្តទៅក្នុងចតុត្ថជ្ឈាននោះ ភិក្ខុនោះ ។ បេ ។ មានសភាពមិនត្រឡប់អំពីលោកនោះមកវិញឡើយ ។ ម្នាលភិក្ខុទាំងឡាយ ពាក្យណាដែលតថាគតពោលហើយថា តថាគត ពោលនូវការអស់ទៅនៃអាសវៈ ព្រោះអាស្រ័យនូវចតុត្ថជ្ឈាន ពាក្យនុ៎ះ តថាគតពោលហើយ ព្រោះអាស្រ័យនូវហេតុនុ៎ះ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវការអស់ទៅនៃអាសវៈ ព្រោះអាស្រ័យនូវអាកាសានញ្ចាយតនជ្ឈាន ព្រោះហេតុនោះពាក្យដែលតថាគតពោលហើយនុ៎ះ ពាក្យនុ៎ះតថាគតពោលហើយ ព្រោះអាស្រ័យនូវហេតុដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ព្រោះកន្លងបង់នូវរូបសញ្ញាដោយប្រការទាំងពួង ព្រោះអស់បដិឃសញ្ញាហើយ លែងធ្វើទុកក្នុងចិត្តនូវនានត្តសញ្ញា ហើយដល់នូវអាកាសា-នញ្ចាយតនជ្ឈាន ដោយការធ្វើទុកក្នុងចិត្តថា អាកាសមិនមានទីបំផុត ។

១៤៧



សោ យទេវ តត្ថ ហោតិ វេទនាគតំ សញ្ញាគតំ សង្ខារគតំ វិញ្ញាណគតំ តេ ធម្មេ អនិច្ចតោ ទុក្ខតោ រោគតោ គណ្ឌតោ សល្លតោ អឃតោ អាពាធតោ បរតោ បលោកតោ សុញ្ញតោ អនត្តតោ សមនុបស្សតិ ។ សោ តេហិ ធម្មេហិ ចិត្តំ បតិដ្ឋាបេតិ សោ តេហិ ធម្មេហិ ចិត្តំ បតិដ្ឋាបេត្វា អមតាយ ធាតុយា ចិត្តំ ឧបសំហរតិ ឯតំ សន្តំ ឯតំ បណីតំ យទិទំ សព្វសង្ខារសមថោ សព្វូបធិប្បដិនិស្សគ្គោ តណ្ហាក្ខយោ វិរាគោ និរោធោ និព្វានន្តិ ។ សោ តត្ថ ឋិតោ អាសវានំ ខយំ បាបុណាតិ នោ ចេ អាសវានំ ខយំ បាបុណាតិ តេនេវ ធម្មរាគេន តាយ ធម្មនន្ទិយា បញ្ចន្នំ ឱរម្ភាគិយានំ សំយោជនានំ បរិក្ខយា ឱបបាតិកោ ហោតិ តត្ថ បរិនិព្វាយី អនាវត្តិធម្មោ តស្មា លោកា ។ សេយ្យថាបិ ភិក្ខវេ ឥស្សាសោ វា ឥស្សាសន្តេវាសី វា តិណបុរិសរូបកេ វា មត្តិកាបុញ្ជេ វា យោគំ ករិត្វា

វេទនា សញ្ញា សង្ខារ វិញ្ញាណណា ដែលប្រព្រឹត្តទៅក្នុងអាកាសានញ្ចាយតនជ្ឈាននោះ ភិក្ខុនោះ ក៏រមែងពិចារណាឃើញនូវធម៌គឺខន្ធទាំងនោះថាជារបស់មិនទៀង ជាទុក្ខ ជារោគ ជាពក ជាសរ ជាសេចក្តីបៀតបៀន ជាអាពាធ ជារបស់ដទៃ ជារបស់ទ្រុឌទ្រោម ជារបស់សូន្យ ជារបស់អនត្តា ។ ភិក្ខុនោះ ញុំាងចិត្តឲ្យតម្កល់នៅស៊ប់ ដោយធម៌ទាំងនោះ លុះភិក្ខុនោះ បានញុំាងចិត្តឲ្យតម្កល់នៅស៊ប់ ដោយធម៌ទាំងនោះហើយ ក៏ប្រមូលចិត្តទៅក្នុងអមតធាតុថា ការរម្ងាប់បង់នូវសង្ខារទាំងពួង លះបង់នូវកិលេសទាំងពួង ការអស់ទៅនៃតណ្ហា សេចក្តីនឿយណាយ សេចក្តីរលត់តណ្ហាគឺព្រះនិព្វានណា ព្រះនិព្វាននុ៎ះ ជាទីស្ងប់ ព្រះនិព្វាននុ៎ះ ជារបស់ប្រសើរ ។ ភិក្ខុនោះ បានឋិតនៅក្នុងវិបស្សនាដែលមានត្រៃលក្ខណ៍ ជាអារម្មណ៍នោះហើយ រមែងដល់នូវការអស់ទៅនៃអាសវៈទាំងឡាយ បើមិនបានដល់នូវការអស់ទៅ នៃអាសវៈទេក៏គង់បានទៅកើតជាឱបបាតិកៈកំណើត ព្រោះសេចក្តីត្រេកអរចំពោះធម៌នោះ ព្រោះសេចក្តីរីករាយចំពោះធម៌នោះ ព្រោះអស់ទៅនៃឱរម្ភាគិយសំយោជនៈ ៥ ហើយ នឹងបរិនិព្វានក្នុងទីនោះ មិនត្រឡប់អំពីលោកនោះមកវិញឡើយ ។ ម្នាលភិក្ខុទាំងឡាយ ដូចខ្មាន់ធ្នូក្តី កូនសិស្សរបស់ខ្មាន់ធ្នូក្តី ធ្វើនូវការប្រកបក្នុងរូបភាពបុរស ជាវិការនៃស្មៅក្តី ក្នុងដុំដីស្អិតក្តី

សោ អបរេន សមយេន ទូរេចាតី ច ហោតិ អក្ខណវេធី ច មហតោ ច កាយស្ស បទាលិតា ឯវមេវ ខោ ភិក្ខវេ ភិក្ខុ សព្វសោ រូបសញ្ញានំ សមតិក្កមា បដិឃសញ្ញានំ អត្ថង្គមា នានត្តសញ្ញានំ អមនសិការា អនន្តោ អាកាសោតិ អាកាសា-នញ្ចាយតនំ ឧបសម្បជ្ជ វិហរតិ ។ សោ យទេវ តត្ថ ហោតិ វេទនាគតំ សញ្ញាគតំ ។ បេ ។ អនាវត្តិធម្មោ តស្មា លោកា ។ អាកាសានញ្ចាយតនម្បាហំ ភិក្ខវេ និស្សាយ អាសវានំ ខយំ វទាមីតិ ឥតិ យន្តំ វុត្តំ ឥទមេតំ បដិច្ច វុត្តំ ។ វិញ្ញាណញ្ចាយ-តនម្បាហំ ភិក្ខវេ និស្សាយ ។ បេ ។ អាកិញ្ចញ្ញាយ-តនម្បាហំ ភិក្ខវេ និស្សាយ អាសវានំ ខយំ វទាមីតិ ឥតិ ខោ បនេតំ វុត្តំ កិញ្ចេតំ បដិច្ច វុត្តំ ។ ឥទ ភិក្ខវេ ភិក្ខុ សព្វសោ វិញ្ញាណញ្ចាយតនំ សមតិក្កម្ម

លុះសម័យខាងក្រោយមក ខ្មាន់ធ្នូនោះបាញ់បានឆ្ងាយផង បាញ់ត្រង់ផង អាចទម្លាយនូវកាយដ៏ធំផង យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុ ព្រោះកន្លងបង់នូវរូបសញ្ញា ដោយប្រការទាំងពួង ព្រោះអស់បដិឃ-សញ្ញាហើយ លែងធ្វើទុកក្នុងចិត្តនូវនានត្តសញ្ញា ហើយដល់នូវអាកា-សានញ្ចាយតនជ្ឈាន ដោយការធ្វើទុកក្នុងចិត្តថា អាកាសមិនមានទីបំផុតដូច្នេះ ។ វេទនា សញ្ញាណា ដែលប្រព្រឹត្តទៅក្នុងអាកាសានញ្ចាយ-តនជ្ឈាននោះ ភិក្ខុនោះ ។ បេ ។ មានសភាពមិនបានត្រឡប់អំពីលោកនោះមកវិញឡើយ ។ ម្នាលភិក្ខុទាំងឡាយ ពាក្យណា ដែលតថាគតពោលថា តថាគតពោលនូវការអស់ទៅនៃអាសវៈ ព្រោះអាស្រ័យនូវអាកាសានញ្ចាយតនជ្ឈាន ពាក្យនេះ តថាគតពោលហើយ ព្រោះអាស្រ័យនូវហេតុនេះ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះអាស្រ័យនូវវិញ្ញាណ-ញ្ចាយតនជ្ឈាន ។ បេ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវការអស់ទៅនៃអាសវៈ ព្រោះអាស្រ័យនូវអាកិញ្ចញ្ញាយតនជ្ឈាន ព្រោះហេតុនោះ ពាក្យដែលតថាគតពោលហើយនុ៎ះ ពាក្យនុ៎ះតថាគតពោលហើយព្រោះអាស្រ័យនូវហេតុដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាស-នានេះ ព្រោះកន្លងបង់នូវវិញ្ញាណញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង

នត្ថិ កិញ្ចីតិ អាកិញ្ចញ្ញាយតនំ ឧបសម្បជ្ជ វិហរតិ ។ សោ យទេវ តត្ថ ហោតិ វេទនាគតំ សញ្ញាគតំ សង្ខារគតំ វិញ្ញាណគតំ តេ ធម្មេ អនិច្ចតោ ទុក្ខតោ រោគតោ គណ្ឌតោ សល្លតោ អឃតោ អាពាធតោ បរតោ បលោកតោ សុញ្ញតោ អនត្តតោ សមនុបស្សតិ ។ សោ តេហិ ធម្មេហិ ចិត្តំ បតិដ្ឋាបេតិ សោ តេហិ ធម្មេហិ ចិត្តំ បតិដ្ឋាបេត្វា អមតាយ ធាតុយា ចិត្តំ ឧបសំហរតិ ឯតំ សន្តំ ឯតំ បណីតំ យទិទំ សព្វសង្ខារសមថោ សព្វូបធិប្បដិ-និស្សគ្គោ តណ្ហាក្ខយោ វិរាគោ និរោធោ និព្វានន្តិ ។ សោ តត្ថ ឋិតោ អាសវានំ ខយំ បាបុណាតិ នោ ចេ អាសវានំ ខយំ បាបុណាតិ តេនេវ ធម្មរាគេន តាយ ធម្មនន្ទិយា បញ្ចន្នំ ឱរម្ភាគិយានំ សញ្ញោ-ជនានំ បរិក្ខយា ឱបបាតិកោ ហោតិ តត្ថ បរិនិព្វាយី អនាវត្តិធម្មោ តស្មា លោកា ។ សេយ្យ-ថាបិ ភិក្ខវេ ឥស្សាសោ វា ឥស្សាសន្តេវាសី វា

ហើយដល់នូវអាកិញ្ចញ្ញាយតនជ្ឈាន ដោយការធ្វើទុកក្នុងចិត្តថា វត្ថុតិចតួច មិនមានដូច្នេះ ។ វេទនា សញ្ញា សង្ខារ វិញ្ញាណណា ដែលប្រព្រឹត្ត ទៅក្នុងអាកិញ្ចញ្ញាយតនជ្ឈាននោះ ភិក្ខុនោះ ក៏រមែងពិចារណាឃើញនូវ ធម៌គឺខន្ធទាំងនោះថាជារបស់មិនទៀង ជាទុក្ខ ជារោគ ជាពក ជាសរ ជាគ្រឿងបៀតបៀន ជាអាពាធ ជារបស់ដទៃ ជារបស់ទ្រុឌទ្រោម ជារបស់សូន្យ ជារបស់អនត្តា ។ ភិក្ខុនោះ ញុំាងចិត្តឲ្យតម្កល់នៅស៊ប់ ដោយធម៌ទាំងនោះ លុះភិក្ខុនោះ ញុំាងចិត្តឲ្យតម្កល់នៅស៊ប់ដោយធម៌ ទាំងនោះហើយ ក៏ប្រមូលចិត្តទៅក្នុងអមតធាតុថា ការរម្ងាប់បង់នូវនូវសង្ខារ ទាំងពួង លះបង់នូវកិលេសទាំងពួង ការអស់ទៅនៃតណ្ហា សេចក្តីនឿយ ណាយ សេចក្តីរលត់តណ្ហាគឺព្រះនិព្វានណា ព្រះនិព្វានទុ៎ះ ជាទីស្ងប់ ព្រះនិព្វានទុ៎ះ ជារបស់ប្រសើរ ។ ភិក្ខុនោះ បានឋិតនៅក្នុងវិបស្សនា ដែលមានត្រៃលក្ខណ៍ជាអារម្មណ៍ ហើយរមែងដល់នូវការអស់ទៅនៃ អាសវៈទាំងឡាយ បើមិនបានដល់នូវការអស់ទៅនៃអាសវៈទេ ក៏គង់ បានទៅកើតជាឱបបាតិកៈកំណើត ព្រោះសេចក្តីត្រេកអរចំពោះធម៌នោះ ព្រោះសេចក្តីរីករាយចំពោះធម៌នោះ ព្រោះអស់ទៅនៃឱរម្ភាគិយសំយោ-ជនៈ ៥ ហើយ នឹងបរិនិព្វានក្នុងទីនោះ មិនត្រឡប់អំពីលោកនោះមកវិញ ឡើយ ។ ម្នាលភិក្ខុទាំងឡាយ ដូចខ្នាន់ធ្នូក្តី កូនសិស្សនៃខ្នាន់ធ្នូក្តី

១៤០



តិណបុរិសរូបកេ វា មត្តិកាបុញ្ជេ វា យោគំ ករិត្វា សោ អបរេន សមយេន ទូរេចាតី ច ហោតិ អក្ខណវេធី ច មហតោ ច កាយស្ស បទាលិតា ឯវមេវ ខោ ភិក្ខវេ ភិក្ខុ សព្វសោ វិញ្ញាណញ្ចា-យតនំ សមតិក្កម្ម នត្ថិ កិញ្ចីតិ អាកិញ្ចញ្ញាយតនំ ឧបសម្បជ្ជ វិហរតិ ។ សោ យទេវ តត្ថ ហោតិ វេទនាគតំ សញ្ញាគតំ សង្ខារគតំ វិញ្ញាណគតំ តេ ធម្មេ អនិច្ចតោ ទុក្ខតោ រោគតោ គណ្ឌតោ សល្លតោ អឃតោ អាពាធតោ បរតោ បលោកតោ សុញ្ញតោ អនត្តតោ សមនុបស្សតិ ។ សោ តេហិ ធម្មេហិ ចិត្តំ បតិដ្ឋាបេតិ សោ តេហិ ធម្មេហិ ចិត្តំ បតិដ្ឋាបេត្វា អមតាយ ធាតុយា ចិត្តំ ឧបសំហរតិ ឯតំ សន្តំ ឯតំ បណីតំ យទិទំ សព្វសង្ខារសមថោ សព្វូបធិប្បដិ-និស្សគ្គោ តណ្ហាក្ខយោ វិរាគោ និរោធោ និព្វានន្តិ ។ សោ តត្ថ ឋិតោ អាសវានំ ខយំ បាបុណាតិ ។

ធ្វើនូវការប្រកបក្នុងរូបភាពបុរស ជាវិការនៃស្មៅក្តី ក្នុងដុំដីស្អិតក្តី លុះសម័យខាងក្រោយមក ខ្មាន់ធ្នូនោះបាញ់បានឆ្ងាយផង បាញ់ត្រង់ផង អាចទម្លាយនូវកាយដ៏ធំផង យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុ ព្រោះកន្លងបង់នូវវិញ្ញាណញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ហើយដល់នូវអាកិញ្ចញ្ញាយតនជ្ឈាន ដោយការធ្វើទុកក្នុងចិត្តថាវត្ថុតិចតួច មិនមានដូច្នេះ យ៉ាងនោះដែរ ។ វេទនា សញ្ញា សង្ខារ វិញ្ញាណ ណា ដែលប្រព្រឹត្តទៅក្នុងអាកិញ្ចញ្ញាយតនជ្ឈាននោះ ភិក្ខុនោះ ក៏រមែងពិចារណាឃើញនូវធម៌គឺខន្ធទាំងនោះថាជារបស់មិនទៀង ជាទុក្ខ ជារោគ ជាពក ជាសរ ជាគ្រឿងបៀតបៀន ជាអាពាធ ជារបស់ដទៃ ជារបស់ទ្រុឌទ្រោម ជារបស់សូន្យ ជារបស់អនត្តា ។ ភិក្ខុនោះ ញុំាងចិត្តឲ្យតម្កល់នៅស៊ប់ដោយធម៌ទាំងនោះ លុះភិក្ខុនោះ ញុំាងចិត្តឲ្យតម្កល់នៅស៊ប់ ដោយធម៌ទាំងនោះហើយ ក៏ប្រមូលចិត្តទៅក្នុងអមតធាតុថា ការរម្ងាប់នូវសង្ខារទាំងពួង ការលះបង់នូវកិលេសទាំងពួង ការអស់ទៅនៃតណ្ហា សេចក្តីនឿយណាយ សេចក្តីរលត់តណ្ហាគឺព្រះនិព្វាន ណា ព្រះនិព្វាននុ៎ះ ជាទីស្ងប់ ព្រះនិព្វាននុ៎ះ ជារបស់ប្រសើរ ។ ភិក្ខុនោះ បានឋិតនៅក្នុងវិបស្សនា ដែលមានត្រៃលក្ខណ៍ ជាអារម្មណ៍នោះហើយ រមែងដល់នូវការអស់ទៅ នៃអាសវៈទាំងឡាយ

បណ្ណាសកេ មហាវគ្គោ

នោ ចេ អាសវានំ ខយំ បាបុណាតិ តេនេវ ធម្មរាគេន តាយ ធម្មនន្ទិយា បញ្ចន្នំ ឱរម្ភាគិយានំ សំយោជនានំ បរិក្ខយា ឱបបាតិកោ ហោតិ តត្ថ បរិនិព្វាយី អនាវត្តិធម្មោ តស្មា លោកា ។ អាកិញ្ចញ្ញាយតនម្បាហំ ភិក្ខវេ និស្សាយ អាសវានំ ខយំ វទាមីតិ ឥតិ យន្តំ វុត្តំ ឥទមេតំ បដិច្ច វុត្តំ ។ ឥតិ ខោ ភិក្ខវេ យាវតា សញ្ញាសមាបត្តិ តាវតា សញ្ញាបដិវេធោ ។ យានិ ច ខោ ឥមានិ ភិក្ខវេ និស្សាយ ទ្វេ អាយតនានិ នេវសញ្ញានាសញ្ញាយតនសមាបត្តិ ច សញ្ញាវេទយិតនិរោធោ ច ឈាយីហេតេ ភិក្ខវេ ភិក្ខុហិ សមាបត្តិកុសលេហិ សមាបត្តិវុដ្ឋានកុសលេហិ សមាបជ្ជិត្វា វុដ្ឋហិត្វា សម្មទក្ខាតព្វានីតិ វទាមីតិ ។

បើមិនបានដល់នូវការអស់ទៅនៃអាសវៈទេ ក៏គង់បានទៅកើតជាឱបបាតិកៈកំណើត ព្រោះសេចក្ដីត្រេកអរចំពោះធម៌នោះ ព្រោះសេចក្ដីរីករាយចំពោះធម៌នោះ ព្រោះអស់ទៅ នៃឱរម្ភាគិយសំយោជនៈ ៥ ហើយនឹងបរិនិព្វានក្នុងទីនោះ មិនត្រឡប់អំពីលោកនោះមកវិញឡើយ ។ ម្នាលភិក្ខុទាំងឡាយ ពាក្យណា ដែលតថាគតពោលហើយថា តថាគតពោលនូវការអស់ទៅនៃអាសវៈ ព្រោះអាស្រ័យនូវអាកិញ្ចញ្ញាយតនជ្ឈាន ពាក្យនុ៎ះតថាគតពោលហើយ ព្រោះអាស្រ័យនូវហេតុនេះឯង ។ ម្នាលភិក្ខុទាំងឡាយ សញ្ញាសមាបត្តិ មាននៅដរាបណា សញ្ញាបដិវេធៈក៏មាននៅដរាបនោះ ដោយប្រការដូច្នេះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកមានឈាន ព្រោះអាស្រ័យនូវអាយតនៈទាំងពីរណា គឺនេវសញ្ញានាសញ្ញាយតនសមាបត្តិ ១ សញ្ញាវេទយិតនិរោធ ១ ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវអាយតនៈទាំងនុ៎ះថា ភិក្ខុដែលមានឈាន ឈ្លាសវៃក្នុងការចូលកាន់សមាបត្តិ ឈ្លាសវៃក្នុងការចេញចាកសមាបត្តិ គួរពោលថា ចូលចេញដោយប្រពៃ ។

[៣៧] ឯកំ សមយំ អាយស្មា អានន្ទោ កោសម្ពិយំ វិហរតិ ឃោសិតារាមេ ។ តត្រ ខោ អាយស្មា អានន្ទោ ភិក្ខូ អាមន្តេសិ អាវុសោ ភិក្ខវោតិ ។ អាវុសោតិ ខោ តេ ភិក្ខូ អាយស្មតោ អានន្ទស្ស បច្ចស្សោសុំ ។ អាយស្មា អានន្ទោ ឯតទវោច អច្ឆរិយំ អាវុសោ អព្ភុតំ អាវុសោ យាវញ្ចិទំ តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន ឱកាសាធិគមោ អនុពុទ្ធោ សត្តានំ វិសុទ្ធិយា សោកបរិទេវានំ សមតិក្កមាយ ទុក្ខទោមនស្សានំ អត្ថង្គមាយ ញាយស្ស អធិគមាយ និព្វានស្ស សច្ឆិកិរិយាយ តទេវ នាម ចក្ខុំ ភវិស្សតិ តេ រូបា តញ្ចាយតនំ នោ បដិសំវេទិស្សតិ តទេវ នាម សោតំ ភវិស្សតិ តេ សទ្ទា តញ្ចាយតនំ នោ បដិសំវេទិស្សតិ តទេវ នាម ឃានំ ភវិស្សតិ តេ គន្ធា តញ្ចាយតនំ នោ បដិសំវេទិស្សតិ

[៣៧] សម័យមួយ ព្រះអានន្ទដ៏មានអាយុ គង់នៅ ក្នុងឃោសិតារាម ជិតក្រុងកោសម្ពី ។ ក្នុងទីនោះឯង ព្រះអានន្ទដ៏មានអាយុ មានថេរវាចានឹងភិក្ខុទាំងឡាយថា ម្នាលអាវុសោភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះ ទទួលតបព្រះអានន្ទដ៏មានអាយុថា ករុណាអាវុសោ ។ ព្រះអានន្ទដ៏មានអាយុ មានថេរវាចាដូច្នេះថា ម្នាលអាវុសោទាំងឡាយ អស្ចារ្យណាស់ ម្នាលអាវុសោទាំងឡាយ ចំឡែកណាស់ ព្រោះព្រះដ៏មានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ ព្រះអង្គត្រាស់ដឹងនូវការបាននូវឱកាស ដើម្បីសេចក្តីបរិសុទ្ធ ដើម្បីកន្លងបង់នូវសេចក្តីសោកនិងខ្សឹកខ្សួល ដើម្បីរលត់ទុក្ខនិងទោមនស្ស ដើម្បីបាននូវព្រះនិព្វាន ដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន របស់សត្វទាំងឡាយ (ការបាននូវឱកាសនោះគឺ) ចក្ខុប្បសាទនោះ ក៏មានរូបទាំងឡាយនោះ មកកាន់រង្វង់ចក្ខុ តែមិនទទួលដឹងចំពោះរូបាយតនៈនោះ ១ សោតប្បសាទ ក៏មាន សំឡេងទាំងឡាយនោះក៏មក តែមិនទទួលដឹងចំពោះសទ្ទាយតនៈនោះ ១ ឃានប្បសាទនោះ ក៏មានក្លិនទាំងឡាយនោះ ក៏មក តែមិនទទួលដឹងចំពោះគន្ធាយតនៈនោះ ១

សា ច នាម ជិវ្ហា ភវិស្សតិ តេ រសា តញ្ចាយតនំ នោ បដិសំវេទិស្សតិ សោ ច នាម កាយោ ភវិស្សតិ តេ ផោដ្ឋព្វា តញ្ចាយតនំ នោ បដិសំវេទិស្សតីតិ ។ ឯវំ វុត្តេ អាយស្មា ឧទាយិ អាយស្មន្តំ អានន្ទំ ឯតទវោច សញ្ញីមេវ នុ ខោ អាវុសោ អានន្ទ តទាយតនំ នោ បដិសំវេទេតិ ឧទាហុ អសញ្ញីតិ ។ សញ្ញីមេវ ខោ អាវុសោ តទាយតនំ បដិសំវេទេតិ នោ អសញ្ញីតិ ។ កឹសញ្ញី បនាវុសោ តទាយតនំ នោ បដិសំវេទេតីតិ ។

ឥធាវុសោ ភិក្ខុ សព្វសោ រូបសញ្ញានំ សមតិក្កមា បដិឃសញ្ញានំ អត្ថង្គមា នានត្តសញ្ញានំ អមនសិការា អនន្តោ អាកាសោតិ អាកាសានញ្ចាយតនំ ឧបស-ម្បជ្ជ វិហរតិ ។ ឯវំសញ្ញីបិ ខោ អាវុសោ តទាយតនំ នោ បដិសំវេទេតិ ។ បុន ចបរំ អាវុសោ ភិក្ខុ

ជិវ្ហាបសាទនោះ ក៏មាន រសទាំងឡាយនោះ ក៏មក តែមិនទទួលដឹងចំពោះរសាយតនៈនោះ ១ កាយប្បសាទនោះ ក៏មាន សម្ផស្សទាំងឡាយ ក៏មក តែមិនទទួលដឹងចំពោះផោដ្ឋព្វាយតនៈនោះ ១ ។ កាលដែលអានន្ទដ៏មានអាយុ មានថេរវាចាយ៉ាងនេះហើយ ព្រះឧទាយីដ៏មានអាយុ បានសួរព្រះអានន្ទដ៏មានអាយុដូច្នេះថា អើអាវុសោអានន្ទចុះដែលមិនទទួលដឹងចំពោះអាយតនៈនោះ តើមានសញ្ញាឬទេ ឬក៏មិនមានសញ្ញា ។ ព្រះអានន្ទដ៏មានអាយុតបថា បុគ្គលដែលទទួលដឹងចំពោះអាយតនៈនោះ សុទ្ធតែជាអ្នកមានសញ្ញា មិនមែនជាមិនមានសញ្ញាទេ ។ ព្រះឧទាយីដ៏មានអាយុសួរទៀតថា ម្នាលអាវុសោ ចុះបុគ្គលមានសញ្ញាបែបណាទៅ ទើបមិនទទួលដឹងចំពោះអាយតនៈនោះ ។

ព្រះអានន្ទដ៏មានអាយុតបថា ម្នាលអាវុសោ ភិក្ខុក្នុងសាសនានេះ ព្រោះកន្លងបង់នូវរូបសញ្ញា ព្រោះរលត់នូវបដិឃសញ្ញា ព្រោះមិនបានធ្វើទុកក្នុងចិត្តនូវនានត្តសញ្ញា ដោយប្រការទាំងពួង ក៏បានដល់នូវអាកាសានញ្ចាយតនជ្ឈាន ដោយការធ្វើទុកក្នុងចិត្តថា អាកាសមិនមានទីបំផុត ។ ម្នាលអាវុសោ ភិក្ខុមានសញ្ញាយ៉ាងនេះឯង តែងមិនទទួលដឹងចំពោះអាយតនៈនោះ ។ ម្នាលអាវុសោ មួយទៀត ភិក្ខុ

សព្វសោ អាកាសានញ្ចាយតនំ សមតិក្កម្ម អនន្តំ វិញ្ញាណន្តិ វិញ្ញាណញ្ចាយតនំ ឧបសម្បជ្ជ វិហរតិ ។ ឯវំសញ្ញីបិ ខោ អាវុសោ តទាយតនំ នោ បដិសំវេទេតិ ។ បុន ចបរំ អាវុសោ ភិក្ខុ សព្វសោ វិញ្ញាណញ្ចាយតនំ សមតិក្កម្ម នត្ថិ កិញ្ចីតិ អាកិញ្ចញ្ញាយតនំ ឧបសម្បជ្ជ វិហរតិ ។ ឯវំសញ្ញីបិ ខោ អាវុសោ តទាយតនំ នោ បដិសំវេទេតិ ។

ឯកមិទាហំ អាវុសោ សមយំ សាកេតេ វិហរាមិ អញ្ជនវនេ មិគទាយេ ។ អថខោ អាវុសោ ជដិលភាគិកា[១] ភិក្ខុនី យេនាហំ តេនុបសង្កមិ ឧបសង្កមិត្វា មំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ ។ ឯកមន្តំ ឋិតា ខោ អាវុសោ ជដិលភាគិកា ភិក្ខុនី មំ ឯតទវោច យាយំ ភន្តេ អានន្ទ សមាធិ ន ចាភិនតោ ន ចាបនតោ ន សសង្ខារនិគ្គយ្ហវារិតវតោ វិមុត្តត្តា ឋិតោ ឋិតត្តា

---

១ ឱ. ជដិលា គាហិយា ។ ម. ជដិលវាសិកា ។ អដ្ឋកថាយន្តុ ជដិលគាហិយាតិ ជដិលគហានគរវាសិនីតិ វុត្តំ ។

ព្រោះកន្លងបង់នូវអាកាសានញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ក៏បានដល់នូវវិញ្ញាណញ្ចាយតនជ្ឈាន ដោយការធ្វើទុកក្នុងចិត្តថា វិញ្ញាណមិនមានទីបំផុត ។ ម្នាលអាវុសោ ភិក្ខុមានសញ្ញាយ៉ាងនេះឯង តែងមិនទទួលដឹងចំពោះអាយតនៈនោះ ។ ម្នាលអាវុសោ មួយទៀត ភិក្ខុ ព្រោះកន្លងបង់នូវវិញ្ញាណញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ក៏បានដល់នូវអាកិញ្ចញ្ញាយតនជ្ឈាន ដោយការធ្វើទុកក្នុងចិត្តថា អ្វីតិចតួចមិនមាន ។ ម្នាលអាវុសោ ភិក្ខុមានសញ្ញាយ៉ាងនេះឯង តែងមិនទទួលដឹងចំពោះអាយតនៈនោះ ។

ម្នាលអាវុសោ សម័យមួយ ខ្ញុំនៅក្នុងអញ្ជនវ័ន (ព្រៃអញ្ជ័ន) ជាទីឲ្យអភ័យដល់ម្រឹគ ជិតក្រុងសាកេត ។ ម្នាលអាវុសោ គ្រានោះ នាងភិក្ខុនី ជាបងប្អូននឹងជដិល បានចូលមករកខ្ញុំ លុះចូលមកដល់ហើយ ថ្វាយបង្គំខ្ញុំ ហើយឋិតនៅក្នុងទីដ៏សមគួរ ។ ម្នាលអាវុសោ លុះភិក្ខុនី ជាបងប្អូននឹងជដិល ឋិតនៅក្នុងទីដ៏សមគួរស៊ប់ហើយ បានសួរខ្ញុំដូច្នេះថា បពិត្រព្រះអានន្ទដ៏ចម្រើន សមាធិដែលលែងទោរទៅ (ដោយអំណាចរាគៈ) លែងផប់ទៅ (ដោយអំណាចទោសៈ) លែងសង្កត់សង្កិនហាមឃាត់នូវកិលេសដោយព្យាយាម (ទៀតហើយ) ជាសមាធិឈ្មោះថា តាំងនៅហើយ ព្រោះផុតស្រឡះចាកកិលេស

សន្តុសិតោ សន្តុសិតត្តា នោ បរិតស្សតិ អយំ ភន្តេ អានន្ទ សមាធិ កិំផលោ វុត្តោ ភគវតាតិ ។ ឯវំ វុត្តេ តាហំ[១] អាវុសោ ជដិលភាគិកា ភិក្ខុនី ឯតទវោច យាយំ ភគិនិ សមាធិ ន ចាភិនតោ ន ចាបនតោ ន សសង្ខារនិគ្គយ្ហវារិតវតោ វិមុត្តត្តា ឋិតោ ឋិតត្តា សន្តុសិតោ សន្តុសិតត្តា នោ បរិតស្សតិ អយំ ភគិនិ សមាធិ អញ្ញាផលោ វុត្តោ ភគវតាតិ ។ ឯវំសញ្ញីបិ ខោ អាវុសោ តទាយតនំ នោ បដិសំវេទេតីតិ ។

[៣៨] អថខោ ទ្វេ លោកាយតិកា ព្រាហ្មណា យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវតា សទ្ធឹ សម្មោទឹសុ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទឹសុ ។

១ ឱ. អហ ។ ម. សោហំ ។

ជាសមាធិឈ្មោះថាត្រេកអរព្រោះតាំងនៅ ជាសមាធិឈ្មោះថាមិនតក់ស្លុត ព្រោះត្រេកអរ បពិត្រព្រះអានន្ទដ៏ចម្រើន តើសមាធិនេះ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថាមានអ្វីជាផល ។ ម្នាលអាវុសោ កាលភិក្ខុនីនោះសួរយ៉ាងនេះហើយ ខ្ញុំក៏បានឆ្លើយតបនឹងនាងភិក្ខុនី ជាបងប្អូននឹងជដិលនោះថា ម្នាលនាង សមាធិ ដែលលែងទោរទៅ (ដោយអំណាចរាគៈ) លែងងប់ទៅ (ដោយអំណាចទោសៈ) លែងសង្កត់សង្កិន ហាមឃាត់នូវកិលេសដោយព្យាយាម (ទៀតហើយ) ជាសមាធិឈ្មោះថា តាំងនៅព្រោះផុតស្រឡះចាកកិលេស ជាសមាធិឈ្មោះថាត្រេកអរ ព្រោះតាំងនៅ ជាសមាធិឈ្មោះថា មិនតក់ស្លុត ព្រោះសេចក្តីត្រេកអរ ម្នាលនាងសមាធិនេះ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា មានអរហត្ត ជាផល ។ ម្នាលអាវុសោ បុគ្គលមានសញ្ញាយ៉ាងនេះឯង តែងមិនទទួលដឹងចំពោះអាយតនៈនោះ ។

[៣៨] គ្រានោះឯង ព្រាហ្មណ៍ពីរនាក់ ជាអ្នកចេះស្ទាត់នូវគម្ពីរលោកាយតៈបានចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយពោលពាក្យរាក់ទាក់ជាមួយនឹងព្រះដ៏មានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររលឹករួចហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។

ឯកមន្តំ និសិន្នា ខោ តេ ព្រាហ្មណា ភគវន្តំ ឯតទវោចុំ បូរណោ ភោ គោតម កស្សបោ សព្វញ្ញូ សព្វទស្សាវី អបរិសេសញាណទស្សនំ បដិជានាតិ ចរតោ ច មេ តិដ្ឋតោ ច មេ សុត្តស្ស ច ជាគរស្ស ច សតតំ សមិតំ ញាណទស្សនំ បច្ចុបដ្ឋិតន្តិ ។ សោ ឯវមាហ អហំ អនន្តេន ញាណេន អនន្តំ លោកំ[១] ជានំ បស្សំ វិហរាមីតិ ។ អយម្បិ ហិ ភោ គោតម និគណ្ឋោ នាដបុត្តោ សព្វញ្ញូ សព្វទស្សាវី អបរិសេសញាណទស្សនំ បដិជានាតិ ចរតោ ច មេ តិដ្ឋតោ ច មេ សុត្តស្ស ច ជាគរស្ស ច សតតំ សមិតំ ញាណទស្សនំ បច្ចុបដ្ឋិតន្តិ ។ សោ ឯវមាហ អហំ អនន្តេន ញាណេន អនន្តំ លោកំ ជានំ បស្សំ វិហរាមីតិ ។ ឥមេសំ ភោ គោតម ឧភិន្នំ ញាណវាទានំ ឧភិន្នំ អញ្ញមញ្ញំ វិបច្ចនីកវាទានំ កោ សច្ចំ កោ មុសាតិ ។

១. ឱ. អន្តវន្តំ លោកំ ។

លុះព្រាហ្មណ៍ទាំងនោះ អង្គុយក្នុងទីដ៏សមគួរហើយ បានក្រាបទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន គ្រូឈ្មោះបូរណកស្សប ជាអ្នកដឹងនូវហេតុទាំងពួង ឃើញនូវហេតុទាំងពួង តែងប្តេជ្ញានូវការដឹង ការឃើញ មិនមានសេសសល់ថា កាលអញដើរក្តី ឈរក្តី កាលអញដេកក្តី ភ្ញាក់ឡើងក្តី ការដឹង និងការឃើញ (នូវហេតុទាំងពួង) តែងតម្កល់នៅស៊ប់ សព្វពេលវេលា ជានិរន្តរ៍ ។ បូរណកស្សបនោះ និយាយ យ៉ាងនេះថា អញតែងដឹង តែងឃើញនូវលោក ដែលមិនមានទីបំផុត ដោយសារញាណមិនមានទីបំផុត ។ បពិត្រព្រះគោតមដ៏ចម្រើន សូម្បីគ្រូឈ្មោះនិគ្គន្ថនាដបុត្រនេះ ក៏ជាអ្នកដឹងនូវហេតុទាំងពួង ឃើញនូវហេតុទាំងពួងដែរ តែងប្តេជ្ញានូវការដឹង ការឃើញ មិនមានសេសសល់ថា កាលអញដើរក្តី ឈរក្តី អញដេកក្តី ភ្ញាក់ឡើងក្តី ការដឹង ការឃើញ (នូវហេតុទាំងពួង) តែងតម្កល់នៅស៊ប់ សព្វពេលវេលា ជានិរន្តរ៍ ។ និគ្គន្ថនាដបុត្តនោះ និយាយយ៉ាងនេះថា អញតែងដឹង តែងឃើញនូវលោក ដែលមិនមានទីបំផុតដោយសារញាណ មិនមានទីបំផុត ។ បពិត្រព្រះគោតមដ៏ចម្រើន បណ្តាញាណវាទៈទាំងពីរ និងវិបច្ចនិកវាទៈ ទៅវិញទៅមកទាំងពីរនេះ តើវាទៈណាពិត វាទៈណាកុហក ។

អលំ ព្រាហ្មណា តិដ្ឋតេតំ ឥមេសំ ឧភិន្នំ ញាណវាទានំ ឧភិន្នំ អញ្ញមញ្ញំ វិបច្ចនីកវាទានំ កោ សច្ចំ កោ មុសា ធម្មំ វោ ព្រាហ្មណា ទេសេស្សាមិ តំ សុណាថ សាធុកំ មនសិករោថ ភាសិស្សាមីតិ ។ ឯវំ ភោតិ ខោ តេ ព្រាហ្មណា ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច សេយ្យថាបិ ព្រាហ្មណា ចត្តារោ បុរិសា ចតុទ្ទិសា ឋិតា បុរិសគតិយា ច ជវេន[១] សមន្នាគតា បរមេន ច បទវីតិហារេន ឯវរូបេន ជវេន សមន្នាគតា អស្សុ សេយ្យថាបិ នាម ទឡ្ហធម្មោ ធនុគ្គហោ សិក្ខិតោ កតហត្ថោ កតុបាសនោ លហុកេន អសនេន អប្បកសិរេន តិរិយំ តាលច្ឆាតឹ អតិបាតេយ្យ ឯវរូបេន ច បទវីតិហារេន សេយ្យថាបិ នាម បុរត្ថិមា សមុទ្ទា បច្ឆិមោ សមុទ្ទោ អថ បុរត្ថិមាយ ទិសាយ ឋិតោ បុរិសោ ឯវំ វទេយ្យ អហំ គមនេន លោកស្ស អន្តំ បាបុណិស្សាមីតិ

១ ឱ. បរមាយ គតិយា ច ជវេន ច ។ ម. បរមេន ជវេន ច ។

ម្នាលព្រាហ្មណ៍ទាំងឡាយ ណ្ហើយកុំសួរត្រង់ពាក្យថា បណ្ដាញាណវាទៈទាំងពីរ និងវិបច្ចនិកវាទៈ ទៅវិញទៅមកទាំងពីរនេះ តើវាទៈណាពិត វាទៈណាកុហក ដូច្នេះនុ៎ះ ចូរផ្អាកទុកទៅចុះ ម្នាលព្រាហ្មណ៍ទាំងឡាយ តថាគតនឹងសម្ដែងធម៌ដល់អ្នកទាំងឡាយ អ្នកទាំងឡាយចូរស្ដាប់ធម៌នោះសិន ចូរធ្វើទុកក្នុងចិត្តឲ្យល្អ តថាគតនឹងសម្ដែង ។ ព្រាហ្មណ៍ទាំងនោះ បានទទួលស្ដាប់ព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ទាំងឡាយ ដូចបុរស ៤ នាក់ ឈរនៅក្នុងទិសទាំង ៤ ដែលបរិបូណ៌ដោយដំណើររបស់បុរសផង ដោយសន្ទុះផង ដោយជំហានជើងដ៏រហ័សក្រៃលែងផង ជាអ្នកប្រកបដោយសន្ទុះ មានសភាពយ៉ាងនេះឯង (ក្នុងបុរសម្នាក់ៗសុទ្ធតែជាអ្នកប្រកប) ដោយជំហានជើង (ដែលអាចដើរឆ្លងចក្កវាឡដោយឆាប់រហ័សបាន) មានសភាពដូចជាខ្មាន់ធ្នូដែលខ្លាំងពូកែ បានសិក្សារួចហើយ មានដៃស្ទាត់ហើយ ធ្លាប់ចូលចំណោមហើយ ក៏យកព្រួញដ៏ស្រាល បាញ់ស្រមោលដើមត្នោត ត្រង់ពាក់កណ្ដាលដើម ដោយមិនលំបាកដូច្នោះឯង មានតួយ៉ាងដូចសមុទ្រទិសខាងកើត និងសមុទ្រទិសខាងលិច គ្រានោះ បុរសដែលឈរ ក្នុងទិសខាងកើត និយាយយ៉ាងនេះថា អញនឹងដើរទៅឲ្យដល់ទីបំផុតនៃលោក

១៥៨



សោ អញ្ញត្រេវ អសិតខាយិតសាយិតា អញ្ញត្រ ឧច្ចារប្បស្សាវកម្មា អញ្ញត្រ និទ្ទាកិលមថប្បដិវិនោទនា វស្សសតាយុកោ វស្សសតជីវី វស្សសតំ គន្ត្វា អប្បត្វា វ លោកស្ស អន្តមន្តរា កាលំ ករេយ្យ អថ បច្ឆិមាយ ទិសាយ ។ បេ ។ អថ ទក្ខិណាយ ទិសាយ ឋិតោ បុរិសោ ឯវំ វទេយ្យ អហំ គមនេន លោកស្ស អន្តំ បាបុណិស្សាមីតិ សោ អញ្ញត្រេវ អសិតខាយិតសាយិតា អញ្ញត្រ ឧច្ចារប្បស្សាវកម្មា អញ្ញត្រ និទ្ទាកិលមថប្បដិវិនោទនា វស្សសតាយុកោ វស្សសតជីវី វស្សសតំ គន្ត្វា អប្បត្វាវ លោកស្ស អន្តមន្តរា កាលំ ករេយ្យ តំ កិស្ស ហេតុ នាហំ ព្រាហ្មណា ឯវរូបាយ សន្ធាវនិកាយ លោកស្ស អន្តំ ញាតេយ្យំ ទិដ្ឋេយ្យំ បត្តេយ្យន្តិ វទាមិ ន ចាហំ ព្រាហ្មណា អប្បត្វាវ លោកស្ស អន្តំ ទុក្ខស្ស អន្តកិរិយំ វទាមិ ។

បុរសនោះ មានអាយុ ១០០ ឆ្នាំ រស់នៅ ១០០ ឆ្នាំ ក៏ដើរទៅអស់ ១០០ ឆ្នាំ (មិនឈប់) វៀរលែងតែស៊ី ទំពាស៊ី លិទ្ធភ្លក្សអាហារ វៀរលែងតែការធ្វើឧច្ចារៈនិងបស្សាវៈ វៀរលែងតែដេកនិងការបន្ទោបង់នូវសេចក្តីនឿយហត់ចេញ ក៏មិនបានដល់ដូចបំណងឡើយ ហើយធ្វើមរណកាល ក្នុងទីជាចន្លោះៗ នៃលោក ចំណែកបុរសដែលឈរក្នុងទិសខាងលិច ។ បេ ។ ចំណែក បុរសដែលឈរ ក្នុងទិសខាងត្បូង ក៏និយាយយ៉ាងនេះថា អញនឹងដើរទៅឲ្យដល់ទីបំផុតនៃលោក បុរសនោះ មានអាយុ ១០០ ឆ្នាំ រស់នៅ ១០០ ឆ្នាំ ក៏ដើរទៅអស់ ១០០ ឆ្នាំ (មិនឈប់) វៀរលែងតែស៊ី ទំពាស៊ី លិទ្ធភ្លក្សអាហារ វៀរលែងតែការធ្វើឧច្ចារៈនិងបស្សាវៈ វៀរលែងតែដេកនិងការបន្ទោបង់នូវសេចក្តីនឿយហត់ចេញ ក៏មិនបានដល់ដូចបំណងឡើយ ហើយធ្វើមរណកាល ក្នុងទីជាចន្លោះៗ នៃលោក ដំណើរនុ៎ះ ព្រោះហេតុអ្វី ម្នាលព្រាហ្មណ៍ទាំងឡាយ ព្រោះតថាគតមិនពោលថា ទីបំផុតនៃលោក បុគ្គលត្រូវដឹង ត្រូវឃើញ ត្រូវទៅដល់បាន ដោយសារសន្ទុះដើង មានសភាពយ៉ាងនោះឡើយ ។ ម្នាលព្រាហ្មណ៍ទាំងឡាយ ឯតថាគត មិនធ្លាប់ពោលអំពីដំណើរសត្វដែលមិនទាន់បានដល់នូវទីបំផុតនៃលោក ហើយ (ថា) ធ្វើនូវទីបំផុតនៃទុក្ខសោះឡើយ ។

១៨៩



បញ្ចិមេ ព្រាហ្មណា កាមគុណា អរិយស្ស វិនយេ លោកោតិ វុច្ចន្តិ ។ កតមេ បញ្ច ។ ចក្ខុវិញ្ញេយ្យា រូបា ឥដ្ឋា កន្តា មនាបា បិយរូបា កាមូបសញ្ហិតា រជនិយា សោតវិញ្ញេយ្យា សទ្ទា ។ បេ ។ ឃានវិញ្ញេយ្យា គន្ធា ជិវ្ហាវិញ្ញេយ្យា រសា កាយ-វិញ្ញេយ្យា ផោដ្ឋព្វា ឥដ្ឋា កន្តា មនាបា បិយរូបា កាមូបសញ្ហិតា រជនិយា ។ ឥមេ ខោ ព្រាហ្មណា បញ្ច កាមគុណា អរិយស្ស វិនយេ លោកោតិ វុច្ចន្តិ ។

ឥធ ព្រាហ្មណា ភិក្ខុ វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ សវិតក្កំ សវិចារំ វិវេកជំ បីតិសុខំ បឋមជ្ឈានំ ឧបសម្បជ្ជ វិហរតិ ។ អយំ វុច្ចតិ ព្រាហ្មណា ភិក្ខុ លោកស្ស អន្តមគមា[១] លោកស្ស អន្តេ វិហរតិ ។

១ ឱ. អន្តំ អាគម្ម ។ ម. អន្តមាគម្ម ។

ម្នាលព្រាហ្មណ៍ទាំងឡាយ កាមគុណ ៥ ប្រការនេះ តថាគត ហៅថា លោក លោកក្នុងអរិយវិន័យ ។ កាមគុណ ៥ ប្រការនោះ តើដូចម្ដេចខ្លះ ។ រូបទាំងឡាយ ដែលគប្បីដឹងបាន ដោយចក្ខុ ជាទីប្រាថ្នា ត្រេកអរ ពេញចិត្ត មានសភាព ជាទីស្រឡាញ់ ប្រកបដោយកាម ជាទីគាប់ចិត្ត ១ សំឡេងទាំងឡាយ ដែលគប្បី ដឹងដោយត្រចៀក ១ ។ បេ ។ ក្លិនទាំងឡាយ ដែលគប្បីដឹងដោយ ច្រមុះ ១ រសទាំងឡាយ ដែលគប្បីដឹងដោយអណ្ដាត ១ ផោដ្ឋព្វៈទាំង-ឡាយ ដែលគប្បីដឹងដោយកាយ ជាទីប្រាថ្នា ត្រេកអរ ពេញចិត្ត មានសភាព ជាទីស្រឡាញ់ ប្រកបដោយកាម ជាទីគាប់ចិត្ត ១ ។ ម្នាល ព្រាហ្មណ៍ទាំងឡាយ កាមគុណ ៥ ប្រការនេះឯង តថាគតហៅថា លោក លោកក្នុងអរិយវិន័យ ។

ម្នាលព្រាហ្មណ៍ទាំងឡាយ ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាក កាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ហើយបានដល់ បឋមជ្ឈាន ដែលប្រកបដោយវិតក្កៈនិងវិចារៈ មានបីតិនិងសុខៈដែល កើតអំពីសេចក្ដីស្ងប់ស្ងាត់ ។ ម្នាលព្រាហ្មណ៍ទាំងឡាយ ភិក្ខុនេះ តថាគតហៅថា បានដល់ទីបំផុតនៃលោក ឋិតនៅក្នុងទីបំផុតនៃលោក ។

តមញ្ញេ ឯវមាហំសុ អយម្បិ លោកបរិយាបន្នោ អយម្បិ អនិស្សដោ លោកម្ហាតិ ។ អហម្បិ ហិ ព្រាហ្មណា ឯវំ វទាមិ អយម្បិ លោកបរិយាបន្នោ អយម្បិ អនិស្សដោ លោកម្ហាតិ ។

បុន ចបរំ ព្រាហ្មណា ភិក្ខុ វិតក្កវិចារានំ វូបសមា ។ បេ ។ ទុតិយជ្ឈានំ តតិយជ្ឈានំ ចតុត្ថជ្ឈានំ ឧបសម្បជ្ជ វិហរតិ ។ អយំ វុច្ចតិ ព្រាហ្មណា ភិក្ខុ លោកស្ស អន្តមគមា លោកស្ស អន្តេ វិហរតិ ។ តមញ្ញេ ឯវមាហំសុ អយម្បិ លោកបរិយាបន្នោ អយម្បិ អនិស្សដោ លោកម្ហាតិ ។ អហម្បិ ហិ ព្រាហ្មណា ឯវំ វទាមិ អយម្បិ លោកបរិយាបន្នោ អយម្បិ អនិស្សដោ លោកម្ហាតិ ។

បុន ចបរំ ព្រាហ្មណា ភិក្ខុ សព្វសោ រូបសញ្ញានំ សមតិក្កមា បដិឃសញ្ញានំ អត្ថង្គមា នានត្តសញ្ញានំ អមនសិការា អនន្តោ អាកាសោតិ អាកាសានញ្ចាយតនំ ឧបសម្បជ្ជ វិហរតិ ។ អយំ វុច្ចតិ ព្រាហ្មណា ភិក្ខុ លោកស្ស អន្តមគមា លោកស្ស អន្តេ វិហរតិ ។

ពួកជនឯទៀតបាននិយាយចំពោះភិក្ខុនោះយ៉ាងនេះថា ភិក្ខុនេះរាប់បញ្ចូលក្នុងលោកផង ភិក្ខុនេះ មិនរលាស់ចេញចាកលោកបានផង ។ ម្នាលព្រាហ្មណ៍ទាំងឡាយ ឯតថាគតក៏ពោលយ៉ាងនេះថា ភិក្ខុនេះ រាប់បញ្ចូលក្នុងលោកផង ភិក្ខុនេះ មិនរលាស់ចេញចាកលោកបានផង ដូច្នេះដែរ ។

ម្នាលព្រាហ្មណ៍ទាំងឡាយ មួយទៀត ភិក្ខុ ព្រោះរម្ងាប់វិតក្កៈ និងវិចារៈ ។ បេ ។ ក៏បានដល់ទុតិយជ្ឈាន តតិយជ្ឈាន ចតុត្ថជ្ឈាន ។ ម្នាលព្រាហ្មណ៍ទាំងឡាយ ភិក្ខុនេះ តថាគតហៅថា បានដល់ទីបំផុតនៃលោក ឋិតនៅក្នុងទីបំផុតនៃលោក ។ ពួកជនឯទៀត បាននិយាយចំពោះភិក្ខុនោះ យ៉ាងនេះថា ភិក្ខុនេះ រាប់បញ្ចូលក្នុងលោកផង ភិក្ខុនេះ មិនរលាស់ចេញចាកលោកបានផង ។ ម្នាលព្រាហ្មណ៍ទាំងឡាយ ឯតថាគតពោលយ៉ាងនេះថា ភិក្ខុនេះ រាប់បញ្ចូលក្នុងលោកផង ភិក្ខុនេះ មិនរលាស់ចេញចាកលោកបានផង ដូច្នេះដែរ ។

ម្នាលព្រាហ្មណ៍ទាំងឡាយ មួយទៀត ភិក្ខុ ព្រោះកន្លងបង់រូបសញ្ញា ព្រោះរលត់បដិឃសញ្ញា ព្រោះធ្វើទុកក្នុងចិត្តនូវនានត្តសញ្ញា ក៏បានដល់អាកាសានញ្ចាយតនជ្ឈាន ដោយការធ្វើទុកក្នុងចិត្តថា អាកាសមិនមានទីបំផុត ។ ម្នាលព្រាហ្មណ៍ទាំងឡាយ ភិក្ខុនេះ តថាគតហៅថា បានដល់ទីបំផុតនៃលោក ឋិតនៅក្នុងទីបំផុតនៃលោក ។

តមញ្ញេ ឯវមាហំសុ អយម្បិ លោកបរិយាបន្នោ អយម្បិ អនិស្សដោ លោកម្ហាតិ ។ អហម្បិ ហិ ព្រាហ្មណា ឯវំ វទាមិ អយម្បិ លោកបរិយាបន្នោ អយម្បិ អនិស្សដោ លោកម្ហាតិ ។

បុន ចបរំ ព្រាហ្មណា ភិក្ខុ សព្វសោ អាកាសានញ្ចាយតនំ សមតិក្កម្ម អនន្តំ វិញ្ញាណន្តិ វិញ្ញាណញ្ចាយតនំ ឧបសម្បជ្ជ វិហរតិ ។ បេ ។ សព្វសោ វិញ្ញាណញ្ចាយតនំ សមតិក្កម្ម នត្ថិ កិញ្ចីតិ អាកិញ្ចញ្ញាយតនំ ឧបសម្បជ្ជ វិហរតិ សព្វសោ អាកិញ្ចញ្ញាយតនំ សមតិក្កម្ម នេវសញ្ញានាសញ្ញាយតនំ ឧបសម្បជ្ជ វិហរតិ ។ អយំ វុច្ចតិ ព្រាហ្មណា ភិក្ខុ លោកស្ស អន្តមគមា លោកស្ស អន្តេ វិហរតិ ។ តមញ្ញេ ឯវមាហំសុ អយម្បិ លោកបរិយាបន្នោ អយម្បិ អនិស្សដោ លោកម្ហាតិ ។ អហម្បិ ហិ ព្រាហ្មណា ឯវំ វទាមិ អយម្បិ លោកបរិយាបន្នោ

ពួកជនឯទៀត បាននិយាយចំពោះភិក្ខុនោះយ៉ាងនេះថា ភិក្ខុនេះ រាប់បញ្ចូលក្នុងលោកផង ភិក្ខុនេះ មិនទាន់រលាស់ចេញចាកលោកបានផង ។ ម្នាលព្រាហ្មណ៍ទាំងឡាយ ឯតថាគតក៏ពោលយ៉ាងនេះថា ភិក្ខុនេះ រាប់បញ្ចូលក្នុងលោកផង ភិក្ខុនេះ មិនទាន់រលាស់ចេញចាកលោកបានផង ដូច្នេះដែរ ។

ម្នាលព្រាហ្មណ៍ទាំងឡាយ មួយទៀត ភិក្ខុ ព្រោះកន្លងបង់អាកាសានញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ក៏បានដល់វិញ្ញាណញ្ចាយតនជ្ឈាន ដោយការធ្វើទុកក្នុងចិត្តថា វិញ្ញាណមិនមានទីបំផុត ។ បេ ។ ព្រោះកន្លងបង់វិញ្ញាណញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ក៏បានដល់អាកិញ្ចញ្ញាយតនជ្ឈាន ដោយការធ្វើទុកក្នុងចិត្តថា អ្វីតិចតួចមិនមាន ព្រោះកន្លងបង់អាកិញ្ចញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង ក៏បានដល់នេវសញ្ញានាសញ្ញាយតនជ្ឈាន ។ ម្នាលព្រាហ្មណ៍ទាំងឡាយ ភិក្ខុនេះ តថាគតហៅថា បានដល់ទីបំផុតនៃលោក ឋិតនៅក្នុងទីបំផុតនៃលោក ។ ពួកជនឯទៀត បាននិយាយចំពោះភិក្ខុនោះ យ៉ាងនេះថា ភិក្ខុនេះ រាប់បញ្ចូលក្នុងលោកផង ភិក្ខុនេះ មិនទាន់រលាស់ចេញចាកលោកបានផង ។ ម្នាលព្រាហ្មណ៍ទាំងឡាយ តថាគតក៏និយាយយ៉ាងនេះថា ភិក្ខុនេះ រាប់បញ្ចូលក្នុងលោកផង

អយម្បិ អនិស្សដោ លោកម្ហាតិ ។

បុន ចបរំ ព្រាហ្មណា ភិក្ខុ សព្វសោ នេវសញ្ញានាសញ្ញាយតនំ សមតិក្កម្ម សញ្ញាវេទយិតនិរោធំ ឧបសម្បជ្ជ វិហរតិ ។ បញ្ញាយបស្ស ទិស្វា អាសវា បរិក្ខីណា ហោន្តិ ។ អយំ វុច្ចតិ ព្រាហ្មណា ភិក្ខុ លោកស្ស អន្តមគមា លោកស្ស អន្តេ វិហរតិ តិណ្ណោ លោកេ វិសត្តិកន្តិ ។

[៣៩] ភូតបុព្វំ ភិក្ខវេ ទេវាសុរសង្គាមោ សមុបព្យូឡ្ហោ អហោសិ តស្មឹ ខោ បន ភិក្ខវេ សង្គាមេ អសុរា ជិនឹសុ ទេវា បរាជិយឹសុ បរាជិតា ច ភិក្ខវេ ទេវា អបស្សឹស្វេវ(១) ឧត្តរាភិមុខា អភិយឹសុ អសុរា ។ អថខោ ភិក្ខវេ ទេវានំ ឯតទហោសិ អភិយន្តេវ ខោ អសុរា យន្នូន មយំ ទុតិយម្បិ អសុរេហិ សង្គាមេយ្យាមាតិ ។

១ ឱ. អបយឹស្វេវ ។ ម. អបយឹសុយេវ ។

ភិក្ខុនេះ មិនទាន់រលាស់ចេញចាកលោកបានផង ដូច្នេះដែរ ។

ម្នាលព្រាហ្មណ៍ទាំងឡាយ មួយទៀត ភិក្ខុ ព្រោះកន្លងបង់នេវសញ្ញានាសញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង ក៏បានដល់សញ្ញាវេទយិតនិរោធ ។ អាសវៈរបស់ភិក្ខុនោះ ក៏អស់រលីងទៅ ព្រោះយល់ឃើញដោយប្រាជ្ញា ។ ម្នាលព្រាហ្មណ៍ទាំងឡាយ ភិក្ខុនេះ តថាគតហៅថា បានដល់ទីបំផុតនៃលោក ឋិតនៅក្នុងទីបំផុតនៃលោក បានឆ្លងផុតនូវតណ្ហាក្នុងលោកហើយ ។

[៣៩] ម្នាលភិក្ខុទាំងឡាយ មានរឿងពីព្រេងនាយមកថា សង្គ្រាមនៃអសុរមួយអន្ទើដោយពួកទេវតា ជាសង្គ្រាមតទល់ប្រឡូកគៀកគ្នាហើយ ម្នាលភិក្ខុទាំងឡាយ ក្នុងសង្គ្រាមនោះឯង ពួកអសុរឈ្នះ ពួកទេវតាចាញ់ ម្នាលភិក្ខុទាំងឡាយ លុះពួកទេវតាបរាជ័យហើយ ក៏បានរត់ផ្ទោះមុខទៅកាន់ទិសខាងជើង ពួកអសុរក៏ដេញតាម ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង ពួកទេវតាមានសេចក្តីត្រិះរិះយ៉ាងនេះថា ពួកអសុរ នាំគ្នានៅតែដេញតាមមិនលែងសោះ បើដូច្នោះ គួរតែពួកយើងតយុទ្ធនឹងពួកអសុរឲ្យអស់ ២ គ្រា ។

១៦៣

បណ្ណាសកេ មហាវគ្គោ

ទុតិយម្បិ ខោ ភិក្ខវេ ទេវា អសុរេហិ សង្គាមេសុំ ទុតិយម្បិ ខោ ភិក្ខវេ អសុរា ជិនឹសុ ទេវា បរាជិយឹសុ ។ បរាជិតា ច ភិក្ខវេ ទេវា អបស្សឹ្យស្វេវ ឧត្តរាភិមុខា អភិយឹសុ អសុរា ។ អថខោ ភិក្ខវេ ទេវានំ ឯតទហោសិ អភិយន្តេវ ខោ អសុរា យន្នូន មយំ តតិយម្បិ អសុរេហិ សង្គាមេយ្យាមាតិ ។

តតិយម្បិ ខោ ភិក្ខវេ ទេវា អសុរេហិ សង្គាមេសុំ ។ តតិយម្បិ ខោ ភិក្ខវេ អសុរា ជិនឹសុ ទេវា បរាជិយឹសុ បរាជិតា ច ភិក្ខវេ ទេវា ភីតា ទេវបុរំយេវ បវិសឹសុ ។ ទេវបុរគតានញ្ច បន ភិក្ខវេ ទេវានំ ឯតទហោសិ ភីរុត្តាណគតេន ខោ ទានិ មយំ ឯតរហិ អត្តនា វិហរាម អករណីយា អសុរេហីតិ ។ អសុរានម្បិ ភិក្ខវេ ឯតទហោសិ ភីរុត្តាណគតេន ខោ ទានិ ទេវា ឯតរហិ អត្តនា វិហរន្តិ អករណីយា អម្ហេហីតិ ។

ម្នាលភិក្ខុទាំងឡាយ ពួកទេវតា បានតយុទ្ធនឹងពួកអសុរ ក្នុងលើកទី ២ ទៀត ម្នាលភិក្ខុទាំងឡាយ ក្នុងលើកទីពីរនេះឯង ពួកអសុរឈ្នះ ពួកទេវតាចាញ់(ទៀត) ។ ម្នាលភិក្ខុទាំងឡាយ លុះពួកទេវតាបរាជ័យហើយ ក៏បានរត់ឆ្ពោះមុខទៅកាន់ទិសខាងជើង ពួកអសុរក៏នាំគ្នាដេញតាម ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង ពួកទេវតាមានសេចក្តីត្រិះរិះយ៉ាងនេះថា ពួកអសុរ នៅតែនាំគ្នាដេញតាមមិនលែងសោះ បើដូច្នោះ គួរតែពួកយើងតយុទ្ធនឹងពួកអសុរឲ្យអស់ ៣ គ្រា ។

ម្នាលភិក្ខុទាំងឡាយ ពួកទេវតា បានតយុទ្ធនឹងពួកអសុរ ក្នុងលើកទី ៣ ទៀត ម្នាលភិក្ខុទាំងឡាយ ក្នុងលើកទី ៣ នោះឯង ពួកអសុរឈ្នះ ពួកទេវតាចាញ់(ទៀត) ម្នាលភិក្ខុទាំងឡាយ លុះពួកទេវតាបរាជ័យហើយ ក៏ភ័យរត់ចូលទៅក្នុងទេវបុរីវិញ ។ ម្នាលភិក្ខុទាំង-ឡាយ ឯពួកទេវតា ដែលបានចូលទៅដល់ទេវបុរីហើយ មានសេចក្តីត្រិះរិះយ៉ាងនេះថា ឥឡូវនេះ ពួកយើងមានខ្លួនបានដល់នូវទីការពារភ័យហើយ ទាំងពួកអសុរ ក៏មិនគប្បីធ្វើអ្វីយើងបាន ។ ម្នាលភិក្ខុទាំង-ឡាយ ចំណែកពួកអសុរ មានសេចក្តីត្រិះរិះយ៉ាងនេះថា ឥឡូវនេះ ពួកទេវតាមានខ្លួនបានដល់នូវទីការពារភ័យហើយ ពួកយើងមិនគប្បីធ្វើអ្វីបានទេ ។

១៦៤



ភូតបុព្វំ ភិក្ខវេ ទេវាសុរសង្គាមោ សមុបព្យូឡ្ហោ អហោសិ ។ តស្មឹ ខោ ច ភិក្ខវេ សង្គាមេ ទេវា ជិនឹសុ អសុរា បរាជិយឹសុ បរាជិតា ច ភិក្ខវេ អសុរា អបស្យឹស្វេវ ទក្ខិណេនាភិមុខា អភិយឹសុ ទេវា ។ អថខោ ភិក្ខវេ អសុរានំ ឯតទហោសិ អភិយន្តេវ ខោ ទេវា យន្នូន មយំ ទុតិយម្បិ ទេវេហិ សង្គាមេយ្យាមាតិ ។

ទុតិយម្បិ ខោ ភិក្ខវេ អសុរា ទេវេហិ សង្គាមេសុំ ។ ទុតិយម្បិ ខោ ភិក្ខវេ ទេវា ជិនឹសុ អសុរា បរាជិយឹសុ បរាជិតា ច ភិក្ខវេ អសុរា អបស្យឹស្វេវ ទក្ខិណេនាភិមុខា អភិយឹសុ ទេវា ។ អថខោ ភិក្ខវេ អសុរានំ ឯតទហោសិ អភិយន្តេវ ខោ ទេវា យន្នូន មយំ តតិយម្បិ ទេវេហិ សង្គា-មេយ្យាមាតិ ។

ម្នាលភិក្ខុទាំងឡាយ មានរឿងពីព្រេងនាយមកថា សង្គ្រាមនៃអសុរមួយអន្លើដោយទេវតា ជាសង្គ្រាមតទល់ប្រឡូកកៀកគ្នាហើយ ។ ម្នាលភិក្ខុទាំងឡាយ ក៏ក្នុងសង្គ្រាមនោះឯង ពួកទេវតាឈ្នះ ពួកអសុរចាញ់ ម្នាលភិក្ខុទាំងឡាយ លុះពួកអសុរបរាជ័យហើយ ក៏បានរត់ឆ្ពោះមុខទៅទិសខាងត្បូង ពួកទេវតាក៏នាំគ្នាដេញតាម ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង ពួកអសុរមានសេចក្ដីត្រិះរិះយ៉ាងនេះថា ពួកទេវតា នៅតែនាំគ្នាដេញតាមមិនលែងសោះ បើដូច្នោះ គួរតែពួកយើងតយុទ្ធនឹងពួកទេវតាឲ្យអស់ ២ គ្រាចុះ ។

ម្នាលភិក្ខុទាំងឡាយ ពួកអសុរ បានតយុទ្ធនឹងពួកទេវតា ក្នុងលើកទី ២ ទៀត ។ ម្នាលភិក្ខុទាំងឡាយ ក្នុងលើកទី ២ នោះឯង ពួកទេវតាឈ្នះ ពួកអសុរចាញ់ទៀត ម្នាលភិក្ខុទាំងឡាយ លុះពួកអសុរបរាជ័យហើយ ក៏បានរត់មុខឆ្ពោះទៅកាន់ទិសខាងត្បូង ពួកទេវតាក៏នាំគ្នាដេញតាម ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង ពួកអសុរមានសេចក្ដីត្រិះរិះយ៉ាងនេះថា ពួកទេវតានៅតែនាំគ្នាដេញតាមមិនលែងសោះ បើដូច្នោះ គួរតែពួកយើងតយុទ្ធនឹងពួកទេវតាឲ្យអស់ ៣ គ្រា ។

តតិយម្បិ ខោ ភិក្ខវេ អសុរា ទេវេហិ សង្គាមេសុំ ។ តតិយម្បិ ខោ ភិក្ខវេ ទេវា ជិនឹសុ អសុរា បរាជិយឹសុ បរាជិតា ច ភិក្ខវេ អសុរា ភីតា អសុរបុរេយេវ បវិសឹសុ អសុរបុរគតានញ្ច បន ភិក្ខវេ អសុរានំ ឯតទហោសិ ភីរុត្តាណគតេន ខោ ទានិ មយំ ឯតរហិ អត្តនា វិហរាម អករណីយា ទេវេហីតិ ។ ទេវានម្បិ ភិក្ខវេ ឯតទហោសិ ភីរុត្តាណគតេន ខោ ទានិ អសុរា ឯតរហិ អត្តនា វិហរន្តិ អករណីយា អម្ហេហីតិ ។

ឯវមេវ ខោ ភិក្ខវេ យស្មឹ សមយេ ភិក្ខុ វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ សវិតក្កំ សវិចារំ វិវេកជំ បីតិសុខំ បឋមជ្ឈានំ ឧបសម្បជ្ជ វិហរតិ តស្មឹ ភិក្ខវេ សមយេ ភិក្ខុស្ស ឯវំ ហោតិ ភីរុត្តាណគតេន ខោ ទានាហំ ឯតរហិ អត្តនា វិហរាមិ អករណីយោ មារស្សាតិ មារស្សាបិ ភិក្ខវេ បាបិមតោ ឯវំ ហោតិ ភីរុត្តាណគតេន ខោ ទានិ ភិក្ខុ ឯតរហិ អត្តនា វិហរតិ អករណីយោ មយ្ហន្តិ ។

ម្នាលភិក្ខុទាំងឡាយ ពួកអសុរច្បាំងតនឹងពួកទេវតាក្នុងលើកទី ៣ ទៀត ។ ម្នាលភិក្ខុទាំងឡាយ ក្នុងលើកទី ៣ នោះឯង ពួកទេវតាឈ្នះ ពួកអសុរចាញ់ទៀត ម្នាលភិក្ខុទាំងឡាយ លុះពួកអសុរបរាជ័យហើយ ក៏ភ័យរត់ចូលទៅកាន់អសុរបុរី ម្នាលភិក្ខុទាំងឡាយ ឯពួកអសុរដែលទៅដល់អសុរបុរីហើយ មានសេចក្តីត្រិះរិះយ៉ាងនេះថា ឥឡូវនេះពួកយើងមានខ្លួនបានដល់នូវទីការពារភ័យហើយ ទាំងពួកទេវតាក៏មិនគប្បីធ្វើអ្វីយើងបាន ។ ម្នាលភិក្ខុទាំងឡាយ ចំណែកពួកទេវតាមានសេចក្តីត្រិះរិះយ៉ាងនេះថា ឥឡូវនេះ ពួកអសុរមានខ្លួនបានដល់នូវទីការពារភ័យហើយ ពួកយើងមិនគប្បីធ្វើអ្វីបានទេ ។

ម្នាលភិក្ខុទាំងឡាយ រឿងនេះមានឧបមេយ្យ ដូចភិក្ខុដែលស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ហើយបានដល់បឋមជ្ឈាន ប្រកបដោយវិតក្កៈនិងវិចារៈ ដែលកើតអំពីសេចក្តីស្ងប់ស្ងាត់ក្នុងសម័យណា ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យនោះ ភិក្ខុមានសេចក្តីត្រិះរិះយ៉ាងនេះថា អញមានខ្លួនបានដល់នូវធម៌ជាគ្រឿងការពារភ័យហើយ មារមិនគប្បីធ្វើអ្វីអញបាន ម្នាលភិក្ខុទាំងឡាយ ចំណែកមារ មានចិត្តបាប មានសេចក្តីត្រិះរិះយ៉ាងនេះថា ឥឡូវនេះ ភិក្ខុមានខ្លួន បានដល់នូវគ្រឿងការពារភ័យហើយ អញមិនគប្បីធ្វើអ្វីបាន ។

យស្មឹ ភិក្ខវេ សមយេ ភិក្ខុ វិតក្កវិចារានំ វូបសមា ។ បេ ។ ទុតិយជ្ឈានំ តតិយជ្ឈានំ ចតុត្ថ-ជ្ឈានំ ឧបសម្បជ្ជ វិហរតិ តស្មឹ ភិក្ខវេ សមយេ ភិក្ខុស្ស ឯវំ ហោតិ ភីរុត្តាណគតេន ខោជានាហំ ឯតរហិ អត្តនា វិហរាមិ អករណីយោ មារស្សាតិ មារស្សាបិ ភិក្ខវេ បាបិមតោ ឯវំ ហោតិ ភីរុត្តា-ណគតេន ខោជានិ ភិក្ខុ ឯតរហិ អត្តនា វិហរតិ អករណីយោ មយ្ហន្តិ ។ យស្មឹ ភិក្ខវេ សមយេ ភិក្ខុ សព្វសោ រូបសញ្ញានំ សមតិក្កមា បដិឃសញ្ញានំ អត្ថង្គមា នានត្តសញ្ញានំ អមនសិ-ការា អនន្តោ អាកាសោតិ អាកាសានញ្ចាយតនំ ឧបសម្បជ្ជ វិហរតិ ។ អយំ វុច្ចតិ ភិក្ខវេ ភិក្ខុ អន្ធមកាសិ មារំ អបទំ ពធិត្វា មារចក្ខុំ អទស្សនំ គតោ បាបិមតោ ។ យស្មឹ ភិក្ខវេ សមយេ ភិក្ខុ សព្វសោ អាកាសានញ្ចាយតនំ សមតិក្កម្ម អនន្តំ វិញ្ញាណន្តិ វិញ្ញាណញ្ចាយតនំ ឧបសម្បជ្ជ វិហរតិ ។ បេ ។ សព្វសោ វិញ្ញាណញ្ចាយតនំ សមតិក្កម្ម

ម្នាលភិក្ខុទាំងឡាយ ភិក្ខុ ព្រោះរម្ងាប់វិតក្កៈនិងវិចារៈ ។ បេ ។ ក៏បាន ដល់ទុតិយជ្ឈាន តតិយជ្ឈាន ចតុត្ថជ្ឈាន ក្នុងសម័យណា ម្នាល ភិក្ខុទាំងឡាយ ក្នុងសម័យនោះ ភិក្ខុមានសេចក្តីត្រិះរិះយ៉ាងនេះថា ឥឡូវនេះ អញមានខ្លួនបានដល់នូវគ្រឿងការពារភ័យហើយ មារមិន គប្បីធ្វើអ្វីអញបាន ម្នាលភិក្ខុទាំងឡាយ ចំណែកមារមានចិត្តបាប ក៏មានសេចក្តីត្រិះរិះយ៉ាងនេះថា ឥឡូវនេះ ភិក្ខុមានគ្រឿងការពារ ភ័យបានហើយ អញមិនគប្បីធ្វើអ្វីបាន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុ ព្រោះកន្លងបង់នូវរូបសញ្ញា ព្រោះរលត់បដិឃសញ្ញា ព្រោះមិនធ្វើទុក ក្នុងចិត្តនូវនានត្តសញ្ញា ដោយប្រការទាំងពួង ក៏បានដល់អាកាសា-នញ្ចាយតនជ្ឈាន ដោយការធ្វើទុកក្នុងចិត្តថា អាកាសមិនមានទីបំផុត ក្នុង សម័យណា ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យនោះ ភិក្ខុនោះ តថាគត ហៅថា បានធ្វើមារឲ្យផុតដើង ហៅថា រុំខ្ទប់ភ្នែកមារឲ្យជិតស្លុង ហៅថា ដល់នូវការមិនឃើញនៃមារ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុ ព្រោះកន្លង បង់អាកាសានញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ក៏បានដល់វិញ្ញា-ណញ្ចាយតនជ្ឈាន ដោយបរិកម្មថា វិញ្ញាណមិនមានទីបំផុត ។ បេ ។ ភិក្ខុ ព្រោះកន្លងបង់វិញ្ញាណញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង

ជត្តិ ភិក្ខវេ ភិក្ខុ សព្វសោ អាកិញ្ចញ្ញាយតនំ ឧបសម្បជ្ជ វិហរតិ ។ បេ ។ សព្វសោ អាកិញ្ចញ្ញាយតនំ សមតិក្កម្ម នេវសញ្ញានាសញ្ញាយតនំ ឧបសម្បជ្ជ វិហរតិ ។ បេ ។ សព្វសោ នេវសញ្ញានាសញ្ញាយតនំ សមតិក្កម្ម សញ្ញាវេទយិតនិរោធំ ឧបសម្បជ្ជ វិហរតិ បញ្ញាយបស្ស ខិស្វា អាសវា បរិក្ខីណា ហោន្តិ ។ អយំ វុច្ចតិ ភិក្ខវេ ភិក្ខុ អន្ធមកាសិ មារំ អបទំ វធិត្វា មារចក្ខុំ អទស្សនំ គតោ បាបិមតោ តិណ្ណោ លោកេ វិសត្តិកន្តិ ។

[៤០] យស្មឹ ភិក្ខវេ សមយេ អារញ្ញកស្ស ជាតស្ស គោចរប្បសុតស្ស ហត្ថីបិ ហត្ថិនិយោបិ ហត្ថិកុឡភាបិ(១) ហត្ថិច្ឆាបាបិ បុរតោ បុរតោ គន្ត្វា តិណគ្គានិ ឆិន្ទន្តិ តេន ភិក្ខវេ អារញ្ញកោ នាគោ អដ្ដីយតិ ហរាយតិ ជិគុច្ឆតិ

១ ឱ. ម. ហត្ថិកឡភាបិ ។

ក៏បានដល់អាកិញ្ចញ្ញាយតនជ្ឈាន ដោយការធ្វើទុកក្នុងចិត្តថា អ្វីតិចតួច មិនមាន ។ បេ ។ ភិក្ខុ ព្រោះកន្លងបង់អាកិញ្ចញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង ក៏បានដល់នេវសញ្ញានាសញ្ញាយតនជ្ឈាន ។ បេ ។ ភិក្ខុ ព្រោះកន្លងបង់នេវសញ្ញានាសញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង ក៏បានដល់សញ្ញាវេទយិតនិរោធ អាសវៈរបស់ភិក្ខុនោះ ក៏អស់រលីងទៅ ព្រោះឃើញដោយប្រាជ្ញា ក្នុងសម័យណា ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យនោះ ភិក្ខុនោះ តថាគតហៅថា បានធ្វើមារឲ្យផុតដើង ហៅថា រំខ្ទប់ភ្នែកមារឲ្យជិតស្ងុង ហៅថា បានដល់នូវការមិនឃើញនៃមារ ហៅថា ឆ្លងផុតនូវតណ្ហាក្នុងលោកហើយ ។

[៤០] ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យណា ដំរីឈ្មោលក្តី ដំរីញីក្តី ដំរីស្ទាវក្តី កូនដំរីក្តី ទៅកាត់ចុងស្មៅមុនៗ ជាងដំរីដ៏ប្រសើរ ដែលនៅក្នុងព្រៃ ខ្វល់ខ្វាយរកចំណី ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ដំរីដ៏ប្រសើរនៅក្នុងព្រៃ តែងធុញទ្រាន់ នឿយណាយ ជិនឆ្អន់

យស្មឹ ភិក្ខវេ សមយេ អារញ្ញកស្ស នាគស្ស គោចរបសុតស្ស ហត្ថីបិ ហត្ថិនិយោបិ ហត្ថិកុឡភាបិ ហត្ថិច្ឆាបាបិ ឧភគ្គោភគ្គំ សាខាភង្គំ ខាទន្តិ តេន ភិក្ខវេ អារញ្ញកោ នាគោ អដ្ដីយតិ ហរាយតិ ជិគុច្ឆតិ យស្មឹ ភិក្ខវេ សមយេ អារញ្ញកស្ស នាគស្ស ឱគាហំ ឱតិណ្ណស្ស ហត្ថីបិ ហត្ថិនិយោបិ ហត្ថិកុឡភាបិ ហត្ថិច្ឆាបាបិ បុរតោ បុរតោ គន្ត្វា សោណ្ឌាយ ឧទកំ អាលោឡេន្តិ តេន ភិក្ខវេ អារញ្ញកោ នាគោ អដ្ដីយតិ ហរាយតិ ជិគុច្ឆតិ យស្មឹ ភិក្ខវេ សមយេ អារញ្ញកស្ស នាគស្ស ឱគាហំ ឱតិណ្ណស្ស ហត្ថិនិយោ កាយំ ឧបឃំសន្តិយោ[១] គច្ឆន្តិ តេន ភិក្ខវេ អារញ្ញកោ នាគោ អដ្ដីយតិ ហរាយតិ ជិគុច្ឆតិ ។ តស្មឹ ភិក្ខវេ សមយេ អារញ្ញកស្ស នាគស្ស ឯវំ ហោតិ អហំ ខោ ឯតរហិ អាកិណ្ណោ វិហរាមិ ហត្ថីហិ ហត្ថិនីហិ ហត្ថិកុឡភេហិ ហត្ថិច្ឆាបេហិ ឆិន្នគ្គានិ ចេវ តិណានិ ខាទាមិ

១ ឱ. ម. ឧបនិឃំសន្តិយោ ។

ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យណា ដំរីឈ្មោលក្តី ដំរីញីក្តី ដំរីស្ទាវក្តី កូនដំរីក្តី ទំពាស៊ីមែកឈើបាក់ ដែលដំរីដ៏ប្រសើរ នៅក្នុងព្រៃ ខ្វល់ខ្វាយរកចំណី បានកាច់បំបាក់ខ្ទេចខ្ទីហើយ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ដំរីដ៏ប្រសើរ នៅក្នុងព្រៃ តែងធុញទ្រាន់ នឿយណាយ ជិនឆ្អន់ ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យណា ដំរីដ៏ប្រសើរ នៅក្នុងព្រៃ ចុះកាន់កំពង់ទឹក ដំរីឈ្មោលក្តី ដំរីញីក្តី ដំរីស្ទាវក្តី កូនដំរីក្តី តែងទៅកូរទឹកដោយប្រមោយមុនៗ (ជាងដំរីនោះ) ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ដំរីដ៏ប្រសើរ នៅក្នុងព្រៃ រមែងធុញទ្រាន់ នឿយណាយ ជិនឆ្អន់ ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យណា ដំរីដ៏ប្រសើរ នៅក្នុងព្រៃ ចុះកាន់កំពង់ទឹក ដំរីញីទាំងឡាយ តែងដើរជជុសកាយ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ដំរីដ៏ប្រសើរ នៅក្នុងព្រៃ រមែងធុញទ្រាន់ នឿយណាយ ជិនឆ្អន់ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យនោះ ដំរីដ៏ប្រសើរ នៅក្នុងព្រៃ មានសេចក្តីត្រិះរិះយ៉ាងនេះថា ក្នុងកាលឥឡូវនេះ អញនៅច្រឡូកច្រឡំ ដោយដំរីឈ្មោល ដំរីញី ដំរីស្ទាវ កូនដំរី អញតែងទំពាស៊ីស្មៅ ដែលដំរីទាំងនោះកាត់ចុងផង

១៦៩



ឱភគ្គោភគ្គញ្ច មេ សាខាភង្គំ ខាទិតំ អាវិលានិ ច បានីយានិ បិវាមិ ឱគាហាបិ ច មេ ឧត្តិណ្ណស្ស ហត្ថិនិយោ កាយំ ឧបឃំសន្តិយោ គច្ឆន្តិ យន្នូនាហំ ឯកោ គណស្មា វូបកដ្ឋោ វិហរេយ្យន្តិ ។ សោ អបរេន សមយេន ឯកោ គណស្មា វូបកដ្ឋោ វិហរតិ អច្ឆិន្នគ្គានិ ចេវ តិណានិ ខាទតិ ន ឱភគ្គោភគ្គញ្ច សាខាភង្គំ ខាទតិ អនាវិលានិ ច បានីយានិ បិវតិ ឱគាហាបិ ចស្ស ឧត្តិណ្ណស្ស ហត្ថិនិយោ កាយំ ន ឧបឃំសន្តិយោ គច្ឆន្តិ ។ តស្មឹ ភិក្ខវេ សមយេ អារញ្ញកស្ស នាគស្ស ឯវំ ហោតិ អហំ ខោ បុព្វេ អាកិណ្ណោ វិហាសឹ ហត្ថីហិ ហត្ថិនីហិ ហត្ថិកុឡភេហិ ហត្ថិច្ឆាបេហិ ឆិន្នគ្គានិ ចេវ តិណានិ ខាទឹ ឱភគ្គោភគ្គញ្ច មេ សាខាភង្គំ ខាទិតំ អាវិលានិ ច បានីយានិ អបាសឹ[១] ឱគាហា[២] ច មេ ឧត្តិណ្ណស្ស ហត្ថិនិយោ កាយំ ឧបឃំសន្តិយោ អគមំសុ សោម្ហិ ឯតរហិ ឯកោ គណស្មា វូបកដ្ឋោ វិហរាមិ

១ ឱ. ម. អបាយឹ ។ ២ ឱ. ឱគាហញ្ច ។

អញទំពាស៊ីមែកឈើបាក់ ដែលដំរីទាំងនោះ កាច់បំបាក់ខ្ទេចខ្ទីហើយផង អញផឹកទឹកដ៏ល្អក់ផង កាលដែលអញឡើងអំពីកំពង់ទឹក ដំរីញីទាំងឡាយ តែងដើរជជុសកាយផង បើដូច្នោះ គួរតែអញគេចចេញចាកហ្វូងទៅនៅតែម្នាក់ឯង ។ ក្នុងសម័យខាងក្រោយមក ដំរីនោះក៏គេចចេញចាកហ្វូង ទៅនៅតែម្នាក់ឯង ក៏ទំពាស៊ីនូវស្មៅមិនរេចចុងផង មិនទំពាស៊ីមែកឈើបាក់ ដែលដំរីទាំងនោះ កាច់បំបាក់ខ្ទេចខ្ទីហើយផង ផឹកទឹកមិនល្អក់ផង កាលដែលឡើងអំពីកំពង់ទឹក ដំរីញីទាំងឡាយមិនបានដើរជជុសកាយផង ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យនោះ ដំរីដ៏ប្រសើរនៅក្នុងព្រៃ មានសេចក្តីត្រិះរិះយ៉ាងនេះថា ក្នុងកាលពីដើម អញនៅច្រឡូកច្រឡំ ដោយដំរីឈ្មោល ដំរីញី ដំរីស្ទាវ កូនដំរី អញទំពាស៊ីនូវស្មៅដែលដំរីទាំងនោះ កាត់ចុងហើយផង អញទំពាស៊ីនូវមែកឈើបាក់ដែលដំរីទាំងនោះ កាច់បំបាក់ខ្ទេចខ្ទីហើយផង អញផឹកទឹកល្អក់ផង កាលដែលអញឡើងអំពីកំពង់ទឹក ដំរីញីទាំងឡាយ ដើរជជុសកាយផង ឥឡូវនេះ អញនោះ ចៀសចេញចាកហ្វូងមកនៅតែម្នាក់ឯង

អច្ឆិន្នគ្គានិ ចេវ តិណានិ ខាទាមិ ឱភគ្គោភគ្គញ្ច មេ សាខាភង្គំ ន ខាទិតំ[១] អនាវិលានិ ច បានីយានិ បិវាមិ ឱគាហាបិ ច មេ ឧត្តិណ្ណស្ស ន ហត្ថិនិយោ កាយំ ឧបឃំសន្តិយោ គច្ឆន្តីតិ ។ សោ សោណ្ឌាយ សាខាភង្គំ ភញ្ជិត្វា សាខាភង្គេន កាយំ បរិមជ្ជិត្វា អត្តមនោ កណ្ឌុំ សំហនតិ ។ ឯវមេវ ខោ ភិក្ខវេ យស្មឹ សមយេ ភិក្ខុ អាកិណ្ណោ វិហរតិ ភិក្ខូហិ ភិក្ខុនីហិ ឧបាសកេហិ ឧបាសិកាហិ រញ្ញា រាជមហាមត្តេហិ តិត្ថិយេហិ តិត្ថិយសាវកេហិ តស្មឹ សមយេ ភិក្ខវេ ភិក្ខុស្ស ឯវំ ហោតិ អហំ ខោ ឯតរហិ អាកិណ្ណោ វិហរាមិ ភិក្ខូហិ ភិក្ខុនីហិ ឧបាសកេហិ ឧបាសិកាហិ រញ្ញា រាជមហាមត្តេហិ តិត្ថិយេហិ តិត្ថិយសាវកេហិ យន្នូនាហំ ឯកោ គណស្មា វូបកដ្ឋោ វិហរេយ្យន្តិ ។ សោ វិវិត្តំ សេនាសនំ ភជតិ អរញ្ញំ រុក្ខមូលំ បព្វតំ

---

១ ឱ. ន ខាទន្តិ ។ ម. ឯវំ ។

បានទំពាស៊ីនូវស្មៅមិនបានរេចចុងផង អញមិនទំពាស៊ីមែកឈើបាក់ដែលដំរីទាំងនោះ កាច់បំបាក់ខ្ទេចខ្ទីហើយផង អញផឹកទឹកមិនល្អក់ផង កាលដែលអញឡើងអំពីកំពង់ទឹក ដំរីញីទាំងឡាយ មិនដើរដងុសកាយអញផង ។ ដំរីនោះ ក៏កាច់បំបាក់មែកឈើដោយប្រមោយ ហើយយកមែកឈើបាក់នោះមកបបោសកាយ មានចិត្តត្រេកអរ កម្ចាត់បង់សេចក្តីស្ញៀបរមាស់ ។ ម្នាលភិក្ខុទាំងឡាយ រឿងនេះមានឧបមេយ្យដូចជា ភិក្ខុដែលនៅច្រឡូកច្រឡំ ដោយពួកភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ព្រះរាជា រាជមហាមាត្យ តិរ្ថិយ និងសាវ័កនៃតិរ្ថិយ ក្នុងសម័យណា ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យនោះ ភិក្ខុរមែងមានសេចក្តីត្រិះរិះយ៉ាងនេះថា ឥឡូវនេះ អញនៅច្រឡូកច្រឡំដោយពួកភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ព្រះរាជា រាជមហាមាត្យ តិរ្ថិយនិងសាវ័កនៃតិរ្ថិយ បើដូច្នោះ គួរតែអញគេចចេញចាកពួកទៅនៅតែម្នាក់ឯង ។ ភិក្ខុនោះ រមែងគប់រកនូវសេនាសនៈស្ងាត់ គឺព្រៃ គល់ឈើ ភ្នំ

១៧១



កណ្ហារំ គិរិគុហំ សុសានំ វនបត្ថំ អព្ភោកាសំ បលាលបុញ្ជំ សោ អរញ្ញគតោ វា រុក្ខមូលគតោ វា សុញ្ញាគារគតោ វា និសីទតិ បល្លង្កំ អាភុជិត្វា ឧជុំ កាយំ បណិធាយ បរិមុខំ សតឹ ឧបដ្ឋបេត្វា សោ អភិជ្ឈំ លោកេ បហាយ វិគតាភិជ្ឈេន ចេតសា វិហរតិ អភិជ្ឈាយ ចិត្តំ បរិសោធេតិ ។ ព្យាបាទប្បទោសំ បហាយ អព្យាបន្នចិត្តំ វិហរតិ សព្វប្បាណភូតហិតានុកម្បី ព្យាបាទប្បទោសា ចិត្តំ បរិសោធេតិ ។ ថីនមិទ្ធំ បហាយ វិគតថីនមិទ្ធោ វិហរតិ អាលោកសញ្ញី សតោ សម្បជានោ ថីនមិទ្ធា ចិត្តំ បរិសោធេតិ ។ ឧទ្ធច្ចកុក្កុច្ចំ បហាយ អនុទ្ធតោ វិហរតិ អជ្ឈត្តំ វូបសន្តចិត្តោ ឧទ្ធច្ចកុក្កុច្ចា ចិត្តំ បរិសោធេតិ ។ វិចិកិច្ឆំ បហាយ តិណ្ណវិចិកិច្ឆោ វិហរតិ អកថំកថី កុសលេសុ វិចិកិច្ឆាយ ចិត្តំ បរិសោធេតិ ។ សោ ឥមេ បញ្ច នីវរណេ បហាយ ចេតសោ ឧបក្កិលេសេ បញ្ញាយ ទុព្វលីករណេ

ញកភ្នំ គុហាភ្នំ ព្រៃស្មសាន ព្រៃស្រោង ទីវាល គំនរចំបើង ភិក្ខុនោះ ទៅនៅក្នុងព្រៃក្តី នៅក្នុងម្លប់ឈើក្តី នៅក្នុងផ្ទះស្ងាត់ក្តី តែង អង្គុយពែនភ្នែន តម្រង់កាយឲ្យត្រង់ហើយ តាំងស្មារតីឲ្យឆ្ពោះមុខទៅ កាន់កម្មដ្ឋាន ភិក្ខុនោះ លះបង់អភិជ្ឈាក្នុងលោក ក៏មានចិត្តប្រាស ចាកអភិជ្ឈា ធ្វើចិត្តឲ្យបរិសុទ្ធចាកអភិជ្ឈា ។ លះបង់នូវការប្រទូស្តគឺ ព្យាបាទ ជាអ្នកមិនមានចិត្តព្យាបាទ ជាអ្នកអនុគ្រោះដោយប្រយោជន៍ ដល់សត្វទាំងពួង ធ្វើចិត្តឲ្យស្អាតចាកការប្រទូស្តគឺព្យាបាទ ។ លះបង់ ថីនមិទ្ធ ជាអ្នកប្រាសចាកថីនមិទ្ធ មានសេចក្តីសម្គាល់នូវពន្លឺ មាន ស្មារតី ជាអ្នកដឹងខ្លួន ធ្វើចិត្តឲ្យស្អាតចាកថីនមិទ្ធ ។ លះបង់ឧទ្ធច្ចកុក្កុច្ចៈ ជាអ្នកមានចិត្តមិនរវើរវាយ មានចិត្តស្ងប់រម្ងាប់ខាងក្នុងសន្តាន ធ្វើចិត្ត ឲ្យស្អាតចាកឧទ្ធច្ចកុក្កុច្ចៈ ។ លះបង់វិចិកិច្ឆា ជាអ្នកឆ្លងផុតវិចិកិច្ឆា មិន មានសេចក្តីងឿងឆ្ងល់ ក្នុងកុសលធម៌ទាំងឡាយ ហើយធ្វើចិត្តឲ្យស្អាត ចាកវិចិកិច្ឆា ។ ភិក្ខុនោះ លុះលះបង់នូវនីវរណៈទាំង ៥ ប្រការដែល ជាឧបក្កិលេសនៃចិត្ត ជាធម៌ធ្វើប្រាជ្ញា ឲ្យមានកម្លាំងថយនេះហើយ

១៧២



វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ សវិតក្កំ សវិចារំ វិវេកជំ បីតិសុខំ បឋមជ្ឈានំ ឧបសម្បជ្ជ វិហរតិ សោ អត្តមនោ កណ្ឌុំ សំហនតិ ។ វិតក្កវិចារានំ វូបសមា ។ បេ ។ ទុតិយជ្ឈានំ តតិយជ្ឈានំ ចតុត្ថជ្ឈានំ ឧបសម្បជ្ជ វិហរតិ សោ អត្តមនោ កណ្ឌុំ សំហនតិ ។ សព្វសោ រូបសញ្ញានំ សមតិក្កមា បដិឃសញ្ញានំ អត្ថង្គមា នានត្តសញ្ញានំ អមនសិការា អនន្តោ អាកាសោតិ អាកាសានញ្ចាយតនំ ឧបសម្បជ្ជ វិហរតិ សោ អត្តមនោ កណ្ឌុំ សំហនតិ ។ សព្វសោ អាកាសានញ្ចាយតនំ សមតិក្កម្ម អនន្តំ វិញ្ញាណន្តិ វិញ្ញាណញ្ចាយតនំ ឧបសម្បជ្ជ វិហរតិ ។ បេ ។ សព្វសោ វិញ្ញាណញ្ចាយតនំ សមតិក្កម្ម នត្ថិ កិញ្ចីតិ អាកិញ្ចញ្ញាយតនំ ឧបសម្បជ្ជ វិហរតិ សព្វសោ អាកិញ្ចញ្ញាយតនំ សមតិក្កម្ម នេវសញ្ញានាសញ្ញាយតនំ ឧបសម្បជ្ជ វិហរតិ សព្វសោ នេវសញ្ញានាសញ្ញាយតនំ សមតិក្កម្ម សញ្ញាវេទយិតនិរោធំ ឧបសម្បជ្ជ វិហរតិ

ក៏ស្ងប់ស្ងាត់ចាកកាមទាំងឡាយ ស្ងប់ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ហើយបានដល់បឋមជ្ឈាន ប្រកបដោយវិតក្កៈនិងវិចារៈ មានបីតិនិងសុខៈ ដែលកើតអំពីសេចក្ដីស្ងប់ស្ងាត់ ភិក្ខុនោះ រមែងមានចិត្តត្រេកអរ កម្ចាត់បង់នូវសេចក្ដីស្មៀបរមាស់ ។ ព្រោះរម្ងាប់បង់នូវវិតក្កៈនិងវិចារៈ ។ បេ ។ ក៏បានដល់ទុតិយជ្ឈាន តតិយជ្ឈាន ចតុត្ថជ្ឈាន ភិក្ខុនោះ រមែងមានចិត្តត្រេកអរ កម្ចាត់បង់នូវសេចក្ដីស្មៀបរមាស់ចេញ ។ ព្រោះកន្លងបង់នូវរូបសញ្ញា ព្រោះរលត់បដិឃសញ្ញា ព្រោះមិនធ្វើទុកក្នុងចិត្តនូវនានត្តសញ្ញាដោយប្រការទាំងពួង ក៏បានដល់អាកាសានញ្ចាយតនជ្ឈានដោយធ្វើទុកក្នុងចិត្តថា អាកាសមិនមានទីបំផុត ភិក្ខុនោះ រមែងមានចិត្តត្រេកអរ កម្ចាត់បង់នូវសេចក្ដីស្មៀបរមាស់ ។ ព្រោះកន្លងបង់នូវអាកាសានញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ក៏បានដល់វិញ្ញាណញ្ចាយតនជ្ឈាន ដោយការធ្វើទុកក្នុងចិត្តថា វិញ្ញាណមិនមានទីបំផុត ។ បេ ។ ព្រោះកន្លងបង់នូវវិញ្ញាណញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ក៏បានដល់អាកិញ្ចញ្ញាយតនជ្ឈាន ដោយការធ្វើទុកក្នុងចិត្តថា អ្វីតិចតួចមិនមាន ព្រោះកន្លងបង់នូវអាកិញ្ចញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង ក៏បានដល់នេវសញ្ញានាសញ្ញាយតនជ្ឈាន ព្រោះកន្លងបង់នូវនេវសញ្ញានាសញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង ក៏បានដល់សញ្ញាវេទយិតនិរោធ

១៧៣



បញ្ញាយបស្ស ទិស្វា អាសវា បរិក្ខីណា ហោន្តិ សោ អត្តមនោ កណ្ឌុំ សំហនតីតិ ។

[៤១] ឯកំ សមយំ ភគវា មល្លេសុ វិហរតិ ឧរុវេលកប្បំ នាម មល្លានំ និគមោ ។ អថខោ ភគវា បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរ-មាទាយ ឧរុវេលកប្បំ បិណ្ឌាយ បាវិសិ ។ ឧរុវេ-លកប្បេ បិណ្ឌាយ ចរិត្វា បច្ឆាភត្តំ បិណ្ឌបាតប្ប-ដិក្កន្តោ អាយស្មន្តំ អានន្ទំ អាមន្តេសិ ឥធេវ តាវ ត្វំ អានន្ទ ហោហិ យាវាហំ មហាវនំ អជ្ឈោគាហាមិ ទិវាវិហារាយាតិ ។ ឯវំ ភន្តេតិ ខោ អាយស្មា អានន្ទោ ភគវតោ បច្ចស្សោសិ ។ អថខោ ភគវា មហាវនំ អជ្ឈោគាហេត្វា អញ្ញតរស្មឹ រុក្ខមូលេ ទិវាវិហារំ និសីទិ ។

*អាសវៈទាំងឡាយ របស់ភិក្ខុនោះ ក៏អស់រលីងទៅ ព្រោះយល់ឃើញដោយប្រាជ្ញា ភិក្ខុនោះ រមែងមានចិត្តត្រេកអរ កម្ចាត់បង់នូវសេចក្តីស្មៀបរមាស់បាន ។*

[៤១] *សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅ ក្នុងឧរុវេលកប្បនិគមរបស់ពួកមល្លជន ក្នុងដែលមល្លៈ ។ គ្រានោះឯង ព្រះដ៏មានព្រះភាគទ្រង់ស្បង់ ប្រដាប់បាត្រនិងចីវរ ក្នុងបុព្វណ្ហសម័យ ហើយស្តេចចូលទៅកាន់ឧរុវេលកប្បនិគម ដើម្បីបិណ្ឌបាត ។ លុះស្តេចទៅបិណ្ឌបាតក្នុងឧរុវេលកប្បនិគម ហើយត្រឡប់មកអំពីបិណ្ឌបាត ក្នុងកាលខាងក្រោយកត្តវិញ បានត្រាស់នឹងព្រះអានន្ទដ៏មានអាយុថា ម្នាលអានន្ទអ្នកចូរនៅ ក្នុងទីនេះសិន ទម្រាំតថាគតចូលទៅកាន់មហាវ័ន (ព្រៃធំ) ដើម្បីសម្រាកក្នុងវេលាថ្ងៃ ។ ព្រះអានន្ទដ៏មានអាយុ បានទទួលស្តាប់ព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ។ លំដាប់នោះ ព្រះដ៏មានព្រះភាគ ទ្រង់ស្តេចចូលទៅកាន់មហាវ័ន ហើយគង់សម្រាកក្នុងវេលាថ្ងៃក្នុងម្លប់ឈើមួយ ។*

អថខោ តបុស្សោ គហបតិ យេនាយស្មា អានន្ទោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ អានន្ទំ អភិវា-ទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ តបុស្សោ គហបតិ អាយស្មន្តំ អានន្ទំ ឯតទវោច មយំ ភន្តេ អានន្ទ គិហី កាមភោគិនោ កាមារាមា កាមរតា កាមសមុទិតា តេសំ នោ ភន្តេ អម្ហាកំ គិហីនំ កាមភោគីនំ កាមារាមានំ កាមរតានំ កាមសមុទិតានំ បបាតោ វិយ ខាយតិ យទិទំ នេក្ខម្មំ សុតមេតំ ភន្តេ ឥមស្មឹ ធម្មវិនយេ ទហរានំ ទហរានំ ភិក្ខូនំ នេក្ខម្មេ ចិត្តំ បក្ខន្ទតិ បសីទតិ សន្តិដ្ឋតិ វិមុច្ចតិ ឯតំ សន្តន្តិ បស្សតោ តយិទំ ភន្តេ ឥមស្មឹ ធម្មវិនយេ ភិក្ខូនំ ពហុនា ជនេន វិសភាគោ យទិទំ នេក្ខម្មន្តិ ។

លំដាប់នោះ តបុស្សគហបតី បានចូលទៅរកព្រះអានន្ទដ៏មានអាយុ លុះចូលទៅដល់ ថ្វាយបង្គំព្រះអានន្ទដ៏មានអាយុ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះតបុស្សគហបតី អង្គុយក្នុងទីសមគួរហើយ បានទូលសួរព្រះអានន្ទដ៏មានអាយុដូច្នេះថា បពិត្រព្រះអានន្ទដ៏ចម្រើន យើងជាគ្រហស្ថ ជាអ្នកបរិភោគកាម មានកាមជាគ្រឿងត្រេកអរ ត្រេកអរក្នុងកាម រីករាយក្នុងកាម បពិត្រលោកម្ចាស់ដ៏ចម្រើន នេក្ខម្មៈគឺបព្វជ្ជា យើងជាគ្រហស្ថ ជាអ្នកបរិភោគកាម មានកាមជាគ្រឿងត្រេកអរ ត្រេកអរក្នុងកាម រីករាយក្នុងកាម យល់ឃើញប្រាកដថាដូចជាជ្រោះធំ បពិត្រលោកម្ចាស់ដ៏ចម្រើន យើងខ្ញុំបានឮថា ពួកភិក្ខុកម្លោះៗ ក្នុងធម្មវិន័យនេះ ដែលយល់ឃើញថានេក្ខម្មៈគឺបព្វជ្ជានុ៎ះជាធម្មជាតស្ងប់ដូច្នេះ ចិត្តក៏ស្ទុះទៅ ជ្រះថ្លា តាំងនៅ ចុះស៊ប់ក្នុងនេក្ខម្មៈគឺបព្វជ្ជា បពិត្រលោកដ៏ចម្រើន នេក្ខម្មៈគឺបព្វជ្ជា ដែលជារបស់ពួកភិក្ខុក្នុងធម្មវិន័យនេះ ជាទំនាស់នឹងជន (ជាគ្រហស្ថ) ច្រើនគ្នា ។

អត្ថិ ខោ ឯតំ គហបតិ កថាចាភតំ ភគវន្តំ ទស្សនាយ អាយាម គហបតិ យេន ភគវា តេនុបសង្កមិស្សាម ឧបសង្កមិត្វា ភគវតោ ឯតមត្ថំ អារោចេស្សាម យថា នោ ភគវា ព្យាករិស្សតិ តថា ការិស្សាមាតិ ។ ឯវំ ភន្តេតិ ខោ តបុស្សោ គហបតិ អាយស្មតោ អានន្ទស្ស បច្ចស្សោសិ ។ អថខោ អាយស្មា អានន្ទោ តបុស្សេន គហបតិនា សទ្ធឹ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា អានន្ទោ ភគវន្តំ ឯតទវោច អយំ ភន្តេ តបុស្សោ គហបតិ ឯវមាហ មយំ ភន្តេ អានន្ទ គិហី កាមភោគិនោ កាមារាមា កាមរតា កាមសម្មុទិតា តេសំ នោ ភន្តេ អម្ហាកំ គិហីនំ កាមភោគីនំ កាមារាមានំ កាមរតានំ កាមសម្មុទិតានំ បចាតោ វិយ ខាយតិ យទិទំ នេក្ខម្មំ

ព្រះអានន្ទដ៏មានអាយុតបថា ម្នាលគហបតី នេះពាក្យជាប្រធាន ដែលនាំឲ្យជួបព្រះដ៏មានព្រះភាគ ម្នាលគហបតី យើងមកទៅ យើងនឹងចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ នឹងក្រាបទូលរឿងនុ៎ះដល់ព្រះដ៏មានព្រះភាគ បើព្រះដ៏មានព្រះភាគទ្រង់ព្យាករដល់យើងយ៉ាងណា យើងនឹងធ្វើតាមយ៉ាងនោះ ។ ឯតបុស្សគហបតីទទួលស្តាប់ព្រះអានន្ទដ៏មានអាយុថា ព្រះករុណាលោកម្ចាស់ដ៏ចម្រើន ។ លំដាប់នោះ ព្រះអានន្ទដ៏មានអាយុ បានចូលទៅគាល់ព្រះដ៏មានព្រះភាគ ជាមួយនឹងតបុស្សគហបតី លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយគង់នៅ ក្នុងទីដ៏សមគួរ ។ លុះព្រះអានន្ទដ៏មានអាយុ គង់នៅ ក្នុងទីដ៏សមគួរហើយ បានក្រាបទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន តបុស្សគហបតីនេះ បាននិយាយនឹងខ្ញុំព្រះអង្គយ៉ាងនេះថា បពិត្រព្រះអានន្ទដ៏ចម្រើន យើងជាគ្រហស្ថ ជាអ្នកបរិភោគកាម មានកាមជាគ្រឿងត្រេកអរ ត្រេកអរក្នុងកាម រីករាយក្នុងកាម បពិត្រលោកម្ចាស់ដ៏ចម្រើន នេក្ខម្មៈគឺបព្វជ្ជា យើងជាគ្រហស្ថ ជាអ្នកបរិភោគកាម មានកាមជាគ្រឿងត្រេកអរ ត្រេកអរក្នុងកាម រីករាយក្នុងកាម យល់ឃើញប្រាកដថា ដូចជាជ្រោះធំ

១៧៦



សុតមេតំ ភន្តេ ឥមស្មឹ ធម្មវិនយេ ទហរានំ ទហរានំ ភិក្ខូនំ នេក្ខម្មេ ចិត្តំ បក្ខន្ទតិ បសីទតិ សន្តិដ្ឋតិ វិមុច្ចតិ ឯតំ សន្តន្តិ បស្សតោ តយិទំ ភន្តេ ឥមស្មឹ ធម្មវិនយេ ភិក្ខូនំ ពហុនា ជនេន វិសភាគោ យទិទំ នេក្ខម្មន្តិ ។

ឯវមេតំ អានន្ទ ឯវមេតំ អានន្ទ មយ្ហម្បិ ខោ អានន្ទ បុព្វេវ សម្ពោធា អនភិសម្ពុទ្ធស្ស ពោធិសត្តស្សេវ សតោ ឯតទហោសិ សាធុ នេក្ខម្មំ សាធុ បវិវេកោតិ ។ តស្ស មយ្ហំ អានន្ទ នេក្ខម្មេ ចិត្តំ ន បក្ខន្ទតិ នប្បសីទតិ ន សន្តិដ្ឋតិ ន វិមុច្ចតិ ឯតំ សន្តន្តិ បស្សតោ តស្ស មយ្ហំ អានន្ទ ឯតទហោសិ កោ នុ ខោ ហេតុ កោ បច្ចយោ យេន មេ នេក្ខម្មេ ចិត្តំ ន បក្ខន្ទតិ នប្បសីទតិ ន សន្តិដ្ឋតិ ន វិមុច្ចតិ ឯតំ សន្តន្តិ បស្សតោ

បពិត្រលោកម្ចាស់ដ៏ចម្រើន យើងខ្ញុំបានឮថា ពួកភិក្ខុកំលោះៗ ក្នុងធម្មវិន័យនេះ ដែលយល់ឃើញថា នេក្ខម្មៈគឺបព្វជ្ជានុ៎ះ ជាធម្មជាតស្ងប់ដូច្នេះ ចិត្តក៏ស្ទុះទៅ ជ្រះថ្លា តាំងនៅ ចុះស៊ប់ក្នុងនេក្ខម្មៈគឺបព្វជ្ជា បពិត្រលោកម្ចាស់ដ៏ចម្រើន នេក្ខម្មៈគឺបព្វជ្ជា ដែលជារបស់ពួកភិក្ខុក្នុងធម្មវិន័យនេះ ជាទំនាស់នឹងជន (ជាគ្រហស្ថ) ច្រើនគ្នាណាស់ ។

ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលអានន្ទ ដំណើរនោះយ៉ាងនេះឯង ម្នាលអានន្ទ ដំណើរនោះយ៉ាងនេះឯង ម្នាលអានន្ទ សូម្បីតថាគតកាលនៅជាពោធិសត្វ មិនទាន់ត្រាស់ដឹង ក្នុងកាលមុន អំពីកាលជាទីត្រាស់ដឹងនៅឡើយ គង់មានសេចក្តីយល់ឃើញថា នេក្ខម្មៈជាគុណជាតប្រពៃ សេចក្តីស្ងប់ស្ងាត់ ជាគុណជាតប្រពៃ ដូច្នេះដែរ ។ ម្នាលអានន្ទ តែកាលតថាគត យល់ឃើញថានេក្ខម្មៈនុ៎ះ ជារបស់ស្ងប់ដូច្នេះហើយ ចិត្តក៏មិនស្ទុះទៅ មិនជ្រះថ្លា មិនតាំងនៅ មិនចុះស៊ប់ក្នុងនេក្ខម្មៈឡើយ ម្នាលអានន្ទ ទើបតថាគតមានសេចក្តីងឿងឆ្ងល់ថា ចុះហេតុអ្វីបច្ច័យអ្វី បានជាកាលអញយល់ឃើញថានេក្ខម្មៈនុ៎ះ ជារបស់ស្ងប់ដូច្នេះហើយ ចិត្តក៏មិនស្ទុះទៅ មិនជ្រះថ្លា មិនតាំងនៅ មិនចុះស៊ប់ក្នុងនេក្ខម្មៈ

១៧៧



តស្ស មយ្ហំ អានន្ទ ឯតទហោសិ កាមេសុ ខោ មេ អាទីនវោ អទិដ្ឋោ សោ ច មេ អពហុលីកតោ នេក្ខម្មេ ច អានិសំសោ អនធិគតោ សោ ច មេ អនាសេវិតោ តស្មា មេ នេក្ខម្មេ ចិត្តំ ន បក្ខន្ទតិ នប្បសីទតិ ន សន្តិដ្ឋតិ ន វិមុច្ចតិ ឯតំ សន្តន្តិ បស្សតោ តស្ស មយ្ហំ អានន្ទ ឯតទហោសិ សចេ ខោ អហំ កាមេសុ អាទីនវំ ទិស្វា តំ ពហុលី-ករេយ្យំ នេក្ខម្មេ អានិសំសំ អធិគម្ម តមាសេវេយ្យំ ឋានំ ខោ បនេតំ វិជ្ជតិ យំ មេ នេក្ខម្មេ ចិត្តំ បក្ខន្ទេយ្យ បសីទេយ្យ សន្តិដ្ឋេយ្យ វិមុច្ចេយ្យ ឯតំ សន្តន្តិ បស្សតោ សោ ខោ អហំ អានន្ទ អបរេន សមយេន កាមេសុ អាទីនវំ ទិស្វា តំ ពហុល-មកាសឹ នេក្ខម្មេ អានិសំសំ អធិគម្ម តមាសេវឹ តស្ស មយ្ហំ អានន្ទ នេក្ខម្មេ ចិត្តំ បក្ខន្ទតិ បសីទតិ សន្តិដ្ឋតិ វិមុច្ចតិ ឯតំ សន្តន្តិ បស្សតោ

ម្នាលអានន្ទ តថាគតមានសេចក្តីយល់ឃើញដូច្នេះថា ឱទោសក្នុងកាមទាំងឡាយ អញមិនទាន់ឃើញទេ ទាំងទោសនោះ អញមិនទាន់ធ្វើឲ្យច្រើន អានិសង្សក្នុងនេក្ខម្មៈ អញមិនទាន់បានទេ ទាំងអានិសង្សនោះ អញមិនទាន់សេពគប់ទេតើ បានជាកាលអញយល់ឃើញថា នេក្ខម្មៈនុ៎ះ ជារបស់ស្ងប់ដូច្នេះហើយ ចិត្តក៏នៅតែមិនស្ទុះទៅ មិនជ្រះថ្លា មិនតាំងនៅ មិនចុះស៊ប់ ក្នុងនេក្ខម្មៈ ម្នាលអានន្ទ ទើបតថាគត មានសេចក្តីត្រិះរិះដូច្នេះថា បើអញឃើញទោស ក្នុងកាមទាំងឡាយហើយ គប្បីធ្វើនូវការឃើញទោសនោះឲ្យច្រើន បើបានអានិសង្ស ក្នុងនេក្ខម្មៈហើយ គប្បីសេពគប់នូវអានិសង្សនោះ ហេតុនុ៎ះតែងមានជាប្រាកដត្រង់ពាក្យថា កាលអញយល់ឃើញថា នេក្ខម្មៈនុ៎ះ ជារបស់ស្ងប់ដូច្នេះហើយ ចិត្តគប្បីស្ទុះទៅ ជ្រះថ្លា តាំងនៅ ចុះស៊ប់ ក្នុងនេក្ខម្មៈបាន ម្នាលអានន្ទ លុះសម័យខាងក្រោយមក តថាគតនោះ ឃើញទោស ក្នុងកាមទាំងឡាយហើយ ក៏ធ្វើនូវការឃើញទោសនោះឲ្យច្រើន បានអានិសង្ស ក្នុងនេក្ខម្មៈហើយ ក៏សេពគប់អានិសង្សនោះ ម្នាលអានន្ទ កាលតថាគតយល់ឃើញថា នេក្ខម្មៈនុ៎ះ ជារបស់ស្ងប់ដូច្នេះ ចិត្តក៏ត្រឡប់ ជាស្ទុះទៅ ជ្រះថ្លា តាំងនៅ ចុះស៊ប់ ក្នុងនេក្ខម្មៈឡើង

សោ ខោ អហំ អានន្ទ វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ សវិតក្កំ សវិចារំ វិវេកជំ បីតិសុខំ បឋមជ្ឈានំ ឧបសម្បជ្ជ វិហរាមិ ។ តស្ស មយ្ហំ អានន្ទ ឥមិនា វិហារេន វិហរតោ កាមសហគតា សញ្ញាមនសិការា សមុទាចរន្តិ ស្វាស្ស មេ ហោតិ អាពាធោ សេយ្យថាបិ អានន្ទ សុខិនោ ទុក្ខំ ឧប្បជ្ជេយ្យ យាវទេវ អាពាធាយ ឯវមស្ស មេ កាមសហគតា សញ្ញាមនសិការា សមុទាចរន្តិ ស្វាស្ស មេ ហោតិ អាពាធោ ។

តស្ស មយ្ហំ អានន្ទ ឯតទហោសិ យន្នូនាហំ វិតក្កវិចារានំ វូបសមា ។ បេ ។ ទុតិយជ្ឈានំ ឧបសម្បជ្ជ វិហរេយ្យន្តិ ។ តស្ស មយ្ហំ អានន្ទ អវិតក្កេ ចិត្តំ ន បក្ខន្ទតិ នប្បសីទតិ ន សន្តិដ្ឋតិ ន វិមុច្ចតិ ឯតំ សន្តន្តិ បស្សតោ តស្ស មយ្ហំ អានន្ទ ឯតទហោសិ

ម្នាលអានន្ទ តថាគតនោះ ស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ហើយចូលកាន់បឋមជ្ឈាន ប្រកបដោយវិតក្កៈនិងវិចារៈ មានបីតិនិងសុខៈ កើតអំពីសេចក្តីស្ងប់ស្ងាត់ ។ ម្នាលអានន្ទ កាលតថាគត ប្រព្រឹត្តនៅដោយវិហារធម៌នេះ សញ្ញា (ការសម្គាល់) និងមនសិការៈ (ការធ្វើទុកក្នុងចិត្ត) ប្រកបដោយកាម ក៏ជ្រួលច្រាល់ឡើង ការជ្រួលច្រាល់នៃសញ្ញានិងមនសិការៈនោះ ទុកជាអាពាធរបស់តថាគត ម្នាលអានន្ទ សេចក្តីទុក្ខ គប្បីកើតឡើង ដល់បុគ្គលដែលធ្លាប់មានសេចក្តីសុខ សេចក្តីទុក្ខនោះ នឹងប្រព្រឹត្តទៅ ដើម្បីអាពាធ ជាកំណត់ មានឧបមាដូចម្តេចមិញ មានឧបមេយ្យដូចសញ្ញានិងមនសិការៈ របស់តថាគតប្រកបដោយកាម ដែលជ្រួលច្រាល់ឡើង ការជ្រួលច្រាល់នៃសញ្ញានិងមនសិការៈនោះ ទុកជាអាពាធរបស់តថាគតដូច្នោះឯង ។

ម្នាលអានន្ទ តថាគត មានសេចក្តីត្រិះរិះដូច្នេះថា បើដូច្នោះ គួរតែអញរម្ងាប់បង់នូវវិតក្កៈនិងវិចារៈ ។ បេ ។ ហើយចូលកាន់ទុតិយជ្ឈាន ។ ម្នាលអានន្ទ កាលតថាគតយល់ឃើញថា អវិតក្កជ្ឈាននុ៎ះ ជារបស់ស្ងប់ដូច្នេះហើយ ចិត្តក៏មិនស្ទុះទៅ មិនជ្រះថ្លា មិនតាំងនៅ មិនចុះស៊ប់ក្នុងអវិតក្កជ្ឈានឡើយ ម្នាលអានន្ទ ទើបតថាគតមានសេចក្តីជឿងឆ្ងល់ថា

១៧៩



កោ នុ ខោ ហេតុ កោ បច្ចយោ យេន មេ អវិតក្កេ ចិត្តំ ន បក្ខន្ទតិ នប្បសីទតិ ន សន្តិដ្ឋតិ ន វិមុច្ចតិ ឯតំ សន្តន្តិ បស្សតោ តស្ស មយ្ហំ អានន្ទ ឯតទហោសិ វិតក្កេ ខោ មេ អាទីនវោ អទិដ្ឋោ សោ ច មេ អពហុលីកតោ អវិតក្កេ ច អានិសំសោ អនធិគតោ សោ ច មេ អនាសេវិតោ តស្មា មេ អវិតក្កេ ចិត្តំ ន បក្ខន្ទតិ នប្បសីទតិ ន សន្តិដ្ឋតិ ន វិមុច្ចតិ ឯតំ សន្តន្តិ បស្សតោ តស្ស មយ្ហំ អានន្ទ ឯតទហោសិ សចេ ខោ អហំ វិតក្កេសុ អាទីនវំ ទិស្វា តំ ពហុលីករេយ្យំ អវិតក្កេ អានិសំសំ អធិគម្ម តមាសេវេយ្យំ ឋានំ ខោ បនេតំ វិជ្ជតិ យំ មេ អវិតក្កេ ចិត្តំ បក្ខន្ទេយ្យ បសីទេយ្យ សន្តិដ្ឋេយ្យ វិមុច្ចេយ្យ ឯតំ សន្តន្តិ បស្សតោ សោ ខោ អហំ អានន្ទ អបរេន សមយេន វិតក្កេសុ អាទីនវំ ទិស្វា តំ ពហុ-លមកាសឹ អវិតក្កេ អានិសំសំ អធិគម្ម តមាសេវឹ

ចុះហេតុអ្វី បច្ច័យអ្វី បានជាកាលអញយល់ឃើញថា អវិតក្កជ្ឈាននុ៎ះ ជារបស់ស្ងប់ដូច្នេះហើយ ចិត្តក៏មិនស្ទុះទៅ មិនជ្រះថ្លា មិនតាំងនៅ មិនចុះស៊ប់ ក្នុងអវិតក្កជ្ឈាន ម្នាលអានន្ទ តថាគត មានសេចក្តីយល់ឃើញដូច្នេះថា ឱ ទោសក្នុងវិតក្កជ្ឈានទាំងឡាយ អញមិនទាន់ឃើញ ទាំងទោសនោះអញមិនទាន់ធ្វើឲ្យច្រើន អានិសង្សក្នុងអវិតក្កជ្ឈាន អញមិនទាន់បានទេ ទាំងអានិសង្សនោះ អញមិនទាន់សេពគប់ទេតើ បានជាកាលអញយល់ឃើញថា អវិតក្កជ្ឈាននុ៎ះ ជារបស់ស្ងប់ដូច្នេះហើយ ចិត្តក៏នៅតែមិនស្ទុះទៅ មិនជ្រះថ្លា មិនតាំងនៅ មិនចុះស៊ប់ ក្នុងអវិតក្កជ្ឈាន ម្នាលអានន្ទ ទើបតថាគតមានសេចក្តីត្រិះរិះដូច្នេះថា បើអញឃើញទោស ក្នុងវិតក្កជ្ឈានទាំងឡាយហើយ គប្បីធ្វើនូវការឃើញទោសនោះឲ្យច្រើន បើបាននូវអានិសង្ស ក្នុងអវិតក្កជ្ឈានហើយ គប្បីសេពគប់នូវអានិសង្សនោះ ហេតុនេះ តែងមានជាប្រាកដ ត្រង់ពាក្យថា កាលអញយល់ឃើញថា អវិតក្កជ្ឈាននុ៎ះ ជារបស់ស្ងប់ដូច្នេះហើយ ចិត្តគប្បីស្ទុះទៅ ជ្រះថ្លា តាំងនៅ ចុះស៊ប់ក្នុងអវិតក្កជ្ឈានបាន ម្នាលអានន្ទ លុះសម័យខាងក្រោយមក តថាគតនោះឃើញនូវទោសក្នុងវិតក្កជ្ឈានទាំងឡាយហើយ ក៏ធ្វើនូវការឃើញទោសនោះ ឲ្យច្រើន បាននូវអានិសង្ស ក្នុងអវិតក្កជ្ឈានហើយ ក៏សេពគប់នូវអានិសង្សនោះ

តស្ស មយ្ហំ អានន្ទ អវិតក្កោ ចិត្តំ បក្ខន្ទតិ បសីទតិ សន្តិដ្ឋតិ វិមុច្ចតិ ឯតំ សន្តន្តិ បស្សតោ សោ ខោ អហំ អានន្ទ វិតក្កវិចារានំ វូបសមា ។ បេ ។ ទុតិយជ្ឈានំ ឧបសម្បជ្ជ វិហរាមិ ។ តស្ស មយ្ហំ អានន្ទ ឥមិនា វិហារេន វិហរតោ វិតក្កសហគតា សញ្ញាមនសិការា សមុទាចរន្តិ ស្វាស្ស មេ ហោតិ អាពាធោ សេយ្យថាបិ អានន្ទ សុខិនោ ទុក្ខំ ឧប្បជ្ជេយ្យ យាវទេវ អាពាធាយ ឯវមេវស្ស មេ វិតក្កសហគតា សញ្ញាមនសិការា សមុទាចរន្តិ ស្វាស្ស មេ ហោតិ អាពាធោ ។

តស្ស មយ្ហំ អានន្ទ ឯតទហោសិ យន្នូនាហំ បីតិយា ច វិរាគា ឧបេក្ខកោ វិហរេយ្យំ សតោ ច សម្បជានោ សុខញ្ច កាយេន បដិសំវេទេយ្យំ យន្តំ អរិយា អាចិក្ខន្តិ ឧបេក្ខកោ សតិមា សុខវិ-ហារីតិ តតិយជ្ឈានំ ឧបសម្បជ្ជ វិហរេយ្យន្តិ ។

ម្នាលអានន្ទ កាលតថាគតយល់ឃើញថា អវិតក្កជ្ឈាននុ៎ះ ជារបស់ស្ងប់ដូច្នេះ ចិត្តក៏ត្រឡប់ជាស្ទុះទៅ ជ្រះថ្លា តាំងនៅ ចុះស៊ប់ក្នុងអវិតក្កជ្ឈានឡើង ម្នាលអានន្ទ តថាគត ព្រោះរម្ងាប់នូវវិតក្កៈនិងវិចារៈ ។ បេ ។ ហើយចូលកាន់ទុតិយជ្ឈាន ។ ម្នាលអានន្ទ កាលតថាគត ប្រព្រឹត្តនៅដោយវិហារធម៌នេះ សញ្ញានិងមនសិការៈ ប្រកបដោយវិតក្កៈក៏ជ្រួលច្រាល់ឡើង ការជ្រួលច្រាល់នៃសញ្ញានិងមនសិការៈនោះ ទុកជាអាពាធរបស់តថាគត ម្នាលអានន្ទ សេចក្តីទុក្ខ គប្បីកើតឡើងដល់បុគ្គលដែលធ្លាប់មានសេចក្តីសុខ សេចក្តីទុក្ខនោះ នឹងប្រព្រឹត្តទៅ ដើម្បីអាពាធជាកំណាត់ មានឧបមាដូចម្តេចមិញ មានឧបមេយ្យដូចសញ្ញានិងមនសិការៈរបស់តថាគត ប្រកបដោយវិតក្កៈដែលជ្រួលច្រាល់ឡើង ការជ្រួលច្រាល់នៃសញ្ញានិងមនសិការៈនោះ ទុកជាអាពាធ របស់តថាគតដូច្នោះឯង ។

ម្នាលអានន្ទ តថាគត មានសេចក្តីត្រិះរិះដូច្នេះថា បើដូច្នោះ អញគួរជាអ្នកព្រងើយកន្តើយ ព្រោះប្រាសចាកបីតិផង ជាអ្នកប្រកបដោយសតិនិងសម្បជញ្ញៈផង សោយសេចក្តីសុខ ដោយនាមកាយផង រួចចូលកាន់តតិយជ្ឈាន ដែលព្រះអរិយៈទាំងឡាយសរសើរថា បុគ្គលអ្នកដល់តតិយជ្ឈាន ជាអ្នកព្រងើយកន្តើយ មានស្មារតី នៅជាសុខ ។

១៨១



តស្ស មយ្ហំ អានន្ទ និប្បីតិកោ ចិត្តំ ន បក្ខន្ទតិ នប្បសីទតិ ន សន្តិដ្ឋតិ ន វិមុច្ចតិ ឯតំ សន្តន្តិ បស្សតោ តស្ស មយ្ហំ អានន្ទ ឯតទហោសិ កោ នុ ខោ ហេតុ កោ បច្ចយោ យេន មេ និប្បី-តិកោ ចិត្តំ ន បក្ខន្ទតិ នប្បសីទតិ ន សន្តិដ្ឋតិ ន វិមុច្ចតិ ឯតំ សន្តន្តិ បស្សតោ តស្ស មយ្ហំ អានន្ទ ឯតទហោសិ បីតិយា ខោ មេ អាទីនវោ អទិដ្ឋោ សោ ច មេ អពហុលីកតោ និប្បីតិកោ ច[១] អានិសំសោ អនធិគតោ សោ ច មេ អនាសេវិតោ តស្មា មេ និប្បីតិកោ ចិត្តំ ន បក្ខន្ទតិ នប្បសីទតិ ន សន្តិដ្ឋតិ ន វិមុច្ចតិ ឯតំ សន្តន្តិ បស្សតោ តស្ស មយ្ហំ អានន្ទ ឯតទហោសិ សចេ ខោ អហំ បីតិយា អាទីនវំ ទិស្វា តំ ពហុលីករេយ្យំ នប្បីតិកោ អានិសំសំ អធិគម្ម តមាសេវេយ្យំ ឋានំ ខោ បនេតំ វិជ្ជតិ យំ មេ និប្បីតិកោ ចិត្តំ បក្ខន្ទេយ្យ បសីទេយ្យ សន្តិដ្ឋេយ្យ វិមុច្ចេយ្យ ឯតំ សន្តន្តិ បស្សតោ

១ ឱ. ចសទ្ទោ នត្ថិ ។

ម្នាលអានន្ទ កាលតថាគតយល់ឃើញថា និប្បីតិកជ្ឈាន (ឈានមិនមានបីតិ) នុ៎ះ ជារបស់ស្ងប់ដូច្នេះ ចិត្តក៏មិនស្ទុះទៅ មិនជ្រះថ្លា មិនតាំងនៅ មិនចុះស៊ប់ ក្នុងនិប្បីតិកជ្ឈានឡើយ ម្នាលអានន្ទ ទើបតថាគតមានសេចក្តីងឿងឆ្ងល់ដូច្នេះថា ចុះហេតុអ្វី បច្ច័យអ្វី បានជាកាលអញយល់ឃើញថា និប្បីតិកជ្ឈាននុ៎ះ ជារបស់ស្ងប់ដូច្នេះហើយ ចិត្តក៏មិនស្ទុះទៅ មិនជ្រះថ្លា មិនតាំងនៅ មិនចុះស៊ប់ ក្នុងនិប្បីតិកជ្ឈាន ម្នាលអានន្ទ តថាគតមានសេចក្តីយល់ឃើញដូច្នេះថា ឱទោសក្នុងបីតិ អញមិនទាន់ឃើញ ទាំងទោសនោះ អញមិនទាន់ធ្វើឲ្យច្រើន អានិសង្សក្នុងនិប្បីតិកជ្ឈាន អញមិនទាន់បានទេ ទាំងអានិសង្សនោះ អញមិនទាន់សេពគប់ទេតើ បានជាកាលអញយល់ឃើញថា និប្បីតិកជ្ឈាននុ៎ះ ជារបស់ស្ងប់ដូច្នេះហើយ ចិត្តក៏នៅតែមិនស្ទុះទៅ មិនជ្រះថ្លា មិនតាំងនៅ មិនចុះស៊ប់ ក្នុងនិប្បីតិកជ្ឈាន ម្នាលអានន្ទ ទើបតថាគតមានសេចក្តីត្រិះរិះដូច្នេះថា បើអញឃើញទោស ក្នុងបីតិហើយ គប្បីធ្វើនូវការឃើញទោសនោះ ឲ្យច្រើន បានអានិសង្ស ក្នុងនិប្បីតិកជ្ឈានហើយ គប្បីសេពគប់នូវអានិសង្សនោះ ហេតុនោះ តែងមានជាប្រាកដ ត្រង់ពាក្យថា កាលអញយល់ឃើញថា និប្បីតិកជ្ឈាននុ៎ះ ជារបស់ស្ងប់ដូច្នេះហើយ ចិត្តគប្បីស្ទុះទៅ ជ្រះថ្លា តាំងនៅ ចុះស៊ប់ ក្នុងនិប្បីតិកជ្ឈានបាន

១៨២

សោ ខោ អហំ អានន្ទ អបរេន សមយេន បីតិយា អាទីនវំ ទិស្វា តំ ពហុលមកាសឹ និប្បីតិកេ អានិសំសំ អធិគម្ម តមាសេវឹ តស្ស មយ្ហំ អានន្ទ និប្បីតិកេ ចិត្តំ បក្ខន្ទតិ បសីទតិ សន្តិដ្ឋតិ វិមុច្ចតិ ឯតំ សន្តន្តិ បស្សតោ សោ ខោ អហំ អានន្ទ បីតិយា ច វិរាគា ។ បេ ។ តតិយជ្ឈានំ ឧបសម្បជ្ជ វិហរាមិ ។ តស្ស មយ្ហំ អានន្ទ ឥមិនា វិហារេន វិហរតោ បីតិសហគតា សញ្ញាមនសិការា សមុទាចរន្តិ ស្វាស្ស មេ ហោតិ អាពាធោ សេយ្យថាបិ អានន្ទ សុខិនោ ទុក្ខំ ឧប្បជ្ជេយ្យ យាវទេវ អាពាធាយ ឯវមេវស្ស មេ បីតិសហគតា សញ្ញាមនសិការា សមុទាចរន្តិ ស្វាស្ស មេ ហោតិ អាពាធោ ។ តស្ស មយ្ហំ អានន្ទ ឯតទហោសិ យន្នូនាហំ សុខស្ស ច បហានា ទុក្ខស្ស ច បហានា បុព្វេវ សោមនស្សទោមនស្សានំ អត្ថង្គមា អទុក្ខមសុខំ ឧបេក្ខាសតិបារិសុទ្ធឹ ចតុត្ថជ្ឈានំ ឧបសម្បជ្ជ វិហរេយ្យន្តិ ។

ម្នាលអានន្ទ លុះសម័យខាងក្រោយមក តថាគតនោះឃើញទោសក្នុងបីតិ ហើយ ក៏ធ្វើនូវការឃើញទោសនោះឲ្យច្រើន បានអានិសង្ស ក្នុងនិប្បីតិ-កជ្ឈានហើយ ក៏សេពគប់នូវអានិសង្សនោះ ម្នាលអានន្ទ កាលតថាគត យល់ឃើញថា និប្បីតិកជ្ឈាននុ៎ះ ជារបស់ស្ងប់ដូច្នេះ ចិត្តក៏ត្រឡប់ជាស្ទុះទៅ ជ្រះថ្លា តាំងនៅ ចុះស៊ប់ ក្នុងនិប្បីតិកជ្ឈានឡើង ម្នាលអានន្ទ តថាគត នោះឯង ព្រោះប្រាសចាកបីតិផង ។ បេ ។ ក៏បានចូលកាន់តតិយជ្ឈាន ។ ម្នាលអានន្ទ តថាគត កាលប្រព្រឹត្តនៅដោយវិហារធម៌នេះ សញ្ញានិង មនសិការៈប្រកបដោយបីតិក៏ជ្រួលច្រាល់ឡើង ការជ្រួលច្រាល់នៃសញ្ញា និងមនសិការៈនោះ ទុកជាអាពាធរបស់តថាគត ម្នាលអានន្ទ សេចក្តី ទុក្ខ គប្បីកើតឡើងដល់បុគ្គលដែលធ្លាប់មានសេចក្តីសុខ សេចក្តីទុក្ខនោះ នឹងប្រព្រឹត្តទៅ ដើម្បីអាពាធជាកំណត់ មានឧបមាដូចម្តេចមិញ មាន ឧបមេយ្យដូចសញ្ញានិងមនសិការៈរបស់តថាគត ប្រកបដោយបីតិ ដែល ជ្រួលច្រាល់ឡើង ការជ្រួលច្រាល់នៃសញ្ញានិងមនសិការៈនោះ ទុកជា អាពាធរបស់តថាគតដូច្នោះឯង ។ ម្នាលអានន្ទ តថាគតមានសេចក្តីត្រិះរិះ ដូច្នេះថា បើដូច្នោះ គួរតែអញចូលកាន់ចតុត្ថជ្ឈាន ដែលឥតទុក្ខឥតសុខ មានឧបេក្ខាដ៏បរិសុទ្ធដោយសតិ ព្រោះលះបង់សេចក្តីសុខផង លះបង់ សេចក្តីទុក្ខផង វិនាសសោមនស្សនិងទោមនស្សផង ក្នុងកាលមុន ។

១៨៣



តស្ស មយ្ហំ អានន្ទ អនុក្ខមសុខេ ចិត្តំ ន បក្ខន្ទតិ នប្បសីទតិ ន សន្តិដ្ឋតិ ន វិមុច្ចតិ ឯតំ សន្តន្តិ បស្សតោ តស្ស មយ្ហំ អានន្ទ ឯតទហោសិ កោ នុ ខោ ហេតុ កោ បច្ចយោ យេន មេ អនុក្ខមសុខេ ចិត្តំ ន បក្ខន្ទតិ នប្បសីទតិ ន សន្តិដ្ឋតិ ន វិមុច្ចតិ ឯតំ សន្តន្តិ បស្សតោ តស្ស មយ្ហំ អានន្ទ ឯតទហោសិ ឧបេក្ខាសុខេ ខោ មេ អាទីនវោ អទិដ្ឋោ សោ ច មេ អពហុលីកតោ អនុក្ខមសុខេ ច អានិសំសោ អនធិគតោ សោ ច មេ អនាសេវិតោ តស្មា មេ អនុក្ខមសុខេ ចិត្តំ ន បក្ខន្ទតិ នប្បសីទតិ ន សន្តិដ្ឋតិ ន វិមុច្ចតិ ឯតំ សន្តន្តិ បស្សតោ តស្ស មយ្ហំ អានន្ទ ឯតទហោសិ សចេ ខោ អហំ ឧបេក្ខាសុខេ អាទីនវំ ទិស្វា តំ ពហុលីករេយ្យំ អនុក្ខមសុខេ អានិសំសំ អធិគម្ម តមាសេវេយ្យំ

ម្នាលអានន្ទ កាលតថាគត យល់ឃើញថា ចតុត្ថជ្ឈានដែលឥត ទុក្ខឥតសុខនុ៎ះ ជារបស់ស្ងប់ដូច្នេះ ចិត្តក៏មិនស្ទុះទៅ មិនជ្រះថ្លា មិនតាំងនៅ មិនចុះស៊ប់ ក្នុងចតុត្ថជ្ឈាន ដែលឥតទុក្ខឥតសុខឡើយ ម្នាលអានន្ទ ទើបតថាគត មានសេចក្តីងឿងឆ្ងល់ដូច្នេះថា ចុះហេតុអ្វី បច្ច័យអ្វី បានជាកាលអញ យល់ឃើញថា ចតុត្ថជ្ឈានដែលឥតទុក្ខ ឥតសុខនុ៎ះ ជារបស់ស្ងប់ដូច្នេះហើយ ចិត្តក៏មិនស្ទុះទៅ មិនជ្រះថ្លា មិនតាំងនៅ មិនចុះស៊ប់ ក្នុងចតុត្ថជ្ឈានដែលឥតទុក្ខឥតសុខ ម្នាលអានន្ទ តថាគតមានសេចក្តីយល់ឃើញដូច្នេះថា ឱទោសក្នុងសេចក្តីសុខ ក្នុង ឧបេក្ខា អញមិនទាន់ឃើញ ទាំងទោសនោះ អញមិនទាន់ធ្វើឲ្យច្រើន អានិសង្សក្នុងចតុត្ថជ្ឈានដែលឥតទុក្ខឥតសុខ អញមិនទាន់បានទេ ទាំង អានិសង្សនោះ អញមិនទាន់សេពគប់ទេតើ បានជាកាលអញយល់ ឃើញថា ចតុត្ថជ្ឈានដែលឥតទុក្ខឥតសុខនុ៎ះ ជារបស់ស្ងប់ដូច្នេះហើយ ចិត្តក៏នៅតែមិនស្ទុះទៅ មិនជ្រះថ្លា មិនតាំងនៅ មិនចុះស៊ប់ ក្នុង ចតុត្ថជ្ឈាន ដែលឥតទុក្ខឥតសុខឡើយ ម្នាលអានន្ទ ទើបតថាគតមាន សេចក្តីត្រិះរិះដូច្នេះថា បើអញឃើញទោស ក្នុងសេចក្តីសុខក្នុងឧបេក្ខា ហើយ គប្បីធ្វើនូវការឃើញទោសនោះឲ្យច្រើន បាននូវអានិសង្សក្នុង ចតុត្ថជ្ឈាន ដែលឥតទុក្ខឥតសុខហើយ គប្បីសេពគប់នូវអានិសង្សនោះ

ហានំ ខោ បនេតំ វិជ្ជតិ យំ មេ អនុត្ខមសុខេ ចិត្តំ បក្ខន្ទេយ្យ បសីទេយ្យ សន្តិដ្ឋេយ្យ វិមុច្ចេយ្យ ឯតំ សន្តន្តិ បស្សតោ សោ ខោ អហំ អានន្ទ អបរេន សមយេន ឧបេក្ខាសុខេ អាទីនវំ ទិស្វា តំ ពហុលមកាសឹ អនុត្ខមសុខេ អានិសំសំ អធិគម្ម តមាសេវឹ តស្ស មយ្ហំ អានន្ទ អនុត្ខមសុខេ ចិត្តំ បក្ខន្ទតិ បសីទតិ សន្តិដ្ឋតិ វិមុច្ចតិ ឯតំ សន្តន្តិ បស្សតោ សោ ខោ អហំ អានន្ទ អបរេន សម-យេន សុខស្ស ច បហានា ។ បេ ។ ចតុត្ថជ្ឈានំ ឧបសម្បជ្ជ វិហរាមិ ។ តស្ស មយ្ហំ អានន្ទ ឥមិនា វិហារេន វិហរតោ ឧបេក្ខាសហាគតា សញ្ញាមនសិ-ការា សមុទាចរន្តិ ស្វាស្ស មេ ហោតិ អាពាធោ

ហេតុនេះតែងមានជាប្រាកដ ត្រង់ពាក្យថា កាលអញយល់ឃើញថា ចតុត្ថជ្ឈាន ដែលឥតទុក្ខឥតសុខនុ៎ះ ជារបស់ស្ងប់ដូច្នេះ ចិត្តគប្បីស្ទុះទៅ ជ្រះថ្លា តាំងនៅ ចុះស៊ប់ក្នុងចតុត្ថជ្ឈាន ដែលឥតទុក្ខឥតសុខបាន ម្នាលអានន្ទ លុះសម័យខាងក្រោយ តថាគតនោះឯង ឃើញទោស ក្នុងសេចក្តីសុខ ក្នុងឧបេក្ខាហើយ ក៏ធ្វើនូវការឃើញទោសនោះឲ្យច្រើន បានអានិសង្ស ក្នុងចតុត្ថជ្ឈានដែលឥតទុក្ខឥតសុខហើយ ក៏សេពគប់នូវអានិសង្សនោះ ម្នាលអានន្ទ កាលតថា-គតយល់ឃើញថា ចតុត្ថជ្ឈាន ដែលឥតទុក្ខឥតសុខនុ៎ះ ជារបស់ស្ងប់ដូច្នេះ ចិត្តក៏ត្រឡប់ជាស្ទុះទៅ ជ្រះថ្លា តាំងនៅ ចុះស៊ប់ ក្នុងចតុត្ថជ្ឈាន ដែលឥតទុក្ខឥតសុខឡើយ ម្នាលអានន្ទ លុះសម័យខាងក្រោយមក តថាគតនោះឯង ព្រោះលះបង់នូវសុខផង ។ បេ ។ ក៏ចូលកាន់ចតុត្ថជ្ឈាន ។ ម្នាលអានន្ទ កាលតថាគតប្រព្រឹត្តនៅដោយវិហារ-ធម៌នេះ សញ្ញានិងមនសិការៈ ប្រកបដោយឧបេក្ខា ក៏ជ្រួលច្រាល់ឡើង ការជ្រួលច្រាល់នៃសញ្ញានិងមនសិការៈនោះ ទុកជាអាពាធ

១៨៥



សេយ្យថាបិ អានន្ទ សុខិនោ ទុក្ខំ ឧប្បជ្ជេយ្យ យាវទេវ អាពាធាយ ឯវមេវស្ស មេ ឧបេក្ខាសហគតា សញ្ញាមនសិការា សមុទាចរន្តិ ស្វាស្ស មេ ហោតិ អាពាធោ ។

តស្ស មយ្ហំ អានន្ទ ឯតទហោសិ យន្នូនាហំ សព្វសោ រូបសញ្ញានំ សមតិក្កមា បដិឃសញ្ញានំ អត្ថង្គមា នានត្តសញ្ញានំ អមនសិការា អនន្តោ អាកាសោតិ អាកាសានញ្ចាយតនំ ឧបសម្បជ្ជ វិហរេយ្យន្តិ ។ តស្ស មយ្ហំ អានន្ទ អាកាសា-នញ្ចាយតនេ ចិត្តំ ន បក្ខន្ទតិ នប្បសីទតិ ន សន្តិដ្ឋតិ ន វិមុច្ចតិ ឯតំ សន្តន្តិ បស្សតោ តស្ស មយ្ហំ អានន្ទ ឯតទហោសិ កោ នុ ខោ ហេតុ កោ បច្ចយោ យេន មេ អាកាសា-នញ្ចាយតនេ ចិត្តំ ន បក្ខន្ទតិ នប្បសីទតិ ន សន្តិដ្ឋតិ ន វិមុច្ចតិ ឯតំ សន្តន្តិ បស្សតោ

របស់តថាគត ម្នាលអានន្ទ សេចក្តីទុក្ខ គប្បីកើតឡើង ដល់បុគ្គលដែលធ្លាប់មានសេចក្តីសុខ សេចក្តីទុក្ខនោះ នឹងប្រព្រឹត្តទៅ ដើម្បីអាពាធជាកំណត់ មានឧបមាដូចម្តេចមិញ មានឧបមេយ្យដូចសញ្ញានិងមនសិការៈរបស់តថាគត ប្រកបដោយឧបេក្ខា ដែលជ្រួលច្រាល់ឡើង ការជ្រួលច្រាល់នៃសញ្ញា និងមនសិការៈនោះ ទុកជាអាពាធ របស់តថាគត ដូច្នោះឯង ។

ម្នាលអានន្ទ តថាគត មានសេចក្តីត្រិះរិះដូច្នេះថា បើដូច្នោះគួរតែអញចូលកាន់អាកាសានញ្ចាយតនជ្ឈាន ដោយការធ្វើទុកក្នុងចិត្តថាអាកាសមិនមានទីបំផុតដូច្នេះ ព្រោះកន្លងបង់នូវរូបសញ្ញា ព្រោះរលត់បដិឃសញ្ញា ព្រោះមិនធ្វើទុកក្នុងចិត្តនូវនានត្តសញ្ញា ដោយប្រការទាំងពួង ។ ម្នាលអានន្ទ កាលតថាគត យល់ឃើញថាអាកាសានញ្ចាយតនជ្ឈាននុ៎ះ ជារបស់ស្ងប់ដូច្នេះ ចិត្តក៏មិនស្ទុះទៅ មិនជ្រះថ្លា មិនតាំងនៅ មិនចុះស៊ប់ ក្នុងអាកាសានញ្ចាយតនជ្ឈានឡើយ ម្នាលអានន្ទ ទើបតថាគត មានសេចក្តីងឿងឆ្ងល់ដូច្នេះថា ហេតុអ្វី បច្ច័យអ្វី កាលអញ យល់ឃើញថា អាកាសានញ្ចាយតនជ្ឈាននុ៎ះ ជារបស់ស្ងប់ដូច្នេះហើយ ចិត្តក៏មិនស្ទុះទៅ មិនជ្រះថ្លា មិនតាំងនៅ មិនចុះស៊ប់ ក្នុងអាកាសានញ្ចាយតនជ្ឈាន

តស្ស មយ្ហំ អានន្ទ ឯតទហោសិ រូបេសុ ខោ មេ អាទីនវោ អទិដ្ឋោ សោ ច មេ អពហុលីកតោ អាកាសានញ្ចាយតនេ ច អានិសំសោ អនធិគតោ សោ ច មេ អនាសេវិតោ តស្មា មេ អាកាសា-នញ្ចាយតនេ ចិត្តំ ន បក្ខន្ទតិ នប្បសីទតិ ន សន្តិដ្ឋតិ ន វិមុច្ចតិ ឯតំ សន្តន្តិ បស្សតោ តស្ស មយ្ហំ អានន្ទ ឯតទហោសិ សចេ ខោ អហំ រូបេសុ អាទីនវំ ទិស្វា តំ ពហុលីករេយ្យំ អាកា-សានញ្ចាយតនេ អានិសំសំ អធិគម្ម តមាសេវេយ្យំ ឋានំ ខោ បនេតំ វិជ្ជតិ យំ មេ អាកាសានញ្ចា-យតនេ ចិត្តំ បក្ខន្ទេយ្យ បសីទេយ្យ សន្តិដ្ឋេយ្យ វិមុច្ចេយ្យ ឯតំ សន្តន្តិ បស្សតោ សោ ខោ អហំ អានន្ទ អបរេន សមយេន រូបេសុ អាទីនវំ ទិស្វា

ម្នាលអានន្ទ តថាគត មានសេចក្តីយល់ឃើញដូច្នេះថា ឱទោសក្នុងរូបទាំងឡាយ អញមិនទាន់ឃើញ ទាំងទោសនោះ អញមិនទាន់ធ្វើឲ្យច្រើន អានិសង្ស ក្នុងអាកាសានញ្ចាយតនជ្ឈាន អញមិនទាន់បានទេ ទាំងអានិសង្សនោះ អញមិនទាន់សេពគប់ទេតើ បានជាកាលអញយល់ឃើញថា អាកាសានញ្ចាយតនជ្ឈាននុ៎ះ ជារបស់ស្ងប់ដូច្នេះហើយ ចិត្តក៏នៅតែមិនស្ទុះទៅ មិនជ្រះថ្លា មិនតាំងនៅ មិនចុះស៊ប់ ក្នុងអាកាសានញ្ចាយតនជ្ឈាន ម្នាលអានន្ទ ទើបតថាគតមានសេចក្តីត្រិះរិះដូច្នេះថា បើអញឃើញទោស ក្នុងរូបទាំងឡាយហើយ គប្បីធ្វើនូវការឃើញទោសនោះឲ្យច្រើន បានអានិសង្ស ក្នុងអាកាសានញ្ចាយតនជ្ឈានហើយ គប្បីសេពគប់នូវអានិសង្សនោះ ហេតុនេះ តែងមានជាប្រាកដ ត្រង់ពាក្យថា កាលអញយល់ឃើញថា អាកាសានញ្ចាយតនជ្ឈាននុ៎ះ ជារបស់ស្ងប់ដូច្នេះហើយ ចិត្តគប្បីស្ទុះទៅ ជ្រះថ្លា តាំងនៅ ចុះស៊ប់ ក្នុងអាកាសានញ្ចាយតនជ្ឈានបាន ម្នាលអានន្ទ លុះសម័យខាងក្រោយមក តថាគតនោះឯង ឃើញទោស ក្នុងរូបទាំងឡាយហើយ

១៨៧



តំ ពហុលមកាសឹ អាកាសានញ្ចាយតនេ អានិសំសំ អធិគម្ម តមាសេវឹ តស្ស មយ្ហំ អានន្ទ អាកាសា-នញ្ចាយតនេ ចិត្តំ បក្ខន្ទតិ បសីទតិ សន្តិដ្ឋតិ វិមុច្ចតិ ឯតំ សន្តន្តិ បស្សតោ សោ ខោ អហំ អានន្ទ សព្វសោ រូបសញ្ញានំ សមតិក្កមា បដិឃសញ្ញានំ អត្ថង្គមា នានត្តសញ្ញានំ អមនសិ-ការា អនន្តោ អាកាសោតិ អាកាសានញ្ចាយតនំ ឧបសម្បជ្ជ វិហរាមិ ។ តស្ស មយ្ហំ អានន្ទ ឥមិនា វិហារេន វិហរតោ រូបសហគតា សញ្ញាមនសិការា សមុទាចរន្តិ ស្វាស្ស មេ ហោតិ អាពាធោ សេយ្យ-ថាបិ អានន្ទ សុខិនោ ទុក្ខំ ឧប្បជ្ជេយ្យ យាវ-ទេវ អាពាធាយ ឯវមេវស្ស មេ រូបសហគតា សញ្ញាមនសិការា សមុទាចរន្តិ ស្វាស្ស មេ ហោតិ អាពាធោ ។

ក៏ធ្វើនូវការឃើញទោសនោះឲ្យច្រើន បាននូវអានិសង្ស ក្នុងអាកាសានញ្ចាយតនជ្ឈានហើយ ក៏សេពគប់នូវអានិសង្សនោះ ម្នាលអានន្ទ កាលតថាគត យល់ឃើញថា អាកាសានញ្ចាយតនជ្ឈាននុ៎ះ ជារបស់ស្ងប់ដូច្នេះហើយ ចិត្តក៏ត្រឡប់ជាស្ទុះទៅ ជ្រះថ្លា តាំងនៅ ចុះស៊ប់ ក្នុងអាកាសានញ្ចាយតនជ្ឈានឡើង ម្នាលអានន្ទ តថាគត នោះឯង ព្រោះកន្លងបង់នូវរូបសញ្ញា ព្រោះរលត់បដិឃសញ្ញា ព្រោះមិនបានធ្វើទុកក្នុងចិត្តនូវនានត្តសញ្ញា ដោយប្រការទាំងពួង ក៏ចូលកាន់អាកាសានញ្ចាយតនជ្ឈាន ដោយការធ្វើទុកក្នុងចិត្តថា អាកាសមិនមានទីបំផុត ។ ម្នាលអានន្ទ កាលតថាគតនោះ ប្រព្រឹត្តនៅដោយវិហារធម៌នេះ សញ្ញានិងមនសិការៈ ប្រកបដោយរូប ក៏ជ្រួលច្រាល់ឡើង ការជ្រួលច្រាល់នៃសញ្ញានិងមនសិការៈនោះ ទុកជាអាពាធរបស់តថាគត ម្នាលអានន្ទ សេចក្តីទុក្ខ គប្បីកើតឡើងដល់បុគ្គលដែលធ្លាប់មានសេចក្តីសុខ សេចក្តីទុក្ខនោះនឹងប្រព្រឹត្តទៅ ដើម្បីអាពាធជាកំណត់ មានឧបមាដូចម្តេចមិញ មានឧបមេយ្យ ដូចសញ្ញានិងមនសិការៈរបស់តថាគត ប្រកបដោយរូប ដែលជ្រួលច្រាល់ឡើង ការជ្រួលច្រាល់នៃសញ្ញានិងមនសិការៈនោះ ទុកជាអាពាធ របស់តថាគត ដូច្នោះឯង ។

តស្ស មយ្ហំ អានន្ទ ឯតេនបោសិ យន្នូនាហំ សព្វសោ អាកាសានញ្ចាយតនំ សមតិក្កម្ម អនន្តំ វិញ្ញាណន្តិ វិញ្ញាណញ្ចាយតនំ ឧបសម្បជ្ជ វិហរេយ្យន្តិ ។ តស្ស មយ្ហំ អានន្ទ វិញ្ញាណញ្ចាយតនេ ចិត្តំ ន បក្ខន្ទតិ នប្បសីទតិ ន សន្តិដ្ឋតិ ន វិមុច្ចតិ ឯតំ សន្តន្តិ បស្សតោ តស្ស មយ្ហំ អានន្ទ ឯតេនបោសិ កោ នុ ខោ ហេតុ កោ បច្ចយោ យេន មេ វិញ្ញាណញ្ចាយតនេ ចិត្តំ ន បក្ខន្ទតិ នប្បសីទតិ ន សន្តិដ្ឋតិ ន វិមុច្ចតិ ឯតំ សន្តន្តិ បស្សតោ តស្ស មយ្ហំ អានន្ទ ឯតេនបោសិ អាកាសានញ្ចា-យតនេ ខោ មេ អាទីនវោ អទិដ្ឋោ សោ ច មេ អពហុលីកតោ វិញ្ញាណញ្ចាយតនេ ច អានិសំសោ អនធិគតោ សោ ច មេ អនាសេវិតោ តស្មា មេ វិញ្ញាណញ្ចាយតនេ ចិត្តំ ន បក្ខន្ទតិ នប្បសីទតិ ន សន្តិដ្ឋតិ ន វិមុច្ចតិ ឯតំ សន្តន្តិ បស្សតោ

ម្នាលអានន្ទ តថាគត មានសេចក្តីត្រិះរិះដូច្នេះថា បើដូច្នោះ គួរតែអញកន្លងបង់នូវអាកាសានញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ហើយចូលកាន់វិញ្ញាណញ្ចាយតនជ្ឈាន ដោយការធ្វើទុកក្នុងចិត្តថា វិញ្ញាណមិនមានទីបំផុត ។ ម្នាលអានន្ទ កាលតថាគតយល់ឃើញថា វិញ្ញាណញ្ចាយតនជ្ឈាននុ៎ះ ជារបស់ស្ងប់ដូច្នេះ ចិត្តក៏មិនស្ទុះទៅ មិនជ្រះថ្លា មិនតាំងនៅ មិនចុះស៊ប់ ក្នុងវិញ្ញាណញ្ចាយ-តនជ្ឈានឡើយ ម្នាលអានន្ទ ទើបតថាគត មានសេចក្តីងឿងឆ្ងល់ថា ចុះហេតុអ្វី បច្ច័យអ្វី បានជាកាលអញ យល់ឃើញថា វិញ្ញាណ-ញ្ចាយតនជ្ឈាននុ៎ះ ជារបស់ស្ងប់ដូច្នេះហើយ ចិត្តក៏មិនស្ទុះទៅ មិនជ្រះថ្លា មិនតាំងនៅ មិនចុះស៊ប់ ក្នុងវិញ្ញាណញ្ចាយតនជ្ឈាន ម្នាលអានន្ទ តថាគត មានសេចក្តីយល់ឃើញថា ឱទោសក្នុងអាកាសានញ្ចាយតន-ជ្ឈាន អញមិនទាន់ឃើញ ទាំងទោសនោះ អញមិនទាន់ធ្វើឲ្យច្រើន អានិសង្សក្នុងវិញ្ញាណញ្ចាយតនជ្ឈាន អញមិនទាន់បានទេ ទាំងអានិសង្សនោះ អញមិនទាន់សេពគប់ទេតើ បានជាកាលអញ យល់ឃើញថា វិញ្ញាណញ្ចាយតនជ្ឈាននុ៎ះ ជារបស់ស្ងប់ដូច្នេះហើយ ចិត្តក៏នៅតែមិនស្ទុះទៅ មិនជ្រះថ្លា មិនតាំងនៅ មិនចុះស៊ប់ ក្នុងវិញ្ញាណញ្ចាយតនជ្ឈាន

តស្ស មយ្ហំ អានន្ទ ឯតទហោសិ សចេ ខោ អហំ អាកាសានញ្ចាយតនេ អាទីនវំ ទិស្វា តំ ពហុលីការេយ្យំ វិញ្ញាណញ្ចាយតនេ អានិសំសំ អធិគម្ម តមាសេវេយ្យំ ឋានំ ខោ បនេតំ វិជ្ជតិ យំ មេ វិញ្ញាណញ្ចាយតនេ ចិត្តំ បក្ខន្ទេយ្យ បសីទេយ្យ សន្តិដ្ឋេយ្យ វិមុច្ចេយ្យ ឯតំ សន្តន្តិ បស្សតោ សោ ខោ អហំ អានន្ទ អបរេន សមយេន អាកាសានញ្ចាយតនេ អាទីនវំ ទិស្វា តំ ពហុលមកាសឹ វិញ្ញាណញ្ចាយតនេ អានិសំសំ អធិគម្ម តមាសេវឹ តស្ស មយ្ហំ អានន្ទ វិញ្ញាណញ្ចាយតនេ ចិត្តំ បក្ខន្ទតិ បសីទតិ សន្តិដ្ឋតិ វិមុច្ចតិ ឯតំ សន្តន្តិ បស្សតោ សោ ខោ អហំ អានន្ទ សព្វសោ អាកាសានញ្ចាយតនំ សមតិក្កម្ម អនន្តំ វិញ្ញាណន្តិ វិញ្ញាណញ្ចាយតនំ ឧបសម្បជ្ជ វិហរាមិ ។ តស្ស មយ្ហំ អានន្ទ ឥមិនា វិហារេន វិហរតោ អាកាសានញ្ចាយតនសហគតា សញ្ញាមនសិការា សមុទាចរន្តិ

ម្នាលអានន្ទ ទើបតថាគត មានសេចក្តីត្រិះរិះដូច្នេះថា បើអញឃើញទោស ក្នុងអាកាសានញ្ចាយតនជ្ឈានហើយ គប្បីធ្វើនូវការឃើញទោសនោះឲ្យច្រើន បាននូវអានិសង្ស ក្នុងវិញ្ញាណញ្ចាយតនជ្ឈានហើយ គប្បីសេពគប់នូវអានិសង្សនោះ ហេតុនេះ តែងមានជាប្រាកដ ត្រង់ពាក្យថា កាលអញយល់ឃើញថា វិញ្ញាណញ្ចាយតនជ្ឈាននុ៎ះ ជារបស់ស្ងប់ដូច្នេះហើយ ចិត្តគប្បីស្ទុះទៅ ជ្រះថ្លា តាំងនៅ ចុះស៊ប់ក្នុងវិញ្ញាណញ្ចាយតនជ្ឈានបាន ម្នាលអានន្ទ លុះសម័យខាងក្រោយមក តថាគតនោះឯង ឃើញទោស ក្នុងអាកាសានញ្ចាយតនជ្ឈានហើយ ក៏ធ្វើនូវការឃើញទោសនោះ ឲ្យច្រើន បាននូវអានិសង្សក្នុងវិញ្ញាណញ្ចាយតនជ្ឈានហើយ ក៏សេពគប់នូវអានិសង្សនោះ ម្នាលអានន្ទ កាលតថាគត យល់ឃើញថា វិញ្ញាណញ្ចាយតនជ្ឈាននុ៎ះជារបស់ស្ងប់ដូច្នេះ ចិត្តក៏ត្រឡប់ជាស្ទុះទៅ ជ្រះថ្លា តាំងនៅ ចុះស៊ប់ក្នុងវិញ្ញាណញ្ចាយតនជ្ឈានឡើង ម្នាលអានន្ទ តថាគតនោះឯងកន្លងបង់នូវអាកាសានញ្ចាយតនជ្ឈានហើយ ចូលកាន់វិញ្ញាណញ្ចា-យតនជ្ឈាន ដោយការធ្វើទុកក្នុងចិត្តថា វិញ្ញាណមិនមានទីបំផុត ។ ម្នាលអានន្ទ កាលតថាគត នៅដោយវិហារធម៌នេះ សញ្ញានិងមន-សិការៈ ប្រកបដោយអាកាសានញ្ចាយតនជ្ឈាន ក៏ជ្រួលច្រាល់ឡើង

១៩០



ស្វាស្ស មេ ហោតិ អាពាធោ សេយ្យថាបិ អានន្ទ សុខិនោ ទុក្ខំ ឧប្បជ្ជេយ្យ យាវទេវ អាពាធាយ ឯវមេវស្ស មេ អាកាសានញ្ចាយតនសហគតា សញ្ញាមនសិការា សមុទាចរន្តិ ស្វាស្ស មេ ហោតិ អាពាធោ ។

តស្ស មយ្ហំ អានន្ទ ឯតទហោសិ យន្នូនាហំ សព្វសោ វិញ្ញាណញ្ចាយតនំ សមតិក្កម្ម នត្ថិ កិញ្ចីតិ អាកិញ្ចញ្ញាយតនំ ឧបសម្បជ្ជ វិហរេយ្យន្តិ ។ តស្ស មយ្ហំ អានន្ទ អាកិញ្ចញ្ញាយតនេ ចិត្តំ ន បក្ខន្ទតិ នប្បសីទតិ ន សន្តិដ្ឋតិ ន វិមុច្ចតិ ឯតំ សន្តន្តិ បស្សតោ តស្ស មយ្ហំ អានន្ទ ឯតទហោសិ កោ នុ ខោ ហេតុ កោ បច្ចយោ យេន មេ អាកិញ្ចញ្ញាយតនេ ចិត្តំ ន បក្ខន្ទតិ នប្បសីទតិ ន សន្តិដ្ឋតិ ន វិមុច្ចតិ ឯតំ សន្តន្តិ បស្សតោ តស្ស មយ្ហំ អានន្ទ ឯតទហោសិ

ការជ្រួលច្រាល់នៃសញ្ញានិងមនសិការៈនោះ ទុកជាអាពាធ របស់តថាគត ម្នាលអានន្ទ សេចក្តីទុក្ខ គប្បីកើតឡើងដល់បុគ្គលដែលធ្លាប់មានសេចក្តីសុខ សេចក្តីទុក្ខនោះ នឹងប្រព្រឹត្តទៅ ដើម្បីអាពាធជាកំណត់ មានឧបមាដូចម្តេចមិញ មានឧបមេយ្យ ដូចសញ្ញានិងមនសិការៈរបស់តថាគត ប្រកបដោយអាកាសានញ្ចាយតនជ្ឈាន ដែលជ្រួលច្រាល់ឡើង ការជ្រួលច្រាល់នៃសញ្ញានិងមនសិការៈនោះ ទុកជាអាពាធរបស់តថាគតដូច្នោះឯង ។

ម្នាលអានន្ទ តថាគតមានសេចក្តីត្រិះរិះដូច្នេះថា បើដូច្នោះ គួរតែអាត្មាអញ កន្លងបង់នូវវិញ្ញាណញ្ចាយតនជ្ឈាន ហើយចូលកាន់អាកិញ្ចញ្ញាយតនជ្ឈាន ដោយការធ្វើទុកក្នុងចិត្តថា អ្វីតិចតួចមិនមាន ។ ម្នាលអានន្ទ កាលតថាគត យល់ឃើញថា អាកិញ្ចញ្ញាយតនជ្ឈាននុ៎ះ ជារបស់ស្ងប់ដូច្នេះហើយ ចិត្តក៏មិនស្ទុះទៅ មិនជ្រះថ្លា មិនតាំងនៅ មិនចុះស៊ប់ ក្នុងអាកិញ្ចញ្ញាយតនជ្ឈានឡើយ ម្នាលអានន្ទ ទើបតថាគតមានសេចក្តីងឿងឆ្ងល់ដូច្នេះថា ចុះហេតុអ្វី បច្ច័យអ្វី បានជា កាលអញយល់ឃើញថា អាកិញ្ចញ្ញាយតនជ្ឈាននុ៎ះ ជារបស់ស្ងប់ដូច្នេះហើយ ចិត្តមិនស្ទុះទៅ មិនជ្រះថ្លា មិនតាំងនៅ មិនចុះស៊ប់ ក្នុងអាកិញ្ចញ្ញាយតនជ្ឈាន ម្នាលអានន្ទ តថាគតមានសេចក្តីយល់ឃើញដូច្នេះថា

វិញ្ញាណញ្ចាយតនេ ខោ មេ អាទីនវា អទិដ្ឋា
សោ ច មេ អពហុលីកតោ អាកិញ្ចញ្ញាយតនេ ច
អានិសំសោ អនធិគតោ សោ ច មេ អនាសេវិតោ
តស្មា មេ អាកិញ្ចញ្ញាយតនេ ចិត្តំ ន បក្ខន្ទតិ
នប្បសីទតិ ន សន្តិដ្ឋតិ ន វិមុច្ចតិ ឯតំ សន្តន្តិ
បស្សតោ តស្ស មយ្ហំ អានន្ទ ឯតទហោសិ
សចេ ខោ អហំ វិញ្ញាណញ្ចាយតនេ អាទីនវំ ទិស្វា
តំ ពហុលីករេយ្យំ អាកិញ្ចញ្ញាយតនេ អានិសំសំ
អធិគម្ម តមាសេវេយ្យំ ឋានំ ខោ បនេតំ វិជ្ជតិ យំ មេ
អាកិញ្ចញ្ញាយតនេ ចិត្តំ បក្ខន្ទេយ្យ បសីទេយ្យ
សន្តិដ្ឋេយ្យ វិមុច្ចេយ្យ ឯតំ សន្តន្តិ បស្សតោ សោ
ខោ អហំ អានន្ទ អបរេន សមយេន វិញ្ញាណញ្ចា-
យតនេ អាទីនវំ ទិស្វា តំ ពហុលមកាសឹ
អាកិញ្ចញ្ញាយតនេ អានិសំសំ អធិគម្ម តមាសេវឹ

ឱទោសក្នុងវិញ្ញាណញ្ចាយតនជ្ឈាន អញមិនទាន់ឃើញ ទាំងទោសនោះ អញមិនទាន់ធ្វើឲ្យច្រើន អានិសង្ស ក្នុងអាកិញ្ចញ្ញាយតនជ្ឈាន អញ មិនទាន់បានទេ ទាំងអានិសង្សនោះ អញមិនទាន់សេពគប់ទេតើ បានជា កាលអញយល់ឃើញថា អាកិញ្ចញ្ញាយតនជ្ឈាននុ៎ះ ជារបស់ស្ងប់ដូច្នេះ ហើយ ចិត្តក៏នៅតែមិនស្ទុះទៅ មិនជ្រះថ្លា មិនតាំងនៅ មិនចុះស៊ប់ ក្នុងអាកិញ្ចញ្ញាយតនជ្ឈាន ម្នាលអានន្ទ ទើបតថាគតមានសេចក្តី ត្រិះរិះដូច្នេះថា បើអញឃើញទោស ក្នុងវិញ្ញាណញ្ចាយតនជ្ឈានហើយ គប្បីធ្វើនូវការឃើញទោសនោះឲ្យច្រើន បាននូវអានិសង្ស ក្នុងអាកិញ្ច-ញ្ញាយតនជ្ឈានហើយ គប្បីសេពគប់នូវអានិសង្សនោះ ហេតុនេះ តែង មានជាប្រាកដ ត្រង់ពាក្យថា កាលអញយល់ឃើញថា អាកិញ្ចញ្ញា-យតនជ្ឈាននុ៎ះ ជារបស់ស្ងប់ដូច្នេះហើយ ចិត្តគប្បីស្ទុះទៅ ជ្រះថ្លា តាំងនៅ ចុះស៊ប់ ក្នុងអាកិញ្ចញ្ញាយតនជ្ឈានបាន ម្នាលអានន្ទ លុះ សម័យខាងក្រោយមក តថាគតនោះឯង ឃើញទោសក្នុងវិញ្ញាណញ្ចា-យតនជ្ឈានហើយ ក៏ធ្វើនូវការឃើញទោសនោះ ឲ្យច្រើន បាននូវ អានិសង្សក្នុងអាកិញ្ចញ្ញាយតនជ្ឈានហើយ ក៏សេពគប់នូវអានិសង្សនោះ

តស្ស មយ្ហំ អានន្ទ អាកិញ្ចញ្ញាយតនេ ចិត្តំ បក្ខន្ទតិ បសីទតិ សន្តិដ្ឋតិ វិមុច្ចតិ ឯតំ សន្តន្តិ បស្សតោ សោ ខោ អហំ អានន្ទ សព្វសោ វិញ្ញាណញ្ចាយតនំ សមតិក្កម្ម នត្ថិ កិញ្ចីតិ អាកិញ្ចញ្ញាយតនំ ឧបសម្បជ្ជ វិហរាមិ ។ តស្ស មយ្ហំ អានន្ទ ឥមិនា វិហារេន វិហរតោ វិញ្ញាណញ្ចា-យតនសហគតា សញ្ញាមនសិការា សមុទាចរន្តិ ស្វាស្ស មេ ហោតិ អាពាធោ សេយ្យថាបិ អានន្ទ សុខិនោ ទុក្ខំ ឧប្បជ្ជេយ្យ យាវទេវ អាពាធាយ ឯវមេវស្ស មេ វិញ្ញាណញ្ចាយតនសហគតា សញ្ញា-មនសិការា សមុទាចរន្តិ ស្វាស្ស មេ ហោតិ អាពាធោ ។

ម្នាលអានន្ទ កាលតថាគតយល់ឃើញថា អាកិញ្ចញ្ញាយតនជ្ឈាននោះ ជារបស់ស្ងប់ដូច្នេះ ចិត្តក៏ត្រឡប់ជាស្ទុះទៅ ជ្រះថ្លា តាំងនៅ ចុះស៊ប់ក្នុងអាកិញ្ចញ្ញាយតនជ្ឈានឡើង ម្នាលអានន្ទ តថាគតនោះ កន្លងបង់នូវវិញ្ញាណញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ហើយចូលកាន់អាកិញ្ចញ្ញាយតនជ្ឈាន ដោយការធ្វើទុកក្នុងចិត្តថា អ្វីតិចតួចមិនមាន ។ ម្នាលអានន្ទ កាលតថាគតនៅដោយវិហារធម៌នេះ សញ្ញានិងមនសិការៈប្រកបដោយវិញ្ញាណញ្ចាយតនជ្ឈាន ក៏ជ្រួលច្រាល់ឡើង ការជ្រួលច្រាល់នៃសញ្ញានិងមនសិការៈនោះ ទុកជាអាពាធ របស់តថាគត ម្នាលអានន្ទ សេចក្ដីទុក្ខ គប្បីកើតឡើង ដល់បុគ្គលដែលធ្លាប់មានសេចក្ដីសុខ សេចក្ដីទុក្ខនោះ នឹងប្រព្រឹត្តទៅ ដើម្បីអាពាធជាកំណត់មានឧបមាដូចម្ដេចមិញ មានឧបមេយ្យ ដូចសញ្ញានិងមនសិការៈរបស់តថាគត ប្រកបដោយវិញ្ញាណញ្ចាយតនជ្ឈាន ដែលជ្រួលច្រាល់ឡើង ការជ្រួលច្រាល់នៃសញ្ញានិងមនសិការៈនោះ ទុកជាអាពាធ របស់តថាគត ដូច្នោះឯង ។

តស្ស មយ្ហំ អានន្ទ ឯតទហោសិ យន្នូនាហំ សព្វសោ អាកិញ្ចញ្ញាយតនំ សមតិក្កម្ម នេវសញ្ញានាសញ្ញាយតនំ ឧបសម្បជ្ជ វិហរេយ្យន្តិ ។ តស្ស មយ្ហំ អានន្ទ នេវសញ្ញានាសញ្ញាយតនេ ចិត្តំ ន បក្ខន្ទតិ នប្បសីទតិ ន សន្តិដ្ឋតិ ន វិមុច្ចតិ ឯតំ សន្តន្តិ បស្សតោ តស្ស មយ្ហំ អានន្ទ ឯតទហោសិ កោ នុ ខោ ហេតុ កោ បច្ចយោ យេន មេ នេវសញ្ញានាសញ្ញាយតនេ ចិត្តំ ន បក្ខន្ទតិ នប្បសីទតិ ន សន្តិដ្ឋតិ ន វិមុច្ចតិ ឯតំ សន្តន្តិ បស្សតោ តស្ស មយ្ហំ អានន្ទ ឯតទហោសិ អាកិញ្ចញ្ញាយតនេ ខោ មេ អាទីនវោ អទិដ្ឋោ សោ ច មេ អពហុលីកតោ នេវសញ្ញានាសញ្ញាយតនេ ច អានិសំសោ អនធិគតោ សោ ច មេ អនាសេវិតោ តស្មា មេ នេវសញ្ញានាសញ្ញាយតនេ ចិត្តំ ន បក្ខន្ទតិ នប្បសីទតិ ន សន្តិដ្ឋតិ ន វិមុច្ចតិ ឯតំ សន្តន្តិ បស្សតោ

ម្នាលអានន្ទ តថាគតមានសេចក្តីត្រិះរិះដូច្នេះថា បើដូច្នោះ គួរតែអញ កន្លងបង់នូវអាកិញ្ចញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង ហើយចូលកាន់នេវសញ្ញានាសញ្ញាយតនជ្ឈាន ។ ម្នាលអានន្ទ កាល តថាគត យល់ឃើញថា នេវសញ្ញានាសញ្ញាយតនជ្ឈាននុ៎ះ ជារបស់ស្ងប់ ដូច្នេះហើយ ចិត្តក៏មិនស្ទុះទៅ មិនជ្រះថ្លា មិនតាំងនៅ មិនចុះស៊ប់ ក្នុងនេវសញ្ញានាសញ្ញាយតនជ្ឈានឡើយ ម្នាលអានន្ទ ទើបតថាគត មានសេចក្តីងឿងឆ្ងល់ដូច្នេះថា ចុះហេតុអ្វី បច្ច័យអ្វី បានជាកាល អញយល់ឃើញថា នេវសញ្ញានាសញ្ញាយតនជ្ឈាននុ៎ះ ជារបស់ស្ងប់ ដូច្នេះហើយ ចិត្តក៏មិនស្ទុះទៅ មិនជ្រះថ្លា មិនតាំងនៅ មិនចុះស៊ប់ក្នុង នេវសញ្ញានាសញ្ញាយតនជ្ឈាន ម្នាលអានន្ទ តថាគតមានសេចក្តីយល់ ឃើញដូច្នេះថា ឱទោស ក្នុងអាកិញ្ចញ្ញាយតនជ្ឈាន អញមិនទាន់ឃើញ ទាំងទោសនោះ អញមិនទាន់ធ្វើឲ្យច្រើន អានិសង្សក្នុងនេវសញ្ញានា-សញ្ញាយតនជ្ឈាន អញមិនទាន់បាន ទាំងអានិសង្សនោះ អញមិន ទាន់សេពគប់ទេតើ បានជាកាលអញ យល់ឃើញថា នេវសញ្ញានា-សញ្ញាយតនជ្ឈាននុ៎ះ ជារបស់ស្ងប់ដូច្នេះហើយ ចិត្តក៏នៅតែមិនស្ទុះទៅ មិនជ្រះថ្លា មិនតាំងនៅ មិនចុះស៊ប់ក្នុងនេវសញ្ញានាសញ្ញាយតនជ្ឈាន

តស្ស មយ្ហំ អានន្ទ ឯតទហោសិ សចេ ខោ អហំ អាកិញ្ចញ្ញាយតនេ អាទីនវំ ទិស្វា តំ ពហុលីការេយ្យំ នេវសញ្ញានាសញ្ញាយតនេ អានិសំសំ អធិគម្ម តមាសេវេយ្យំ ឋានំ ខោ បនេតំ វិជ្ជតិ យំ មេ នេវសញ្ញានាសញ្ញាយតនេ ចិត្តំ បក្ខន្ទេយ្យ បសីទេយ្យ សន្តិដ្ឋេយ្យ វិមុច្ចេយ្យ ឯតំ សន្តន្តិ បស្សតោ សោ ខោ អហំ អានន្ទ អបរេន សមយេន អាកិញ្ចញ្ញាយតនេ អាទីនវំ ទិស្វា តំ ពហុលមកាសឹ នេវសញ្ញានាសញ្ញាយតនេ អានិសំសំ អធិគម្ម តមាសេវឹ តស្ស មយ្ហំ អានន្ទ នេវសញ្ញានាសញ្ញាយតនេ ចិត្តំ បក្ខន្ទតិ បសីទតិ សន្តិដ្ឋតិ វិមុច្ចតិ ឯតំ សន្តន្តិ បស្សតោ សោ ខោ អហំ អានន្ទ សព្វសោ អាកិញ្ចញ្ញាយតនំ សមតិក្កម្ម នេវសញ្ញានាសញ្ញាយតនំ ឧបសម្បជ្ជ វិហរាមិ ។ តស្ស មយ្ហំ អានន្ទ ឥមិនា វិហារេន វិហរតោ អាកិញ្ចញ្ញាយតនសហគតា សញ្ញាមនសិការា សមុទាចរន្តិ

ម្នាលអានន្ទ ទើបតថាគតមានសេចក្ដីត្រិះរិះដូច្នេះថា បើអញឃើញទោស ក្នុងអាកិញ្ចញ្ញាយតនជ្ឈានហើយ គប្បីធ្វើនូវការឃើញទោសនោះឲ្យច្រើន បើបានអានិសង្ស ក្នុងនេវសញ្ញានាសញ្ញាយតនជ្ឈានហើយ គប្បីសេពគប់នូវអានិសង្សនោះ ហេតុនេះ តែងមានជាប្រាកដ ត្រង់ពាក្យថា កាលអញ យល់ឃើញថា នេវសញ្ញា-នាសញ្ញាយតនជ្ឈាននុ៎ះ ជារបស់ស្ងប់ដូច្នេះហើយ ចិត្តគប្បីស្ទុះទៅ ជ្រះថ្លា តាំងនៅ ចុះស៊ប់ក្នុងនេវសញ្ញានាសញ្ញាយតនជ្ឈាន ម្នាលអានន្ទ លុះសម័យខាងក្រោយមក តថាគតនោះឯង ឃើញទោសក្នុងអាកិញ្ចញ្ញាយតនជ្ឈានហើយ ក៏ធ្វើនូវការឃើញទោសនោះ ឲ្យច្រើន បាននូវអានិសង្ស ក្នុងនេវសញ្ញានាសញ្ញាយតនជ្ឈានហើយ ក៏សេពគប់នូវអានិសង្សនោះ ម្នាលអានន្ទ កាលតថាគត យល់ឃើញថា នេវ-សញ្ញានាសញ្ញាយតនជ្ឈាននុ៎ះ ជារបស់ស្ងប់ដូច្នេះ ចិត្តក៏ត្រឡប់ជាស្ទុះទៅ ជ្រះថ្លា តាំងនៅ ចុះស៊ប់ក្នុងនេវសញ្ញានាសញ្ញាយតនជ្ឈានឡើង ម្នាលអានន្ទ តថាគតនោះឯងកន្លងបង់នូវអាកិញ្ចញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង ហើយចូលកាន់នេវសញ្ញានាសញ្ញាយតនជ្ឈាន ។ ម្នាលអានន្ទ កាលតថាគត នៅដោយវិហារធម៌នេះ សញ្ញានិងមនសិការៈ ដែលប្រកបដោយអាកិញ្ចញ្ញាយតនជ្ឈាន ក៏ជ្រួលច្រាល់ឡើង

ស្វាស្ស មេ ហោតិ អាពាធោ សេយ្យថាបិ អានន្ទ សុខិនោ ទុក្ខំ ឧប្បជ្ជេយ្យ យាវទេវ អាពាធាយ ឯវមេ-វស្ស មេ អាកិញ្ចញ្ញាយតនសហគតា សញ្ញាមន-សិការា សមុទាចរន្តិ ស្វាស្ស មេ ហោតិ អាពាធោ ។

តស្ស មយ្ហំ អានន្ទ ឯតទហោសិ យន្នូនាហំ នេវសញ្ញានាសញ្ញាយតនំ សមតិក្កម្ម សញ្ញាវេទយិត-និរោធំ ឧបសម្បជ្ជ វិហរេយ្យន្តិ ។ តស្ស មយ្ហំ អានន្ទ សញ្ញាវេទយិតនិរោធេ ចិត្តំ ន បក្ខន្ទតិ នប្បសីទតិ ន សន្តិដ្ឋតិ ន វិមុច្ចតិ ឯតំ សន្តន្តិ បស្សតោ តស្ស មយ្ហំ អានន្ទ ឯតទហោសិ កោ នុ ខោ ហេតុ កោ បច្ចយោ យេន មេ សញ្ញា-វេទយិតនិរោធេ ចិត្តំ ន បក្ខន្ទតិ នប្បសីទតិ ន សន្តិដ្ឋតិ ន វិមុច្ចតិ ឯតំ សន្តន្តិ បស្សតោ តស្ស មយ្ហំ អានន្ទ ឯតទហោសិ នេវសញ្ញានាសញ្ញា-យតនេ ខោ មេ អាទីនវោ អទិដ្ឋោ សោ ច មេ អពហុលីកតោ សញ្ញាវេទយិតនិរោធេ ច អានិសំសោ អនធិគតោ សោ ច មេ អនាសេវិតោ

ការជ្រួលច្រាល់នៃសញ្ញានិងមនសិការៈនោះ ទុកជាអាពាធរបស់តថាគត ម្នាលអានន្ទ សេចក្តីទុក្ខគប្បីកើតឡើង ដល់បុគ្គលដែលធ្លាប់មានសេចក្តីសុខ សេចក្តីទុកនោះនឹងប្រព្រឹត្តទៅ ដើម្បីអាពាធជាកំណត់ មានឧបមាដូចម្តេចមិញ មានឧបមេយ្យដូចសញ្ញានិងមនសិការៈរបស់តថាគត ដែលប្រកបដោយអាកិញ្ចញ្ញាយតនជ្ឈាន ដែលជ្រួលច្រាល់ឡើង ការជ្រួលច្រាល់នៃសញ្ញានិងមនសិការៈនោះ ទុកជាអាពាធរបស់តថាគតដូច្នោះឯង ។

ម្នាលអានន្ទ តថាគតមានសេចក្តីត្រិះរិះដូច្នេះថា បើដូច្នោះ គួរតែអញកន្លងបង់នូវនេវសញ្ញានាសញ្ញាយតនជ្ឈាន ហើយចូលកាន់សញ្ញាវេទយិតនិរោធ ។ ម្នាលអានន្ទ កាលតថាគត យល់ឃើញថា សញ្ញាវេទយិតនិរោធនុ៎ះ ជារបស់ស្ងប់ដូច្នេះហើយ ចិត្តក៏មិនស្ទុះទៅ មិនជ្រះថ្លា មិនតាំងនៅ មិនចុះស៊ប់ក្នុងសញ្ញាវេទយិតនិរោធឡើយ ម្នាលអានន្ទ ទើបតថាគតមានសេចក្តីងឿងឆ្ងល់ថា ចុះហេតុអ្វី បច្ច័យអ្វី បានជាកាលអញយល់ឃើញថា សញ្ញាវេទយិតនិរោធនុ៎ះ ជារបស់ស្ងប់ដូច្នេះហើយ ចិត្តក៏មិនស្ទុះទៅ មិនជ្រះថ្លា មិនតាំងនៅ មិនចុះស៊ប់ក្នុងសញ្ញាវេទយិតនិរោធ ម្នាលអានន្ទ តថាគតមានសេចក្តីយល់ឃើញដូច្នេះថា ឱទោស ក្នុងនេវសញ្ញានាសញ្ញាយតនជ្ឈាន អញមិនទាន់ឃើញ ទាំងទោសនោះ អញមិនទាន់ធ្វើឲ្យច្រើន អានិសង្សក្នុងសញ្ញាវេទយិតនិរោធ អញមិនទាន់បាន

តស្មា មេ សញ្ញាវេទយិតនិរោធេ ចិត្តំ ន បក្ខន្ទតិ នប្បសីទតិ ន សន្តិដ្ឋតិ ន វិមុច្ចតិ ឯតំ សន្តន្តិ បស្សតោ តស្ស មយ្ហំ អានន្ទ ឯតទហោសិ សចេ ខោ អហំ នេវសញ្ញានាសញ្ញាយតនេ អាទីនវំ ទិស្វា តំ ពហុលីករេយ្យំ សញ្ញាវេទយិតនិរោធេ អានិសំសំ អធិគម្ម តមាសេវេយ្យំ ឋានំ ខោ បនេតំ វិជ្ជតិ យំ មេ សញ្ញាវេទយិតនិរោធេ ចិត្តំ បក្ខន្ទេយ្យ បសីទេយ្យ សន្តិដ្ឋេយ្យ វិមុច្ចេយ្យ ឯតំ សន្តន្តិ បស្សតោ សោ ខោ អហំ អានន្ទ អបរេន សមយេន នេវសញ្ញានាសញ្ញាយតនេ អាទីនវំ ទិស្វា តំ ពហុលមកាសឹ សញ្ញាវេទយិត-និរោធេ អានិសំសំ អធិគម្ម តមាសេវឹ តស្ស មយ្ហំ អានន្ទ សញ្ញាវេទយិតនិរោធេ ចិត្តំ បក្ខន្ទតិ បសីទតិ សន្តិដ្ឋតិ វិមុច្ចតិ ឯតំ សន្តន្តិ បស្សតោ សោ ខោ អហំ អានន្ទ សព្វសោ នេវសញ្ញានាសញ្ញា-យតនំ សមតិក្កម្ម សញ្ញាវេទយិតនិរោធំ ឧបសម្បជ្ជ

ទាំងអានិសង្សនោះ អញមិនទាន់សេពគប់ទេតើ បានជាកាលអញយល់ឃើញថា សញ្ញាវេទយិតនិរោធនុ៎ះ ជារបស់ស្ងប់ដូច្នេះហើយ ចិត្តក៏នៅតែមិនស្ទុះទៅ មិនជ្រះថ្លា មិនតាំងនៅ មិនចុះស៊ប់ក្នុងសញ្ញាវេទយិ-តនិរោធ ម្នាលអានន្ទ ទើបតថាគតមានសេចក្តីត្រិះរិះដូច្នេះថា បើអញឃើញទោស ក្នុងនេវសញ្ញានាសញ្ញាយតនជ្ឈានហើយ គប្បីធ្វើនូវការឃើញទោសនោះ ឲ្យច្រើន បាននូវអានិសង្សក្នុងសញ្ញាវេទយិតនិរោធហើយ គប្បីសេពគប់នូវអានិសង្សនោះ ហេតុនេះ តែងមានជាប្រាកដត្រង់ពាក្យថា កាលអញ យល់ឃើញថា សញ្ញាវេទយិតនិរោធនុ៎ះជារបស់ស្ងប់ដូច្នេះហើយ ចិត្តគប្បីស្ទុះទៅ ជ្រះថ្លា តាំងនៅ ចុះស៊ប់ក្នុងសញ្ញាវេទយិតនិរោធបាន ម្នាលអានន្ទ លុះសម័យខាងក្រោយមកតថាគតនោះឯង ឃើញទោសក្នុងនេវសញ្ញានាសញ្ញាយតនជ្ឈានហើយក៏ធ្វើនូវការឃើញទោសនោះ ឲ្យច្រើន បាននូវអានិសង្សក្នុងសញ្ញាវេទ-យិតនិរោធហើយ ក៏សេពគប់នូវអានិសង្សនោះ ម្នាលអានន្ទ កាលតថាគតយល់ឃើញថា សញ្ញាវេទយិតនិរោធនុ៎ះ ជារបស់ស្ងប់ដូច្នេះ ចិត្តក៏ត្រឡប់ជាស្ទុះទៅ ជ្រះថ្លា តាំងនៅ ចុះស៊ប់ក្នុងសញ្ញាវេទយិតនិរោធឡើង ម្នាលអានន្ទ តថាគតនោះឯង កន្លងបង់នូវនេវសញ្ញានាសញ្ញា-យតនជ្ឈាន ដោយប្រការទាំងពួង ហើយចូលកាន់សញ្ញាវេទយិតនិរោធ

១៩៧



វិហាភមិ បញ្ញាយ ច មេ ទិស្វា អាសវា បរិក្ខយំ អគមំសុ ។

យាវកីវញ្ចាហំ អានន្ទ ឥមា នវ អនុបុព្វវិហារសមាបត្តិយោ ន ឯវំ អនុលោមប្បដិលោមំ សមាបជ្ជិម្បិ វុដ្ឋហិម្បិ នេវ តាវាហំ អានន្ទ សទេវកេ លោកេ សមារកេ សព្រហ្មកេ សស្សមណព្រាហ្មណិយា បជាយ សទេវមនុស្សាយ អនុត្តរំ សម្មាសម្ពោធឹ អភិសម្ពុទ្ធោ បច្ចញ្ញាសឹ យតោ ច ខោ អហំ អានន្ទ ឥមា នវ អនុបុព្វវិហារសមាបត្តិយោ ឯវំ អនុលោមប្បដិលោមំ សមាបជ្ជិម្បិ វុដ្ឋហិម្បិ អថាហំ អានន្ទ សទេវកេ លោកេ សមារកេ សព្រហ្មកេ សស្សមណព្រាហ្មណិយា បជាយ សទេវមនុស្សាយ អនុត្តរំ សម្មាសម្ពោធឹ អភិសម្ពុទ្ធោ បច្ចញ្ញាសឹ ញាណញ្ច បន មេ ទស្សនំ ឧទបាទិ អកុប្បា មេ ចេតោវិមុត្តិ អយមន្តិមា ជាតិ នត្ថិទានិ បុនព្ភវោតិ ។

មហាវគ្គោ ចតុត្ថោ ។

ឯអាសវៈទាំងឡាយ របស់តថាគត ក៏ដល់នូវការអស់រលីងទៅ ព្រោះឃើញដោយប្រាជ្ញា ។

ម្នាលអានន្ទ អនុបុព្វវិហារសមាបត្តិទាំង ៩ នេះ តថាគត មិនទាន់ចូលផង មិនទាន់ចេញផង ជាអនុលោមប្បដិលោម យ៉ាងនេះបាន ដរាបណា ម្នាលអានន្ទ តថាគតក៏មិនទាន់ហ៊ានប្តេជ្ញាថា ជាអ្នកត្រាស់ដឹងច្បាស់ នូវសម្មាសម្ពោធិញ្ញាណដ៏ប្រសើរ ក្នុងលោកនេះ ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វ ព្រមទាំងសមណៈនិងព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស ដរាបនោះឡើយ ម្នាលអានន្ទ លុះតែអនុបុព្វវិហារសមាបត្តិទាំង ៩ នេះ តថាគតចូលផង ចេញផង ជាអនុលោមប្បដិលោម យ៉ាងនេះបាន ក្នុងកាលណា ម្នាលអានន្ទ ទើបតថាគត ហ៊ានប្តេជ្ញាថា ជាអ្នកត្រាស់ដឹងច្បាស់ នូវសម្មាសម្ពោធិញ្ញាណដ៏ប្រសើរ ក្នុងលោកនេះ ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វ ព្រមទាំងសមណៈនិងព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស ក្នុងកាលនោះ ឯញាណ-ទស្សនៈ (ការដឹងនិងការឃើញ) ក៏កើតឡើងដល់តថាគតថា ចេតោវិមុត្តិរបស់អញមិនកម្រើក នេះជាតិជាទីបំផុត (របស់អញ) ភពថ្មីក្នុងកាលឥឡូវនេះ មិនមានឡើយ ។

ចប់មហាវគ្គទី ៤ ។

## តត្រុទ្ធានំ ភវតិ[(១)]

ទ្វេ វិហារេ ច និព្វានំ តាវី ឈានេន បញ្ចមំ អានន្ទោ ព្រាហ្មណោ[(២)] ទេវា ឯតេន តបុស្សេន ចាតិ ។

---

១ ឱ. ម. តត្រុទ្ធានំ ។ ២ ឱ. ព្រាហ្មណា ។

# ឧទ្ទានក្នុងមហាវគ្គនោះ គឺ

*និយាយអំពីអនុបុព្វវិហារធម៌ ២ លើក ព្រះនិព្វាន ១ មេគោ ១ ឈាន ជាគម្រប់ ៥ ព្រះអានន្ទ ១ លោកាយតិកព្រាហ្មណ៍ ១ សង្គ្រាមរបស់ទេវតានិងអសុរ ១ ដំរីដ៏ប្រសើរ ១ តបុស្សគហបតី ១ ។*

---

# បញ្ចមោ បញ្ចាលវគ្គោ

[៤២] ឯកំ សមយំ អាយស្មា អានន្ទោ កោសម្ពិយំ វិហរតិ ឃោសិតារាមេ ។ អថខោ អាយស្មា ឧទាយិ យេនាយស្មា អានន្ទោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មតា អានន្ទេន សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា ឧទាយិ អាយស្មន្តំ អានន្ទំ ឯតទវោច វុត្តមិទំ អាវុសោ បញ្ចាលចណ្ឌេន ទេវបុត្តេន

សម្ពាធេ គតំ ឱកាសំ អវិទា ភូរិមេធសោ
យោ ឈានមពុជ្ឈិ ពុទ្ធោ បដិលីននិសភោ មុនីតិ ។

កតមោ[១] អាវុសោ សម្ពាធោ ។ កតមោ សម្ពាធេ ឱកាសាធិគមោ វុត្តោ ភគវតាតិ ។ បញ្ចិមេ អាវុសោ កាមគុណា សម្ពាធោ វុត្តោ ភគវតា ។ កតមេ បញ្ច ។

---

១ ឱ. កតមោ នុ ខោ ។

# បញ្ចាលវគ្គទី ៥

[៤២] សម័យមួយ ព្រះអានន្ទដ៏មានអាយុ កាលគង់នៅ ក្នុងឃោសិតារាម ជិតក្រុងកោសម្ពី ។ គ្រានោះ ព្រះឧទាយិដ៏មានអាយុ បានចូលទៅរកព្រះអានន្ទដ៏មានអាយុ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយជាមួយនឹងព្រះអានន្ទដ៏មានអាយុ លុះបញ្ចប់ពាក្យដែលគួររីករាយនិងពាក្យដែលគួររលឹកហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះព្រះឧទាយិដ៏មានអាយុ អង្គុយក្នុងទីដ៏សមគួរហើយ បាននិយាយនឹងព្រះអានន្ទដ៏មានអាយុដូច្នេះថា ម្នាលអាវុសោ ទេវបុត្រឈ្មោះបញ្ចាលចណ្ឌ ពោលនូវពាក្យនេះថា

បុគ្គលណាមានបញ្ញាក្រាស់ ដូចផែនដី ជ្រាបច្បាស់នូវ
ឱកាសដែលតាំងនៅ ក្នុងទីចង្អៀត ជាព្រះពុទ្ធ ត្រាស់ដឹងនូវ
ឈាន បុគ្គលនោះ ជាអ្នកប្រាជ្ញ លាក់ខ្លួននិងប្រសើរបំផុត ។

ម្នាលអាវុសោ ទីចង្អៀតនោះ តើដូចម្តេចខ្លះ ។ ការត្រាស់ដឹងនូវឱកាស ក្នុងទីចង្អៀត ដែលព្រះដ៏មានព្រះភាគសម្តែងហើយ តើដូចម្តេចខ្លះ ។ ម្នាលអាវុសោ កាមគុណ ៥ យ៉ាងនេះ ព្រះដ៏មានព្រះភាគទ្រង់សម្តែងថា ទីចង្អៀត ។ កាមគុណ ៥ យ៉ាង តើដូចម្តេចខ្លះ ។

ចក្ខុវិញ្ញេយ្យា រូបា ឥដ្ឋា កន្តា មនាបា បិយរូបា កាមូបសញ្ហិតា រជនីយា សោតវិញ្ញេយ្យា សទ្ទា ។ បេ ។ ឃានវិញ្ញេយ្យា គន្ធា ជិវ្ហាវិញ្ញេយ្យា រសា កាយវិញ្ញេយ្យា ផោដ្ឋព្វា ឥដ្ឋា កន្តា មនាបា បិយរូបា កាមូបសញ្ហិតា រជនីយា ។ ឥមេ ខោ អាវុសោ បញ្ច កាមគុណា សម្ពាធោ វុត្តោ ភគវតា ។ ឥធាវុសោ ភិក្ខុ វិវិច្ចេវ កាមេហិ ។ បេ ។ បឋមជ្ឈានំ ឧបសម្បជ្ជ វិហរតិ ឯត្តាវតាបិ ខោ អាវុសោ សម្ពាធេ ឱកាសាធិគមោ វុត្តោ ភគវតា បរិយាយេន ។ តត្របត្ថិ[១] សម្ពាធោ កិញ្ច តត្ថ សម្ពាធោ ។ យទេវ តត្ថ វិតក្កវិចារា អនិរុទ្ធា ហោន្តិ អយមេត្ថ សម្ពាធោ ។ បុន ចបរំ អាវុសោ ភិក្ខុ

១ ឱ. តត្ថបត្ថិ ។ ម. តត្រាបត្ថិ ។

គឺរូបដែលគប្បីដឹងដោយចក្ខុ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត មានសភាពជាទីស្រឡាញ់ ប្រកបដោយកាម ជាហេតុនៃសេចក្តីត្រេកអរ ១ សំឡេងដែលគប្បីដឹងដោយសោតៈ ១ ។ បេ ។ ក្លិនដែលគប្បីដឹងដោយច្រមុះ ១ រសដែលគប្បីដឹងដោយអណ្តាត ១ ផ្សព្វដែលគប្បីដឹងច្បាស់ដោយកាយ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត មានសភាពជាទីស្រឡាញ់ ប្រកបដោយកាម ជាហេតុនៃសេចក្តីត្រេកអរ ១ ។ ម្នាលអាវុសោ កាមគុណ ៥ យ៉ាងនេះឯង ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សម្តែងថា ទីចង្អៀត ។ ម្នាលអាវុសោ ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ បានដល់នូវបឋមជ្ឈាន ម្នាលអាវុសោ ការត្រាស់ដឹងនូវឱកាស ក្នុងទីចង្អៀត ដែលព្រះដ៏មានព្រះភាគត្រាស់សម្តែងហើយ ដោយបរិយាយ មានប្រមាណប៉ុណ្ណោះឯង ។ ទីចង្អៀតតែងមាន ក្នុងបឋមជ្ឈាននោះ ទីចង្អៀតក្នុងបឋមជ្ឈាននោះ តើដូចម្តេច ។ កាលណា បើវិតក្កៈនិងវិចារៈ ក្នុងបឋមជ្ឈាននោះ មិនទាន់រលត់ទៅទេ កាលនោះវិតក្កៈនិងវិចារៈនេះ ឈ្មោះថាជាទីចង្អៀត ក្នុងបឋមជ្ឈានទុំះ ។ ម្នាលអាវុសោ មួយទៀត ភិក្ខុ

២០១



វិតក្កវិចារានំ វូបសមា ។ បេ ។ ទុតិយជ្ឈានំ ឧបសម្បជ្ជ វិហរតិ ឯត្តាវតាបិ ខោ អាវុសោ សម្ពាធេ ឱកាសាធិគមោ វុត្តោ ភគវតា បរិយាយេន ។ តត្របត្ថិ សម្ពាធោ កិញ្ច តត្ថ សម្ពាធោ ។ យទេវ តត្ថ បីតិ អនិរុទ្ធា ហោតិ អយមេត្ថ សម្ពាធោ ។ បុន ចបរំ អាវុសោ ភិក្ខុ បីតិយា ច វិរាគា ។ បេ ។ តតិយជ្ឈានំ ឧបសម្បជ្ជ វិហរតិ ឯត្តាវតាបិ ខោ អាវុសោ សម្ពាធេ ឱកាសាធិគមោ វុត្តោ ភគវតោ បរិយាយេន ។ តត្របត្ថិ សម្ពាធោ កិញ្ច តត្ថ សម្ពាធោ ។ យទេវ តត្ថ ឧបេក្ខាសុខំ អនិរុទ្ធំ ហោតិ អយមេត្ថ សម្ពាធោ ។ បុន ចបរំ អាវុសោ ភិក្ខុ សុខស្ស ច បហានា ។ បេ ។ ចតុត្ថជ្ឈានំ ឧបសម្បជ្ជ វិហរតិ ឯត្តាវតាបិ ខោ អាវុសោ សម្ពាធេ ឱកាសាធិគមោ វុត្តោ ភគវតា បរិយាយេន ។

ព្រោះស្ងប់រម្ងាប់នូវវិតក្កៈនិងវិចារៈ ។ បេ ។ បានដល់នូវទុតិយជ្ឈាន ម្នាលអាវុសោ ការត្រាស់ដឹងនូវឱកាស ក្នុងទីចង្អៀត ដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់សម្តែងហើយ ដោយបរិយាយមានប្រមាណប៉ុណ្ណោះឯង ។ ទីចង្អៀតតែងមាន ក្នុងទុតិយជ្ឈាននោះ ទីចង្អៀតក្នុងទុតិយ-ជ្ឈាននោះ តើដូចម្តេច ។ កាលណា បើបីតិ ក្នុងទុតិយជ្ឈាននោះ មិនទាន់រលត់ទៅទេ កាលនោះ ភាពមិនរលត់ទៅនៃបីតិនេះ ឈ្មោះថាទីចង្អៀត ក្នុងទុតិយជ្ឈាននុ៎ះ ។ ម្នាលអាវុសោ មួយទៀត ភិក្ខុ ព្រោះប្រាសចាកបីតិផង ។ បេ ។ បានដល់នូវតតិយជ្ឈាន ម្នាលអាវុសោ ការត្រាស់ដឹងនូវឱកាស ក្នុងទីចង្អៀត ដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់សម្តែងហើយ ដោយបរិយាយ ត្រឹមប៉ុណ្ណោះឯង ។ ទីចង្អៀតតែងមាន ក្នុងតតិយជ្ឈាននោះ ទីចង្អៀតក្នុងតតិយជ្ឈាននោះ តើដូចម្តេច ។ កាលណា បើឧបេក្ខានិងសុខៈ ក្នុងតតិយជ្ឈាននោះ មិនទាន់រលត់ទៅទេ កាលនោះ ភាពមិនរលត់ទៅនៃឧបេក្ខា និងសុខៈនេះឈ្មោះថា ទីចង្អៀត ក្នុងតតិយជ្ឈាននុ៎ះ ។ ម្នាលអាវុសោ មួយទៀត ភិក្ខុព្រោះលះបង់នូវសេចក្តីសុខផង ។ បេ ។ បានដល់នូវចតុត្ថជ្ឈាន ម្នាលអាវុសោ ការត្រាស់ដឹងនូវឱកាស ក្នុងទីចង្អៀត ដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់សម្តែងហើយ ដោយបរិយាយ ត្រឹមប៉ុណ្ណោះឯង ។

តត្របត្ថិ សម្ពាធោ កិញ្ច តត្ថ សម្ពាធោ ។ យទេវ តត្ថ រូបសញ្ញា អនិរុទ្ធា ហោតិ អយមេត្ថ សម្ពាធោ ។ បុន ចបរំ អាវុសោ ភិក្ខុ សព្វសោ រូបសញ្ញានំ សមតិក្កមា បដិឃសញ្ញានំ អត្ថង្គមា នានត្តសញ្ញានំ អមនសិការា អនន្តោ អាកាសោតិ អាកាសានញ្ចាយតនំ ឧបសម្បជ្ជ វិហរតិ ឯត្តាវតាបិ ខោ អាវុសោ សម្ពាធេ ឱកាសាធិគមោ វុត្តោ ភគវតា បរិយាយេន ។ តត្របត្ថិ សម្ពាធោ កិញ្ច តត្ថ សម្ពាធោ ។ យទេវ តត្ថ អាកាសានញ្ចាយតនសញ្ញា អនិរុទ្ធា ហោតិ អយមេត្ថ សម្ពាធោ ។ បុន ចបរំ អាវុសោ ភិក្ខុ សព្វសោ អាកាសានញ្ចាយតនំ សមតិក្កម្ម អនន្តំ វិញ្ញាណន្តិ វិញ្ញាណញ្ចាយតនំ ឧបសម្បជ្ជ វិហរតិ

ទីចង្អៀតរមែងមាន ក្នុងចតុត្ថជ្ឈាននោះ ទីចង្អៀតក្នុងចតុត្ថជ្ឈាននោះ តើដូចម្ដេច ។ កាលណា បើរូបសញ្ញា ក្នុងចតុត្ថជ្ឈាននោះ មិនទាន់រលត់ទៅទេ កាលនោះ ភាពមិនរលត់ទៅ នៃរូបសញ្ញានេះ ឈ្មោះថា ទីចង្អៀត ក្នុងចតុត្ថជ្ឈាននុ៎ះ ។ ម្នាលអាវុសោ មួយទៀត ភិក្ខុបានដល់នូវអាកាសានញ្ចាយតនជ្ឈាន ដោយការធ្វើទុកក្នុងចិត្តថា អាកាសមិនមានទីបំផុតដូច្នេះ ព្រោះកន្លងនូវរូបសញ្ញា ព្រោះរលត់នូវបដិឃសញ្ញា ព្រោះមិនធ្វើទុកក្នុងចិត្តនូវនានត្តសញ្ញា ដោយប្រការទាំងពួង ម្នាលអាវុសោ ការត្រាស់ដឹងនូវឱកាស ក្នុងទីចង្អៀត ដែលព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សម្ដែងហើយ ដោយបរិយាយត្រឹមប៉ុណ្ណេះឯង ។ ទីចង្អៀត រមែងមានក្នុងអាកាសានញ្ចាយតនជ្ឈាននោះ ទីចង្អៀត ក្នុងអាកាសានញ្ចាយតនជ្ឈាននោះ តើដូចម្ដេច ។ កាលណា បើអាកាសានញ្ចាយតនសញ្ញា ក្នុងអាកាសានញ្ចាយតនជ្ឈាននោះ មិនទាន់រលត់ទៅទេ កាលនោះ ភាពមិនរលត់ទៅនៃអាកាសានញ្ចាយតនសញ្ញានេះ ឈ្មោះថាទីចង្អៀត ក្នុងអាកាសានញ្ចាយតនជ្ឈាននុ៎ះ ។ ម្នាលអាវុសោ មួយទៀត ភិក្ខុបានដល់នូវវិញ្ញាណញ្ចាយតនជ្ឈាន ដោយការធ្វើទុកក្នុងចិត្តថា វិញ្ញាណមិនមានទីបំផុតដូច្នេះ ព្រោះកន្លងនូវអាកាសានញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង

២០៣

បណ្ណាសកេ បញ្ចាលវគ្គោ

ឯត្តាវតាបិ ខោ អាវុសោ សម្ពាធេ ឱកាសាធិគមោ វុត្តោ ភគវតា បរិយាយេន ។ តត្របត្ថិ សម្ពាធោ កិញ្ច តត្ថ សម្ពាធោ ។ យទេវ តត្ថ វិញ្ញាណញ្ចាយតនសញ្ញា អនិរុទ្ធា ហោតិ អយមេត្ថ សម្ពាធោ ។ បុន ចបរំ អាវុសោ ភិក្ខុ សព្វសោ វិញ្ញាណញ្ចាយតនំ សមតិក្កម្ម នត្ថិ កិញ្ចីតិ អាកិញ្ចញ្ញាយតនំ ឧបសម្បជ្ជ វិហរតិ ឯត្តាវតាបិ ខោ អាវុសោ សម្ពាធេ ឱកាសាធិគមោ វុត្តោ ភគវតា បរិយាយេន ។ តត្របត្ថិ សម្ពាធោ កិញ្ច តត្ថ សម្ពាធោ ។ យទេវ តត្ថ អាកិញ្ចញ្ញាយតនសញ្ញា អនិរុទ្ធា ហោតិ អយមេត្ថ សម្ពាធោ ។

ម្នាលអាវុសោ ការត្រាស់ដឹងនូវឱកាស ក្នុងទីចង្អៀត ដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់សម្តែងហើយ ដោយបរិយាយ ត្រឹមប៉ុណ្ណោះឯង ។ ទីចង្អៀតរមែងមាន ក្នុងវិញ្ញាណញ្ចាយតនជ្ឈាននោះ ទីចង្អៀតក្នុងវិញ្ញាណញ្ចាយតនជ្ឈាននោះ តើដូចម្តេច ។ កាលណា បើវិញ្ញា-ណញ្ចាយតនសញ្ញា ក្នុងវិញ្ញាណញ្ចាយតនជ្ឈាននោះ មិនទាន់រលត់ទៅទេ កាលនោះ ភាពមិនរលត់ទៅនៃវិញ្ញាណញ្ចាយតនសញ្ញានេះ ឈ្មោះថាទីចង្អៀត ក្នុងវិញ្ញាណញ្ចាយតនជ្ឈាននុ៎ះ ។ ម្នាលអាវុសោ មួយទៀត ភិក្ខុបានដល់នូវអាកិញ្ចញ្ញាយតនជ្ឈាន ដោយការធ្វើទុកក្នុងចិត្តថា វត្ថុតិចតួចមិនមានដូច្នេះ ព្រោះកន្លងនូវវិញ្ញាណញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ម្នាលអាវុសោ ការត្រាស់ដឹងនូវឱកាស ក្នុងទីចង្អៀត ដែលព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សម្តែងហើយ ដោយបរិយាយ ត្រឹមប៉ុណ្ណោះឯង ។ ទីចង្អៀតរមែងមាន ក្នុងអាកិញ្ចញ្ញាយ-តនជ្ឈាននោះ ទីចង្អៀតក្នុងអាកិញ្ចញ្ញាយតនជ្ឈាននោះ តើដូចម្តេច ។ កាលណា បើអាកិញ្ចញ្ញាយតនសញ្ញា ក្នុងអាកិញ្ចញ្ញាយតនជ្ឈាននោះ មិនទាន់រលត់ទៅទេ កាលនោះ ភាពមិនរលត់ទៅនៃអាកិញ្ចញ្ញា-យតនសញ្ញានេះ ឈ្មោះថាទីចង្អៀត ក្នុងអាកិញ្ចញ្ញាយតនជ្ឈាននុ៎ះ ។

បុន ចបរំ អាវុសោ ភិក្ខុ សព្វសោ អាកិញ្ចញ្ញាយតនំ សមតិក្កម្ម នេវសញ្ញានាសញ្ញាយតនំ ឧបសម្បជ្ជ វិហរតិ ឯត្តាវតាបិ ខោ អាវុសោ សម្ពាធេ ឱកាសាធិគមោ វុត្តោ ភគវតា បរិយាយេន ។ តត្របត្ថិ សម្ពាធោ កិញ្ច តត្ថ សម្ពាធោ ។ យទេវ តត្ថ នេវសញ្ញានាសញ្ញាយតនសញ្ញា អនិរុទ្ធា ហោតិ អយមេត្ថ សម្ពាធោ ។ បុន ចបរំ អាវុសោ ភិក្ខុ សព្វសោ នេវសញ្ញានាសញ្ញាយតនំ សមតិក្កម្ម សញ្ញាវេទយិតនិរោធំ ឧបសម្បជ្ជ វិហរតិ បញ្ញាយ-បស្ស ចិស្វា អាសវា បរិក្ខីណា ហោន្តិ ឯត្តាវតាបិ ខោ អាវុសោ សម្ពាធេ ឱកាសាធិគមោ វុត្តោ ភគវតា និប្បរិយាយេនាតិ ។

ម្នាលអាវុសោ មួយទៀត ភិក្ខុបានដល់នូវនេវសញ្ញានាសញ្ញាយតនជ្ឈាន ព្រោះកន្លងនូវអាកិញ្ចញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង ម្នាលអាវុសោ ការត្រាស់ដឹងនូវឱកាស ក្នុងទីចង្អៀត ដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់សម្តែងហើយ ដោយបរិយាយ ត្រឹមប៉ុណ្ណោះឯង ។ ទីចង្អៀត រមែងមានក្នុងនេវសញ្ញានាសញ្ញាយតនជ្ឈាននោះ ទីចង្អៀត ក្នុងនេវសញ្ញានាសញ្ញាយតនជ្ឈាននោះ តើដូចម្តេច ។ កាលណា បើនេវសញ្ញានាសញ្ញាយតនសញ្ញា ក្នុងនេវសញ្ញានាសញ្ញាយតនជ្ឈាន នោះ មិនទាន់រលត់ទៅទេ កាលនោះ ភាពមិនរលត់ទៅនៃនេវសញ្ញានាសញ្ញាយតនសញ្ញានេះ ឈ្មោះថាទីចង្អៀត ក្នុងនេវសញ្ញានាសញ្ញាយតនជ្ឈាននុ៎ះ ។ ម្នាលអាវុសោ មួយទៀត ភិក្ខុបាន ដល់នូវសញ្ញាវេទយិតនិរោធ ព្រោះកន្លងនូវនេវសញ្ញានាសញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង អាសវៈទាំងឡាយរបស់ភិក្ខុនោះ ក៏អស់រលីងទៅ ព្រោះឃើញដោយបញ្ញា ម្នាលអាវុសោ ការត្រាស់ដឹងនូវឱកាស ក្នុងទីចង្អៀត ដែលព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សម្តែងហើយ ដោយនិប្បរិយាយ ត្រឹមប៉ុណ្ណោះឯង ។

[៤៣] កាយសក្ខី កាយសក្ខីតិ អាវុសោ វុច្ចតិ កិត្តាវតា នុ ខោ អាវុសោ កាយសក្ខី វុត្តោ ភគវតាតិ ។ ឥធាវុសោ ភិក្ខុ វិវិច្ចេវ កាមេហិ ។ បេ ។ បឋមជ្ឈានំ ឧបសម្បជ្ជ វិហរតិ យថា យថា ច តទាយតនំ តថា តថា នំ កាយេន ផុសិត្វា វិហរតិ ឯត្តាវតាបិ ខោ អាវុសោ កាយសក្ខី វុត្តោ ភគវតា បរិយាយេន ។ បុន ចបរំ អាវុសោ ភិក្ខុ វិតក្កវិចារានំ វូបសមា ។ បេ ។ ទុតិយជ្ឈានំ តតិយជ្ឈានំ ចតុត្ថជ្ឈានំ ឧបសម្បជ្ជ វិហរតិ យថា យថា ច តទាយតនំ តថា តថា នំ កាយេន ផុសិត្វា វិហរតិ ឯត្តាវតាបិ ខោ អាវុសោ កាយសក្ខី វុត្តោ ភគវតា បរិយាយេន ។ បុន ចបរំ អាវុសោ ភិក្ខុ សព្វសោ រូបសញ្ញានំ សមតិក្កមា បដិឃសញ្ញានំ អត្ថង្គមា នានត្តសញ្ញានំ អមនសិការា អនន្តោ អាកាសោតិ អាកាសានញ្ចាយតនំ ឧបសម្បជ្ជ វិហរតិ យថា យថា ច តទាយតនំ តថា តថា នំ កាយេន ផុសិត្វា វិហរតិ

បណ្ណាសក បញ្ចាលវគ្គ

[៤៣] ម្នាលអាវុសោ ព្រះដ៏មានព្រះភាគទ្រង់សម្តែងថា កាយសក្ខិ កាយសក្ខិ ដូច្នេះ ម្នាលអាវុសោ កាយសក្ខិ ដែលព្រះមានព្រះភាគសម្តែងហើយ តើដោយហេតុប៉ុន្មាន ។ ម្នាលអាវុសោ ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ បានដល់នូវបឋមជ្ឈាន អាយតនៈ គឺបឋមជ្ឈាននោះមាន ព្រោះអាការណាៗ ភិក្ខុក៏ពាល់ត្រូវនូវអាយតនៈនោះ ដោយកាយ ព្រោះអាការនោះៗ ម្នាលអាវុសោ កាយសក្ខិបុគ្គល ដែលព្រះដ៏មានព្រះភាគទ្រង់សម្តែងហើយ ដោយបរិយាយត្រឹមប៉ុណ្ណោះឯង ។ ម្នាលអាវុសោ មួយទៀត ភិក្ខុ ព្រោះស្ងប់រម្ងាប់នូវវិតក្កៈនិងវិចារៈ ។ បេ ។ ក៏បានដល់នូវទុតិយជ្ឈាន តតិយជ្ឈាន ចតុត្ថជ្ឈាន អាយតនៈនោះកើតព្រោះអាការណាៗ ភិក្ខុក៏ពាល់ត្រូវនូវអាយតនៈនោះ ដោយកាយ ព្រោះអាការនោះៗ ម្នាលអាវុសោ កាយសក្ខិបុគ្គលដែលព្រះដ៏មានព្រះភាគទ្រង់សម្តែងហើយ ដោយបរិយាយ ត្រឹមប៉ុណ្ណោះឯង ។ ម្នាលអាវុសោ មួយទៀត ភិក្ខុបានដល់នូវអាកាសានញ្ចាយតនជ្ឈាន ដោយការធ្វើទុកក្នុងចិត្តថា អាកាសមិនមានទីបំផុតដូច្នេះ ព្រោះកន្លងនូវរូបសញ្ញា ព្រោះវិនាសទៅនៃបដិឃសញ្ញា ព្រោះមិនបានធ្វើទុកក្នុងចិត្តនូវនានត្តសញ្ញា ដោយប្រការទាំងពួង អាយតនៈនោះ កើតព្រោះអាការណាៗ ភិក្ខុក៏ពាល់ត្រូវនូវអាយតនៈនោះដោយកាយ ព្រោះអាការនោះៗ

ឯត្តាវតាបិ ខោ អាវុសោ កាយសក្ខី វុត្តោ ភគវតា បរិយាយេន ។ បេ ។ បុន ចបរំ អាវុសោ ភិក្ខុ សព្វសោ នេវសញ្ញានាសញ្ញាយតនំ សមតិក្កម្ម សញ្ញាវេទយិតនិរោធំ ឧបសម្បជ្ជ វិហរតិ បញ្ញាយ- បស្ស ខិស្វា អាសវា បរិក្ខីណា ហោន្តិ យថា យថា ច តទាយតនំ តថា តថា នំ កាយេន ផុសិត្វា វិហរតិ ឯត្តាវតាបិ ខោ អាវុសោ កាយ- សក្ខី វុត្តោ ភគវតា និប្បរិយាយេនាតិ ។

[៤៤] បញ្ញាវិមុត្តោ បញ្ញាវិមុត្តោតិ អាវុសោ វុច្ចតិ កិត្តាវតា នុ ខោ អាវុសោ បញ្ញាវិមុត្តោ វុត្តោ ភគវតាតិ ។ ឥធាវុសោ ភិក្ខុ វិវិច្ចេវ កាមេហិ ។ បេ ។ បឋមជ្ឈានំ ឧបសម្បជ្ជ វិហរតិ បញ្ញាយ បន បជានាតិ[១] ឯត្តាវតាបិ ខោ អាវុសោ បញ្ញាវិមុត្តោ វុត្តោ ភគវតា បរិយាយេន ។ បេ ។ បុន ចបរំ អាវុសោ ភិក្ខុ

១ ឱ. ម. បញ្ញាយ ច នំ បជានាតិ ។

ម្នាលអាវុសោ កាយសក្ខិបុគ្គល ដែលព្រះដ៏មានព្រះភាគ ទ្រង់សម្តែង ហើយ ដោយបរិយាយ ត្រឹមប៉ុណ្ណោះឯង ។ បេ ។ ម្នាលអាវុសោ មួយទៀត ភិក្ខុបានដល់នូវសញ្ញាវេទយិតនិរោធ ព្រោះកន្លងនូវនេវ-សញ្ញានាសញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង អាសវៈទាំងឡាយ របស់ភិក្ខុនោះ ក៏អស់រលីងទៅ ព្រោះឃើញដោយបញ្ញា អាយតនៈ នោះកើតព្រោះអាការណាៗ ភិក្ខុក៏ពាល់ត្រូវនូវអាយតនៈនោះដោយកាយ ព្រោះអាការនោះៗ ម្នាលអាវុសោ កាយសក្ខិបុគ្គល ដែលព្រះដ៏មាន ព្រះភាគទ្រង់សម្តែងហើយ ដោយនិប្បរិយាយ ត្រឹមប៉ុណ្ណោះឯង ។

[៤៤] ម្នាលអាវុសោ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា បញ្ញាវិមុត្ត បញ្ញាវិមុត្ត ដូច្នេះ ម្នាលអាវុសោ បញ្ញាវិមុត្តបុគ្គល ដែលព្រះអង្គសម្តែងហើយ តើដោយហេតុប៉ុន្មាន ។ ម្នាលអាវុសោ ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ ក៏បាន ដល់នូវបឋមជ្ឈាន ទាំងដឹងច្បាស់ដោយបញ្ញា ម្នាលអាវុសោ បញ្ញា-វិមុត្តបុគ្គល ដែលព្រះដ៏មានព្រះភាគ ទ្រង់សម្តែងហើយ ដោយ បរិយាយ ត្រឹមប៉ុណ្ណោះឯង ។ បេ ។ ម្នាលអាវុសោ មួយទៀត ភិក្ខុ

សព្វសោ នេវសញ្ញានាសញ្ញាយតនំ សមតិក្កម្ម សញ្ញាវេទយិតនិរោធំ ឧបសម្បជ្ជ វិហរតិ បញ្ញាយ-បស្ស ចិស្វា អាសវា បរិក្ខីណា ហោន្តិ បញ្ញាយ បន បជានាតិ ឯត្តាវតាបិ ខោ អាវុសោ បញ្ញាវិមុត្តោ វុត្តោ ភគវតា និប្បរិយាយេនាតិ ។

[៤៩] ឧភតោភាគវិមុត្តោ ឧភតោភាគវិមុត្តោតិ អាវុសោ វុច្ចតិ កិត្តាវតា នុ ខោ អាវុសោ ឧភតោភា-គវិមុត្តោ វុត្តោ ភគវតាតិ ។ ឥធាវុសោ ភិក្ខុ វិវិច្ចេវ កាមេហិ ។ បេ ។ បឋមជ្ឈានំ ឧបសម្បជ្ជ វិហរតិ យថា យថា ច តទាយតនំ តថា តថា នំ កាយេន ផុសិត្វា វិហរតិ បញ្ញាយ បន បជានាតិ ឯត្តាវតាបិ ខោ អាវុសោ ឧភតោភាគវិមុត្តោ វុត្តោ ភគវតា បរិយា-យេន ។ បេ ។ បុន ចបរំ អាវុសោ ភិក្ខុ សព្វសោ នេវ-សញ្ញានាសញ្ញាយតនំ សមតិក្កម្ម សញ្ញាវេទយិតនិរោធំ ឧបសម្បជ្ជ វិហរតិ បញ្ញាយបស្ស ចិស្វា អាសវា បរិក្ខីណា ហោន្តិ យថា យថា ច តទាយតនំ

បានដល់នូវសញ្ញាវេទយិតនិរោធ ព្រោះកន្លងនូវនេវសញ្ញានាសញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង អាសវៈទាំងឡាយរបស់ភិក្ខុនោះ ក៏អស់រលីងទៅ ព្រោះឃើញដោយបញ្ញា ទាំងភិក្ខុនោះ ក៏ដឹងច្បាស់ដោយបញ្ញា ម្នាលអាវុសោ បញ្ញាវិមុត្តបុគ្គល ដែលព្រះដ៏មានព្រះភាគទ្រង់សម្តែងហើយ ដោយនិប្បរិយាយ ត្រឹមប៉ុណ្ណោះឯង ។

[៤៥] ម្នាលអាវុសោ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ឧភតោភាគវិមុត្ត ឧភតោភាគវិមុត្ត ដូច្នេះ ម្នាលអាវុសោ ឧភតោភាគវិមុត្តបុគ្គល ដែលព្រះដ៏មានព្រះភាគ សម្តែងហើយ តើដោយហេតុប៉ុន្មាន ។ ម្នាលអាវុសោ ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ ក៏បានដល់នូវបឋមជ្ឈាន អាយតនៈនោះ កើតព្រោះអាការណាៗ ភិក្ខុពាល់ត្រូវនូវអាយតនៈនោះដោយកាយ ព្រោះអាការនោះៗ ទាំងដឹងច្បាស់ដោយបញ្ញា ម្នាលអាវុសោ ឧភតោភាគវិមុត្តបុគ្គល ដែលព្រះដ៏មានព្រះភាគទ្រង់សម្តែងហើយ ដោយបរិយាយ ត្រឹមប៉ុណ្ណោះឯង ។ បេ ។ ម្នាលអាវុសោ មួយទៀត ភិក្ខុបានដល់នូវសញ្ញាវេទយិតនិរោធ ព្រោះកន្លងនូវនេវសញ្ញានាសញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង អាសវៈទាំងឡាយរបស់ភិក្ខុនោះ ក៏អស់រលីងទៅ ព្រោះឃើញដោយបញ្ញា អាយតនៈនោះកើតព្រោះអាការណា ៗ ភិក្ខុពាល់ត្រូវនូវអាយតនៈនោះ

តថា តថា នំ កាយេន ផុសិត្វា វិហរតិ បញ្ញាយ បន បជានាតិ ឯត្តាវតាបិ ខោ អាវុសោ ឧភតោភាគវិមុត្តោ វុត្តោ ភគវតា និប្បរិយាយេនាតិ ។

[៤៦] សន្ទិដ្ឋិកោ ធម្មោ សន្ទិដ្ឋិកោ ធម្មោតិ អាវុសោ វុច្ចតិ កិត្តាវតា នុ ខោ អាវុសោ សន្ទិដ្ឋិកោ ធម្មោ វុត្តោ ភគវតាតិ ។ ឥធាវុសោ ភិក្ខុ វិវិច្ចេវ កាមេហិ ។ បេ ។ បឋមជ្ឈានំ ឧបសម្បជ្ជ វិហរតិ ឯត្តាវតាបិ ខោ អាវុសោ សន្ទិដ្ឋិកោ ធម្មោ វុត្តោ ភគវតា បរិយាយេន ។ បេ ។ បុន ចបរំ អាវុសោ ភិក្ខុ សព្វសោ នេវសញ្ញានាសញ្ញាយតនំ សមតិក្កម្ម សញ្ញាវេទយិតនិរោធំ ឧបសម្បជ្ជ វិហរតិ បញ្ញាយបស្ស ចស្វា អាសវា បរិក្ខីណា ហោន្តិ ឯត្តាវតាបិ ខោ អាវុសោ សន្ទិដ្ឋិកោ ធម្មោ វុត្តោ ភគវតា និប្បរិយាយេនាតិ ។

[៤៧] សន្ទិដ្ឋិកំ និព្វានំ សន្ទិដ្ឋិកំ និព្វានន្តិ អាវុសោ វុច្ចតិ កិត្តាវតា នុ ខោ អាវុសោ សន្ទិដ្ឋិកំ និព្វានំ វុត្តំ ភគវតាតិ ។ ឥធាវុសោ ភិក្ខុ វិវិច្ចេវ កាមេហិ ។ បេ ។

ដោយកាយ ព្រោះអាការនោះៗ ទាំងបានដឹងច្បាស់ដោយបញ្ញា ម្នាលអាវុសោ ឧភតោភាគវិមុត្តបុគ្គល ដែលព្រះដ៏មានព្រះភាគទ្រង់សម្តែងហើយ ដោយនិប្បរិយាយ ត្រឹមប៉ុណ្ណោះឯង ។

[៤៦] ម្នាលអាវុសោ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា សន្ទិដ្ឋិកធម៌ សន្ទិដ្ឋិកធម៌ ដូច្នេះ ម្នាលអាវុសោ សន្ទិដ្ឋិកធម៌ ដែលព្រះអង្គសម្តែងហើយ តើដោយហេតុប៉ុន្មាន ។ ម្នាលអាវុសោ ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាមទាំងឡាយ ។បេ។ ក៏បានដល់នូវបឋមជ្ឈាន ម្នាលអាវុសោ សន្ទិដ្ឋិកធម៌ ដែលព្រះដ៏មានព្រះភាគទ្រង់សម្តែងហើយ ដោយបរិយាយ ត្រឹមប៉ុណ្ណោះឯង ។បេ។ ម្នាលអាវុសោ មួយទៀត ភិក្ខុបានដល់នូវសញ្ញាវេទយិតនិរោធ ព្រោះកន្លងនូវនេវសញ្ញានាសញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង អាសវៈទាំងឡាយរបស់ភិក្ខុនោះ ក៏អស់រលីងទៅ ព្រោះឃើញដោយបញ្ញា ម្នាលអាវុសោ សន្ទិដ្ឋិកធម៌ ដែលព្រះដ៏មានព្រះភាគទ្រង់សម្តែងហើយ ដោយនិប្បរិយាយ ត្រឹមប៉ុណ្ណោះឯង ។

[៤៧] ម្នាលអាវុសោ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា សន្ទិដ្ឋិកនិព្វាន សន្ទិដ្ឋិកនិព្វាន ដូច្នេះ ម្នាលអាវុសោ សន្ទិដ្ឋិកនិព្វាន ដែលព្រះដ៏មានព្រះភាគទ្រង់សម្តែងហើយ តើដោយហេតុប៉ុន្មាន ។ ម្នាលអាវុសោ ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាមទាំងឡាយ ។បេ។

បឋមជ្ឈានំ ឧបសម្បជ្ជ វិហរតិ ឯត្តាវតាបិ ខោ អាវុសោ សន្ទិដ្ឋិកំ និព្វានំ វុត្តំ ភគវតា បរិយាយេន ។ បេ ។ បុន ចបរំ អាវុសោ ភិក្ខុ សព្វសោ នេវសញ្ញា-នាសញ្ញាយតនំ សមតិក្កម្ម សញ្ញាវេទយិតនិរោធំ ឧបសម្បជ្ជ វិហរតិ បញ្ញាយបស្ស និស្វា អាសវា បរិក្ខីណា ហោន្តិ ឯត្តាវតាបិ អាវុសោ សន្ទិដ្ឋិកំ និព្វានំ វុត្តំ ភគវតា និប្បរិយាយេនាតិ ។

[៤៨] និព្វានំ និព្វានន្តិ អាវុសោ វុច្ចតិ ។ បេ ។

[៤៩] បរិនិព្វានំ បរិនិព្វានន្តិ ។ បេ ។

[៥០] តទង្គនិព្វានំ តទង្គនិព្វានន្តិ អាវុសោ វុច្ចតិ ។ បេ ។

[៥១] ទិដ្ឋធម្មនិព្វានំ ទិដ្ឋធម្មនិព្វានន្តិ អាវុសោ វុច្ចតិ កិត្តាវតា នុ ខោ អាវុសោ ទិដ្ឋធម្មនិព្វានំ វុត្តំ ភគវតាតិ ។ ឥធាវុសោ ភិក្ខុ វិវិច្ចេវ កាមេហិ ។ បេ ។

កំបានដល់នូវបឋមជ្ឈាន ម្នាលអាវុសោ សន្ទិដ្ឋិកនិព្វាន ដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់សម្តែងហើយ ដោយបរិយាយមានត្រឹមប៉ុណ្ណោះឯង ។ បេ ។ ម្នាលអាវុសោ មួយទៀត ភិក្ខុបានដល់នូវសញ្ញាវេទយិតនិរោធ ព្រោះកន្លងនូវនេវសញ្ញានាសញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង អាសវៈទាំងឡាយរបស់ភិក្ខុនោះក៏អស់រលីងទៅ ព្រោះឃើញដោយបញ្ញា ម្នាលអាវុសោ សន្ទិដ្ឋិកនិព្វាន ដែលព្រះដ៏មានព្រះភាគទ្រង់សម្តែងហើយ ដោយនិប្បរិយាយ ត្រឹមប៉ុណ្ណោះឯង ។

[៤៨] ម្នាលអាវុសោ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា និព្វាន និព្វាន ដូច្នេះ ។ បេ ។

[៤៩] ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា បរិនិព្វាន បរិនិព្វាន ដូច្នេះ ។ បេ ។

[៥០] ម្នាលអាវុសោ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា តទង្គនិព្វាន តទង្គនិព្វាន ដូច្នេះ ។ បេ ។

[៥១] ម្នាលអាវុសោ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា ទិដ្ឋធម្មនិព្វាន ទិដ្ឋធម្មនិព្វាន ដូច្នេះ ម្នាលអាវុសោ ទិដ្ឋធម្មនិព្វាន ដែលព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សម្តែងហើយ ដោយហេតុប៉ុន្មាន ។ ម្នាលអាវុសោ ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាមទាំងឡាយ ។ បេ ។

បឋមជ្ឈានំ ឧបសម្បជ្ជ វិហរតិ ឯត្តាវតាបិ ខោ អាវុសោ ទិដ្ឋធម្មនិព្វានំ វុត្តំ ភគវតា បរិយាយេន ។ បេ ។ បុន ចបរំ អាវុសោ ភិក្ខុ សព្វសោ នេវសញ្ញានាសញ្ញាយ-តនំ សមតិក្កម្ម សញ្ញាវេទយិតនិរោធំ ឧបសម្បជ្ជ វិហរតិ បញ្ញាយបស្ស ទិស្វា អាសវា បរិក្ខីណា ហោន្តិ ឯត្តាវតាបិ ខោ អាវុសោ ទិដ្ឋធម្មនិព្វានំ វុត្តំ ភគវតា និប្បរិយាយេនាតិ ។

បញ្ចាលវគ្គោ បញ្ចមោ ។

## តត្រុទ្ទានំ ភវតិ

បញ្ចាលោ កាមហេសញ្ច[១] ឧភោ[២] សន្ទិដ្ឋិកា ទ្វេ
និព្វានំ បរិនិព្វានំ តទង្គទិដ្ឋធម្មិកេន ចាតិ ។

នវកនិបាតេ បណ្ណាសកោ សមត្តោ[៣] ។

---

១ ឱ. បញ្ចាលោ កាយសក្ខិ ច ។ ម. សម្ពាធោ កាយសក្ខិ បញ្ញា ។ ២ ម. ឧភតោ ភាគោ ។ ៣ ឱ. ម. បឋមំ បណ្ណាសកំ សមត្តំ ។

ក៏បានដល់នូវបឋមជ្ឈាន ម្នាលអាវុសោ ទិដ្ឋធម្មនិព្វាន ដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់សម្តែងហើយ ដោយបរិយាយ ត្រឹមប៉ុណ្ណោះឯង ។ បេ ។ ម្នាលអាវុសោ មួយទៀត ភិក្ខុបានដល់នូវសញ្ញាវេទយិតនិរោធ ព្រោះកន្លងនូវនេវសញ្ញានាសញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង អាសវៈទាំងឡាយ របស់ភិក្ខុនោះ ក៏អស់រលីងទៅ ព្រោះឃើញដោយបញ្ញា ម្នាលអាវុសោ ទិដ្ឋធម្មនិព្វាន ដែលព្រះដ៏មានព្រះភាគ ទ្រង់សម្តែងហើយ ដោយនិប្បរិយាយ ត្រឹមប៉ុណ្ណោះឯង ។

ចប់ បញ្ចាលវគ្គទី ៥ ។

# ឧទ្ទានក្នុងបញ្ចាលវគ្គនោះគឺ

និយាយអំពីបញ្ចាលចណ្ឌទេវបុត្រ ១ ការបៀតបៀនកាម ១ បញ្ញាវិមុត្ត ១ ឧភតោភាគវិមុត្តបុគ្គល ១ សន្ទិដ្ឋិកៈ មាន ២ លើក និព្វាន ១ បរិនិព្វាន ១ តទង្គនិព្វាន ១ និងទិដ្ឋធម្មិកនិព្វាន ១ ។

ចប់ បណ្ណាសកៈ ក្នុងនវកនិបាត ។

# បណ្ណាសកាសង្គហិតា វគ្គា

## បឋមោ ខេមវគ្គោ

[៤២] ខេមំ ខេមន្តិ អាវុសោ វុច្ចតិ កិត្តាវតា នុ ខោ អាវុសោ ខេមំ វុត្តំ ភគវតាតិ ។ ឥធាវុសោ ភិក្ខុ វិវិច្ចេវ កាមេហិ ។ បេ ។ បឋមជ្ឈានំ ឧបសម្បជ្ជ វិហរតិ ឯត្តាវតាបិ ខោ អាវុសោ ខេមំ វុត្តំ ភគវតា បរិយាយេន ។ បេ ។ បុន ចបរំ អាវុសោ ភិក្ខុ សព្វសោ នេវសញ្ញានាសញ្ញាយតនំ សមតិក្កម្ម សញ្ញា-វេទយិតនិរោធំ ឧបសម្បជ្ជ វិហរតិ បញ្ញាយបស្ស និស្វា អាសវា បរិក្ខីណា ហោន្តិ ឯត្តាវតាបិ ខោ អាវុសោ ខេមំ វុត្តំ ភគវតា និប្បរិយាយេនាតិ ។

[៤៣] ខេមប្បត្តោ ខេមប្បត្តោតិ អាវុសោ វុច្ចតិ ។ បេ ។

[៤៤] អមតំ អមតន្តិ អាវុសោ វុច្ចតិ ។

# បណ្ណាសកាសង្គហិតវគ្គ

## ខេមវគ្គទី ១

[៥២] ម្នាលអាវុសោ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា សេចក្តីក្សេម សេចក្តីក្សេម ដូច្នេះ ម្នាលអាវុសោ សេចក្តីក្សេម ដែលព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហើយ តើដោយហេតុប៉ុន្មាន ។ ម្នាលអាវុសោ ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ បានដល់នូវបឋមជ្ឈាន ម្នាលអាវុសោ សេចក្តីក្សេម ដែលព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហើយ ដោយបរិយាយ ត្រឹមប៉ុណ្ណោះឯង ។ បេ ។ ម្នាលអាវុសោ មួយទៀត ភិក្ខុបានដល់នូវសញ្ញាវេទយិតនិរោធ ព្រោះកន្លងនូវនេវសញ្ញានាសញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង អាសវៈទាំងឡាយ របស់ភិក្ខុនោះក៏អស់រលីងទៅ ព្រោះឃើញដោយបញ្ញា ម្នាលអាវុសោ សេចក្តីក្សេម ដែលព្រះដ៏មានព្រះភាគ ទ្រង់សម្តែងហើយ ដោយនិប្បរិយាយ ត្រឹមប៉ុណ្ណោះឯង ។

[៥៣] ម្នាលអាវុសោ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា បុគ្គលដល់នូវសេចក្តីក្សេម ដល់នូវសេចក្តីក្សេម ដូច្នេះ ។ បេ ។

[៥៤] ម្នាលអាវុសោ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា អមតៈ អមតៈ ដូច្នេះ ។

[៥៥] អមតប្បត្តោ អមតប្បត្តោតិ អាវុសោ វុច្ចតិ ។

[៥៦] អភយំ អភយន្តិ អាវុសោ វុច្ចតិ ។

[៥៧] អភយប្បត្តោ អភយប្បត្តោតិ អាវុសោ វុច្ចតិ ។

[៥៨] បស្សទ្ធិ បស្សទ្ធីតិ អាវុសោ វុច្ចតិ ។

[៥៩] អនុបុព្វប្បស្សទ្ធិ អនុបុព្វប្បស្សទ្ធីតិ អាវុសោ វុច្ចតិ ។

[៦០] និរោធោ និរោធោតិ អាវុសោ វុច្ចតិ ។

[៦១] អនុបុព្វនិរោធោ អនុបុព្វនិរោធោតិ អាវុសោ វុច្ចតិ កិត្តាវតា នុ ខោ អាវុសោ អនុបុព្វនិរោធោ វុត្តោ ភគវតាតិ ។ ឥធាវុសោ ភិក្ខុ វិវិច្ចេវ កាមេហិ ។ បេ ។

[៥៥] ម្នាលអាវុសោ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា បុគ្គលដល់នូវអមតៈ ដល់នូវអមតៈ ដូច្នេះ ។

[៥៦] ម្នាលអាវុសោ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា ទីមិនមានភ័យ ទីមិនមានភ័យ ដូច្នេះ ។

[៥៧] ម្នាលអាវុសោ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា បុគ្គលដល់នូវទីមិនមានភ័យ ដល់នូវទីមិនមានភ័យ ដូច្នេះ ។

[៥៨] ម្នាលអាវុសោ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា សេចក្តីស្ងប់រម្ងាប់ សេចក្តីស្ងប់រម្ងាប់ ដូច្នេះ។

[៥៩] ម្នាលអាវុសោ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា សេចក្តីស្ងប់រម្ងាប់ដោយលំដាប់ សេចក្តីស្ងប់រម្ងាប់ដោយលំដាប់ ដូច្នេះ ។

[៦០] ម្នាលអាវុសោ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា សេចក្តីរលត់ សេចក្តីរលត់ ដូច្នេះ ។

[៦១] ម្នាលអាវុសោ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា សេចក្តីរលត់ដោយលំដាប់ៗ ដូច្នេះ ម្នាលអាវុសោ សេចក្តីរលត់ដោយលំដាប់ ដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់សម្តែងហើយ តើដោយហេតុប៉ុន្មាន ។ ម្នាលអាវុសោ ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាមទាំងឡាយ ។ បេ ។

បឋមជ្ឈានំ ឧបសម្បជ្ជ វិហរតិ ឯត្តាវតាបិ ខោ អាវុសោ អនុបុព្វនិរោធោ វុត្តោ ភគវតា បរិយាយេន ។ បេ ។ បុន ចបរំ អាវុសោ ភិក្ខុ សព្វសោ នេវសញ្ញានាសញ្ញាយតនំ សមតិក្កម្ម សញ្ញាវេទយិតនិរោធំ ឧបសម្បជ្ជ វិហរតិ បញ្ញាយ-បស្ស ចិស្វា អាសវា បរិក្ខីណា ហោន្តិ ឯត្តាវតាបិ ខោ អាវុសោ អនុបុព្វនិរោធោ វុត្តោ ភគវតា និប្ប-រិយាយេនាតិ ។

[៦២] ឆវ ភិក្ខវេ ធម្មេ អប្បហាយ អភព្វោ អរហត្តំ សច្ឆិកាតុំ ។ កតមេ ឆវ ។ រាគំ ទោសំ មោហំ កោធំ ឧបនាហំ មក្ខំ បលាសំ ឥស្សំ មច្ឆរិយំ ។ ឥមេ ខោ ភិក្ខវេ ឆវ ធម្មេ អប្បហាយ អភព្វោ អរហត្តំ សច្ឆិកាតុំ ។

បានដល់នូវបឋមជ្ឈាន ម្នាលអាវុសោ សេចក្តីរលត់ដោយលំដាប់ ដែលព្រះដ៏មានព្រះភាគទ្រង់សម្តែងហើយ ដោយបរិយាយ ត្រឹមប៉ុណ្ណេះឯង ។ បេ ។ ម្នាលអាវុសោ មួយទៀត ភិក្ខុបានដល់នូវសញ្ញាវេទយិតនិរោធ ព្រោះកន្លងនូវនេវសញ្ញានាសញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង អាសវៈទាំងឡាយ របស់ភិក្ខុនោះ ក៏អស់រលីងទៅ ព្រោះឃើញដោយបញ្ញា ម្នាលអាវុសោ សេចក្តីរលត់ដោយលំដាប់ ដែលព្រះដ៏មានព្រះភាគ ទ្រង់សម្តែងហើយ ដោយនិប្បរិយាយ ត្រឹមប៉ុណ្ណេះឯង ។

[៦២] ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនលះបង់នូវធម៌ ៩ យ៉ាង មិនគួរដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះអរហត្តបានទេ ។ ធម៌ ៩ យ៉ាង តើដូចម្តេចខ្លះ ។ គឺរាគៈ ១ ទោសៈ ១ មោហៈ ១ កោធៈ ១ ឧបនាហៈ ១ មក្ខៈ ១ បលាសៈ ១ ឥស្សា ១ មច្ឆរិយៈ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនទាន់លះបង់នូវធម៌ ៩ យ៉ាងនេះទេ មិនគួរដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះអរហត្តបានឡើយ ។

នវ ភិក្ខវេ ធម្មេ បហាយ ភព្វោ អរហត្តំ សច្ឆិកាតុំ ។ កតមេ នវ ។ រាគំ ទោសំ មោហំ កោធំ ឧបនាហំ មក្ខំ បឡាសំ ឥស្សំ មច្ឆរិយំ ។ ឥមេ ខោ ភិក្ខវេ នវ ធម្មេ បហាយ ភព្វោ អរហត្តំ សច្ឆិកាតុន្តិ ។

ខេមវគ្គោ បឋមោ ។

## តត្រុទ្ទានំ

ខេមោ ច អមតំ ចេវ អភយបស្សទ្ធិយេន ច
និរោធោ អនុបុព្វោ ចេវ ធម្មំ បហាយ ភព្វេន ចាតិ ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលបានលះបង់ នូវធម៌ ៩ យ៉ាងនេះហើយ គួរដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះអរហត្តបាន ។ ធម៌ ៩ យ៉ាង តើដូចម្តេចខ្លះ ។ គឺរាគៈ ១ ទោសៈ ១ មោហៈ ១ កោធៈ ១ ឧបនាហៈ ១ មក្ខៈ ១ បលាសៈ ១ ឥស្សា ១ មច្ឆរិយៈ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលបានលះបង់នូវធម៌ ៩ យ៉ាងនេះឯងហើយ ទើបគួរដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះអរហត្តបាន ។

ចប់ ខេមវគ្គ ទី ១ ។

# ឧទ្ទានក្នុងខេមវគ្គនោះគឺ

និយាយអំពីសេចក្តីក្សេម ១ អ្នកដល់នូវសេចក្តីក្សេម ១ អមតៈ ១ អ្នកដល់នូវអមតៈ ១ ទីមិនមានភ័យ ១ អ្នកដល់នូវទីមិនមានភ័យ ១ សេចក្តីស្ងប់រម្ងាប់ ១ សេចក្តីស្ងប់រម្ងាប់ដោយលំដាប់ ១ សេចក្តីរលត់ ១ សេចក្តីរលត់ដោយលំដាប់ ១ និងបុគ្គលលះបង់នូវធម៌ ៩ យ៉ាង គួរធ្វើឲ្យជាក់ច្បាស់នូវព្រះអរហត្ត ១ ។

# ទុតិយោ សតិប្បដ្ឋានវគ្គោ

[៦៣] បញ្ចិមានិ ភិក្ខវេ សិក្ខាទុព្វល្យានិ ។ កតមានិ បញ្ច ។ ចាណាតិចាតោ អទិន្នាទានំ កាមេសុ មិច្ឆាចារោ មុសាវាទោ សុរាមេរយមជ្ជប្បមា-ទដ្ឋានំ ។ ឥមានិ ខោ ភិក្ខវេ បញ្ច សិក្ខាទុព្វល្យានិ ។ ឥមេសំ ខោ ភិក្ខវេ បញ្ចន្នំ សិក្ខាទុព្វល្យានំ បហានាយ ចត្តារោ សតិប្បដ្ឋានា ភាវេតព្វា ។ កតមេ ចត្តារោ ។ ឥធ ភិក្ខវេ ភិក្ខុ កាយេ កាយានុ-បស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ វេទនាសុ ។ បេ ។ ចិត្តេ ធម្មេសុ ធម្មានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោ-មនស្សំ ។ ឥមេសំ ខោ ភិក្ខវេ ភិក្ខុ បញ្ចន្នំ សិក្ខា-ទុព្វល្យានំ បហានាយ ឥមេ ចត្តារោ សតិប្បដ្ឋានា ភាវេតព្វាតិ ។

# សតិប្បដ្ឋានវគ្គទី ២

[៦៣] ម្នាលភិក្ខុទាំងឡាយ ហេតុនៃសិក្ខា មានកម្លាំងថយនេះ មាន ៥ យ៉ាង ។ ហេតុនៃសិក្ខា មានកម្លាំងថយ ៥ យ៉ាងតើអ្វីខ្លះ ។ គឺ បាណាតិបាត ១ អទិន្នាទាន ១ កាមេសុ មិច្ឆាចារ ១ មុសាវាទ ១ សុរាមេរយមជ្ជប្បមាទដ្ឋាន ១ ។ ម្នាលភិក្ខុទាំងឡាយ ហេតុនៃសិក្ខា មានកម្លាំងថយមាន ៥ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគួរចម្រើនសតិប្បដ្ឋាន ៤ ដើម្បីលះបង់នូវហេតុនៃសិក្ខា មានកម្លាំងថយ ៥ យ៉ាងនេះឯង ។ សតិប្បដ្ឋាន ៤ យ៉ាង តើដូចម្ដេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញនូវកាយ ក្នុងកាយជាប្រក្រតី មានព្យាយាម ជាគ្រឿងដុតកម្ដៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្ស ក្នុងលោកចេញ ១ ក្នុងវេទនាទាំងឡាយ ១ ។ បេ ។ ក្នុងចិត្ត ១ ពិចារណាឃើញនូវធម៌ ក្នុងធម៌ទាំងឡាយជាប្រក្រតី មានព្យាយាម ជាគ្រឿងដុតកម្ដៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្ស ក្នុងលោកចេញ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគួរចម្រើននូវសតិប្បដ្ឋាន ៤ នេះ ដើម្បីលះបង់នូវហេតុនៃសិក្ខា មានកម្លាំងថយ ៥ យ៉ាងនេះឯង ។

[៦៤] បញ្ចិមានិ ភិក្ខវេ នីវរណានិ ។ កតមានិ បញ្ច ។ កាមច្ឆន្ទនីវរណំ ព្យាបាទនីវរណំ ថីនមិទ្ធនី-វរណំ ឧទ្ធច្ចកុក្កុច្ចនីវរណំ វិចិកិច្ឆានីវរណំ ។ ឥមានិ ខោ ភិក្ខវេ បញ្ច នីវរណានិ ។ ឥមេសំ ខោ ភិក្ខវេ បញ្ចន្នំ នីវរណានំ បហានាយ ចត្តារោ សតិប្បដ្ឋានា ភាវេតព្វា ។ កតមេ ចត្តារោ ។ ឥធ ភិក្ខវេ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ វេទនាសុ ។ បេ ។ ចិត្តេ ធម្មេសុ ធម្មានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ ឥមេសំ ខោ ភិក្ខវេ បញ្ចន្នំ នីវរណានំ បហានាយ ឥមេ ចត្តារោ សតិប្បដ្ឋានា ភាវេតព្វាតិ ។

[៦៤] ម្នាលភិក្ខុទាំងឡាយ នីវរណធម៌នេះមាន ៥ យ៉ាង ។ នីវរណធម៌ ៥ យ៉ាង តើដូចម្តេចខ្លះ ។ គឺកាមច្ឆន្ទនីវរណៈ ១ ព្យាបាទ-នីវរណៈ ១ ថីនមិទ្ធនីវរណៈ ១ ឧទ្ធច្ចកុក្កុច្ចនីវរណៈ ១ វិចិកិច្ឆា-នីវរណៈ ១ ។ ម្នាលភិក្ខុទាំងឡាយ នីវរណធម៌មាន ៥ យ៉ាង នេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគួរចម្រើននូវសតិប្បដ្ឋាន ៤ ដើម្បីលះបង់នូវនីវរណៈ ៥ យ៉ាងនេះឯង ។ សតិប្បដ្ឋាន ៤ តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញនូវកាយ ក្នុងកាយជាប្រក្រតី មានព្យាយាម ជាគ្រឿងដុតកម្តៅនូវកិលេស ជាអ្នកដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្ស ក្នុងលោកចេញ ១ ក្នុងវេទនាទាំងឡាយ ១ ។ បេ ។ ក្នុងចិត្ត ១ ពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយ ជាប្រក្រតី មានព្យាយាម ជាគ្រឿងដុតកម្តៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្ស ក្នុងលោកចេញ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគួរចម្រើននូវសតិប្បដ្ឋាន ៤ នេះ ដើម្បីលះបង់នូវនីវរណៈ ៥ យ៉ាងនេះឯង ។

[៦៥] បញ្ចិមេ ភិក្ខវេ កាមគុណា ។ កតមេ បញ្ច ។ ចក្ខុវិញ្ញេយ្យា រូបា ឥដ្ឋា កន្តា មនាបា បិយរូបា កាមូបសញ្ហិតា រជនីយា សោតវិញ្ញេយ្យា សទ្ទា ។ បេ ។ ឃានវិញ្ញេយ្យា គន្ធា ជិវ្ហាវិញ្ញេយ្យា រសា កាយវិញ្ញេយ្យា ផោដ្ឋព្វា ឥដ្ឋា កន្តា មនាបា បិយរូបា កាមូបសញ្ហិតា រជនីយា ។ ឥមេ ខោ ភិក្ខវេ បញ្ច កាមគុណា ។ ឥមេសំ ខោ ភិក្ខវេ បញ្ចន្នំ កាមគុណានំ បហានាយ ឥមេ ចត្តារោ សតិប្បដ្ឋានា ភាវេតព្វាតិ ។

[៦៦] បញ្ចិមេ ភិក្ខវេ ឧបាទានក្ខន្ធា ។ កតមេ បញ្ច ។ រូបូបាទានក្ខន្ធោ វេទនូបាទានក្ខន្ធោ សញ្ញូបាទានក្ខន្ធោ សង្ខារូបាទានក្ខន្ធោ វិញ្ញាណូបាទានក្ខន្ធោ ។ ឥមេ ខោ ភិក្ខវេ បញ្ចុបាទានក្ខន្ធា ។ ឥមេសំ ខោ ភិក្ខវេ បញ្ចន្នំ ឧបាទានក្ខន្ធានំ បហានាយ ឥមេ ចត្តារោ សតិប្បដ្ឋានា ភាវេតព្វាតិ ។

[៦៥] ម្នាលភិក្ខុទាំងឡាយ កាមគុណនេះមាន ៥ យ៉ាង ។ កាមគុណ ៥ យ៉ាង តើដូចម្ដេចខ្លះ ។ គឺរូបដែលគប្បីដឹងដោយចក្ខុ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីពេញចិត្ត មានសភាពជាទីស្រឡាញ់ ប្រកបដោយកាម ជាហេតុនៃសេចក្ដីត្រេកអរ ១ សំឡេងដែលគប្បីដឹងដោយត្រចៀក ១ ។ បេ ។ ក្លិនដែលគប្បីដឹងដោយច្រមុះ ១ រសដែលគប្បីដឹងដោយអណ្ដាត ១ ផ្សព្វដែលគប្បីដឹងដោយកាយ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីពេញចិត្ត មានសភាពជាទីស្រឡាញ់ ប្រកបដោយកាម ជាហេតុនៃសេចក្ដីត្រេកអរ ១ ។ ម្នាលភិក្ខុទាំងឡាយ កាមគុណមាន ៥ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគួរចម្រើននូវសតិប្បដ្ឋាន ៤ យ៉ាងនេះ ដើម្បីលះបង់នូវកាមគុណ ៥ យ៉ាងនេះឯង ។

[៦៦] ម្នាលភិក្ខុទាំងឡាយ ឧបាទានក្ខន្ធនេះមាន ៥ យ៉ាង ។ ឧបាទានក្ខន្ធ ៥ យ៉ាង តើដូចម្ដេចខ្លះ ។ គឺរូបូបាទានក្ខន្ធ ១ វេទនូបាទានក្ខន្ធ ១ សញ្ញូបាទានក្ខន្ធ ១ សង្ខារូបាទានក្ខន្ធ ១ វិញ្ញាណូបាទានក្ខន្ធ ១ ។ ម្នាលភិក្ខុទាំងឡាយ ឧបាទានក្ខន្ធមាន ៥ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគួរចម្រើននូវសតិប្បដ្ឋាន ៤ យ៉ាងនេះ ដើម្បីលះបង់នូវឧបាទានក្ខន្ធ ៥ យ៉ាងនេះឯង ។

[៦៧] បញ្ចិមានិ ភិក្ខវេ ឱរម្ភាគិយានិ សំយោជនានិ ។ កតមានិ បញ្ច ។ សក្កាយទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាសោ កាមច្ឆន្ទោ ព្យាបាទោ ។ ឥមានិ ខោ ភិក្ខវេ បញ្ច ឱរម្ភាគិយានិ សំយោជនានិ ។ ឥមេសំ ខោ ភិក្ខវេ បញ្ចន្នំ ឱរម្ភាគិយានំ សំយោជនានំ បហានាយ ឥមេ ចត្តារោ សតិប្បដ្ឋានា ភាវេតព្វាតិ ។

[៦៨] បញ្ចិមា ភិក្ខវេ គតិយោ ។ កតមា បញ្ច ។ និរយោ តិរច្ឆានយោនិ បិត្តិវិសយោ មនុស្សា ទេវា ។ ឥមា ខោ ភិក្ខវេ បញ្ច គតិយោ ។ ឥមាសំ ខោ ភិក្ខវេ បញ្ចន្នំ គតីនំ បហានាយ ឥមេ ចត្តារោ សតិប្បដ្ឋានា ភាវេតព្វាតិ ។

[៦៩] បញ្ចិមានិ ភិក្ខវេ មច្ឆរិយានិ ។ កតមានិ បញ្ច ។ អាវាសមច្ឆរិយំ កុលមច្ឆរិយំ លាភមច្ឆរិយំ វណ្ណមច្ឆរិយំ ធម្មមច្ឆរិយំ ។ ឥមានិ ខោ ភិក្ខវេ បញ្ច មច្ឆរិយានិ ។ ឥមេសំ ខោ ភិក្ខវេ បញ្ចន្នំ មច្ឆរិយានំ បហានាយ ឥមេ ចត្តារោ សតិប្បដ្ឋានា ភាវេតព្វាតិ ។

[៦៧] ម្នាលភិក្ខុទាំងឡាយ សំយោជនៈ ជាចំណែកខាងក្រោម នេះមាន ៥ យ៉ាង ។ សំយោជនៈ ៥ យ៉ាង តើដូចម្តេចខ្លះ ។ គឺសក្កាយ-ទិដ្ឋិ ១ វិចិកិច្ឆា ១ សីលព្វតបរាមាស ១ កាមច្ឆន្ទៈ ១ ព្យាបាទ ១ ។ ម្នាលភិក្ខុទាំងឡាយ សំយោជនៈ ជាចំណែកខាងក្រោមមាន ៥ យ៉ាង នេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគួរចម្រើននូវសតិប្បដ្ឋាន ៤ យ៉ាងនេះ ដើម្បីលះបង់នូវសំយោជនៈ ជាចំណែកខាងក្រោម ៥ យ៉ាងនេះឯង ។

[៦៨] ម្នាលភិក្ខុទាំងឡាយ គតិនេះ មាន ៥ យ៉ាង ។ គតិ ៥ យ៉ាង តើដូចម្តេចខ្លះ ។ គឺ និរយៈ ១ តិរច្ឆានយោនិ ១ បិត្តិវិស័យ ១ មនុស្ស ១ ទេវតា ១ ។ ម្នាលភិក្ខុទាំងឡាយ គតិមាន ៥ យ៉ាង នេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគួរចម្រើននូវសតិប្បដ្ឋាន ៤ យ៉ាងនេះ ដើម្បីលះបង់នូវគតិ ៥ យ៉ាងនេះឯង ។

[៦៩] ម្នាលភិក្ខុទាំងឡាយ សេចក្តីកំណាញ់នេះ មាន ៥ យ៉ាង ។ សេចក្តីកំណាញ់ ៥ យ៉ាង តើដូចម្តេចខ្លះ ។ គឺកំណាញ់អាវាស ១ កំ-ណាញ់ត្រកូល ១ កំណាញ់លាភ ១ កំណាញ់គុណ ១ កំណាញ់ធម៌ ១ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីកំណាញ់មាន ៥ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគួរចម្រើននូវសតិប្បដ្ឋាន ៤ យ៉ាងនេះ ដើម្បីលះបង់នូវសេចក្តីកំណាញ់ ៥ យ៉ាងនេះឯង ។

[៧០] បញ្ចិមានិ ភិក្ខវេ ឧទ្ធម្ភាគិយានិ សំយោជនានិ ។ កតមានិ បញ្ច ។ រូបរាគោ អរូបរាគោ មានោ ឧទ្ធច្ចំ អវិជ្ជា ។ ឥមានិ ខោ ភិក្ខវេ បញ្ចុទ្ធម្ភាគិយានិ សំយោជនានិ ។ ឥមេសំ ខោ ភិក្ខវេ បញ្ចន្នំ ឧទ្ធម្ភាគិយានំ សំយោជនានំ បហានាយ ឥមេ ចត្តារោ សតិប្បដ្ឋានា ភាវេតព្វាតិ ។

[៧១] បញ្ចិមេ ភិក្ខវេ ចេតោខីលា ។ កតមេ បញ្ច ។ ឥធ ភិក្ខវេ ភិក្ខុ សត្ថរិ កង្ខតិ វិចិកិច្ឆតិ នាធិមុច្ចតិ ន សម្បសីទតិ ។ យោ សោ ភិក្ខវេ ភិក្ខុ សត្ថរិ កង្ខតិ វិចិកិច្ឆតិ នាធិមុច្ចតិ ន សម្បសីទតិ តស្ស ចិត្តំ ន នមតិ អាតប្បាយ អនុយោគាយ សាតច្ចាយ បធានាយ ។ យស្ស ចិត្តំ ន នមតិ អាតប្បាយ អនុយោគាយ សាតច្ចាយ បធានាយ អយំ បឋមោ ចេតោខីលោ ។

[៧០] ម្នាលភិក្ខុទាំងឡាយ សំយោជនៈ ជាចំណែកខាងលើនេះ មាន ៥ យ៉ាង ។ សំយោជនៈ ៥ យ៉ាង តើដូចម្ដេចខ្លះ ។ គឺរូបរាគៈ ១ អរូបរាគៈ ១ មានៈ ១ ឧទ្ធច្ចៈ ១ អវិជ្ជា ១ ។ ម្នាលភិក្ខុទាំងឡាយ សំយោជនៈ ជាចំណែកខាងលើមាន ៥ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំង-ឡាយ ភិក្ខុគួរចម្រើននូវសតិប្បដ្ឋាន ៤ យ៉ាងនេះ ដើម្បីលះបង់នូវសំយោជនៈ ជាចំណែកខាងលើ ៥ យ៉ាងនេះឯង ។

[៧១] ម្នាលភិក្ខុទាំងឡាយ សេចក្ដីរឹងត្អឹងនៃចិត្តនេះមាន ៥ យ៉ាង ។ សេចក្ដីរឹងត្អឹងនៃចិត្ត ៥ យ៉ាង តើដូចម្ដេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ សង្ស័យ ងឿងឆ្ងល់ មិនចុះចិត្តស៊ប់ មិនជ្រះថ្លា ក្នុងព្រះសាស្ដា ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុណា សង្ស័យ ងឿងឆ្ងល់ មិនចុះចិត្តស៊ប់ មិនជ្រះថ្លា ក្នុងព្រះសាស្ដា ចិត្តរបស់ភិក្ខុនោះរមែងមិនឱនទៅ ដើម្បីព្យាយាម ជាគ្រឿងដុតកម្ដៅកិលេស ដើម្បីប្រកបព្យាយាមរឿយៗ ដើម្បីប្រព្រឹត្តព្យាយាមមិនដាច់ ដើម្បីតាំងទុកនូវព្យាយាម ។ ចិត្តរបស់ភិក្ខុណា មិនឱនទៅ ដើម្បីព្យាយាម ជាគ្រឿងដុតកម្ដៅកិលេស ដើម្បីប្រកបព្យាយាមរឿយៗ ដើម្បីប្រព្រឹត្តព្យាយាមមិនដាច់ ដើម្បីតាំងទុកនូវព្យាយាម នេះជាសេចក្ដីរឹងត្អឹងនៃចិត្តទី ១ ។

បុន ចបរំ ភិក្ខវេ ភិក្ខុ ធម្មេ កង្ខតិ ។ បេ ។ សង្ឃេ កង្ខតិ សិក្ខាយ កង្ខតិ សព្រហ្មចារីសុ កុបិតោ ហោតិ អនត្តមនោ អាហតចិត្តោ ខីលជាតោ ។ យោ សោ ភិក្ខវេ ភិក្ខុ សព្រហ្មចារីសុ កុបិតោ ហោតិ អនត្តមនោ អាហតចិត្តោ ខីលជាតោ តស្ស ចិត្តំ ន នមតិ អាតប្បាយ អនុយោគាយ សាតច្ចាយ បធានាយ ។ យស្ស ចិត្តំ ន នមតិ អាតប្បាយ អនុយោគាយ សាតច្ចាយ បធានាយ អយំ បញ្ចមោ ចេតោខីលោ ។ ឥមេសំ ខោ ភិក្ខវេ បញ្ចន្នំ ចេតោខីលានំ បហានាយ ឥមេ ចត្តារោ សតិប្បដ្ឋានា ភាវេតព្វាតិ ។

ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុសង្ស័យ ក្នុងព្រះធម៌ ។ បេ ។ សង្ស័យក្នុងព្រះសង្ឃ សង្ស័យក្នុងសិក្ខា ជាមនុស្សខឹង មានចិត្តអាក់អន់ មានចិត្តត្រូវទោសខ្ទាំងខ្ទប់ហើយ មានចិត្តរឹងរូស ក្នុងពួកសព្រហ្មចារី ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុណា ជាមនុស្សខឹង មានចិត្តអាក់អន់ មានចិត្តត្រូវទោសខ្ទាំងខ្ទប់ហើយ មានចិត្តរឹងរូស ក្នុងពួកសព្រហ្មចារី ចិត្តរបស់ភិក្ខុនោះ រមែងមិនឱនទៅ ដើម្បីព្យាយាម ជាគ្រឿងដុតកម្តៅកិលេស ដើម្បីប្រកបព្យាយាមរឿយៗ ដើម្បីប្រព្រឹត្តព្យាយាមមិនដាច់ ដើម្បីតាំងទុកនូវព្យាយាម ។ ចិត្តរបស់ភិក្ខុណា រមែងមិនឱនទៅ ដើម្បីព្យាយាម ជាគ្រឿងដុតកម្តៅកិលេស ដើម្បីប្រកបព្យាយាមរឿយៗ ដើម្បីប្រព្រឹត្តព្យាយាមមិនដាច់ ដើម្បីតាំងទុកនូវព្យាយាម នេះជាសេចក្តីរឹងត្អឹងនៃចិត្តទី ៥ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគួរចម្រើននូវសតិប្បដ្ឋាន ៤ យ៉ាងនេះ ដើម្បីលះបង់នូវសេចក្តីរឹងត្អឹងនៃចិត្ត ៥ យ៉ាងនេះឯង ។

[៧២] បញ្ចិមេ ភិក្ខវេ ចេតសោវិនិពន្ធា ។ កតមេ បញ្ច ។ ឥធ ភិក្ខវេ ភិក្ខុ កាមេសុ អវីតរាគោ ហោតិ អវីតច្ឆន្ទោ អវីតប្បេមោ អវីតបិចាសោ អវីតបរិឡាហោ អវីតតណ្ហោ ។ យោ សោ ភិក្ខវេ ភិក្ខុ កាមេសុ អវីតរាគោ ហោតិ អវីតច្ឆន្ទោ អវីតប្បេមោ អវីតបិចាសោ អវីតបរិឡាហោ អវីតតណ្ហោ តស្ស ចិត្តំ ន នមតិ អាតប្បាយ អនុយោគាយ សាតច្ចាយ បធានាយ ។ យស្ស ចិត្តំ ន នមតិ អាតប្បាយ អនុយោគាយ សាតច្ចាយ បធានាយ អយំ បឋមោ ចេតសោវិនិពន្ធោ ។ បុន ចបរំ ភិក្ខវេ ភិក្ខុ កាយេ អវីតរាគោ ហោតិ

[៧២] ម្នាលភិក្ខុទាំងឡាយ ចំណងរបស់ចិត្តនេះមាន ៥ យ៉ាង ។ ចំណងរបស់ចិត្ត ៥ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមិនទាន់ប្រាសចាកតម្រេក មិនទាន់ប្រាសចាកសេចក្តីពេញចិត្ត មិនទាន់ប្រាសចាកសេចក្តីស្រឡាញ់ មិនទាន់ប្រាសចាកសេចក្តីស្រេកឃ្លាន មិនទាន់ប្រាសចាកសេចក្តីក្តៅក្រហាយ មិនទាន់ប្រាសចាកសេចក្តីប្រាថ្នា ក្នុងកាមទាំងឡាយ ។ ម្នាលភិក្ខុទាំង-ឡាយ ភិក្ខុណាមិនទាន់ប្រាសចាកតម្រេក មិនទាន់ប្រាសចាកសេចក្តីពេញចិត្ត មិនទាន់ប្រាសចាកសេចក្តីស្រឡាញ់ មិនទាន់ប្រាសចាកសេចក្តីស្រេកឃ្លាន មិនទាន់ប្រាសចាកសេចក្តីក្តៅក្រហាយ មិនទាន់ប្រាសចាកសេចក្តីប្រាថ្នា ក្នុងកាមទាំងឡាយ ចិត្តរបស់ភិក្ខុនោះ រមែងមិនឱនទៅ ដើម្បីព្យាយាម ជាគ្រឿងដុតកម្តៅកិលេស ដើម្បីប្រកបព្យាយាមរឿយៗ ដើម្បីប្រព្រឹត្តព្យាយាមមិនដាច់ ដើម្បីតាំងទុកនូវព្យាយាម ។ ចិត្តរបស់ភិក្ខុណា មិនឱនទៅ ដើម្បីព្យាយាម ជាគ្រឿងដុតកម្តៅកិលេស ដើម្បីប្រកបព្យាយាមរឿយៗ ដើម្បីប្រព្រឹត្តព្យា-យាមមិនដាច់ ដើម្បីតាំងទុកនូវព្យាយាម នេះជាចំណងនៃចិត្តទី ១ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុមិនទាន់ប្រាសចាកតម្រេកក្នុងកាយ

រូបេ អវីតរាគោ ហោតិ យាវទត្ថំ ឧទរាវទេហកំ ភុញ្ជិត្វា សេយ្យសុខំ បស្សសុខំ មិទ្ធសុខំ អនុយុត្តោ វិហរតិ អញ្ញតរំ ទេវនិកាយំ បណិធាយ ព្រហ្មចរិយំ ចរតិ ឥមិនាហំ សីលេន វា វតេន វា តបេន វា ព្រហ្មចរិយេន វា ទេវោ វា ភវិស្សាមិ ទេវញ្ញតរោ វាតិ ។ យោ សោ ភិក្ខវេ ភិក្ខុ អញ្ញតរំ ទេវនិកាយំ បណិធាយ ព្រហ្មចរិយំ ចរតិ ឥមិនាហំ សីលេន វា វតេន វា តបេន វា ព្រហ្មចរិយេន វា ទេវោ វា ភវិស្សាមិ ទេវញ្ញតរោ វាតិ តស្ស ចិត្តំ ន នមតិ អាតប្បាយ អនុយោគាយ សាតច្ចាយ បធានាយ ។ យស្ស ចិត្តំ ន នមតិ អាតប្បាយ អនុយោគាយ សាតច្ចាយ បធានាយ អយំ បញ្ចមោ ចេតសោវិនិពន្ធោ ។ ឥមេ ខោ ភិក្ខវេ បញ្ច ចេតសោវិនិពន្ធា ។ ឥមេសំ ខោ ភិក្ខវេ បញ្ចន្នំ ចេតសោវិនិពន្ធានំ បហានាយ ចត្តារោ សតិប្បដ្ឋានា ភាវេតព្វា ។ កតមេ ចត្តារោ ។

មិនទាន់ប្រាសចាកតម្រេកក្នុងរូប ជាអ្នកបរិភោគភោជន ដរាបដល់ឆ្អែតពេញផ្ទៃ ហើយប្រកបរឿយៗ នូវទីដេកស្រួល នូវទីផ្អែកស្រួល និងសេចក្តីលក់ស្រួល ប្រព្រឹត្តព្រហ្មចារ្យ ប្រាថ្នានូវទេវនិកាយណាមួយ ដោយគិតថា អាត្មាអញនឹងបានជាទេវតាមានស័ក្តិធំ ឬជាទេវតាមានស័ក្តិតូចណាមួយ ដោយសីល ឬ វត្ត តបៈឬព្រហ្មចារ្យនេះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាប្រព្រឹត្តព្រហ្មចារ្យ ប្រាថ្នានូវទេវនិកាយណាមួយ ដោយគិតថា អាត្មាអញនឹងបានជាទេវតាមានស័ក្តិធំ ឬជាទេវតាមានស័ក្តិតូចណាមួយ ដោយសីល ឬ វត្ត តបៈ ឬព្រហ្មចារ្យនេះ ចិត្តរបស់ភិក្ខុនោះ រមែងមិនឱនទៅ ដើម្បីព្យាយាម ជាគ្រឿងដុតកម្តៅកិលេស ដើម្បីប្រកបព្យាយាមរឿយៗ ដើម្បីប្រព្រឹត្តព្យាយាមមិនដាច់ ដើម្បីតាំងទុកនូវព្យាយាម ។ ចិត្តរបស់ភិក្ខុណា រមែងមិនឱនទៅ ដើម្បីព្យាយាម ជាគ្រឿងដុតកម្តៅកិលេស ដើម្បីប្រកបព្យាយាមរឿយៗ ដើម្បីប្រព្រឹត្តព្យាយាមមិនដាច់ ដើម្បីតាំងទុកនូវព្យាយាម នេះជាចំណងនៃចិត្តទី ៥ ។ ម្នាលភិក្ខុទាំងឡាយ ចំណងរបស់ចិត្តមាន ៥ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគួរចម្រើននូវសតិប្បដ្ឋាន ៤ ដើម្បីលះបង់នូវចំណងរបស់ចិត្ត ៥ យ៉ាងនេះ ។ សតិប្បដ្ឋាន ៤ យ៉ាង តើដូចម្តេចខ្លះ ។

២២៣

បណ្ណាសកាសង្គហិតោ សតិប្បដ្ឋានវគ្គោ

ឥធ ភិក្ខវេ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ វេទនាសុ ។ បេ ។ ចិត្តេ ធម្មេសុ ធម្មានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ ឥមេសំ ខោ ភិក្ខវេ បញ្ចន្នំ ចេតសោវិនិពន្ធានំ បហានាយ ឥមេ ចត្តារោ សតិប្បដ្ឋានា ភាវេតព្វាតិ ។

សតិប្បដ្ឋានវគ្គោ ទុតិយោ ។

## តត្រុទ្ទានំ ភវតិ

សិក្ខា នីវរណា កាមា ខន្ធា ច ឱរម្ភាគិយា
គតិ មច្ឆរិយញ្ចេវ ឧទ្ធម្ភាគិយានំ អដ្ឋមំ
ចេតោខីលវិនិពន្ធាតិ ។

*ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណារឿយៗ នូវកាយក្នុងកាយជាប្រក្រតី មានព្យាយាម ជាគ្រឿងដុតកម្តៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្ស ក្នុងលោកចេញ ក្នុងវេទនាទាំងឡាយ ។ បេ ។ ក្នុងចិត្តពិចារណារឿយៗ នូវធម៌ ក្នុងធម៌ទាំងឡាយជាប្រក្រតី មានព្យាយាម ជាគ្រឿងដុតកម្តៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្ស ក្នុងលោកចេញ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគួរចម្រើននូវសតិប្បដ្ឋាន ៤ យ៉ាងនេះ ដើម្បីលះបង់នូវចំណងរបស់ចិត្ត ៥ យ៉ាងនេះឯង ។*

ចប់ សតិប្បដ្ឋានវគ្គទី ២ ។

## ឧទ្ទានក្នុងសតិប្បដ្ឋានវគ្គនេះគឺ

*និយាយអំពីសិក្ខា ១ នីវរណៈ ១ កាម ១ ឧបាទានក្ខន្ធ ១ សំយោជនៈ ជាចំណែកខាងក្រោម ១ គតិ ១ សេចក្តីកំណាញ់ ១ សំយោជនៈ ជាចំណែកខាងលើជាគម្រប់ប្រាំបី ១ សេចក្តីរឹងត្អឹងនៃចិត្ត ១ និងចំណងរបស់ចិត្ត ១ ។*

# តតិយោ សម្មប្បធានវគ្គោ

[៧៣] បញ្ចិមានិ ភិក្ខវេ សិក្ខាទុព្វល្យានិ ។ កតមានិ បញ្ច ។ បាណាតិបាតោ ។ បេ ។ សុរាមេរយមជ្ជប្បមាទដ្ឋានំ ។ ឥមានិ ខោ ភិក្ខវេ បញ្ច សិក្ខាទុព្វល្យានិ ។ ឥមេសំ ខោ ភិក្ខវេ បញ្ចន្នំ សិក្ខាទុព្វល្យានំ បហានាយ ចត្តារោ សម្មប្បធានា ភាវេតព្វា ។ កតមេ ចត្តារោ ។ ឥធ ភិក្ខវេ ភិក្ខុ អនុប្បន្នានំ បាបកានំ អកុសលានំ ធម្មានំ អនុប្បាទាយ ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ឧប្បន្នានំ បាបកានំ អកុសលានំ ធម្មានំ បហានាយ ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ អនុប្បន្នានំ កុសលានំ ធម្មានំ ឧប្បាទាយ ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ

# សម្មប្បធានវគ្គ ទី ៣

[៧៣] ម្នាលភិក្ខុទាំងឡាយ ហេតុនៃសិក្ខា មានកម្លាំងថយនេះមាន ៥ យ៉ាង ។ ហេតុនៃសិក្ខា មានកម្លាំងថយ ៥ យ៉ាង តើដូចម្តេចខ្លះ ។ គឺ បាណាតិបាត ១ ។ បេ ។ សុរាមេរយមជ្ជប្បមាទដ្ឋាន ១ ។ ម្នាលភិក្ខុទាំងឡាយ ហេតុនៃសិក្ខា មានកម្លាំងថយមាន ៥ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគួរចម្រើនសម្មប្បធាន ៤ យ៉ាង ដើម្បីលះបង់នូវហេតុនៃសិក្ខា មានកម្លាំងថយ ៥ យ៉ាងនេះ ។ សម្មប្ប-ធាន ៤ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ញុំាងឆន្ទៈ ឲ្យកើតឡើង សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត តម្កល់ចិត្ត ដើម្បីបិទអកុសលធម៌ទាំងឡាយ ដ៏លាមក ដែលមិនទាន់កើតឡើង មិនឲ្យកើតឡើងបាន ១ ញុំាងឆន្ទៈ ឲ្យកើតឡើង សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត តម្កល់ចិត្ត ដើម្បីលះបង់នូវអកុសលធម៌ទាំងឡាយដ៏លាមក ដែលកើតឡើងហើយ ១ ញុំាងឆន្ទៈ ឲ្យកើតឡើង សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត តម្កល់ចិត្ត ដើម្បីបណ្តុះបណ្តាលកុសលធម៌ទាំងឡាយ ដែលមិនទាន់កើតឡើង ឲ្យកើតឡើងបាន ១

ឧប្បន្នានំ កុសលានំ ធម្មានំ ឋិតិយា អសម្មោសាយ ភិយ្យោភាវាយ វេបុល្លាយ ភាវនាយ បារិបូរិយា ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ។ ឥមេសំ ខោ ភិក្ខវេ បញ្ចន្នំ សិក្ខាទុព្វល្យានំ បហានាយ ឥមេ ចត្តារោ សម្មប្បធានា ភាវេតព្វា ។ (យាវតា[១] សម្មប្បធានវសេន វិត្ថារេន្តិ) ។

[៧៤] បញ្ចិមេ ភិក្ខវេ ចេតោខិលា ។ កតមេ បញ្ច ។ ឥធ ភិក្ខវេ ភិក្ខុ កាមេសុ អវីតរាគោ ហោតិ ។ បេ ។ ឥមេ ខោ ភិក្ខវេ បញ្ច ចេតោខិលា ។ ឥមេសំ ខោ ភិក្ខវេ បញ្ចន្នំ ចេតោខិលានំ បហានាយ ចត្តារោ សម្មប្បធានា ភាវេតព្វា ។ កតមេ ចត្តារោ ។ ឥធ ភិក្ខវេ ភិក្ខុ អនុប្បន្នានំ បាបកានំ អកុសលានំ ធម្មានំ អនុប្បាទាយ ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ឧប្បន្នានំ បាបកានំ អកុសលានំ ធម្មានំ បហានាយ ។ បេ ។

១ ឱ. ម. យាវ វគ្គា ។

ញ៉ាំងឆន្ទៈ ឲ្យកើតឡើង សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត តម្កល់ចិត្ត ដើម្បីញ៉ាំងកុសលធម៌ទាំងឡាយ ដែលកើតឡើងហើយ ឲ្យឋិតនៅ មិនឲ្យវិនាសទៅ ឲ្យរឹងរឹតតែចម្រើនឡើង ឲ្យធំទូលាយ ឲ្យចម្រើនពេញលេញ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគួរចម្រើនសម្មប្បធាន ៤ យ៉ាងនេះ ដើម្បីលះបង់នូវហេតុនៃសិក្ខា មានកម្លាំងថយ ៥ យ៉ាងនេះឯង ។ បណ្ឌិតសម្តែងសេចក្តីឲ្យពិស្តារ ដោយអំណាចសម្មប្បធានត្រឹមណាផងចុះ ។

[៧៤] ម្នាលភិក្ខុទាំងឡាយ ចំណងនៃចិត្តនេះមាន ៥ យ៉ាង ។ ចំណងរបស់ចិត្ត ៥ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមិនទាន់ប្រាសចាកតម្រេកក្នុងកាមទាំងឡាយ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ចំណងរបស់ចិត្តមាន ៥ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគួរចម្រើនសម្មប្បធាន ៤ យ៉ាង ដើម្បីលះបង់នូវចំណងរបស់ចិត្ត ៥ យ៉ាងនេះ ។ សម្មប្បធាន ៤ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ញ៉ាំងឆន្ទៈ ឲ្យកើតឡើង សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត តម្កល់ចិត្ត ដើម្បីបិទអកុសលធម៌ទាំងឡាយដ៏លាមក ដែលមិនទាន់កើតឡើង មិនឲ្យកើតឡើងបាន ១ ដើម្បីលះបង់នូវអកុសលធម៌ទាំងឡាយដ៏លាមក ដែលកើតឡើងហើយ ១ ។ បេ ។

២២៦



អនុប្បន្នានំ កុសលានំ ធម្មានំ ឧប្បាទាយ ឧប្បន្នានំ កុសលានំ ធម្មានំ ឋិតិយា អសម្មោសាយ ភិយ្យោ-ភាវាយ វេបុល្លាយ ភាវនាយ បារិបូរិយា ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ។ ឥមេសំ ខោ ភិក្ខវេ បញ្ចន្នំ ចេតសោ-វិនិពន្ធានំ បហានាយ ឥមេ ចត្តារោ សម្មប្បធានា ភាវេតព្វាតិ ។

សម្មប្បធានវគ្គោ តតិយោ ។

---

ញុំាងឆន្ទៈ ឲ្យកើតឡើង សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត តម្កល់ចិត្ត ដើម្បីញុំាងកុសលធម៌ទាំងឡាយ ដែលមិនទាន់កើតឡើង ឲ្យកើតឡើងបាន ១ ដើម្បីញុំាងកុសលធម៌ទាំងឡាយ ដែលកើតឡើងហើយ ឲ្យឋិតនៅ មិនឲ្យវិនាសទៅ ឲ្យរឹងរឹតតែចម្រើនឡើង ឲ្យធំទូលាយ ឲ្យចម្រើនពេញលេញ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគួរចម្រើនសម្មប្បធាន ៤ យ៉ាងនេះ ដើម្បីលះបង់នូវចំណងរបស់ចិត្ត ៥ យ៉ាងនេះឯង ។

ចប់ សម្មប្បធានវគ្គទី ៣ ។

---

# ចតុត្ថោ ឥទ្ធិបាទវគ្គោ

[៧៨] បញ្ចិមានិ ភិក្ខវេ សិក្ខាទុព្វល្យានិ ។ កតមានិ បញ្ច ។ បាណាតិបាតោ ។ បេ ។ សុរាមេរយមជ្ជប្បមាទដ្ឋានំ ។ ឥមានិ ខោ ភិក្ខវេ បញ្ច សិក្ខាទុព្វល្យានិ ។ ឥមេសំ ខោ ភិក្ខវេ បញ្ចន្នំ សិក្ខាទុព្វល្យានំ បហានាយ ចត្តារោ ឥទ្ធិបាទា ភាវេតព្វា ។ កតមេ ចត្តារោ ។ ឥធ ភិក្ខវេ ភិក្ខុ ឆន្ទសមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ វីរិយសមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ ចិត្តសមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ វីមំសាសមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ ។ ឥមេសំ ខោ ភិក្ខវេ បញ្ចន្នំ សិក្ខាទុព្វល្យានំ បហានាយ ឥមេ ចត្តារោ ឥទ្ធិបាទា ភាវេតព្វាតិ ។ (ទ្វិបទសេសា ឥទ្ធិបាទវសេន វិត្ថារេតព្វា) ។

# ឥទ្ធិបាទវគ្គទី ៤

[៧៥] ម្នាលភិក្ខុទាំងឡាយ ហេតុនៃសិក្ខា មានកម្លាំងថយនេះ មាន ៥ យ៉ាង ។ ហេតុនៃសិក្ខា មានកម្លាំងថយ ៥ យ៉ាង តើដូចម្តេចខ្លះ ។ គឺបាណាតិបាត ១ ។ បេ ។ សុរាមេរយមជ្ជប្បមាទដ្ឋាន ១ ។ ម្នាលភិក្ខុទាំងឡាយ ហេតុនៃសិក្ខា មានកម្លាំងថយ មាន ៥ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគួរចម្រើនឥទ្ធិបាទ ៤ យ៉ាង ដើម្បីលះបង់នូវហេតុនៃសិក្ខា មានកម្លាំងថយ ៥ យ៉ាង នេះ ។ ឥទ្ធិបាទ ៤ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចម្រើនឥទ្ធិបាទ ដែលប្រកបដោយឆន្ទសមាធិ និងបធានសង្ខារ ១ ចម្រើនឥទ្ធិបាទ ដែលប្រកបដោយវីរិយសមាធិ និងបធានសង្ខារ ១ ចម្រើនឥទ្ធិបាទ ដែលប្រកបដោយចិត្តសមាធិនិង បធានសង្ខារ ១ ចម្រើនឥទ្ធិបាទ ដែលប្រកបដោយវីមំសាសមាធិ និងបធានសង្ខារ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគួរចម្រើនឥទ្ធិបាទ ៤ យ៉ាងនេះ ដើម្បីលះបង់នូវហេតុនៃសិក្ខា មានកម្លាំងថយ ៥ យ៉ាង នេះឯង ។ (បទដ៏សេសទាំង ២ ត្រូវសម្តែងឲ្យពិស្តារដោយអំណាច ឥទ្ធិបាទផងចុះ) ។

[៧៦] បញ្ចិមេ ភិក្ខវេ ចេតសោវិនិពន្ធា ។ កតមេ បញ្ច ។ ឥធ ភិក្ខវេ ភិក្ខុ កាមេសុ អវីតរាគោ ហោតិ ។ បេ ។ ឥមេ ខោ ភិក្ខវេ បញ្ច ចេតសោវិនិពន្ធា ។ ឥមេសំ ខោ ភិក្ខវេ បញ្ចន្នំ ចេតសោវិនិពន្ធានំ បហានាយ ឥមេ ចត្តារោ ឥទ្ធិ-បាទា ភាវេតព្វា ។ កតមេ ចត្តារោ ។ ឥធ ភិក្ខវេ ភិក្ខុ ឆន្ទសមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ វីរិយសមាធិចិត្តសមាធិវីមំសាសមាធិប្បធាន-សង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ ។ ឥមេសំ ខោ ភិក្ខវេ បញ្ចន្នំ ចេតសោវិនិពន្ធានំ បហានាយ ឥមេ ចត្តារោ ឥទ្ធិបាទា ភាវេតព្វាតិ ។

ឥទ្ធិបាទវគ្គោ ចតុត្ថោ ។

ចត្តារោ សតិប្បដ្ឋានា បធានា ចតុរោ បទេ

ចត្តារោ ឥទ្ធិបាទាបិ បុរិមេហោតេហិ យោជយេតិ ។

[៧៦] ម្នាលភិក្ខុទាំងឡាយ ចំណងរបស់ចិត្តនេះមាន ៥ យ៉ាង ។ ចំណងរបស់ចិត្ត ៥ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ មិនទាន់ប្រាសចាកតម្រេកក្នុងកាមទាំងឡាយ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ចំណងរបស់ចិត្តមាន ៥ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគួរចម្រើនឥទ្ធិបាទ ៤ យ៉ាងនេះ ដើម្បីលះបង់នូវចំណងរបស់ចិត្ត ៥ យ៉ាងនេះឯង ។ ឥទ្ធិបាទ ៤ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចម្រើននូវឥទ្ធិបាទ ដែលប្រកបដោយឆន្ទសមាធិនិងបធានសង្ខារ ចម្រើនឥទ្ធិបាទ ដែលប្រកបដោយវីរិយសមាធិ ចិត្តសមាធិ វីមំសាសមាធិ និងបធានសង្ខារ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគួរចម្រើនឥទ្ធិបាទ ៤ យ៉ាងនេះ ដើម្បីលះបង់នូវចំណងរបស់ចិត្ត ៥ យ៉ាងនេះឯង ។

ចប់ ឥទ្ធិបាទវគ្គ ទី ៥ ។

គប្បីប្រកបសតិប្បដ្ឋាន ៤ យ៉ាង បទគឺសម្មប្បធាន ៤ យ៉ាង ឥទ្ធិបាទ ៤ យ៉ាង តាមន័យដែលមានមកហើយក្នុងខាងដើមផងចុះ ។

---

# បញ្ចមោ វគ្គោ

[៧៧] រាគស្ស ភិក្ខវេ អភិញ្ញាយ នវ ធម្មា ភាវេតព្វា ។ កតមេ នវ ។ អសុភសញ្ញា មរណសញ្ញា អាហារេ បដិក្កូលសញ្ញា សព្វលោកេ អនភិរតសញ្ញា អនិច្ចសញ្ញា អនិច្ចេ ទុក្ខសញ្ញា ទុក្ខេ អនត្តសញ្ញា បហានសញ្ញា វិរាគសញ្ញា ។ រាគស្ស ភិក្ខវេ អភិញ្ញាយ ឥមេ នវ ធម្មា ភាវេតព្វាតិ ។

[៧៨] រាគស្ស ភិក្ខវេ អភិញ្ញាយ នវ ធម្មា ភាវេតព្វា ។ កតមេ នវ ។ បឋមជ្ឈានំ ទុតិយជ្ឈានំ តតិយជ្ឈានំ ចតុត្ថជ្ឈានំ អាកាសានញ្ចាយតនំ វិញ្ញាណញ្ចាយតនំ អាកិញ្ចញ្ញាយតនំ នេវសញ្ញានាសញ្ញាយតនំ សញ្ញាវេទយិតនិរោធោ ។ រាគស្ស ភិក្ខវេ អភិញ្ញាយ ឥមេ នវ ធម្មា ភាវេតព្វា ។

# វគ្គទី ៥

[៧៧] ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីចម្រើនធម៌ ៩ យ៉ាង ដើម្បីដឹងច្បាស់នូវរាគៈ ។ ធម៌ ៩ យ៉ាង តើដូចម្ដេចខ្លះ ។ គឺសេចក្ដីសម្គាល់ថាមិនល្អ ១ សេចក្ដីសម្គាល់ ដោយមរណានុបស្សនាញាណ ១ សេចក្ដីសម្គាល់ ក្នុងអាហារថាជារបស់គួរខ្ពើម ១ សេចក្ដីសម្គាល់ ក្នុងលោកទាំងពួងថា មិនគួរត្រេកអរ ១ សេចក្ដីសម្គាល់ថា មិនទៀង ១ សេចក្ដីសម្គាល់ ក្នុងរបស់ដែលមិនទៀងថាជាទុក្ខ ១ សេចក្ដីសម្គាល់ ក្នុងរបស់ដែលជាទុក្ខថា មិនមែនរបស់ខ្លួន ១ សេចក្ដីសម្គាល់នូវរបស់ដែលត្រូវលះបង់ ១ សេចក្ដីសម្គាល់ថា គួរនឿយណាយ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគួរចម្រើនធម៌ ៩ យ៉ាងនេះ ដើម្បីដឹងច្បាស់នូវរាគៈ ។

[៧៨] ម្នាលភិក្ខុទាំងឡាយ ភិក្ខុគួរចម្រើនធម៌ ៩ យ៉ាង ដើម្បីដឹងច្បាស់នូវរាគៈ ។ ធម៌ ៩ យ៉ាង តើដូចម្ដេចខ្លះ ។ គឺបឋមជ្ឈាន ១ ទុតិយជ្ឈាន ១ តតិយជ្ឈាន ១ ចតុត្ថជ្ឈាន ១ អាកាសានញ្ចាយតនជ្ឈាន ១ វិញ្ញាណញ្ចាយតនជ្ឈាន ១ អាកិញ្ចញ្ញាយតនជ្ឈាន ១ នេវសញ្ញានាសញ្ញាយតនជ្ឈាន ១ សញ្ញាវេទយិតនិរោធ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគួរចម្រើនធម៌ ៩ យ៉ាងនេះឯង ដើម្បីដឹងច្បាស់នូវរាគៈ ។

[៧៩] រាគស្ស ភិក្ខវេ បរិញ្ញាយ បរិក្ខយាយ បហានាយ ខយាយ វយាយ វិរាគាយ និរោធាយ ចាគាយ បដិនិស្សគ្គាយ ឥមេ នវ ធម្មា ភាវេតព្វា ។ ទោសស្ស មោហស្ស កោធស្ស ឧបនាហស្ស មក្ខស្ស បលាសស្ស ឥស្សាយ មច្ឆរិយស្ស មាយាយ សាឋេយ្យស្ស ថម្ភស្ស សារម្ភស្ស មានស្ស អតិមានស្ស មទស្ស បមាទស្ស អភិញ្ញាយ បរិញ្ញាយ បរិក្ខយាយ បហានាយ ខយាយ វយាយ វិរាគាយ និរោធាយ ចាគាយ បដិនិស្សគ្គាយ ឥមេ នវ ធម្មា ភាវេតព្វាតិ ។ ឥទមវោច ភគវា ។ អត្តមនា តេ ភិក្ខូ ភគវតោ ភាសិតំ អភិនន្ទុន្តិ ។

នវកនិបាតោ សមត្តោ ។

[៧៩] ម្នាលភិក្ខុទាំងឡាយ ភិក្ខុគួរចម្រើននូវធម៌ ៩ យ៉ាងនេះ ដើម្បីកំណត់ដឹង ដើម្បីអស់រលីងទៅ ដើម្បីលះ ដើម្បីអស់ទៅ ដើម្បីសូន្យទៅ ដើម្បីនឿយណាយ ដើម្បីរលត់ ដើម្បីលះបង់ ដើម្បីរលាស់ចោលនូវរាគៈ ។ ភិក្ខុគួរចម្រើនធម៌ ៩ យ៉ាងនេះ ដើម្បីដឹងច្បាស់ ដើម្បីកំណត់ដឹង ដើម្បីអស់រលីងទៅ ដើម្បីលះ ដើម្បីអស់ទៅ ដើម្បីសូន្យទៅ ដើម្បីនឿយណាយ ដើម្បីរលត់ ដើម្បីលះបង់ ដើម្បីរលាស់ចោលនូវទោសៈ មោហៈ កោធៈ ឧបនាហៈ មក្ខៈ បលាសៈ ឥស្សា មច្ឆរិយៈ មាយា សាថេយ្យៈ ថម្ភៈ សារម្ភៈ មានៈ អតិមានៈ មទៈ បមាទៈ ។ លុះព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ព្រះសូត្រនេះចប់ហើយ ។ ភិក្ខុទាំងនោះ ក៏ពេញចិត្តត្រេកអរនឹងភាសិតរបស់ព្រះដ៏មានព្រះភាគ ។

ចប់ នវកនិបាត ។

# សុត្តន្តបិដកេ
# អង្គុត្តរនិកាយស្ស នវកនិបាតោ
# ទសមោ ភាគោ

---

## មាតិកា អង្កេ

## បណ្ណាសកោ


| | | | |
|---|---|---|---|
| *បណ្ណាសកេ* | *សម្ពោធវគ្គោ* | *បឋមោ* | ១ |
| | *សីហនាទវគ្គោ* | *ទុតិយោ* | ៤៤ |
| | *សត្តាវាសវគ្គោ* | *តតិយោ* | ៨៤ |
| | *មហាវគ្គោ* | *ចតុត្ថោ* | ១១៥ |
| | *បញ្ចាលវគ្គោ* | *បញ្ចមោ* | ១៩៩ |


## បណ្ណាសកាសង្គហិតា វគ្គា


| | | | |
|---|---|---|---|
| *បណ្ណាសកាសង្គហិតវគ្គេសុ* | *ខេមវគ្គោ* | *បឋមោ* | ២១១ |
| | *សតិប្បដ្ឋានវគ្គោ* | *ទុតិយោ* | ២១៥ |
| | *សម្មប្បធានវគ្គោ* | *តតិយោ* | ២២៤ |
| | *ឥទ្ធិបាទវគ្គោ* | *ចតុត្ថោ* | ២២៧ |
| | *វគ្គោ* | *បញ្ចមោ* | ២២៩ |

# សុត្តន្តបិដក

# អង្គុត្តរនិកាយ នវកនិបាត

# ទសមភាគ

---

## មាតិកា លេខទំព័រ

## បណ្ណាសក


| | | | |
|---|---|---|---|
| បណ្ណាសក | សម្ពោធវគ្គ | ទី ១ ........................................ | ១ |
| | សីហនាទវគ្គ | ទី ២ ........................................ | ៥៥ |
| | សត្តាវាសវគ្គ | ទី ៣ ........................................ | ៨៥ |
| | មហាវគ្គ | ទី ៤ ........................................ | ១១៥ |
| | បញ្ចាលវគ្គ | ទី ៥ ........................................ | ១៩៩ |


## បណ្ណាសកាសង្គហិតវគ្គ


| | | | |
|---|---|---|---|
| បណ្ណាសកាសង្គហិតវគ្គ | ខេមវគ្គ | ទី ១ ........................................ | ២១១ |
| | សតិប្បដ្ឋានវគ្គ | ទី ២ ........................................ | ២១៥ |
| | សម្មប្បធានវគ្គ | ទី ៣ ........................................ | ២២៥ |
| | ឥទ្ធិបាទវគ្គ | ទី ៤ ........................................ | ២២៧ |
| | វគ្គ | ទី ៥ ........................................ | ២២៩ |

